# សមន្តប្បាសាទិកា

## អដ្ឋកថា វិនយបិដក

## បរិវារៈ

## ភាគ ១២_១៣

# សមន្តប្បាសាទិកា

## អដ្ឋកថា  វិនយបិដក

## បរិវារៈ

## ភាគ  ១២-១៣

ឈ្មោះសៀវភៅ សមន្តបាសាទិកា អដ្ឋកថាបិដក បរិវារៈ

ភាគ ១២_១៣

ប្រែដោយ ភិក្ខុ អគ្គធីរោ គង់ សុមិត្ត

ផ្ទៀងផ្ទាត់ដោយ ភិក្ខុ_សាមណេរវត្តនិគ្រោធវ័ន

| | |
|---|---|
| ភិក្ខុ គូ សុភាព | ភិក្ខុ តុន ប៊ុនសាយ |
| ភិក្ខុ ភួង សុវណ្ណ | សាមណេរ គល់ សុភាព |
| ភិក្ខុ ឈឹម ហ៊ាន | សាមណេរ នៅ ហៃឡុន |
| ភិក្ខុ ភុល ណារិន | សាមណេរ សឿន សាន |

កាលបរិច្ឆេទ ព.ស. ២៥៥៣

ស្ថានទីធ្វើ ពុទ្ធមណ្ឌលមហាសតិប្បដ្ឋាន វត្តនិគ្រោធវ័ន "គល់ទទឹង" ភូមិកោះក្របី ឃុំព្រែកថ្មី ស្រុកកៀនស្វាយ ខេត្តកណ្ដាល

ISBN 9789996306013



ភិក្ខុ អគ្គធីរោ គង់-សុមិត្ត

# ជីវប្រវត្តិសង្ខេប

ភិក្ខុ គង់-សុមិត្ត អាយុ៣៩ឆ្នាំ គង់នៅវត្តនិគ្រោធវ័នគល់ទទឹង ។ ញោមប្រុសឈ្មោះ គង់-គិក( ស្លាប់ ) ញោមស្រីឈ្មោះ ហុក-តាង កើតថ្ងៃព្រហស្បតិ៍៩កើត ខែមិគសិរ ឆ្នាំថោះ ព.ស.២៥១៩ ។ មានបងប្អូន ៧ នាក់ គឺប្រុស ៥ នាក់ ស្រី ២ នាក់. ជាកូនពៅ ។ ក្នុងកុមារបានចូលរៀនសាលារដ្ឋ ដល់ថ្នាក់ទី ៨ ។

ក្នុងព.ស.២៥៣៧ មានអាយុ១៩ឆ្នាំ បួសជាសាមណេរក្នុងសំណាក់ឧបជ្ឈាយ៍ ព្រះនាម ឡាយលឿង វត្តស្លាកែត មកគង់នៅវត្តក្តាំងផា ខេត្តបាត់ដំបង ។ ព.ស. ២៥៣៨ មានអាយុគ្រប់ ២០ បានឧបសម្បទា ជាភិក្ខុភាវៈ ។

ព.ស. ២៥៤០ មកគង់នៅវត្តនិគ្រោធវ័ន រៀនធម៌វិន័យ ។ ព.ស. ២៥៤១ ចេញទៅគង់នៅវត្តខេមវ័ន( ខេត្តកំពង់ចាម ) បង្រៀនធម៌វិន័យ ។ ព.ស. ២៥៤៥ បានត្រឡប់មកវត្តនិគ្រោធវ័នវិញហើយលាសិក្ខា បានខិតខំ រៀបចំ និងជួយសរសេរសៀវភៅធម៌វិន័យ ។

ព.ស. ២៥៤៦ បួសជាសាមណេរវិញ ឧបជ្ឈាយ៍ព្រះនាម យឹ ទិត វត្តកោះក្របី ឃុំព្រែកថ្មី ស្រុក គៀនស្វាយ ខេត្តកណ្ដាល បានជួយបង្រៀនព្រះវិន័យដល់ព្រះសង្ឃ ក្នុងវត្តនិគ្រោធវ័ន ។

ព.ស. ២៥៤៧ បំពេញជាភិក្ខុភាវៈ បានជួយបង្រៀននិងខិតខំរៀបចំអដ្ឋកថា និងសៀវភៅធម៌វិន័យជាច្រើនទៀត រហូតមក ។

# ហេតុដែលព្រះពុទ្ធទ្រង់បញ្ញត្តសិក្ខាបទ

ព្រះសម្ពុទ្ធជាម្ចាស់ដ៏មានជោគ ទ្រង់គង់នៅក្បែរដើមស្តៅ ជាលំនៅរបស់នឡេរុយក្ស ជិតក្រុងវេរញ្ជា ជាមួយនឹងភិក្ខុសង្ឃមានប្រមាណច្រើនចំនួន ៥០០ រូប ។ វេរញ្ជព្រាហ្មណ៍បានចូលទៅលើកពាក្យចោទប្រកាន់ ចំពោះព្រះដ៏មានព្រះភាគ មានពាក្យជាដើមថា "ព្រះគោតមមិនសំពះ មិនក្រោកទទួលព្រាហ្មណ៍ទាំងឡាយ ដែលចាស់គ្រាំគ្រាជាព្រឹទ្ធាចារ្យ មានអាយុច្រើន រស់នៅបានយូរឆ្នាំមកហើយ មានអាយុក៏ជ្រុលចូលមក ក្នុងបច្ឆិមវ័យហើយ ទោះបីគ្រាន់តែអញ្ជើញហៅរកព្រាហ្មណ៍ទាំងនោះ ឱ្យអង្គុយលើអាសនៈ(ក៏ព្រះអង្គមិនធ្វើ)" ព្រះដ៏មានព្រះភាគទ្រង់ញ៉ាំងព្រាហ្មណ៍នោះ ឱ្យជ្រះថ្លាហើយ និងប្រកាសខ្លួនជាឧបាសក ដល់ព្រះត្រ័យសរណគមន៍ស្មើដោយជីវិត រួចក៏អារាធនាឱ្យទ្រង់ចាំវស្សាជិតស្រុកវេរញ្ជានោះមួយអន្លើដោយភិក្ខុសង្ឃ ។

ក្នុងវស្សានោះ ស្រុកវេរញ្ជាកើតអំណត់អត់បាយ ព្រះដ៏មានព្រះភាគ និងព្រះភិក្ខុសង្ឃឆាន់បាយក្រៀមរបស់ពួកឈ្មួញសេះ ។ ព្រះមហាមោគ្គល្លានទូលសូមសម្តែងឫទ្ធិប្រែត្រឡប់ផែនដី ដើម្បី បានឱជារសដែលកើតឡើងអំពីស្រទាប់នៃផែនដី និងទូលសូមនាំភិក្ខុទៅបិណ្ឌបាត

ឯឧត្តរកុរុទ្វីប, តែព្រះដ៏មានព្រះភាគទ្រង់មិនអនុញ្ញាត ។ ចំណែកព្រះសារីបុត្រ ក៏ក្រាបទូលសួរអំពីសាសនារបស់ព្រះពុទ្ធទាំងឡាយ ដែលឋិតនៅមិនបានយូរ និងដែលឋិតនៅបានយូរ, ព្រះដ៏មានព្រះភាគក៏ទ្រង់សម្ដែងសាសនារបស់ព្រះពុទ្ធទាំង ៦ ព្រះអង្គមានព្រះពុទ្ធព្រះនាមវិបស្សីជាដើម ។ លំដាប់នោះ ព្រះសារីបុត្តដ៏មានអាយុ ក្រោកចាកអាសនៈហើយ ធ្វើសំពត់ឧត្តរាសង្គឆៀងស្មាម្ខាង ប្រណម្យអញ្ជលីចំពោះព្រះដ៏មានព្រះភាគ ហើយក្រាបទូលពាក្យនេះចំពោះព្រះដ៏មានព្រះភាគថា "សូមទ្រង់ព្រះមេត្តាប្រោស កាលនេះជាកាលគួរហើយ បពិត្រព្រះសុគត កាលនេះជាកាលគួរដល់ព្រះដ៏មានព្រះភាគជាម្ចាស់ ៗ គួរបញ្ញត្តិសិក្ខាបទ គួរសម្ដែងអាណាបាតិមោក្ខដល់សាវកទាំងឡាយ ព្រោះកិច្ចដូច្នេះហើយ ជាហេតុនឹងឱ្យព្រហ្មចរិយធម៌ឋិតនៅអស់កាលអង្វែងទៅ" ។ ព្រះដ៏មានព្រះភាគជាម្ចាស់ទ្រង់ត្រាស់ថា "ម្នាលសារីបុត្ត អ្នកចូរបង្អង់សិន ម្នាលសារីបុត្ត អ្នកចូរបង្អង់សិន តថាគតឯងស៊ីងដឹងកាលគួរក្នុងកិច្ចដែលនឹងបញ្ញត្តសិក្ខាបទជាដើមនោះ ម្នាលសារីបុត្ត ក៏ធម៌ទាំងឡាយខ្លះ ដែលជាទីតាំងនៃអាសវៈ មិនទាន់ប្រាកដចំពោះសង្ឃក្នុងសាសនានេះត្រឹមណា ព្រះសាស្ដាក៏មិនទាន់បញ្ញត្តសិក្ខាបទ មិនទាន់សម្ដែងអាណាបាតិមោក្ខដល់សាវកទាំងឡាយត្រឹមនោះ ម្នាលសារីបុត្ត ក៏ធម៌ទាំងឡាយខ្លះ ដែលជាទី

តាំងនៃអាសវៈ មានប្រាកដចំពោះសង្ឃក្នុងសាសនានេះក្នុងកាលណា ទើបព្រះសាស្ដាបញ្ញត្តសិក្ខាបទ សម្ដែងអាណាបាតិមោក្ខដល់សាវកទាំងឡាយក្នុងកាលនោះ ដើម្បីនឹងការពារកាំងនូវធម៌ទាំងឡាយ ដែលជាទីតាំងនៃអាសវៈទាំងនោះប៉ុណ្ណោះ ម្នាលសារីបុត្ត សង្ឃនៅមិនទាន់មានភិក្ខុបួសចាស់វស្សាច្រើនគ្នាត្រឹមណា ធម៌ទាំងឡាយខ្លះ ដែលជាទីតាំងនៃអាសវៈ ក៏មិនទាន់មានប្រាកដចំពោះសង្ឃក្នុងសាសនានេះត្រឹមនោះ ម្នាលសារីបុត្ត ម្យ៉ាងទៀត សង្ឃបានដល់នូវសេចក្ដីចម្រើនមានភិក្ខុបួសចាស់វស្សាច្រើនគ្នា ក្នុងកាលណា ធម៌ទាំងឡាយខ្លះ ដែលជាទីតាំងនៃអាសវៈ ក៏នឹងមានប្រាកដចំពោះសង្ឃក្នុងសាសនានេះក្នុងកាលនោះ ទើបព្រះសាស្ដាបញ្ញត្តសិក្ខាបទ សម្ដែងអាណាបាតិមោក្ខដល់សាវកទាំងឡាយ ដើម្បីការពារកាំងនូវធម៌ទាំងឡាយ ដែលជាទីតាំងនៃអាសវៈទាំងអម្បាលនោះក្នុងកាលនោះឯង ម្នាលសារីបុត្ត សង្ឃមិនទាន់បាននូវសេចក្ដីចម្រើនមានគ្នាច្រើនត្រឹមណា ធម៌ទាំងឡាយខ្លះ ដែលជាទីតាំងនៃអាសវៈ ក៏មិនទាន់មានប្រាកដចំពោះសង្ឃក្នុងសាសនានេះ ត្រឹមនោះ ម្នាលសារីបុត្ត ម្យ៉ាងទៀត សង្ឃបានដល់នូវសេចក្ដីចម្រើនមានគ្នាច្រើន ក្នុងកាលណា ធម៌ទាំងឡាយខ្លះ ដែលជាទីតាំងនៃអាសវៈ ក៏មានប្រាកដចំពោះសង្ឃក្នុងសាសនានេះក្នុងកាលនោះ ទើបព្រះសាស្ដាបញ្ញត្តសិក្ខាបទ សម្ដែងអាណាបាតិមោក្ខដល់សាវកទាំងឡាយ ដើម្បីការពារកាំងនូវធម៌ទាំងឡាយ

ដែលជាទីតាំងនៃអាសវៈទាំងអម្បាលនោះក្នុងកាលនោះឯង ម្នាលសារីបុត្ត សង្ឃមិនទាន់ដល់នូវសេចក្ដីចម្រើនដោយលាភសក្ការៈដ៏ប្រសើរត្រឹមណា ធម៌ទាំងឡាយខ្លះ ដែលជាទីតាំងនៃអាសវៈ ក៏នៅមិនទាន់មានប្រាកដចំពោះសង្ឃត្រឹមនោះ ម្នាលសារីបុត្ត លុះសង្ឃបានដល់នូវសេចក្ដីចម្រើនដោយលាភសក្ការៈដ៏ប្រសើរក្នុងកាលណា ធម៌ទាំងឡាយខ្លះ ដែលជាទីតាំងនៃអាសវៈ ក៏មានប្រាកដចំពោះសង្ឃក្នុងកាលនោះដែរ ទើបព្រះសាស្ដាបញ្ញត្តសិក្ខាបទ សម្ដែងអាណាបាតិមោក្ខដល់សាវកទាំងឡាយ ដើម្បីការពារពាំងនូវធម៌ដែលជាទីតាំងនៃអាសវៈទាំងអម្បាលនោះ ក្នុងកាលនោះឯង ម្នាលសារីបុត្ត ពីព្រោះ( ឥឡូវ )ភិក្ខុសង្ឃនៅមិនទាន់មានពុត( ហិានលបលួចធ្វើអាក្រក់ )នៅឡើយ មិនទាន់មានទោសមោះមៃនៅឡើយ កំពុងនៅមានធម៌បរិសុទ្ធ ឥតទាន់មានពណ៌ខ្មៅសៅហ្មង សុទ្ធសឹងតែផូរផង់ផ្ចង់ចិត្តឋិតនៅក្នុងធម៌មានខ្លឹមនៅឡើយ ម្នាលសារីបុត្ត ក៏បណ្ដាភិក្ខុទាំង ៥០០ រូបនេះ ភិក្ខុដែលមានមគ្គផលយ៉ាងទាបចុងគេបំផុតនោះ ក៏គង់បានសម្រេចត្រឹមថ្នាក់សោតៈ ជាបុគ្គលទៀងទាត់ លែងធ្លាក់ទៅក្នុងអបាយភូមិហើយ នឹងបានត្រាស់ដឹងមគ្គផលត ៗទៅទៀតជាប្រាកដ” ។

ហេតុដែលព្រះពុទ្ធទ្រង់បញ្ញត្តសិក្ខាបទ ចប់

# ប្រវត្តិរបស់ព្រះពុទ្ធឃោសាចារ្យ

## ឃោសកុមារកើតឡើង និងការសិក្សាត្រៃវេទ

រាប់អំពីកាលនៃការបរិនិព្វានរបស់ព្រះមានព្រះភាគ កន្លងទៅហើយបាន ៩៥៦ ព្រះវស្សា ។ ព្រះរាជាមួយព្រះអង្គទ្រង់ព្រះនាមថា មហានាម បានគ្រងរាជ្យសម្បត្តិ ប្រកបដោយទសពិធរាជធម៌ក្នុងលង្កាទ្វីប ។ បានឮថា ក្នុងសម័យនោះឯង មានព្រាហ្មណ៍ មាណពម្នាក់ កើតនៅក្នុងត្រកូលព្រាហ្មណ៍មួយ បិតាឈ្មោះ **កេសី** ជារាជបុរោហិត មាតាឈ្មោះ **កេសិនី** មានលំនៅស្ថិតនៅក្នុងទីជិតនៃពោធិមណ្ឌល (កន្លែងត្រាស់ដឹងរបស់ព្រះសម្ពុទ្ធ) ក្នុងមជ្ឈិមប្រទេសជម្ពូទ្វីប ។

ក៏ព្រោះក្នុងវេលាដែលមាណពនោះប្រសូតមក ពួកបរិវាររបស់ព្រាហ្មណ៍ មានទាសនិងកម្មករជាដើម បញ្ចេញសំឡេង សម្តែងភាពត្រេកអររីករាយយ៉ាងគឹកកង ដូច្នោះ ទើបគេដាក់ឈ្មោះឱ្យកុមារនោះថា **ឃោសៈ** ។ ទីខ្លះក៏ពោលថា មាណពនោះ កើតនៅក្នុងឃោសគ្រាម ទើបដាក់ឈ្មោះឱ្យថា ឃោសៈ ។ ឃោសៈមាណពនោះ ជាអ្នកដឹងវិជ្ជានិងក្បួនសិល្បៈទាំងពួងយ៉ាងជំនាញ ចេះចប់ត្រៃវេទយ៉ាងប្រាកដក្នុងលទ្ធិ បានត្រាច់ទៅដើម្បីសាកសួរ និងដោះស្រាយបញ្ហាវិជ្ជាសិល្បៈ ក្នុងស្រុកនិគមជនបទ រាជធានីទាំងឡាយ ក្នុងជម្ពូទ្វីប ។

ដឹងថា មានសមណព្រាហ្មណ៍ ដែលជាបណ្ឌិតនៅក្នុងទីណា ៗ ក៏ចូលទៅធ្វើការសាកប្ញាក្នុងទីនោះ ៗ បណ្ឌិតដទៃ ( នោះ ) ៗ មិនអាចឆ្លើយនូវបញ្ហាដែលមាណពនោះ សួរបានឡើយ តែមាណពនោះ អាចឆ្លើយនូវបញ្ហារបស់បណ្ឌិតទាំងនោះ ៗ ដែលសួរហើយបាន ។

## ឃោសមាណពជួបនឹងព្រះរេវតត្ថេរ

មាណពនោះ ត្រេចសង្កត់ពេញ ទូទាំងជម្ពូទ្វីបដោយអាការយ៉ាងនេះ រហូតមកដល់វត្តមួយ ( ក៏បានស្នាក់នៅក្នុងបរិវេណវត្តនោះ ) ។ ក៏ក្នុងវត្តនោះ មានភិក្ខុនៅច្រើនរូប ព្រះរេវតៈ( ឬធម្មឃោសៈ ) ជាសង្ឃត្ថេររបស់ភិក្ខុទាំងនោះ ជាព្រះមហាខីណាស្រពបានសម្រេចបដិសម្ភិទា អាចញុំាញុំបរប្បវាទបាន ។ គ្រានោះ កាលវេលាអាធ្រាត្រ ព្រាហ្មណ៍មាណព បានបរិវត្តបាតញ្ជលី ( ស្វាធ្យាយ ) នូវមន្តឱ្យមានបទបរិបូណ៌ និងឱ្យជាបរិមណ្ឌល ព្រះថេរៈស្តាប់នូវសំឡេងព្រាហ្មណ៍ស្វាធ្យាយមន្ត ក៏ជ្រាបថា “ព្រាហ្មណ៍នេះជាអ្នកមានបញ្ញាច្រើន” ( រូបទើប ) គិតថា “បើយើងទូន្មានឱ្យមករាប់អានព្រះពុទ្ធសាសនាបាននឹងជាការល្អ” ទើបហៅព្រាហ្មណ៍នោះមក រួចសួរថា “ម្នាលព្រាហ្មណ៍ អ្នកណាហ្ន៎ស្រែកជាសំឡេងដូចលា” ។ ឃោសៈព្រាហ្មណ៍នោះសួរថា “នែបព្វជិតដ៏ចម្រើន លោកដឹងនូវសំឡេងរបស់ពួកលាឬ ?” ព្រះថេរៈតបថា “យើង

ដឹង” ។ ព្រាហ្មណ៍នោះ ទើបសួរព្រះថេរៈក្នុងគណ្ឋិដ្ឋាន (គឺមន្តដែលយល់បានលំបាក) ទាំងឡាយក្នុងគម្ពីរត្រៃវេទ ទាំងគម្ពីរឥតិហាសជាគម្ពីរ ទី៥ ដែលខ្លួនឯងសម្លឹងមិនឃើញន័យឡើយ ទាំងអាចារ្យរបស់ខ្លួន ក៏មិនឃើញមកហើយផង ដែលព្រះថេរៈនោះ ដោយប្រក្រតីក៏ជាអ្នកចេះចប់ត្រៃវេទហើយ មកដល់ឥឡូវនេះ ជាអ្នកបានសម្រេចនូវបដិសម្ភិទាទៀត ព្រោះហេតុនោះ សេចក្ដីលំបាកក្នុងការឆ្លើយនូវបញ្ហាទាំងនោះ ទើបមិនមានដល់លោក ព្រោះដូច្នោះ ទើបព្រះថេរៈឆ្លើយនូវបញ្ហាទាំងនោះបានភ្លាម ។ ហើយពោលនឹងព្រាហ្មណ៍នោះថា “នែព្រាហ្មណ៍ដ៏ចំរើន អ្នកសាកសួរយើងមកច្រើនហើយ ឥឡូវនេះ យើងនឹងសាកសួរនូវបញ្ហាកម្មនឹងអ្នកមួយ អ្នកនឹងឆ្លើយបញ្ហារបស់យើងបានឬទេ ?” ព្រាហ្មណ៍តបថា “ខ្ញុំនឹងឆ្លើយមន្តនោះប្រគេនបាន លោកម្ចាស់ចូរសួរមកចុះ” ទើបព្រះថេរៈសួរនូវបញ្ហាក្នុងគម្ពីរអភិធម្ម ចិត្តយមកៈ[១]នេះថា “**យស្ស ចិត្តំ ឧប្បជ្ជតិ ន និរុជ្ឈតិ តស្ស ចិត្តំ និរុជ្ឈិស្សតិ ន ឧប្បជ្ជិស្សតិ យស្ស វា បន ចិត្តំ និរុជ្ឈិស្សតិ ន ឧប្បជ្ជិស្សតិ តស្ស ចិត្តំ ឧប្បជ្ជតិ ន និរុជ្ឈតិ :** ចិត្តរបស់បុគ្គលណា រមែងកើតឡើង រមែងមិនរលត់ ចិត្តរបស់បុគ្គលនោះ នឹងរលត់ នឹងមិនកើតឡើង ឬក៏ចិត្តរបស់បុគ្គលណា នឹងរលត់ នឹងមិនកើត

---

១. អភិ. យម. យមកវគ្គ. ៩១. ១/១ ។

ឡើង ចិត្តរបស់បុគ្គលនោះ រមែងកើតឡើង រមែងមិនរលត់"[១] ។

ព្រាហ្មណមាណពនោះ មិនអាចនឹងឆ្លើយបាន មិនថា លើ ឬក្រោម ទើបសួរថា "បពិត្រលោកម្ចាស់ដ៏ចំរើន មន្តនេះឈ្មោះមន្តអ្វី ?" ព្រះថេរៈតបថា "ម្នាលព្រាហ្មណ៍ មន្តនេះ ឈ្មោះថា ពុទ្ធមន្ត" ។ ព្រាហ្មណ៍សួរថា "លោកម្ចាស់ដ៏ចម្រើន ឱ្យមន្តនេះដល់ខ្ញុំព្រះករុណាបានដែរឬទេ ?" ព្រះថេរៈតបថា "ម្នាលព្រាហ្មណ៍ យើងឱ្យ (មន្តនេះ) ដល់អ្នកបាន លុះត្រាតែអ្នកបួសជាបព្វជិតដូចយើង" ។

## មាណពបួស ប្រាកដឈ្មោះ ព្រះពុទ្ធឃោសៈ

ឃោសៈព្រាហ្មណ៍ដែលបុព្វហេតុ (គឺកុសលក្នុងកាលមុន) ទាំងឡាយជាស់តឿនហើយ ទើបសូមបព្វជ្ជា ដើម្បីត្រូវការមន្ត ព្រះថេរៈទើឱ្យព្រាហ្មណ៍បព្វជ្ជាឧបសម្បទាហើយ ឱ្យរៀនព្រះត្រៃបិដកពុទ្ធវចនៈ ភិក្ខុនោះ ក៏យល់ដឹងអត្ថធម៌របស់ព្រះត្រៃបិដកថា "នេះជាឯកាយមគ្គ (ដំណើរផ្លូវដ៏ឯក ប្រសើរជាងលទ្ធិចាស់របស់ខ្លួន)" (តមក) ក៏បានជាអ្នកប្រាកដច្បាស់ក្នុងលោក ដូច

---

១. ពាក្យថា **រមែងកើតឡើង** គឺនៅក្នុងឧប្បាទខណៈ, ពាក្យថា **រមែងមិនរលត់** គឺមិនទាន់ដល់និរោធឬភង្គខណៈ ។ ចិត្តក្នុងទីនេះ សំដៅដល់បច្ឆិមចិត្ត គឺចុតិចិត្ត របស់ព្រះអរហន្ត ខណៈចិត្តរបស់ព្រះអរហន្តកំពុងប្រព្រឹត្តទៅ ឈ្មោះថា រមែងកើតឡើង រមែងមិនរលត់ កាលដល់ភង្គខណៈហើយ ចុតិចិត្តនោះ ក៏នឹងរលត់ និងមិនមានចិត្តដទៃកើតឡើងតទៅទៀត ។

ពន្លឺភ្លើង ដូចពន្លឺព្រះចន្ទ ដូចពន្លឺព្រះអាទិត្យ ដោយការដែលលោកបានព្យាករណ៍ពោលឆ្លើយបញ្ហាព្រះធម៌ដ៏ជ្រាលជ្រៅដល់ជនទាំងឡាយ ដូចជាពុទ្ធព្យាករណ៍, ភិក្ខុឃោសៈ ទើបបានប្រាកដនាមថា "ព្រះពុទ្ធឃោសៈ" ព្រោះល្បីផ្សាយទៅក្នុងផ្ទៃផែនដីដូចព្រះពុទ្ធអង្គ ។

## ព្រះថេរៈបញ្ជូនឱ្យទៅប្រែគម្ពីរអដ្ឋកថា

ព្រះពុទ្ធឃោសៈនោះ ជាអ្នកនៅក្នុងវិហារនោះ បានតែងបករណ៍ឈ្មោះញាណោទ័យទុកក្នុងវិហារហើយ ផ្តើមតែងអដ្ឋកថា ព្រះអភិធម្មសង្គណី និងអដ្ឋកថាច្បាប់ឈ្មោះអដ្ឋសាលិនី ព្រះថេរៈឃើញដូច្នោះទើបប្រាប់ថា "ម្នាលអាវុសោពុទ្ធឃោសៈ ក្នុងជម្ពូទ្វីបនេះ មានតែគម្ពីរព្រះត្រៃបិដកបាលីប៉ុណ្ណោះ អដ្ឋកថារបស់ព្រះត្រៃបិដកនោះ និងថេរវាទ (គឺពាក្យដែលព្រះថេរៈក្នុងសម័យសង្គីតិ ពោលទុកជាច្បាប់) មិនមាន តែអដ្ឋកថាព្រះត្រៃបិដកដែលឡើងកាន់សង្គីតិទាំង៣លើក ជាពាក្យដែលព្រះសម្មាសម្ពុទ្ធទ្រង់ត្រាស់សម្តែងទុក និងព្រះថេរៈទាំងឡាយ មានព្រះសារីបុត្រជាដើមចងក្រងទុកហើយ ឯព្រះមហិន្ទត្ថេរត្រួតមើលកថាមគ្គ (សម្តែងផ្លូវនៃពាក្យដែលពោលទុក)ហើយ (រួបរួមមក) តែងទុកដោយភាសាសីហឡៈ កំពុងប្រព្រឹត្តទៅនៅក្នុងសីហឡទ្វីប ចូរលោកទៅកាន់សីហឡទ្វីបនោះ ត្រួតមើលឱ្យសព្វអន្លើហើយ បកប្រែមកជាភាសាមគធ

បាន អដ្ឋកថានោះ នឹងនាំមកនូវប្រយោជន៍សុខដល់មនុស្សលោកទាំងពួង” ។

កាលព្រះថេរណែនាំយ៉ាងនោះ ព្រះពុទ្ធឃោសៈ ជាអ្នកមានបញ្ញាច្រើន ក៏កើតបីតិសោមនស្ស ក្រាបទូលលាព្រះឧបជ្ឈាយ៍ និងភិក្ខុសង្ឃ បានធ្វើដំណើរទៅកាន់កំពង់ទឹកដោយលំដាប់ឡើង ទូកទៅជួបព្រះពុទ្ធទត្តត្ថេរតាមផ្លូវដែលមកដល់កណ្ដាលសមុទ្រ ក៏បាននិយាយប្រាស្រ័យគ្នា ហើយធ្វើដំណើរបន្តទៅដរាបដល់កំពុង ក្រុងលង្កា ក្នុងកាលនោះ ព្រះបាទមហានាម គ្រប់គ្រងរាជ្យក្នុងលង្កាទ្វីប ។

# តែងបករណ៍ ឈ្មោះវិសុទ្ធិមគ្គ

ព្រះពុទ្ធឃោសៈ និមន្តទៅជួបព្រះសង្ឃក្នុងវិហារ ក្រុងអនុរាធបុរី ហើយទើបទៅកាន់សំណាក់ព្រះសង្ឃបាលត្ថេរ ដែលគង់នៅក្នុងមហាបធានឃរៈ បានស្ដាប់( ជ្រាបសេចក្ដី ) អដ្ឋកថាភាសាសីហឡៈ និងថេរវាទទាំងពួងហើយ ជឿទុកចិត្តថា “នេះឯងជាព្រះពុទ្ធាធិប្បាយរបស់ព្រះធម្មសាមិត្រពិត” ទើបទៅកាន់ទីប្រជុំសង្ឃ ក្នុងវិហារនោះ ដើម្បីសូមគម្ពីរធ្វើអដ្ឋកថាព្រះត្រៃបិដក ក៏បានពោលសូមថា “សូមលោកម្ចាស់ទាំងឡាយ មេត្តាឱ្យសៀវភៅគម្ពីរទាំងឡាយដល់ខ្ញុំព្រះករុណាដើម្បីធ្វើអដ្ឋកថា” ។ ដើម្បីសាកល្បង សមត្ថភាពរបស់

លោក ទើបភិក្ខុសង្ឃឱ្យគាថា ២ បទ ហើយពោលថា "លោកចូរសម្ដែងសមត្ថភាពក្នុងគាថា ២ បទនេះ យើងទាំងឡាយ បានឃើញសមត្ថភាពរបស់លោកហើយ នឹងប្រគល់ ច្បាប់គម្ពីរឱ្យទាំងអស់" ព្រះពុទ្ធឃោសមើលបាលីព្រះត្រៃបិដក និងអដ្ឋកថារបស់ព្រះត្រៃបិដកនោះហើយ ទើបព្រះថេរៈរួបរួមព្រះត្រៃបិដកព្រមទាំងអដ្ឋកថាដោយសង្ខេប តែងបករណ៍ ឈ្មោះ វិសុទ្ធិមគ្គឡើង ក្នុងមហាវិហារនេះឯង ។

គ្រានោះ ទេវតា[១]មានបំណង ដើម្បីនឹងប្រកាសថ្វីដៃរបស់លោកឱ្យប្រាកដ ក្នុងមហាជន ទើបបណ្ដាលឱ្យសៀវភៅគម្ពីរច្បាប់ (ដែលលោកសរសេររួចហើយ) ឱ្យអន្តរធានបាត់ទៅ ទើបលោកសរសេរឡើងថ្មីមួយច្បាប់ទៀត ទេវតាក៏បណ្ដាលឱ្យអន្តរធានបាត់ទៅទៀត ទើបលោកសរសេរឡើងថ្មីលើកទី ៣ ទៀត ក៏បាន ចប់សព្វគ្រប់ទៀត ក្នុងគ្រានោះ ព្រះពុទ្ធឃោសៈនិមន្តព្រះសង្ឃ ដែលជាអ្នកឆ្លាសក្នុងធម៌របស់ព្រះសម្ពុទ្ធឱ្យមកប្រជុំគ្នា ក្នុងទីជិតមហាពោធិព្រឹក្ស (ប្រទេសលង្កា) ប្រារព្ធនឹងអានបករណ៍វិសុទ្ធិមគ្គនោះ (ឱ្យសង្ឃស្ដាប់) ស្រាប់តែទេវតាដែលបំបាំងសៀវភៅនោះ នាំសៀវភៅទាំងពីរចប់នោះ មកប្រគេនសងវិញព្រមក្នុងខណៈនោះ ទើបបានជាសៀវភៅវិសុទ្ធិមគ្គ

---

១. ខ្លះថា ព្រះសង្ឃ ។

បីចប់ឡើង ក៏បានប្រគល់សៀវភៅទាំងបីចប់ ទៅព្រះភិក្ខុសង្ឃ, ភិក្ខុសង្ឃឱ្យអានសៀវភៅទាំងបីចប់ ព្រមគ្នា ការខុសភ្លាំងភ្លាត់បីចប់នោះ ដោយគណ្ឋៈក្តី ដោយអក្ខរៈក្តី ដោយបទក្តី ដោយព្យញ្ជនៈក្តី ដោយអត្ថក្តី ដោយការសរសេរមុន ក្រោយក្តី ដោយវាទៈទាំងឡាយមានថេរវាទជាដើមក្តី ដោយព្រះបាលីទាំងឡាយក្តី មិនមានឡើយ បានឮថា កាលគម្ពីរវិសុទ្ធិមគ្គ ទាំង ៣ ដែលព្រះពុទ្ធឃោសៈធ្វើរួចស្រេចហើយយ៉ាងនោះ ទេវតាទាំងឡាយ បាននាំគ្នាធ្វើសាធុការ សម័យនោះភិក្ខុច្រើនពាន់ប្រជុំ គ្នានៅក្នុងវិហារ ឃើញការអស្ចារ្យនោះហើយ ក៏នាំគ្នាសរសើរឱ្យសាធុការ ប្រកាសប្រាប់គ្នាសុសសាយទៅថា "នេះព្រះពោធិសត្វ មេត្រីមកកើត ដោយឥតសង្ស័យ"[១] ។

## បកប្រែអដ្ឋកថាព្រះត្រៃបិដក មកជាភាសាមគធៈ

ចំណែកស្តេចផែនដី ទ្រង់បានស្តាប់ដំណឹងនោះ ក៏ស្តេចចេញពីព្រះនគរព្រមទាំងរាជបរិវារទៅកាន់មហាវិហារ ទ្រង់នមស្ការព្រះសង្ឃហើយ ទ្រង់នមស្ការព្រះពុទ្ធឃោសៈ និមន្តឱ្យទទួលនូវចង្ហាន់នៅក្នុងរាជវាំងជាប្រចាំ រហូតដល់ការតែងគម្ពីរចប់ ព្រះថេរៈ ទទួលនិមន្តដោយតុណ្ហីភាព ។

ព្រះភិក្ខុសង្ឃឃើញសមត្ថភាពរបស់ព្រះថេរៈហើយ ទើបប្រគល់សៀវភៅ

---

១. នេះជាការឃើញអស្ចារ្យរបស់ភិក្ខុទាំងឡាយទេ មិនប្រាកដជាព្រះមេត្រីឡើយ ។

ព្រះត្រៃបិដកបាលី ព្រមទាំងសៀវភៅអដ្ឋកថាសីហឡៈឱ្យដល់ព្រះថេរៈ, ព្រះថេរៈទទួលសៀវភៅគម្ពីរទាំងអស់ទៅទុកក្នុងប្រាសាទ ឈ្មោះថា បធានឃរៈ ដែលតាំងនៅខាងត្បូងនៃមហាវិហារ ប្រែអដ្ឋកថាទាំងអស់ធ្វើជាអដ្ឋកថាព្រះត្រៃបិដកក្នុងភាសាមគធ ដែលជាមូលភាសា ( គឺភាសាដើម ) ។

ក៏អដ្ឋកថាសីហឡៈនោះ មាន ៣ ភាគ គឺ មហាអដ្ឋកថា ១ បច្ចរិយអដ្ឋកថា ១ កុរុន្ទីអដ្ឋកថា ១ ។

អដ្ឋកថាដែលឡើងកាន់មហាសង្គីតិ ព្រះមហិន្ទត្ថេរនាំមកតែងទុកក្នុងភាសាសីហឡៈ ឈ្មោះថា **មហាអដ្ឋកថា** ។

មានផ្ទះផែមួយខ្នង មានឈ្មោះហៅក្នុងភាសាសីហឡៈថា បច្ចរិយៈ ។ អដ្ឋកថាដែលភិក្ខុទាំងនោះប្រជុំគ្នាធ្វើក្នុងផ្ទះផែនោះ ឈ្មោះថា **បច្ចរិយអដ្ឋកថា** ។

មានវិហារមួយកន្លែង ឈ្មោះកុរុន្ទីវិហារ ។ អដ្ឋកថាដែលភិក្ខុទាំងនោះប្រជុំគ្នាធ្វើក្នុងវិហារនោះ ឈ្មោះថា **កុរុន្ទីអដ្ឋកថា** ។

វាទដែលព្រះថេរៈជំនាន់មុនមានព្រះថេរិកាចារ្យ ( អាចារ្យធំ ) ជាដើម កាន់យកន័យព្រះបាលីតែងទុក ឈ្មោះថា **ថេរវាទ** ។

ព្រះពុទ្ធឃោសៈ ប្រែកុរុន្ទីអដ្ឋកថាភាសាសីហឡៈ ធ្វើអដ្ឋកថាព្រះវិន័យបិដក ឈ្មោះសមន្តប្បាសាទិកា ក្នុងភាសាមគធៈហើយ តពីនោះក្នុងសុត្តន្តបិដក បកប្រែមហាអដ្ឋកថាអំពីភាសាសីហឡៈ តាំងជាអដ្ឋកថាទីឃនិកាយ

ឈ្មោះសុមង្គលវិលាសិនី, ជាអដ្ឋកថាមជ្ឈិមនិកាយ ឈ្មោះបបញ្ចសូទនី, ជាអដ្ឋកថាសំយុត្តនិកាយ ឈ្មោះ សារត្ថបកាសិនី, និងជាអដ្ឋកថាអង្គុត្តរនិកាយ ឈ្មោះមនោរថបូរណី, តពីនោះ ក្នុងអភិធម្មបិដក បកប្រែបច្ចរិយអដ្ឋកថាអំពីភាសាសីហឡ: តាំងជាអដ្ឋកថាបករណ៍ធម្មសង្គណី ឈ្មោះអដ្ឋសាលិនីក្នុងភាសាមគធ: ជាអដ្ឋកថាបករណ៍វិភង្គ ឈ្មោះសម្មោហវិនោទនី និងជាអដ្ឋកថា ៥ បករណ៍ ឈ្មោះបរមត្ថទីបនី ។

ព្រះពុទ្ឃោស: ធ្វើអដ្ឋកថាសីហឡ:ទាំងអស់ឱ្យជាអដ្ឋកថា ព្រះត្រៃបិដក ក្នុងភាសាមគធ: ដែលជាមូលភាសាដូចពោលមកហើយដូច្នោះ អដ្ឋកថានោះឯង បាននាំមកនូវប្រយោជន៍សុខដល់ពពួកជន ក្នុងប្រទេសដទៃ ៗទាំងពួងយ៉ាងច្រើនសន្ធឹកសន្ធាប់ហើយ រស់នៅរហូតដល់អស់អាយុ ទើបទៅកាន់ទេវលោកនោះឯង ។

កាលដែលបានបកប្រែអដ្ឋកថាព្រះត្រៃបិដក ចប់សព្វគ្រប់ហើយ ផែនដីក៏កក្រើកញ័រ (ជាអស្ចារ្យ) អដ្ឋកថាព្រះត្រៃបិដក ដែលព្រះថេរ: ធ្វើដូចពោលមកនេះ គឺបកប្រែចប់សព្វ គ្រប់ តែក្នុងរយ:កាល ១ ឆ្នាំប៉ុណ្ណោះ ។

លុះបកប្រែរួចហើយ ព្រះពុទ្ឃោស: ប្រាថ្នាដើម្បីនឹងបាន មកថ្វាយបង្គំព្រះមហាពោធិព្រឹក្ស ទើបក្រាបថ្វាយបង្គំព្រះភិក្ខុសង្ឃ ត្រឡប់មកជម្ពូទ្វីបវិញ ។

ព្រះរាជាមហានាម ទ្រង់គ្រងផែនដីអស់ ១២ ឆ្នាំ ទ្រង់ធ្វើបុណ្យច្រើនយ៉ាង ដោយប្រការផ្សេង ៗហើយ ស្ដេចក៏ទៅកាន់បរលោកតាមយថាកម្ម ។ ចំណែកព្រះពុទ្ធឃោសត្ថេរនោះ បានរចនាអដ្ឋកថានៃព្រះត្រៃបិដកទុក បានសាងប្រយោជន៍ដ៏សមគួរដល់សត្វលោកជាច្រើន តាំងនៅរហូតគ្រប់អាយុខ័យ ក៏បានទៅកាន់ឋានតាវត្តិង្សហើយ ដូច្នេះឯង ។

## សេចក្ដីប្រាថ្នារបស់ព្រះពុទ្ធឃោសត្ថេរ

យំ សិទ្ធំ ឥមិនា បុញ្ញំ យំ ចញ្ញំ បសុតំ មយា
ឯតេន បុញ្ញកម្មេន ទុតិយេ អត្តសម្ភវេ
តាវតឹសេ បមោទេន្តោ សីលាចារគុណេ រតោ
អលគ្គោ បញ្ចកាមេសុ បត្វា បឋមំ ផលំ
អន្តិមេ អត្តភាវម្ហិ មេត្តេយ្យំ មុនិបុង្គវំ
លោកគ្គបុគ្គលំ នាថំ សព្វសត្តហិតេ រតំ
ទិស្វាន តស្ស ធីរស្ស សុត្វា សទ្ធម្មទេសនំ
អធិគន្ត្វា ផលំ អគ្គំ សោភេយ្យំ ជិនសាសនន្តិ ។

បុណ្យណា ដែលសម្រេចហើយដោយការធ្វើនេះ និងបុណ្យដទៃណា ដែលខ្ញុំបានខ្វល់ខ្វាយទុក ដោយអំណាចនៃបុណ្យនោះ ក្នុងអត្តភាពទី២ សូមឱ្យខ្ញុំរីករាយក្នុងឋានតាវត្តិង្ស ត្រេកអរក្នុងគុណគឺសីលនិងអាចារៈ មិនជាប់ជំពាក់ក្នុងកាមគុណទាំង ៥ បានសម្រេចអរិយផលទី ១ (សោតាបត្តិផល) ក្នុងអត្តភាពចុងបំផុត សូមឱ្យខ្ញុំបានជួបព្រះអារ្យមេត្រី ព្រះមុនីដ៏ប្រសើរ ជាបុគ្គលចម្បងក្នុងលោក ជាព្រះលោកនាថ ទ្រង់ពេញព្រះទ័យក្នុងការជួយសត្វលោកទាំងពួង សូមឱ្យខ្ញុំបានស្តាប់ព្រះសទ្ធម្មរបស់ព្រះមុនីអង្គនោះ ដែលទ្រង់ជាអ្នកប្រាជ្ញ ហើយបានសម្រេចអរិយផលជាន់ខ្ពស់ (អរហត្តផល) ញ៉ាំងព្រះសាសនារបស់ព្រះជិនស្រីឱ្យល្អស្អាត ដោយប្រការដូច្នេះហោង ។

ប្រវត្តិរបស់ព្រះពុទ្ធឃោសាចារ្យ ចប់

# ឧប្បត្តិកថា

សមន្តប្បាសាទិកា អដ្ឋកថាព្រះវិន័យ ជាស្នាដៃរបស់ព្រះពុទ្ធឃោសាចារ្យ ។

ប្រទេសខ្មែរយើងនេះ មានគម្ពីរព្រះត្រៃបិដកចប់សព្វគ្រប់ ដែលក្រុមជំនុំ បានរៀបចំឡើងជាភាសាបាលីផង ភាសាខ្មែរផង ខ្ញុំមានចិត្តសោមនស្សរីករាយ ហើយក៏រៀបចំប្រែអដ្ឋកថាព្រះវិន័យនេះ ឱ្យមកជាភាសាខ្មែរផង ដើម្បីបានការយល់ដឹងក្នុងផ្នែកព្រះវិន័យរបស់ព្រះសង្ឃនិងពុទ្ធបរិស័ទខ្មែរយើង ដែលកំពុង តែប្រឹងប្រែងសិក្សាព្រះវិន័យ ។

ខ្ញុំបានសសេរពាក្យបញ្ចូលថែម, គឺ ពាក្យខ្លះយកអំពីបិដក តាមដែល អដ្ឋកថាចង្អុលប្រាប់ផង មិនប្រាប់ផង ដោយមានលេខយោងបញ្ជាក់, ពាក្យខ្លះ មិនមានក្នុងបាលីអដ្ឋកថាទេ ថែមដោយបំណងដើម្បីបញ្ជាក់សេចក្តីប៉ុណ្ណោះ, ម្យ៉ាងទៀត បានដាក់លេខឃ្នាបតាមបិដក ដើម្បីងាយដឹងថា នេះជាសេចក្តីពន្យល់ ក្នុងបិដកត្រង់លេខឃ្នាបនេះ ។ តែដោយសមត្ថភាពរបស់ខ្ញុំព្រមទាំងក្រុមប្រឹក្សា តិចតួច សៀវភៅនេះក៏នៅមានសេចក្តី និងអក្ខរៈ ខុសភ្លាំងភ្លាត់នៅឡើយ ដោយអចេតនា សូម

មេត្តាជួយសម្រួលដោយអនុគ្រោះផងចុះ ។

បុណ្យដែលកើតអំពីការព្យាយាមសាងសៀវភៅនេះ សូមចែកដល់អ្នកសិក្សាទាំងឡាយផង ។ សូមអ្នកសិក្សាទាំងឡាយ ទទួលអនុមោទនាត្រេកអរនូវបុណ្យនេះ ដោយមហាកុសលសោមនស្សវីកកាយ ដែលប្រកបដោយបញ្ញា ឱ្យបានគ្រប់ ៗគ្នា សូមអនុមោទនា !!! ។

សូមឱ្យកុលបុត្រខ្មែរ ខិតខំសិក្សាព្រះធម៌វិន័យ ឱ្យកើតបញ្ញាយល់ដឹង ហើយទ្រទ្រង់សិក្ខាឱ្យបានមាំមួន ឱ្យបានតាំងនៅក្នុងភាពជាអ្នកខ្លាសបាប សង្រួម ប្រយ័ត្នដើម្បីកម្ចាត់បង់នូវបាបចេញ លាងជម្រះមន្ទិលសៅហ្មងក្នុងចិត្ត បំពាក់ អលង្ការ គឺព្រះសទ្ធម្ម ធ្វើខ្លួនឱ្យមានគុណតម្លៃ ឱ្យប្រសើរ ឱ្យផុតពីទុក្ខកង្វល់ នាំខ្លួនឱ្យដល់ឋានសុខសាន្ត ។

ខ្ញុំសូមប្រាថ្នាឱ្យមានបញ្ញាទ្រទ្រង់ព្រះធម៌ព្រះវិន័យ សូមឱ្យបានផុតពីក្តី អន្តរាយទាំងពួង និងបានសម្រេចតាមគោលបំណងដ៏ល្អ ជាពិសេសឱ្យបានដល់ ទីបំផុតទុក្ខ គឺ ព្រះនិព្វាន ដោយឆាប់រហ័សហោង ។

# អក្សរសង្ខេប និងអក្សរពេញ

## បិដក

| អក្សរសង្ខេប | អក្សរពេញនៃបិដក | | | ភាគ |
|---|---|---|---|---|
| វិន. បារា. | វិន័យបិដក | ខុទ្ទកនិកាយ | បារាជិក | ភាគ ១ |
| វិន. សង្ឃា. | វិន័យបិដក | ខុទ្ទកនិកាយ | សង្ឃាទិសេស | ភាគ ២ |
| វិន. និស្ស. | វិន័យបិដក | ខុទ្ទកនិកាយ | និស្សគ្គិយ | ភាគ ៣ |
| វិន. បាចិ. | វិន័យបិដក | ខុទ្ទកនិកាយ | បាចិត្តិយ | ភាគ ៤ |
| វិន. ភិក្ខុនី. | វិន័យបិដក | ខុទ្ទកនិកាយ | ភិក្ខុនីវិភង្គ | ភាគ ៥ |
| វិន. មហា. | វិន័យបិដក | ខុទ្ទកនិកាយ | មហាវគ្គ | ភាគ ៦-៨ |
| វិន. ចុល្ល. | វិន័យបិដក | ខុទ្ទកនិកាយ | ចុល្លវគ្គ | ភាគ ៩-១១ |
| វិន. បរិ. | វិន័យបិដក | ខុទ្ទកនិកាយ | បរិវារៈ | ភាគ ១២-១៣ |
| ទីឃ. សីល. | សុត្តន្តបិដក | ទីឃនិកាយ | សីលក្ខន្ធវគ្គ | ភាគ ១៤-១៥ |
| ទីឃ. មហា. | សុត្តន្តបិដក | ទីឃនិកាយ | មហាវគ្គ | ភាគ ១៦-១៧ |
| ទីឃ. បាដិ. | សុត្តន្តបិដក | ទីឃនិកាយ | បាដិកវគ្គ | ភាគ ១៨-១៩ |
| មជ្ឈិ. មូល. | សុត្តន្តបិដក | មជ្ឈិមនិកាយ | មូលបណ្ណាសក | ភាគ ២០-២២ |
| មជ្ឈិ. មជ្ឈិ. | សុត្តន្តបិដក | មជ្ឈិមនិកាយ | មជ្ឈិមបណ្ណាសក | ភាគ ២៣-២៥ |
| មជ្ឈិ. ឧប. | សុត្តន្តបិដក | មជ្ឈិមនិកាយ | ឧបរិបណ្ណាសក | ភាគ ២៦-២៨ |
| សំយុ. សគា. | សុត្តន្តបិដក | សំយុត្តនិកាយ | សគាថវគ្គ | ភាគ ២៩-៣០ |
| សំយុ. និទា. | សុត្តន្តបិដក | សំយុត្តនិកាយ | និទានវគ្គ | ភាគ ៣១-៣២ |

| **អក្សរសង្ខេប** | **អក្សរពេញនៃអដ្ឋកថា** | | | **ភាគ** |
|---|---|---|---|---|
| សំយុ. ខន្ធ. | សុត្តន្តបិដក | សំយុត្តនិកាយ | ខន្ធវារវគ្គ | ភាគ ៣៣-៣៤ |
| សំយុ. សឡា. | សុត្តន្តបិដក | សំយុត្តនិកាយ | សឡាយតនវគ្គ | ភាគ ៣៥-៣៦ |
| សំយុ. មហា. | សុត្តន្តបិដក | សំយុត្តនិកាយ | មហាវារវគ្គ | ភាគ ៣៧-៣៩ |
| អង្គុ. ឯក. | សុត្តន្តបិដក | អង្គុត្តរនិកាយ | ឯកនិបាត | ភាគ ៤០ |
| អង្គុ. ទុក. | សុត្តន្តបិដក | អង្គុត្តរនិកាយ | ទុកនិបាត | ភាគ ៤០ |
| អង្គុ. តិក. | សុត្តន្តបិដក | អង្គុត្តរនិកាយ | តិកនិបាត | ភាគ ៤១ |
| អង្គុ. បតុ. | សុត្តន្តបិដក | អង្គុត្តរនិកាយ | បតុកនិបាត | ភាគ ៤២-៤៣ |
| អង្គុ. បញ្ច. | សុត្តន្តបិដក | អង្គុត្តរនិកាយ | បញ្ចកនិបាត | ភាគ ៤៤-៤៥ |
| អង្គុ. ឆក្ក. | សុត្តន្តបិដក | អង្គុត្តរនិកាយ | ឆក្កនិបាត | ភាគ ៤៦ |
| អង្គុ. សត្ត. | សុត្តន្តបិដក | អង្គុត្តរនិកាយ | សត្តកនិបាត | ភាគ ៤៧ |
| អង្គុ. អដ្ឋ. | សុត្តន្តបិដក | អង្គុត្តរនិកាយ | អដ្ឋកនិបាត | ភាគ ៤៨ |
| អង្គុ. នវ. | សុត្តន្តបិដក | អង្គុត្តរនិកាយ | នវកនិបាត | ភាគ ៤៩ |
| អង្គុ. ទស. | សុត្តន្តបិដក | អង្គុត្តរនិកាយ | ទសកនិបាត | ភាគ ៥០-៥១ |
| អង្គុ. ឯកា. | សុត្តន្តបិដក | អង្គុត្តរនិកាយ | ឯកាទសកនិបាត | ភាគ ៥១ |
| ខុទ្ទ. បាឋ. | សុត្តន្តបិដក | ខុទ្ទកនិកាយ | ខុទ្ទកបាឋ | ភាគ ៥២ |
| ខុទ្ទ. ធម្ម. | សុត្តន្តបិដក | ខុទ្ទកនិកាយ | ធម្មបទ | ភាគ ៥២ |
| ខុទ្ទ. ឧទា. | សុត្តន្តបិដក | ខុទ្ទកនិកាយ | ឧទាន | ភាគ ៥២ |
| ខុទ្ទ. ឥតិ. | សុត្តន្តបិដក | ខុទ្ទកនិកាយ | ឥតិវុត្តក | ភាគ ៥៣ |
| ខុទ្ទ. សុត្ត. | សុត្តន្តបិដក | ខុទ្ទកនិកាយ | សុត្តនិបាត | ភាគ ៥៤ |

| អក្សរសង្ខេប | អក្សរពេញនៃអដ្ឋកថា | | | ភាគ |
|---|---|---|---|---|
| ខុទ្ទ. វិមា. | សុត្តន្តបិដក | ខុទ្ទកនិកាយ | វិមានវត្ថុ | ភាគ ៥៥ |
| ខុទ្ទ. បេត. | សុត្តន្តបិដក | ខុទ្ទកនិកាយ | បេតវត្ថុ | ភាគ ៥៦ |
| ខុទ្ទ. ថេរ. | សុត្តន្តបិដក | ខុទ្ទកនិកាយ | ថេរគាថា | ភាគ ៥៦. ៥៧. |
| ខុទ្ទ. ថេរី. | សុត្តន្តបិដក | ខុទ្ទកនិកាយ | ថេរីគាថា | ភាគ ៥៧ |
| ខុទ្ទ. ជាត. | សុត្តន្តបិដក | ខុទ្ទកនិកាយ | ជាតក | ភាគ ៥៨-៦៣ |
| ខុទ្ទ. មហា. | សុត្តន្តបិដក | ខុទ្ទកនិកាយ | មហានិទ្ទេស | ភាគ ៦៤-៦៦. |
| ខុទ្ទ. ចូឡ. | សុត្តន្តបិដក | ខុទ្ទកនិកាយ | ចូឡនិទ្ទេស | ភាគ ៦៧. ៦៨. |
| ខុទ្ទ. បដិ. | សុត្តន្តបិដក | ខុទ្ទកនិកាយ | បដិសម្ភិទាមគ្គ | ភាគ ៦៩-៧១. |
| ខុទ្ទ. អប្ប. | សុត្តន្តបិដក | ខុទ្ទកនិកាយ | អប្បទាន | ភាគ ៧២-៧៦ |
| ខុទ្ទ. ពុទ្ធ. | សុត្តន្តបិដក | ខុទ្ទកនិកាយ | ពុទ្ធវង្ស | ភាគ ៧៦ |
| ខុទ្ទ. ចរិ. | សុត្តន្តបិដក | ខុទ្ទកនិកាយ | ចរិយាបិដក | ភាគ ៧៦ |
| អភិ. សង្គ. | អភិធម្មបិដក | ខុទ្ទកនិកាយ | ធម្មសង្គណី | ភាគ ៧៨. ៧៩. |
| អភិ. វិភ. | អភិធម្មបិដក | ខុទ្ទកនិកាយ | វិភង្គ | ភាគ ៨០-៨២. |
| អភិ. ធាតុ. | អភិធម្មបិដក | ខុទ្ទកនិកាយ | ធាតុកថា | ភាគ ៨៣. |
| អភិ. បុគ្គ. | អភិធម្មបិដក | ខុទ្ទកនិកាយ | បុគ្គលបញ្ញត្តិ | ភាគ ៨៣. |
| អភិ. កថា. | អភិធម្មបិដក | ខុទ្ទកនិកាយ | កថាវត្ថុ | ភាគ ៨៤-៩០ |
| អភិ. យម. | អភិធម្មបិដក | ខុទ្ទកនិកាយ | យមក | ភាគ ៩១-៩៣. |
| អភិ. បដ្ឋា. | អភិធម្មបិដក | ខុទ្ទកនិកាយ | មហាបដ្ឋាន | ភាគ ៩៤-១១០ |

# អដ្ឋកថា

| អក្សរសង្ខេប | អក្សរពេញនៃអដ្ឋកថា | | |
|---|---|---|---|
| សមន្ត. ពាហិ. | សមន្តប្បាសាទិកា | អដ្ឋកថានៃវិនយ | ពាហិរនិទាន |
| សមន្ត. វេរ. | សមន្តប្បាសាទិកា | អដ្ឋកថានៃវិនយ | វេរញ្ជកណ្ឌ |
| សមន្ត. បារា. | សមន្តប្បាសាទិកា | អដ្ឋកថានៃវិនយ | បារាជិកកណ្ឌ |
| សមន្ត. សង្ឃា. | សមន្តប្បាសាទិកា | អដ្ឋកថានៃវិនយ | សង្ឃាទិសេស |
| សមន្ត. និស្ស. | សមន្តប្បាសាទិកា | អដ្ឋកថានៃវិនយ | និស្សគ្គិយ |
| សមន្ត. បាចិ. | សមន្តប្បាសាទិកា | អដ្ឋកថានៃវិនយ | បាចិត្តិយ |
| សមន្ត. មហា. | សមន្តប្បាសាទិកា | អដ្ឋកថានៃវិនយ | មហាវគ្គ |
| សមន្ត. ចុល្ល. | សមន្តប្បាសាទិកា | អដ្ឋកថានៃវិនយ | ចុល្លវគ្គ |
| សមន្ត. បរិ. | សមន្តប្បាសាទិកា | អដ្ឋកថានៃវិនយ | បរិវារៈ |
| សុមង្គ. សីល. | សុមង្គលវិលាសិនី | អដ្ឋកថានៃទីឃនិកាយ | សីលក្ខន្ធវគ្គ |
| សុមង្គ. មហា. | សុមង្គលវិលាសិនី | អដ្ឋកថានៃទីឃនិកាយ | មហាវគ្គ |
| សុមង្គ. បាដិ. | សុមង្គលវិលាសិនី | អដ្ឋកថានៃទីឃនិកាយ | បាដិកវគ្គ |
| បបញ្ច. មូល. | បបញ្ចសូទនី | អដ្ឋកថានៃមជ្ឈិមនិកាយ | មូលបណ្ណាសក |
| បបញ្ច. មជ្ឈិ. | បបញ្ចសូទនី | អដ្ឋកថានៃមជ្ឈិមនិកាយ | មជ្ឈិមបណ្ណាសក |
| បបញ្ច. ឧប. | បបញ្ចសូទនី | អដ្ឋកថានៃមជ្ឈិមនិកាយ | ឧបរិបណ្ណាសក |
| សារត្ថ. សគា. | សារត្ថប្បកាសិនី | អដ្ឋកថានៃសំយុត្តនិកាយ | សគាថវគ្គ |
| សារត្ថ. និទា. | សារត្ថប្បកាសិនី | អដ្ឋកថានៃសំយុត្តនិកាយ | និទានវគ្គ |
| សារត្ថ. ខន្ធ. | សារត្ថប្បកាសិនី | អដ្ឋកថានៃសំយុត្តនិកាយ | ខន្ធវារវគ្គ |

| អក្សរសង្ខេប | អក្សរពេញនៃអដ្ឋកថា | | |
|---|---|---|---|
| សារត្ថ. សឡា. | សារត្ថប្បកាសិនី | អដ្ឋកថានៃសំយុត្តនិកាយ | សឡាយតនវគ្គ |
| សារត្ថ. មហា. | សារត្ថប្បកាសិនី | អដ្ឋកថានៃសំយុត្តនិកាយ | មហាវារវគ្គ |
| មនោរ. ឯក. | មនោរថបូរណី | អដ្ឋកថានៃអង្គុត្តរនិកាយ | ឯកនិបាត |
| មនោរ. ទុក. | មនោរថបូរណី | អដ្ឋកថានៃអង្គុត្តរនិកាយ | ទុកនិបាត |
| មនោរ. តិក. | មនោរថបូរណី | អដ្ឋកថានៃអង្គុត្តរនិកាយ | តិកនិបាត |
| មនោរ. ចតុ. | មនោរថបូរណី | អដ្ឋកថានៃអង្គុត្តរនិកាយ | ចតុកនិបាត |
| មនោរ. បញ្ច. | មនោរថបូរណី | អដ្ឋកថានៃអង្គុត្តរនិកាយ | បញ្ចកនិបាត |
| មនោរ. ឆក្ក. | មនោរថបូរណី | អដ្ឋកថានៃអង្គុត្តរនិកាយ | ឆក្កនិបាត |
| មនោរ. សត្ត. | មនោរថបូរណី | អដ្ឋកថានៃអង្គុត្តរនិកាយ | សត្តកនិបាត |
| មនោរ. អដ្ឋ. | មនោរថបូរណី | អដ្ឋកថានៃអង្គុត្តរនិកាយ | អដ្ឋកនិបាត |
| មនោរ. នវ. | មនោរថបូរណី | អដ្ឋកថានៃអង្គុត្តរនិកាយ | នវកនិបាត |
| មនោរ. ទស. | មនោរថបូរណី | អដ្ឋកថានៃអង្គុត្តរនិកាយ | ទសកនិបាត |
| មនោរ. ឯកា. | មនោរថបូរណី | អដ្ឋកថានៃអង្គុត្តរនិកាយ | ឯកាទសកនិបាត |
| បរត្ថ. បាឋ. | បរមត្ថជោតិកាយ | អដ្ឋកថានៃខុទ្ទកនិកាយ | ខុទ្ទកបាឋ |
| អដ្ឋ. ធម្ម. | ធម្មបទដ្ឋកថា | អដ្ឋកថានៃខុទ្ទកនិកាយ | ធម្មបទគាថា |
| បរត្ថ. ឧទា. | បរមត្ថទីបនី | អដ្ឋកថានៃខុទ្ទកនិកាយ | ឧទាន |
| បរត្ថ. ឥតិ. | បរមត្ថទីបនី | អដ្ឋកថានៃខុទ្ទកនិកាយ | ឥតិវុត្តក |
| បរត្ថ. សុត្ត. | បរមត្ថជោតិកា | អដ្ឋកថានៃខុទ្ទកនិកាយ | សុត្តនិបាត |
| បរត្ថ. វិមា. | បរមត្ថទីបនី | អដ្ឋកថានៃខុទ្ទកនិកាយ | វិមានវត្ថុ |
| បរត្ថ. បេត. | បរមត្ថទីបនី | អដ្ឋកថានៃខុទ្ទកនិកាយ | បេតវត្ថុ |

## អក្សរសង្ខេប អក្សរពេញនៃអដ្ឋកថា

| | | | |
|---|---|---|---|
| បរត្ថ. ថេរ. | បរមត្ថទីបនី | អដ្ឋកថានៃខុទ្ទកនិកាយ | ថេរគាថា |
| បរត្ថ. ថេរី. | បរមត្ថទីបនី | អដ្ឋកថានៃខុទ្ទកនិកាយ | ថេរីគាថា |
| អដ្ឋ. ជាត. | ជាតកដ្ឋកថា | អដ្ឋកថានៃខុទ្ទកនិកាយ | ជាតក |
| សទ្ធម្ម. មហា. | សទ្ធម្មប្បជោតិកា | អដ្ឋកថានៃខុទ្ទកនិកាយ | មហានិទ្ទេស |
| សទ្ធម្ម. ចូឡ. | សទ្ធម្មប្បជោតិកា | អដ្ឋកថានៃខុទ្ទកនិកាយ | ចូឡនិទ្ទេស |
| សទ្ធម្ម. បដិ. | សទ្ធម្មប្បកាសិនី | អដ្ឋកថានៃខុទ្ទកនិកាយ | បដិសម្ភិទាមគ្គ |
| វិសុទ្ធ. អប្ប. | វិសុទ្ធជនវិលាសិនី | អដ្ឋកថានៃខុទ្ទកនិកាយ | អប្បទាន |
| មធុរ. ពុទ្ធ. | មធុរត្ថវិលាសិនី | អដ្ឋកថានៃខុទ្ទកនិកាយ | ពុទ្ធវង្ស |
| បរម. ចរិ. | វិមលវិលាសិនី | អដ្ឋកថានៃខុទ្ទកនិកាយ | ចរិយា |
| អដ្ឋសា. សង្គ. | អដ្ឋសាលិនី | អដ្ឋកថានៃព្រះអភិធម្ម | ធម្មសង្គណី |
| សម្មោហ. វិភ. | សម្មោហវិនោទនី | អដ្ឋកថានៃព្រះអភិធម្ម | វិភង្គ |
| បរម. បញ្ចប. | បរមត្ថទីបនី | អដ្ឋកថានៃព្រះអភិធម្ម | បញ្ចបករណ៍ |
| វិសុ. សីល. | វិសុទ្ធិមគ្គ | សីលនិទ្ទេស | ភាគ ១ |
| វិសុ. សមាធិ. | វិសុទ្ធិមគ្គ | សមាធិនិទ្ទេស | ភាគ ២ |
| វិសុ. បញ្ញា. | វិសុទ្ធិមគ្គ | បញ្ញានិទ្ទេស | ភាគ ៣ |
| ថៃ. | អដ្ឋកថាថៃ | | |
| ភូមា. | ឆដ្ឋសង្គាយនាភូមា | | |

គប្បីជ្រាបលេខ ដែលនៅបន្ទាប់ពីអក្សរសង្ខេប ដូច្នេះ គឺ លេខខាងដើមជាលេខភាគ នៃគម្ពីរ លេខកណ្ដាលជាលេខឃ្នាប លេខខាងចុងជាលេខទំព័រ ។

ឧទាហរណ៍ ៤. ៤៧៦/៤៧៨ គឺ ភាគទី ៤ ឃ្នាបទី ៤៧៦ ទំព័រទី ៤៧៨ ។



# បញ្ជីមាតិកា

**មាតិកា** **ទំព័រ**


ហេតុដែលព្រះពុទ្ធទ្រង់បញ្ញត្តសិក្ខាបទ ... ... ... ... ... ... ក

ប្រវត្តិរបស់ព្រះពុទ្ធឃោសាចារ្យ ... ... ... ... ... ... ... ... ង

ឧប្បត្តិកថា ... ... ... ... ... ... ... ... ... ... ... ... ... ឋ

អក្សរសង្ខេប និងអក្សរពេញ ... ... ... ... ... ... ... ... ធ

បញ្ជីមាតិកា ... ... ... ... ... ... ... ... ... ... ... ... ... ម


## មាតិកាបរិវារៈ


ពណ៌នាមហាវារៈ ១៦ ក្នុងឧភតោវិភង្គ ... ... ... ... ... ... ១

វារៈផ្សេង ៗ ... ... ... ... ... ... ... ... ... ... ... ... ១០

ពណ៌នាសមុដ្ឋានសីស ... ... ... ... ... ... ... ... ... ... ... ១២

បឋមបារាជិកសមុដ្ឋាន ... ... ... ... ... ... ... ... ... ១៥

ទុតិយបារាជិកសមុដ្ឋាន ... ... ... ... ... ... ... ... ... ២០

សញ្ចរិត្តសមុដ្ឋាន ... ... ... ... ... ... ... ... ... ... ៣០

កឋិនសមុដ្ឋាន ... ... ... ... ... ... ... ... ... ... ... ៤០

ឯឡកលោមសមុដ្ឋាន ... ... ... ... ... ... ... ... ... ៤៥

បទសោធម្មសមុដ្ឋាន ... ... ... ... ... ... ... ... ... ... ៥១

អទ្ធានសមុដ្ឋាន ... ... ... ... ... ... ... ... ... ... ... ៥៣

យ បញ្ជីមាតិកាអដ្ឋកថាបរិវារៈ

**មាតិកា** **ទំព័រ**

ថេយ្យសត្ថសមុដ្ឋាន ... ... ... ... ... ... ... ... ... ... ៥៤
ធម្មទេសនាសមុដ្ឋាន ... ... ... ... ... ... ... ... ... ... ៥៦
ពណ៌នាកតិបុច្ឆាវារ
វិនិច្ឆ័យក្នុងពាក្យថា កតិ អាបត្តិយោ ជាដើម ... ... ... ៥៨
វិគ្រោះនៃអាវតិសព្ទជាដើម ... ... ... ... ... ... ... ... ៦០
អគារវៈ ៦ ... ... ... ... ... ... ... ... ... ... ... ... ៦២
វិវាទមូលនិទ្ទេស ... ... ... ... ... ... ... ... ... ... ... ៦៤
អនុវាទមូលនិទ្ទេស ... ... ... ... ... ... ... ... ... ... ៦៦
សាធារណីយធម្មនិទ្ទេស ... ... ... ... ... ... ... ... ... ៦៧
ពណ៌នាខន្ធកបុច្ឆា ... ... ... ... ... ... ... ... ... ... ... ... ៧៣
ពណ៌នាឯកុត្តរិកៈ ... ... ... ... ... ... ... ... ... ... ... ... ៧៨
អធិប្បាយពួក ១ ... ... ... ... ... ... ... ... ... ... ៧៨
អធិប្បាយពួក ២ ... ... ... ... ... ... ... ... ... ... ៨៦
អធិប្បាយពួក ៣ ... ... ... ... ... ... ... ... ... ... ៩៨
ការបិទ ៣ យ៉ាងជាដើម ... ... ... ... ... ... ... ... ... ១០៤
អាបត្តិដែលភិក្ខុអាពាធត្រូវជាដើម ... ... ... ... ... ... ១០៥
អាបត្តិដែលត្រូវនៅកណ្ដាលជំនុំសង្ឃជាដើម ... ... ... ១០៦

អង្គជាហេតុដាក់ទោសនិងបន្ថែមទោស ... ... ... ... ... ១០៧



**មាតិកា** **ទំព័រ**

ពណ៌នាពួក ៤

ប្រភេទរបស់អាបត្តិ ... ... ... ... ... ... ... ... ... ... ១១៤

វិនិច្ឆ័យក្នុងកម្មចតុក្កៈ ... ... ... ... ... ... ... ... ... ១១៨

វិនិច្ឆ័យក្នុងបរិក្ខារចតុក្កៈ .. ... ... ... ... ... ... ... ... ១១៩

វិនិច្ឆ័យក្នុងសម្មុខចតុក្កៈ ... ... ... ... ... ... ... ... ... ១១៩

ក្លាយភេទ ... ... ... ... ... ... ... ... ... ... ... ... ១២០

វិនិច្ឆ័យក្នុងសហបដិលាភចតុក្កៈ ... ... ... ... ... ... ... ១២១

វិនិច្ឆ័យក្នុងអាគន្តុកាទិចតុក្កៈ ... ... ... ... ... ... ... ១២៣

វិនិច្ឆ័យក្នុងវត្តុទានត្តតាទិចតុក្កៈ ... ... ... ... ... ... ... ១២៤

វិនិច្ឆ័យក្នុងវត្តុសភាគាទិចតុក្កៈ ... ... ... ... ... ... ... ១២៥

វិនិច្ឆ័យក្នុងឧបជ្ឈាយ៍ចតុក្កៈ ... ... ... ... ... ... ... ... ១២៦

វិនិច្ឆ័យក្នុងអាទិយន្តចតុក្កៈជាដើម ... ... ... ... ... ... ១២៧

វិនិច្ឆ័យក្នុងកាលចតុក្កៈជាដើម ... ... ... ... ... ... ... ១២៨

វិនិច្ឆ័យក្នុងបុព្វកិច្ចាទិចតុក្កៈ ... ... ... ... ... ... ... ... ១៣២

វិនិច្ឆ័យក្នុងគិលានចតុក្កៈ ... ... ... ... ... ... ... ... ... ១៣៤

ពណ៌នាពួក ៥ ... ... ... ... ... ... ... ... ... ... ... ១៣៥

សំពត់បង្សុកូលជាអាទិ ... ... ... ... ... ... ... ... ... ១៣៧

អានិសង្សនៃការបោស ... ... ... ... ... ... ... ... ... ១៤១

អង្គរបស់ព្រះវិន័យធរ ... ... ... ... ... ... ... ... ... ១៤៦

ល បញ្ជីមាតិកាអដ្ឋកថាបរិវារៈ

**មាតិកា** **ទំព័រ**

ភិក្ខុដែលនៅព្រៃ ... ... ... ... ... ... ... ... ... ១៥១
អង្គរបស់ភិក្ខុដែលត្រូវកាន់និស្ស័យ ... ... ... ... ១៥២
វិនិច្ឆ័យក្នុងអបាសាទិកបញ្ចកៈ ... ... ... ... ... ... ១៥៣
ពណ៌នាពួក ៦ ... ... ... ... ... ... ... ... ... ... ... ១៥៤
ពណ៌នាពួក ៧ ... ... ... ... ... ... ... ... ... ... ... ១៥៩
ពណ៌នាពួក ៨ ... ... ... ... ... ... ... ... ... ... ... ១៦២
ពណ៌នាពួក ៩ ... ... ... ... ... ... ... ... ... ... ... ១៦៧
ពណ៌នាពួក ១០ ... ... ... ... ... ... ... ... ... ... ... ១៧២
ពណ៌នាពួក ១១ ... ... ... ... ... ... ... ... ... ... ... ១៧៦
ពណ៌នាបុច្ឆាវិសជ្ជនាអំពីឧបោសថកម្មជាដើម ... ... ... ... ... ១៨២
ពណ៌នាបករណៈ អំពីអំណាចប្រយោជន៍ ... ... ... ... ... ... ១៨៤
ពណ៌នាបឋមគាថាសង្គណិកៈ ... ... ... ... ... ... ... ... ... ១៨៧
វិបត្តិ ៤ ... ... ... ... ... ... ... ... ... ... ... ... ... ១៨៩
ប្រមូលសិក្ខាបទ ... ... ... ... ... ... ... ... ... ... ... ១៩១
ចែកសិក្ខាបទ ... ... ... ... ... ... ... ... ... ... ... ១៩៣
កងអាបត្តិដែលរម្ងាប់បាន ... ... ... ... ... ... ... ... ១៩៨
វិគ្រោះបារាជិក ... ... ... ... ... ... ... ... ... ... ... ២០១
វិគ្រោះសង្ឃាទិសេស ... ... ... ... ... ... ... ... ... ២០២

វិគ្រោះអនិយតៈ ... ... ... ... ... ... ... ... ... ... ... ២០៣



**មាតិកា** **ទំព័រ**

វិគ្រោះបុល្លច្ច័យ វិគ្រោះនិស្សគ្គិយ ... ... ... ... ... ២០៤
វិគ្រោះបាចិត្តិយ វិគ្រោះបាដិទេសនីយៈ ... ... ... ... ២០៥
វិគ្រោះទុក្កដ ... ... ... ... ... ... ... ... ... ... ... ២០៦
វិគ្រោះទុព្ភាសិត ... ... ... ... ... ... ... ... ... ... ... ២០៧
វិគ្រោះសេក្ខិយៈ ... ... ... ... ... ... ... ... ... ... ... ២០៨
ឧបមានៃអាបត្តិអនាបត្តិ ... ... ... ... ... ... ... ... ... ២០៩
ពណ៌នាអធិករណភេទ
សើរើសមថៈ ដោយសើរើអធិករណ៍ ... ... ... ... ... ២១១
ការសើរើ ១២ ... ... ... ... ... ... ... ... ... ... ... ២១២
ការបានទូវការសើរើ ១០ យ៉ាង ... ... ... ... ... ... ... ២១៣
អង្គ ៤ ជាហេតុសើរើអធិករណ៍ ... ... ... ... ... ... ២១៧
អ្នកសើរើអធិករណ៍ត្រូវអាបត្តិ ... ... ... ... ... ... ... ២១៨
និទានជាដើមនៃអធិករណ៍ ... ... ... ... ... ... ... ... ២២១
មូលជាដើមនៃអធិករណ៍ ... ... ... ... ... ... ... ... ... ២២៤
សមថៈលាយនិងមិនលាយគ្នា ... ... ... ... ... ... ... ២២៦
និទានជាដើមនៃសមថៈ ... ... ... ... ... ... ... ... ... ២២៧
សមុដ្ឋាននៃសមថៈ ... ... ... ... ... ... ... ... ... ... ២២៨
ពណ៌នាគាថាសង្គណិកៈ ជាតំណាមក ... ... ... ... ... ... ... ២៣០

**មាតិកា** **ទំព័រ**

ពណ៌នាចោទនាកណ្ឌ
កិច្ចរបស់ភិក្ខុដែលពោលអត្តក្តី ... ... ... ... ... ... ... ២៣៨
ខាងដើមរបស់ចោទនាជាដើម ... ... ... ... ... ... ... ២៣៩
ពណ៌នាចូឡសង្គាម ... ... ... ... ... ... ... ... ... ... ... ... ២៤៥
ប្រយោជន៍នៃព្រះសូត្រជាដើម ... ... ... ... ... ... ... ២៥៣
ប្រយោជន៍នៃព្រះវិន័យជាដើម ... ... ... ... ... ... ... ២៥៥
អនុយោគវត្តគាថា ... ... ... ... ... ... ... ... ... ... ២៥៩
បណ៌នាមហាសង្គាម ... ... ... ... ... ... ... ... ... ... ... ២៦២
ពណ៌នាកឋិនភេទ
ធម៌ដែលកើតជាមួយនឹងការក្រាលកឋិន ... ... ... ... ... ២៦៦
អនន្តរប្បច្ច័យជាដើម ... ... ... ... ... ... ... ... ... ២៦៦
បច្ច័យប្រយោគជាដើម ... ... ... ... ... ... ... ... ... ២៦៧
និទាននៃប្រយោគជាដើម ... ... ... ... ... ... ... ... ... ២៧១
វិបត្តិនៃកឋិនជាដើម ... ... ... ... ... ... ... ... ... ... ២៧២
ការដោះកឋិន ... ... ... ... ... ... ... ... ... ... ... ២៧៣
អង្គ ៥ នៃភិក្ខុដែលកាន់និស្ស័យ ... ... ... ... ... ... ២៧៥
អង្គ ៥ របស់ភិក្ខុដែលចូលសង្គ្រាម ... ... ... ... ... ២៧៧
អង្គ ៥ របស់ភិក្ខុដែលពោលមិនជាទីស្រឡាញ់ ... ... ... ២៧៨

អង្គរបស់ភិក្ខុដែលមិនគួរនិយាយក្នុងសង្ឃ ... ... ... ... ២៨១



**មាតិកា** **ទំព័រ**

ផ្ញើសេចក្ដីឃើញជំទាស់គ្នា ... ... ... ... ... ... ... ... ២៨៧
ឱកាសកម្ម ... ... ... ... ... ... ... ... ... ... ... ... ២៨៩
សួរបញ្ហា ... ... ... ... ... ... ... ... ... ... ... ... ២៩០
អធិប្បាយមុសាវាទ ... ... ... ... ... ... ... ... ... ... ២៩១
អាការជាហេតុត្រូវអាបត្តិ ... ... ... ... ... ... ... ... ២៩២
អង្គជាហេតុដាក់ទោស ... ... ... ... ... ... ... ... ... ២៩៣
អ្នកមានចិត្តធ្ងន់ ... ... ... ... ... ... ... ... ... ... ... ២៩៧
សង្ឃភេទ ... ... ... ... ... ... ... ... ... ... ... ... ២៩៨
សង្ឃរាជី ... ... ... ... ... ... ... ... ... ... ... ... ៣០១
ភិក្ខុដែលទម្លាយសង្ឃ ... ... ... ... ... ... ... ... ... ៣០២
បុគ្គលដែលមិនគួរសំពះ ... ... ... ... ... ... ... ... ... ៣០៤
ពណ៌នាសមុដ្ឋាន ... ... ... ... ... ... ... ... ... ... ... ... ៣០៧
ពណ៌នាទុតិយគាថាសង្គណិកៈ ... ... ... ... ... ... ... ... ៣១០
អាបត្តិដែលតាំងឡើងអំពីកាយជាដើម ... ... ... ... ... ៣១០
អាបត្តិដែលត្រូវក្នុងវេលាអរុណរះជាដើម ... ... ... ... ៣១១
មូលរបស់វិន័យជាដើម អាបត្តិដែលត្រូវក្នុងចន្លោះផ្ទះជាដើម ៣១៣
អាបត្តិដែលប្រកបដោយវាចាត្រូវតែក្នុងរាត្រីជាដើម ... ... ៣១៥
អាបត្តិដែលជាទេសនាគាមិនីជាដើម ... ... ... ... ... ... ៣១៦

អាបត្តិបារាជិកដែលតាំងឡើងអំពីកាយជាដើម ... ... ... ៣១៨

ឡ បញ្ជីមាតិកាអដ្ឋកថាបរិវារៈ

**មាតិកា** **ទំព័រ**

អាបត្តិដែលធ្វើការវាយតប់ខ្លួនឯងជាដើម ... ... ... ... ៣១៩
អាបត្តិក្នុងបាណាតិបាតជាដើម ... ... ... ... ... ... ... ៣២០
បុគ្គលដែលមិនគួរឱ្យឧបសម្បទាជាដើម ... ... ... ... ... ៣២០
អាបត្តិក្នុងអទិន្នាទានជាដើម ... ... ... ... ... ... ... ... ៣២៤
ពិន័យអាបត្តិគួបបញ្ចូលគ្នាជាដើម ... ... ... ... ... ... ៣២៥
អាបត្តិក្នុងការដើរជាដើម ... ... ... ... ... ... ... ... ... ៣២៧
អាបត្តិច្រើនត្រូវក្នុងខណៈជាមួយគ្នា ... ... ... ... ... ៣២៨
វិធីសម្តែងអាបត្តិ ... ... ... ... ... ... ... ... ... ... ... ៣២៩
ត្រូវអាបត្តិក្នុងខណៈសូធ្យសមនុភាសនកម្មជាដើម ... ... ៣៣០
ស្ថានៈ ៥ នៃយាវតតិយកាបត្តិជាដើម ... ... ... ... ... ៣៣២
អាបត្តិមកកាយក្នុងរាត្រីជាដើម ... ... ... ... ... ... ... ៣៣៤
ភិក្ខុដែលសង្ឃលើកវត្តជាដើម ... ... ... ... ... ... ... ៣៣៦
មុសាវាទមានអង្គ ៨ ជាដើម ... ... ... ... ... ... ... ៣៣៨
កម្មជាប់ដោយញត្តិជាដើម.. ... ... ... ... ... ... ... ... ៣៤០
ទោសរបស់កម្មជាដើម ... ... ... ... ... ... ... ... ... ៣៤៣
អាបត្តិរម្ងាប់និងមិនរម្ងាប់ ... ... ... ... ... ... ... ... ៣៤៤
បុគ្គលដែលបំបែកសង្ឃទៅកាន់អបាយ ... ... ... ... ... ៣៤៦
ពណ៌នាសេទមោចនគាថា ... ... ... ... ... ... ... ... ... ... ៣៤៩

ពណ៌នាបញ្ចវគ្គ ... ... ... ... ... ... ... ... ... ... ... ... ៣៦៥



| មាតិកា | ទំព័រ |
| --- | --- |
| សេចក្តីផ្សេងនៃកម្ម ៤ | ៣៦៥ |
| កម្មវិបត្តិដោយវត្ថុ | ៣៦៨ |
| កម្មវិបត្តិដោយញត្តិ | ៣៧២ |
| កម្មវិបត្តិដោយអនុស្សាវនា | ៣៧៤ |
| កម្មវិបត្តិដោយសីមា | ៣៨១ |
| កម្មវិបត្តិដោយបរិស័ទ | ៣៨៤ |
| អបលោកនកម្ម | ៣៨៥ |
| និស្សារណា និង ឱសារណា | ៣៨៦ |
| ព្រហ្មទណ្ឌ | ៣៨៨ |
| កម្មលក្ខណៈ | ៣៩០ |
| កម្មលក្ខណវិនិច្ឆ័យ | ៣៩៣ |
| ញត្តិកម្ម | ៤០៤ |
| ញត្តិទុតិយកម្ម | ៤០៩ |
| ញត្តិចតុត្ថកម្ម | ៤១០ |
| ប្រយោជន៍នៃការបញ្ញត្តិសិក្ខាបទ | ៤១២ |
| ពណ៌នាបញ្ញត្តិវគ្គ អានិសង្សនៃបញ្ញត្តិ | ៤១៥ |
| សង្គហៈ ការសង្គ្រោះ | ៤១៦ |
| វិនយដ្ឋកថាវសានគាថា | ៤១៩ |

# សមន្តបាសាទិកា

## អដ្ឋកថា វិនយបិដក

## បរិវារៈ

## បឋមភាគ

## ១២

# បរិវារវណ្ណនា

វិន័យណា ដែលព្រះថេរៈទាំងឡាយចាត់ចូលពួក ដោយឈ្មោះថា បរិវារៈ ជាលំដាប់នៃខន្ធកៈទាំងឡាយ ក្នុងសាសនារបស់ព្រះមានព្រះភាគ ដែលមានបរិវារៈល្អស្អាត មានកងធម៌ជាព្រះសរីរៈ, ឥឡូវនេះ ខ្ញុំនឹងលះន័យដែលពោលរួចមកហើយក្នុងកាលមុនចេញ នឹងធ្វើការពណ៌នាសេចក្តីដែលមិនទាន់យល់ នៃវិន័យដែលឈ្មោះថា **បរិវារៈ** នោះ ។

## ពណ៌នាមហាវារៈ ១៦ ក្នុងឧភតោវិភង្គ

[១] សេចក្តីសង្ខេបនៃបុច្ឆា ដែលប្រព្រឹត្តទៅដោយន័យថា យន្តេន ភគវតា ជានតា បស្សតា អរហតា សម្មាសម្ពុទ្ធេន បឋមំ បារាជិកំ កត្ថ បញ្ញត្តំ : សួរថា បឋមបារាជិក ព្រះមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធ ព្រះអង្គជ្រាបច្បាស់ (នូវកាលនៃការបញ្ញត្តិសិក្ខាបទ) ឃើញច្បាស់នូវប្រយោជន៍ ១០ យ៉ាង នៃការបញ្ញត្តិសិក្ខាបទ) ទ្រង់បញ្ញត្តិក្នុងទីណា ក្នុងគម្ពីរបរិវារៈនោះ គប្បីជ្រាបដូចតទៅនេះ ៖

ព្រះមានព្រះភាគអង្គណា ដែលព្រះធម្មសេនាបតីប្រតិស្ឋាន ទុក

ហើយនូវអញ្ជលី ដោយកម្លាំងនៃសេចក្តីគោរព និងរាប់អានច្រើនក្នុងព្រះសទ្ធម្ម លើកឡើងហើយលើសិរសា ទូលសូមអង្វរហើយ ទើបទ្រង់បញ្ញត្តិព្រះវិន័យ អាស្រ័យអំណាចប្រយោជន៍ ១០ ប្រការ ដើម្បីការតាំងនៅយូរនៃព្រះសាសនា ។ ព្រះមានព្រះភាគព្រះអង្គនោះ ទ្រង់ដឹងកាលដែលត្រូវបញ្ញត្តិសិក្ខាបទនោះ ៗ ទ្រង់ឃើញអំណាចប្រយោជន៍ ១០ ប្រការនៃការបញ្ញត្តិសិក្ខាបទនោះ ៗ ម្យ៉ាងទៀត ទ្រង់ដឹងដោយញាណទាំងឡាយ មានបុព្វេនិវាសញ្ញាណជាដើម ទ្រង់ឃើញដោយទិព្វចក្ខុ ទ្រង់ដឹងដោយវិជ្ជា៣ ឬដោយអភិញ្ញា៦ ទ្រង់ឃើញដោយសមន្តចក្ខុ ដែលមិនមានវត្ថុណាមករារាំងក្នុងធម៌ទាំងពួង ទ្រង់ដឹងដោយបញ្ញា ដែលអាចដឹងធម៌ទាំងមូល ទ្រង់ឃើញសូម្បីនូវរូបទាំងឡាយ ដែលនៅខាងក្រៅជញ្ជាំងជាដើម ដែលកន្លងវិស័យចក្ខុនៃសត្វទាំងពួង ដោយមំសចក្ខុដ៏ថ្លាផូរផង់ក្រៃលែង ទ្រង់ដឹងដោយបញ្ញា គ្រឿងចាក់ធ្លុះ មានសមាធិជាបទដ្ឋាន ញ៉ាំងប្រយោជន៍ខ្លួនឱ្យសម្រេច ទ្រង់ឃើញដោយទេសនាបញ្ញាមានករុណាជាបទដ្ឋាន ញ៉ាំងប្រយោជន៍អ្នកដទៃឱ្យសម្រេច ទ្រង់ជាព្រះអរហន្ត ត្រាស់ដឹងដោយប្រពៃ ចំពោះព្រះអង្គ ឥតគ្រូអាចារ្យណាមកប្រដៅ ឱ្យត្រាស់ដឹងឡើយ ទ្រង់បញ្ញត្តិបឋមបារាជិកណា ទុកបឋមបារាជិកនោះ ទ្រង់បញ្ញត្តិក្នុងទីណា ? ទ្រង់ប្រារព្ធបុគ្គលណា ទើប

បញ្ញត្តិ ? ទ្រង់បញ្ញត្តិ ព្រោះរឿងអ្វី ? ក្នុងបឋមបារាជិកនោះ មានបញ្ញត្តិដែរឬ ទេ ? ។ល។ បឋមបារាជិកនោះ អ្នកណានាំមក ?

[២] តែពាក្យថា យន្តេន ភគវតា ជានតា បស្សតា អរហតា សម្មាសម្ពុទ្ធេន បឋមំ បារាជិកំ នេះ ត្រឹមតែជាពាក្យពន្យល់របស់បទដើម ដែលមកហើយក្នុងបុច្ឆាតែម្យ៉ាង ក្នុងវារៈពាក្យសួរ និង ពាក្យឆ្លើយប៉ុណ្ណោះ ។

ក៏ឯក្នុងវារៈពាក្យសួរ និងពាក្យឆ្លើយនេះ គប្បីសួរហើយ ឆ្លើយម្តងមួយបទ ៗ ទៀតនោះឯង ដោយន័យមានជាដើមយ៉ាងនេះថា សួរថា បឋមបារាជិក ទ្រង់បញ្ញត្តិក្នុងទីណា ? ឆ្លើយថា ទ្រង់បញ្ញត្តិនៅក្នុងក្រុងវេសាលី ទ្រង់ប្រារព្ធនឹងបុគ្គលណា ? ទ្រង់ប្រារព្ធសុទិន្នភិក្ខុជាកូននៃកលន្ទសេដ្ឋី ។

ពាក្យថា ឯកា បញ្ញត្តិ : មានតែបញ្ញត្តិ ១ មានសេចក្តីថា បញ្ញត្តិដែលថា ក៏ភិក្ខុណា សេពមេថុនធម្ម ភិក្ខុនោះ ត្រូវអាបត្តិបារាជិក រកសំវាសគ្មាន នេះជាបញ្ញត្តិមួយ ។

ពាក្យថា ទ្វេ អនុប្បញ្ញត្តិយោ : អនុប្បញ្ញត្តិ ២ មានសេចក្តីថា អនុប្បញ្ញត្តិ ២ នេះ ដែលព្រះមានព្រះភាគត្រាស់ ដោយអំណាចនៃរឿងស្វាញីថា អន្តមសោ តិរច្ឆានគតាយបិ : ដោយហោចទៅសូម្បី

តែនឹងសត្ថុតិរច្ឆានញី និងរឿងភិក្ខុវជ្ជីបុត្រថា សិក្ខំ អប្បច្ចក្ខាយ : ហើយមិនពោលលាសិក្ខា ។

បុច្ឆានេះថា បញ្ញត្តិ១ អនុបញ្ញត្តិ១ អនុបន្នបញ្ញត្តិ១ មានក្នុងបឋមបារាជិកនោះដែរឬទេ ។ ជាការវិសជ្ជនាហើយ ២ ផ្នែក ដោយពាក្យមានប្រមាណប៉ុណ្ណេះ, ក៏ដើម្បីវិសជ្ជនាផ្នែកទី៣ ទើបលោកពោលថា ក្នុងបឋមបារាជិកនោះ មិនមានអនុបន្នបញ្ញត្តិ ។ ពិតមែន ដែលឈ្មោះថា អនុបន្នបញ្ញត្តិនេះ បានដល់ វិន័យដែលទ្រង់បញ្ញត្តិក្នុងកាលទោសមិនទាន់កើតឡើង អនុបន្នបញ្ញត្តិនោះ មិនមានក្រៅអំពីដែលមកដោយអំណាចគរុធម៌ ៨ របស់ភិក្ខុនីទាំងឡាយនោះទេ ព្រោះដូច្នោះ លោកទើបពោលថា ក្នុងបឋមបារាជិកនោះ មិនមានអនុបន្នបញ្ញត្តិ ។

ពាក្យថា សព្វត្ថ បញ្ញត្តិ : ជាសព្វត្ថបញ្ញត្តិ នោះ បានដល់ បញ្ញត្តិក្នុងទីទាំងពួង ទាំងក្នុងមជ្ឈិមប្រទេស ទាំងក្នុងបច្ចន្តជនបទទាំងឡាយ ។

ពិតមែន សិក្ខាបទ ៤ នេះ គឺ ឧបសម្បទាដោយគណៈមានព្រះវិន័យធរជាគម្រប់ ៥, ស្បែកជើងតាំងពី ៤ ជាន់ឡើងទៅ, ការងូតទឹកជានិច្ច, កម្រាលស្បែក ទ្រង់បញ្ញត្តិតែក្នុងមជ្ឈិមប្រទេសប៉ុណ្ណោះ, ព្រោះសិក្ខាបទទាំងនោះ ត្រូវអាបត្តិ ក្នុងមជ្ឈិមប្រទេសនោះប៉ុណ្ណោះ ក្នុងបច្ចន្ត

ជនបទទាំងឡាយ មិនជាអាបត្តិទេ ។ សិក្ខាបទដ៏សេសទាំងអស់ ឈ្មោះថា សព្វត្ថបញ្ញត្តិ ។

ពាក្យថា សាធារណបញ្ញត្តិ : ជាសាធារណបញ្ញត្តិ នោះ បានដល់ ព្រះបញ្ញត្តិដែលទូទៅដល់ភិក្ខុ និងភិក្ខុនីទាំងឡាយ ។

ពិតមែន សិក្ខាបទដែលទ្រង់បញ្ញត្តិចំពោះភិក្ខុសុទ្ធ ឬ ភិក្ខុនីសុទ្ធ ជាសាធារណបញ្ញត្តិ ។ ចំណែកសិក្ខាបទដែលថា យា បន ភិក្ខុនី ឆន្ទសោ មេថុនំ ធម្មំ បដិសេវេយ្យ អន្តមសោ តិរច្ឆានគតេបិ ចារាជិកា ហោតិ អសំវាសា នេះ ព្រះមានព្រះភាគ ទ្រង់ប្រារព្ធភិក្ខុទាំងឡាយ បញ្ញត្តិហើយ សូម្បីដល់ភិក្ខុនីទាំងឡាយ ក្នុងកាលរឿងកើតឡើងហើយ ពិតមែន ត្រឹមតែរឿង ប្រៀបធៀបប៉ុណ្ណោះរបស់ភិក្ខុនីទាំងឡាយនោះ មិនមាន ។ តែសិក្ខាបទមាន ដោយហេតុនោះ ទើបលោកពោលថា បឋមបារាជិកជាសាធារណបញ្ញត្តិ ។

សូម្បីក្នុងឧភតោបញ្ញត្តិ ក៏មានន័យដូចគ្នា ។ ពិតមែន ក្នុងឧភតោបញ្ញត្តិនេះ ផ្សេងគ្នាត្រឹមតែព្យញ្ជនៈប៉ុណ្ណោះ ។ បឋមបារាជិក ចាត់ជាសាធារណបញ្ញត្តិ ព្រោះជាសិក្ខាបទដែលទូទៅ ដល់ភិក្ខុទាំងឡាយ និងដល់ភិក្ខុនីទាំងឡាយ ចាត់ជាឧភតោបញ្ញត្តិ ព្រោះជាសិក្ខាបទដែលទ្រង់

បញ្ញត្តិដល់ភិក្ខុ និងភិក្ខុនីទាំង ២ ផ្នែកដូច្នេះឯង ។ ចំណែកសេចក្ដីមិនផ្សេងគ្នាឡើយ ។

បទថា និធានោគធំ : ដាក់ចុះក្នុងនិទាន មានសេចក្ដីថា ឈ្មោះថា ដាក់ ចុះក្នុងនិទាន គឺ រាប់បញ្ចូលក្នុងនិទាន ព្រោះអាបត្តិទាំងពួងរាប់បញ្ចូលក្នុងនិទានុទ្ទេសនេះថា យស្ស សិយា អាបត្តិ, សោ អាវិករេយ្យ ។

ពីរបទថា ធុតិយេន ឧទ្ទេសេន : ត្រង់ឧទ្ទេសទី ២ មានសេចក្ដីថា បឋមបារាជិកនេះដាក់ចុះក្នុងនិទាន គឺ សូម្បីរាប់បញ្ចូលក្នុងនិទាន ក៏ពិតមែន តែរមែងមិនមកកាន់ឧទ្ទេស ដោយឧទ្ទេសទី ២ ប៉ុណ្ណោះ ដូច្នេះថា តត្រិមេ ចត្តារោ បារាជិកា ធម្មា ជាដើម ។

ពីរបទថា ចតុន្នំ វិបត្តីនំ : បណ្ដាវិបត្តិ ៤ យ៉ាង បានដល់ បណ្ដាវិបត្តិទាំងឡាយ មានសីលវិបត្តិជាដើម ។

ពិតមែន អាបត្តិ ២ កងខាងដើម ឈ្មោះថា សីលវិបត្តិ ។ ៥ កងដ៏សេស ឈ្មោះថា អាចារវិបត្តិ ។ មិច្ឆាទិដ្ឋិ និងអន្តគាហិកទិដ្ឋិ ឈ្មោះថា ទិដ្ឋិវិបត្តិ សិក្ខាបទ ៦ ដែលទ្រង់បញ្ញត្តិ ព្រោះអាជីវៈជាហេតុ ឈ្មោះថា អាជីវវិបត្តិ ។ បណ្ដាវិបត្តិ ទាំង ៤ នេះ បារាជិកនេះ ចាត់ជា

សីលវិបត្តិ ដោយប្រការដូច្នេះ ។

ពាក្យថា ឯកេន សមុដ្ឋានេន : ដោយសមុដ្ឋាន ១ មានសេចក្តីថា បឋមបារាជិកនេះកើតឡើងដោយសមុដ្ឋានតែមួយ មានអង្គ ២ (គឺ កាយ និងចិត្ត) ។

ពិតមែន ក្នុងអង្គ ២ នេះ ចិត្តជាអង្គ, តែភិក្ខុរមែងត្រូវអាបត្តិដោយកាយ ។ ដោយហេតុនោះ លោកទើបពោលថា រមែងកើតឡើងអំពីមកកាយនិងចិត្ត ។

ពាក្យថា ទ្វីហិ សមថេហិ : ដោយសមថៈ ២ យ៉ាង មានសេចក្តីថា ភិក្ខុដែលត្រូវសួរចំពោះមុខគ្នាថា “លោកជាអ្នកត្រូវឬ ?” ទើបប្តេជ្ញាថា “មែនខ្ញុំជាអ្នកត្រូវហើយ” ។ ការប្រេះឆា ការឈ្លោះ និងទាស់ទែង ជាការស្ងប់ក្នុងវេលានោះឯង, និងឧបោសថ ឬបវារណា ក៏ជាកម្មដែលសង្ឃអាចកម្ចាត់បុគ្គលនោះចេញ ហើយធ្វើបាន ; ព្រោះហេតុនោះ អធិករណ៍នោះ ទើបរម្ងាប់ដោយសមថៈ ២ គឺ សម្មុខាវិន័យ ១ បដិញ្ញាតករណៈ ១ ។ ឧបទ្វៈយ៉ាងណាមួយ រមែងមិនមានព្រោះបច្ច័យគឺ ការកម្ចាត់បុគ្គលនោះ ។

ចំណែកពាក្យណា ដែលលោកពោលទុកក្នុងបញ្ញត្តិវគ្គ បន្ទាប់ទៅ

ថា ន កតមេន សមថេន សម្មតិ : មិនបានចាត់ជាអធិករណ៍ណាមួយឡើយ ពាក្យនោះ លោកពោលសំដៅយកសេចក្តីនេះថា អនាបត្តិដែលភិក្ខុមិនអាចឱ្យធ្លាក់ចុះកាន់សមថៈហើយធ្វើបាន ។

ពាក្យថា បញ្ញត្តិ វិនយោ : បញ្ញត្តិជាវិន័យ មានសេចក្តីថា បញ្ញត្តិមានមាតិកាដែលត្រាស់ទុកដោយន័យមានពាក្យថា យោ បន ភិក្ខុ ជាដើមជាវិន័យ ។

បទភាជនៈ ហៅថា វិភត្តិ ពាក្យថា វិភត្តិ នោះ ជាឈ្មោះនៃវិភង្គ ។

ការប្រព្រឹត្តកន្លង ឈ្មោះថា អសំវរៈ ។ ការមិនប្រព្រឹត្តកន្លង ឈ្មោះថា សំវរៈ ។

ពាក្យថា យេសំ វត្តតិ : ប្រព្រឹត្តទៅដល់ជនពួកណា មានសេចក្តីថា វិន័យបិដកនិងអដ្ឋកថារបស់ព្រះមហាថេរៈពួកណា ជាអ្នកស្ទាត់ជំនាញទាំងអស់ ។

ពាក្យថា តេ ធារេន្តិ : ជនពួកនោះ រមែងទ្រទ្រង់ទុក មានសេចក្តីថា ព្រះមហាថេរៈទាំងនោះ បានទ្រទ្រង់ទុកនូវបឋមបារាជិកនោះ ទាំងបាលី ទាំងអដ្ឋកថា ។

ពិតមែន សេចក្តីនៃបឋមបារាជិកនោះ បុគ្គលដែលមិនដឹងវិន័យបិដកទាំងអស់ មិនអាចជ្រាបបាន ។

ពាក្យថា កេនាភដំ : **អ្នកណានាំមក** មានសេចក្តីថា បឋមបារាជិកនេះ អ្នកណា នាំមកដោយអំណាចបាលី និងដោយអំណាចអដ្ឋកថា រហូតមកដល់សព្វថ្ងៃនេះ ?

ពាក្យថា បរម្បរាភដំ : **ព្រះថេរៈនាំត ៗគ្នាមក** មានសេចក្តីថា ដែលព្រះមហាថេរៈទាំងឡាយនាំមកដោយបន្តជាលំដាប់គ្នា ។

[៣] បឋមបារាជិកនេះ ដែលព្រះមហាថេរៈទាំងឡាយ នាំមកដោយបន្តជាលំដាប់គ្នាយ៉ាងណា, ឥឡូវនេះ ដើម្បីសម្តែងកិរិយាដែលបន្តលំដាប់គ្នាយ៉ាងនោះ ព្រះមហាថេរៈទាំងឡាយ ពីបូរាណ ទើបតាំងគាថាទុកដោយន័យមានពាក្យថា ឧបាលិ ទាសកោ ចេវ : **ព្រះថេរៈ ឈ្មោះឧបាលិ ១ ទាសកៈ ១ ជាដើម** ។ ក្នុងគាថាទាំងនោះ ពាក្យណាដែលខ្ញុំគប្បីពោល, ពាក្យនោះ ខ្ញុំបានពោលហើយ ក្នុងនិទានវណ្ណនាន៎ុះឯង ។

សូម្បីក្នុងបុច្ឆាវិសជ្ជនាទាំងឡាយ មានទុតិយបារាជិកជាដើម គប្បីជ្រាបវិនិច្ឆ័យដោយន័យនេះ ដូច្នេះឯង ។

បញ្ញត្តិវារវណ្ណនា ក្នុងមហាវិភង្គ ចប់

## វារៈផ្សេងៗ

[២៤៤] បន្ទាប់អំពីនេះទៅ វារៈ ៧ ទាំងនេះ គឺ កតាបត្តិវារៈ មានប្រភេទជាដើមថា "ភិក្ខុសេពមេថុនធម្មត្រូវអាបត្តិប៉ុន្មាន" ។

[៥០៥] វិបត្តិវារៈ មានប្រភេទជាដើមថា "ពួកអាបត្តិ ព្រោះបច្ច័យ គឺការសេពមេថុនធម្ម បណ្តាវិបត្តិទាំង ៤ រាប់បញ្ចូលក្នុងវិបត្តិប៉ុន្មាន" ។

[៥០៦] សង្គហវារៈ មានប្រភេទជាដើមថា "ពួកអាបត្តិ ព្រោះបច្ច័យ គឺ ការសេពមេថុនធម្ម បណ្តាកងនៃអាបត្តិទាំង ៧ សង្គ្រោះដោយកងនៃអាបត្តិប៉ុន្មាន" ។

[៥០៧] សមុដ្ឋានវារៈ មានប្រភេទជាដើមថា "ពួកអាបត្តិ ព្រោះបច្ច័យ គឺ ការសេព មេថុនធម្ម បណ្តាសមុដ្ឋាននៃអាបត្តិទាំង ៦ តាំងឡើងដោយសមុដ្ឋានប៉ុន្មាន" ។

[៥០៨] អធិករណវារៈ មានប្រភេទជាដើមថា "ពួកអាបត្តិព្រោះបច្ច័យ គឺការសេពមេថុនធម្ម បណ្តាអធិករណ៍ទាំង ៤ ជាអធិករណ៍អ្វី" ។

[៥០៩] សមថវារៈ មានប្រភេទជាដើមថា "ពួកអាបត្តិ ព្រោះបច្ច័យ គឺ ការសេពមេថុនធម្ម បណ្តាសមថៈទាំង ៧ រម្ងាប់ ដោយសម

ថៈប៉ុន្មាន” ។

[៥១០] និងសមុច្ចយវារៈ ដែលជាលំដាប់នៃសមថវារៈនោះ មានសេចក្ដីងាយយល់ទាំងអស់ ។

បន្ទាប់ពីនោះទៅ ៨ វារៈ លោកពោលទុកយ៉ាងនេះ គឺ បញ្ញត្តិវារៈ ជាប់ដោយបច្ច័យ ១ វារៈ ទៀត ដោយន័យជាដើមថា ព្រោះបច្ច័យ គឺ ការសេពមេថុនធម្ម, បារាជិកទ្រង់បញ្ញត្តិទីណា ? ដូច្នេះ, ៧ វារៈ មានកតាបត្តិវារៈជាដើម ដូចវារៈមុន ៗ ជាប់ដោយបច្ច័យនោះដូចគ្នា ។ សូម្បីវារៈទាំង ៨ នោះ ក៏មាន សេចក្ដីងាយយល់ទាំងអស់ ។

វារៈ ១៦ ក្នុងមហាវិភង្គ គឺ ដែលមានមកក្នុងកាលមុន ៨ ទាំងនេះ, ៨ ទៀត ខ្ញុំសម្ដែងហើយដោយប្រការដូច្នេះ ។

[៥១១] បន្ទាប់អំពីវារៈនោះទៅ ១៦ វារៈ មកហើយ សូម្បីក្នុងភិក្ខុនីវិភង្គ ដោយន័យនោះដូចគ្នា ព្រោះដូច្នោះ គប្បីជ្រាបវារៈ ៣២ ក្នុងឧភតោវិភង្គទាំងនេះ ដោយន័យបាលីទុំះឯង ដោយប្រការដូច្នេះ ។

ពិតមែន ក្នុង៣២ វារៈនេះ ពាក្យណា ៗ ដែលរាប់ថា មិនបានវិនិច្ឆ័យហើយក្នុងកាលមុន រមែងមិនមាន ។

**ពណ៌នាមហាវារៈ ១៦ ក្នុងឧភតោវិភង្គ ចប់**

# ពណ៌នាសមុដ្ឋានសីស

[៨២៦] ក៏ឯវិនិច្ឆ័យក្នុងសមុដ្ឋានកថា ដែលជាលំដាប់នៃសោឡសមហាវារៈនោះ គប្បីជ្រាបដូច្នេះ ៖

គាថាថា អនត្តា ឥតិ និច្ឆយា : ក៏លោកវិនិច្ឆ័យថា ជាអនត្តាដែរ មានសេចក្តីថា និព្វាន និងបញ្ញត្តិ លោកវិនិច្ឆ័យថា ជាអនត្តា ។ (កាលព្រះចន្ទ គឺ ព្រះពុទ្ធនៅ មិនទាន់កើតឡើង កាលព្រះអាទិត្យ គឺព្រះពុទ្ធមិនទាន់កើតឡើងមក ) ។

បទថា សភាគធម្មានំ : របស់សភាគធម៌(គឺសង្ខត)ទាំងឡាយ បានដល់ សង្ខតធម៌ដែលមានចំណែកស្មើគ្នា ដោយអាការ មានការមិនទៀងជាដើម ។

ពាក្យថា នាមមត្តំ ន ញាយតិ : នាមបញ្ញត្តិ ក៏មិនមានអ្នកណាអាចដឹងបាន សេចក្តីថា សូម្បីត្រឹមតែឈ្មោះ (នៃសង្ខតធម៌ទាំងនោះ) រមែងមិនប្រាកដ ។

បទថា ទុក្ខហានី : ផ្ចាញ់នូវកងទុក្ខ បានដល់ កំចាត់សេចក្តីទុក្ខចេញ ។

បាទគាថាថា ខន្ធកា យា ច មាតិកា : ខន្ធកវិន័យ និងមាតិកា មានសេចក្តីថា ខន្ធកៈទាំងឡាយនិងមាតិកាពួកណា ។ មួយទៀតបាលីក៏ដូចគ្នានេះ ។

បាទគាថាថា សមុដ្ឋានំ និយតោ កតំ : ជាសមុដ្ឋានដែលអ្នកប្រាជ្ញាធ្វើឱ្យទៀងទាត់ មានសេចក្ដីថា សមុដ្ឋានដែលលោកធ្វើឱ្យជារបស់ពិតប្រាកដ គឺចាត់ទុកជាគោលប្រាកដ ឈ្មោះថា និយតសមុដ្ឋាន ។

ការសង្គ្រោះ ៣ សិក្ខាបទ គឺ ភូតារោចនសិក្ខាបទ ចោរីវុដ្ឋាបនសិក្ខាបទ និងអននុញ្ញាតសិក្ខាបទ ដោយពាក្យថា សមុដ្ឋានំ និយតោ កតំ នោះ ដែលបណ្ឌិតគប្បីពិចារណា ។

ពិតមែន ៣ សិក្ខាបទនេះប៉ុណ្ណោះ ជានិយតសមុដ្ឋាន គឺ ជាសមុដ្ឋានដែលមិនលាយឡំជាមួយនឹងសមុដ្ឋានពួកដទៃ ។

បាទគាថាថា សមេ្ភទនិទានញ្ចញ្ញំ : សមេ្ភទផង និទានផង សមុដ្ឋានដទៃផង មានសេចក្ដីថា លាយប្រឡំគ្នានឹងហេតុសូម្បីដទៃ, បណ្ឌិតគប្បីពិចារណា ការកាន់យកសេចក្ដីលាយប្រឡំគ្នានៃសមុដ្ឋានក្នុងបណ្ដាពាក្យទាំង ២ នោះ ដោយពាក្យថា សមេ្ភទ ។ ពិតមែន វៀរសិក្ខាបទ ៣ នោះចេញសិក្ខាបទដ៏សេស ចាត់ជាសមិ្ភន្នសមុដ្ឋាន ។ បណ្ឌិតគប្បីត្រួតមើលនិទាន ពោលគឺ ប្រទេសដែលបញ្ញត្តិនៃសិក្ខាបទទាំងឡាយដោយពាក្យថា និទាន ។

បាទគាថាថា សុត្តេ ទិស្សន្តិ ឧបរិ : មានប្រាកដមកក្នុងសូត្រដូចសម្ដែងមកហើយខាងដើម មានសេចក្ដីថា ៣ ផ្នែកនេះ គឺសមុដ្ឋាន

និយម សម្មេទ និទាន នៃសិក្ខាបទទាំងឡាយ រមែងឃើញបាន គឺ រមែងប្រាកដក្នុងសូត្របុំណោះ ។

បណ្តាសមុដ្ឋាននិយម សម្មេទ និងនិទាននោះ សមុដ្ឋាននិយម និងសម្មេទ ក្នុងបរិមន័យមុន រមែងប្រាកដក្នុងពាក្យថា រមែងកើតឡើង ដោយសមុដ្ឋានតែមួយ គឺ កាយនិងចិត្តជាដើម ។ ចំណែកក្រៅអំពីនេះ ឈ្មោះនិទាន រមែងប្រាកដក្នុងខាងមុខយ៉ាងនេះថា ព្រះមានព្រះភាគទ្រង់បញ្ញត្តិហើយ ក្នុងក្រុងវេសាលី ក្នុងក្រុងរាជគ្រឹះក្នុងក្រុងសាវត្ថី ក្នុងក្រុងអាឡវី ក្នុងក្រុងកោសម្ពី ក្នុងដែនសក្កៈទាំងឡាយ និងក្នុងដែនភគ្គៈទាំងឡាយ ។ បណ្ឌិតគប្បីជ្រាបថា ពាក្យនេះនឹងប្រាកដក្នុងសូត្រដែលមកខាងមុខ ។

សេចក្តីនៃគាថាថា វិភង្គេ ទ្វីសុ : ក្នុងវិភង្គទាំងពីរ ជាដើម គប្បីជ្រាបដូចតទៅនេះ ៖

ក្នុងថ្ងៃឧបោសថ ភិក្ខុ និង ភិក្ខុនីទាំងឡាយ រមែងសូធ្យសិក្ខាបទណា ដែលព្រះមានព្រះភាគទ្រង់បញ្ញត្តិទុកក្នុងវិភង្គទាំង ២, ខ្ញុំនឹងពោលសមុដ្ឋានតាមសមគួរដល់សិក្ខាបទនោះ ; លោកទាំងឡាយ ចូរស្តាប់ពាក្យនោះរបស់ខ្ញុំ ។

បទថា សព្វវិត្ថានុភាសញ្ច បានដល់ សព្វវិត្ថសិក្ខាបទ និងសមនុភាសនសិក្ខាបទ ។

ពីរបទថា អតិរេកញ្ច ចីវរំ បានដល់ អតិរេកចីវរសិក្ខាបទ អធិប្បាយថា កឋិនសិក្ខាបទ ។

ពីរបទថា លោមានិ បធសោធម្មោ បានដល់ ឯឡកលោមសិក្ខាបទទាំងឡាយ និងបទសោធម្មសិក្ខាបទ ។

បទថា ភូតសំវិធានេន ច បានដល់ ភូតារោចនសិក្ខាបទ និងសំវិធានសិក្ខាបទ ។

បទថា ថេយ្យទេសនាចោរិញ្ច បានដល់ ថេយ្យសត្ថសិក្ខាបទ នធត្ថបាណិទេសនសិក្ខាបទ និងចោរីវុដ្ឋាបនសិក្ខាបទ ។

ពីរបទថា អននុញ្ញាតាយ តេរស មានសេចក្តីថា សមុដ្ឋានទាំងនេះ រួមនឹងអននុញ្ញាតសិក្ខាបទ ទើបជាសមុដ្ឋាន ១៣ ។

បាទគាថាថា សទិសា ឥធ ទិស្សរេ មានសេចក្តីថា ក្នុងឧភតោវិភង្គនេះ សមុដ្ឋានទាំងឡាយដូចគ្នា សូម្បីពួកដទៃ រមែងប្រាកដ ក្នុងសមុដ្ឋានមួយ ៗ ក្នុងបណ្តាសមុដ្ឋាន ១៣ ទាំងនេះ ។

## បឋមបារាជិកសមុដ្ឋាន

[៤២៧] ឥឡូវនេះ លោកពោលពាក្យថា មេថុនំ សុក្កសំសគ្គោ ជាដើម ដើម្បីសម្តែងសមុដ្ឋានទាំងនោះ ។

បណ្តាបទទាំងនោះ បទថា មេថុនំ នេះ គប្បីជ្រាបថា ៖ សមុដ្ឋានតែមួយ ឈ្មោះថា បឋមបារាជិក ។ សមុដ្ឋានដ៏សេសដូចនឹងបឋមបារាជិកសមុដ្ឋាននោះ ។

បណ្តាបទទាំងនោះ បទថា សុក្កសំសគ្គោ បានដល់ សុក្កវិស្សដ្ឋិសមុដ្ឋាន និងកាយសំសគ្គសមុដ្ឋាន (សង្ឃាទិសេសសិក្ខាបទទី១, ទី២) ។

បាទគាថាថា អនិយតា បឋមិកា បានដល់ អនិយតសិក្ខាបទទី១ ។

បាទគាថាថា បុព្វូបបរិបាចិតា បានដល់ អនុប្បខជ្ជសិក្ខាបទ, ដែលត្រាស់ថា "ជានំ បុព្វុបគតំ ភិក្ខុំ : ដឹងហើយចូលទៅជ្រៀតបៀតនូវភិក្ខុដែលចូលទៅមុន" ១ និងបរិបាចនសិក្ខាបទ ១ (ភូតគាមវគ្គ សិក្ខាបទទី៦ ឱវាទវគ្គ សិក្ខាបទទី៩) ។

បាទគាថាថា រហោ ភិក្ខុនិយា សហ បានដល់ រហោនិសជ្ជសិក្ខាបទ, ដែលត្រាស់ថា "ភិក្ខុនិយា សទ្ធឹ រហោ និសជ្ជំ : សម្រេចការអង្គុយក្នុងទីស្ងាត់ ជាមួយនឹងភិក្ខុនី" (ឱវាទវគ្គសិក្ខាបទទី១០) ។

បាទគាថាថា សភោជនេ រហោ ទ្វេ ច បានដល់ សភោជន

សិក្ខាបទ ដែលត្រាស់ថា "សភោជនេ កុលេ អនុប្បខជ្ជ ចូលទៅសម្រេចការអង្គុយនៅ ក្នុងត្រកូលដែលមានជនតែពីរនាក់" ១ និងរហោនិសជ្ជសិក្ខាបទទាំង ២ (អចេលកវគ្គសិក្ខាបទទី៣ ទី៤ ទី៥) ។

បាទគាថាថា អង្គុលិ ឧទកេ ហសំ បានដល់ អង្គុលីបតោទកសិក្ខាបទ និងឧទកេហសធម្មសិក្ខាបទ (សុរាបានវគ្គសិក្ខាបទទី២ ទី៣) ។

បាទគាថាថា បហារេ ឧគ្គិរេ ចេវ បានដល់ បហារទានសិក្ខាបទ និងតលសត្តិកឧគ្គិរណសិក្ខាបទ (សហធម្មិកវគ្គសិក្ខាបទទី៤ ទី៥) ។

បាទគាថាថា តេ បញ្ញាសា ច សេក្ខិយា បានដល់ សេក្ខិយសិក្ខាបទ ៥៣ មានបរិមណ្ឌលនិវាសនសិក្ខាបទជាដើម ដែលលោកពោលទុកក្នុងទីបំផុតនៃខុទ្ទកវណ្ណនាទាំងនេះ គឺ ៖

បរិមណ្ឌលកសិក្ខាបទ ២, សុប្បដិច្ឆន្នកសិក្ខាបទ ២, សុសំវុតសិក្ខាបទ ២, ឱក្ខិត្តចក្ខុកសិក្ខាបទ ២, ឧក្ខិត្តកាយកសិក្ខាបទ ២, កាយប្បចាលិកសិក្ខាបទ ២, ពាហុប្បចាលិកសិក្ខាបទ ២, សីសប្បចាលិកសិក្ខាបទ ២, ខម្ភកសិក្ខាបទ ២, ឱគុណ្ឋិតសិក្ខាបទ ២, ឧក្កុដិកសិក្ខាបទ ១, បល្លត្ថិកសិក្ខាបទ ១, សក្កច្ចបដិគ្គហណសិក្ខាបទ ១, បត្តសញ្ញិតាសិក្ខាបទ ១, សមសូបកសិក្ខាបទ ១, សមតិត្ថិ

កសិក្ខាបទ ១, សក្កច្ចភុញ្ជិស្សសិក្ខាបទ ១, បត្តសញ្ញីភុញ្ជិស្សសិក្ខាបទ ១, សបទានភុញ្ជិស្សសិក្ខាបទ ១, សមសូបកភុញ្ជិស្សសិក្ខាបទ ១, ថូបិកតសិក្ខាបទ ១, ព្យញ្ជនសិក្ខាបទ ១, ឧជ្ឈានសញ្ញិសិក្ខាបទ ១, នាតិមហន្តកវឡសិក្ខាបទ ១, មណ្ឌលអាលោបសិក្ខាបទ ១, អនាហតសិក្ខាបទ ១, សព្វហត្ថសិក្ខាបទ ១, បិណ្ឌុក្ខេបកសិក្ខាបទ ១, កវឡវច្ឆេទកសិក្ខាបទ ១, អវគណ្ឌកសិក្ខាបទ ១, ហត្ថនិទ្ធូនកសិក្ខាបទ ១, សិត្ថាវការកសិក្ខាបទ ១, ជិវ្ហានិច្ឆារកសិក្ខាបទ ១, ចបុចបុការកសិក្ខាបទ ១, សុរុសុរុការកសិក្ខាបទ ១, ហត្ថនិល្លេហសិក្ខាបទ ១, បត្តនិល្លេហសិក្ខាបទ ១, ឱដ្ឋនិល្លេហសិក្ខាបទ ១, សាមិសសិក្ខាបទ ១, សសិត្ថកសិក្ខាបទ ១, និងបកិណ្ណកសិក្ខាបទទាំង ៣ នេះ គឺ នឋិតករណសិក្ខាបទ ១ នហរិតកណសិក្ខាបទ ១ នឧទកករណសិក្ខាបទ១ ។

បាទគាថាថា អជក្ខគាមាវស្សុតា បានដល់ ឧព្ភជាណុមណ្ឌលិកា-សិក្ខាបទ ១ គាមន្តរគមនសិក្ខាបទ ១ និងបឋមភោជនប្បដិគ្គហណសិក្ខាបទ, ដែលត្រាស់ថា "ភិក្ខុនី អវស្សុតា អវស្សុតស្ស ហត្ថតោ ខាទនីយំ វា ភោជនីយំ វា បដិគ្គហេត្វា : ភិក្ខុនីមានតម្រេកទទួលយកខាទនីយក្តី ភោជនីយក្តី អំពីដៃបុរសដែលមានតម្រេកដែរ" ១ (បារាជិកទី១ សង្ឃាទិសេសទី៣ ទី៥ នៃភិក្ខុនី) ។

បាទគាថាថា តលមដ្ឋញ្ច សុទ្ធិកា បានដល់ តលឃាដក

សិក្ខាបទ ១ ជតុមដ្ឋកសិក្ខាបទ ១ និងឧទកសុទ្ធិកាសិក្ខាបទ ១ (លសុណវគ្គសិក្ខាបទទី៣ ទី៤ ទី៥) សាទិយនសិក្ខាបទ[1] ១ ។

បាទគាថាថា វស្សំ វុត្ថា ច ឱវាទំ បានដល់ចារិកនបក្កមនសិក្ខាបទ, ដែលត្រាស់ថា "វស្សំ វុត្ថា ឆប្បញ្ច យោជនានិ : នៅចាំវស្សារួចហើយ មិនចេញទៅ ៥-៦ យោជន៍" ១ និងឱវាទសិក្ខាបទ, ដែលត្រាស់ថា "ឱវាទាយ វា សំវាសាយ វា ន គច្ឆេយ្យ : មិនទៅដើម្បីឱវាទក្តី ដើម្បីនៅរួបរួមគ្នាក្តី" ១ (តុវដ្តវគ្គសិក្ខាបទទី១០ អារាមវគ្គសិក្ខាបទទី៨) ។

បាទគាថាថា ឆានុពន្ធេ បវត្តិនី មានសេចក្តីថា សិក្ខាបទទាំងនេះ មាន ៧៦ រួមទាំងនានុពន្ធសិក្ខាបទ ដែលត្រាស់ថា "វុដ្ឋាបិតំ បវត្តិនី ទ្វេ វស្សានិ នានុពន្ធេយ្យ : មិនតាមបម្រើភិក្ខុនីជាបវត្តិនី ដែលបំបួសខ្លួនអស់ពីរវស្សា ភិក្ខុនីនោះ" (គព្ភិនីវគ្គសិក្ខាបទទី៩) ។

ពីរបទថា ឥមេ សិក្ខា បានដល់ សិក្ខាបទទាំងឡាយ ៧៦ នេះ ។ សព្ទថា ឥមេ លោកធ្វើឱ្យខុសលិង្គ ។

បាទគាថាថា កាយមានសិកា កតា សេចក្តីថា សិក្ខាបទទាំងនេះ លោកចាត់ជាសិក្ខាបទមានកាយចិត្តជាសមុដ្ឋាន ។

---

១. ក្នុងបិដកមិនមាន មិនដឹងនៅក្នុងវគ្គណាទេ ។

# ទុតិយបារាជិកសមុដ្ឋាន

[៨២៨] បទថា អទិន្នំ នេះ គប្បីជ្រាបថា ៖

ពាក្យថា អទិន្នាទាន ឬពាក្យថា ទុតិយបារាជិក ជាសមុដ្ឋានតែមួយ ។ បទដ៏សេស ដូចនឹងអទិន្នាទាននោះ ។

បណ្ដាបទទាំងនោះ បទថា វិគ្គហុត្តរិ បានដល់ មនុស្សវិគ្គហសិក្ខាបទ ១ និងឧត្តរិមនុស្សធម្មសិក្ខាបទ ១ (បារាជិកសិក្ខាបទទី ៣ ទី៤) ។

ពីរបទថា ទុដ្ឋុល្លា អត្តកាមិនំ បានដល់ ទុដ្ឋុល្លវាចសិក្ខាបទ ១ និងអត្តកាមបារិចរិយសិក្ខាបទ ១ (សង្ឃាទិសេសសិក្ខាបទទី៣ ទី៤) ។

ពីរបទថា អមូលា អញ្ញភាគិយា បានដល់ ទុដ្ឋទោសសិក្ខាបទទាំង ២ (សង្ឃាទិសេសសិក្ខាបទទី៨ ទី៩) ។

ពីរបទថា អនិយតា ទុតិយិកា បានដល់ អនិយតសិក្ខាបទទី ២ ។

ពីរបទថា អច្ឆិន្ទេ បរិណាមនេ បានដល់ ចីវរអច្ឆិន្ទនសិក្ខាបទដែលត្រាស់ថា "សាមំ ចីវរំ ទត្វា អច្ឆិន្ទេយ្យ វា អច្ឆិន្ទាបេយ្យ : ឱ្យចីវរដល់ភិក្ខុ (ដទៃ) ដោយខ្លួនឯងហើយខឹងអន់ចិត្តដណ្ដើមយក (ចីវរ)

មកវិញ” ១ និងបរិណតសិក្ខាបទ, ដែលត្រាស់ថា “សង្ឃិកំ លាភំ បរិណតំ អត្តនោ បរិណាមេយ្យ : បង្អោនទូវលាភរបស់សង្ឃ មកដើម្បីខ្លួនវិញ” ១ (បត្តវគ្គសិក្ខាបទទី៥ ទី១០) ។

បាទគាថាថា មុសាឱមសបេសុណា បានដល់ មុសាវាទសិក្ខាបទ ១ ឱមសវាទសិក្ខាបទ ១ ភិក្ខុបេសុញ្ញសិក្ខាបទ ១ (មុសាវាទវគ្គសិក្ខាបទទី១_ទី៣) ។

ពីរបទថា ទុដ្ឋុល្លា បថវីខណេ បានដល់ ទុដ្ឋុល្លារោចនសិក្ខាបទ ១ បថវីខណនសិក្ខាបទ ១ (មុសាវាទវគ្គសិក្ខាបទទី៩ ទី១០) ។

បីបទថា ភូតំ អញ្ញាយ ឧជ្ឈាបេ បានដល់ ភូតគាមសិក្ខាបទ ១ អញ្ញវាទកសិក្ខាបទ ១ និងឧជ្ឈាបនកសិក្ខាបទ ១ (ភូតគាមវគ្គសិក្ខាបទទី១_៣) ។

ពីរបទថា និកឌ្ឍនំ សិញ្ចនញ្ច បានដល់ និកឌ្ឍនសិក្ខាបទ ១ សិញ្ចនសិក្ខាបទ ១ (ភូតគាមវគ្គសិក្ខាបទទី៧ ទី១០) ។

ពីរបទថា អាមិសហេតុ ភុត្តាវី បានដល់ អាមិសហេតុសិក្ខាបទ, ដែលត្រាស់ថា “អាមិសហេតុ ភិក្ខុនិយោ ឱវទន្តិ : ប្រដៅភិក្ខុនីទាំងឡាយ ព្រោះហេតុតែអាមិស” ១, ទុតិយបវារណាសិក្ខាបទ, ដែលត្រាស់ថា “ភុត្តាវី អនតិរិត្តេន ខាទនីយាទិនា : បន្ទំភិក្ខុដែលឆាន់

ហើយហាមភត្តហើយដោយខាទនីយជាដើម ដែលជាអនតិរិត្តភោជន” ១ (ឱវាទវគ្គសិក្ខាបទទី៤ ភោជនវគ្គ សិក្ខាបទទី៦) ។

បីបទថា ឯហិ អនាទរិ ភីសា បានដល់ ឧយ្យោជនសិក្ខាបទ, ដែលត្រាស់ថា “ឯហាវុសោ គាមំ វា : ម្នាលអាវុសោ លោកចូរមក យើងទាំងឡាយនឹងទៅកាន់ស្រុក” ជាដើម ១, អនាទរិយសិក្ខាបទ ១, ភិក្ខុភីសាបនកសិក្ខាបទ ១, (អចេលកវគ្គសិក្ខាបទទី២ សុរាបានវគ្គ សិក្ខាបទទី៤ ទី៥) ។

ពីរបទថា អបនិធេ ច ជីវិតំ បានដល់ ចីវរាបនិធានសិក្ខាបទ ដែលពោលអំពីការលាក់ទុកនូវបាត្រជាដើម ១, សញ្ចិច្ចបាណសិក្ខាបទ, ដែលត្រាស់ថា “សញ្ចិច្ច បាណំ ជីវិតា : ក្លែងផ្ដាច់បង់សត្វចាកជីវិត” ១ (សុរាបានវគ្គ សិក្ខាបទទី១០ សប្បាណវគ្គសិក្ខាបទទី១) ។

បីបទថា ជានំ សប្បាណកំ កម្មំ បានដល់ សប្បាណកឧទកសិក្ខាបទ១, ឧក្កោដនសិក្ខាបទ១ (សប្បាណវគ្គសិក្ខាបទទី២ ទី៣) ។

បទថា ឩនសំវាសនាសនា បានដល់ ឩនវីសតិវស្សសិក្ខាបទ ១, ឧក្ខិត្តសម្ភោគសិក្ខាបទ, ដែលត្រាស់ថា “ឧក្ខិត្តកេន សទ្ធឹ សម្ភុញ្ជ សំវាសំ : បរិភោគរួមនៅរួមជាមួយនឹងភិក្ខុដែលសង្ឃលើកវត្ត”

១, កណ្ឌកសិក្ខាបទ ១ (សប្បាណវគ្គសិក្ខាបទទី៥ ទី៩ ទី១០) ។

បទថា សហធម្មិកាវិលេខា បានដល់ សហធម្មិកសិក្ខាបទ ១, វិលេខនសិក្ខាបទ, ដែលមានជាដើមថា "វិលេខាយ សំវត្តន្តីតិ : ប្រព្រឹត្តទៅដើម្បីរសេមរសាមចិត្ត" ១ (សហធម្មិកវគ្គសិក្ខាបទទី១ ទី២) ។

ពីរបទថា មោហោ អមូលកេន ច បានដល់ មោហនសិក្ខាបទ, ដែលត្រាស់ថា "មោហនកេ បាចិត្តិយំ : នេះជាអាបត្តិបាចិត្តិយ ព្រោះក្លែងធ្វើវង្វេងនោះ(ធ្វើពើ)" ១, អមូលកសិក្ខាបទ, ដែលត្រាស់ថា "អមូលកេន សង្ឃាទិសេសេន អនុទ្ធំសេយ្យ : ចោទភិក្ខុផងគ្នាដោយអាបត្តិសង្ឃាទិសេសមិនមានមូល" ១ (សហធម្មិកវគ្គសិក្ខាបទទី៣ ទី៦) ។

បីបទថា កុក្កុច្ចំ ធម្មិកំ ចីវរំ ទត្វា បានដល់ សញ្ចិច្ចសិក្ខាបទ ១, កម្មប្បដិពាហនសិក្ខាបទ, ដែលត្រាស់ថា "ធម្មិកានំ កម្មានំ ឆន្ទំ ទត្វា ខីយនធម្មំ : ឱ្យឆន្ទះដើម្បីកម្មទាំងឡាយ ដែលប្រកបដោយធម៌ ហើយពោលតិះដៀលជាខាងក្រោយ" ១, ទព្វសិក្ខាបទ, ដែលត្រាស់ថា "ចីវរំ ទត្វា បច្ឆា ខីយនធម្មំ : ឱ្យចីវរ(ដល់ភិក្ខុ)ហើយដល់នូវធម៌ គឺកិរិយាតិះដៀលជាខាងក្រោយវិញ" ១ (សហធម្មិកវគ្គ

សិក្ខាបទទី៧ ទី៩ ទី១១ ) ។

ពីរបទថា បរិណាមេយ្យ បុគ្គលេ បានដល់ បរិណាមនសិក្ខាបទ, ដែលត្រាស់ថា "សង្ឃិកំ លាភំ បុគ្គលស្ស បរិណាមេយ្យ : លាភរបស់សង្ឃ គេបង្អោនទៅ ( ដើម្បីសង្ឃហើយ ) ត្រឡប់បង្អោនទៅដើម្បីបុគ្គលវិញ" ( សហធម្មិកវគ្គសិក្ខាបទទី១២ ) ។

បាទគាថាថា កិន្តេ អកាលអច្ឆិន្នេ បានដល់ ទុតិយភោជនប្បដិគ្គហណ, ដែលត្រាស់ថា "កិន្តេ អយ្យេ ឯសោ បុរិសបុគ្គលោ ករិស្សតិ : បុគ្គលប្រុសនេះ នឹងធ្វើអ្វីដល់លោកបាន" ១ ; អាគតសិក្ខាបទ ១, អកាលចីវរសិក្ខាបទ, ដែលត្រាស់ថា "អកាលចីវរំ កាលចីវរន្តិ : អធិដ្ឋានអកាលចីវរឱ្យជាកាលចីវរហើយប្រើគ្នាឱ្យចែក" ១, ចីវរបរិវត្តនសិក្ខាបទ, ដែលត្រាស់ថា "ភិក្ខុនិយា សទ្ធឹ ចីវរំ បរិវត្តេត្វា អច្ឆិន្ទនំ : ប្តូរចីវរទឹងភិក្ខុនីផងគ្នា ... ... ដណ្តើមយកមកវិញ" ១ ( សង្ឃាទិសេសសិក្ខាបទទី៦ និស្សគ្គិយសិក្ខាបទទី២ ទី៣ នៃភិក្ខុនី ) ។

ពីរបទថា ទុគ្គហិ និរយេន ច បានដល់ បរឧជ្ឈាបនកសិក្ខាបទ, ដែលត្រាស់ថា "ទុគ្គហិតេន ទុប្បធារិតេន បរំ ឧជ្ឈាបេយ្យ : មើលងាយគេដោយការប្រកាន់អាក្រក់ ដោយការពិចារណាខុស" ១ ; បរអភិសបនសិក្ខាបទ, ដែលត្រាស់ថា "និរយេន

វា ព្រហ្មចរិយេន វា អភិសបេយ្យ : ផ្ដាសាដោយនរកក្ដី ដោយព្រហ្មចរិយធម៌ក្ដី” ១ ( រត្តន្ធការវគ្គសិក្ខាបទទី៨ ទី៩ ) ។

បីបទថា គណំ វិភង្គំ ទុព្វលំ បានដល់ គណចីវរសិក្ខាបទ, ដែលត្រាស់ថា “គណស្ស ចីវរលាភំ អន្តរាយំ ករេយ្យ : ភិក្ខុនីណាធ្វើចីវរលាភរបស់គណៈឱ្យអន្តរាយទៅ” ១; បដិពាហនសិក្ខាបទ, ដែលត្រាស់ថា “ធម្មិកំ ចីវរវិភង្គំ បដិពាហេយ្យ : ភិក្ខុនីណា ហាមឃាត់ការចែកចីវរដែលប្រកបដោយធម៌” ១ កាលអតិក្កមនសិក្ខាបទ, ដែលត្រាស់ថា “ទុព្វលចីវរបច្ចាសាយ ចីវរកាលសមយំ អតិក្កាមេយ្យ : ភិក្ខុនីណា ញ៉ាំងសម័យនៃចីវរកាលឱ្យកន្លងហួសទៅដោយសេចក្ដីប្រាថ្នាចីវរដ៏ទុព្វល” ១ ( នគ្គវគ្គសិក្ខាបទទី៦ ទី៧ ទី៩ ) ។

បាទគាថាថា កឋិនា ផាសុ បស្សយំ បានដល់ កឋិនុទ្ធារសិក្ខាបទ, ដែលព្រះមានព្រះភាគត្រាស់ថា “ធម្មិកំ កឋិនុទ្ធារំ បដិពាហេយ្យ : ភិក្ខុនីណា ហាមឃាត់នូវការដកកឋិនប្រកបដោយធម៌” ១ ; អផាសុករណសិក្ខាបទ, ដែលត្រាស់ថា “ភិក្ខុនិយា សញ្ចិច្ច អផាសុម ករេយ្យ : ភិក្ខុនីណាមួយ ក្លែងធ្វើសេចក្ដីមិនសប្បាយដល់ភិក្ខុនីផងគ្នា” ១ ; និក្កឌ្ឍនសិក្ខាបទ, ដែលត្រាស់ថា “ភិក្ខុនិយា ឧបស្សយំ ទត្វា កុបិតា អនត្តមនា និក្កឌ្ឍេយ្យ វា : ភិក្ខុនីណាមួយ ឱ្យលំនៅដល់ភិក្ខុនីផងគ្នា

ហើយទឹងអាក់អន់ចិត្ត ក៏ទង់ទាញឯងក្តី" ១ (នគ្គវគ្គសិក្ខាបទទី១០ តុវដ្ដវគ្គសិក្ខាបទទី៣ ទី៥) ។

ពីរបទថា អក្កោសចណ្ឌី មច្ឆរី បានដល់ ភិក្ខុអក្កោសនសិក្ខាបទ, ដែលព្រះមានព្រះភាគត្រាស់ថា "ភិក្ខុំ អក្កោសេយ្យ វា បរិភាសេយ្យ វា : ភិក្ខុនីណាមួយ ជេរ គំរាមភិក្ខុ" ១; គណបរិភាសនសិក្ខាបទ, ដែលត្រាស់ថា "ចណ្ឌិកតា គណំ បរិភាសេយ្យ : ភិក្ខុនីណាមួយ ផ្តាសាគណភិក្ខុនី ដោយសេចក្តីកាច" ១ ; កុលមច្ឆរិនីសិក្ខាបទ, ដែលត្រាស់ថា "កុលេ មច្ឆរិនី អស្ស : ភិក្ខុនីណាមួយ មានសេចក្តីកំណាញ់ត្រកូល" ១ (អារាមវគ្គសិក្ខាបទទី២ ទី៣ ទី៥) ។

ពីរបទថា គព្ភិនី ច បាយន្តិយា បានដល់ គព្ភិនីសិក្ខាបទ, ដែលព្រះមានព្រះភាគត្រាស់ថា "គព្ភិនី វុដ្ឋាបេយ្យ : ភិក្ខុនីណាមួយ ឱ្យឧបសម្បទាដល់ស្រីមានគភ៌" ១ ; បាយន្តីសិក្ខាបទ, ដែលត្រាស់ថា "បាយន្តី វុដ្ឋាបេយ្យ : ភិក្ខុនីណាមួយ ឱ្យឧបសម្បទាដល់ស្រីមេដោះ" ១ ; (គព្ភិនីវគ្គសិក្ខាបទទី១ ទី២) ។

ប្រើនបទថា ទ្វេ វស្សា សិក្ខា សង្ឃេន បានដល់ បឋមសិក្ខមានសិក្ខាបទ, ដែលព្រះមានព្រះភាគត្រាស់ថា "ទ្វេ វស្សានិ ឆសុ ធម្មេសុ អសិក្ខិតសិក្ខំ សិក្ខមានំ វុដ្ឋាបេយ្យ : ភិក្ខុនីណាមួយ ឱ្យ

ឧបសម្បទាដល់សិក្ខមានាដែលមិនទាន់បានសិក្សាសិក្ខាក្នុងធម៌ទាំងឡាយ ៦ អស់ពីរវស្សា” ១ ; ទុតិយសិក្ខមានសិក្ខាបទ, ដែលត្រាស់ថា “សិក្ខំ សិក្ខមានំ សង្ឃេន អសម្មតំ វុដ្ឋាបេយ្យ : ភិក្ខុនីណាមួយ ញុំាង សិក្ខមានាដែលបានសិក្សាសិក្ខាក្នុងធម៌ទាំងឡាយ ៦ អស់ពីរវស្សា ដែលសង្ឃមិនបានសន្មត ឱ្យបានឧបសម្បទា” ១ ; ( គព្ភិនីវគ្គសិក្ខាបទ ទី៣ ទី៤ ) ។

ពីរបទថា តយោ ចេវ គិហិគតា បានដល់ បឋមគិហិគតសិក្ខាបទ, ដែលព្រះមានព្រះភាគត្រាស់ថា “ឩនទ្វាទសវស្សំ គិហិគតំ : ភិក្ខុនីណាមួយ ឱ្យឧបសម្បទាដល់ស្រីគិហិគតាមានវស្សាខ្វះពី ១២ ឆ្នាំ” ១ ; ទុតិយគិហិគតសិក្ខាបទ, ដែលត្រាស់ថា “បរិបុណ្ណទ្វាទសវស្សា គិហិគតំ ទ្វេ វស្សានិ ឆសុ ធម្មេសុ អសិក្ខិតសិក្ខំ : ភិក្ខុនីណាមួយ ឱ្យឧបសម្បទាដល់ស្រីគិហិគតាមានវស្សាគ្រប់ ១២ ឆ្នាំហើយ ដែលមិនបានសិក្សាសិក្ខាក្នុងធម៌ ៦ យ៉ាងអស់ពីរវស្សា” ១ ; តតិយគិហិគតសិក្ខាបទ, ដែលត្រាស់ថា “ទ្វេ វស្សានិ សិក្ខិតសិក្ខំ សង្ឃេន អសម្មតន្តិ : ភិក្ខុនីណាមួយ ឱ្យឧបសម្បទាដល់ស្រីគិហិគតាមានវស្សាគ្រប់ ១២ ឆ្នាំហើយ បានសិក្សាក្នុងធម៌ ៦ យ៉ាងអស់ពីរវស្សាហើយ តែសង្ឃមិនសន្មត( ឱ្យ )” ១ ( គព្ភិនីវគ្គសិក្ខាបទទី៥ ទី៦

ទី៧ ) ។

ពីរបទថា កុមារិភូតា តិស្សោ ច បានដល់ បឋមកុមារិភូតសិក្ខាបទ, ដែលព្រះមានព្រះភាគត្រាស់ថា “ឩនវីសតិវស្សំ កុមារិភូតំ : ភិក្ខុនីណាមួយ ឱ្យឧបសម្បទាដល់កុមារីភូតាមានអាយុខ្វះពី ២០ ឆ្នាំ” ១ ; (និងសិក្ខាបទ ២ ទៀត ដែលមានន័យដូចស្រីគិហិគតាដែរ គឺ) ទុតិយកុមារិភូតសិក្ខាបទ ១ តតិយកុមារិភូតសិក្ខាបទ ១ (កុមារិភូតវគ្គសិក្ខាបទទី១ ទី២ ទី៣ ) ។

បទថា ឩនទ្វាទសសម្មតា បានដល់ ២ សិក្ខាបទ គឺ ឩនទ្វាទសវស្សសិក្ខាបទ, ដែលព្រះមានព្រះភាគត្រាស់ថា “ឩនទ្វាទសវស្សា វុដ្ឋាបេយ្យ : ភិក្ខុនីណាមួយ មានវស្សាមិនទាន់គ្រប់ ១២ ហើយឱ្យឧបសម្បទា(គេ)” ១ ; បរិបុណ្ណទ្វាទសវស្សសិក្ខាបទ, ដែលត្រាស់ថា “បរិបុណ្ណទ្វាទសវស្សា សង្ឃេន អសម្មតា វុដ្ឋាបេយ្យ : ភិក្ខុនីណាមួយ មានវស្សា ១២ បរិបូណ៌ហើយ សង្ឃមិនបានសន្មត (ហើយឱ្យឧបសម្បទា)” ១ ; (កុមារិភូតវគ្គសិក្ខាបទទី៤ ទី៥ ) ។

ពីរបទថា អលន្តា វ សោកាវស្សំ បានដល់ ២ សិក្ខាបទ គឺ ខីយនធម្មសិក្ខាបទ, ដែលព្រះមានព្រះភាគត្រាស់ថា “អលំ តាវ តេ អយ្យេ វុដ្ឋាបិតេនាតិ : ភិក្ខុនីណាមួយ កាលដែលសង្ឃនិយាយថា

នៃម៉ែម្ចាស់ ម៉ែមិនទាន់គួរ (ដើម្បី) ឱ្យឧបសម្បទានៅឡើយទេ”ជាដើម ១; សោកាវាសសិក្ខាបទ, ដែលត្រាស់ថា “ចណ្ឌី សោកាវស្សំ[១] សិក្ខមានំ វុដ្ឋាបេយ្យ : ភិក្ខុនីណាមួយ ញុំាងសិក្ខមានា … ជាស្រីកាច ជាស្រីបណ្ដាលសេចក្ដីសោក ឱ្យបានឧបសម្បទា” ១; (កុមារិភូតវគ្គ សិក្ខាបទទី៦ ទី៩) ។

បីបទថា ឆន្ទា អនុវស្សា ច ទ្វេ បានដល់ ៣ សិក្ខាបទ គឺ បារិវាសិកសិក្ខាបទ, ដែលព្រះមានព្រះភាគត្រាស់ថា “បារិវាសិកឆន្ទទានេន សិក្ខមានំ វុដ្ឋាបេយ្យ : ភិក្ខុនីណាមួយ ឱ្យឧបសម្បទាដល់សិក្ខមានា ដោយឱ្យឆន្ទៈឈ្មោះបារិវាសិក” ១ ; អនុវស្សសិក្ខាបទ, ដែលត្រាស់ថា “អនុវស្សំ វុដ្ឋាបេយ្យ : ភិក្ខុនីណាមួយ ឱ្យឧបសម្បទារាល់ឆ្នាំ” ១ ; ឯកវស្សសិក្ខាបទ, ដែលត្រាស់ថា “ឯកំ វស្សំ ទ្វេ វុដ្ឋាបេយ្យ : ភិក្ខុនីណាមួយ ឱ្យឧបសម្បទាដល់ស្រីពីរក្នុង១ ឆ្នាំ” ១ ; (កុមារិភូតវគ្គសិក្ខាបទទី១១ ទី១២ ទី១៣) ។

បីបទថា សមុដ្ឋានា តិកា កតា មានសេចក្ដីថា ៧១ សិក្ខាបទនេះ ចាត់ជាតិកសមុដ្ឋាន (គឺ កើតដោយទ្វារ ៣) ។

---

១. ភូមា. សោកាវាសំ ។

# សញ្ចរិត្តសមុដ្ឋាន

[៨២៩] បីបទថា សញ្ចរិ កុដិ វិហារោ បានដល់ សញ្ចរិត្តសិក្ខាបទ១ កុដិការសិក្ខាបទ១ វិហារការសិក្ខាបទ១ (សង្ឃាទិសេសសិក្ខាបទទី៥, ៦, ៧) ។

ពីរបទថា ធោវនញ្ច បដិគ្គហោ បានដល់ ២សិក្ខាបទ គឺ បុរាណចីវរសិក្ខាបទ១ ចីវរបដិគ្គហណសិក្ខាបទ១ (ចីវរវគ្គសិក្ខាបទទី៤ ទី៥) ។

ពីរបទថា វិញ្ញត្តុត្តរិ អភិហដ្ឋុំ បានដល់ អញ្ញាតកវិញ្ញត្តិសិក្ខាបទ, ដែលត្រាស់ថា "អញ្ញាតកំ គហបតិ វា គហបតានិ វា ចីវរំ វិញ្ញាបេទ្យ : សូមចីវរចំពោះគហបតី ឬគហបតានី ដែលមិនមែនជាញាតិ" ១; តតុត្តរិសិក្ខាបទ, ដែលត្រាស់ថា "តតោ ឧត្តរឹ សាទិយេយ្យ : បើភិក្ខុត្រេកអរឡើងលើសជាងកំណត់នោះ" ១ (ចីវរវគ្គសិក្ខាបទទី៦ ទី៧) ។

ពីរបទថា ឧភិន្នំ ទូតកេន ច បានដល់ ២ សិក្ខាបទ គឺ បឋមឧបក្ខដសិក្ខាបទ ១ ទុតិយឧបក្ខដសិក្ខាបទ ១, ដែលមកថា "ចីវរចេតាបន្នំ ឧបក្ខដំ ហោតិ : តម្លៃចីវរដែល... ... ចំពោះភិក្ខុហើយតាំង

ទុក" និង រាជសិក្ខាបទ, ដែលត្រាស់ថា "ទូតេន ចីវរចេតាបន្នំ បហិតណ្ឌយ្យ : បញ្ជូនតម្លៃចីវរទៅដោយបម្រើចំពោះភិក្ខុមួយរូប" ១ (ចីវរវគ្គសិក្ខាបទទី៨ ទី៩ ទី១០) ។

ច្រើនបទថា កោសិយា សុទ្ធទ្វេភាគា ឆព្វស្សានិ និសីទនំ បានដល់ ៥ សិក្ខាបទ គឺ កោសិយសិក្ខាបទ ១ សុទ្ធកាឡកសិក្ខាបទ ១ ទ្វេភាគសិក្ខាបទ ១ ឆព្វស្សសិក្ខាបទ ១ និសីទនសន្ថតសិក្ខាបទ ១, ដែលមកថា "កោសិយមិស្សកំ សន្ថតំ : ឱ្យគេធ្វើសន្ថតលាយដោយសូត្រ"ជាដើម (កោសិយវគ្គសិក្ខាបទទី១-៥) ។

ពីរបទថា រិញ្ចន្តិ រូបិកា ចេវ បានដល់ ឯឡកលោមធោវាបនសិក្ខាបទ, ដែលមកក្នុងគម្ពីរវិភង្គថា "រិញ្ចន្តិ ឧទ្ទេសំ : លះបោលនូវការរៀនសូត្របាលី" ១ រូបិយបដិគ្គហណសិក្ខាបទ ១ (កោសិយវគ្គសិក្ខាបទទី៧, ទី៨) ។

ពីរបទថា ឧភោ នានប្បការកា បានដល់ ២ សិក្ខាបទ គឺ រូបិយសំវោហារសិក្ខាបទ ១ និងកយវិក្កយសិក្ខាបទ ១ (កោសិយវគ្គសិក្ខាបទទី៩-១០) ។

ពីរបទថា ឩនពន្ធនវស្សិកា បានដល់ ឩនបញ្ចពន្ធនបត្តសិក្ខាបទ ១ វស្សិកសាដិកសិក្ខាបទ ១ (បត្តវគ្គសិក្ខាបទទី ២ ទី៤) ។

ពីរបទថា សុត្តំ វិកប្បនេន ច បានដល់ សុត្តវិញ្ញត្តិសិក្ខាបទ, ដែលត្រាស់ថា "សុត្តំ វិញ្ញាបេត្វា តន្តវាយេហិ ចីវរំ វាយាបេយ្យ : សូមអម្បោះមកដោយខ្លួនឯង ហើយឱ្យពួកជាងដម្បាញត្បាញចីវរឱ្យ" ១ ; មហាបេសការសិក្ខាបទ ដែលថា "ឧបសង្កមិត្វា ចីវរេ វិកប្បំ អាបជ្ជេយ្យ : ហ៊ានចូលទៅរកជាងតម្បាញ ហើយដល់នូវកិរិយាកំណត់ក្នុងចីវរ" ១ (បត្តវគ្គសិក្ខាបទទី៦ ទី៧) ។

បទថា ទ្វារទានសិព្វនី ច បានដល់ សិក្ខាបទ ៣ គឺ មហល្លកវិហារសិក្ខាបទ, ដែលព្រះមានព្រះភាគត្រាស់ថា "យាវ ទ្វារកោសា អគ្គឡដ្ឋបនាយ : គប្បីឈរ(បូកញយ ៗបាន) កំណត់ទីមានឱកាសត្រឹមតែសន្ទឹកទ្វារ (និងសន្ទឹកបង្អួច" ១; ចីវរទានសិក្ខាបទ, ដែលត្រាស់ថា "អញ្ញាតិកាយ ភិក្ខុនិយា ចីវរំ ទទេយ្យ : ភិក្ខុណាមួយឱ្យចីវរដល់ភិក្ខុនីមិនមែនជាញាតិ" ១ ; ចីវរសិព្វនសិក្ខាបទ, ដែលត្រាស់ថា "ចីវរំ សិព្វេយ្យ វា សិព្វាបេយ្យ វា : ភិក្ខុណាមួយ ដេរឯងឬប្រើគេឱ្យដេរនូវចីវរ" ១ (ភូតគាមវគ្គសិក្ខាបទទី៩ ឱវាទវគ្គសិក្ខាបទទី៥ ទី៦) ។

បទថា បូវបច្ចយជោតិ ច បានដល់ សិក្ខាបទ ៣ គឺ កាណមាតាសិក្ខាបទ ដែលថា "បូវេហិ វា មន្ថេហិ វា អភិហដ្ឋុំ : ដោយ

នំទាំងឡាយក្តី ដោយសដូវទាំងឡាយក្តី ដើម្បីនាំទៅតាមប្រាថ្នា” ១ ; មហានាមសិក្ខាបទ* ១ ជោតិសមាទហនសិក្ខាបទ ១ ; (ភោជនវគ្គសិក្ខាបទទី៤ អចេលកវគ្គសិក្ខាបទទី៧ សុរាបានវគ្គសិក្ខាបទទី៦) ។

ប្រើនបទថា រតនំ សូចិ មញ្ចោ ច តូលំ និសីទនកណ្ឌុ ច វស្សិកា ច សុគតេន បានដល់ រតនសិក្ខាបទ ១ និង ៧ សិក្ខាបទ គឺ សូចិឃរសិក្ខាបទ ១ មញ្ចសិក្ខាបទ ១ តូលោនទ្ធសិក្ខាបទ ១ និសីទនសិក្ខាបទ ១ កណ្ឌុបដិចឆាទិសិក្ខាបទ ១ វស្សិកសាដិកសិក្ខាបទ ១ សុគតចីវរសិក្ខាបទ ១ (រតនវគ្គសិក្ខាបទទី២ ទី៤ ដល់ទី ១០) ។

ប្រើនបទថា វិញ្ញត្តិ អញ្ញចេតាបនា, ទ្វេ សង្ឃិកា មហាជនិកា ទ្វេ បុគ្គលា លហុកា គរុ បានដល់ ៩ សិក្ខាបទ, ដែលមានមកថា “យា បន ភិក្ខុនី អញ្ញំ វិញ្ញាបេត្វា អញ្ញំ វិញ្ញាបេយ្យ : ភិក្ខុនីណាមួយ សូមរបស់ដទៃ ហើយសូមរបស់ឯទៀតវិញ”ជាដើម គឺ អញ្ញវិញ្ញាបនសិក្ខាបទ ១ អញ្ញចេតាបនសិក្ខាបទ ១ បឋមសង្ឃិកចេតាបនសិក្ខាបទ ១ ទុតិយសង្ឃិកចេតាបនសិក្ខាបទ ១ បឋមគណិកចេតាបនសិក្ខាបទ ១ ទុតិយគណិកចេតាបនសិក្ខាបទ ១ បុគ្គលិកចេតាបនសិក្ខាបទ១ គរុបាវុរណសិក្ខាបទ១ លហុបាវុរណសិក្ខាបទ១ (ភិក្ខុនីនិស្សគ្គិយសិក្ខាបទទី ៤ ដល់ ទី១២) ។

---

* ឬ ចាតុមាសបច្ចយប្បវារណាសិក្ខាបទ ។

បីបទថា ទ្វេ វិឃាសា សាដិកា ច បានដល់ វិឃាសសិក្ខាបទទាំង ២ គឺ បឋមឧច្ចារឆឌ្ឌនសិក្ខាបទ, ដែលព្រះមានព្រះភាគត្រាស់ថា “ឧច្ចារំ វា បស្សាវំ វា សង្ការំ វា វិឃាសំ វា តិរោកុឌ្ឌេ វា តិរោបាការេ វា ឆឌ្ឌេយ្យ វា ឆឌ្ឌាបេយ្យ វា : ចោលខ្លួនឯងក្តី ឲ្យគេចោលក្តី នូវឧច្ចារៈក្តី បស្សាវៈក្តី សម្រាមក្តី កាកអាហារ ក្តី ទៅខាងក្រៅជញ្ជាំងក្តី ខាងក្រៅរបងក្តី” ១ ; ទុតិយឧច្ចារឆឌ្ឌនសិក្ខាបទ, ដែលចោលរបស់អាក្រក់ដូចគ្នាថា “ឧច្ចារាទិ ហរិតេ ឆឌ្ឌេយ្យ វា ឆឌ្ឌាបេយ្យ វា : ចោលខ្លួនឯងក្តី ឲ្យគេចោលក្តី នូវឧច្ចារៈជាដើម ក្នុងទីមានវត្ថុមានពណ៌ខៀវ”១ និងឧទកសាដិកសិក្ខាបទ (លសុណវគ្គសិក្ខាបទទី៨ ទី៩ នគ្គវគ្គសិក្ខាបទទី២) ។

ពាក្យថា សមណចីវរេន ច នោះ លោកពោលសំដៅយកព្រះបាលីនេះថា “សមណចីវរំ ទទេយ្យ : ឲ្យសមណចីវរ” គឺចីវរទានសិក្ខាបទ (នគ្គវគ្គសិក្ខាបទទី៨) ។

# សមនុភាសនសមុដ្ឋាន

[៨៣០] បទថា ភេទានុវត្តទុព្ពច ទូសទុដ្ឋុល្លទិដ្ឋិ ច បានដល់ សង្ឃភេទសិក្ខាបទ ១ ភេទានុវត្តកសិក្ខាបទ ១ ទុព្វចសិក្ខាបទ ១ កុលទូសកសិក្ខាបទ១ (សង្ឃាទិសេសសិក្ខាបទទី១០, ១១, ១២, ១៣) ទុដ្ឋុល្លាបត្តិបដិច្ឆាទនសិក្ខាបទ១ ទិដ្ឋិអប្បដិនិស្សជ្ជសិក្ខាបទ១ ។[១]

បីបទថា ឆន្ទំ ឧជ្ជគ្ឃិកា ទ្វេ ច បានដល់ ឆន្ទាទានសិក្ខាបទ, ដែលត្រាស់ថា "ឆន្ទំ អទត្វា : មិនឱ្យឆន្ទៈហើយក្រោកចាកអាសនៈចៀសចេញទៅ" ១ និង ការមិនសើចខ្លាំង ២ សិក្ខាបទ គឺ នឧជ្ជគ្ឃិកាយគមនសិក្ខាបទ ១ នឧជ្ជគ្ឃិកាយ និសីទនសិក្ខាបទ ១ (សហធម្មិកវគ្គសិក្ខាបទទី១០ ឧជ្ជគ្ឃិកវគ្គសិក្ខាបទទី១ ទី២) ។

បទថា ទ្វេ ច សទ្ទា បានដល់ ការមានសំឡេងតិច ២ សិក្ខាបទ គឺ អប្បសទ្ទគមនសិក្ខាបទ ១ អប្បសទ្ទនិសីទនសិក្ខាបទ ១ (ឧជ្ជគ្ឃិកវគ្គសិក្ខាបទ ទី៣ ទី៤) ។

បទថា ន ព្យាហរេ បានដល់ ការមិននិយាយទាំងពំនូតបាយ នៅក្នុងមាត់ គឺនសកពឡព្យាហរណសិក្ខាបទ (កពឡវគ្គសិក្ខាបទទី៣) ។

---

១. សិក្ខាបទ ២ ក្រោយនេះ មិនដឹងនៅក្នុងវគ្គណា ។

ច្រើនបទថា ឆមា នីចាសនេ ឋានំ, បច្ឆតោ ឧប្បថេន ច បានដល់ ការសម្ដែងធម៌ដល់មនុស្សគ្មានជម្ងឺ ៥ សិក្ខាបទ គឺ

ឆមាយទេសនសិក្ខាបទ "មិនសម្ដែងធម៌ដល់អ្នកអង្គុយនៅលើអាសនៈ" ១

នីចាសនទេសនសិក្ខាបទ "មិនអង្គុយលើអាសនៈទាប ហើយសម្ដែងធម៌ដល់ អ្នកអង្គុយលើអាសនៈខ្ពស់" ១

ឋិតទេសនសិក្ខាបទ "មិនឈរសម្ដែងធម៌ដល់អ្នកដែលអង្គុយ"១

បច្ឆតោទេសនសិក្ខាបទ "មិនដើរខាងក្រោយសម្ដែងធម៌ដល់អ្នកដើរខាងមុខ" ១

ឧប្បថទេសនសិក្ខាបទ "មិនដើរក្រៅមកសម្ដែងធម៌ដល់អ្នកដើរតាមមក" ១

( បាទុកាវគ្គសិក្ខាបទទី៨, ដល់ ទី១២ ) ។

ពីរបទថា វជ្ជានុវត្តិ គហណា បានដល់ បារាជិករបស់ភិក្ខុនី ៣ សិក្ខាបទ គឺ វជ្ជបដិច្ឆាទនសិក្ខាបទ ១ ឧក្ខិត្តានុវត្តនសិក្ខាបទ ១ ហត្ថគហណាទិសិក្ខាបទ ១ ។

ពីរបទថា ឱសារេ បច្ចាចិក្ខនា បានដល់ ២ សិក្ខាបទ គឺ ឧក្ខិត្តកឱសារណ សិក្ខាបទ, ដែលព្រះដ៏មានព្រះភាគត្រាស់ថា

“អនបលោកេត្វា ការកសង្ឃំ អនញ្ញាយ គណស្ស ឆន្ទំ ឱសារេយ្យ : ភិក្ខុនីណាមួយ មិនបានប្រាប់ការក សង្ឃ មិនដឹងសេចក្ដីប្រាថ្នារបស់គណៈ ហើយសូត្របញ្ចូលភិក្ខុនី” ១ ; សិក្ខំបច្ចាចិក្ខណសិក្ខាបទ, ដែលត្រាស់ថា “យា បន ភិក្ខុនី កុបិតោ អត្តមនា ឯវំ វទេយ្យ, ពុទ្ធំ បច្ចក្ខាមិ ។បេ ។ : ភិក្ខុនីណាមួយ ខឹងអាក់អន់ចិត្តហើយពោលយ៉ាងនេះថា ខ្ញុំលាព្រះពុទ្ធ ។ល ។” ១ (សង្ឃាទិសេសភិក្ខុនីទី៤ ទី៧) ។

ច្រើនបទថា គិស្មឹ សំសដ្ឋា ទ្វេ វធិ បានដល់ ច្រើនសិក្ខាបទ គឺ អធិករណកុបិតសិក្ខាបទ, ដែលព្រះដ៏មានព្រះភាគត្រាស់ថា “កិស្មិញ្ចិទេវ អធិករណេ បច្ចា កតា : ភិក្ខុនីណាមួយ ដែលសង្ឃធ្វើឱ្យចាញ់ព្រោះអធិករណ៍ទីមួយ” ១ បឋមបាបសមាចារ, ដែលត្រាស់ថា “ភិក្ខុនិយោ បនេវ សំសដ្ឋា វិហរន្តីតិ : ចំណែកភិក្ខុនីទាំងឡាយនៅច្រឡំដោយគ្រហស្ថ” ១ ទុតិយបាបសមាចារ, ដែលត្រាស់ថា “យា បន ភិក្ខុនី ឯវំ វទេយ្យ សំសដ្ឋាវ អយ្យេ តុម្ហេ វិហរថ : ភិក្ខុនីណាមួយពោលយ៉ាងនេះថា បពិត្រម៉ែម្ចាស់ទាំងឡាយ ម៉ែទាំងឡាយចូរនៅច្រឡំដោយគ្រហស្ថចុះ” ១ រោទនសិក្ខាបទ, ដែលត្រាស់ថា “អត្តានំ វធិត្វា វធិត្វា រោទេយ្យ : ភិក្ខុនីណាមួយ វាយតប់ទះខ្លួនឯង ហើយយំ” ១ (ភិក្ខុនីសង្ឃាទិសេសទី៨-១០ និងរត្តន្ធការវគ្គសិក្ខាបទទី១០) ។

ពីរបទថា វិសិព្វេ ទុក្ខិតាយ ៥ បានដល់ ២ សិក្ខាបទ គឺ

ចីវរសិព្វនសិក្ខាបទ, ដែលព្រះដ៏មានព្រះភាគត្រាស់ថា "ភិក្ខុនិយា ចីវរំ វិសិព្វេត្វា វា វិសិព្វាបេត្វា វា : ភិក្ខុនីណាមួយ រុសខ្ទនឯងក្តី ឱ្យគេរុសក្តី នូវចីវររបស់ភិក្ខុនីផងគ្នា" ១ ទនឧបដ្ឋាបនសិក្ខាបទ, ដែលត្រាស់ថា "ទុក្ខិតំ សហជីវិនឹ : ភិក្ខុនីជាកូនសិស្ស ដែលដល់នូវសេចក្តីទុក្ខ" ១ (ទន្តវគ្គសិក្ខាបទទី៣ តុវដ្តវគ្គ សិក្ខាបទទី៤) ។

ច្រើនបទថា បុន សំសដ្ឋា ន វូបសមេ បានដល់សំសដ្ឋសិក្ខាបទ ដែលព្រះដ៏មានព្រះភាគត្រាស់ដដែលទៀតថា "សំសដ្ឋា វិហរេយ្យ គហបតិនា វា គហបតិបុត្តេន វា : នៅច្រឡូកច្រឡំដោយគហបតីក្តី កូនគហបតីក្តី" ១ និង អធិករណសិក្ខាបទ, ដែលព្រះដ៏មានព្រះភាគត្រាស់ថា "ឯហាយ្យេ ឥមំ អធិករណំ វូបសមេហីតិ វុច្ចមានា សាធូតិ បដិស្សុណិត្វា សា បច្ឆា អនន្តរាយិកិនី នេវ វូបសម្មេយ្យ : កាលដែលភិក្ខុនិយាយថា នែនាងម្ចាស់ នាងចូរមករម្ងាប់អធិករណ៍នេះដូច្នេះ ទទួលពាក្យថា សាធុហើយ ភិក្ខុនីនោះ ក្នុងកាលជាខាងក្រោយឥតមានអន្តរាយអ្វី ហើយមិនរម្ងាប់" ១ ; (តុវដ្តវគ្គសិក្ខាបទទី៦ ចិត្តាគារវគ្គសិក្ខាបទទី៥) ។

ពីរបទថា អារាមញ្ច បវារណា បានដល់ ២ សិក្ខាបទ គឺ អារាមបវិសនសិក្ខាបទ, ដែលព្រះដ៏មានព្រះភាគត្រាស់ថា "ជានំ សភិក្ខុកំ អារាមំ អនាបុច្ឆា បវិសេយ្យ : កាលដឹងហើយ មិនបានប្រាប់ភិក្ខុ

ដែលមាននៅ ហើយចូលទៅកាន់អារាម” ១ អបវារណាសិក្ខាបទ, ដែលត្រាស់ថា “ឧភតោសង្ឃេ តីហិ ឋានេហិ ន បវារេយ្យ ៖ មិនបវារណានឹងឧភតោសង្ឃដោយស្ថានបីយ៉ាង ១ ( អារាមវគ្គសិក្ខាបទទី១ ទី៧ ) ។

ច្រើនបទថា អន្វឌ្ឍមាសំ សហជីវិនី ទ្វេ បានដល់ ឱវាទូបសង្កមនសិក្ខាបទ, ដែលព្រះដ៏មានព្រះភាគត្រាស់ថា “អន្វឌ្ឍមាសំ បទ[១] ភិក្ខុនិយា ភិក្ខុសង្ឃតោ ទ្វេ ធម្មា បច្ចាសីសិតព្វា ៖ ភិក្ខុនីត្រូវប្រាថ្នាធម៌ពីរអំពីសង្ឃ ( គឺ សួរឧបោសថ១ ចូលទៅទទួលឱវាទ១ ) រាល់ ៗកន្លះខែ” ១ និង ២ សិក្ខាបទ គឺ បឋមសហជីវិនិសិក្ខាបទ ដែលព្រះដ៏មានព្រះភាគត្រាស់ថា “សហជីវិនី វុដ្ឋាបេត្វា ទ្វេ វស្សានិ នេវ អនុគ្គណ្ហេយ្យ ៖ ភិក្ខុនីណាមួយ ឱ្យឧបសម្បទាដល់សិក្ខមានាជាសហជីវិនី ហើយមិនបង្រៀនអស់ពីរវស្សា” ១ ; ទុតិយសហជីវិនិសិក្ខាបទ, ដែលត្រាស់ថា “សហជីវិនី វុដ្ឋាបេត្វា នេវ វូបកាសេយ្យា ៖ ភិក្ខុនីណាមួយ ឱ្យឧបសម្បទាដល់សិក្ខមានាជាសហជីវិនី ហើយមិននាំយកទៅ” ១ ( អារាមវគ្គសិក្ខាបទទី៩ គព្ភិនីវគ្គសិក្ខាបទទី៨ ទី១០ ) ។

ពីរបទថា ចីវរំ អនុពន្ធនា បានដល់ ២ សិក្ខាបទ គឺ បឋម

---

១. ភូមា. មិនមាន “បទ” នេះ ។

សិក្ខមាននវុដ្ឋាបនសិក្ខាបទ, ដែលព្រះដ៏មានព្រះភាគត្រាស់ថា "សចេ មេ ត្វំ អយ្យេ ចីវរំ ទស្សសិ ឯវាហំ តំ វុដ្ឋាបេស្សាមីតិ : បើនាងឱ្យចីវរដល់យើង យើងនឹងឱ្យនាងបានឧបសម្បទាដោយអាការយ៉ាងនេះ" ១ ; ទុតិយសិក្ខមាននវុដ្ឋាបនសិក្ខាបទ, ដែលត្រាស់ថា "សចេ មំ ត្វំ អយ្យេ ទ្វេ វស្សានិ អនុពន្ធិស្សសិ ឯវាហំ តំ វុដ្ឋាបេស្សាមីតិ : បើនាងតាមបម្រើយើងអស់ពីរឆ្នាំ យើងនឹងឱ្យនាងបានឧបសម្បទាដោយអាការយ៉ាងនេះ" ១ (កុមារិភូតវគ្គសិក្ខាបទទី៧ ទី៨) ។

ធម៌ទាំង ៣៧ នេះ (មានសមុដ្ឋានតែមួយ មានអង្គ ៣ គឺ កាយវាចាចិត្ត ដូចសមនុភាសនសមុដ្ឋាន) ។

## កឋិនសមុដ្ឋាន

[៨៣១] បីបទថា ឧព្ភតំ កឋិនំ តីណិ បានដល់ ៣ សិក្ខាបទខាងដើមចីវរវគ្គ, ដែលព្រះដ៏មានព្រះភាគត្រាស់ថា "និដ្ឋិតចីវរស្មឹ ភិក្ខុនា ឧព្ភតស្មឹ កឋិនេ : កាលបើចីវរសម្រេចហើយ(ក្តី) កឋិនដែលភិក្ខុដោះហើយ(ក្តី)" គឺ កឋិនសិក្ខាបទ ១ ឧទោសិតសិក្ខាបទ ១ អកាលចីវរសិក្ខាបទ ១ ។

ពីរបទថា បឋមំ បត្តភេសជ្ជំ បានដល់ បត្តសិក្ខាបទ, ដែលព្រះដ៏មានព្រះភាគត្រាស់ថា "ទសាហបរមំ អតិរេកបត្តោ ធារេតព្វោ :

អតិរេកបាត្រភិក្ខុទ្រទ្រង់ទុកបានត្រឹមកំណត់ ១០ ថ្ងៃ” ១ និង ភេសជ្ជសិក្ខាបទ, ដែលព្រះដ៏មានព្រះភាគត្រាស់ថា “បដិសាយនីយនិ ភេសជ្ជានិ : ភេសជ្ជណាមួយ ដែលពួកភិក្ខុមានជម្ងឺគប្បីឆាន់បាន” ១ (បត្តវគ្គសិក្ខាបទទី១ ទី៣) ។

ពីរបទថា អច្ចេកញ្ចាបិ សាសង្កំ បានដល់ អច្ចេកចីវរសិក្ខាបទ ១ សាសង្កសិក្ខាបទ ដែលបន្ទាប់ពីទី៨នោះ ១ (បត្តវគ្គសិក្ខាបទទី៨ ទី៩) ។

ពីរបទថា បក្កមន្តេន វា ទុវេ បានដល់ ២ សិក្ខាបទ ដែលព្រះដ៏មានព្រះភាគត្រាស់ក្នុងភូតគាមវគ្គថា “តំ បក្កមន្តោ នេវ ឧទ្ធរេយ្យ : មិនបានរើយកគ្រឿងសេនាសនៈ មានគ្រែជាដើមនោះ មកទុកដាក់ស្រាប់តែដើរចេញទៅ គឺ បឋមសេនាសនសិក្ខាបទ ១ ទុតិយសេនាសនសិក្ខាបទ ១ (ភូតគាមវគ្គសិក្ខាបទ ទី៤ ទី៥) ។

ពីរបទថា ឧបស្សយំ បរម្បរា បានដល់ ២ សិក្ខាបទ គឺ ភិក្ខុនីឧបស្សយសិក្ខាបទ, ដែលព្រះដ៏មានព្រះភាគត្រាស់ថា “ភិក្ខុនូបស្សយំ គន្ត្វា[១] ភិក្ខុនិយោ ឱវទេយ្យ : ចូលទៅកាន់លំនៅភិក្ខុនី ហើយប្រដៅពួកភិក្ខុនី” ១ បរម្បរភោជនសិក្ខាបទ, ដែលព្រះដ៏មានព្រះ

---

១. ក្នុងបិដកមិនមាន “គន្ត្វា” នេះ ។

ភាគត្រាស់ថា "**បរម្បរភោជនេ បាចិត្តិយំ** : ភិក្ខុត្រូវអាបត្តិបាចិត្តិយ ព្រោះឆាន់បរម្បរភោជន" ១ ; (ឱវាទវគ្គសិក្ខាបទទី៣ ភោជនវគ្គ សិក្ខាបទទី៣) ។

ពីរបទថា **អនតិរិត្តំ និមន្តនា** បានដល់ ២ សិក្ខាបទ គឺ បឋម បវារណា, ដែលព្រះដ៏មានព្រះភាគត្រាស់ថា "**អនតិរិត្តំ ខាទនីយំ វា ភោជនីយំ វា** ខាទនីយាហារ ឬភោជនីយហារដែលជាអនតិរិត្ត គឺជាវត្ថុ ដែលមិនបានធ្វើវិន័យកម្ម" ១ ; ចារិតសិក្ខាបទ ដែលថា "**និមន្តិតោ សភត្តោ សមានោ** : បានទទួលនិមន្តគេ ជាអ្នកមានភត្ត" ១ ; (ភោជនវគ្គសិក្ខាបទទី៥ អចេលកវគ្គ សិក្ខាបទទី៦) ។

បីបទថា **វិកប្បំ រញ្ញោ វិកាលេ** បានដល់ ៣ សិក្ខាបទ គឺ វិកប្បបទសិក្ខាបទ, ដែលព្រះដ៏មានព្រះភាគត្រាស់ថា "**សាមំ ចីវរំ វិកប្បេត្វា** : បានវិកប្បចីវរដោយខ្លួនឯង" ១ អន្តេបុរសិក្ខាបទ, ដែលត្រាស់ថា "**រញ្ញោ ខត្តិយស្ស** : (បើ) ស្តេចជាក្សត្រិយ៍" ១ ; វិកាលេគាមប្បវេសនសិក្ខាបទ, ដែលត្រាស់ថា "**វិកាលេ គាមំ បវិសេយ្យ** : ចូលស្រុកក្នុងវេលាវិកាល" ១ (សុរាបានវគ្គសិក្ខាបទទី៩ រតនវគ្គសិក្ខាបទទី១ ទី៣) ។

បទថា វោសាសមានរូបេន ៥ បានដល់ ២ សិក្ខាបទ គឺ នប្បដិភាសេយ្យសិក្ខាបទ, ដែលព្រះដ៏មានព្រះភាគត្រាស់ថា "**ភិក្ខុនី**

**រោសាសមានរូបា ឋិត** : មានភិក្ខុនីមកឈរបង្ហាប់គេ” ១ អរញ្ញកសេនាសនសិក្ខាបទ, ដែលត្រាស់ថា “**តថារូបេសុ អារញ្ញកេសុ សេនាសនេសុ បុព្វេ អប្បដិសំវិទិ** : ភិក្ខុណាមួយ ឥតមានជម្ងឺនៅក្នុងទីសេនាសនៈព្រៃទាំងឡាយ មានសភាពដូច្នោះ ... ... គេមិនបានឱ្យដំណឹងជាមុន” ១ ( បាដិទេសនីយសិក្ខាបទទី២ ទី៤ ) ។

ពីរបទថា ឧស្សយា សន្និចយញ្ច បានដល់ ២ សិក្ខាបទ គឺ ឧស្សយវាទិកាសិក្ខាបទ, ដែលព្រះដ៏មានព្រះភាគត្រាស់ថា “**ឧស្សយវាទិក** : ជាអ្នកប្តឹងប្តល់” ១ ; បត្តសន្និចយសិក្ខាបទ, ដែលត្រាស់ថា “**បត្តសន្និចយំ ករេយ្យ** : ធ្វើការសន្សំ បាត្រ” ១ ( ភិក្ខុនី សង្ឃាទិសេសសិក្ខាបទទី១ និស្សគ្គិយសិក្ខាបទទី១ ) ។

ច្រើនបទថា បុរេ បច្ឆា វិកាលេ ច បានដល់ ៣ សិក្ខាបទ គឺ អនាបុច្ឆាបក្កមនសិក្ខាបទ, ដែលព្រះដ៏មានព្រះភាគត្រាស់ថា “**យា បន ភិក្ខុនី បុរេភត្តំ កុលានិ ឧបសង្កមិត្វា** : ភិក្ខុនីណាមួយ ចូលទៅរកត្រកូលទាំងឡាយក្នុងពេលមុនបាយ” ១ អនាបុច្ឆាអភិនិសីទនសិក្ខាបទ, ដែលត្រាស់ថា “**បច្ឆាភត្តំ កុលានិ ឧបសង្កមិត្វា** : ភិក្ខុនីណាមួយ ចូលទៅរកត្រកូលទាំងឡាយក្នុងពេលក្រោយបាយ” ១ អនាបុច្ឆាសន្ថរណសិក្ខាបទ, ដែលត្រាស់ថា “**វិកាលេ កុលានិ ឧបសង្កមិត្វា** : ភិក្ខុនីណាមួយ ចូលទៅរកត្រកូលទាំងឡាយក្នុងវេលាវិកាល” ១ ( រត្តន្ធ

ការវគ្គសិក្ខាបទទី៥ ទី៦ ទី៧ ) ។

ពីរបទថា បញ្ចាហិកា សង្ឃមនី បានដល់ ២ សិក្ខាបទ គឺ សង្ឃាដិចារសិក្ខាបទ, ដែលព្រះដ៏មានព្រះភាគត្រាស់ថា "បញ្ចាហិកា សង្ឃាដិវារំ[១] អតិក្កមេយ្យ : ភិក្ខុនីណាមួយញ៉ាំងវារៈនៃសង្ឃាដិឱ្យកន្លងហួស ៥ ថ្ងៃទៅ ១ ចីវរសង្កមនីយសិក្ខាបទ, ដែលត្រាស់ថា "ចីវរសង្កមនីយំ ធារេយ្យ : ភិក្ខុនីណាមួយទ្រទ្រង់ (ស្លៀកដណ្តប់) នូវសង្កមនីយចីវរ គឺចីវរដែលខ្លួនលបយកទៅប្រើប្រាស់មួយសំណើរ" ១ (នគ្គវគ្គសិក្ខាបទទី ៤ ទី៥ ) ។

ពីរបទថា ទេ្វបិ អាវសថេន ច បានដល់ ២ សិក្ខាបទ, គឺ អាវសថចីវរសិក្ខាបទ ដែលព្រះដ៏មានព្រះភាគត្រាស់រួមទីងទីសម្រាកយ៉ាងនេះថា "អាវសថចីវរំ អនិស្សជ្ជិត្វា បរិភុញ្ជេយ្យ : មិនប្រគល់អាវសថចីវរ ហើយប្រើប្រាស់" ១ អាវសថវិហារសិក្ខាបទ, ដែលត្រាស់ថា "អាវសថំ អនិស្សជ្ជិត្វា ចារិកំ បក្កមេយ្យ : មិនប្រគល់លំនៅហើយចៀសចេញទៅកាន់ចារិក"១ ។ (ចិត្តាគារវគ្គសិក្ខាបទទី៧-៨ ) ។

ពីរបទថា បសាខេ អាសនេ ចេវ បានដល់ ២ សិក្ខាបទ គឺ បសាខេជាតសិក្ខាបទ, ដែលព្រះដ៏មានព្រះភាគត្រាស់ថា "បសាខេ ជាតំ

---

១. ភូមា. សង្ឃាដិចារំ ។

គណ្ឋំ វា វុហិតំ វា ៖ ពកក្ត បូសក្ត ដែលកើតត្រង់កាយខាងក្រោម” ១ អនាបុច្ឆាសិក្ខាបទ, ដែលត្រាស់ថា “ភិក្ខុស្ស បុរតោ អនាបុច្ឆា អាសនេ និសីទេយ្យ ៖ មិនប្រាប់ហើយអង្គុយលើអាសនៈខាងមុខភិក្ខុ” ១ (អារាមវគ្គសិក្ខាបទទី ១០ ឆត្តុបាហនវគ្គសិក្ខាបទទី១១) ។

សិក្ខាបទទាំង ២៩ នេះ (រមែងកើតដោយទ្វារ ៣ គឺ កាយនិង វាចា តែមិនកើតដោយចិត្ត គ្រប់សិក្ខាបទរួមទាំងកឋិនសិក្ខាបទមានសមុដ្ឋាន ២ ស្មើគ្នា) ។

## ឯឡកលោមសមុដ្ឋាន

[៨៣២] បីបទថា ឯឡកលោមា ទ្វេ សេយ្យា បានដល់ ឯឡកលោមសិក្ខាបទ ១ និងសហសេយ្យសិក្ខាបទ ២ ; (កោសិយវគ្គ សិក្ខាបទទី៦ មុសាវាទវគ្គសិក្ខាបទទី៥ ទី៦) ។

បទថា អាហច្ចបិណ្ឌភោជនំ បានដល់ វេហាសកុដិសិក្ខាបទ និងអាវសថបិណ្ឌសិក្ខាបទ (ភូតគាមវគ្គសិក្ខាបទទី៨ ភោជនវគ្គសិក្ខាបទ ទី១) ។

បទថា គណវិកាលសន្និធិ បានដល់ ៣ សិក្ខាបទ គឺ គណភោជនសិក្ខាបទ ១ វិកាលភោជនសិក្ខាបទ ១ សន្និធិការកសិក្ខាបទ ១ (ភោជនវគ្គសិក្ខាបទទី២ ទី៧ ទី៨) ។

បទថា ទន្តបោណេន ចេលកា បានដល់ ទន្តបោណសិក្ខាបទ និង អចេលកសិក្ខាបទ (ភោជនវគ្គសិក្ខាបទទី១០ អចេលកវគ្គសិក្ខាបទទី១)។

បីបទថា ឧយ្យុត្តំ វសេ ឧយ្យោធិ បានដល់ ៣ សិក្ខាបទ គឺ ឧយ្យុត្តសិក្ខាបទ, ដែលព្រះដ៏មានព្រះភាគត្រាស់ថា “ឧយ្យុត្តំ សេនំ ទស្សនាយ គច្ឆេយ្យ : ទៅដើម្បីមើលកងទ័ពដែលគេលើកចេញទៅ” ១ សេនាវាសសិក្ខាបទ, ដែលត្រាស់ថា “សេនាយ វសេយ្យ : ត្រូវនៅក្នុងកងទ័ព” ១ ឧយ្យោធិកសិក្ខាបទ, ដែលត្រាស់ថា “ឧយ្យោធិកំ វា ពលគ្គំ វា សេនាព្យូហំ វា អនីកទស្សនំ វា គច្ឆេយ្យ : ទៅកាន់ទីដែលគេច្បាំងក្តី ទីដែលគេត្រួតពលក្តី ទីតាំងនៅនៃកងទ័ពក្តី ទីសម្រាប់ចាត់ក្បួនទ័ពក្តី” ១ (អចេលកវគ្គសិក្ខាបទទី៨ ទី៩ ទី១០)។

បីបទថា សុរា ឱរេន ឆហាយនា បានដល់ សុរាបានសិក្ខាបទ ១ ន្ហានសិក្ខាបទ[1] ១ (សុរាបានវគ្គសិក្ខាបទទី១ ទី៧)។

បីបទថា ទុព្វណ្ណេ ទ្វេ ទេសនិកា បានដល់ ៣ សិក្ខាបទ គឺ ទុព្វណ្ណករណសិក្ខាបទ, ដែលព្រះដ៏មានព្រះភាគត្រាស់ថា “តិណ្ណំ ទុព្វណ្ណករណានំ : វត្ថុសម្រាប់ធ្វើឱ្យខូចពណ៌, ៣ យ៉ាង” ១

---

១ ឬថា ឱរេនទ្ធមាសនហានសិក្ខាបទ ។

បាដិទេសនីយៈ ២ សិក្ខាបទដ៏សេសអំពីដែលត្រាស់ហើយ គឺ អញ្ញាតិកាយសិក្ខាបទ ១ សេក្ខសម្មតសិក្ខាបទ ១ ( សុរាបានវគ្គសិក្ខាបទទី៨ បាដិទេសនីយៈសិក្ខាបទទី១, ៣ ) ។

ពីរបទថា លសុណុត្តិដ្ឋេ ឆច្ឆា បានដល់ លសុណសិក្ខាបទ ១ ឧបតិដ្ឋនសិក្ខាបទ, ដែលព្រះដ៏មានព្រះភាគត្រាស់ថា "ភិក្ខុស្ស ភុញ្ជន្តស្ស បានីយេន វា វិធូបនេន វា ឧបតិដ្ឋេយ្យ ៈ កាលភិក្ខុកំពុងឆាន់ ទៅបម្រើដោយទឹកក្តី ដោយផ្លិតក្តី"១ នច្ចគីតសិក្ខាបទ, ដែលត្រាស់ថា "នច្ចំ វា គីតំ វា វាទិតំ វា ទស្សនាយ គច្ឆេយ្យ ៈ ទៅដើម្បីមើលរបាំក្តី ច្រៀងក្តី ប្រគំក្តី" ១ ( លសុណវគ្គសិក្ខាបទទី១ ទី៦ ទី១០ ) ។

តពីនេះទៅ ព្រះធម្មសង្គាហកាចារ្យទាំងឡាយ សរសេរឃ្លៀងឃ្លាតបាលី, អ្នកសិក្សាគប្បីជ្រាបលំដាប់ក្នុងពាក្យថា ឆហានំ អត្ថរណំ សេយ្យា ជាដើមនេះ ដូចសេចក្តីដែលខ្ញុំអធិប្បាយតទៅ ។

បីបទថា ឆហានំ អត្ថរណំ សេយ្យា បានដល់ សិក្ខាបទ ៣ គឺ នគ្គសិក្ខាបទ, ដែលព្រះដ៏មានព្រះភាគត្រាស់ថា "នគ្គា នហាយេយ្យ ៈ អាក្រាតកាយងូតទឹក" ១ ; ឯកត្ថរណតុវដ្ដនសិក្ខាបទ, ដែលត្រាស់ថា "ឯកត្ថរណបាបុរណា[១] តុវដ្ដេយ្យុំ ៈ មានសំពត់សម្រាប់ក្រាល សម្រាប់

១. ភូមា. ឯកត្ថរណបាវុរណា ។

ដណ្តប់តែមួយ ដេកជាមួយគ្នា” ១ ; ឯកមញ្ចតុវដ្តនសិក្ខាបទ, ដែលត្រាស់ថា “ឯកមញ្ចេ តុវដ្ដេយ្យុំ : ដេកលើគ្រែមួយ(ជាមួយគ្នា)” ១ (នគ្គវគ្គសិក្ខាបទទី១ តុវដ្ដវគ្គសិក្ខាបទទី១ ទី២) ។

បីបទថា អន្តោរដ្ឋេ តថា ពហិ បានដល់ ២ សិក្ខាបទ គឺអន្តោរដ្ឋសិក្ខាបទ, ដែលព្រះដ៏មានព្រះភាគត្រាស់ថា “អន្តោរដ្ឋេ សាសង្កសម្មតេ : ខាងក្នុងដែនដែលគេសន្មតថា ជាទីប្រកបដោយសេចក្តីរង្កៀស” ១ ; តិរោរដ្ឋសិក្ខាបទ, ដែលត្រាស់ថា “តិរោរដ្ឋេ សាសង្កសម្មតេតិ : ខាងក្រៅដែនដែលគេសន្មតថា ជាទីប្រកបដោយសេចក្តីរង្កៀស” ១ (តុវដ្ដវគ្គសិក្ខាបទទី ៧ ទី៨) ។

ពីរបទថា អន្តោវស្សំ ចិត្តាគារំ បានដល់ ២ សិក្ខាបទ គឺអន្តោវស្សសិក្ខាបទ, ដែលព្រះដ៏មានព្រះភាគត្រាស់ថា “អន្តោវស្សំ ចារិកំ ចរេយ្យ[១] : ត្រាច់ទៅកាន់ចារិកខាងក្នុងវស្សា” ១ ; រាជាគារសិក្ខាបទ, ដែលត្រាស់ថា “រាជាគារំ វា ចិត្តាគារំ វា អារាមំ វា ឧយ្យានំ វា បោក្ខរណី វា ទស្សនាយ គច្ឆេយ្យ : ទៅដើម្បីមើលដំណាក់សម្រាប់ក្រសាលរបស់ស្តេចក្តី រោងដ៏វិចិត្រក្តី សួនក្តី ឧទ្យានក្តី ស្រះបោក្ខរណីក្តី”១; (តុវដ្ដវគ្គសិក្ខាបទទី ៩ ចិត្តាគារវគ្គសិក្ខាបទទី ១) ។

---

១. ភូមា. បក្កមេយ្យ ។

ពីរបទថា អាសន្ទិ សុត្តកន្តនា បានដល់ ២ សិក្ខាបទ គឺ អាសន្ទិបរិភុញ្ជនសិក្ខាបទ, ដែលព្រះដ៏មានព្រះភាគត្រាស់ថា "អាសន្ទឹ វា បល្លង្កំ វា បរិភុញ្ជេយ្យ : ប្រើប្រាស់អាសន្ទិក្តី បល្លង្កក្តី" ១, សុត្តកន្តនសិក្ខាបទដែលត្រាស់ថា "សុត្តំ កន្តេយ្យ : ការអំបោះ(គឺមួរអំបោះ)" ១ (ចិត្តាគារវគ្គសិក្ខាបទទី២ ទី៣) ។

ពីរបទថា វេយ្យាវច្ចំ សហត្ថា ច បានដល់ ២ សិក្ខាបទ គឺ គិហិវេយ្យាវច្ចសិក្ខាបទ, ដែលព្រះដ៏មានព្រះភាគត្រាស់ថា "គិហិវេយ្យាវច្ចំ ករេយ្យ ធ្វើការបម្រើគ្រហស្ថ" ១ ភោជនទានសិក្ខាបទ អគារិកស្ស វា បរិព្វាជកស្ស វា បរិព្វាជិកាយ វា សហត្ថា ខាទនីយំ វា ភោជនីយំ វា ទទេយ្យ : ឱ្យខាទនីយ ឬ ភោជនីយ ដល់គ្រហស្ថក្តី ដល់បរិព្វាជកក្តី ដល់បរិព្វាជិកាក្តី ដោយដៃខ្លួនឯង" ១ (ចិត្តាគារវគ្គសិក្ខាបទទី៤ ទី៦) ។

ពាក្យថា អភិក្ខុកាវាសេន ច នោះ ព្រះមានព្រះភាគត្រាស់សំដៅយកសិក្ខាបទនេះ គឺ អភិក្ខុកាវាសសិក្ខាបទ, ដែលថា "អភិក្ខុកេ អាវាសេ វស្សំ វសេយ្យ : នៅចាំវស្សាក្នុងអាវាសឥតភិក្ខុ" (អារាមវគ្គសិក្ខាបទទី៦) ។

បីបទថា ឆត្តំ យានញ្ច សង្ឃាណឹ បានដល់ ៣ សិក្ខាបទ គឺ ឆត្តុបាហនសិក្ខាបទ, ដែលព្រះដ៏មានព្រះភាគត្រាស់ថា "ឆត្តុបាហនំ

ធារេយ្យ : ទ្រទ្រង់ឆត្រ និងស្បែកជើង” ១ យានសិក្ខាបទ, ដែលត្រាស់ថា “យានេន យាយេយ្យ : ទៅដោយយាន” ១ ; សព្វង្គណិសិក្ខាបទ, ដែលថា “សព្វង្គណឹ ធារេយ្យ : ពាក់ខ្សែក្រវាត់” ១ (ឆត្តុបាហនវគ្គសិក្ខាបទទី១ ទី២ ទី៣) ។

ពីរបទថា អលង្ការំ គន្ធវាសិតំ បានដល់ ៣ សិក្ខាបទ គឺឥត្ថាលង្ការសិក្ខាបទ, ដែលព្រះដ៏មានព្រះភាគត្រាស់ថា “ឥត្ថាលង្ការំ ធារេយ្យ : ប្រើប្រាស់គ្រឿងអលង្ការរបស់ស្រី” ១ គន្ធវណ្ណកសិក្ខាបទ, ដែលត្រាស់ថា “គន្ធចុណ្ណកេន នហាយេយ្យ : ងូតទឹកដោយគ្រឿងក្រអូបនិងគ្រឿងលាប” ១ វាសិតកសិក្ខាបទ, ដែលត្រាស់ថា “វាសិតកេន បិញ្ញាកេន នហាយេយ្យ : ងូតទឹកដោយគ្រឿងអប់និងគ្រឿងលំអិត” ១ (ឆត្តុបាហនវគ្គសិក្ខាបទទី៤ ទី៥ ទី៦) ។

ដោយបទថា ភិក្ខុនី ជាដើម ត្រាស់ ៤ សិក្ខាបទ, ដែលព្រះដ៏មានព្រះភាគត្រាស់ថា “ភិក្ខុនិយា ឧម្មទ្ទាបេយ្យ វា បរិមទ្ទាបេយ្យ វា : ឱ្យភិក្ខុនីរឹតក្តី ប្រឋាប់ក្តី”ជាដើម គឺ ភិក្ខុនុម្មទ្ទាបនសិក្ខាបទ ១ សិក្ខមានុម្មទ្ទាបនសិក្ខាបទ ១ សាមណេរិយុម្មទ្ទាបនសិក្ខាបទ ១ គិហិនិយុម្មទ្ទាបនសិក្ខាបទ១ (ឆត្តុបាហនវគ្គសិក្ខាបទទី៧, ៨, ៩, ១០) ។

ពីរបទថា អសង្កច្ចិកា អាបត្តិ បានដល់ អាបត្តិដែលព្រះមានព្រះភាគត្រាស់នៅក្នុងអសង្កច្ចិកសិក្ខាបទ, យ៉ាងនេះថា “អសង្កច្ចិកា គាមំ

**បរិសេយ្យ បាចិត្តិយំ :** ភិក្ខុនីណាមួយគ្មានសំពត់ចោមពុងចូលទៅកាន់ស្រុក ភិក្ខុនីនោះ ត្រូវអាបត្តិបាចិត្តិយ” (ឆត្តុបាហនវគ្គសិក្ខាបទទី ១៣) ។

បាទគាថាថា ចត្តារិសា ចតុត្តរី បានដល់ សិក្ខាបទ ៤៤ ទាំងអស់នេះ ។

ច្រើនបទថា កាយេន ន វាចាចិត្តេន កាយចិត្តេន ន វាចតោ មានសេចក្តីថា កើតពីកាយ និងកើតពីកាយចិត្ត មិនកើតពីវាចាចិត្ត មិនកើតពីវាចា ។

ពាក្យថា គ្រប់សិក្ខាបទ មានសមុដ្ឋាន ២ ឈ្មោះថា ឯឡកលោមសមុដ្ឋានដូចគ្នានេះ មានសេចក្តីច្បាស់លាស់ហើយ ។

## បទសោធម្មសមុដ្ឋាន

[៨៣៣] ពីរបទថា បទញ្ញត្រ អសម្មតា បានដល់ ៣ សិក្ខាបទ គឺ បទសោធម្មសិក្ខាបទ, ដែលព្រះដ៏មានព្រះភាគត្រាស់ថា “**បទសោ ធម្មំ :** ធម៌ជាបទ” ១ ; ធម្មទេសនាសិក្ខាបទ ដែលថា “**មាតុគាមស្ស ឧត្តរិឆប្បញ្ចវាចាហិ ធម្មំ ទេសេយ្យ អញ្ញត្រ វិញ្ញុនា បុរិសវិគ្គហេន :** សម្តែងធម៌ដល់មាតុគ្រាមលើសពីប្រាំមាត់ ឬប្រាំមួយ

មាត់ឡើងទៅ វៀរលែងតែមានបុរសដែលជីផក្តី (អន្ទយជិត)” ១ ; ឱវាទសិក្ខាបទ ដែលថា “អសម្មតោ ភិក្ខុនិយោ ឱវទេយ្យ : សង្ឃមិនបានសន្មត ហើយទៅប្រដៅពួកភិក្ខុនី” ១ (មុសាវាទវគ្គសិក្ខាបទទី៤ ទី៧ ឱវាទវគ្គសិក្ខាបទទី១) ។

ពាក្យថា តថា អត្ថង្គតេន ច នេះ ព្រះមានព្រះភាគត្រាស់សំដៅយកសិក្ខាបទនេះ គឺ អត្ថង្គតសិក្ខាបទ, ដែលព្រះដ៏មានព្រះភាគត្រាស់ថា “អត្ថង្គតេ សូរិយេ ឱវទេយ្យ : កាលបើព្រះអាទិត្យអស្តង្គតហើយទៅប្រដៅ” (ឱវាទវគ្គ សិក្ខាបទទី២) ។

ពីរបទថា តិរច្ឆានវិជ្ជា ទ្វេ បានដល់ ២ សិក្ខាបទ, ដែលព្រះដ៏មានព្រះភាគត្រាស់ថា “តិរច្ឆានវិជ្ជំ បរិយាបុណេយ្យ : រៀនតិរច្ឆានវិជ្ជា ; តិរច្ឆានវិជ្ជំ វាចេយ្យ : បង្រៀនតិរច្ឆានវិជ្ជា” គឺ តិរច្ឆានវិជ្ជាបរិយាបុណនសិក្ខាបទ ១ តិរច្ឆានវិជ្ជាវាចនសិក្ខាបទ ១ (ចិត្តាគារវគ្គសិក្ខាបទទី៩ ទី១០) ។

ពាក្យថា អនោកាសេ ច បុច្ឆនា នេះ ព្រះមានព្រះភាគត្រាស់សំដៅយកសិក្ខាបទនេះ បញ្ហាបុច្ឆនសិក្ខាបទ, ដែលព្រះដ៏មានព្រះភាគត្រាស់ថា “អនោកាសកតំ ភិក្ខុំ បញ្ហំ បុច្ឆេយ្យ : សួរបញ្ហានឹងភិក្ខុដែលខ្លួនមិនបានសូមឱកាស” (ឆត្តុបាហនវគ្គសិក្ខាបទទី ១២) ។

# អទ្ធានសមុដ្ឋាន

[៨៣៤] ពីរបទថា អទ្ធាននាវំ បណីតំ បានដល់ ៣ សិក្ខាបទ គឺ សំវិធានសិក្ខាបទ, ដែលព្រះដ៏មានព្រះភាគត្រាស់ថា "ភិក្ខុនិយា សទ្ធឹ សំវិធាយ ឯកទ្ធានមគ្គំ បដិបជ្ជេយ្យ : បបួលភិក្ខុនីដើរទៅកាន់មកឆ្ងាយជាមួយគ្នា" ១ ; នាវាភិរុហនសិក្ខាបទ ដែលថា "ឯកំ នាវំ អភិរុហេយ្យ : ឡើងជិះទូកមួយ" ១ ; បណីតភោជនសិក្ខាបទ ដែលថា "បណីតភោជនានិ អគិលានោ អត្តនោ អត្ថាយ វិញ្ញាបេត្វា ភុញ្ជេយ្យ : សូមភោជនដ៏ឧត្តម ដើម្បីប្រយោជន៍ដល់ខ្លួនហើយឆាន់" ១ (ឱវាទវគ្គសិក្ខាបទទី៧ ទី៨ ភោជនវគ្គសិក្ខាបទទី៩) ។

ពីរបទថា មាតុគាមេន សច្ឆរេ បានដល់ ២ សិក្ខាបទ គឺ សំវិធានសិក្ខាបទ, ដែលព្រះដ៏មានព្រះភាគត្រាស់ថា មាតុគាមេន សទ្ធឹ សំវិធាយ គមនញ្ច : បបួលគ្នាដើរជាមួយគ្នាមួយអន្លើដោយមាតុគ្រាម" ១ ; សម្ពាធលោមសិក្ខាបទ ដែលត្រាស់ថា "សម្ពាធេ លោមំ សំហរាបេយ្យ : ឱ្យគេដកពោមក្នុងទីចង្អៀត" ១ (សប្បាណវគ្គសិក្ខាបទទី ៧ លសុណវគ្គសិក្ខាបទទី២) ។

ពីរបទថា ធញ្ញំ និមន្តិតា ចេវ បានដល់ ២ សិក្ខាបទ គឺ អាមកធញ្ញសិក្ខាបទ ដែលព្រះដ៏មានព្រះភាគត្រាស់ថា "ធញ្ញំ វិញ្ញាបេត្វា វា

: សូមខ្ទឹងឯងក្តី នូវស្រូវ" ១ ; បរារិតសិក្ខាបទ ដែលត្រាស់ថា "និមន្តិតា វា បវារិតា វា ខាទនីយំ វា ភោជនីយំ វា ខាទេយ្យ វា ភុញ្ជេយ្យ វា ដែលគេនិមន្តហើយក្តី ហាមភត្តហើយក្តី ទំពាស៊ីក្តី បរិភោគក្តី នូវខាទនីយ ឬភោជនីយ" ១ ( លសុណវគ្គសិក្ខាបទទី៧ អារាមវគ្គសិក្ខាបទទី៤ )

បទថា អដ្ឋ ច បានដល់ បាដិទេសនីយៈ ៨ សិក្ខាបទ ដែលត្រាស់ដើម្បីភិក្ខុនីទាំងឡាយ គឺ សប្បិវិញ្ញាបនសិក្ខាបទ ១ តេលវិញ្ញាបនសិក្ខាបទ ១ មធុវិញ្ញាបនសិក្ខាបទ ១ ផាណិតវិញ្ញាបនសិក្ខាបទ ១ មច្ឆវិញ្ញាបនសិក្ខាបទ ១ មំសវិញ្ញាបនសិក្ខាបទ ១ ខីរវិញ្ញាបនសិក្ខាបទ ១ ទធិវិញ្ញាបនសិក្ខាបទ ១ ។

## ថេយ្យសត្ថសមុដ្ឋាន

[៨៣៥] ពីរបទថា ថេយ្យសត្ថំ ឧបស្សុតិ បានដល់ ២ សិក្ខាបទ គឺ ថេយ្យសត្ថសិក្ខាបទ, ដែលព្រះដ៏មានព្រះភាគត្រាស់ថា "ថេយ្យសត្ថេន សទ្ធឹ សំវិធាយ ឯកទ្ធានមគ្គំ បដិបជ្ជេយ្យ : បបួលគ្នាដើរមកជាមួយគ្នា មួយអន្លើដោយពួកឈ្មួញជាចោរ" ១ ; ឧបស្សុតិកសិក្ខាបទ "ទៅឈរអែបស្តាប់" ១ ( សប្បាណវគ្គសិក្ខាបទទី៦ សហធម្មិកវគ្គសិក្ខាបទទី៨ ) ។

ពាក្យថា សូបវិញ្ញាបនេន ច នេះ ត្រាស់សំដៅយក នសូបោទនវិញ្ញត្តិសិក្ខាបទ, ដែលថា "មិនសូមសម្លប្លបាយដើម្បីប្រយោជន៍ខ្លួនហើយឆាន់" ( សក្កច្ចវគ្គសិក្ខាបទទី៧ ) ។

បីបទថា រត្តិ ឆន្នេណញ្ច ឱកាសំ បានដល់ ៣ សិក្ខាបទ គឺ រត្តន្ធការសិក្ខាបទ, ដែលព្រះដ៏មានព្រះភាគត្រាស់យ៉ាងនេះថា "រត្តន្ធការេ អប្បទីបេ : ក្នុងយប់ងងឹត ឥតមានប្រទីប" ១ ; បដិច្ឆន្នោកាសសិក្ខាបទ, ដែលត្រាស់ថា "បដិច្ឆន្នេ ឱកាសេ : ក្នុងទីកំបាំង" ១ ; អជ្ឈោកាសសល្លបនសិក្ខាបទ, ដែលត្រាស់ថា "អជ្ឈោកាសេ បុរិសេន សទ្ធិំ : មួយអន្លើដោយបុរសក្នុងទីវាល" ១ ; ( រត្តន្ធការវគ្គសិក្ខាបទទី១ ទី២ ទី៣ ) ។

ពាក្យថា ព្យូហេន សត្តមា នេះ ត្រាស់សំដៅយកសិក្ខាបទដែលមកជាលំដាប់នៃសិក្ខាបទនោះឯង គឺ ទុតិយិកឧយ្យោជនសិក្ខាបទ, ដែលព្រះដ៏មានព្រះភាគត្រាស់ថា "រថិកាយ[1] វា ព្យូហេ វា សិង្ឃាដកេ វា បុរិសេន សទ្ធិំ : មួយអន្លើដោយបុរស ក្នុងច្រករហូតក្តី ក្នុងច្រកទាល់ក្តី ក្នុងទីប្រជុំមកក្តី" ( រត្តន្ធការវគ្គសិក្ខាបទទី៤ ) ។

---

១. បិដកខ្មែរ. រថិយាយ ។

## ធម្មទេសនសមុដ្ឋាន

ធម្មទេសនសមុដ្ឋាន មាន១១សិក្ខាបទក្នុងធម្មទេសនាបដិសំយុត្ត គឺ

១. នឆត្តបាណិទេសនៈ មិនសម្តែងធម៌ដល់អ្នកមានឆត្រក្នុងដៃ

២. នទណ្ឌបាណិទេសនៈ មិនសម្តែងធម៌ដល់អ្នកមានដំបងក្នុងដៃ

៣. នសត្ថបាណិទេសនៈ មិនសម្តែងធម៌ដល់អ្នកមានគ្រឿងសាស្ត្រាក្នុងដៃ

៤. នអាវុធបាណិទេសនៈ មិនសម្តែងធម៌ដល់អ្នកមានគ្រឿងអាវុធក្នុងដៃ

៥. នបាទុការុឡ្ហទេសនៈ មិនសម្តែងធម៌ដល់អ្នកពាក់ទ្រនាប់ជើង

៦. នឧបាហនទេសនៈ មិនសម្តែងធម៌ដល់អ្នកពាក់ស្បែកជើង

៧. នយានគតទេសនៈ មិនសម្តែងធម៌ដល់អ្នកនៅលើយាន

៨. នសយនគតទេសនៈ មិនសម្តែងធម៌ដល់អ្នកនៅលើដំណេក

៩. នបល្លត្ថិកទេសនៈ មិនសម្តែងធម៌ដល់អ្នកអង្គុយត្របោមក្បាលជង្គង់

១០. នវេឋ្ធិតសីសទេសនៈ មិនសម្តែងធម៌ដល់អ្នកជួតក្បាល

១១. នឱគុណ្ឋិតសីសទេសនៈ មិនសម្តែងធម៌ដល់អ្នកទទូរក្បាល ។

(វៀរ ៥ សិក្ខាបទខាងចុង) ងាយយល់ទាំងអស់ ។

គប្បីជ្រាបសមុដ្ឋានដែលលាយគ្នានេះមុន ។

[៨៣៧] ចំណែកនិយតសមុដ្ឋានមាន ៣ យ៉ាង, និយតសមុដ្ឋាន នោះ មានចំពោះតែមួយសិក្ខាបទ ៗប៉ុណ្ណោះ, ដើម្បីសម្តែងនិយតសមុ

ដ្ឋានទោះចំពោះផ្នែក ទើបត្រាស់ពាក្យថា ភូតំ កាយេន ជាយតិ : ភូតារោចនសិក្ខាបទ កើតឡើងអំពីកាយ ជាដើម ។ ពាក្យនោះផងាយយល់ទាំងអស់ ។

[៨៤០] បទថា នេត្តិធម្មានុលោមិកំ : សមគួរដល់វិន័យ និងបាលី និងធម៌ បានដល់ អនុលោមដល់ធម៌ ពោល គឺបាលីនៃវិន័យ ។

**ពណ៌នាសមុដ្ឋានសីស ចប់**

## ពណ៌នាកតិបុច្ឆាវារៈ

### វិនិច្ឆ័យក្នុងពាក្យថា កតិ អាបត្តិយោ ជាដើម

[៨៤១] ឥឡូវនេះ ព្រះធម្មសង្គាហកាចារ្យទាំងឡាយ តាំងបទមាតិកាដោយន័យ មានពាក្យថា កតិ អាបត្តិយោ : (សួរថា) អាបត្តិមានប៉ុន្មាន ៗ ជាដើមហើយ ពោលវិភង្គដោយអំណាចនិទ្ទេស និងបដិនិទ្ទេស ដើម្បីឱ្យកើតសេចក្តីឆ្លាត ក្នុងចំណែកទាំងឡាយមានអាបត្តិជាដើម ។

បណ្តាបទទាំងនោះ បទថា កតិ អាបត្តិយោ ជាពាក្យសួរដល់អាបត្តិដែលមកក្នុងមាតិកា និងក្នុងវិភង្គ ។ សូម្បីក្នុងបទទី ២ ក៏មានន័យដូចគ្នា ។ ពិតមែន ក្នុងបទទី ២ នេះ អាបត្តិទាំងអស់ មិនមានសល់ទុំះឯង លោកពោលថា កង ដោយអំណាចនៃពួក ។

ពាក្យដែលថា វិនីតវត្ថូនិ : វិនីតវត្ថុ ជាពាក្យសួរដល់សេចក្តីរម្ងាប់អាបត្តិទាំងនោះ ។

ពិតមែន បីបទថា វិនីតំ វិនយោ វូបសមោ នេះ ដោយសេចក្តីដូចគ្នា ។

សេចក្តីនៃបទក្នុងពាក្យថា វិនីតវត្ថូនិ នេះ គប្បីជ្រាបដូច្នេះថា

វត្ថុជាគ្រឿងកម្ចាត់អាបត្តិទាំងឯង ឈ្មោះថា វិនីតវត្ថុ ។

ឥឡូវនេះ កាលអគារវៈពួកណាមាន អាបត្តិទើបមាន, កាលអគារវៈពួកណាមិនមាន អាបត្តិរមែងមិនមាន, ដើម្បីសម្ដែងអគារវៈទាំងនោះ លោកទើបពោលពាក្យសួរថា **កតិ អគារវា : សេចក្ដីគោរពមានប៉ុន្មាន** ជាដើម ។ ចំណែកពាក្យថា **វិនីតវត្ថូនិ** នេះ ជាពាក្យសួរដល់ការកម្ចាត់អគារវៈទាំងនោះ ។

ក៏ព្រោះអាបត្តិទាំងនោះ ដែលចាត់ថា មិនដល់សេចក្ដីវិបត្តិ រមែងមិនមាន ដូច្នោះ ពាក្យដែលថា **កតិ វិបត្តិយោ : វិបត្តិមានប៉ុន្មាន** នេះ ទើបជាពាក្យសួរដល់ការមានវិបត្តិនៃអាបត្តិទាំងឡាយ ។

ពាក្យដែលថា **កតិ អាបត្តិសមុដ្ឋានា : សមុដ្ឋាននៃអាបត្តិមានប៉ុន្មាន** នេះ ជាពាក្យសួរដល់សមុដ្ឋាននៃអាបត្តិទាំងនោះឯង ។

ពាក្យដែលថា **វិវាទមូលានិ អនុវាទមូលានិ : មូលនៃវិវាទ មូលនៃអនុវាទ** ទាំងនេះ ជាពាក្យសួរដល់មូលនៃវិវាទ និងអនុវាទដែលមកថា វិវាទាធិករណ៍ អនុវាទាធិករណ៍ ។

ពាក្យដែលថា **សារាណីយា ធម្មា : សារាណីយធម៌មានប៉ុន្មាន** នេះ ជាពាក្យសួរដល់ធម៌ដែលធ្វើសេចក្ដីមិនមានមូលរបស់វិវាទ និង

អនុវាទ ។

ពាក្យដែលថា ភេទករវត្ថូនិ : រឿងដែលធ្វើឱ្យបែកគ្នា នេះ ជាពាក្យសួរដល់វត្ថុដែលកកើតការបែកបាក់ ដែលព្រះមានព្រះភាគត្រាស់ទុកក្នុងពាក្យថា អធិករណ៍ប្រព្រឹត្តទៅដើម្បីបែកគ្នាក្តី ជាដើម ។

ពាក្យដែលថា អធិករណានិ នេះ ជាពាក្យសួរដល់ធម៌ដែលកើតឡើង ក្នុងកាលមានភេទករវត្ថុ ។

ពាក្យដែលថា សមថា នេះ ជាពាក្យសួរដល់ធម៌ដែលសម្រាប់រម្ងាប់អធិករណ៍ទាំងនោះឯង ។

[៨៤២] ពាក្យដែលថា បញ្ច អាបត្តិយោ : (ឆ្លើយថា) អាបត្តិមាន ៥ ត្រាស់ដោយអំណាចអាបត្តិដែលមកក្នុងមាតិកា ។

ពាក្យដែលថា សត្ត : មាន ៧ ត្រាស់ដោយអំណាចអាបត្តិ ៧ កង ដែលមកក្នុងវិភង្គ ។

## វិគ្រោះនៃអារតិសំព្ទជាដើម

[៨៤៥] ដែលឈ្មោះថា អារតិ : កិរិយាវៀរឱ្យឆ្ងាយ ព្រោះវិគ្រោះថា វៀរឆ្ងាយចាកកងអាបត្តិទាំងនោះ ។

ម្យ៉ាងទៀត ធម្មជាតិដែលវៀរយ៉ាងប្រិតប្រៀនអំពីកងអាបត្តិទាំងនោះ ឈ្មោះថា អារតិ ។

ដែលឈ្មោះថា វិរតិ : វៀរឱ្យស្រឡះ ព្រោះវិគ្រោះថា វៀរចេញស្រឡះឱ្យផ្សេងដទៃពីកងអាបត្តិទាំងនោះ ។

ដែលឈ្មោះថា បដិវិរតិ : វៀរចំពោះ ព្រោះវិគ្រោះថា វៀរចំពោះមួយ ៗ អំពីកងអាបត្តិទាំងនោះ ។

ដែលឈ្មោះថា វេរមណី : ចៀសវាង ព្រោះវិគ្រោះថា ដេញវេរាចេញ គឺ ញ៉ាំងពៀរឱ្យសាបសូន្យ ។

ដែលឈ្មោះថា អកិរិយា : កិរិយាមិនធ្វើ ព្រោះវិគ្រោះថា វិរតិនោះ ជាហេតុដែលភិក្ខុមិនធ្វើកងអាបត្តិទាំងនោះ ។

ដែលឈ្មោះថា អករណំ : មិនបង្កើត ព្រោះជាសត្រូវចំពោះការធ្វើកងអាបត្តិដែលនឹងគប្បីកើតឡើង ក្នុងកាលវិរតិនោះមិនមាន ។

ដែលឈ្មោះថា អនជ្ឈាបត្តិ : មិនត្រូវអាបត្តិ ព្រោះជាសត្រូវចំពោះការត្រូវអាបត្តិ ។

ដែលឈ្មោះថា វេលា : មិនកន្លងនូវដែន ព្រោះជាហេតុបំផ្លិចបំផ្លាញ, អធិប្បាយថា ព្រោះជាហេតុបង្ខិនបង្ខោច គឺ ធ្វើឱ្យ

វិនាស ។

ដែលឈ្មោះថា សេតុ ព្រោះវិគ្រោះថា ចងទុក គឺសង្កត់ទុក បាន ដល់ ឃុំទុកត្រង់មកជាទីចេញទៅ ។ ពាក្យថា **សេតុ** នេះ ជាឈ្មោះនៃ កងអាបត្តិទាំងឡាយ ។ សេតុនោះដែលភិក្ខុ រមែងសម្លាប់ដោយ វិរតិនោះ ព្រោះដូច្នោះ វិរតិនោះ ទើបឈ្មោះថា សេតុឃាតោ : **សម្លាប់ បង់នូវកងនៃអាបត្តិ** ។

សូម្បីក្នុងនិទ្ទេសនៃវិនីតវត្ថុដ៏សេសទាំងឡាយ ក៏ន័យនេះឯង ។

## **អគារវៈ ៦**

[៨៤៩] វិនិច្ឆ័យក្នុងពាក្យថា ពុទ្ធេ អគារវោ : **ការមិនគោរព ព្រះពុទ្ធ** ជាដើម គប្បីជ្រាបដូច្នេះ ៖

អ្នកណា កាលព្រះពុទ្ធទ្រង់នៅមានព្រះជន្ម មិនទៅកាន់ទីបម្រើ, កាលព្រះពុទ្ធបរិញ្ញានហើយ មិនទៅកាន់ទីចេតិយ ទីពោធិព្រឹក្ស មិនសំពះ ចេតិយ ឬដើមពោធិ បាំងឆត្រ និងពាក់ស្បែកជើង ដើរទៅលើលាន ចេតិយ គប្បីជ្រាបថា អ្នកនោះ មិនមានសេចក្ដីគោរពក្នុងព្រះពុទ្ធ ។

ចំណែកអ្នកណាអាច តែមិនទៅកាន់ទីស្ដាប់ធម៌ មិនសូធ្យ

សវភេញ្ញៈ មិនពោលធម្មកថា ទម្លាយពេលធម្មសវនៈចេញហើយទៅ មានចិត្តរវើរវាយ ឬមិនអើពើអង្គុយស្តាប់ គប្បីជ្រាបថា អ្នកនោះ មិនមានសេចក្តីគោរពក្នុងព្រះធម៌ ។

អ្នកណា មិនតាំងទុកនូវសេចក្តីកោតក្រែង ក្នុងព្រះថេរៈ ភិក្ខុថ្មី និងភិក្ខុកណ្តាល សម្តែងសេចក្តីរពឹសកាយ ក្នុងទីទាំងឡាយ មានរោងឧបោសថ និងរោងវិតក្កៈជាដើម មិនសំពះ តាមលំដាប់ចាស់វស្សា គប្បីជ្រាបថា អ្នកនោះ មិនមានសេចក្តីគោរពក្នុងព្រះសង្ឃ ។

ចំណែកអ្នកណា មិនសមាទានសិក្ខាត្រៃសិក្ខាឡើយ គប្បីជ្រាបថា អ្នកនោះ មិនមានសេចក្តីគោរពក្នុងសិក្ខា ។

ចំណែកអ្នកណា តាំងនៅក្នុងសេចក្តីប្រមាទ គឺ ក្នុងសេចក្តីនៅប្រាសចាកសតិប៉ុណ្ណោះ មិនបង្កើនលក្ខណៈសេចក្តីមិនប្រមាទ គប្បីជ្រាបថា អ្នកនោះមិនមានសេចក្តីគោរពក្នុងសេចក្តីមិនប្រមាទ ។

មួយទៀត អ្នកណា មិនធ្វើនូវបដិសណ្ឋារៈ ២ យ៉ាងនេះ គឺ អាមិសបដិសណ្ឋារៈ ធម្មបដិសណ្ឋារៈ គប្បីជ្រាបថា អ្នកនោះ មិនមានសេចក្តីគោរពក្នុងបដិសណ្ឋារៈ ។

សេចក្តីក្នុងគារវនិទ្ទេស គប្បីជ្រាបដោយបរិយាយ ដែលប្លែកអំពីសេចក្តីដែលពោលហើយ ។

# វិវាទមូលនិទ្ទេស

[៨៥៤] វិនិច្ឆ័យក្នុងវិវាទមូលនិទ្ទេស គប្បីជ្រាបដូច្នេះ ៖

សេចក្តីនៃពាក្យថា សត្ថរិបិ អគារវោ : មិនគោរព ក្នុងព្រះសាស្តាផង ជាដើម គប្បីជ្រាបតាមន័យដែលពោលហើយ ក្នុងការមិនមានសេចក្តីគោរព ក្នុងព្រះពុទ្ធជាដើមនុ៎ះឯង ។

បទថា អប្បតិស្សោ : មិនឱនលំទោន បានដល់ មិនប្រព្រឹត្តបន្ទាបខ្លួន គឺ មិនលើកព្រះសាស្តាឱ្យជាធំ ។

បទថា អជ្ឈត្តំ វា : ក្នុងសន្តានខាងក្នុងក្តី សេចក្តីថា (បើថាលោកទាំងឡាយ គប្បីសម្លឹងឃើញមូលនៃវិវាទបែបនោះ) ក្នុងសន្តាននៃខ្លួនក្តី ក្នុងពួកនៃខ្លួនក្តី ក្នុងបរិស័ទនៃខ្លួនក្តី ។

បទថា ពហិទ្ធា វា : ក្នុងសន្តានខាងក្រៅក្តី សេចក្តីថា ក្នុងសន្តាននៃបុគ្គលដទៃ ឬក្នុងពួកនៃបុគ្គលដទៃក្តី ។

ពីរបទថា តត្រ តុម្ហេ : អ្នកទាំងឡាយ ... ... នោះ សេចក្តីថា ទាំងក្នុងសន្តានរបស់ខ្លួន និងអ្នកដទៃឬទាំងក្នុងបរិស័ទរបស់ខ្លួន និងអ្នកដទៃ ដែលផ្សេងគ្នា ដោយមានខាងក្នុងនិងមានខាងក្រៅនោះ ។

ពីរបទថា បហានាយ វាយមេយ្យាថ : អ្នកទាំងឡាយត្រូវព្យាយាមលះបង់ មានសេចក្ដីថា លោកទាំងឡាយគប្បីព្យាយាម ដើម្បីលះមូលនៃវិវាទដ៏លាមកនុ៎ះឯង ដោយន័យទាំងឡាយ មានមេត្តាភាវនាជាដើម ។

ពិតមែន វិវាទមូលនោះ ដែលមានទាំងខាងក្នុងទាំងខាងក្រៅ រមែងលះចេញបាន ដោយន័យមានមេត្តាភាវនាជាដើម ។

បទថា អនវស្សវាយ : កុំឱ្យប្រព្រឹត្តទៅ បានដល់ ដើម្បីសេចក្ដីមិនប្រព្រឹត្តទៅ ។

បទថា សន្ទិដ្ឋិបរាមាសី : ជាអ្នកប្រកាន់តាមសេចក្ដីយល់របស់ខ្លួន មានសេចក្ដីថា រមែងប្រកាន់សេចក្ដីឃើញរបស់ខ្លួនប៉ុណ្ណោះ គឺសេចក្ដីណា ដែលខ្លួនបានឃើញហើយ រមែងប្រកាន់សេចក្ដីនោះថា "សេចក្ដីនេះប៉ុណ្ណោះ ពិត" ។

បទថា អាធានគាហី : ទាំងប្រកាន់មាំ បានដល់ ទាំងប្រកាន់ទុកយ៉ាងមាំ ។

# អនុវាទមូលនិទ្ទេស

[៨៥៥] អនុវាទមូលនិទ្ទេស ស្មើដោយវិវាទមូលនិទ្ទេសនុ៎ះឯង ក៏ពិតមែន តែថាក្នុងវិវាទមូលនិទ្ទេស និងអនុវាទមូលនិទ្ទេសនេះ រមែងមានសេចក្តីប្លែកគ្នាដូច្នេះថា ទោសទាំងឡាយ មានសេចក្តីក្រោធ និងសេចក្តីចងក្រោធគ្នាជាដើម របស់ភិក្ខុទាំងឡាយ អ្នកវិវាទគ្នាអាស្រ័យភេទករវត្ថុ ១៨ ចាត់ជាមូលនៃវិវាទ ក៏ឯកាលវិវាទគ្នាយ៉ាងនោះ រមែងដល់វិបត្តិយ៉ាងណាមួយ ក្នុងវិបត្តិ ៤ មានសីលវិបត្តិជាដើមហើយ ចោទគ្នានិងគ្នាថា "ភិក្ខុឈ្មោះឯណោះ ត្រូវវិបត្តិឈ្មោះឯណោះ" ខ្លះ, ថា "លោកត្រូវអាបត្តិបារាជិក" ខ្លះ, ថា "លោកត្រូវអាបត្តិសង្ឃាទិសេស" ខ្លះ ។ ទោសទាំងឡាយ មានសេចក្តីក្រោធ និងចងសេចក្តី ក្រោធគ្នាជាដើម របស់ភិក្ខុទាំងឡាយដែលចោទនូវគ្នានិងគ្នា យ៉ាងនោះ ចាត់ជា មូលនៃអនុវាទ ។

# សារាណីយធម្មនិទ្ទេស

[៨៥៦] វិនិច្ឆ័យក្នុងសារាណីយធម្មនិទ្ទេស ដូច្នេះ ៖

កាយកម្ម ដែលធ្វើដោយចិត្តប្រកបដោយមេត្តា ឈ្មោះថា មេត្តាកាយកម្ម ។

ពីរបទថា អាវិ ចេវ រហោ ច : ក្នុងទីស្រឡះផង ក្នុងទីស្ងាត់ផង បានដល់ ទាំងក្នុងទីចំពោះមុខ ទាំងក្នុងទីកំបាំងមុខ ។

ក្នុងកាយកម្ម ២ យ៉ាង ដោយអំណាចនៃចំពោះមុខ និងកំបាំងមុខនោះ ការដល់ភាពជាសម្លាញ់ ក្នុងការងារទាំងឡាយ មានចីវរកម្មជាដើមរបស់ភិក្ខុថ្មីទាំងឡាយ ឈ្មោះថា មេត្តាកាយកម្មចំពោះមុខ ។ ចំណែកសាមីចិកម្មទាំងពួង សូម្បីផ្សេងដោយកិច្ចមានលាងជើង និងបក់ផ្លិតជាដើមឱ្យព្រះថេរៈទាំងឡាយ ឈ្មោះថា មេត្តាកាយកម្មចំពោះមុខ ។

ការរក្សាទុកដាក់ភណ្ឌៈទាំងឡាយ មានភណ្ឌៈឈើជាដើម ដែលភិក្ខុថ្មី និងព្រះថេរៈទាំង ២ ពួករក្សាទុកដាក់ទុកមិនល្អ មិនធ្វើសេចក្តីមើលងាយក្នុងភិក្ខុថ្មី និងព្រះថេរៈទាំងនោះ ដូចជារក្សាទុកដាក់នូវវត្ថុដែលខ្លួនរក្សាទុកមិនល្អដូច្នោះ ឈ្មោះថា មេត្តាកាយកម្មកំបាំងមុខ ។

ពាក្យថា អយម្បិ ធម្មោ សារាណីយោ : ធម៌នេះឯង ដែលបុគ្គលគប្បីរលឹក មានសេចក្តីថា ធម៌ ពោលគឺ មេត្តាកាយកម្មនេះ ដែលសព្រហ្មចារីទាំងឡាយគប្បីរលឹកដល់, អធិប្បាយថា បុគ្គលណា

ញ៉ាំងសតិឲ្យកើតធ្វើធម៌ ពោលគឺ មេត្តាកាយកម្មនោះ ធម៌គឺ មេត្តាកាយកម្មនោះ ជាធម៌ ដែលបុគ្គលនោះធ្វើហើយដល់ជនពួកណា ជនទាំងនោះ មានចិត្តជ្រះថ្លាហើយ រមែងរលឹកដល់បុគ្គលនោះថា អ្នកនេះជាសប្បុរសពិត ។

បទថា បិយករណោ : ឈ្មោះថា ធ្វើនូវសេចក្តីស្រឡាញ់ មានសេចក្តីថា ធម៌គឺ មេត្តាកាយកម្មនោះ រមែងធ្វើបុគ្គលនោះ ឲ្យជាទីស្រឡាញ់របស់សព្រហ្មចារីទាំងឡាយ ។

បទថា គរុករណោ : ឈ្មោះថា ធ្វើនូវសេចក្តីគោរព មានសេចក្តីថា ធម៌នោះ រមែងធ្វើបុគ្គលនោះ ឲ្យជាទីគោរពរបស់សព្រហ្មចារីទាំងឡាយ ។

វិនិច្ឆ័យក្នុងពាក្យថា សង្គហាយ : ប្រព្រឹត្តទៅដើម្បីសេចក្តីសង្គ្រោះ ជាដើម គប្បីជ្រាបដូច្នេះ ៖

ធម៌នោះ ប្រព្រឹត្តទៅដើម្បីបានភាពជាអ្នកដែលសព្រហ្មចារីទាំងឡាយគប្បីជួយសង្គ្រោះ ដើម្បីមិនវិវាទ ដើម្បីជាអ្នកព្រមព្រៀងគ្នាជាពួកតែមួយរួមជាមួយនឹងសព្រហ្មចារីទាំងនោះ ។

វិនិច្ឆ័យក្នុងពាក្យថា មេត្តំ វចីកម្មំ : វចីកម្មប្រកបដោយមេត្តាជាដើម គប្បីជ្រាបដូច្នេះ ៖

ការពោលសរសើរយ៉ាងនេះថា "ព្រះទេវត្ថេរ, ព្រះតិស្សត្ថេរ"

ឈ្មោះថា មេត្តាវចីកម្មចំពោះមុខ ។ ចំណែកការពោលពាក្យដែលសម្តែងសេចក្តីស្រឡាញ់ របស់បុគ្គលដែលសាកសួរដល់លោកក្នុងកាលលោកមិននៅក្នុងសំណាក់ យ៉ាងនេះថា "លោកម្ចាស់ទេវត្ថេររបស់ពួកយើងទៅណា ? លោកម្ចាស់តិស្សត្ថេររបស់ពួកយើងទៅណា ? កាលណាហ្ន៎ លោកម្ចាស់នឹងមក ?" ដូច្នេះ ឈ្មោះថា មេត្តាវចីកម្មកំបាំងមុខ ។

ក៏ការបើកភ្នែកដ៏ស្និទ្ធ ជិតជាប់ទៅដោយសេចក្តីស្រឡាញ់ ពោលគឺ មេត្តាក្រឡេកមើលដោយមុខដែលរីករាយ ឈ្មោះថា មេត្តាមនោកម្មចំពោះមុខ ។ ការនឹករលឹកដល់ជានិច្ចថា "លោកម្ចាស់ទេវត្ថេរ លោកម្ចាស់តិស្សត្ថេរ ចូរជាអ្នកមិនមានរោគ មានអាពាធតិច" ឈ្មោះថា មេត្តាមនោកម្មកំបាំងមុខ ។

បទថា **អប្បដិវិភត្តភោគី : ភិក្ខុអ្នកមិនទាន់បរិភោគ ទាំងមិនទាន់បានចែក** មានសេចក្តីថា រមែងបែងចែកអាមិសទុកសម្រាប់ខ្លួនហើយបរិភោគ ក៏ទេ បែងចែកទុកចំពោះបុគ្គលហើយបរិភោគ ក៏មិនមែនដែរ ។

ក៏ភិក្ខុណា រមែងបែងចែកទុកបរិភោគថា "យើងនឹងឲ្យដល់ភិក្ខុពួកដទៃប៉ុណ្ណោះ នឹងបរិភោគដោយខ្លួនឯងប៉ុណ្ណោះ" ឬថា "យើងនឹងឲ្យដល់ភិក្ខុឯណោះ និងភិក្ខុឯណោះប៉ុណ្ណោះ នឹងបរិភោគដោយខ្លួនឯង

ប៉ុណ្ណេះ” ភិក្ខុនេះ ឈ្មោះថា អ្នកបែងចែកបរិភោគដោយចំពោះ ។

ចំណែកភិក្ខុដែលតាំងនៅក្នុងសារាណីយធម៌នេះ មិនធ្វើយ៉ាងនោះ ថ្វាយបិណ្ឌបាតដែលខ្លួននាំមកតាំងពីព្រះថេរៈ ហើយឆាន់ចំណែកដ៏សេស ពីដែលព្រះថេរៈទទួលយកទុក ។

ព្រះអដ្ឋកថាចារ្យទាំងឡាយពោលថា សូម្បីមិនឱ្យដល់បុគ្គលទ្រុស្ត សីល ក៏គួរ ព្រោះព្រះបាលីថា **សីលវន្តេហិ : អ្នកមានសីលទាំងឡាយ,** តែភិក្ខុដែលបំពេញសារាណីយធម៌ គប្បីឱ្យដល់អ្នកមានសីល និងអ្នកទ្រុស្តសីលទាំងពួងតែម្តង ។

សូម្បីជ្រើសរើសឱ្យដល់អ្នកអាពាធ និងអ្នកព្យាបាលជម្ងឺ អ្នកអាគន្តុកៈ អ្នកត្រៀមទឹងទៅ និងអ្នកខ្វល់ខ្វាយក្នុងការងារ មានចីវរកម្មជាដើម ក៏គួរ ។ ព្រោះថា ភិក្ខុជ្រើសរើសបុគ្គលទាំងនោះ ហើយឱ្យ ទឹង ឈ្មោះថា ធ្វើការបែងចែកបុគ្គល ក៏ទេ ។ ពិតមែន ព្រោះភិក្ខុទាំងឡាយបែបនេះ ជាអ្នកមានលាភខ្វះខាត ទើបគួរធ្វើឱ្យជាចំណែកពិសេសពិត ព្រោះហេតុនោះ បុគ្គលបំពេញសារាណីយធម៌នេះ ទើបធ្វើការជ្រើសរើសឱ្យ ។

វិនិច្ឆ័យក្នុងបទថា **អខណ្ឌានិ : ដែលមិនដាច់** ជាដើម គប្បីជ្រាបដូច្នេះ ៖

បណ្តាអាបត្តិ ៧ កង សិក្ខាបទរបស់ភិក្ខុណា ជាគុណដាច់ខាងដើមឬខាងចុង សីលរបស់ភិក្ខុនោះ ឈ្មោះថា **ខណ្ឌានិ : ដាច់** ប្រៀប

ដូចសំពត់ដាច់ដាយដោយជុំវិញដូច្នោះ ។

ចំណែកសិក្ខាបទរបស់ភិក្ខុណា ធ្លាយត្រង់កណ្ដាល សីលរបស់ភិក្ខុនោះ ឈ្មោះថា ឆិទ្ទានិ : ធ្លុះ ប្រៀបដូចសំពត់ដែលមានប្រហោងធ្លុះនៅកណ្ដាល ដូច្នោះ ។

សិក្ខាបទរបស់ភិក្ខុណា ធ្លុះធ្លាយ ២-៣ សិក្ខាបទដោយលំដាប់ សីលរបស់ភិក្ខុនោះ ឈ្មោះថា សពលានិ : ពពាល ប្រៀបដូចមេគោដែលមានពណ៌ខ្មៅនិងក្រហមជាដើម យ៉ាងណាមួយ ឆ្លាស់គ្នានឹងពណ៌ដែលមិនដូចគ្នា ដែលប្រាកដឡើងត្រង់ខ្នង ឬត្រង់ពោះ ដូច្នោះ ។

សិក្ខាបទរបស់ភិក្ខុណា ធ្លាយក្នុងចន្លោះ ៗ សីលរបស់ភិក្ខុនោះ ឈ្មោះថា កម្មាសានិ : ពព្រុះ ប្រៀបដូចមេគោដែលពាសពេញដោយពណ៌មិនដូចគ្នាក្នុងចន្លោះ ៗ ដូច្នោះ ។

ចំណែកសីលរបស់ភិក្ខុណា មិនធ្លាយដោយប្រការទាំងពួង សីលទាំងនោះ របស់ភិក្ខុនោះ ឈ្មោះថា មិនដាច់ មិនធ្លុះ មិនពពាល មិនពព្រុស ។

ក៏សីលទាំងនេះ ដែលព្រះមានព្រះភាគត្រាស់ថា ភុជិស្សានិ : ជាសីល រួចខ្លួន ព្រោះធ្វើខ្លួនមិនឱ្យជំពាក់បំណុល វិញ្ញុប្បសត្ថានិ : ជាសីលដែលអ្នកប្រាជ្ញសរសើរ ព្រោះជាសីលដែលលោកអ្នកដឹងលើកតម្កើង អបរាមដ្ឋានិ : ជាសីលដែលកិលេសមិនបានប៉ះពាល់ ព្រោះ

ជាសីលដែលតណ្ហា និងទិដ្ឋិ មិនបានពាល់ត្រូវ ប្រព្រឹត្តទៅដើម្បីសមាធិ ព្រោះញ៉ាំងឧបចារសមាធិ ឬ អប្បនាសមាធិឱ្យប្រព្រឹត្តទៅព្រម ។

ពីរបទថា សីលសាមញ្ញគតោ វិហរតិ : ភិក្ខុជាអ្នកមានសីលស្មើគ្នា នៅ មានសេចក្តីថា អ្នកមានសីលចូលដល់ភាពជាអ្នកស្មើគ្នានឹងភិក្ខុទាំងឡាយអ្នកមានសីលល្អ ដែលនៅក្នុងទិសាភាគទាំងនោះ ៗ ។

ពីរបទថា យាយំ ទិដ្ឋិ : ទិដ្ឋិណា បានដល់ សម្មាទិដ្ឋិ ដែលសម្បយុត្តដោយមគ្គ ។

បទថា អរិយា : ដ៏ប្រសើរ បានដល់ មិនមានទោស ។

បទថា និយ្យាតិ : ជាទីនាំសត្វចេញចាកវដ្តទុក្ខ បានដល់ នាំចេញទៅ ។

បទថា តក្ករស្ស : របស់បុគ្គលអ្នកធ្វើយ៉ាងនោះ បានដល់អ្នកមានប្រក្រតីធ្វើយ៉ាងនោះ ។

បទថា ទុក្ខក្ខយាយ : ដើម្បីជាទីអស់ទៅនៃកងទុក្ខដោយប្រពៃ បានដល់ ដើម្បីអស់ទៅនៃទុក្ខទាំងពួង ។

ពាក្យដ៏សេស រហូតដល់ប្រភេទសមថៈជាទីបំផុត មានសេចក្តីងាយយល់ទាំងអស់ ។

**ពណ៌នាគតិបុច្ឆាវារៈ ចប់**

# សមន្តបាសាទិកា

## អដ្ឋកថា វិនយបិដក

បរិវារៈ

## បឋមភាគ

១២

ចប់

# សមន្តបាសាទិកា

## អដ្ឋកថា វិនយបិដក

### បរិវារៈ

## ទុតិយភាគ

## ១៣

# ពណ៌នាខន្ធកបុច្ឆា

[១] ពីរបទថា ឧបសម្បទំ បុច្ឆិស្សំ : ខ្ញុំនឹងសួរនូវឧបសម្បទា មាន សេចក្ដីថា ខ្ញុំនឹងសួរដល់ឧបសម្បទាខន្ធកៈ ។

ពីរបទថា សនិទានំ សនិទ្ទេសំ : ដែលប្រកបដោយនិទាន ប្រកបដោយនិទ្ទេស មានសេចក្ដីថា ខ្ញុំនឹងសួរព្រមដោយដើមហេតុ និងអធិប្បាយ ។

ច្រើនបទថា សមុក្កដ្ឋបទានំ កតិ អាបត្តិយោ : អាបត្តិរបស់បទឧក្រិដ្ឋ មានប៉ុន្មាន មានសេចក្ដីថា បទពួកណាជាបទឧក្រិដ្ឋ គឺជាបទខ្ពស់បំផុត ដែលព្រះមានព្រះភាគ ត្រាស់ទុកក្នុងឧបសម្បទាខន្ធកៈនោះ បទឧក្រិដ្ឋដោយសង្ខេប មានអាបត្តិប៉ុន្មាន ?

អាបត្តិណា ៗ ដែលព្រះមានព្រះភាគទ្រង់បញ្ញត្តិដោយបទណា ៗ, អាបត្តិនោះ ៗ លោកពោលថា អាបត្តិនៃបទនោះ ៗ, ព្រោះហេតុនោះលោកទើបពោលថា បទខ្ពស់បំផុតទាំងឡាយ មានអាបត្តិប៉ុន្មាន ?

ពីរបទថា ទ្វេ អាបត្តិយោ : អាបត្តិ មាន ២ មានសេចក្ដីថា ភិក្ខុដែលឱ្យឧបសម្បទា ដល់បុគ្គលមានអាយុមិនទាន់គ្រប់ ២០ ឆ្នាំ ជាអាបត្តិបាចិត្តិយ, ក្នុងបទទាំងពួងដ៏សេស ជាអាបត្តិទុក្កដ ។

[២] បទថា តិស្សោ មានសេចក្ដីថា ក្នុងឧបោសថក្ខន្ធកៈ មានអាបត្តិ ៣ យ៉ាងនេះគឺ ការធ្វើឧបោសថរបស់ភិក្ខុទាំងឡាយ ដែលប្រាថ្នា

ការបំបែកថា "ពួកភិក្ខុនុ៎ះចូរបាត់បង់ទៅ ពួកភិក្ខុនុ៎ះចូរវិនាសទៅ ប្រយោជន៍អ្វីដោយភិក្ខុទាំងនោះ ហើយក៏ធ្វើឧបោសថ"[១] ជាអាបត្តិថុល្លច្ច័យ, ការធ្វើឧបោសថរួមនឹងភិក្ខុដែលសង្ស័យលើកវត្ត ជាអាបត្តិបាចិត្តិយ, បទទាំងឡាយដ៏សេស ជាអាបត្តិទុក្កដ ។

[៣] បទថា ឯកា មានសេចក្ដីថា ក្នុងវស្សូបនាយិកក្ខន្ធកៈ មានអាបត្តិទុក្កដតែមួយប្រភេទប៉ុណ្ណោះ ។

[៤] បទថា តិស្សោ មានសេចក្ដីថា សូម្បីក្នុងបវារណាខន្ធកៈក៏មានអាបត្តិ ៣ យ៉ាងនេះ គឺ ភិក្ខុដែលមានបំណងនឹងបំបែកសង្ឃដោយគិតថា "ពួកភិក្ខុទាំងនុ៎ះចូរបាត់ទៅ ពួកភិក្ខុទាំងនុ៎ះចូរវិនាសទៅ ត្រូវការអ្វីដោយភិក្ខុទាំងនោះ" ហើយក៏បវារណា ត្រូវអាបត្តិថុល្លច្ច័យ[២] ភិក្ខុដែលបវារណាជាមួយភិក្ខុដែលសង្ស័យលើកវត្ត ជាអាបត្តិបាចិត្តិយ, បទទាំងឡាយដ៏សេស ជាអាបត្តិទុក្កដ ។

[៥] បទថា តិស្សោ មានសេចក្ដីថា សូម្បីក្នុងចម្មសំយុត្ត ក៏មានអាបត្តិ ៣ យ៉ាងនេះ គឺ ពួកឆព្វគ្គិយភិក្ខុចាប់ជ្រមុជកូនគោទៅក្នុងទឹកឱ្យស្លាប់ ជាអាបត្តិបាចិត្តិយ, មានចិត្តតម្រេកស្ទាបអង្គជាត ជាអាបត្តិថុល្លច្ច័យ[៣] បទទាំងឡាយដ៏សេស ជាអាបត្តិទុក្កដ ។

---

១. វិន. មហា. ឧបោសថក្ខន្ធកៈ. ៦. ១៩៥/៤២៤ ។ ២. វិន. មហា. បវារណាខន្ធកៈ. ៧. ៣៦/១០៩ ។ ៣. វិន. មហា. ចម្មក្ខន្ធកៈ. ៧. ៦១/១៩២ ។

[៦] សូម្បីក្នុងភេសជ្ជក្ខន្ធកៈ ក៏មានអាបត្តិ ៣ យ៉ាងនេះ គឺ ភិក្ខុដែលធ្វើសត្ថកម្មក្នុងទីចង្អៀតប្រមាណ ២ ធ្នាប់ ដោយជុំវិញ (នៃវច្ចមគ្គនិងបស្សាវមគ្គ) ជាអាបត្តិថុល្លច្ច័យ, ឆាន់បបរភោជ្ជ ជាអាបត្តិបាចិត្តិយ,[១] បទទាំងឡាយដ៏សេស ជាអាបត្តិទុក្កដ ។

[៧] កឋិន ព្រះមានព្រះភាគត្រឹមតែទ្រង់បញ្ញត្តិប៉ុណ្ណោះ, មិនមានអាបត្តិក្នុងកឋិនក្ខន្ធកៈនោះ ។

[៨] ក្នុងចីវរសំយុត្ត មានអាបត្តិ ៣ ទាំងនេះ គឺ ជាថុល្លច្ច័យ ព្រោះស្លៀកសំពត់ដែលគេធ្វើពីស្បូវភ្លាំង និងសំពត់ដែលគេធ្វើពីសំបកឈើជាដើម, ជានិស្សគ្គិយបាចិត្តិយ ព្រោះអតិរេកចីវរ[២] បទទាំងឡាយដ៏សេស ជាអាបត្តិទុក្កដ ។

[៩] សូម្បីក្នុងចម្មេយ្យក្ខន្ធកៈ ក៏មានអាបត្តិទុក្កដតែមួយប្រភេទប៉ុណ្ណោះ ។

[១០] សូម្បីក្នុងកោសម្ពិកក្ខន្ធកៈ កម្មក្ខន្ធកៈ បារិវាសិកក្ខន្ធកៈ និងសមុច្ចយក្ខន្ធកៈ ក៏មានអាបត្តិទុក្កដតែមួយប្រភេទប៉ុណ្ណោះ ។

[១៤] ក្នុងសមថក្ខន្ធកៈ មានអាបត្តិ ២ ទាំងនេះ គឺ ភិក្ខុអ្នក

---

១. វិន. មហា. ភេសជ្ជក្ខន្ធកៈ ៧. ១១២/២៩៣ ។

២. វិន. មហា. ចីវរក្ខន្ធកៈ. ៨. ៧៤/១៦៦ ។

ប្រគល់ឆន្ទៈ ត្រឡប់តិះដៀល ត្រូវខិយនកបាចិត្តិយ, បទទាំងឡាយដ៏សេស ជាអាបត្តិទុក្កដ ។

[១៥] ក្នុងខុទ្ទកវត្ថុកខន្ធកៈ មានអាបត្តិ ៣ ទាំងនេះ គឺ ភិក្ខុកាត់អង្គជាតិរបស់ខ្លួន ជាអាបត្តិថុល្លច្ច័យ[១] ខ្លាក់អាហារដែលកើតចេញមកខាងក្រោមាត់ហើយលេបចូលទៅវិញ ជាអាបត្តិបាចិត្តិយ[២] បទទាំងឡាយដ៏សេស ជាអាបត្តិទុក្កដ ។

[១៦] ក្នុងសេនាសនក្ខន្ធកៈ មានអាបត្តិ ៣ ទាំងនេះ គឺ ការបែកគរុភណ្ឌ ជាអាបត្តិថុល្លច្ច័យ[៣] ទាញកន្ទ្រាក់ភិក្ខុទាំងឡាយ ឱ្យចេញចាកវិហារជារបស់សង្ឃ ជាអាបត្តិបាចិត្តិយ[៤] បទទាំងឡាយដ៏សេស ជាអាបត្តិទុក្កដ ។

[១៧] ក្នុងសង្ឃភេទក្ខន្ធកៈ មានអាបត្តិ ២ ទាំងនេះ គឺ ភិក្ខុដែលប្រព្រឹត្តតាមភិក្ខុអ្នកទម្លាយសង្ឃ ជាអាបត្តិថុល្លច្ច័យ[៥] ភិក្ខុឆាន់គណភោជន ជាអាបត្តិបាចិត្តិយ[៦] ។

---

១. វិន. ចុល្ល. ខុទ្ទកវត្ថុកខន្ធកៈ. ១០. ១៣៨/១៤១ ។ ២. វិន. ចុល្ល. ខុទ្ទកវត្ថុកខន្ធកៈ. ១០. ២៥៤/២១១ ។ ៣. វិន. ចុល្ល. សេនាសនក្ខន្ធកៈ. ១០. ៤០៣/៣៤៤ ។ ៤. វិន. ចុល្ល. សេនាសនក្ខន្ធកៈ. ១០. ៣៨៦/៣២៨ ។ ៥. វិន. ចុល្ល. សង្ឃភេទក្ខន្ធកៈ. ១១. ៥៩/៦៨ ។ ៦. វិន. ចុល្ល. សង្ឃភេទក្ខន្ធកៈ. ១១. ៤៦/៥៤ ។

[១៨] ក្នុងវត្តខន្ធកៈ ដែលលោកពោលថា ខ្ញុំនឹងសួរដល់សមាចារ មានអាបត្តិទុក្កដ តែមួយប៉ុណ្ណោះ ។ អាបត្តិទុក្កដនោះ ព្រោះការមិនអើពើក្នុងវត្តទាំងពួង ។

[១៩] ក្នុងបាតិមោក្ខដ្ឋបនក្ខន្ធកៈ ក៏ដូចគ្នា ។

[២០] ក្នុងភិក្ខុនីខន្ធកៈ មានអាបត្តិ ២ ទាំងនេះ គឺ មិនបវារណា ជាអាបត្តិបាចិត្តិយ[១] បទទាំងឡាយដ៏សេស ជាអាបត្តិទុក្កដ ។

[២១] ក្នុងបញ្ចសតិកក្ខន្ធកៈ និងសត្តសតិកក្ខន្ធកៈ លោកលើកធម៌សុទ្ធ ៗ ឡើងកាន់ពួក មិនមានអាបត្តិក្នុងខន្ធកៈទាំង ២ នោះ ដូច្នេះឯង ។

## ខន្ធកបុច្ឆាវណ្ណនា ចប់

១. វិន. ចុល្ល. ភិក្ខុនីខន្ធកៈ. ១១. ២៤៨/៣២៨ ; វិន. ភិក្ខុនី. អារាមវគ្គ. ៥. ៣៥២/៣០៥ ។

# ពណ៌នាឯកុត្តរិកៈ

[២៤] វិនិច្ឆ័យក្នុងឯកុត្តរិកន័យ មានពាក្យថា អាបត្តិករា ធម្មា ជានិតញ្ញា : ភិក្ខុស្គាល់ធម៌ ដែលធ្វើឱ្យមានអាបត្តិ ជាដើម គប្បីជ្រាបដូច្នេះ ៖

## អធិប្បាយពួក ១

អាបត្តិសមុដ្ឋាន ៦ ឈ្មោះថា ធម៌ជាទីកើតអាបត្តិ ។ ពិតមែន បុគ្គលរមែងត្រូវអាបត្តិដោយអំណាចនៃធម៌ទាំងនោះ ព្រោះហេតុនោះ ធម៌ទាំងនោះ លោកទើបពោលថា ធ្វើឱ្យមានអាបត្តិ ។

សមថៈ ៧ ឈ្មោះថា ធម៌ធ្វើមិនឱ្យមានអាបត្តិ ។

ពីរបទថា អាបត្តិ ជានិតញ្ញា បានដល់ គប្បីស្គាល់អាបត្តិដែលលោកពោលទុកក្នុងសិក្ខាបទ និងវិភង្គនោះ ៗ ។

បទថា អនាបត្តិ បានដល់ គប្បីស្គាល់អនាបត្តិដែលព្រះមានព្រះភាគត្រាស់ទុក ដោយន័យជាដើមថា "ម្នាលភិក្ខុ អ្នកឯងមិនត្រូវអាបត្តិទេ ព្រោះមិនត្រេកអរ" ។

បទថា លហុកា បានដល់ គប្បីស្គាល់អាបត្តិ ៥ យ៉ាង ដោយសេចក្តីបរិសុទ្ធិដោយវិន័យកម្មដែលស្រាល ។

បទថា គរុកា បានដល់ គប្បីស្គាល់អាបត្តិសង្ឃាទិសេស ដោយសេចក្តីបរិសុទ្ធិ ដោយវិន័យកម្មដែលធ្ងន់ និងគប្បីស្គាល់អាបត្តិបារាជិក ដោយភាពជាអាបត្តិ ដែលមិនអាចដើម្បីបង្វែរ ចូលទៅកាន់ភាពជាអនាបត្តិ ដោយអាការណា ៗ ។

បទថា សាវសេសា បានដល់ គប្បីស្គាល់អាបត្តិដ៏សេស វៀរបារាជិកចេញ ។

បទថា អនវសេសា បានដល់ អាបត្តិបារាជិក ។

អាបត្តិ ២ កង គ្រោតគ្រាត ។ អាបត្តិដ៏សេស មិនគ្រោតគ្រាត ។

អាបត្តិដែលនៅសម្តែងចេញបាន ២ ពួក ដូចនឹងអាបត្តិដែលមានចំណែកនៅសល់ ២ ពួកអាបត្តិដែលជាទោសនាគាមិនី ២ ពួក រួមចូលនឹងអាបត្តិស្រាល ២ ពួក ។

អាបត្តិទាំង ៧ កង ឈ្មោះថា ធម៌ធ្វើនូវសេចក្តីអន្តរាយ ។ អាបត្តិដែលភិក្ខុក្លែងកន្លងហើយ រមែងធ្វើអន្តរាយដល់សួគ៌, និងនិព្វាន ព្រោះដូច្នោះ អាបត្តិដែលភិក្ខុក្លែងកន្លង ទើបឈ្មោះថា ធ្វើនូវសេចក្តីអន្តរាយ ។

ចំណែកអាបត្តិដែលមានទោសតាមព្រះបញ្ញត្តិ ដែលភិក្ខុមិនដឹង

ហើយប្រព្រឹត្តល្មើស មិនធ្វើអន្តរាយដល់សួគ៌, និងនិព្វានទេ ព្រោះដូច្នោះ អាបត្តិដែលមានទោសតាមព្រះបញ្ញត្តិ ទើបឈ្មោះថា មិនធ្វើអន្តរាយ ។

មគ្គនៃសួគ៌, និងនិព្វាន ដែលអន្តរាយិកាបត្តិមិនហាមហើយ សូម្បីដល់ភិក្ខុដែលត្រូវអន្តរាយិកាបត្តិហើយ សម្តែងអាបត្តិដែលជាទេសនាគាមិនីចេញ ចេញចាកអាបត្តិដែលជាវុដ្ឋានគាមិនី ចេញហើយដល់សេចក្តីបរិសុទ្ធិ និងអ្នកតាំងនៅក្នុងភូមិរបស់សាមណេរ ដូច្នេះឯង ។

អាបត្តិដែលមានទោសមកលោក ឈ្មោះថា អាបត្តិដែលទ្រង់បញ្ញត្តិព្រមទាំងទោស ។

អាបត្តិដែលមានទោសតាមព្រះបញ្ញត្តិ ឈ្មោះថា បណ្ណត្តិវជ្ជៈ (អាបត្តិដែលទ្រង់បញ្ញត្តិ) មិនមានទោស ។

ភិក្ខុធ្វើទើបត្រូវអាបត្តិណា អាបត្តិនោះ ឈ្មោះថា កិរិយា (ត្រូវអាបត្តិព្រោះការធ្វើ) ដូចអាបត្តិបារាជិក ។

ភិក្ខុមិនធ្វើ ត្រូវអាបត្តិណា អាបត្តិនោះ ឈ្មោះថា អកិរិយា (ត្រូវអាបត្តិ ព្រោះមិនធ្វើ) ដូចអាបត្តិដែលត្រូវព្រោះមិនអធិដ្ឋានចីវរ ។

ភិក្ខុធ្វើផង មិនធ្វើផង រមែងត្រូវអាបត្តិណា អាបត្តិនោះ ឈ្មោះថា កិរិយាកិរិយា (ត្រូវអាបត្តិព្រោះធ្វើនិងមិនធ្វើ) ដូចអាបត្តិក្នុងកុដិការសិក្ខាបទ ។

អាបត្តិដែលត្រូវដំបូង ឈ្មោះថា បុព្វាបត្តិ ; អាបត្តិដែលភិក្ខុនៅបរិវាសជាដើមត្រូវខាងក្រោយ ឈ្មោះថា អបរាបត្តិ ។

អន្តរាបត្តិនៃវិធីជម្រះឱ្យបរិសុទ្ធិ ដែលសង្ឃឱ្យក្នុងអាបត្តិដើម ឈ្មោះថា អន្តរាបត្តិនៃបុព្វាបត្តិទាំងឡាយ ។

អន្តរាបត្តិនៃវិធីជម្រះឱ្យបរិសុទ្ធិ ពោលគឺ អគ្ឃសមោធាន ឈ្មោះថា អន្តរាបត្តិនៃអបរាបត្តិ ។

ចំណែកក្នុងកុរុន្ទីពន្យល់ថា អាបត្តិដែលត្រូវមុន ឈ្មោះថា បុព្វាបត្តិ អាបត្តិដែលត្រូវក្នុងវេលាដែលគួរដល់មានត្ត ឈ្មោះថា អបរាបត្តិ អាបត្តិដែលត្រូវក្នុងបរិវាស ឈ្មោះថា អន្តរាបត្តិនៃបុព្វាបត្តិ អាបត្តិដែលត្រូវក្នុងខណៈប្រព្រឹត្តមានត្ត ឈ្មោះថា អន្តរាបត្តិនៃអបរាបត្តិ ។ សូម្បីពាក្យនេះ ក៏ត្រូវដោយបរិយាយតែមួយ ។

អាបត្តិណា ដែលភិក្ខុធ្វើសេចក្ដីដាក់ធុរៈ សម្ដែងចេញដោយតាំងចិត្តថា យើងនឹងមិនត្រូវទៀត អាបត្តិនោះ ឈ្មោះថា អាបត្តិដែលខ្លួនសម្ដែងហើយ ជាអាបត្តិគួរដល់កិរិយារាប់ គឺ ដាក់ធុរៈចេញបាន ។

អាបត្តិណា ដែលភិក្ខុមិនធ្វើការដាក់ធុរៈ សម្ដែងចេញ ដោយចិត្តដែលនៅមានសេចក្ដីអង់អាច មិនបរិសុទ្ធិតែម្ដង អាបត្តិនោះ ឈ្មោះថា អាបត្តិដែលខ្លួនសម្ដែងហើយ តែមិនគួរដល់កិរិយារាប់ គឺដាក់ធុរៈចេញបាន ។

ពិតមែន អាបត្តិនេះ សូម្បីសម្តែងហើយ ក៏មិនរាប់បញ្ចូលក្នុងចំនួនអាបត្តិដែលសម្តែងហើយ ។

ក្នុងវត្ថុទី ៨ រមែងជាបារាជិក ដល់ភិក្ខុនី ។

ក្នុង៩ បទ មានបទថា បញ្ញត្តិ ជាដិតញ្ញា : ភិក្ខុស្គាល់បញ្ញត្តិជាដើម គប្បីជ្រាបវិនិច្ឆ័យ តាមន័យដែលពោលហើយ ក្នុងការសួរដល់បឋមបារាជិកនុ៎ះឯង ។

អាបត្តិធ្ងន់ ដែលទ្រង់បញ្ញត្តិព្រោះទោសធ្ងន់ ឈ្មោះថា ថុល្លវជ្ជា ( អាបត្តិមានទោសធ្ងន់ ) ។

អាបត្តិស្រាល ឈ្មោះថា អថុល្លវជ្ជា ( អាបត្តិមានទោសមិនធ្ងន់ ) ។

អាបត្តិរបស់ព្រះសុធម្មត្ថេរ និងអាបត្តិដែលត្រូវព្រោះក្លែងធ្វើពាក្យទទួលដែលប្រកបដោយធម៌ឱ្យឃ្លៀងឃ្លាត ឈ្មោះថា គិហិបដិសញ្ញុត្តា[1] ( អាបត្តិជាប់ដោយគ្រហស្ថ ) ។

អាបត្តិទាំងឡាយដ៏សេស ឈ្មោះថា ន គិហិបដិសញ្ញុត្តា ( អាបត្តិមិនជាប់ដោយគ្រហស្ថ ) ។

អាបត្តិដែលរាប់ថា ជាអនន្តរិយកម្ម ៥ ឈ្មោះថា និយតា

១. ភូមា. គិហិបដិសំយុត្តា ។

( អាបត្តិដែលទៀង គឺអ្នកត្រូវអនន្តរិយកម្ម ៥ ទៀងតែធ្លាក់នរក ) ។ អាបត្តិដ៏សេសឈ្មោះថា **អនិយតា** អាបត្តិមិនទៀង ។

ភិក្ខុដែលជាដើមបញ្ញត្តិ មានព្រះសុទិន្នត្ថេរជាដើម ឈ្មោះថា **អាទិកម្មិកោ** ( ភិក្ខុដែលធ្វើខុសខាងដើមបញ្ញត្តិ ) ។

ភិក្ខុដែលបង្កអនុប្បញ្ញត្តិ មានព្រះមក្កដីសមណៈជាដើម ឈ្មោះថា **អនាទិកម្មិកោ** ( ភិក្ខុអ្នកមិនបានធ្វើខុសខាងដើមបញ្ញត្តិ ) ។

ភិក្ខុណា ត្រូវអាបត្តិក្នុងពេលខ្លះ គ្រាខ្លះ ភិក្ខុនោះ ឈ្មោះថា **អធិច្ចាបត្តិកោ** ( អ្នកត្រូវអាបត្តិមិនបានជានិច្ច ) ។

ភិក្ខុណា ត្រូវជានិច្ច ភិក្ខុនោះ ឈ្មោះថា **អភិណ្ហាបត្តិកោ** ( អ្នកត្រូវអាបត្តិរឿយ ៗ ) ។

ភិក្ខុណា ចោទភិក្ខុដទៃដោយវត្ថុឬអាបត្តិ ភិក្ខុនោះ ឈ្មោះថា **ចោទកោ** ( អ្នកចោទ ) ។ ចំណែកភិក្ខុណា ត្រូវគេចោទយ៉ាងនោះ ភិក្ខុនេះ ឈ្មោះថា **ចុទិតកោ** ( អ្នកជាប់ចោទ ) ។

ភិក្ខុដែលមិនតាំងនៅក្នុងធម៌ ១៥ ប្រការ ចោទដោយវត្ថុ មិនពិត ឈ្មោះថា **អធម្មចោទកោ** ( បុគ្គលអ្នកចោទមិនត្រូវតាមធម៌ ) ។ ភិក្ខុអ្នកជាប់ចោទត្រូវអ្នកចោទនោះ ចោទយ៉ាងនោះ ឈ្មោះថា **អធម្មចុទិតកោ** ( បុគ្គលដែលគេចោទមិនត្រូវតាមធម៌ ) ។

អ្នកចោទនិងអ្នកជាប់ចោទដែលត្រូវតាមធម៌ គប្បីជ្រាបដោយបរិយាយដែលផ្ទុយគ្នា ។

បុគ្គលអ្នកប្រកបដោយធម៌ទាំងឡាយ ដែលទៀងដោយភាពជាធម៌ខុសក្តី ដែលទៀងដោយភាពជាធម៌ត្រូវក្តី ឈ្មោះថា **និយតោ** ( និយតបុគ្គល ) ។ បុគ្គលដែលផ្ទុយពីនេះ ឈ្មោះថា **អនិយតោ** ( អនិយតបុគ្គល ) ។

សាវកទាំងឡាយ ឈ្មោះថា **ភព្វាបត្តិកា** ( បុគ្គលដែលគួរដល់អាបត្តិ ) ។ ព្រះពុទ្ធនិងព្រះបច្ចេកពុទ្ធទាំងឡាយ ឈ្មោះថា **អភព្វាបត្តិកា** ( បុគ្គលដែលមិនគួរដល់អាបត្តិ ) ។

បុគ្គលដែលត្រូវសង្ឃធ្វើឧក្ខេបនីយកម្ម ឈ្មោះថា **ឧក្ខិត្តកោ** ( អ្នកត្រូវសង្ឃធ្វើឧក្ខេបនីយកម្ម គឺ លើកវត្ត ) ។

បុគ្គលដែលត្រូវសង្ឃធ្វើកម្ម ៤ យ៉ាងដ៏សេស មានតជ្ជនីយកម្មជាដើម ឈ្មោះថា **អនុក្ខិត្តកោ** អ្នកមិនត្រូវសង្ឃលើកវត្ត ។

ពិតមែន ភិក្ខុដែលត្រូវសង្ឃធ្វើតជ្ជនីយកម្មជាដើមនេះ មិនញ៉ាំងឧបោសថ ឬបវារណា ឬធម្មបរិភោគ ឬអាមិសបរិភោគ ឱ្យកម្រើក ។

ចំពោះបុគ្គលដែលព្រះមានព្រះភាគឱ្យវិនាសចេញ ដោយលិង្គនាសនា ទណ្ឌកម្មនាសនា និងសំវាសនាសនា យ៉ាងនេះថា ម្នាល

ភិក្ខុទាំងឡាយ បើដូច្នោះអ្នកទាំងឡាយ ចូរឱ្យមេត្តិយាភិក្ខុនីសឹកចេញ, សង្ឃត្រូវឱ្យវិនាសតែអ្នកដែលប្រទូស្ត, ម្នាលភិក្ខុទាំងឡាយ បើដូច្នោះ សង្ឃចូរញ៉ាំងកណ្ឌកសមណុទ្ទេសឱ្យវិនាសចុះ, ដូច្នេះ ឈ្មោះថា អ្នកត្រូវនាសនា បុគ្គលទាំងពួងដ៏សេស ឈ្មោះថា អ្នកមិនត្រូវនាសនា ។

ធម៌ដែលជាទីនៅរួមគ្នា មានឧបោសថជាដើម មានជាមួយនឹងបុគ្គលណា បុគ្គលនេះ ឈ្មោះថា អ្នកមានសំវាសស្មើគ្នា ។ បុគ្គលក្រៅនោះ ឈ្មោះថា អ្នកមានសំវាសផ្សេងគ្នា ។

បុគ្គលដែលមានសំវាសផ្សេងគ្នានោះ មាន ២ ពួក គឺ កម្មនានាសំវាសពួកមួយ លទ្ធិនានាសំវាសពួកមួយ ។

ពីរបទថា ឋបនំ ជានិតព្វំ មានសេចក្ដីថា គប្បីជ្រាបការវៀរបាដិមោក្ខ ដែលព្រះមានព្រះភាគត្រាស់ទុកដោយន័យជាដើមថា "ម្នាលភិក្ខុទាំងឡាយ ការបញ្ឈប់បាដិមោក្ខមិនប្រកបដោយធម៌ ១"[១] ដូច្នេះ ឯង ។

ពណ៌នាពួក ១ ចប់

១. វិន. ចុល្ល. បាតិមោក្ខដ្ឋបនក្ខន្ធកៈ. ១១. ១៣២/២១៩ ។

# អធិប្បាយពួក ២

[២៦] វិនិច្ឆ័យក្នុងពួក ២ គប្បីជ្រាបដូច្នេះ ៖

អាបត្តិជាសចិត្តកៈ ជាសញ្ញាវិមោក្ខ អាបត្តិជាអចិត្តកៈ ជានោសញ្ញាវិមោក្ខ ។

អាបត្តិព្រោះប្រាប់ឧត្តរិមនុស្សធម៌ដែលមានពិត ឈ្មោះថា **អាបត្តិដែលត្រូវដល់ភិក្ខុដែលបានសមាបត្តិ** ។

អាបត្តិព្រោះអួតឧត្តរិមនុស្សធម្មដែលមិនពិត ឈ្មោះថា **អាបត្តិដែលត្រូវដល់ភិក្ខុដែលមិនបានសមាបត្តិ** ។

អាបត្តិក្នុងបទសោធម្មសិក្ខាបទជាដើម ឈ្មោះថា **អាបត្តិដែលប្រកបទើងសទ្ធម្ម** ។

អាបត្តិព្រោះទុដ្ឋុល្លវាចា ឈ្មោះថា **អាបត្តិដែលប្រកបទើងអសទ្ធម្ម** ។

អាបត្តិព្រោះបរិភោគបរិក្ខារដែលមិនគួរយ៉ាងនេះ គឺ ព្រោះមិនលះបង់វត្ថុជានិស្សគ្គិយចេញមុនបរិភោគ ព្រោះហាលបាត្រ និងចីវរទុកយូរ ព្រោះមិនបោកគក់ចីវរដែលកខ្វក់ ព្រោះមិនដុតបាត្រដែលប្រេះចាប់ ឈ្មោះថា **អាបត្តិដែលប្រកបទើងគ្រឿងបរិក្ខាររបស់ខ្លួន** ។

អាបត្តិដែលគប្បីត្រូវ ព្រោះចេញទៅដោយមិនប្រាប់ មិនប្រើឱ្យ

រើយកបរិក្ខារមានគ្រែនិងតាំងជាដើមរបស់សង្ឃ ដែលទុកក្នុងទីវាលជាដើម មកទុកដាក់ ឈ្មោះថា **អាបត្តិដែលប្រកបនឹងគ្រឿងបរិក្ខាររបស់បុគ្គលដទៃ** ។

អាបត្តិដែលព្រះមានព្រះភាគ ត្រាស់ទុកដោយន័យជាដើមថា ជាអាបត្តិដល់ភិក្ខុអ្នកមានខ្នងទន់ អ្នកមានអង្គជាតិយាវវែង អ្នកញៀតអង្គជាតិដោយភ្លៅ ឈ្មោះថា **អាបត្តិដែលប្រកបនឹងបុគ្គល គឺ ខ្លួនឯង** ។

អាបត្តិដែលព្រះមានព្រះភាគត្រាស់ ក្នុងមេថុនធម្ម កាយសំសគ្គៈនិងការវាយជាដើម ឈ្មោះថា **អាបត្តិដែលប្រកបនឹងបុគ្គល គឺអ្នកដទៃ** ។

ភិក្ខុកាលនិយាយពិតថា មេសិខិវណី រមែងត្រូវអាបត្តិធ្ងន់ ។ កាលនិយាយកុហក រមែងត្រូវអាបត្តិស្រាល ដោយព្រះបាលីថា "ភិក្ខុពោលពាក្យកុហកដោយដឹងខ្លួន ត្រូវអាបត្តិបាចិត្តិយ" ។

កាលនិយាយកុហក ព្រោះអួតឧត្តរិមនុស្សធម៌ដែលមិនមានពិត ត្រូវអាបត្តិធ្ងន់ ។ កាលនិយាយពិត ព្រោះប្រាប់ឧត្តរិមនុស្សធម៌ដែលមានពិត ត្រូវអាបត្តិស្រាល ។

ភិក្ខុកាលអង្គុយនៅក្នុងចំណែកមួយខាង ក្នុងសីមា ដោយតាំងចិត្តថា យើងនឹងធ្វើសង្ឃកម្មជាពួក ឈ្មោះថា **នៅលើផែនដីត្រូវអាបត្តិ** ។

ក៏បើថា លោកគប្បីតាំងនៅក្នុងអាកាស សូម្បីត្រឹមតែមួយឆ្នាប់ មិនគប្បីត្រូវ; ព្រោះដូច្នោះ លោកទើបពោលថា **នៅលើអាកាស មិនត្រូវអាបត្តិក៏មាន ។**

កាលភិក្ខុអង្គុយសង្កត់ លើគ្រែ ឬតាំងដែលមានជើងស៊កក្នុងមេលើផ្ទៃ (ថ្នាក់ខ្ពស់) ដែលថា នៅក្នុងអាកាសត្រូវអាបត្តិ ។ ក៏បើថា លោកគប្បីតាំងគ្រែ និងតាំងនោះលើផែនដីហើយ ទើបដេកមិនគប្បីត្រូវ; ព្រោះដូច្នោះ លោកទើបពោលថា **នៅលើផែនដី មិនត្រូវអាបត្តិក៏មាន ។**

ភិក្ខុដែលត្រៀមទីងទៅ កាលមិនញ៉ាំងគមិយវត្តឱ្យពេញ ហើយចេញទៅ ឈ្មោះថា **ភិក្ខុដើរចេញទៅត្រូវអាបត្តិ ដើរចូលមក មិនត្រូវអាបត្តិ ។**

ភិក្ខុអាគន្តុកៈ មិនញ៉ាំងអាគន្តុកវត្តឱ្យពេញ បាំងឆត្រ ពាក់ស្បែកជើងចូលទៅ ឈ្មោះថា **ដើរចូលមកត្រូវអាបត្តិ ដើរចេញទៅ មិនត្រូវអាបត្តិ ។**

ភិក្ខុនី កាលកាន់យកការជម្រះឱ្យស្អាតដោយទឹក ជ្រៅពេកទៅ ឈ្មោះថា **កាន់យកត្រូវអាបត្តិ ។**

ចំណែកភិក្ខុ កាលមិនកាន់យកពណ៌សម្រាប់ធ្វើឱ្យសៅហ្មង ប្រើ

ប្រាស់ចីវរ ឈ្មោះថា **មិនកាន់យកត្រូវអាបត្តិ ។**

កាលសមាទានវត្តរបស់តិរិយ មានមូគវត្តជាដើម ឈ្មោះថា **សមាទានត្រូវអាបត្តិ ។**

ចំណែកភិក្ខុដែលនៅបរិវាសជាដើមក្តី អ្នកត្រូវសង្ឃធ្វើតជ្ជនីយកម្មជាដើមក្តី កាលមិនសមាទានវត្តរបស់ខ្លួន ឈ្មោះថា **មិនសមាទានត្រូវអាបត្តិ ។**

ពាក្យដែលថា មានអាបត្តិ ភិក្ខុមិនសមាទាន រមែងត្រូវ ដូច្នេះ លោកពោលសំដៅយកភិក្ខុទាំងនោះ ។

ភិក្ខុដេរចីវររបស់ភិក្ខុនីមិនមែនញាតិក្តី ធ្វើវេជ្ជកម្ម ភណ្ឌាគារិកកម្មនិងចិត្រកម្មក្តី ឈ្មោះថា **ធ្វើត្រូវអាបត្តិ ;** អ្នកមិនធ្វើឧបជ្ឈាយ៍វត្តជាដើម ឈ្មោះថា **មិនធ្វើត្រូវអាបត្តិ ។**

ភិក្ខុដែលឱ្យចីវរដល់ភិក្ខុនីដែលមិនមែនញាតិ ឈ្មោះថា **ឱ្យត្រូវអាបត្តិ ។**

កាលមិនឱ្យបរិក្ខារមានចីវរជាដើមដល់សទ្ធិវិហារិក និងអន្តេវាសិក ឈ្មោះថា **មិនឱ្យត្រូវអាបត្តិ ។**

កាលកាន់យកចីវររបស់ភិក្ខុនី ដែលមិនមែនញាតិ ឈ្មោះថា **ទទួលត្រូវអាបត្តិ ។**

កាលមិនកាន់យកនូវឱវាទ ដោយព្រះបាលីថា ភិក្ខុទាំងឡាយ ឱវាទដែលភិក្ខុនីមិនគប្បីទទួលមិនបាន ដូច្នេះ ឈ្មោះថា **មិនទទួលត្រូវអាបត្តិ** ។

កាលមិនលះបង់និស្សគ្គិយវត្ថុមុនបរិភោគ ឈ្មោះថា **ត្រូវអាបត្តិព្រោះបរិភោគ** ។

កាលញ៉ាំងវារៈនៃសង្ឃាដិឱ្យកន្លងហួស ៥ ថ្ងៃទៅ ឈ្មោះថា **ត្រូវអាបត្តិ ព្រោះមិនបរិភោគ** ។

ឈ្មោះថា **ត្រូវអាបត្តិតែក្នុងវេលាយប់** ព្រោះដេកក្នុងផ្ទះរួមគ្នា ។ កាលមិនបិទទ្វារពួនសម្ងំ ឈ្មោះថា **ត្រូវអាបត្តិតែក្នុងវេលាថ្ងៃ មិនត្រូវក្នុងវេលាយប់** ។

កាលត្រូវអាបត្តិដែលត្រាស់ទុក ព្រោះឈានកន្លង ១ រាត្រី ៦ រាត្រី ៧ ថ្ងៃ ១០ ថ្ងៃ និងមួយខែ ឈ្មោះថា **ត្រូវអាបត្តិក្នុងវេលាអរុណរះ** ។

កាលហាមភត្តហើយឆាន់ ឈ្មោះថា **ត្រូវអាបត្តិក្នុងវេលាអរុណមិនទាន់រះ** ។

កាលកាត់នូវភូតគាម និង អង្គជាតិ ឈ្មោះថា **កាត់ត្រូវអាបត្តិ** ។

កាលមិនកោរសក់ និង មិនកាត់ក្រចក ឈ្មោះថា **មិនកាត់ត្រូវ**

អាបត្តិ ។

កាលបិទអាបត្តិទុក ឈ្មោះថា **បិទបាំងត្រូវអាបត្តិ** ។ និងឈ្មោះថា **មិនបិទបាំងត្រូវអាបត្តិនេះ** (ដែលព្រះមានព្រះភាគត្រាស់) ថា "ភិក្ខុនោះ ត្រូវបិទបាំង (រាងកាយ) ដោយស្មៅ ឬ ស្លឹកឈើហើយសឹមមក មិនត្រូវដើរមកទាំងអាក្រាតកាយឡើយ ភិក្ខុឯណាមក ភិក្ខុនោះ ត្រូវអាបត្តិទុក្កដ"[១] ។

កាលទ្រទ្រង់ទុកនូវសំពត់ដែលគេធ្វើពីស្បូវភ្លាំងជាដើម ឈ្មោះថា **ទ្រទ្រង់ ត្រូវអាបត្តិ** ។

ឈ្មោះថា **មិនទ្រទ្រង់ត្រូវអាបត្តិនេះ** (ដែលព្រះមានព្រះភាគត្រាស់) ថា "ម្នាលភិក្ខុ នេះបាត្ររបស់លោក, លោកគប្បីប្រើប្រាស់ត្រាតែបែក"[២] ។

[២៧] ពាក្យថា **អត្តនា វា អត្តានំ នានាសំវាសកំ ករោតិ** មានសេចក្តីថា កាលសង្ឃ ២ ពួក អង្គុយក្នុងសីមាជាមួយគ្នា ភិក្ខុអង្គុយក្នុងពួកមួយ កាន់យកលទ្ធិរបស់ពួកមួយទៀត ឈ្មោះថា **ភិក្ខុធ្វើខ្លួនឯងឱ្យមានសំវាសផ្សេងគ្នារបស់ភិក្ខុទាំងឡាយនោះ** ក្នុងពួកដែលខ្លួន

---

១. វិន. ទិស្ស. ចីវរវគ្គ. ៣. ៥៤/៥៤ ។

២. វិន. ទិស្ស. បត្តវគ្គ. ៣. ១៣០/១៥៨ ។

អន្ទ័យនោះ ។ ភិក្ខុអន្ទ័យក្នុងសំណាក់របស់ភិក្ខុ ពួកណាហើយ សូម្បីជាគណបូរកៈរបស់ភិក្ខុទាំងនោះ ឈ្មោះថា **រមែងញ៉ាំងកម្មឱ្យកម្រើកព្រោះខ្វះនមិនមកចូលហត្ថបាសរបស់ពួកមួយទៀត** ។

សូម្បីក្នុងសមានសំវាសកៈ ក៏មានន័យដូចគ្នា ។ ពិតមែន ភិក្ខុនោះ ពេញចិត្តក្នុងលទ្ធិរបស់ពួកណា រមែងជាសមានសំវាសកៈរបស់ភិក្ខុទាំងនោះ ជានានាសំវាសកៈរបស់ពួកមួយទៀត ។

[២៨] ពាក្យថា សត្ត អាបត្តិយោ សត្ត អាបត្តិក្ខន្ធា : **រួមជាអាបត្តិ ៧ គឺកងនៃអាបត្តិទាំង ៧** មានសេចក្ដីថា ពួក ២ (នៃអាបត្តិ) ដែលព្រះមានព្រះភាគទ្រង់សម្ដែងដោយអំណាចនៃឈ្មោះថា មាន ២ ឈ្មោះប៉ុណ្ណោះ យ៉ាងនេះ គឺ ឈ្មោះថា **អាបត្តិ** ព្រោះជាវិតិក្កមៈ ដែលនឹងគប្បីត្រូវ ឈ្មោះថា កង ព្រោះអត្ថថា ជាទីនៅ ។

វិនិច្ឆ័យក្នុងពាក្យថា កម្មេន វា សលាកគ្គាហេន វា : **ដោយកម្ម ១ ដោយការចាប់ស្លាក ១** នេះ គប្បីជ្រាបដូច្នេះ ៖

ឧទ្ទេសនិងកម្មតែមួយ ។ វោហារអនុស្សាវនា និងការចាប់ស្លាកក៏តែមួយដូចគ្នា ។ វោហារអនុស្សាវនានិងការចាប់ស្លាក ជាបុព្វភាគ ។ កម្មនិងឧទ្ទេសជាសំខាន់ ។

[២៩] បុគ្គលអ្នកមានអាយុមិនទាន់គ្រប់ ២០ ឆ្នាំ ឈ្មោះថា

បុគ្គលសាបសូន្យចាកកាល ។ បុគ្គលអ្នកមានបញ្ញាទោសដោយប្រភេទផ្សេង ៗ មានមនុស្សកំបុតដៃជាដើម ឈ្មោះថា បុគ្គលសាបសូន្យចាកអវយវៈ ។

បណ្ឌកៈ សត្វតិរច្ឆាន និងឧភតោព្យញ្ជនកៈ ឈ្មោះថា បុគ្គលជាវត្ថុវិបត្តិ ។

អភព្វបុគ្គល ៨ ដ៏សេស មានអ្នកលួចសំវាសជាដើម ឈ្មោះថា បុគ្គលធ្លាប់ធ្វើអំពើអាក្រក់ ។

អ្នកមានកម្មដែលខ្លួនធ្វើឱ្យខូច ឈ្មោះថា បុគ្គលធ្លាប់ធ្វើអំពើអាក្រក់ ។ អធិប្បាយថា អ្នកដល់ឋាននៃអភព្វបុគ្គល ព្រោះកម្មរបស់ខ្លួនដែលធ្វើដោយខ្លួនឯងក្នុងអត្តភាពនេះតែម្តង ។

អ្នកមានបាត្រចីវរមិនគ្រប់ ឈ្មោះថា បុគ្គលមានបរិក្ខារមិនគ្រប់គ្រាន់ ។ បុគ្គល( មានបរិក្ខារគ្រប់គ្រាន់ហើយ តែ ) មិនសូមឧបសម្បទា ឈ្មោះថា បុគ្គល មិនសូម( ឧបសម្បទា ) ។

ពីរបទថា អលជ្ជិស្ស ច ពាលស្ស ច : បុគ្គលជាអលជ្ជី ១ បុគ្គលពាល ១ មានសេចក្តីថា ភិក្ខុអលជ្ជីសូម្បីថា ជាអ្នកទ្រទ្រង់ព្រះត្រៃបិដក ភិក្ខុពាល សូម្បីថា ជាអ្នកមានវស្សា ៦០ ដែលភិក្ខុមិនគប្បីអាស្រ័យនៅទាំង ២ ។

វិនិច្ឆ័យក្នុងពាក្យថា ពាលស្ស ច លជ្ជិស្ស ច យាចតិ នេះ គប្បីជ្រាបដូច្នេះ ៖

និស្ស័យដែលបុគ្គលអ្នកឱ្យនិស្ស័យ គប្បីឱ្យសូម្បីដោយបង្គាប់បញ្ជាថា លោកចូរកាន់និស្ស័យក្នុងសំណាក់ភិក្ខុដែលល្ងង់ ។ តែគប្បីឱ្យដល់ភិក្ខុលជ្ជីអ្នកសូមពិត ។

បទថា សាតិសារំ : ដែលប្រកបដោយទោសយ៉ាងធំ មានសេចក្តីថា កាលប្រព្រឹត្តកន្លងវត្ថុណា រមែងត្រូវអាបត្តិវត្ថុនោះ ឈ្មោះថា ប្រព្រឹត្តទៅព្រមដោយទោស ។

ការជំទាស់ ដោយកាយវិការ មានហត្ថវិការជាដើម ឈ្មោះថា ជំទាស់ដោយកាយ ។

[៣០] ពាក្យថា កាយេន វា បដិជានាតិ : ហាមឃាត់ដោយកាយ បានដល់ បដិញ្ញាដោយកាយវិការមានហត្ថវិការជាដើម ។

ការចូលទៅធ្វើការប្រេះស្រាយ ឈ្មោះថា ការបៀតបៀន ។

ការចូលទៅធ្វើការប្រេះស្រាយនូវសិក្ខា ឈ្មោះថា ការបៀតបៀនសិក្ខា ។

ការចូលទៅធ្វើការប្រេះស្រាយនូវភោគៈ ឈ្មោះថា ការបៀតបៀនគ្រឿងបរិភោគ ។

ក្នុងបណ្ដា ២ យ៉ាងនោះ គប្បីជ្រាបការបៀតបៀនសិក្ខារបស់ភិក្ខុដែលមិនសិក្សាសិក្ខា ៣ ។ គប្បីជ្រាបការបៀតបៀនភោគៈរបស់ភិក្ខុដែលប្រើប្រាស់គ្រឿងបរិភោគរបស់សង្ឃ ឬ របស់បុគ្គលវិនាសអស់ទៅ ។

[៣១] ពាក្យថា ទ្វេ វេនយិកា : **អត្ថរបស់វិន័យមាន ២ យ៉ាង** បានដល់ អត្ថ ២ យ៉ាង សម្រេចក្នុងវិន័យ ។

វិន័យដែលព្រះមានព្រះភាគទ្រង់បញ្ញត្តិ ដោយអំណាចវត្ថុដែលគួរនិងមិនគួរក្នុងវិន័យបិដកទាំងអស់ ឈ្មោះថា **បញ្ញត្តិ** ។ ដែលឈ្មោះថា **បញ្ញត្តានុលោម** គប្បីឃើញក្នុងមហាបទេស ៤ ។

ការបំផ្លាញបច្ច័យ ឈ្មោះថា សម្លាប់នូវបច្ច័យក្នុងអកប្បិយវត្ថុ, អធិប្បាយថា ភិក្ខុគប្បីធ្វើកម្មដែលមិនគួរ ដោយចិត្តណា ការដែលមិនញ៉ាំងចិត្តនោះឱ្យកើតឡើង ឈ្មោះថា **ការសម្លាប់នូវបច្ច័យក្នុងអកប្បិយវត្ថុ** ។

ការធ្វើដោយប្រមាណ គឺ ដោយល្មមសមគួរ អធិប្បាយថា សេចក្ដីតាំងនៅក្នុងសេចក្ដីល្មមសមគួរ ឈ្មោះថា **ការធ្វើប្រមាណក្នុងកប្បិយវត្ថុ** ។

[៣២] ពាក្យថា កាយេន អាបជ្ជតិ : **ត្រូវដោយកាយ** មាន

សេចក្តីថា ត្រូវអាបត្តិដែលកើតអំកាយទ្វារ ដោយកាយ ។ ត្រូវអាបត្តិដែលកើតតាមវចីទ្វារ ដោយវាចា ។

ពាក្យថា កាយេន វុដ្ឋាតិ មានសេចក្តីថា សូម្បីវៀរការសម្តែងក្នុងតិណវត្ថារកសមថៈចេញ ឈ្មោះថា **ចេញចាកដោយកាយ** ។ តែកាលសម្តែងហើយចេញ ឈ្មោះថា **ចេញចាកដោយវាចា** ។

[៣៣] បរិភោគដោយការលេបចូល ឈ្មោះថា **អព្ភន្តរបរិភោគ** (បរិភោគលេបចូលទៅ) ។ ការលាបសីសៈជាដើម ឈ្មោះថា **ពាហិរបរិភោគ** (ប្រើប្រាស់ខាងក្រៅ) ។

[៣៤] ពាក្យថា អនាគតំ ភារំ វហតិ : **បុគ្គលដែលនាំភារៈមិនទាន់មក** មានសេចក្តីថា ភិក្ខុមិនមែនជាថេរៈ តែនាំភារៈមានកាន់ផ្លិតនិងអាវាធនាឱ្យសម្តែងធម៌ជាដើម ដែលព្រះថេរៈទាំងឡាយនឹងគប្បីនាំ គឺផ្តើមព្យាយាមប្រុងទទួលភារៈនោះ ។

ពាក្យថា អាគតំ ភារំ ន វហតិ : **បុគ្គលដែលមិននាំភារៈដែលមកហើយ** មានសេចក្តីថា ភិក្ខុដែលជាថេរៈ តែមិនធ្វើកិច្ចរបស់ព្រះថេរៈ, អធិប្បាយថា ឱ្យសាបសូន្យនូវកិច្ចទាំងពួងមានជាដើមយ៉ាងនេះថា "ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឱ្យភិក្ខុជាថេរៈសម្តែងធម៌ខ្លួន

ឯង ឬអារាធនាភិក្ខុដទៃបាន[១] ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតបាដិមោក្ខមានព្រះថេរៈជាធំ[២]” ។

[៣៥] ពាក្យថា ន កុក្កុច្ចាយិតព្វំ កុក្កុច្ចាយតិ : បុគ្គលដែលសង្ស័យចំពោះហេតុដែលមិនគួរសង្ស័យ មានសេចក្តីថា ប្រព្រឹត្តរង្កៀស ធ្វើវត្ថុដែលមិនគួររង្កៀស ។

ពាក្យថា កុក្កុច្ចាយិតព្វំ ន កុក្កុច្ចាយតិ : បុគ្គលដែលមិនសង្ស័យចំពោះហេតុដែលគួរសង្ស័យ មានសេចក្តីថា ភិក្ខុមិនប្រព្រឹត្តរង្កៀសធ្វើវត្ថុដែលគួររង្កៀស, អធិប្បាយថា អាសវៈទាំងឡាយ តែងចម្រើនដល់បុគ្គល ២ ពួក នេះឯង[៣] រមែងចម្រើនកពូនទាំងថ្ងៃ ទាំងយប់ ។

សេចក្តីសួម្បីក្នុងពួក ២ ដែលជាលំដាប់ទៅ គប្បីជ្រាបដោយអំណាចនៃសេចក្តី ដែលផ្ទុយគ្នានឹងការពោលហើយ ។

បទដ៏សេស រាប់ថា មានសេចក្តីច្បាស់ទាំងអស់នោះឯង ព្រោះមានន័យដូចពោលហើយក្នុងបទនោះ ៗ ។

ពណ៌នាពួក ២ ចប់

១. វិន. មហា. ឧបោសថក្ខន្ធកៈ. ៦. ១៦៨/៣៦៩ ។ ២. វិន. មហា. ឧបោសថក្ខន្ធកៈ. ៦. ១៧៤/៣៧៥ ។ ៣. អង្គុ. ទុក. ពាលវគ្គ. ៤០. ៣៥៣/១៩១ ។

# អធិប្បាយពួក ៣

វិនិច្ឆ័យក្នុងពួក ៣ គប្បីជ្រាបដូច្នេះ ៖

[៣៧] ត្រើនបទថា អត្ថាបត្តិ តិដ្ឋន្តេ ភគវតិ អាបជ្ជតិ : ភិក្ខុត្រូវអាបត្តិតែក្នុងកាលដែលព្រះមានព្រះភាគគង់នៅ មានសេចក្តីថា កាលព្រះមានព្រះភាគនៅមានព្រះជន្ម ភិក្ខុទើបត្រូវអាបត្តិណា អាបត្តិនោះមាន ។ មានន័យដូចគ្នាគ្រប់បទ ។

បណ្តាអាបត្តិទាំងនោះ ភិក្ខុត្រូវអាបត្តិតែក្នុងកាលដែលព្រះមានព្រះភាគគង់នៅ ព្រោះលោហិតុប្បាទ ។ ភិក្ខុត្រូវអាបត្តិតែក្នុងកាលដែលព្រះមានព្រះភាគបរិញ្វានហើយ កាលដែលព្រះអង្គគង់នៅឡើយ មិនត្រូវអាបត្តិ ព្រោះហៅព្រះថេរៈដោយពាក្យថា **អាវុសោ** ជាបច្ច័យ ព្រោះព្រះពុទ្ធដីកាថា "ម្នាលអានន្ទ ក៏ក្នុងកាលសព្វថ្ងៃនេះ ពួកភិក្ខុហៅគ្នានឹងគ្នាដោយពាក្យថា **អាវុសោ** អំណើះឥតតថាគតទៅ អ្នកទាំងឡាយ កុំហៅយ៉ាងនេះទៀតឡើយ, ម្នាលអានន្ទ ភិក្ខុចាស់ជាង ត្រូវហៅភិក្ខុខ្ចីជាងដោយគោត្រ ក៏បាន ដោយពាក្យថា **អាវុសោ** ក៏បាន; ចំណែកភិក្ខុខ្ចីជាងត្រូវហៅភិក្ខុចាស់ជាងថា **ភន្តេ** ក៏បាន ថា **អាយស្មា** ក៏បាន"[១] ដូច្នេះ ។

---

១. ទីឃ. សីល. មហាបរិនិព្វានសូត្រ. ១៤. ១៤១/៣២០ ។

ភិក្ខុត្រូវអាបត្តិទាំងក្នុងកាលដែលព្រះអង្គគង់នៅ ទាំងក្នុងកាលដែលព្រះអង្គបរិព្វានហើយ វៀរអាបត្តិទាំង ២ នេះចេញ ភិក្ខុរមែងត្រូវអាបត្តិដ៏សេស ។

កាលហាមហើយ ឆាន់របស់ទំពា របស់ឆាន់ ដែលមិនជារបស់សល់ ឈ្មោះថា ត្រូវអាបត្តិតែក្នុងកាល មិនត្រូវក្នុងវិកាលទេ ។ អាបត្តិព្រោះវិកាលភោជន ឈ្មោះថា ត្រូវអាបត្តិតែក្នុងវិកាល មិនត្រូវក្នុងកាលទេ ។ អាបត្តិដ៏សេស រមែងត្រូវទាំងក្នុងកាលទាំងក្នុងវិកាល ។

ក្នុងវេលាយប់ រមែងត្រូវអាបត្តិព្រោះដេកក្នុងផ្ទះរួមគ្នា, ក្នុងវេលាថ្ងៃ រមែងត្រូវអាបត្តិព្រោះមិនបិទទ្វារពួនសម្ងំ ( ដេក ) ។ ទាំងវេលាយប់ទាំងវេលាថ្ងៃ រមែងត្រូវអាបត្តិដ៏សេស ។

ភិក្ខុពាល មិនឆ្លាត កាលឱ្យបរិស័ទឧបដ្ឋាក ដោយគិតថា យើងមានវស្សា ១០ យើងមានវស្សាច្រើនជាង ១០ ភិក្ខុមានវស្សា ១០ ត្រូវអាបត្តិ, មានវស្សាខ្វះពី ១០ មិនត្រូវអាបត្តិ ។

ភិក្ខុថ្មីឬកណ្តាល កាលឱ្យបរិស័ទឧបដ្ឋាក ដោយគិតថា យើងជាបណ្ឌិត យើងជាអ្នកឆ្លាត ភិក្ខុមានវស្សាខ្វះពី ១០ ត្រូវអាបត្តិ មានវស្សា ១០ មិនត្រូវអាបត្តិ ។

ទាំងភិក្ខុមានវស្សា ១០ ទាំងភិក្ខុមានវស្សាខ្វះពី ១០ រមែងត្រូវ

អាបត្តិដ៏សេស ។

ភិក្ខុពាល មិនឆ្លាត កាលមិនកាន់និស្ស័យ ដោយគិតថា យើងមានវស្សាគ្រប់ ៥ ភិក្ខុមានវស្សា ៥ ត្រូវអាបត្តិ ។

ភិក្ខុថ្មីមិនកាន់និស្ស័យ ដោយគិតថា យើងជាបណ្ឌិត ជាអ្នកឆ្លាតមានវស្សាខ្វះពី ៥ ត្រូវអាបត្តិ ។ ទាំងភិក្ខុមានវស្សា ៥ ទាំងភិក្ខុមានវស្សាខ្វះពី ៥

រមែងត្រូវអាបត្តិដ៏សេស ។ ភិក្ខុមានចិត្តជាកុសល ត្រូវអាបត្តិ គឺត្រូវអាបត្តិព្រោះបង្រៀនធម៌ជាបទចំពោះអនុបសម្បន្ន, សម្តែងធម៌ដល់មាតុគ្រាម ។

ភិក្ខុមានចិត្តជាអកុសល ត្រូវអាបត្តិ គឺ អាបត្តិច្រើនប្រភេទ មានបាពជិក, សុក្កវិសដ្ឋិ, កាយសំសគ្គៈ, ទុដ្ឋុល្លៈ, អត្តកាមបារិចរិយា, ទុដ្ឋទោសៈ, សង្ឃភេទៈ, បហារទានៈ, តលសត្តិកៈ ជាដើម ។

ភិក្ខុមានចិត្តជាអព្យាក្រិត ត្រូវអាបត្តិ គឺ មានការមិនក្លែងដេកក្នុងផ្ទះរួមគ្នាជាដើម ។ ព្រះអរហន្ត រមែងត្រូវអាបត្តិណា ភិក្ខុដែលមានចិត្តជាអព្យាក្រិត រមែងត្រូវអាបត្តិនោះទាំងអស់ ។

ភិក្ខុមានចិត្តប្រកបដោយសុខវេទនា ត្រូវអាបត្តិ គឺ អាបត្តិច្រើនប្រភេទ មានមេថុនធម្មជាដើម ។ ភិក្ខុមានចិត្តប្រកបដោយសុខវេទនា រមែងត្រូវអាបត្តិណា ភិក្ខុដែលមានខ្លួនមជ្ឈត្ត( ព្រងើយ ) ក៏ត្រូវអាបត្តិ

នោះដែរ ឈ្មោះថា **ភិក្ខុមានចិត្តប្រកបដោយអទុក្ខមសុខវេទនា ត្រូវអាបត្តិ** ។

[៣៨] ពាក្យថា **តយោ បដិក្ខេបា : បំរាម ៣ យ៉ាង** មានសេចក្តីថា ការហាម ៣ យ៉ាងរបស់ព្រះមានព្រះភាគ គឺ ជាអ្នកប្រាថ្នាច្រើន ជាអ្នកមិនសន្តោសក្នុងបច្ច័យ ៤ សេចក្តីមិនរក្សាការបដិបត្តិដែលជុសខាត់កិលេស, ធម៌ ៣ យ៉ាងទាំងនេះឯង ដែលព្រះមានព្រះភាគទ្រង់ហាមហើយ ។

ចំណែកធម៌ ៣ យ៉ាង មានអ្នកប្រាថ្នាតិចជាដើម ដែលព្រះមានព្រះភាគទ្រង់អនុញ្ញាតហើយ ។ ព្រោះហេតុនោះ លោកទើបពោលថា ធម៌ ៣ យ៉ាងទ្រង់អនុញ្ញាត ។

[៣៩] ភិក្ខុឱ្យបរិស័ទឧបដ្ឋាក ដោយគិតថា យើងមានវស្សាគ្រប់ ១០ មិនកាន់និស្ស័យដោយគិតថា យើងមានវស្សាគ្រប់ ៥ **ភិក្ខុពាលត្រូវអាបត្តិ ភិក្ខុជាបណ្ឌិតមិនត្រូវអាបត្តិ** ។

អ្នកមានវស្សាខ្វះពី ១០ គិតថា យើងជាអ្នកឆ្លាត កាលឱ្យបរិស័ទឧបដ្ឋាក ព្រោះភាពជាពហុស្សូត និងភិក្ខុមានវស្សាខ្វះពី ៥ មិនកាន់និស្ស័យ **ភិក្ខុជាបណ្ឌិតត្រូវអាបត្តិ ភិក្ខុពាលមិនត្រូវអាបត្តិ** ។

ទាំងអ្នកឆ្លាត ទាំងអ្នកល្ងង់ រមែងត្រូវអាបត្តិដ៏សេស ។

កាលមិនចូលវស្សា ភិក្ខុត្រូវអាបត្តិក្នុងកាឡបក្ខ មិនត្រូវក្នុងជុណ្ហបក្ខ ។ កាលមិនបវារណាក្នុងថ្ងៃមហាបវារណា ភិក្ខុត្រូវអាបត្តិក្នុងជុណ្ហបក្ខ មិនត្រូវក្នុងកាឡបក្ខ ។ រមែងត្រូវអាបត្តិ ដ៏សេសទាំងក្នុងកាឡបក្ខនិងជុណ្ហបក្ខ ។

ការចូលវស្សា រមែងសម្រេចក្នុងកាឡបក្ខ មិនគួរក្នុងជុណ្ហបក្ខ ។

បវារណាក្នុងថ្ងៃមហាបវារណា រមែងគួរក្នុងជុណ្ហបក្ខ មិនគួរក្នុងកាឡបក្ខ ។

សង្ឃកិច្ចដែលទ្រង់អនុញ្ញាតដ៏សេសផ្សេងទៀត រមែងគួរទាំងក្នុងកាឡបក្ខ និងជុណ្ហបក្ខ ។

ភិក្ខុស្លៀកសំពត់ងូតទឹកភ្លៀង ដែលវិកប្បរក្សាទុកក្នុងថ្ងៃបាដិបទក្រោយពីថ្ងៃពេញបូរមីខែកត្តិក ភិក្ខុត្រូវក្នុងហេមន្តរដូវ ។

តែក្នុងកុរុន្ទីពោលថា មិនដកក្នុងថ្ងៃពេញបូណ៌មីខែកត្តិក រមែងត្រូវក្នុងហេមន្តរដូវ ។ ពាក្យក្នុងអដ្ឋកថាកុរុន្ទីនោះ លោកពោលប្រពៃ ។ ព្រោះព្រះមានព្រះភាគបានត្រាស់ទុកថា "(ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាត)ឱ្យអធិដ្ឋានសំពត់សម្រាប់ងូតទឹកភ្លៀងអស់ ៤ ខែនៃរដូវភ្លៀង បន្ទាប់អំពីកាល ៤ ខែនោះទៅ ត្រូវវិកប្បទុក"[១] ។

១. វិន. មហា. ចីវរក្ខន្ធកៈ. ៨. ៦៦/១៤៣ ។

កាលរដូវក្តៅនៅសល់ជាង ១ ខែ ភិក្ខុស្វែងរក និងកាលរដូវក្តៅនៅសល់ជាងកន្លះខែ ភិក្ខុស្លៀក ឈ្មោះថា **ត្រូវអាបត្តិក្នុងគិម្ហរដូវ** ។

កាលមានសំពត់ងូតទឹកភ្លៀង តែអាក្រាតកាយងូតទឹកភ្លៀង ឈ្មោះថា **ត្រូវអាបត្តិក្នុងវស្សានរដូវ** ។

សង្ឃកាលធ្វើបារិសុទ្ធិឧបោសថ ឬ អធិដ្ឋានឧបោសថ សង្ឃត្រូវអាបត្តិ ។

គណៈកាលធ្វើសុត្តុទ្ទេស និងអធិដ្ឋានឧបោសថ គណៈត្រូវអាបត្តិ ។

ភិក្ខុតែមួយរូប កាលធ្វើសុត្តុទ្ទេស បុគ្គលត្រូវអាបត្តិ ។

សូម្បីក្នុងបវារណាក៏ន័យនេះដែរ ។

សង្ឃឧបោសថ និងសង្ឃបវារណា រមែងសម្រេចដល់សង្ឃប៉ុណ្ណោះ ។

គណៈឧបោសថ និងគណៈបវារណា រមែងសម្រេចដល់គណៈប៉ុណ្ណោះ ។

អធិដ្ឋានឧបោសថ និងអធិដ្ឋានបវារណា រមែងសម្រេចដល់បុគ្គលប៉ុណ្ណោះ ។

## ការបិទ ៣ យ៉ាងជាដើម

[៤០] កាលពោលពាក្យថា "ខ្ញុំត្រូវអាបត្តិបារាជិក"ជាដើម ឈ្មោះថា ភិក្ខុបិទបាំងវត្ថុ មិនបិទបាំងអាបត្តិ ។

កាលពោលពាក្យថា "ខ្ញុំបានសេពមេថុនធម្ម" ជាដើម ឈ្មោះថា ភិក្ខុបិទបាំងអាបត្តិ មិនបិទបាំងវត្ថុ ។

ភិក្ខុណា មិនប្រាប់វត្ថុ មិនប្រាប់អាបត្តិ, ភិក្ខុនេះ ឈ្មោះថា បិទបាំងទាំងវត្ថុ ទាំងអាបត្តិ ។

ដែលឈ្មោះថា ទីកំបាំង ព្រោះបិទបាំងទុក ។

ទីកំបាំង គឺ ពេងភ្លើង ឈ្មោះថា គ្រឿងបិទបាំង គឺ ផ្ទះជាទីរក្សាកាយ ។ សូម្បីក្នុងទីបិទបាំងក្រៅនេះ ក៏មានន័យដូចគ្នា ។

ភិក្ខុដែលបិទទ្វារនៅខាងក្នុងពេងភ្លើង គួរធ្វើបរិកម្ម ។ សូម្បីភិក្ខុដែលឋិតនៅក្នុងទឹក ក៏គួរធ្វើបរិកម្មនោះដូចគ្នា ។ តែមិនគួរទំពាឬឆាន់ក្នុងស្ថានទាំង ២ ។

របស់ដែលបិទបាំង គឺ សំពត់ គួរក្នុងទីទាំងពួង ។

ភិក្ខុដែលបិទបាំង (កាយ) ដោយរបស់បិទបាំង គឺ សំពត់នោះហើយ សមគួរធ្វើកិច្ចទាំងពួង ។

បទថា វហន្តិ : ប្រព្រឹត្តទៅស្រួល មានសេចក្តីថា រមែងទៅ គឺ

រមែងចេញទៅ បានដល់ មិនបានសេចក្តីតិះដៀលឬពាក្យជំទាស់ ។ ព្រះចន្ទផុតពីពពក អ័ព្ទ ផែ្សង ធូលី និងរាហូហើយ ស្រឡះល្អ រមែងរុងរឿង, កាលវត្ថុទាំងនោះណាមួយកំបាំងហើយ រមែងមិនរុងរឿង ។ ព្រះអាទិត្យក៏ដូចគ្នា ។ សូម្បីធម្មវិន័យដែលភិក្ខុបើកបង្ហាញ គឺ សម្តែងចេញនោះឯង ទើបរុងរឿង, បិទបាំងទុកមិនរុងរឿងទេ ។

## អាបត្តិដែលភិក្ខុអាពាធត្រូវជាដើម

[៤១] ភិក្ខុអាពាធ កាលសូមភេសជ្ជៈដទៃ ក្រៅពីភេសជ្ជៈដែលចាំបាច់ត្រូវធ្វើ ឈ្មោះថា **ភិក្ខុឈឺត្រូវអាបត្តិ** ។

ភិក្ខុមិនមានអាពាធ កាលសូមភេសជ្ជៈ ក្នុងកាលមិនចាំបាច់ត្រូវធ្វើដោយភេសជ្ជៈ ឈ្មោះថា **ភិក្ខុមិនឈឺត្រូវអាបត្តិ** ។

អាបត្តិដ៏សេស ឈ្មោះថា **ទាំងភិក្ខុឈឺ ទាំងភិក្ខុមិនឈឺត្រូវអាបត្តិ** ។

[៤៣] ពាក្យថា អន្តោ អាបជ្ជតិ នោ ពហិ មានសេចក្តីថា កាលសម្រេចការដេក ចូលទៅប្រៀតបៀត (ភិក្ខុចូលទៅមុន) ឈ្មោះថា **ភិក្ខុនៅខាងក្នុងត្រូវអាបត្តិ នៅខាងក្រៅ មិនត្រូវ** ។ ពាក្យថា ពហិ អាបជ្ជតិ នោ អន្តោ មានសេចក្តីថា កាលតាំង និងគ្រែជាដើមរបស់

សង្ឃទុកក្នុងទីវាលហើយជៀសចេញទៅ ឈ្មោះថា **នៅខាងក្រៅត្រូវអាបត្តិ នៅខាងក្នុងមិនត្រូវ ។** អាបត្តិដ៏សេស ឈ្មោះថា **ត្រូវអាបត្តិទាំងខាងក្នុងទាំងខាងក្រៅ ។**

ពាក្យថា **អន្តោ សីមាយ** មានសេចក្តីថា ភិក្ខុអាគន្តុកៈ កាលមិនសម្តែងអាគន្តុកវត្ត បាំងឆត្រ ពាក់ស្បែកជើង ចូលកាន់វិហារ ល្មមត្រឹមតែចូលឧបចារសីមា ក៏ត្រូវ ឈ្មោះថា **ភិក្ខុនៅខាងក្នុងសីមា ត្រូវអាបត្តិ ។** ពាក្យថា **ពហិ សីមាយ** មានសេចក្តីថា ភិក្ខុត្រៀមនឹងទៅ កាលមិនបំពេញគមិកវត្ត មានរក្សាទុកដាក់ភណ្ឌៈឈើជាដើម ជៀសទៅ តែល្មមឈានកន្លងឧបចារសីមាក៏ត្រូវ ឈ្មោះថា **ភិក្ខុនៅខាងក្រៅសីមា ត្រូវអាបត្តិ ។** ត្រូវអាបត្តិដ៏សេស ឈ្មោះថា **ត្រូវអាបត្តិ ទាំងខាងក្នុងសីមាទាំងខាងក្រៅសីមា ។**

## អាបត្តិដែលត្រូវក្នុងកណ្តាលសង្ឃជាដើម

[៤៤] កាលភិក្ខុដែលចាស់ជាងមាន ភិក្ខុមិនបានទទួលអារាធនាពោលធម៌ ឈ្មោះថា **ត្រូវក្នុងកណ្តាលសង្ឃ ។** **ក្នុងកណ្តាលគណៈក្តី ក្នុងសំណាក់នៃបុគ្គលក្តី** ក៏ន័យនេះឯង ។

ចេញ (ចាកពីអាបត្តិ) ដោយតិណវត្ថារកសមថៈ ឈ្មោះថា

ចេញចាកដោយកាយ ។

កាលភិក្ខុមិនញុំាងកាយឱ្យញ័រ សម្តែងដោយវាចា អាបត្តិ ឈ្មោះថា ចេញចាកដោយវាចា ។

កាលធ្វើកិរិយាតាមមកកាយប្រែកបទីងវាចា សម្តែងអាបត្តិ ឈ្មោះថា ចេញចាកដោយកាយនិងវាចា ។

អាបត្តិដែលជាទេសនាគាមិនី និងជាវុដ្ឋានគាមិនី ឈ្មោះថា ចេញចាកក្នុងកណ្តាលសង្ឃ ។ តែអាបត្តិជាទេសនាគាមិនីប៉ុណ្ណោះ ឈ្មោះថា ចេញចាកក្នុងកណ្តាលគណៈ និងក្នុងសំណាក់នៃបុគ្គល ។

## អង្គជាហេតុដាក់ទោសនិងបន្ថែមទោស

[៤៥] ពីរបទថា អាគាឡ្ហាយ ចេតេយ្យ : គប្បីលៃលកដើម្បីសេចក្តីមាំមួន មានសេចក្តីថា សង្ឃគប្បីតាំងចិត្តដើម្បីសេចក្តីតឹងរឹង គឺ ដើម្បីសេចក្តីមាំទាំ, អធិប្បាយថា សង្ឃកាលប្រាថ្នា គប្បីដាក់ឧក្ខេបនីយកម្ម ដល់ភិក្ខុដែលត្រូវសង្ឃដាក់តជ្ជនីយកម្មជាដើម ហើយមិនញុំាងវត្តឱ្យពេញ ។

ក្នុងពាក្យថា អលជ្ជី ច ហោតិ ពាលោ ច អបកតត្តោ ច : ភិក្ខុជាអ្នកឥតមានខ្មាស ១ ភិក្ខុល្ងង់ ១ មិនមែនជាបកតត្ត ១ នេះ

មានសេចក្តីថា មិនគប្បីដាក់ទោសដោយហេតុត្រឹមតែប៉ុណ្ណោះថា អ្នកនេះជាមនុស្សល្ងង់ មិនស្គាល់ធម៌និងអធម៌ ឬថា អ្នកនេះ មិនមែនបកតត្តមិនស្គាល់អាបត្តិនិងមិនមែនអាបត្តិ ។ គប្បីដាក់ទោសដល់ភិក្ខុដែលត្រូវអាបត្តិ ដែលជាមនុស្សល្ងង់ជាមូល និងមានភាពមិនមែនអ្នកបកតត្តជាមូល ។

អ្នកត្រូវអាបត្តិ ២ កង ឈ្មោះថា **ភិក្ខុជាអ្នកមានសីលវិបត្តិក្នុងអធិសីល** ។

អ្នកត្រូវអាបត្តិ ៥ កង ឈ្មោះថា **មានអាចារវិបត្តិក្នុងអជ្ឈាចារ** ។

អ្នកប្រកបដោយអន្តគាហិកទិដ្ឋិ ឈ្មោះថា **មានទិដ្ឋិវិបត្តិក្នុងអតិទិដ្ឋិ** ។

គប្បីដាក់ទោសដល់ភិក្ខុទាំងនោះ ដែលមិនឃើញ មិនសម្តែងអាបត្តិ និងមិនព្រមលះបង់ទិដ្ឋិប៉ុណ្ណោះ ។

អនាចារៈផ្សេង ៗ មានលេងល្បែងភ្នាល់ជាដើម ដោយគ្រឿងលេងមានបាសា[1]ជាដើម ឈ្មោះថា **ភិក្ខុជាអ្នកប្រកបខាងល្បែងដោយកាយ** ។

អនាចារផ្សេង ៗមានធ្វើភ្លេងមាត់ជាដើម ឈ្មោះថា **ជាអ្នកប្រកប**

---

១. បាសកាទីហិ, បាសក = ដាក់គ្រាប់កាក់ - លេងបាស្កា ។

ខានល្បែងដោយវាចា ។

អនាចារតាមទ្វារទាំង ២ ដោយប្រភេទផ្សេង ៗ មានរាំ ប្រគំ និង ច្រៀងជាដើម ឈ្មោះថា ជាអ្នកប្រកបខានល្បែងដោយកាយនិងវាចា ។

ការប្រព្រឹត្តិកន្លងសិក្ខាបទដែលទ្រង់បញ្ញត្តិក្នុងកាយទ្វារ ឈ្មោះថា អ្នកប្រកបដោយមារយាទ មិនមានសណ្តាប់ធ្នាប់ដោយកាយ ។

ការប្រព្រឹត្តិកន្លងសិក្ខាបទ ដែលទ្រង់បញ្ញត្តិក្នុងវចីទ្វារ ឈ្មោះថា អ្នកប្រកបដោយមារយាទ មិនមានសណ្តាប់ធ្នាប់ដោយវាចា ។

ការប្រព្រឹត្តិកន្លងសិក្ខាបទដែលទ្រង់បញ្ញត្តិក្នុងទ្វារទាំង ២ ឈ្មោះថា អ្នកប្រកបដោយមារយាទ មិនមានសណ្តាប់ធ្នាប់ដោយកាយនិងវាចា ។

ពីរបទថា កាយិកេន ឧបឃាតិកេន បានដល់ ដោយការមិនសិក្សាសិក្ខាបទដែលទ្រង់បញ្ញត្តិក្នុងកាយទ្វារ ។

ពិតមែន ភិក្ខុណាមិនសិក្សាសិក្ខាបទនោះ ភិក្ខុនោះឈ្មោះថា បៀតបៀនសិក្ខាបទនោះ ។ ព្រោះហេតុនោះ ការមិនសិក្សានោះរបស់ភិក្ខុនោះ លោកទើបពោលថា ការបៀតបៀនដោយកាយ ។ សូម្បីក្នុងអន្ត ២ ដ៏សេស ក៏ន័យនេះឯង ។

ពាក្យថា កាយិកេន មិច្ឆាជីវេន : មិច្ឆាទិដ្ឋិដោយកាយ បានដល់ ដោយការទទួលជាខ្ញុំបម្រើរបស់គ្រហស្ថ មាននាំដំណឹងជាដើមក្តី ដោយវេជ្ជកម្ម មានវះបូសជាដើមក្តី ។

បទថា វាចសិកេន : ដោយវាចា បានដល់ ដោយទទួលឬប្រាប់ដំណឹង (របស់គ្រហស្ថ)ជាដើម ។ បទទី ៣ លោកពោលដោយអំណាចប្រកបបទទាំង ២ ចូលជាមួយគ្នា ។

ច្រើនបទថា អលំ ភិក្ខុ មា ភណ្ឌនំ : ម្នាលភិក្ខុ មិនគួរទេ អ្នកកុំបង្ក ហេតុ មានសេចក្តីថា នែភិក្ខុកុំឡើយ លោកកុំធ្វើការបង្កហេតុ កុំឈ្លោះគ្នា កុំទាស់ទែងគ្នា កុំធ្វើការវិវាទគ្នាឡើយ[1] ។

បទថា ន វោហរិតព្វំ : មិនត្រូវស្តីពោលរក បានដល់ មិនគប្បីពោលអ្វីឡើយ ។

ពិតមែន ភិក្ខុទាំងឡាយ រមែងមិនសម្គាល់ (នូវន័យ) ដែលនឹងគប្បីស្តាប់ពាក្យរបស់ភិក្ខុដូច្នោះសូម្បីថា កំពុងពោល ។

ពាក្យថា ន កិស្មិញ្ចិ បច្ចេកដ្ឋានេ : មិនត្រូវតម្កល់ទុកក្នុងតំណែងផ្សេងណាមួយ មានសេចក្តីថា (ភិក្ខុដែលប្រកបដោយអង្គ ៣

១. វិន. មហា. បវារណាខន្ធកៈ. ៧. ៤៣/១២៨ ។

គឺ ជាអលជ្ជីជាដើម ) ដែលសង្ឃមិនគប្បីតាំងទុកក្នុងតំណែងណា ៗ គឺ សូម្បីតំណែងតែមួយ មានកាន់ផ្តិត ( អនុមោទនា ) ជាដើម ។

ពីរបទថា ឱកាសំ ការាបេន្តស្ស : ដែលមកសូមឱកាស មានសេចក្តីថា ( ភិក្ខុដែលប្រកបដោយអង្គ ៣ គឺ ជាអលជ្ជីជាដើម ) ដែលសូមឱកាសយ៉ាងនេះថា សូមលោកឱ្យឱកាស ខ្ញុំចង់និយាយនឹងលោក ។

ពាក្យថា នាលំ ឱកាសកម្មំ កាតុំ : មិនត្រូវធ្វើឱកាសកម្ម មានសេចក្តីថា ឱកាសដែលភិក្ខុមិនគប្បីធ្វើថា លោកនឹងធ្វើអ្វី ? ដូច្នេះ ។

ពាក្យថា សវចនីយំ នាទាតព្វំ : មិនត្រូវជឿស្តាប់ពាក្យ មានសេចក្តីថា ពាក្យឆ្លើយ មិនគួរជឿតាម គឺ សូម្បីពាក្យក៏មិនគួរស្តាប់ មិនគួរទៅក្នុងទីដែលលោកប្រាប្ថានឹងជាប់តាមខ្លួនទៅ ។

ច្រើនបទថា តីហាង្គេហិ សមន្នាគតស្ស ភិក្ខុនោ វិនយោ : ភិក្ខុមិនត្រូវសួរវិន័យចំពោះភិក្ខុដែលប្រកបដោយអង្គ ៣ មានសេចក្តីថា ភិក្ខុនោះ រមែងដឹងវិន័យណា វិន័យនោះ រមែងជាវិន័យរបស់លោក វិន័យនោះ ដែលសង្ឃមិនគប្បីសួរ ។

ពីរបទថា អនុយោគោ ន ទាតព្វោ : ភិក្ខុមិនត្រូវឱ្យការសាកសួរ មានសេចក្តីថា សង្ឃមិនគប្បីឱ្យឱកាសដើម្បីសួរ ដល់ភិក្ខុពាលនោះ អ្នកសួរថា នេះ គួរឬ ? លោកដែលសង្ឃគប្បីឆ្លើយថា ចូរសួរ

ភិក្ខុដទៃ ។ សួម្បីភិក្ខុណា រមែងសួរភិក្ខុនោះ ភិក្ខុនោះ ដែលភិក្ខុអ្នកបណ្ឌិតគប្បីពោលថា លោកចូរសួរភិក្ខុដទៃ ព្រោះហេតុនោះ ភិក្ខុពាលនោះ ដែលភិក្ខុដទៃមិនគប្បីសួរសោះឡើយ គឺ ពាក្យសួររបស់ភិក្ខុពាលនោះ ដែលអ្នកណា ៗ មិនគប្បីស្តាប់ ។

ពីរបទថា វិនយោ ន សាកច្ឆិតព្វោ : ភិក្ខុមិនត្រូវសាកច្ឆាវិន័យ មានសេចក្តីថា បញ្ហាវិន័យដែលអ្នកណា ៗ មិនគប្បីសន្ទនា គឺ រឿងដែលគួរ ឬមិនគួរ ក៏មិនគប្បីសន្ទនា ( នឹងភិក្ខុពាលនោះ ) ។

## បុគ្គលទៅកាន់អបាយ ៣ ពួកជាដើម

[៤៦] ពីរបទថា ឥទមប្បហាយ : ព្រោះមិនលះលទ្ធិនេះចេញបានដល់ មិនលះបង់លទ្ធិមានអ្នកបដិញ្ញាថា ខ្លួនជាព្រហ្មចារីបុគ្គលជាដើមនោះ ។

ពីរបទថា សុទ្ធំ ព្រហ្មចារឹ : ព្រហ្មចារីបុគ្គលដ៏បរិសុទ្ធ បានដល់ភិក្ខុខីណាស្រព ។

ពីរបទថា ធាតព្យតំ អាបជ្ជតិ : តែងដល់នូវការសេពគប់ បានដល់ ជាអ្នកធ្លាក់ទៅ គឺការសេព ។

តែព្រោះព្រះបាលីថា ឥទមប្បហាយ បុគ្គលនោះ គប្បីលះសេចក្តីប្តេជ្ញាថា "ខ្ញុំនជាព្រហ្មចារីបុគ្គល" នោះចេញ ហើយសូមខមាទោសចំពោះព្រះវិញ្ញូណាស្រេពថា "ខ្ញុំពោលកុហក សូមលោកអត់ទោសដល់ខ្ញុំ" ហើយលះបង់ទិដ្ឋិដែលថា "ទោសក្នុងកាមទាំងឡាយមិនមាន" ចេញ ធ្វើការជម្រះគតិឱ្យស្អាត ។

អកុសលទាំងឡាយផង ឫសគល់ទាំងឡាយផង ឈ្មោះថា អកុសលមូល ;ម្យ៉ាងទៀត ឫសគល់របស់អកុសលទាំងឡាយ ឈ្មោះថា អកុសលមូល ។ សូម្បីក្នុងកុសលមូល ក៏ន័យនេះដែរ ។

ការប្រព្រឹត្តអាក្រក់ ឬការប្រព្រឹត្តខុស ឈ្មោះថា ទុច្ចរិត ។

ការប្រព្រឹត្តរៀបរយ ឬការប្រព្រឹត្តល្អ ឈ្មោះថា សុចរិត ។

ទុច្ចរិត ដែលធ្វើតាមមកកាយ ឈ្មោះថា កាយទុច្ចរិត ។

ក្នុងបទទាំងពួង ក៏ន័យនេះឯង ។ ពាក្យដ៏សេស រាប់ថា ច្បាស់លាស់ហើយ ព្រោះមានន័យដូចពោលហើយ ក្នុងទីនោះ ៗ ដូច្នេះឯង ។

ពណ៌នាពួក ៣ ចប់

# ពណ៌នាពួក ៤

## ប្រភេទរបស់អាបត្តិ

[៤៨] វិនិច្ឆ័យក្នុងពួក ៤ គប្បីជ្រាបដូច្នេះ ៖

ពាក្យថា សកវាចាយ អាបជ្ជតិ បរវាចាយ វុដ្ឋាតិ : មានសេចក្តីថា ភិក្ខុត្រូវអាបត្តិដោយប្រភេទផ្សេង ៗ មានបទសោធម្មាបត្តិជាដើម ជាប់ដោយវចីទ្វារ ដល់ស្ថានដែលរម្ងាប់ដោយតិណវត្ថារកៈហើយ ឈ្មោះថា ភិក្ខុត្រូវអាបត្តិដោយវាចារបស់ខ្លួន ចេញចាកអាបត្តិដោយវាចារបស់អ្នកដទៃ ។

ពាក្យថា បរវាចាយ អាបជ្ជតិ សកវាចាយ វុដ្ឋាតិ មានសេចក្តីថា ភិក្ខុត្រូវដោយកម្មវាចារបស់ភិក្ខុដទៃ ព្រោះមិនព្រមលះបង់ទិដ្ឋិលាមក កាលសម្តែងក្នុងសំណាក់របស់បុគ្គល ឈ្មោះថា ភិក្ខុត្រូវអាបត្តិដោយវាចារបស់អ្នកដទៃ ចេញចាកអាបត្តិ ដោយវាចារបស់ខ្លួន ។

ពាក្យថា សកវាចាយ អាបជ្ជតិ សកវាចាយ វុដ្ឋាតិ មានសេចក្តីថា ភិក្ខុត្រូវអាបត្តិផ្សេង ៗ មានបទសោធម្មាបត្តិជាដើម ជាប់ដោយវចីទ្វារដោយវាចារបស់ខ្លួន សូម្បីកាលសម្តែងចេញហើយ ដោយ

ខ្លួនឯង ឈ្មោះថា ភិក្ខុត្រូវអាបត្តិដោយវាចារបស់ខ្លួន ចេញចាកអាបត្តិដោយវាចារបស់ខ្លួន ។

ពាក្យថា បរវាចាយ អាបជ្ជតិ បរវាចាយ វុដ្ឋាតិ មានសេចក្តីថា ភិក្ខុត្រូវអាបត្តិសង្ឃាទិសេស មានសុចក្ខសមនុភាសនៈ ៣ ជង ដោយកម្មវាចារបស់អ្នកដទៃ សូម្បីកាលចេញ ក៏ដូចគ្នា ឈ្មោះថា ភិក្ខុត្រូវអាបត្តិដោយវាចារបស់អ្នកដទៃ ចេញចាកអាបត្តិ ដោយវាចារបស់អ្នកដទៃ មានបរិវាសកម្មវាចាជាដើម ។

វិនិច្ឆ័យក្នុងចតុក្កៈពួកដទៃបន្ទាប់អំពីបឋមចតុក្កៈនោះ គប្បីជ្រាបដូច្នេះ ៖

ភិក្ខុត្រូវអាបត្តិដែលប្រព្រឹត្តទៅតាមកាយទ្វារ ដោយកាយ កាលសម្តែងចេញ ឈ្មោះថា ត្រូវអាបត្តិដោយកាយ ចេញដោយវាចា ។

ត្រូវអាបត្តិដែលប្រព្រឹត្តទៅតាមវចីទ្វារ ដោយវាចា ឈ្មោះថា ត្រូវអាបត្តិដោយវាចា ចេញដោយកាយ ព្រោះតិណវត្ថារកសមថៈ ។

ត្រូវអាបត្តិដែលប្រព្រឹត្តទៅតាមកាយទ្វារ ដោយកាយ ឈ្មោះថា រមែងចេញចាកអាបត្តិ ដែលប្រព្រឹត្តទៅតាមកាយទ្វារនោះឯង ដោយកាយ ព្រោះតិណវត្ថារកសមថៈ ឈ្មោះថា ត្រូវអាបត្តិដោយកាយ ចេញ

ដោយកាយ ។

ត្រូវអាបត្តិដែលប្រព្រឹត្តទៅតាមវចីទ្វារ កាលសម្តែងអាបត្តិនោះឯងចេញ ដោយវាចា ឈ្មោះថា ត្រូវអាបត្តិដោយវាចា ចេញដោយវាចា ។

ភិក្ខុដែលដេកលក់ រមែងត្រូវអាបត្តិតាមចំនួននៃពេម ព្រោះកាយពាល់ត្រូវគ្រែរបស់សង្ឃ ដែលមិនក្រាលដោយកម្រាលរបស់ខ្លួន និងអាបត្តិដែលគប្បីត្រូវព្រោះដេកក្នុងផ្ទះរួមគ្នា ។ និងកាលភ្ញាក់ហើយដឹងថាខ្លួនត្រូវហើយសម្តែងចេញ ឈ្មោះថា ភិក្ខុដេកលក់ត្រូវអាបត្តិ ភ្ញាក់ឡើងចេញចាកអាបត្តិ តែកាលភ្ញាក់ត្រូវហើយ ដេកក្នុងស្ថានទីរម្ងាប់ដោយតិណវត្ថារកៈ ឈ្មោះថា ភិក្ខុភ្ញាក់ឡើងត្រូវអាបត្តិ ដេកលក់ទៅវិញចេញចាកអាបត្តិ ។ សុម្បី ២ បទខាងក្រោយ ក៏គប្បីជ្រាបដោយទំនងដែលពោលហើយនុ៎ះឯង ។

ភិក្ខុដែលមិនមានសេចក្តីតាំងចិត្ត ឈ្មោះថា ភិក្ខុមិនមានចិត្តត្រូវអាបត្តិ ។ កាលសម្តែងចេញខាងក្រោយ ឈ្មោះថា ប្រកបដោយចិត្តចេញចាកអាបត្តិ ។

ភិក្ខុដែលមានសេចក្តីតាំងចិត្ត ឈ្មោះថា ភិក្ខុមានចិត្តត្រូវអាបត្តិ ។

លោកដេកនៅក្នុងស្ថានទីរម្ងាប់ ដោយតិណវត្ថារកៈ ឈ្មោះថា មិនមានចិត្តចេញចាកអាបត្តិ ។ សូម្បី ២ បទដ៏សេស ក៏គប្បីជ្រាបដោយទំនងដែលពោលហើយនុ៎ះឯង ។

ភិក្ខុណា សម្តែងសភាគាបត្តិ គឺ សម្តែងអាបត្តិយ៉ាងណាមួយមានអាបត្តិបាចិត្តិយជាដើម ត្រូវអាបត្តិទុក្កដ ព្រោះការសម្តែងជាបច្ច័យ ឈ្មោះថា ភិក្ខុសម្តែងអាបត្តិហើយ កំពុងតែសម្តែងត្រូវអាបត្តិទៀត ។ ពិតមែន កាលសម្តែងអាបត្តិនោះ រមែងត្រូវអាបត្តិទុក្កដ ។ តែកាលត្រូវអាបត្តិទុក្កដនោះ ឈ្មោះថា រមែងចេញចាកអាបត្តិបាចិត្តិយជាដើម ។ កាលចេញចាកអាបត្តិមានបាចិត្តិយជាដើម រមែងត្រូវអាបត្តិទុក្កដនោះ ឈ្មោះថា ភិក្ខុត្រូវអាបត្តិហើយ ចេញចាកអាបត្តិ កំពុងចេញចាកអាបត្តិ ត្រូវអាបត្តិទៀត ។ ចតុក្កៈនេះថា អត្ថិ អាបជ្ជន្តោ ទេសេតិ : ភិក្ខុត្រូវអាបត្តិហើយសម្តែង មាន ដូច្នេះ គប្បីជ្រាបថា លោកពោលសំដៅយកប្រយោគតែមួយប៉ុណ្ណោះ របស់បុគ្គលម្នាក់ ដោយប្រការដូច្នេះ ។

# វិនិច្ឆ័យក្នុងកម្មចតុក្កៈ

វិនិច្ឆ័យក្នុងកម្មចតុក្កៈ គប្បីជ្រាបដូច្នេះ ៖

ភិក្ខុត្រូវអាបត្តិព្រោះមិនព្រមលះបង់ទិដ្ឋិលាមក ដោយកម្ម, កាលសម្តែងចេញ ឈ្មោះថា **ត្រូវអាបត្តិដោយកម្ម ចេញចាកអាបត្តិដោយមិនមែនកម្ម** ។

ត្រូវអាបត្តិព្រោះបញ្ចេញសុក្កៈជាដើម ដោយមិនមែនកម្ម, ឈ្មោះថា **ត្រូវអាបត្តិដោយមិនមែនកម្ម ចេញចាកអាបត្តិដោយកម្ម** មានបរិវាសកម្មជាដើម ។

ត្រូវអាបត្តិព្រោះសមនុភាសនៈ ដោយកម្មប៉ុណ្ណោះ ហើយចេញដោយកម្ម ឈ្មោះថា **ត្រូវអាបត្តិដោយកម្ម ចេញចាកអាបត្តិដោយកម្ម** ។

រមែងត្រូវអាបត្តិដ៏សេស ដោយមិនមែនកម្ម រមែងចេញដោយមិនមែនកម្ម ឈ្មោះថា **ត្រូវអាបត្តិដោយមិនមែនកម្ម ចេញចាកអាបត្តិដោយមិនមែនកម្ម** ។

## វិនិច្ឆ័យក្នុងបរិក្ខារចតុក្កៈ

[៤៩] វិនិច្ឆ័យក្នុងបរិក្ខារចតុក្កៈ គប្បីជ្រាបដូច្នេះ ៖

ទី១ បរិក្ខាររបស់ខ្លួន ទី២ បរិក្ខាររបស់សង្ឃ

ទី៣ បរិក្ខាររបស់ចេតិយ ទី៤ បរិក្ខាររបស់គ្រហស្ថ ។

ក៏បើថា បរិក្ខាររបស់គ្រហស្ថនោះ ជារបស់ដែលគេនាំមកដើម្បីប្រយោជន៍ដល់បាត្រ ចីវរ នវកម្ម និងភេសជ្ជៈ ។ ភិក្ខុនឹងឱ្យកូនសោ និងឱ្យបរិក្ខារនោះនៅខាងក្នុងក៏គួរ ។

## វិនិច្ឆ័យក្នុងសម្មុខចតុក្កៈ

[៥០] វិនិច្ឆ័យក្នុងសម្មុខាចតុក្កៈ គប្បីជ្រាបដូច្នេះ ៖

ភិក្ខុត្រូវអាបត្តិព្រោះមិនព្រមលះបង់ទិដ្ឋិលាមក ចំពោះមុខសង្ឃពិត, តែក្នុងវេលាចេញ មិនមានកិច្ចដែលសង្ឃត្រូវធ្វើ ព្រោះដូច្នោះ ទើបឈ្មោះថា **ភិក្ខុត្រូវអាបត្តិក្នុងទីចំពោះមុខ ចេញចាកអាបត្តិក្នុងទីកំបាំងមុខ** ។

ត្រូវអាបត្តិ ព្រោះបញ្ចេញសុក្កៈជាដើមកំបាំងមុខ រមែងចេញចំពោះមុខសង្ឃ ឈ្មោះថា **ភិក្ខុត្រូវអាបត្តិក្នុងទីកំបាំងមុខ ចេញចាកអាបត្តិក្នុងទីចំពោះមុខ** ។

ត្រូវអាបត្តិសមនុភាសនៈចំពោះមុខសង្ឃ សូម្បីចេញក៏ចំពោះមុខសង្ឃប៉ុណ្ណោះ ឈ្មោះថា **ភិក្ខុត្រូវអាបត្តិក្នុងទីចំពោះមុខ ចេញចាកអាបត្តិក្នុងទីចំពោះមុខ** ។

រមែងត្រូវអាបត្តិដ៏សេស ដោយប្រភេទផ្សេង ៗ មានសម្បជានមុសាវាទជាដើម ឈ្មោះថា **ភិក្ខុត្រូវអាបត្តិក្នុងទីកំបាំងមុខ ចេញចាកអាបត្តិក្នុងទីកំបាំងមុខ** ។

អជាននូបតុក្កៈ ដូចគ្នានឹងអចិត្តកបតុក្កៈ ។

## ក្លាយភេទ

[៩១] បទថា **លិង្គបាតុភាវេន : ដោយក្លាយភេទ** មានសេចក្តីថា កាលការក្លាយភេទកើតដល់ភិក្ខុ ឬភិក្ខុនីដែលដេកហើយប៉ុណ្ណោះ ទើបជាអាបត្តិព្រោះដេកក្នុងផ្ទះរួមគ្នា ។

ពាក្យថា **លិង្គបាតុភាវេន** នេះឯង លោកពោលចំពោះអាបត្តិព្រោះដេកក្នុងផ្ទះរួមគ្នានោះ ។

ក៏អាបត្តិដែលមិនទូទៅ ដល់ភិក្ខុនិងភិក្ខុនីទាំង ២ ចំណែករមែងចេញ ព្រោះការប្រាកដនៃភេទ ឈ្មោះថា **ចេញចាកអាបត្តិ ដោយក្លាយភេទ** ។

# វិនិច្ឆ័យក្នុងសហបដិលាភចតុក្កៈ

វិនិច្ឆ័យក្នុងសហបដិលាភចតុក្កៈ គប្បីជ្រាបដូច្នេះ ៖

ភេទរបស់ភិក្ខុណា រមែងប្តូរផ្លាស់ទៅ, ភិក្ខុនោះ ព្រមគ្នានឹងការបានភេទ (ថ្មី) រមែងលះភេទបុរសដើមចេញដោយអំណាចនៃភេទដែលកើតឡើងមុន និងដោយភាពជាភេទប្រសើរ តាំងនៅក្នុងភេទស្រ្តីដែលកើតខាងក្រោយ ។ កាយវិញ្ញត្តិ និងវចីវិញ្ញត្តិ ដែលប្រព្រឹត្តទៅដោយអំណាចនៃចរិតរបស់បុរស និង អាការរបស់បុរសជាដើម រមែងរម្ងាប់ទៅ បញ្ញត្តិដែលប្រព្រឹត្តទៅយ៉ាងនេះថា ភិក្ខុក្តី បុរសក្តី រមែងរលត់ទៅ ។ ក៏សិក្ខាបទ ៤៦ ពួកណា ដែលមិនទូទៅដល់ភិក្ខុនីទាំងឡាយ, មិនមានអាបត្តិ ព្រោះសិក្ខាបទទាំងនោះឡើយ ។

ក៏វិនិច្ឆ័យក្នុងចតុក្កៈទី ២ គប្បីជ្រាបដូច្នេះ ៖

ភេទរបស់ភិក្ខុនីណាមួយ រមែងផ្លាស់ទៅ, ភិក្ខុនីនោះ រមែងលះភេទស្រ្តីដែលរាប់ថា កើតខាងក្រោយ ព្រោះកើតឡើងខាងក្រោយខ្លះ ព្រោះភាពជាភេទខ្សោយខ្លះ តាំងនៅក្នុងភេទបុរស ដែលរាប់ថា កើតមុនដោយប្រការដូចពោលហើយ ។ វិញ្ញត្តិដែលប្លែកពីការពោលហើយរមែងរម្ងាប់ទៅ ។ បញ្ញត្តិដែលប្រព្រឹត្តទៅយ៉ាងនេះថា ភិក្ខុនីក្តី ស្រ្តីក្តី រមែងរលត់ទៅ ។ សិក្ខាបទ ១៣០ ពួកណា ដែលមិនទូទៅដោយភិក្ខុ

ទាំងឡាយ, មិនមានអាបត្តិ ព្រោះសិក្ខាបទទាំងនោះឡើយ ។

ពីរបទថា ចត្តារោ សាមុក្កំសា : គ្រឿងអាង មាន ៤ បានដល់ មហាបទេស ៤ ។ ពិតមែន មហាបទេស ៤ នេះ លោកពោលថា "សាមុក្កំសា" ព្រោះជាបទដែលព្រះមានព្រះភាគទ្រង់រើឡើង គឺលើកឡើងតាំងទុកដោយខ្លួន ព្រះអង្គឯង ក្នុងកាលមិនទាន់កើតរឿងឡើង ។

បទថា បរិភោគា : គ្រឿងបរិភោគ បានដល់ លេបរបស់ដែលគួរលេប ។

ចំណែកទឹក ព្រោះមិនជាកាលិក មិនបានទទួលប្រគេន ក៏គួរ ។

យាវកាលិកជាដើម ដែលមិនបានទទួលប្រគេន មិនគួរលេប ។

ថ្នាំមហាវិកដ្ត ៤ យ៉ាង ព្រោះជារបស់ចំពោះកាល គួរលេបក្នុងកាល ដែលត្រាស់ទុកយ៉ាងណា ។

ពីរបទថា ឧបាសកោ សីលវា : ឧបាសកមានសីល បានដល់ អ្នកទ្រទ្រង់សីល ៥ ឬសីល ១០ ។

# វិនិច្ឆ័យក្នុងអាគន្តុកាទិចតុក្កៈ

[៥២] វិនិច្ឆ័យក្នុងអាគន្តុកាទិចតុក្កៈ គប្បីជ្រាបដូច្នេះ ៖

ភិក្ខុដែលបាំងឆត្រ ពាក់ស្បែកជើង ទទូរសីសៈចូលកាន់វិហារ និងត្រាច់ទៅក្នុងវិហារនោះ ចំពោះអាគន្តុកៈទើបត្រូវ ឯម្ចាស់អាវាសមិនត្រូវ ។

ចំណែកភិក្ខុដែលមិនធ្វើអាវាសិកវត្ត ជាអាវាសិកទើបត្រូវ អាគន្តុកៈមិនត្រូវ ។ ទាំង ២ ពួក រមែងត្រូវអាបត្តិដែលជាកាយទ្វារ និងវចីទ្វារដ៏សេស ។ ទាំងអាគន្តុកៈ ទាំងអាវាសិក រមែងមិនត្រូវអាបត្តិដែលមិនទូទៅ (ដល់ខ្លួន) ។

វិនិច្ឆ័យសូម្បីក្នុងគមិយចតុក្កៈ គប្បីជ្រាបដូច្នេះ ៖

ភិក្ខុដែលមិនញុំាងគមិយវត្តឱ្យពេញ ហើយចេញទៅ ជាអ្នកត្រៀមនឹងទៅ ទើបត្រូវ, ជាអាវាសិក មិនត្រូវ ។

កាលមិនធ្វើអាវាសិកវត្ត ជាអាវាសិក ទើបត្រូវ អ្នកត្រៀមនឹងទៅមិនត្រូវ ។ ទាំង ២ ពួក រមែងត្រូវអាបត្តិដ៏សេស ។ ទាំង ២ ពួក មិនត្រូវ អាបត្តិដែលមិនទូទៅ (ដល់ខ្លួន) ។

# វិនិច្ឆ័យក្នុងវត្ថុនានត្តតាទិចតុក្កៈ

[៥៣] វិនិច្ឆ័យក្នុងវត្ថុនានត្តតាទិចតុក្កៈ គប្បីជ្រាបដូច្នេះ ៖

សេចក្ដីដែលបារាជិក ៤ មានវត្ថុផ្សេងពីគ្នានិងគ្នានុ៎ះឯង រមែងមាន, សេចក្ដីដែលបារាជិក ៤ មានអាបត្តិផ្សេងពីគ្នានិងគ្នាមិនមានទេ ។ ពិតមែន អាបត្តិបារាជិកទាំងអស់នោះ គង់ជាអាបត្តិបារាជិកដូចគ្នា ។ សូម្បីក្នុងសង្ឃាទិសេសជាដើម ក៏ន័យនេះឯង ។

ចំណែកយោជនាក្នុងពាក្យថា អាបត្តិនានត្តតា នោ វត្ថុនានត្តតា : ផ្សេងគ្នាដោយអាបត្តិ តែមិនផ្សេងគ្នាដោយវត្ថុ នេះគប្បីជ្រាបដោយន័យមានជាដើមយ៉ាងនេះថា សេចក្ដីផ្សេងគ្នានៃអាបត្តិនុ៎ះឯង រមែងមានយ៉ាងនេះ គឺ ជាអាបត្តិសង្ឃាទិសេសដល់ភិក្ខុ, ជាអាបត្តិបារាជិកដល់ភិក្ខុនី ព្រោះស្ទាបអង្អែលគ្នា និងគ្នា ដោយកាយនៃភិក្ខុ និងភិក្ខុនី, ការផ្សេងគ្នានៃវត្ថុ មិនមានទេ, ការស្ទាបអង្អែលគ្នាដោយកាយនុ៎ះឯង ជាវត្ថុនៃអាបត្តិសូម្បីទាំង ២ ។

មួយទៀត ព្រោះការឆាន់ខ្ទឹម ភិក្ខុនី ត្រូវអាបត្តិបាចិត្តិយ, ឯភិក្ខុត្រូវអាបត្តិទុក្កដ ។

គប្បីជ្រាបសេចក្ដីដែលបារាជិក ៤ នឹងសង្ឃាទិសេស ១៣ មានវត្ថុផ្សេងគ្នា និងមានអាបត្តិផ្សេងគ្នា ។

គប្បីជ្រាបសេចក្តីដែលសង្ឃាទិសេសជាដើម ទីងអនិយតជាដើម មានវត្ថុផ្សេងគ្នា និងមានអាបត្តិផ្សេងគ្នាយ៉ាងនោះ ។

សេចក្តីផ្សេងគ្នា នៃវត្ថុ និងអាបត្តិមិនមានដល់ភិក្ខុ និងភិក្ខុនីដែលត្រូវអាបត្តិបារាជិក ៤ ខាងដើមស្របគ្នា ។

ក្នុងភិក្ខុនិងភិក្ខុនីដែលត្រូវអាបត្តិផ្សេងគ្នាក៏ដោយ ក្នុងភិក្ខុនិងភិក្ខុនីដែលត្រូវអាបត្តិទូទៅ (ដល់គ្នានិងគ្នា) ដ៏សេសក៏ដោយ មានន័យដូចគ្នា ។

## វិនិច្ឆ័យក្នុងវត្ថុសភាគាទិចតុក្កៈ

វិនិច្ឆ័យក្នុងវត្ថុសភាគាទិចតុក្កៈ គប្បីជ្រាបដូច្នេះ ៖

ព្រោះភិក្ខុនិងភិក្ខុនីស្ទាបអង្អែលគ្នាដោយកាយ មានសេចក្តីដែលវត្ថុជាសភាគគ្នាមិនមានសេចក្តីដែលអាបត្តិជាសភាគគ្នា ។

ក្នុងបារាជិក ៤ មានសេចក្តីដែលអាបត្តិជាសភាគគ្នា មិនមានសេចក្តីដែលវត្ថុជាសភាគគ្នា ។ ក្នុងសង្ឃាទិសេសជាដើម មានន័យដូចគ្នា ។

ក្នុងបារាជិក ៤ របស់ភិក្ខុនិងភិក្ខុនី មានសេចក្តីដែលវត្ថុជាសភាគគ្នាផង ដោយមានអាបត្តិជាសភាគគ្នាផង ។ ក្នុងអាបត្តិដែលទូទៅ

ទាំងពួង ក៏ន័យនេះ ។

ក្នុងអាបត្តិដែលមិនទូទៅ វត្ថុជាសភាគគ្នាក៏មិនមាន និងអាបត្តិជាសភាគគ្នាក៏មិនមាន ។

ក៏បញ្ហាទី ១ ក្នុងចតុក្កៈដើម ជាបញ្ហាទី ២ ក្នុងចតុក្កៈនេះ, និងបញ្ហាទី ២ ក្នុងចតុក្កៈដើមនោះ ជាបញ្ហាទី ១ ក្នុងចតុក្កៈនេះ ។ មិនមានការធ្វើផ្សេងគ្នាក្នុងបញ្ហាទី ៣ និងទី ៤ ។

## វិនិច្ឆ័យក្នុងឧបជ្ឈាយចតុក្កៈ

[៥៤] វិនិច្ឆ័យក្នុងឧបជ្ឈាយ៍ចតុក្កៈ គប្បីជ្រាបដូច្នេះ ៖

ក៏ព្រោះមិនធ្វើវត្តដែលឧបជ្ឈាយ៍ គប្បីធ្វើដល់សទ្ធិវិហារិក ឧបជ្ឈាយ៍ត្រូវអាបត្តិ, សទ្ធិវិហារិកមិនត្រូវ ។

កាលមិនធ្វើវត្តដែលសទ្ធិវិហារិក គប្បីធ្វើដល់ឧបជ្ឈាយ៍ សទ្ធិវិហារិកត្រូវអាបត្តិ, ឧបជ្ឈាយ៍មិនត្រូវ ។

អាបត្តិដ៏សេស ទាំងសទ្ធិវិហារិកទាំងឧបជ្ឈាយ៍ត្រូវអាបត្តិនោះ ។ ទាំង ២ ផ្នែក មិនត្រូវអាបត្តិដែលមិនទូទៅ ។ សូម្បីក្នុងអាចរិយចតុក្កៈ ក៏ន័យនេះឯង ។

# វិនិច្ឆ័យក្នុងអាទិយន្តចតុក្កៈជាដើម

[៥៦] វិនិច្ឆ័យក្នុងអាទិយន្តចតុក្កៈ គប្បីជ្រាបដូច្នេះ ៖

ភិក្ខុកាន់យកទ្រព្យដែលម្ចាស់របស់មិនបានឱ្យ មួយបាទ ឬ ច្រើនជាងមួយបាទ ដោយដៃរបស់ខ្លួន ឈ្មោះថា ភិក្ខុកាន់យកទ្រព្យគេដោយខ្លួន ត្រូវគរុកាអាបត្តិ ។ ប្រើអ្នកដទៃដោយបង្គាប់ថា លោកចូរកាន់យកទ្រព្យតិចជាង ១ បាទ ឈ្មោះថា ប្រើគេឱ្យកាន់យក ត្រូវលហុកាបត្តិ ។ ៣ បទដ៏សេស គប្បីជ្រាបដោយន័យនេះ ។

វិនិច្ឆ័យក្នុងអភិវាទនារហចតុក្កៈ គប្បីជ្រាបដូច្នេះ ៖

សម្រាប់ភិក្ខុនីទាំងឡាយមុន ក្នុងរោងឆាន់ សូម្បីឧបជ្ឈាយ៍នៅបន្ទាប់ពីភិក្ខុនីអង្គទី៩ ទៅ ក៏ជាអ្នកគួរអភិវាទ តែមិនគួរក្រោកទទួល ។ និងសម្រាប់ភិក្ខុដែលកំពុងឆាន់ ភិក្ខុរូបណាមួយ ដែលជាអ្នកចាស់ជាងរមែងជាអ្នកគួរអភិវាទ តែមិនគួរក្រោកទទួលដោយមិនប្លែកគ្នា ។

ភិក្ខុសូម្បីឧបសម្បទាក្នុងថ្ងៃនោះ ទៅដល់សំណាក់ហើយ ជាអ្នកគួរក្រោកទទួល តែមិនគួរអភិវាទ របស់ភិក្ខុដែលនៅបរិវាស សូម្បីមានវស្សា ៦០ ។

ក្នុងស្ថានដែលទ្រង់មិនហាម ភិក្ខុដែលជាអ្នកចាស់ ជាអ្នកគួរអភិវាទ និងគួរក្រោកទទួលរបស់ភិក្ខុថ្មី ។ ចំណែកភិក្ខុថ្មី ជាអ្នកមិនគួរ

អភិវាទ មិនគួរក្រោកទទួលរបស់ភិក្ខុចាស់ ។

បទទី ១ នៃអាសនាវហចតុក្កៈ ទឹងបទទី ២ ក្នុងចតុក្កៈមុន និង បទទី ២ នៃអាសនាវហចតុក្កៈ ទឹងបទទី ១ ក្នុងចតុក្កៈមុន ដូចគ្នាដោយសេចក្តី ។

## វិនិច្ឆ័យក្នុងកាលចតុក្កៈ ជាដើម

[៥៧] វិនិច្ឆ័យក្នុងកាលចតុក្កៈ គប្បីជ្រាបដូច្នេះ ៖

ភិក្ខុកាលហាម ( ភោជន ) ហើយឆាន់ ឈ្មោះថា ភិក្ខុត្រូវអាបត្តិតែក្នុងកាល មិនត្រូវអាបត្តិក្នុងវិកាល ។

កាលត្រូវអាបត្តិព្រោះវិកាលភោជន ឈ្មោះថា ត្រូវអាបត្តិតែក្នុងវិកាល មិនត្រូវអាបត្តិក្នុងកាល ។

កាលត្រូវអាបត្តិដ៏សេស ឈ្មោះថា ត្រូវអាបត្តិទាំងក្នុងកាល ទាំងក្នុងវិកាល ។ អាបត្តិដែលមិនទូទៅ ( ដល់ខ្លួន ) នោះ មិនត្រូវក្នុងទីណា ៗ ឈ្មោះថា មិនត្រូវអាបត្តិទាំងក្នុងកាលទាំងក្នុងវិកាល ។

វិនិច្ឆ័យក្នុងបដិគ្គហិតចតុក្កៈ គប្បីជ្រាបដូច្នេះ ៖

អាមិសដែលទទួលប្រគេនមុនភត្តកាល គួរក្នុងកាល មិនគួរក្នុងវិកាល ។

ទឹកបានៈ គួរក្នុងវិកាល មិនគួរក្នុងកាលក្នុងថ្ងៃស្អែក ។

សត្តាហកាលិក យាវជីវិក គួរទាំងក្នុងកាលនិងក្នុងវិកាល ។

កាលិក ៣ មានយាវកាលិកជាដើម ដែលកន្លងកាលរបស់ខ្លួន ៗ និងអកប្បិយមំសៈជាឧគ្គហិតក៍ និងអាហារដែលទទួលប្រគេន (សន្សំ) ទុក មិនគួរទាំងក្នុងកាល និងក្នុងវិកាល ។

វិនិច្ឆ័យក្នុងបច្ចន្តិមបតុក្កៈ គប្បីជ្រាបដូច្នេះ ៖

កាលចងសីមាក្នុងសមុទ្រ ឈ្មោះថា ត្រូវក្នុងបច្ចន្តិមជនបទ មិនត្រូវក្នុងមជ្ឈិមជនបទ ។

កាលឱ្យឧបសម្បទាដោយគណៈបញ្ចវគ្គ និងកាលទ្រង់ទុកនូវស្បែកជើង ៤ ជាន់ ងូតទឹកជានិច្ច និងកម្រាលស្បែក ឈ្មោះថា ត្រូវក្នុងមជ្ឈិមជនបទ មិនត្រូវក្នុងបច្ចន្តិមជនបទ ។

សូម្បីភិក្ខុដែលពោលថា វត្ថុ៤ នេះ មិនគួរក្នុងបច្ចន្តិមជនបទនេះ ឈ្មោះថា ត្រូវក្នុងបច្ចន្តិមជនបទ ។

ចំណែកភិក្ខុដែលពោលថា វត្ថុ៤ នេះ គួរក្នុងមជ្ឈិមជនបទនេះ ឈ្មោះថា ត្រូវក្នុងមជ្ឈិមជនបទ ។

ភិក្ខុរមែងត្រូវអាបត្តិដ៏សេស ឈ្មោះថា ត្រូវអាបត្តិ ទាំងក្នុង

មជ្ឈិមជនបទ ទាំងក្នុងបច្ចន្តិមជនបទ ។ អាបត្តិដែលមិនទូទៅ (ដល់ ខ្លួន) មិនត្រូវក្នុងទីណា ៗ ឈ្មោះថា មិនត្រូវអាបត្តិ ទាំងក្នុងមជ្ឈិមជនបទ ទាំងក្នុងបច្ចន្តិមជនបទ ។

វិនិច្ឆ័យក្នុងបតុក្កៈទី ២ គប្បីជ្រាបដូច្នេះ ៖

វត្ថុទាំង ៤ ប្រការ មានឧបសម្បទាដោយគណៈបញ្ចវគ្គជាដើម គួរក្នុងបច្ចន្តិមជនបទ ។

សូម្បីការដែលភិក្ខុសម្តែងថា នេះគួរ ក៏គួរក្នុងបច្ចន្តិមជនបទនោះដូចគ្នា តែមិនគួរក្នុងមជ្ឈិមជនបទ ។

ចំណែកការដែលភិក្ខុសម្តែងថា "នេះមិនគួរ" គួរក្នុងមជ្ឈិមជនបទ មិនគួរក្នុងបច្ចន្តិមជនបទ ។ វត្ថុដ៏សេសដែលព្រះមានព្រះភាគទ្រង់អនុញ្ញាតថា "អនុជានាមិ ភិក្ខវេ លោណានិ ភេសជ្ជានិ : ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតអំបិលជាភេសជ្ជៈ"(១) ជាដើម វត្ថុនោះគួរក្នុងជនបទទាំង ២ ។ ចំណែកវត្ថុណា ទ្រង់ហាមថា មិនគួរ, វត្ថុនោះ មិនគួរក្នុងជនបទសូម្បីទាំង ២ ។

១. វិន. មហា. ភេសជ្ជក្ខន្ធកៈ. ៧. ៨១/២៣០ ។

# វិនិច្ឆ័យក្នុងអន្តោអាទិចតុក្កៈ

វិនិច្ឆ័យក្នុងអន្តោអាទិចតុក្កៈ គប្បីជ្រាបដូច្នេះ ៖

ភិក្ខុ រមែងត្រូវអាបត្តិព្រោះដេកជ្រៀតជ្រៀតជាដើម ឈ្មោះថា **ភិក្ខុនៅខាងក្នុងត្រូវអាបត្តិ នៅខាងក្រៅមិនត្រូវអាបត្តិ** ។

កាលដាក់សេនាសនៈ មានគ្រែរបស់សង្ឃជាដើម ទុកក្នុងទីវាល ហើយជៀសចេញទៅ ឈ្មោះថា **នៅខាងក្រៅត្រូវអាបត្តិ នៅខាងក្នុងមិនត្រូវអាបត្តិ** ។ ត្រូវអាបត្តិដ៏សេស ឈ្មោះថា **ត្រូវអាបត្តិទាំងខាងក្នុងទាំងខាងក្រៅ** ។ អាបត្តិដែលមិនទូទៅ (ដល់ខ្លួន) ឈ្មោះថា **មិនត្រូវទាំងខាងក្នុងទាំងខាងក្រៅ** ។

វិនិច្ឆ័យក្នុងអន្តោសីមាទិចតុក្កៈ គប្បីជ្រាបដូច្នេះ ៖

ភិក្ខុអាគន្តុកៈ កាលមិនញុំាងវត្តឲ្យពេញ ឈ្មោះថា **នៅខាងក្នុងសីមាត្រូវអាបត្តិ** ។

ភិក្ខុដែលត្រៀមនឹងទៅ កាលមិនញុំាងវត្តឲ្យពេញ ឈ្មោះថា **នៅខាងក្រៅសីមាត្រូវអាបត្តិ** ។

ភិក្ខុរមែងត្រូវអាបត្តិ ព្រោះមុសាវាទជាដើម ឈ្មោះថា **នៅខាងក្នុងសីមាក៏ត្រូវអាបត្តិ នៅខាងក្រៅសីមាក៏ត្រូវអាបត្តិ** ។ រមែងមិនត្រូវអាបត្តិដែលមិនទូទៅ (ដល់ខ្លួន) ក្នុងទីណា ៗ ។

វិនិច្ឆ័យក្នុងគាមចតុក្កៈ គប្បីជ្រាបដូច្នេះ ៖

ភិក្ខុ រមែងត្រូវអាបត្តិដែលទ្រង់តាំងទុកគួរសិក្សា ដែលជាប់ចំពោះដោយចន្លោះស្រុក ឈ្មោះថា ភិក្ខុនៅក្នុងស្រុកត្រូវអាបត្តិ, នៅក្នុងព្រៃ មិនត្រូវអាបត្តិ ។

ភិក្ខុនីកាលឱ្យអរុណរះ ឈ្មោះថា នៅក្នុងព្រៃត្រូវអាបត្តិ, នៅក្នុងស្រុកមិនត្រូវអាបត្តិ ។

ភិក្ខុរមែងត្រូវអាបត្តិព្រោះមុសាវាទជាដើម ភិក្ខុនៅក្នុងស្រុក ក៏ត្រូវអាបត្តិ, នៅក្នុងព្រៃ ក៏ត្រូវអាបត្តិ ។ រមែងមិនត្រូវអាបត្តិ ដែលមិនទូទៅ (ដល់ខ្លួន) ក្នុងទីណា ៗ ។

## វិនិច្ឆ័យក្នុងបុព្វកិច្ចាទិចតុក្កៈ

[៥៨] ពីរបទថា ចត្តារោ បុព្វកិច្ចា : បុព្វកិច្ច មាន ៤ មានសេចក្តីថា ព្រះអដ្ឋកថាចារ្យពោលថា កម្ម ៤ យ៉ាងនេះ គឺ ការបោសសំអាតអុជប្រទីប តាំងទឹកឆាន់ទឹកប្រើប្រាស់ព្រមទាំងក្រាលអាសនៈ ហៅថា បុព្វករណៈ ។ ចំណែកកិច្ច ៤ យ៉ាងនេះគឺ នាំឆន្ទៈបារិសុទ្ធិ ប្រាប់រដូវ រាប់ចំនួនភិក្ខុ និងទូន្មានភិក្ខុនី គប្បីជ្រាបថា បុព្វកិច្ច ។

ពីរបទថា ចត្តារោ បត្តកល្លា : កម្មមានកាលដ៏គួរ មាន ៤ មានសេចក្តីថា ថ្ងៃឧបោសថ ១ ភិក្ខុធ្វើកម្មមានចំនួនប៉ុន្មាន លោកជាអ្នក

មកហើយ ១ សភាគាបត្តិមិនមាន ១ បុគ្គលគួរវៀរមិនមានក្នុងហត្ថបាសសង្ឃនោះ ១ រួមហៅថា បត្តកល្លៈ ដូច្នេះឯង ។

ពីរបទថា **ចត្តារិ អនញ្ញបាចិត្តិយានិ : អនញ្ញបាចិត្តិយ មាន ៤** មានសេចក្ដីថា បាចិត្តិយ ៤ សិក្ខាបទនេះ ដែលព្រះមានព្រះភាគត្រាស់ទុកយ៉ាងនេះថា "**ឯតទេវ បច្ចយំ ករិត្វា អនញ្ញំ បាចិត្តិយំ** : ភិក្ខុនោះត្រូវអាបត្តិបាចិត្តិយ ព្រោះធ្វើនូវសេចក្ដី (ប្រៀតបៀត១ បញ្ជូនឱ្យត្រឡប់ទៅវិញ១ សង្ស័យ១ ឈរអែបស្ដាប់១) នោះឯងឱ្យជាបច្ច័យ មិនមែនហេតុដទៃទេ" គឺ អនុបខជ្ជសិក្ខាបទ ១, ឧយ្យោជនសិក្ខាបទ ដែលត្រាស់ថា "**ឯហាវុសោ គាមំ វា និគមំ វា** : ម្នាលអាវុសោ លោកចូរមក យើងទាំងឡាយនឹងទៅកាន់ស្រុកឬនិគម"ជាដើម ១, សញ្ចិច្ចសិក្ខាបទ ១, ឧបស្សុតិកសិក្ខាបទ ១ ។ (ភូតគាមវគ្គទី៦, អចេលកវគ្គទី២ សហធម្មិកវគ្គទី៧ ទី៨)

ពីរបទថា **ចតស្សោ ភិក្ខុសម្មុតិយោ : ភិក្ខុសម្មុតិ មាន ៤** មានសេចក្ដីថា សន្មតក្នុងទីដទៃផុតពីសម្មុតិ ១៣ ដែលមកហើយយ៉ាងនេះថា បើភិក្ខុនៅប្រាសចាកត្រៃចីវរ សូម្បីតែមួយយប់ វៀរលែងតែភិក្ខុដែលបានអវិប្បវាសសម្មុតិអំពីសង្ឃ[១] ភិក្ខុឱ្យធ្វើសន្ថត់ដទៃថ្មី... ឱ្យធ្វើ

១. វិន. និស្ស. ចីវរវគ្គ. ៣. ១១/១៤ ។

សន្ធត់ជទៃថ្មីទៀត វៀរលែងតែភិក្ខុបានសន្ធតអំពីសង្ឃ[១] បើនៅប្រាស ចាកឱ្យហួសពីកំណត់នោះទៅ វៀរលែងតែភិក្ខុដែលបានសន្ធតអំពីសង្ឃ[២] ប្រាប់ទុដ្ឋុល្លាបត្តិរបស់ភិក្ខុផងគ្នា ដល់អនុបសម្បន្នបុគ្គល វៀរលែងតែ ភិក្ខុដែលបានសន្ធតអំពីសង្ឃ[៣] ។

## វិនិច្ឆ័យក្នុងគិលានចតុក្កៈ

[៥៩] វិនិច្ឆ័យក្នុងគិលានចតុក្កៈ គប្បីជ្រាបដូច្នេះ ៖

កាលសូមភេសជ្ជជទៃ ព្រោះជាអ្នកល្មោភ ក្នុងកាលមានកិច្ចដែល ត្រូវធ្វើដោយភេសជ្ជៈជទៃ ភិក្ខុដែលអាពាធត្រូវអាបត្តិ ។

កាលសូមភេសជ្ជៈ ក្នុងកាលមានកិច្ចដែលត្រូវធ្វើដោយរបស់មិន មែនភេសជ្ជៈ ភិក្ខុមិនអាពាធត្រូវ ។

ភិក្ខុអាពាធនិងមិនអាពាធទាំង ២ រមែងត្រូវអាបត្តិ ព្រោះ មុសាវាទជាដើម ។ ទាំង ២ មិនត្រូវអាបត្តិដែលមិនទូទៅ (ដល់ខ្លួន) បទដ៏សេសក្នុងទីទាំងពួងងាយយល់ទាំងអស់ ដូច្នេះឯង ។

ពណ៌នាពួក ៤ ចប់

---

១. វិន. និស្ស. កោសិយវគ្គ. ៣. ៨៧/១០២ ។ ២. វិន. និស្ស. បត្តវគ្គ. ៣. ១៦៥/២១១ ។ ៣. វិន. បាចិ. មុសាវាទវគ្គ. ៣. ៣៤២/៣៣៨ ។

## ពណ៌នាពួក ៥

វិនិច្ឆ័យក្នុងពួក ៥ គប្បីជ្រាបដូច្នេះ ៖

[៦២] ពាក្យថា បញ្ច បុគ្គលា និយតា : និយតបុគ្គល មាន ៥ ពួក នេះ បំណងយកបុគ្គលដែលធ្វើអនន្តរិយកម្មទាំងឯង ។

ដែលឈ្មោះថា អាបត្តិ មានការកាត់ជាវិន័យកម្ម ៥ គប្បីជ្រាបដល់គ្រែ តាំង និងសំពត់ក្រោលអង្គុយ សំពត់បិទបូស សំពត់ងូតទឹកភ្លៀង និងសុគតចីវរ ដែលលើសប្រមាណ ។

បទថា បញ្ចហាការេហិ : ដោយអាការ ៥ យ៉ាង មានសេចក្ដីថា ភិក្ខុរមែងត្រូវអាបត្តិ ដោយអាការ ៥ យ៉ាងនេះ គឺ ជាអ្នកមិនខ្មាសសេចក្ដីមិនដឹង ជាអ្នកសង្ស័យហើយចេះតែធ្វើ ជាអ្នកមានសេចក្ដីសម្គាល់ថា គួរក្នុងរបស់ដែលមិនគួរ ជាអ្នកមានសេចក្ដីសម្គាល់ថា មិនគួរក្នុងរបស់ដែលគួរ ។

ពាក្យថា បញ្ចាបត្តិយោ មុសាវាទបច្ចយា : អាបត្តិ ៥ យ៉ាង មានមុសាវាទជាបច្ច័យ បានដល់ បារាជិក ថុល្លច្ច័យ ទុក្កដ សង្ឃាទិសេស និងបាចិត្តិយ ។

បទថា អនាមន្តចារោ : ត្រាច់ទៅក្នុងត្រកូលមិនបាច់លាភិក្ខុផងគ្នា បានដល់ ការមិនមាននៃកិច្ចដែលត្រូវប្រាប់លា ទើបត្រាច់ទៅនេះ

ថា ភិក្ខុមិនបាន លា ឬប្រាប់ភិក្ខុដែលមាននៅ ហើយដល់កិរិយាត្រាច់ទៅក្នុងត្រកូលទាំងឡាយ ក្នុងពេលមុនភត្តក្តី ក្រោយភត្តក្តី ។

បទថា **អនធិដ្ឋានំ : មិនអធិដ្ឋាន** មានសេចក្តីថា ការឆាន់ត្រូវនឹករលឹកដល់សម័យដែលព្រះមានព្រះភាគត្រាស់ថា “**គណភោជនេ អញ្ញត្រ សមយា** : ភិក្ខុត្រូវអាបត្តិបាចិត្តិយ ព្រោះឆាន់គណភោជន វៀរលែងតែមានសម័យ” ឈ្មោះថា សេចក្តីនឹកដល់ ។ ការដែលមិនត្រូវធ្វើយ៉ាងនោះ ឈ្មោះថា សេចក្តីមិនត្រូវនឹកដល់ ។

អត្ថន័យយ៉ាងណា ក្នុងភោជនខាងក្រោយ ដែលព្រះមានព្រះភាគត្រាស់ហើយ, ការដែលមិនត្រូវធ្វើសេចក្តីសំដៅយ៉ាងនោះ ឈ្មោះថា សេចក្តីមិនត្រូវសំដៅ ។

ពិតមែន ៥ វត្ថុនេះ ព្រះមានព្រះភាគទ្រង់ហាមហើយ ដោយធុតង្គរបស់ភិក្ខុអ្នកកាន់ត្រាច់បិណ្ឌបាតជាវត្តទុំះឯង ។

បទថា **ឧស្សង្កិតបរិសង្កិតោ : ក៏គួរឱ្យរង្កៀសសង្ស័យបាន** មានសេចក្តីថា ជាអ្នកដែលភិក្ខុទាំងឡាយ អ្នកបានឃើញ បានស្តាប់សង្ស័យហើយ និង រង្កៀសហើយ ។

ម្យ៉ាងទៀត ភិក្ខុសូម្បីជាព្រះខីណាស្រព អ្នកមានការមិនកម្រើកជាធម្មតា ក៏ជាអ្នកត្រូវសង្ស័យត្រូវរង្កៀស ។ ព្រោះហេតុនោះ អគោចរ

ទាំងឡាយ ដែលភិក្ខុគប្បីវៀរចេញ ។ ពិតមែន ភិក្ខុដែលប្រាកដស្មើក្នុងអគោចរទាំងនោះ រមែងមិនផុតពីសេចក្ដីសាបសូន្យយស ឬចាកសេចក្ដីតិះដៀល ។

## សំពត់បង្សុកូលជាដើម

បទថា សោសានិកំ : សំពត់ដែលធ្លាក់ចុះក្នុងព្រៃស្មសាន បានដល់ សំពត់ដែលធ្លាក់ក្នុងព្រៃជាទីចោលសាកសព ។

បទថា អាបណិកំ : សំពត់ដែលធ្លាក់ចុះទៀបរានផ្សារ បានដល់ សំពត់ដែលធ្លាក់ត្រង់ទ្វារផ្សារ ។

បទថា ជូបចីវរំ : សំពត់ដែលគេរុំដំបូកធ្វើពលីកម្ម បានដល់ សំពត់ដែលគេរុំដំបូកធ្វើពលីកម្ម ។

បទថា អភិសេកិកំ : សំពត់ដែលគេចោលក្នុងទីអភិសេកស្ដេច បានដល់ ចីវរដែលគេចោលត្រង់ស្ថានទីងូតទឹក ឬត្រង់ស្ថានទីអភិសេករបស់ព្រះរាជា ។

បទថា គតប្បដិយាគតំ : សំពត់ដែលគេទៅព្រៃស្មសាន លុះត្រឡប់មកវិញហើយ គេផ្លាស់ចោល បានដល់ សំពត់ដែលគេនាំទៅកាន់ព្រៃជាទីចោលសាកសពហើយ នាំត្រឡប់មកទៀត ។

មហាចោរ៥ពួក បានពោលហើយក្នុងឧត្តរិមនុស្សធម្មសិក្ខាបទ[១] ។

ពាក្យថា បញ្ចាបត្តិយោ កាយតោ សមុដ្ឋហន្តិ : **អាបត្តិ ៥ យ៉ាង តាំងឡើងអំពីកាយ** មានសេចក្តីថា ភិក្ខុត្រូវអាបត្តិ ៥ ដោយសមុដ្ឋាននៃអាបត្តិទី ១ បានដល់ អាបត្តិដែលព្រះអង្គត្រាស់ទុកក្នុងអន្តរបេយ្យាលយ៉ាងនេះថា "ភិក្ខុសម្គាល់ថា គួរ ហើយធ្វើកុដិ ដោយការសូមគេមកដោយខ្លួនឯង"[២] ។

ពាក្យថា បញ្ចាបត្តិយោ កាយតោ ច វាចតោ ច : **អាបត្តិ ៥ យ៉ាង តាំងឡើងអំពីកាយនិងវាចា** មានសេចក្តីថា ភិក្ខុរមែងត្រូវអាបត្តិ ៥ ដោយសមុដ្ឋាននៃអាបត្តិទី ៣ គឺ រមែងត្រូវអាបត្តិដែលព្រះដ៏មានព្រះភាគត្រាស់ទុកក្នុងអន្តរបេយ្យាលនោះឯង យ៉ាងនេះថា "ភិក្ខុសម្គាល់ថា គួរ ក៏ចាត់ចែងធ្វើកុដិ"[៣] ។

បទថា ឆេសនាគាមិនិយោ : **ជាទេសនាគាមិនី** មានសេចក្តីថា វៀរបារាជិក និងសង្ឃាទិសេសចេញ បានដល់ អាបត្តិដ៏សេស ។

ពីរបទថា បញ្ច កម្មានិ : **កម្ម មាន ៥ យ៉ាង** បានដល់ កម្ម ៥ គឺ តជ្ជនីយកម្ម និយស្សកម្ម បព្វាជនីយកម្ម និងបដិសារណីយកម្ម

---

១. វិន. បារា. ឧត្តរិមនុស្សធម្ម. ១. ២៣០/២៩៣ ។ ២. វិន. បរិ. វីសតិវារៈ. ១២. ៨៦៧/៣៨២ ។ ៣. វិន. បរិ. វីសតិវារៈ. ១២. ៨៦៩/៣៨៥ ។

រូម ៤, និង ឧក្ខេបនីយកម្មទាំង ៣ យ៉ាង ១ ។

ពីរបទថា យាវតតិយកេ បញ្ច : អាបត្តិ ៥ យ៉ាង ត្រូវក្នុងខណៈដែលសង្ឃសូត្រសមនុភាសនកម្ម ជាគម្រប់ ៣ ដង ចប់ បានដល់ អាបត្តិ៣ គឺ បារាជិក ថុល្លច្ច័យ ទុក្កដ របស់ភិក្ខុនីដែលប្រព្រឹត្តតាមភិក្ខុដែលសង្ឃលើកវត្ត អ្នកមិនព្រមលះបង់ព្រោះសមនុភាសនៈ ៣ ដង សង្ឃាទិសេស ព្រោះសមនុភាសនៈ ក្នុងភេទកានុវត្តកសិក្ខាបទជាដើម ។ បាចិត្តិយ ព្រោះមិនព្រមលះបង់ទិដ្ឋិលាមក( ក្នុងអរិដ្ឋសិក្ខាបទ ) ។

បទថា អធិន្នំ : របស់ដែលគេមិនបានឱ្យ បានដល់ របស់ដែលអ្នកដទៃមិនប្រគេន ។

បទថា អវិធិតំ : របស់ដែលភិក្ខុមិនស្គាល់ជាក់លាក់ បានដល់ ឈ្មោះថា មិនជ្រាប ព្រោះមិនមានចេតនាថា យើងទទួលប្រគេន ។

បទថា អកប្បិយំ : របស់ដែលមិនគួរ បានដល់ របស់ដែលមិនបានធ្វើឱ្យគួរដោយសមណកប្បៈ ៥ ។ ឬថា សាច់ដែលមិនគួរ ភោជនដែលមិនគួរ សូម្បីដទៃ ក៏ឈ្មោះថា របស់មិនគួរ ។

បទថា អកតាតិរិត្តំ : របស់ដែលមិនទទួលប្រគេន បានដល់ របស់ភិក្ខុហាមភោជនហើយ មិនបានធ្វើឱ្យជារបស់សល់ ។

បទថា សមជ្ជធានំ : ឱ្យមហោស្រព បានដល់ ការឱ្យមហោស្រព គឺ របាំជាដើម ។

បទថា ឧសភធានំ : ឱ្យគោឈ្មោល(ដល់គោញី) បានដល់ការលែងគោបាខាងក្នុងនៃហ្វូងគោ ។

បទថា ចិត្តកម្មធានំ : ឱ្យរូបគំនូរ(ដែលប្រកបដោយមេថុន) មានសេចក្ដីថា ការដែលឱ្យសាងអាវាសហើយធ្វើចិត្រកម្មក្នុងអាវាសនោះសមគួរ ។ តែពាក្យថា ចិត្តកម្មធានំ នេះ លោកពោលសំដៅយកការឱ្យចិត្រកម្ម ដែលលាយរូបភាព ។

ពិតមែន ទាន ៥ យ៉ាងនេះ លោកសន្មតិគ្នាថា ជាបុណ្យមែន, តែតាមការពិត មិនជាបុណ្យទេ គឺ ជាអកុសលទាំងឯង ។

ភាពជាអ្នកប្រាថ្នាដើម្បីនិយាយ ហៅថា បដិភាណ ក្នុងពាក្យថា ឧប្បន្នំ បដិភាណំ : បដិភាណកើតឡើងហើយ នេះ សេចក្ដីថា ធម៌ ៥ យ៉ាងនេះ ដែលបុគ្គលបន្ទោបង់បានដោយលំបាក ព្រោះដូច្នោះ ទើបឈ្មោះថា បន្ទោបង់បានមិនងាយ ។ តែបុគ្គលអាចបន្ទោបង់បានដោយហេតុដែលជាឧបាយ គឺ ដោយការពិចារណា និងទូន្មានជាដើមដែលសមគួរ ។

# អានិសង្សនៃការបោស

ក្នុងពីរបទថា សកចិត្តំ បសីទតិ : ចិត្តរបស់ខ្លួនក៏ជ្រះថ្លា នេះ មានរឿងទាំងនេះ ជាឧទាហរណ៍ ។

បានឮថា ព្រះបុស្សទេវត្ថេរនៅក្នុងកាឡន្ទកាឡវិហារបោសលាន ចេតិយ ធ្វើឧត្តរាសង្គឆៀងស្មាម្ខាង ក្រឡេកមើលលានចេតិយដែលកៀរ ខ្សាច់ទុករៀបរយ ហាក់ដូចជាក្រាលដោយផ្កាដូចខ្សាច់ ឱ្យកើតបីតិ និង បាមោជ្ជៈមានព្រះពុទ្ធជាអារម្មណ៍ បានឈរហើយ ។ ក្នុងខណៈនោះ មារបានប្លែងជាស្វាខ្មៅកើតហើយត្រង់ជើងភ្នំ ពោយពាយអាចម៍គោទុក ពាសពេញ ទីលានចេតិយទៅហើយ ។ ព្រះថេរៈមិនអាចបានសម្រេច ព្រះអរហត្ត, បោសហើយបានចេញទៅ ។ សូម្បីក្នុងថ្ងៃទី ២ មារបាន ប្លែងជាគោចាស់ ធ្វើប្រការប្លែកដូច្នោះទុំះឯង ។ ក្នុងថ្ងៃទី ៣ បាននិមិត្ត អត្តភាពជាមនុស្ស មានជើងខ្ចក ដើរទៅមក យកជើងកកាយជុំវិញ ទៅ ។ ព្រះថេរៈគិតថា បុរសប្លែកដូច្នេះមិនមានក្នុងគោចរគ្រាម ប្រមាណមួយយោជន៍ដោយជុំវិញ នេះគឺ ជាមារពិតប្រាកដណាស់ ទើប ពោលថា "អ្នកឯង ជាមារឬ ?" ។ មារឆ្លើយថា "ត្រូវហើយលោក ដ៏ចម្រើន ខ្ញុំជាមារ ឥឡូវនេះ មិនអាចដើម្បីបោកបញ្ឆោតលោកទេ" ។ ព្រះថេរៈសួរថា "លោកធ្លាប់ឃើញព្រះតថាគតឬ ?" ។ មារឆ្លើយថា "ខ្ញុំ

ពិតជាធ្លាប់ឃើញ” ព្រះថេរៈពោលថា “ធម្មតាមាររមែងជាអ្នកមានអានុភាពធំ អញ្ជើញលោកនិមិត្តអត្តភាព ឱ្យដូចអត្តភាពរបស់ព្រះមានព្រះភាគជាព្រះពុទ្ធមកមើល” ។ មារពោលថា “ខ្ញុំមិនអាចនិមិត្តរូបដូច្នោះ លោកដ៏ចម្រើនតែឈ្លើយចុះ ខ្ញុំនឹងនិម្មិតរូបធៀប ដែលនឹងគប្បីឃើញស្រដៀងនឹងរូបនោះ” ដូច្នេះ ហើយបានប្លែងភេទរបស់ខ្លួន តាំងនៅដោយអត្តភាពស្រដៀងនឹងព្រះរូបរបស់ព្រះពុទ្ធ ។ ព្រះថេរៈសម្លឹងមើលមារហើយគិតថា “មារនេះ មានរាគៈ ទោសៈ មោហៈ នៅល្អស្អាតដល់ម៉្លេះ ព្រះមានព្រះភាគនឹងទ្រង់ល្អស្អាតយ៉ាងណាហ្ន៎ ? ព្រោះថា ព្រះអង្គប្រាសចាករាគៈ ទោសៈ មោហៈ ដោយប្រការទាំងពួង” ដូច្នេះហើយ បានបីតិមានព្រះពុទ្ធជាអារម្មណ៍ ចម្រើនវិបស្សនាសម្រេចព្រះអរហត្តហើយ ។ មារពោលថា “លោកដ៏ចម្រើន ខ្ញុំត្រូវលោកលួងលោមហើយ” ។ ចំណែកព្រះថេរៈពោលថា “មារចាស់ នឹងមានប្រយោជន៍អ្វី ដែលយើងលួងលោមបុគ្គលដូចជាលោក” ។

សូម្បីភិក្ខុកម្លោះឈ្មោះទត្តៈ នៅក្នុងលោកន្តវិហារ បោសលានចេតិយហើយក្រឡេកមើលបានឱទាតកសិណ, ញ៉ាំងសមាបត្តិ ៨ ឱ្យកើតហើយ, ខាងក្រោយចម្រើនវិបស្សនា ធ្វើឱ្យច្បាស់នូវផល ៣ ។

ក្នុង២ បទថា បរចិត្តំ បសីទតិ : ចិត្តរបស់អ្នកដទៃក៏ជ្រះថ្លា

នេះ មានរឿងទាំងនេះ ជាឧទាហរណ៍ ។

ភិក្ខុកម្លោះឈ្មោះតិស្សៈ បោសលានចេតិយជិតកំពង់ជម្ពុកោលៈ ហើយ បានយកដៃកាន់កញ្ច្រែងឈរចាក់សម្រាម ។ ក្នុងខណៈនោះ ព្រះថេរៈឈ្មោះតិស្សទត្តៈ ចុះពីទូកក្រឡេកមើលលានចេតិយ ជ្រាបថា ជាស្ថានទីដែលលោកអ្នកមានចិត្តអប់រំហើយបោសទុក ទើបសួរបញ្ហាទាំងពាន់ន័យ ។ ចំណែកព្រះតិស្សៈឆ្លើយបានទាំងអស់ ។

សូម្បីព្រះថេរៈក្នុងវិហារខ្លះ បោសលានចេតិយហើយ ធ្វើវត្តរួចស្រេចហើយ ។ ព្រះថេរៈ ៤ រូបថ្វាយបង្គំចេតិយ មកពីយោនកប្រទេស ឃើញលានចេតិយហើយ មិនចូលខាងក្នុងឈរត្រង់ទ្វារទ្រុំៈឯង ព្រះថេរៈមួយរូប តាមរលឹកជាតិបាន ៨ កប្ប មួយរូបតាមរលឹកជាតិបាន ១៦ កប្ប មួយរូបតាមរលឹកជាតិបាន ២០ កប្ប មួយរូបតាមរលឹកជាតិបាន ៣០ កប្ប ។

ក្នុងពាក្យថា ទេវតា អត្តមនា ហោន្តិ : ពួកទេវតាតែងពេញចិត្ត នេះ មានរឿងនេះ ជាឧទាហរណ៍ ។

បានឮថា ភិក្ខុមួយរូប ក្នុងវិហារមួយ បោសលានចេតិយ និងលានពោធិព្រឹក្សហើយ ទៅដងទឹក ។ ទេវតាទាំងឡាយ មានចិត្តជ្រះថ្លាថា "តាំងពីកាលដែលសាងវិហារនេះមក មិនមានភិក្ខុដែលធ្លាប់បំពេញវត្ត

បោសយ៉ាងនេះ” ទើបនាំគ្នាមក បានឈរកាន់ផ្កាឈើនៅក្នុងដៃ ៗ ព្រះថេរៈមកហើយពោលថា “ពួកលោកជាអ្នកស្រុកណា ?” ទេវតាទើបពោលថា “លោកដ៏ចម្រើន ពួកខ្ញុំនៅត្រង់នេះឯង ជ្រះថ្លាក្នុងវត្តរបស់លោក តាំងពីកាលដែលកសាងវិហារនេះមក មិនមានភិក្ខុដែលធ្លាប់បំពេញវត្តបោសយ៉ាងនេះ ទើបមកឈរកាន់ផ្កាឈើនៅក្នុងដៃ” ៗ

ក្នុងបទថា បសាទិកសំវត្តនិយំ អ្នកបោសរមែងសន្សំនូវការដែលប្រព្រឹត្តទៅដើម្បីសេចក្តីជ្រះថ្លា នេះ មានរឿងនេះជាឧទាហរណ៍ ៗ

បានឮថា ពាក្យនេះ ប្រារព្ធបុត្រអាមាត្យម្នាក់ និងព្រះអភយត្ថេរកើតឡើងថា “បុត្រអាមាត្យជាអ្នកគួរជ្រះថ្លា ឬថា ព្រះអភយត្ថេរជាអ្នកគួរជ្រះថ្លាហ្ន៎ ?” ញាតិទាំងឡាយនិយាយគ្នាថា “យើងទាំងឡាយនឹងឃើញជនទាំង ២ នោះក្នុងទី ជាមួយគ្នា” ទើបតែងខ្លួនបុត្រអាមាត្យហើយបាននាំគ្នាទៅ ដោយសេចក្តីគិតថា “នឹងឱ្យថ្វាយបង្គំព្រះមហាចេតិយ” ៗ ចំណែកមាតារបស់ព្រះថេរៈ ឱ្យធ្វើចីវរមានតម្លៃមួយបាទ[១] បញ្ជូនទៅឱ្យបុត្រដោយបង្គាប់ថា “បុត្ររបស់យើងចូរកោរសក់ ហើយដណ្តប់ចីវរនេះ មានភិក្ខុសង្ឃហែហមចូរថ្វាយបង្គំព្រះមហាចេតិយ” ៗ បុត្រអាមាត្យមានញាតិហែហម ឡើងកាន់លានចេតិយតាមទ្វារខាងលិច ៗ

១. បាលីខ្លះច្បាប់ជា បាសទិកំ ប្រែថា គួរជ្រះថ្លាក៏មាន ៗ

ព្រះអភយត្ថេរ មានភិក្ខុសង្ឃហែហមឡើងកាន់លានចេតិយ តាមទ្វារខាងត្បូង មកជួបនឹងបុត្រអាមាត្យនោះ លើលានចេតិយ ទើបពោលថា "អ្នកមានអាយុ លោកចាក់សម្រាម ក្នុងទីដែលព្រះមហាល្លកត្ថេរបានបោសទុក នឹងចាប់គូប្រកួតជាមួយនឹងយើងឬ ?" បានឮថា ក្នុងអត្តភាពដែលកន្លងទៅហើយ ព្រះអភយត្ថេរ ជាព្រះមហាល្លកត្ថេរ បានបោសលានចេតិយក្នុងកាលជរគ្រោម ។ បុត្រអាមាត្យជាមហាឧបាសក កាន់សម្រាមទៅចាក់ក្នុងទីដែលលោកបោសទុក ។

ប្រើបទថា សត្ថុ សាសនំ កតំ ហោតិ : ឈ្មោះថា ធ្វើតាមសាសនារបស់ព្រះសាស្ដា មានសេចក្ដីថា ឈ្មោះថា វត្តគឺការបោសនេះ ដែលព្រះពុទ្ធទាំងឡាយទ្រង់សរសើរ ។

ព្រោះហេតុនោះ ភិក្ខុដែលធ្វើវត្ត គឺ ការបោសនោះ ទើបឈ្មោះថា បានធ្វើតាមពាក្យទូន្មានរបស់ព្រះសាស្ដា ។ រឿងជាឧទាហរណ៍ ក្នុងសេចក្ដីនោះ តទៅនេះ ៖

បានឮថា ព្រះសារីបុត្រទៅកាន់ហិមវន្តប្រទេស មិនបោសមុនអន្លុយចូលនិរោធត្រង់ញកនៃភ្នំមួយ ។ ព្រះមានព្រះភាគទ្រង់រលឹកដល់ក៏ទ្រង់ជ្រាបនូវព្រះថេរៈ ដែលមិនបោសមុននឹងអន្លុយ ទើបស្ដេចមកតាមអាកាស ទ្រង់សម្ដែងស្នាមព្រះបាទទុក ក្នុងទីដែលមិនបានបោសខាងមុខ

ព្រះថេរៈ ហើយស្តេចត្រឡប់មកវិញ ។ ព្រះថេរៈចេញចាកសមាបត្តិ ហើយ ឃើញស្នាមព្រះបាទរបស់ព្រះមានព្រះភាគហើយ ក៏ផ្ងង់តាំងទុកនូវសេចក្តីខ្មាស និងសេចក្តីកោតក្រែងយ៉ាងខ្លាំងក្លា លុតជង្គង់ចុះគិតថា "ព្រះសាស្តាបានទ្រង់ជ្រាបនូវយើង ដែលមិនបោសមុននឹងអង្គុយហើយហ្ន៎ ឥឡូវនេះ យើងនឹងសូមឱ្យព្រះអង្គ ធ្វើការព្រមានក្នុងទីកណ្តាលជំនុំសង្ឃ", ទៅកាន់សំណាក់របស់ព្រះទសពល ថ្វាយបង្គំហើយអង្គុយ ។ ព្រះមានព្រះភាគត្រាស់ថា "សារីបុត្រ អ្នកទៅណា ?" ហើយត្រាស់ថា "ឥឡូវនេះ ការដែលមិនបោសមុនអង្គុយ មិនសមគួរដល់អ្នក ដែលតាំងនៅក្នុងតំណែងបន្ទាប់ពីតថាគតឡើយ" ។ ចាប់តាំងពីនោះមក ព្រះថេរៈកាលឈរ សូម្បីក្នុងស្ថានទីដោះក្តៅ បានយកជើងកៀសសម្រាមហើយទើបឈរ ។

## អង្គរបស់ព្រះវិន័យធរ

[៦៣] ប្រើនបទថា អត្តនោ ភាសបរិយន្តំ ន ឧគ្គណ្ហាតិ : មិនរៀនទីកំណត់ភាសារបស់ខ្លួន មានសេចក្តីថា មិនកំណត់ទីបំផុតនៃពាក្យរបស់ខ្លួន យ៉ាងនេះថា ក្នុងក្តីនេះ បានសូត្រប៉ុណ្ណេះ បានវិនិច្ឆ័យប៉ុណ្ណេះ យើងនឹងពោលសូត្រនិងវិនិច្ឆ័យប៉ុណ្ណេះ ។

តែកាលមិនកំណត់យ៉ាងនេះថា "នេះជាពាក្យដើម នេះជាពាក្យចុងរបស់អ្នកចោទ នេះជាពាក្យដើម នេះជាពាក្យចុងរបស់អ្នកជាប់ចោទ ក្នុងពាក្យរបស់អ្នកចោទ និងអ្នកជាប់ចោទនេះ ពាក្យដែលគួរជឿប៉ុណ្ណោះ ពាក្យដែលមិនគួរជឿប៉ុណ្ណោះ" ឈ្មោះថា មិនកំណត់ទីបំផុតនៃពាក្យរបស់អ្នកដទៃ ។

ពីរបទថា **អាបត្តឹ ន ជានាតិ : មិនស្គាល់អាបត្តិ** បានដល់ មិនស្គាល់ការធ្វើផ្សេងគ្នានៃអាបត្តិ ៧ កងថា បារាជិក ឬសង្ឃាទិសេសជាដើម ។

បទថា **មូលំ : មូល** មានសេចក្ដីថា មូលរបស់អាបត្តិមាន ២ គឺ កាយនិងវាចា មិនស្គាល់មូល ២ នោះ ។

បទថា **សមុទយំ : ហេតុឲ្យកើត** មានសេចក្ដីថា សមុដ្ឋាននៃអាបត្តិ ៦ ឈ្មោះថា ហេតុកើតរបស់អាបត្តិ មិនស្គាល់ហេតុរបស់អាបត្តិ ៦ នោះ ។ មានពាក្យអធិប្បាយថា មិនស្គាល់វត្ថុ របស់អាបត្តិមានបារាជិកជាដើមខ្លះ ។

បទថា **និរោធំ : សេចក្ដីរលត់** មានសេចក្ដីថា មិនស្គាល់ហេតុរលត់របស់អាបត្តិយ៉ាងនេះថា អាបត្តិនេះ រមែងរលត់ គឺ រមែងរម្ងាប់ដោយការសម្ដែង, អាបត្តិនេះ ដោយការនៅប្រព្រឹត្តកម្ម ។

មួយទៀត កាលមិនស្គាល់សមថៈ ៧ ឈ្មោះថា មិនស្គាល់ការបដិបត្តិជាមកឱ្យដល់សេចក្ដីរលត់នៃអាបត្តិ ។

វិនិច្ឆ័យក្នុងពួក ៥ នៃអធិករណ៍ គប្បីជ្រាបដូច្នេះ ៖

សេចក្ដីថា មិនដឹងវិភាគនេះ គឺ អធិករណ៍ ៤ ឈ្មោះថា អធិករណ៍ ។ មូល ៣៣ ឈ្មោះថា មូលនៃអធិករណ៍ ។ វិវាទាធិករណ៍ មានមូល ១២ ។ អនុវាទាធិករណ៍ មានមូល ១៤ ។ អាបត្តាធិករណ៍ មានមូល ៦ ។ កិច្ចាធិករណ៍ មានមូល ១ ។ មូលទាំងនោះនឹងមានច្បាស់ខាងមុខ ។

សមុដ្ឋាននៃអធិករណ៍ ឈ្មោះថា ហេតុកើតនៃអធិករណ៍ ។ វិវាទាធិករណ៍អាស្រ័យភេទករវត្ថុ ១៨ កើតឡើង, អនុវាទាធិករណ៍អាស្រ័យវិបត្តិ ៤ កើតឡើង អាបត្តាធិករណ៍ អាស្រ័យកងអាបត្តិ ៧ កើតឡើង កិច្ចាធិករណ៍អាស្រ័យសង្ឃកិច្ច ៤ យ៉ាងកើតឡើង ។

ពីរបទថា **អធិករណំ ន ជានាតិ** : មិនស្គាល់សេចក្ដីរលត់ដោយអធិករណ៍ មានសេចក្ដីថា មិនអាចពិនិត្យសង្កេតដល់មូលចាកមូល ឱ្យវិនិច្ឆ័យដល់សេចក្ដីរម្ងាប់ដោយធម៌ ដោយវិន័យ ដោយសត្ថុសាសនា ។

មួយទៀត កាលមិនស្គាល់សមថៈ ៧ យ៉ាងនេះថា អធិករណ៍

នេះ រម្ងាប់ដោយសមថៈ ២, អធិករណ៍នេះ រម្ងាប់ដោយសមថៈ ៤, អធិករណ៍នេះ រម្ងាប់ដោយសមថៈ ៣, អធិករណ៍នេះ រម្ងាប់ដោយសមថៈ ១, ឈ្មោះថា មិនស្គាល់សេចក្តីរលត់នៃអធិករណ៍ ។

ពីរបទថា វត្ថុំ ន ជានាតិ : មិនស្គាល់វត្ថុ បានដល់ មិនស្គាល់វត្ថុនៃអាបត្តិ ៧ កង យ៉ាងនេះថា នេះជាវត្ថុនៃបារាជិក នេះជាវត្ថុនៃសង្ឃាទិសេស ។

បទថា និទានំ : និទាន បានដល់ មិនដឹងថា សិក្ខាបទនេះទ្រង់បញ្ញត្តិហើយក្នុងនគរនេះ បណ្តានគរទាំងឡាយ ៧ សិក្ខាបទនេះទ្រង់បញ្ញត្តិក្នុងនគរនេះ ។

ពីរបទថា បញ្ញត្តឹ ន ជានាតិ : មិនស្គាល់បញ្ញត្តិ បានដល់ អ្នកមិនស្គាល់បញ្ញត្តិដំបូងក្នុងសិក្ខាបទនោះ ៗ ។

បទថា អនុប្បញ្ញត្តឹ បានដល់ មិនស្គាល់បញ្ញត្តិបន្ថែម ។

បទថា អនុសន្ធិវចនបថំ : មិនស្គាល់គន្លងនៃពាក្យដែលតគ្នា បានដល់ មិនស្គាល់ដើម្បីពោលដោយអំណាចការបន្តជាប់គ្នានៃពាក្យសំដី និងការបន្តជាប់គ្នានៃពាក្យវិនិច្ឆ័យ ។

ពីរបទថា ញត្តឹ ន ជានាតិ : មិនស្គាល់ញត្តិ បានដល់ មិនស្គាល់ញត្តិគ្រប់ ៗ យ៉ាង ។

ប្រើនបទថា ញត្តិយា ករណំ ន ជានាតិ : មិនស្គាល់កិរិយាធ្វើញត្តិ មានសេចក្តីថា មិនស្គាល់កិច្ចដែលនឹងគប្បីធ្វើដោយញត្តិ ។ ឈ្មោះថា ញត្តិកម្ម រមែងប្រើក្នុង៩ ស្ថាន មានឱសារណាជាដើម ។ មិនដឹងថា ជាអ្នកចូលកម្មហើយដោយញត្តិ ក្នុងញត្តិទុតិយកម្មនិងញត្តិចតុត្ថកម្ម ។

ប្រើនបទថា ន បុព្វកុសលោ ហោតិ ន អបរកុសលោ : មិនស្គាល់កិច្ចខាងដើម មិនស្គាល់កិច្ចខាងចុង មានសេចក្តីថា មិនស្គាល់ពាក្យដែលត្រូវសូធ្យមុន និងពាក្យដែលត្រូវសូធ្យក្រោយខ្លះ, មិនដឹងថាធម្មតាញត្តិត្រូវតាំងមុនខ្លះ មិនគួរតាំងក្រោយខ្លះ ។

ពីរបទថា អកាលញ្ញូ ច ហោតិ : មិនស្គាល់កាលគួរ មានសេចក្តីថា មិនស្គាល់វេលា គឺ មិនបានទទួលប្រកាស មិនបានទទួលអារាធនា ក៏សូធ្យគឺ មិនស្គាល់ទាំងកាលញត្តិ ទាំងខេត្តញត្តិ ទាំងឱកាសនៃញត្តិ ។

# ភិក្ខុដែលនៅព្រៃ

[៦៤] ពីរបទថា មន្ទត្តា មោមូហត្តា : ដោយសេចក្ដីល្ងង់ សេចក្ដីវង្វេង បានដល់ មិនស្គាល់អានិសង្សក្នុងធុតង្គ ព្រោះជាអ្នកល្ងង់ដោយមិនដឹងគ្រប់យ៉ាង ។

បទថា ធាបិច្ឆោ : ប្រាថ្នាលាមក បានដល់ ប្រាថ្នាបច្ច័យលាភដោយការនៅព្រៃនោះ ។

បទថា បវិវេកំ : សេចក្ដីស្ងប់ស្ងាត់ បានដល់ កាយវិវេក ចិត្តវិវេក ឧបធិវិវេក ។

បទថា ឥទមដ្ឋិតំ : សេចក្ដីប្រតិបត្តិដែលមានប្រយោជន៍ផងមានវិគ្រោះថា ប្រយោជន៍នៃការនៅព្រៃនោះ រមែងមានដោយបដិបត្តិល្អនេះ ព្រោះហេតុនោះ ការនៅព្រៃនោះ ឈ្មោះថា ឥទមដ្ឋ (មានប្រយោជន៍ដោយការបដិបត្តិល្អនេះ) ។ ភាពជាអ្នកនៅព្រៃមានប្រយោជន៍ដោយការបដិបត្តិល្អ នេះឈ្មោះថា ឥទមដ្ឋិតា អាស្រ័យការនៅព្រៃមានប្រយោជន៍ ដោយការបដិបត្តិល្អនេះឯង, អធិប្បាយថា មិនពឹងលោកមិសតិចតួចដទៃ ។

# អង្គរបស់ភិក្ខុដែលត្រូវកាន់និស្ស័យ

[៦៥] ពីរបទថា ឧបោសថំ ន ជានាតិ : ភិក្ខុមិនស្គាល់ឧបោសថ បានដល់ មិនស្គាល់ឧបោសថ ៩ យ៉ាង ។

បទថា ឧបោសថកម្មំ បានដល់ មិនស្គាល់ឧបោសថកម្ម ៤ យ៉ាង ដោយប្រភេទផ្សេង ៗ មានជាពួក ដោយអធម៌ជាដើម ។

បទថា បាដិមោក្ខំ បានដល់ មិនស្គាល់មាតិកា ២ យ៉ាង ។

បទថា បាតិមោក្ខុទ្ទេសំ បានដល់ មិនស្គាល់បាដិមោក្ខុទ្ទេស ៩ យ៉ាង សូម្បីទាំងអស់ ។

បទថា បវារណំ បានដល់ មិនស្គាល់បវារណា ៩ យ៉ាង ។ បវារណាកម្មដូចនឹងឧបោសថកម្មនុ៎ះឯង ។

# វិនិច្ឆ័យក្នុងអបាសាទិកបញ្ចកៈ

[៦៦] វិនិច្ឆ័យក្នុងអបាសាទិកបញ្ចកៈ គប្បីជ្រាបដូច្នេះ ៖

អកុសលកម្ម មានកាយទុច្ចរិតជាដើម ហៅថា កម្មមិនគួរជ្រះថ្លា ។

កុសលកម្ម មានកាយសុចរិតជាដើម ហៅថា កម្មគួរជ្រះថ្លា ។

បទថា អតិវេលំ : ហួសវេលា មានសេចក្តីថា ប្រឹបូកប្រឹបល់នៅក្នុងត្រកូលទាំងឡាយហួសវេលា គឺអស់កាលច្រើន នៅក្នុងវិហារតិច ។ ការដែលកិលេសទាំងឡាយធ្លាក់ចុះខាងក្នុងឈ្មោះថា ប្រហោង ។

បទថា សច្ចិលិដ្ឋំ : ដែលសៅហ្មង បានដល់ អាបត្តិដោយប្រភេទផ្សេង ៗ មានអាបត្តិ ព្រោះទុដ្ឋុល្លវាចានិងអាបត្តិ ព្រោះកាយសំសគ្គៈជាដើម ។

វិនិច្ឆ័យក្នុងវិសុទ្ធិបញ្ចកៈ គប្បីជ្រាបដូច្នេះ ៖

បវារណាទាំង ៩ យ៉ាង គប្បីជ្រាបដោយបវារណាសូត្រ ។

បទដ៏សេសក្នុងទីទាំងពួង ងាយយល់ទាំងអស់ ដូច្នេះឯង ។

ពណ៌នាពួក ៥ ចប់

# ពណ្ណនាពួក ៦

[៧១] វិនិច្ឆ័យក្នុងពួក ៦ គប្បីជ្រាបដូច្នេះ ៖

ពីរបទថា ឆ សាមីចិយោ បានដល់ សាមីចិកម្ម ៦ ចំពោះក្នុងភិក្ខុបាដិមោក្ខទាំងនេះ គឺ "ភិក្ខុនោះ មិនបានឈ្មោះថា សង្ឃឱ្យអព្ភានកម្មផង, ទាំងពួកភិក្ខុ( ជាការកសង្ឃ )នោះ ឈ្មោះថា ត្រូវព្រះពុទ្ធជាម្ចាស់តិះដៀលបានផង ។ សេចក្តីប្រតិបត្តិនេះ ជាសាមីចិកម្មក្នុងកម្មនោះ"[១] ថា "អ្នកដ៏មានអាយុចូរទាមទារយករបស់ខ្លួនវិញចុះ, ទ្រព្យរបស់អ្នកទាំងឡាយកុំឱ្យវិនាសឡើយនេះ ជាសាមីចិ កម្មក្នុងសិក្ខាបទនោះ"[២] ។ ថា "ម្នាលភិក្ខុ នេះបាត្រ របស់លោក, លោកគប្បីប្រើប្រាស់ត្រាតែបែក ។ នេះ ជាសាមីចិកម្ម ក្នុងការលះបង់បាត្រនោះ"[៣] ។ "ត្រូវនាំចេញអំពីទីនោះ មកចែកមួយអន្លើដោយភិក្ខុទាំងឡាយ ការចែកនំ ឬ សដូវនេះ ជាសាមីចិកម្មក្នុងសិក្ខាបទនោះ"[៤] ។ "ម្នាលភិក្ខុទាំងឡាយ ភិក្ខុអ្នកសិក្សាគួរដឹងច្បាស់, គួរសាកសួរ, គួរពិចារណា, នេះ ជាសាមីចិកម្ម ក្នុងសិក្ខាបទនោះ"[៥] ។ "ដោយសំដៅថា វត្ថុនេះរបស់ជនណា ជននោះ នឹងនាំយកទៅ នេះជាសាមីចិកម្ម ក្នុងសិក្ខាបទនោះ"[៦] ។

---

១ វិន. សង្ឃា. ២. ៣៣០/៣៤៨ ។ ២. វិន. និស្ស. ៣. ៧០/៨១ ។
៣ វិន. បាចិ. ៣. ១៣០/១៥៨ ។ ៤. វិន. បាចិ. ៤. ១១៣/១១៥ ។
៥. វិន. បាចិ. ៤. ២៩៨/៣០៧ ។ ៦. វិន. បាចិ. ៤. ៣៥៨/៣៧០ ។

ពីរបទថា ឆ ឆេទនកា : ដែលមានកិរិយាកាត់ជាវិនយកម្ម មាន ៦ យ៉ាង បានដល់ អាបត្តិ ៥ ដែលពោលទុកក្នុងពួក ៥ នឹងសំពត់សម្រាប់ងូតទឹករបស់ភិក្ខុនីរួមជា ៦ ។

បទថា ឆ ឋានេហិ : ដោយអាការ ៦ យ៉ាង បានដល់ ជាអ្នកមិនខ្មាស, សេចក្តីមិនដឹង, ជាអ្នកសង្ស័យហើយនៅតែធ្វើ, ជាអ្នកមានសេចក្តីសម្គាល់ថា គួរ ក្នុងរបស់ដែលមិនគួរ, ជាអ្នកមានសេចក្តីសម្គាល់ថា មិនគួរ ក្នុងរបស់ដែលគួរ សេចក្តីភ្លេចសតិ ។

ក្នុងអាការ ៦ នោះ កាលត្រូវអាបត្តិ ព្រោះត្រៃចីវរ និង សត្តាហកាលិកកន្លងហួស ១ រាត្រី ៦ រាត្រី និង ៧ ថ្ងៃជាដើម ឈ្មោះថា ត្រូវព្រោះសេចក្តីភ្លេចសតិ ។ ពាក្យដ៏សេសមានន័យដូចពោលហើយនោះឯង ។

ច្រើនបទថា ឆ អានិសំសា វិនយធរេ : អ្នកទ្រទ្រង់វិន័យតែងបានអានិសង្ស ៦ ប្រការ បានដល់ អានិសង្ស ៥ ដែលពោលហើយក្នុងពួក ៥ រួមជា ៦ និងទាំងអានិសង្សនេះ គឺ ឧបោសថសម្រេចលើព្រះវិន័យធរនោះ ។

ពីរបទថា ឆ បរមានិ : សិក្ខាបទដែលមានទីកំណត់ មាន ៦ មានសេចក្តីថា "ទសាហបរមំ អតិរេកចីវរំ ធារេតព្វំ : ភិក្ខុត្រូវទុក

អតិរេកចីវរបានតែត្រឹមដប់ថ្ងៃ[១] ។ **មាសបរមំ តេន ភិក្ខុនា តំ ចីវរំ និក្ខិបិតព្វំ** : ភិក្ខុនោះត្រូវទុកចីវរនោះ យ៉ាងយូរបំផុតត្រឹម ១ ខែ[២] ។ **សន្តរុត្តរបរមំ តេន ភិក្ខុនា តតោ ចីវរំ សាទិតព្វំ** ភិក្ខុនោះ គប្បីត្រេកអរចំពោះចីវរនោះ តែត្រឹមអន្តរវាសកៈ និងឧត្តរាសង្គៈ[៣] ។ **ឆក្ខត្តុបរមំ តុណ្ហីភូតេន ឧទ្ទិស្ស ឋាតព្វំ** : ភិក្ខុគប្បីចូលទៅឈរស្ងៀមចំពោះមុខ ប្រាំមួយលើក យ៉ាងច្រើន[៤] ។ **នវំ បន ភិក្ខុនា សន្ថតំ ការាបេត្វា ឆព្វស្សានិ ធារេតព្វំ** : មួយទៀត ភិក្ខុឱ្យធ្វើសន្ថតថ្មី គប្បីប្រើប្រាស់ឱ្យអស់ ៦ ឆ្នាំ[៥]; ព្រោះដូច្នោះ សន្ថតថ្មីដែលភិក្ខុគប្បីទ្រទ្រង់ទុកដោយកាលមាន ៦ ឆ្នាំជាយ៉ាងយូរ ។ **តិយោជនបរមំ សហត្ថា ធារេតព្វានិ** : (រោមចៀមទាំងនោះ) ដែលភិក្ខុគប្បីនាំយកទៅដោយដៃខ្លួនឯង កាន់ចម្ងាយមកយ៉ាងឆ្ងាយត្រឹមបីយោជន៍[៦] ។ **ទសាហបរមំ អតិរេកបត្តោ ធារេតព្វោ** : អតិរេកបាត្រ ភិក្ខុទ្រទ្រង់ទុក បានត្រឹមកំណត់ ១០ថ្ងៃ[៧] ។ **សត្តាហបរមំ សន្និធិការកំ បរិភុញ្ជិតព្វានិ** : ភិក្ខុទទួលភេសជ្ជៈ ទាំងនោះហើយ គួរទុកឆាន់បានយ៉ាងយូរត្រឹម ៧ ថ្ងៃ[៨] ។ **ឆារត្តបរមំ តេន**

---

១. វិន. និស្ស. ចីវរវគ្គ. ៣. ២/៤ ។
២. វិន. និស្ស. ចីវរវគ្គ. ៣. ៣៣/២៧ ។
៣. វិន. និស្ស. ចីវរវគ្គ. ៣. ៥៨/៥៩ ។
៤. វិន. និស្ស. ចីវរវគ្គ. ៣. ៧០/៨១ ។
៥ វិន. និស្ស. ៣. ៨៧/១០២ ។
៦. វិន. និស្ស. ៣. ៩៧/១១៧ ។
៧. វិន. និស្ស. ៣. ១១០/១៤៧ ។
៨. វិន. និស្ស. ៣. ១៤០/១៧៥ ។

ភិក្ខុនា តេន ចីវរេន វិប្បវសិតព្វំ ៖ ភិក្ខុនោះ គប្បីនៅប្រាសចាកចីវរនោះ យ៉ាងយូរ ត្រឹម ៦ រាត្រី[១] ។ គរុបាបុរណំ បន ភិក្ខុនិយា ចេតាបេន្តិយា ចតុក្កំសបរមំ ចេតាបេតព្វំ ៖ ភិក្ខុនី កាលត្រូវចាត់ចែងសំពត់ដណ្តប់ ដែលមានសាច់ក្រាស់ ត្រូវចាត់ចែងបានតែសំពត់ដែលមានតម្លៃ ១៦ កហាបណៈជាយ៉ាងច្រើន[២] ។ លហុបាបុរណំ បន ភិក្ខុនិយា ចេតាបេន្តិយា អឌ្ឍតេយ្យកំសបរមំ ចេតាបេតព្វំ ៖ ភិក្ខុនី កាលត្រូវចាត់ចែងសំពត់ដណ្តប់ដែលមានសាច់ស្តើង ត្រូវចាត់ចែងបានតែសំពត់ដែលមានតម្លៃ ១០ កហាបណៈជាយ៉ាងច្រើន[៣] ។ ឧទកសុទ្ធិកំ បន ភិក្ខុនីយា អាទិយមានាយ ទ្វង្គុលបព្វបរមំ អាទាតព្វំ ៖ កាលភិក្ខុនីធ្វើការជម្រះដោយទឹក ត្រូវធ្វើការជម្រះបានត្រឹមពីរថ្នាំងម្រាមដៃ ២ ជាកំណត់[៤] ។ អដ្ឋង្គុលបរមំ ទន្តកដ្ឋំ ៖ ឈើស្ទន់ យ៉ាងវែងត្រឹម ៨ ធ្នាប់[៥] ។ អដ្ឋង្គុលបរមំ មញ្ចបដិបាទកំ ៖ ទ្រនាប់គ្រែយ៉ាងខ្ពស់ត្រឹម ៨ ធ្នាប់[៦] ។ រួមជាអតិរេក (ជាយ៉ាងច្រើន) ១៤ នេះ ដោយប្រការដូច្នេះ ។

---

១. វិន. និស្ស. ៣. ១៦៥/២១១ ។ ២. វិន. ភិក្ខុនី. ៥. ១៣៨/១៤៦ ។
៣. វិន. ភិក្ខុនី ៥. ១៤២/១៤៩ ។ ៤. វិន. ភិក្ខុនី. ៥. ១៦៤/១៦៤ ។
៥. វិន. ចុល្ល. ខុទ្ទកវត្ថុក្ខន្ធកៈ. ១០. ២៨៤/២២៧ ។ ៦. វិន. ចុល្ល. សេនាសនក្ខន្ធកៈ. ១០. ៣២៦/២៧៣ ។

ក្នុងអតិរេកទាំង ១៤ នោះ ៦ ដំបូង ជាពួក ៦ មួយប្រភេទ, តទៅនោះ គប្បីចាត់ពួក ៦ ពួកដទៃខ្លះ ដោយន័យមានជាដើម គឺ នាំចេញមួយពួក ដ៏សេសចាត់ចូលជាពួកមួយប្រភេទ ៗ ។

ពីរបទថា ឆ អាបត្តិយោ **:** អាបត្តិ ៦ យ៉ាង បានដល់ ពួកប្រាំមួយ ៣ ពួកដែលពោលហើយក្នុងអន្តរបេយ្យាល ។

ពីរបទថា ឆ កម្មានិ **:** សង្ឃកម្ម ៦ យ៉ាង បានដល់ តជ្ជនីយកម្ម និយស្សកម្ម បព្វាជនីយកម្ម បដិសារណីយកម្ម រួមជា ៤, ទាំងកម្មពីរដែលពោលព្រោះមិនឃើញអាបត្តិ និងព្រោះមិនសម្តែងអាបត្តិចេញ ១, កម្មព្រោះមិនព្រមលះបង់ទិដ្ឋិលាមក ១ ។

បទថា ឆ ឆហានេ **:** ក្នុងនហានសិក្ខាបទ មាន ៦ លើក បានដល់ (អនុប្បញ្ញត្តិ ៦) ព្រោះងូតទឹកនៅខ្វះកន្លះខែ ។

ពួកប្រាំមួយ ២ ពួកពោលអំពីចីវរដែលធ្វើឃាំងជាដើម បានអធិប្បាយទុកហើយក្នុងកឋិនក្ខន្ធកៈ ។

ពាក្យដ៏សេសក្នុងទីទាំងពួង ងាយយល់ទាំងអស់ ដូច្នេះឯង ។

ពណ៌នាពួក ៦ ចប់

# ពណ៌នាពួក ៧

[៧៥] វិនិច្ឆ័យក្នុងពួក ៧ គប្បីជ្រាបដូច្នេះ ៖

ពីរបទថា សត្ត សាមីចិយោ : សិក្ខាបទដែលមានពាក្យថា សាមីចិកម្ម (ប្រព្រឹត្តដោយសមគួរ) មាន ៧ មានសេចក្តីថា គប្បីជ្រាបសាមីចិកម្ម ៧ ព្រោះបន្ថែមពាក្យថា "ភិក្ខុនីនោះ ឈ្មោះថា ភិក្ខុនីសង្ឃមិនឱ្យអញ្ញាកម្មផង ភិក្ខុនីទាំងឡាយនោះ ឈ្មោះថា ត្រូវព្រះមានព្រះភាគតិះដៀលផង នេះជាសាមីចិកម្មក្នុងរឿងនោះ[១] នេះចូលក្នុងសាមីចិកម្ម ៦ ដែលពោលមកហើយក្នុងខាងដើម[២] ។

ច្រើនបទថា សត្ត អធម្មិកា បដិញ្ញាតករណា : សមថៈឈ្មោះបដិញ្ញាតករណៈ មិនប្រកបដោយធម៌ មាន ៧ យ៉ាង បានដល់ធ្វើតាមបដិញ្ញាដែលមិនប្រកបដោយធម៌ ៧ ដែលទ្រង់សម្តែងហើយក្នុងសមថក្ខន្ធកៈ យ៉ាងនេះថា "ភិក្ខុត្រូវអាបត្តិបារាជិកហើយ ។ សង្ឃក្តី ភិក្ខុច្រើនរូបក្តី បុគ្គល ១ រូបក្តី ចោទភិក្ខុនោះថា លោកមានអាយុត្រូវអាបត្តិបារាជិកហើយ ។ ភិក្ខុនោះនិយាយយ៉ាងនេះថា ម្នាលអាវុសោ ខ្ញុំមិនត្រូវអាបត្តិបារាជិកទេ ត្រូវអាបត្តិសង្ឃាទិសេសទេតើ ។ សង្ឃក៏ឱ្យ

១. វិន. ភិក្ខុនី. សង្ឃាទិសេស. ៥. ៩២/១០២ ។ ២. នៅក្នុងទំព័រ ១២៤ ។

ភិក្ខុនោះធ្វើ ( វុដ្ឋានវិធី ) ដោយអាបត្តិសង្ឃាទិសេស ។ ការធ្វើតាមប្តេជ្ញា យ៉ាងនេះ ឈ្មោះថា មិនប្រកបដោយធម៌ ។ "[១] សូម្បីធ្វើតាម បដិញ្ញាដែលប្រកបដោយធម៌ ក៏ទ្រង់បានសម្តែងហើយក្នុងសមថក្ខន្ធកៈ នោះឯង ។

ប្រើនបទថា សត្តន្នំ អនាបត្តិ សត្តាហករណីយេន គន្តុំ : ភិក្ខុទៅដោយសត្តាហករណី មិនត្រូវអាបត្តិ ព្រោះអាស្រ័យបុគ្គល ៧ ពួក នេះ បានពោលហើយក្នុងវស្សូបនាយិកក្ខន្ធកៈ ។

ពីរបទថា សត្តានិសំសា វិនយធរេ : ភិក្ខុអ្នកទ្រទ្រង់វិន័យ តែងបានអានិសង្ស ៧ យ៉ាង មានសេចក្តីថា អានិសង្ស ៥ ដែលពោល ហើយក្នុងពួក ៥ និងអានិសង្ស ២ នេះ គឺ ឧបោសថ បវារណាទីង សម្រេចលើព្រះវិន័យធរនោះ ទើបរួមជា ៧ ។

ពីរបទថា សត្ត បរមានិ : សិក្ខាបទដែលមានទីកំណត់ ៧ យ៉ាង បានដល់ យ៉ាងក្រៅលែងដែលពោលហើយក្នុងពួក ៦ នុ៎ះឯង គប្បីចាត់ដោយអំណាចពួក ៧ ។

ពួកប្រាំពីរ ២ ពួក មានពោលអំពីចីវរដែលធ្វើហើយជាដើម

---

១. វិន. ចុល្ល. សមថក្ខន្ធកៈ. ១០. ២៥/៣៧ ។

បានសម្តែងហើយក្នុងកឋិនក្ខន្ធកៈ ។ ពួកទាំងនេះ គឺ អាបត្តិដែលត្រូវឃើញ មិនមានដល់ភិក្ខុ, អាបត្តិដែលត្រូវឃើញមានដល់ភិក្ខុ, អាបត្តិដែលត្រូវសម្តែងចេញ មានដល់ភិក្ខុ, ជាពួកប្រាំពីរ ៣ ពួក ។

អធម្មិកៈ ២ ពួក, ធម្មិកៈ ១ ពួក ។ ទាំង ៣ ពួកនោះ បានសម្តែងហើយក្នុងចម្បេយ្យក្ខន្ធកៈ ។

[៧៧] បទថា អសទ្ធម្មា បានដល់ ធម៌របស់អសប្បុរស ឬធម៌ដែលមិនស្ងប់, អធិប្បាយថា ធម៌មិនល្អ គឺ អាក្រក់ លាមក ។

បទថា សទ្ធម្មា បានដល់ ធម៌របស់សប្បុរស គឺ របស់ព្រះអរិយៈមានព្រះពុទ្ធជាដើម ឬធម៌ដែលស្ងប់, អធិប្បាយថា ធម៌ដែលល្អ គឺ ខ្ពស់បំផុត ។

ពាក្យដ៏សេសក្នុងទីទាំងពួង ងាយយល់ទាំងអស់ ដូច្នេះឯង ។

ពណ៌នាពួក ៧ ចប់

# ពណ៌នាពួក ៨

[៧៩] វិនិច្ឆ័យក្នុងពួក ៨ គប្បីជ្រាបដូច្នេះ ៖

បទថា អដ្ឋានិសំសេ : អនិសង្ស ៨ បានដល់ អនិសង្ស ៨ ដែលត្រាស់ទុកក្នុងកោសម្ពិកក្ខន្ធកៈយ៉ាងនេះ គឺ យើងនឹងមិនធ្វើឧបោសថជាមួយនឹងភិក្ខុនេះ យើងនឹងវៀរលែងភិក្ខុនេះចេញ ទើបធ្វើឧបោសថ (នោះ), យើងមុខជាមិនបវារណាជាមួយនឹងភិក្ខុនេះ ..., យើងមុខជានឹងមិនធ្វើសង្ឃកម្មជាមួយនឹងភិក្ខុនេះដែរ ..., យើងមុខជានឹងមិនអង្គុយលើអាសនៈជាមួយនឹងភិក្ខុនេះដែរ ..., យើងមុខជានឹងមិនអង្គុយក្នុងទីឆាន់បបរជាមួយនឹងភិក្ខុនេះដែរ ..., យើងមុខជានឹងមិនអង្គុយក្នុងរោងភត្តជាមួយនឹងភិក្ខុនេះដែរ ..., យើងមុខជានឹងមិននៅក្នុងទីដែលមានដម្បូលមួយ ជាមួយនឹងភិក្ខុនេះដែរ ..., យើងមុខជានឹងមិនធ្វើអភិវាទនកម្ម (ការថ្វាយបង្គំ), បច្ចុដ្ឋានកម្ម (ក្រោកឡើងទទួល), អញ្ជលីកម្ម (ការប្រណម្យដៃគោរព) សាមីចិកម្ម (ការកោតក្រែង), តាមលំដាប់ចាស់ជាមួយនឹងភិក្ខុនេះដែរ, តែយើងវៀរលែងភិក្ខុនេះចេញហើយ ទើបធ្វើអភិវាទនកម្ម, បច្ចុដ្ឋានកម្ម, អញ្ជលីកម្ម, សាមីចិកម្ម, សូម្បីក្នុងពួកប្រាំបីទី ២ ក៏ន័យនេះឯង[១] ។

---

១. វិន. មហា. កោសម្ពិកក្ខន្ធកៈ. ៨. ១៤៥/៣១២ ។

ពិតមែន សូមប្បីពួកប្រាំបី ទី ២ នោះ ដែលព្រះមានព្រះភាគបានត្រាស់ទុកក្នុងកោសម្ពិកក្ខន្ធកៈយ៉ាងនេះដូចគ្នា ។

ពីរបទថា អដ្ឋ យាវតតិយកា : សិក្ខាបទជាយាវតតិយកាមាន ៨ បានដល់ សង្ឃាទិសេសដែលជាយាវតតិយកៈ ៤ ក្នុងសង្ឃាទិសេស ១៣ របស់ភិក្ខុទាំងឡាយ សង្ឃាទិសេសដែលជាយាវតតិយកៈ ៤ ដែលមិនទូទៅដោយពួកភិក្ខុ ក្នុងសង្ឃាទិសេស ១៧ របស់ភិក្ខុនីទាំងឡាយ ទើបរួមជាយាវតតិយកៈ ៨ ។

ច្រើនបទថា អដ្ឋហាការេហិ កុលានិ ទូសេតិ : ភិក្ខុទ្រុស្តត្រកូលដោយអាការ ៨ យ៉ាង មានសេចក្តីថា រមែងទ្រុស្តត្រកូលដោយអាការទាំង ៨ នេះ គឺ ដោយឱ្យផ្កាឈើខ្លះ, ផ្លែឈើខ្លះ, គ្រឿងលំអិតសម្រាប់ងូតខ្លះ, ដីស្អិតខ្លះ, ឈើស្ទន់ខ្លះ, ឫស្សីខ្លះ, ដោយកិរិយាធ្វើពេទ្យខ្លះ, ដោយការបម្រើដោយស្ទូងខ្លះ[1] ។

មាតិកា ៨ ( ដើម្បីកើតឡើងនៃចីវរ ) ពោលហើយក្នុងចីវរក្ខន្ធកៈ មាតិកា៨ក្រោយ ( ដើម្បីដោះកឋិន ) បានពោលហើយក្នុងកឋិនក្ខន្ធកៈ ។

ពីរបទថា អដ្ឋហិ អសទ្ធម្មេហិ : អសទ្ធម្ម ៨ ប្រការ មាន

---

១. វិន. សង្ឃា. កុលទូសកសិក្ខាបទ ២. ៣២២/៣៤១ ។

សេចក្តីថា ព្រោះលាភ មិនមានលាភ ព្រោះយស មិនមានយស ព្រោះសក្ការៈ មិនមានសក្ការៈ ព្រោះជាអ្នកមានប្រាថ្នាលាមក ព្រោះជាអ្នកមានបាបមិត្ត[1] ។

ឈ្មោះថា លោកធម៌ ៨ គឺ ត្រេកអរក្នុងលាភ ប្រទូស្តក្នុងការមិនមានលាភ ត្រេកអរក្នុងយស សរសើរ សុខ ប្រទូស្តក្នុងការមិនមានយស និន្ទា ទុក្ខ ។

ពីរបទថា អដ្ឋង្គិកោ មុសាវាទោ : មុសាវាទប្រកបដោយអង្គ ៨ បានដល់ ការពោលកុហកដែលប្រកបដោយអង្គ ៨ គឺ អង្គ ៧ ដែលមកក្នុងបាលីទីងអង្គនេះ គឺ វិនិធាយ សញ្ញំ : បិទបាំងនូវសេចក្តីសំគាល់ ទើបជាមុសាវាទ ប្រកបដោយអង្គ ៨ ។

ពីរបទថា អដ្ឋ ឧបោសថង្គានិ : អង្គរបស់ឧបោសថ បានដល់ អង្គ ៨ ដែលព្រះមានព្រះភាគត្រាស់ទុកយ៉ាងនេះថា ៖

បុគ្គលមិនគប្បីសម្លាប់សត្វ ១ មិនគប្បីកាន់យកវត្ថុដែលគេមិនឱ្យ ១ មិនគប្បីពោលពាក្យកុហក ១ មិនគប្បីផឹកទឹកស្រវឹង ១ គប្បីវៀរចាកការប្រព្រឹត្តមិនប្រសើរគឺមេថុន ១

១. វិន. ចុល្ល. សង្ឃភេទក្ខន្ធកៈ. ១១. ៦៥/៧១ ។

មិនគប្បីបរិភោគភោជន ក្នុងវេលារាត្រីនិងក្នុងវេលាវិកាល ១ មិនគប្បីទ្រទ្រង់ផ្កាក្រអូប និងមិនគប្បីប្រស់ព្រំដោយគ្រឿងក្រអូប ១ គប្បីដេកលើគ្រែលើផែនដី ឬលើកម្រាល(ដែលសមគួរ) ១ ព្រះពុទ្ធព្រះអង្គ ដល់ទីបំផុតនៃទុក្ខ ទ្រង់ប្រកាសហើយនូវឧបោសថ ដែលប្រកបដោយអង្គ ៨ ប្រការនេះឯង[1] ។

ពីរបទថា អដ្ឋ ទូតេយ្យង្គានិ : អង្គរបស់ភិក្ខុដែលជាទូត មាន ៨ បានដល់ អង្គ ៨ ដែលព្រះមានព្រះភាគត្រាស់ទុកក្នុងសង្ឃភេទក្ខន្ធកៈ ដោយន័យមានជាដើមថា "ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកស្តាប់បានដោយខ្លួនឯង ១ ញុំាងបុគ្គលដទៃឱ្យស្តាប់បាន ១"[2] ។

តិត្ថិយវត្ត បានទ្រង់សម្តែងហើយក្នុងមហាខន្ធកៈ[3] ។

ខាទនីយៈ ភោជនីយៈ មិនជារបស់សល់និងជារបស់សល់ ទ្រង់បានសម្តែងហើយក្នុងបវារណាសិក្ខាបទ[4] ។

ពីរបទថា អដ្ឋន្នំ បច្ចុដ្ឋាតព្វំ : ត្រូវក្រោកទទួលបុគ្គល ៨ ពួក

---

១. អង្គុ. អដ្ឋ. ឧបោសថវគ្គ. ៤៨. ៤២/១៩៤ ។ ២. វិន. ចុល្ល. សង្ឃភេទក្ខន្ធកៈ. ១១. ៦២/៧០ ។ ៣. វិន. មហា. មហាខន្ធកៈ. ៦. ១០០/២៣១ ។ ៤. វិន. បាចិ. ភោជនវគ្គ. ៤. ១១៨/១២១ ។

មានសេចក្តីថា ក្នុងពេលឆាន់ គប្បីក្រោកឡើងទទួលភិក្ខុនីចាស់ទាំងឡាយ សូម្បីអាសនៈ ក៏គប្បីឱ្យដល់ភិក្ខុនីទាំងនោះពិត ។

បទថា ឧបាសិកា បានដល់ ឧបាសិកាវិសាខា ។

ពីរបទថា អដ្ឋានិសំសា វិនយធរេ : អានិសង្សវិនយធរ មាន ៨ មានសេចក្តីថា គប្បីជ្រាបអានិសង្ស ៨ ព្រោះថែមអានិសង្ស ៣ នេះ គឺ ឧបោសថ បវារណា សង្ឃកម្ម សម្រេចលើភិក្ខុនោះ ចូលក្នុងអានិសង្ស ៥ ដែលពោលហើយក្នុងពួក ៥ ។

ពីរបទថា អដ្ឋ បរមានិ : សិក្ខាបទដែលមានទីកំណត់ មាន ៨ បានដល់ គប្បីជ្រាបយ៉ាងក្រៃលែងទាំងឡាយ ដែលពោលហើយក្នុងកាលមុននុ៎ះឯង តែចាត់ដោយអំណាចពួក ៨ ។

ច្រើនបទថា អដ្ឋសុ ធម្មេសុ សម្មាវត្តិតព្វំ : គួរប្រព្រឹត្តដោយប្រពៃក្នុងធម៌ ៨ ប្រការ បានដល់ ក្នុងធម៌ ៨ ដែលទ្រង់សម្តែងក្នុងសមថក្ខន្ធកៈ ដោយន័យមានពាក្យថា មិនគប្បីវៀរឧបោសថដល់ភិក្ខុជាបកតត្ត មិនគប្បីវៀរបវារណា ដល់ភិក្ខុជាបកតត្តជាដើម ។

ពាក្យដ៏សេសក្នុងទីទាំងពួង ងាយយល់ទាំងអស់ ដូច្នេះឯង ។

ពណ៌នាពួក ៨ ចប់

# ពណ៌នាពួក ៩

[៨១] វិនិច្ឆ័យក្នុងពួក ៩ គប្បីជ្រាបដូច្នេះ ៖

ពីរបទថា នវ អាឃាតវត្ថូនិ : វត្ថុជាទីកើតនៃគំនុំ មាន ៩ បានដល់ អាឃាតវត្ថុ ៩ មាន "បុគ្គលចងគំនុំដោយគិតថា ជនឯណោះ បានប្រព្រឹត្តធ្វើនូវអំពើមិនជាប្រយោជន៍ដល់អាត្មាអញហើយ"[១] ជាដើម ។

ពីរបទថា នវ អាឃាតបដិវិនយា : ធម៌សម្រាប់កម្ចាត់នូវគំនុំ មាន ៩ បានដល់ ឧបាយកម្ចាត់អាឃាត ៩ មានពាក្យថា "បុគ្គលកម្ចាត់បង់នូវគំនុំ ដោយគិតថា ជនឯណោះ បានប្រព្រឹត្តធ្វើនូវអំពើមិនជាប្រយោជន៍ដល់អាត្មាអញហើយ អាត្មាអញគប្បីបាននូវអំពើមិនជាប្រយោជន៍នោះ ក្នុងបុគ្គលនុ៎ះអំពីណា"[២] ដូច្នេះ ជាដើម ។

ពីរបទថា នវ វិនីតវត្ថូនិ : វិនីតវត្ថុ មាន ៩ បានដល់ ការវៀរ ការវៀរបង់ ការកម្ចាត់នូវវត្ថុនៃអាឃាត ៩ ចេញដោយអរិយមគ្គ ។

---

១. អង្គុ. ទស. អាកង្ខវគ្គ. ៥០. ៧៩/៣២៦ ។ ២. អង្គុ. ទស. អាកង្ខវគ្គ. ៥០. ៨០/៣២៧ ។

ប្រែថាបទថា នវហិ សង្ឃោ ភិជ្ជតិ : **សង្ឃបែកគ្នាដោយធម៌ ៩ ប្រការ** បានដល់ ការបែកគ្នានៃសង្ឃ ដែលព្រះមានព្រះភាគត្រាស់ថា "ម្នាលឧបាលិ សេចក្តីប្រេះឆានៃសង្ឃនិងសង្ឃភេទ រមែងមានដល់ភិក្ខុ ៩ រូបក៏មាន ដល់ភិក្ខុច្រើនជាង ៩ រូបទៅក៏មាន"[១] ដូច្នេះ ។

ពីរបទថា នវ បរមានិ : **សិក្ខាបទដែលមានទីកំណត់ មាន ៩** បានដល់ គប្បីជ្រាបយ៉ាងក្រៃលែងទាំងឡាយ ដែលពោលហើយក្នុងកាលមុនទុំះឯង តែចាត់ដោយអំណាចពួក ៩ ។

**ធម៌ដែលមានតណ្ហាជាមូល មាន ៩** បានដល់ ការអាស្រ័យតណ្ហា ទើបមានការស្វែងរក ១ អាស្រ័យការស្វែងរក ទើបកើតលាភ ១ អាស្រ័យលាភ ទើបកើតសេចក្តីត្រិះរិះ ១ អាស្រ័យសេចក្តីត្រិះរិះ ទើបកើតសេចក្តីប្រាថ្នា សេចក្តីត្រេកអរ ១ អាស្រ័យសេចក្តីប្រាថ្នា សេចក្តីត្រេកអរ ទើបកើតសេចក្តីជ្រៀតជ្រាប់ ១ អាស្រ័យសេចក្តីជ្រៀតជ្រាប់ ទើបកើតការហួងហែងទុក ១ អាស្រ័យការហួងហែងទុក ទើបកើតសេចក្តីកំណាញ់ ១ អាស្រ័យសេចក្តីកំណាញ់ ទើបកើតការរក្សាទុក ១

---

១. វិន. ចុល្ល. សង្ឃភេទក្ខន្ធកៈ. ១១ ៦៧/៧៨ ។

អាស្រ័យករក្សា ជាហេតុហើយ ទើបកើតអកុសលធម៌ទាំងឡាយដ៏លាមកជាច្រើន គឺ ការកាន់ដម្បង ការកាន់គ្រឿងសស្ត្រាវុធ ឈ្លោះទាស់ទែង ជេរគ្នាថា ឯង ៗ (អា មឹង មី ហង) ទាំងនិយាយញុះញង់ និយាយកុហក ក៏កើតឡើង ១ ។[១]

បទថា នវាឃាតវត្ថូនិ : មានះ មាន ៩ ប្រការ បានដល់ មានះរបស់បុគ្គលប្រសើរថា "អញជាបុគ្គលប្រសើរ"[២] ជាដើម ។

ពីរបទថា នវ ចីវរានិ : ចីវរ ៩ ប្រការ មានសេចក្ដីថា ចីវរដែលព្រះមានព្រះភាគត្រាស់ដោយន័យមានជាដើមថា ត្រៃចីវរក្ដី សំពត់សម្រាប់ជូតទឹកភ្លៀងក្ដី ជាដើម[៣] ។

បទថា ន វិកប្បេតព្វានិ : មិនគួរវិកប្ប មានសេចក្ដីថា ចាប់ផ្ដើមតាំងពីកាលដែលភិក្ខុអធិដ្ឋានហើយ មិនគួរវិកប្ប ។

ច្រើនបទថា នវ អធម្មិកានិ ទានានិ : ទានដែលមិនប្រកបដោយធម៌ មាន ៩ យ៉ាង មានសេចក្ដីថា ទានដែលព្រះមានព្រះភាគ

១. អង្គុ. នវ. សត្តាវាសវគ្គ. ៤៩ ២៣/៩១-២ ។ ២. ខុទ្ទ. មហា. ទុដ្ឋដ្ឋកសុត្តនិទ្ទេស. ៦៤ ១០២/១៤៩ ។ ៣. វិន. មហា. ចីវរក្ខន្ធកៈ ៨. ៦៦/១៤២ ។

ត្រាស់យ៉ាងនេះថា លាភគេបង្អោនទៅដើម្បីសង្ឃ តែភិក្ខុបង្អោនមកដើម្បីសង្ឃដទៃវិញក្តី ដើម្បីចេតិយក្តី ដើម្បីបុគ្គលក្តី ។ លាភគេបង្អោនទៅដើម្បីចេតិយ ភិក្ខុបង្អោនមក ដើម្បីចេតិយដទៃវិញក្តី ដើម្បីសង្ឃក្តី ដើម្បីបុគ្គលក្តី ។ លាភគេបង្អោនទៅដើម្បីបុគ្គលហើយ ភិក្ខុត្រឡប់បង្អោនមកដើម្បីបុគ្គលដទៃវិញក្តី ដើម្បីសង្ឃក្តី ដើម្បីចេតិយក្តី ។[១]

ប្រើបទថា នវ បដិគ្គហា បរិភោគា : ការទទួល, ការបរិភោគ, មាន ៩ បានដល់ ទទួល និងបរិភោគទានទាំងនោះឯង ។

ប្រើបទថា តីណិ ធម្មិកានិ ទានានិ : ទានដែលប្រកបដោយធម៌ ៣ យ៉ាង បានដល់ ទាន ៣ នេះ គឺឱ្យរបស់ដែលគេថ្វាយសង្ឃដល់សង្ឃប៉ុណ្ណោះ, ឱ្យរបស់ដែលគេថ្វាយចេតិយដល់ចេតិយប៉ុណ្ណោះ, ឱ្យរបស់ដែលគេថ្វាយបុគ្គលដល់បុគ្គលប៉ុណ្ណោះ ។ សូម្បីការទទួល និងបរិភោគ ក៏គឺ ទទួលនិងបរិភោគទាន ៣ នោះឯង ។

ប្រើបទថា នវ អធម្មិកា សញ្ញត្តិយោ : ការពន្យល់ ឬបញ្ជាក់ ដែលមិនប្រកបដោយធម៌ ៩ យ៉ាង បានដល់ តិកៈ ៣ ដែល

១. វិន. បាចិ. ៤. ៣៤៧/៣៥២ ។

ទ្រង់សម្តែងហើយ ក្នុងសមថក្ខន្ធកៈយ៉ាងនេះ គឺ បុគ្គលជាអធម្មវាទី, គណៈជាអធម្មវាទី, សង្ឃជាអធម្មវាទី ។ សូម្បីបញ្ញត្តិដែលប្រកបដោយធម៌ ក៏ទ្រង់សម្តែងហើយក្នុងសមថក្ខន្ធកៈនោះឯង ដោយន័យមានជាដើមថា បុគ្គលជាធម្មវាទី[១] ដូច្នេះ ។

ពួកប្រាំបួន ២ ពួក ក្នុងកម្មមិនជាធម៌ ព្រះមានព្រះភាគបានត្រាស់ទុកហើយ ដោយអំណាចនៃបាចិត្តិយ ក្នុងនិទ្ទេសនៃសិក្ខាបទទី ១ នៃឱវាទវគ្គ[២] ។

ពួកប្រាំបួន ២ ពួក ក្នុងកម្មជាធម៌ ព្រះមានព្រះភាគបានត្រាស់ហើយ ដោយអំណាចនៃទុក្កដ ក្នុងនិទ្ទេសនៃសិក្ខាបទទី ១ នៃឱវាទវគ្គនោះដូចគ្នា ។

ពាក្យដ៏សេសក្នុងទីទាំងពួង ងាយយល់ទាំងអស់ ដូច្នេះឯង ។

ពណ៌នាពួក ៩ ចប់

---

១. វិន. ចុល្ល. សមថក្ខន្ធកៈ. ១០. ២/៣ ។ ២. វិន. បាចិ. ៤. ២៩/៣៤ ។

## ពណ៌នាពួក ១០

[៨៣] វិនិច្ឆ័យក្នុងពួក ១០ គប្បីជ្រាបដូច្នេះ ៖

ពីរបទថា ទស អាឃាតវត្ថូនិ : វត្ថុជាទីកើតគំនុំ មាន ១០ បានដល់ អាឃាតវត្ថុ ៩ ដែលពោលហើយក្នុងពួក ៩ នីងមួយប្រការនេះថា ក៏អាឃាត រមែងកើតឡើងក្នុងអដ្ឋានៈ ទើបរួមជា ១០ ។ សូម្បីឧបាយកម្ចាត់អាឃាត គប្បីជ្រាបឧបាយ ៩ ដែលពោលហើយក្នុងពួក ៩ នោះ រួមជា ១០ ទាំងពាក្យនេះថា ក៏អាឃាតកើតក្នុងអដ្ឋានៈ ទើបកម្ចាត់អាឃាតចេញ ដោយពិចារណាថា "អាត្មាអញ គប្បីបាននូវអំពើមិនជាប្រយោជន៍នោះ ក្នុងបុគ្គលនុ៎ះអំពីណា"[១] ។

ពីរបទថា ទស វិនីតវត្ថូនិ : វិនីតវត្ថុ មាន ១០ បានដល់ វិនីតវត្ថុ ១០ ពោលគឺ វៀរចាកអាឃាតវត្ថុ ១០ ។

ពីរបទថា ទសវត្ថុកា មិច្ឆាទិដ្ឋិ : មិច្ឆាទិដ្ឋិ មានវត្ថុ ១០ បានដល់ គប្បីជ្រាបដោយអំណាចនៃវត្ថុថា "ទានដែលបុគ្គលឱ្យហើយ មិនមានផល"ជាដើម[២] ។

---

១. អង្គុ. ទស. អាកង្ខវគ្គ. ៥០. ៨០/៣២៧ ។ ២. មជ្ឈិ. មូល. សាលេយ្យកសូត្រ. ២២. ១២៤-៥/២៤៥,២៤៩ ។

សម្មាទិដ្ឋិ គប្បីជ្រាបដោយអំណាចវត្ថុថា "ទានដែលបុគ្គលឱ្យហើយ មាន ផល"[១] ជាដើម ។

ចំណែកអន្តគាហិកទិដ្ឋិ គប្បីជ្រាបដោយអំណាចនៃសេចក្តីឃើញថា "លោកទៀង"ជាដើម ។ មិច្ឆត្តៈ ១០ មានមិច្ឆាទិដ្ឋិជាដើម មានមិច្ឆាវិមុត្តិជាបរិយោសាន ។ ទិដ្ឋិដែលផ្ទុយគ្នា ជាសម្មត្តៈ ។

ការចាប់ស្លាក ទ្រង់សម្តែងហើយក្នុងសមថក្ខន្ធកៈ[២] ។

[៨៥] ត្រើនបទថា ទសហាង្គេហិ សមន្នាគតោ ភិក្ខុ ឧព្វាហិកាយសម្មន្និតព្វោ : ភិក្ខុប្រកបដោយអង្គ ១០ សង្ឃគួរសន្មតដោយឧព្វាហិកាកម្ម បានដល់ ដោយអង្គ ១០ ដែលត្រាស់ទុកក្នុងសមថក្ខន្ធកៈ[៣] ដោយន័យមានពាក្យថា "ភិក្ខុជាអ្នកមានសីល"ជាដើម ។

ទោស ១០ ប្រការ ក្នុងការចូលកាន់ខាងក្នុងរាជវាំង បានទ្រង់សម្តែងហើយក្នុងរាជសិក្ខាបទ[៤] ។

ពីរបទថា ទស ទានវត្ថូនិ : ទានវត្ថុ មាន ១០ យ៉ាង បានដល់ បាយ ទឹក សំពត់ យានជំនិះ ផ្កាកម្រង គ្រឿងក្រអូប គ្រឿង

---

១. មជ្ឈិ. មូល. សាលេយ្យកសូត្រ. ២២. ១២៤-៥/២៤៥,២៤៩ ។

២. វិន. ចុល្ល. សមថក្ខន្ធកៈ. ១០. ២៩/៤៣ ។ ៣. វិន. ចុល្ល. សមថក្ខន្ធកៈ. ១០. ៩១/៨៨ ។ ៤. វិន. បាចិ. រតនវគ្គ. ៤. ៣៥១/៣៥៩ ។

លាប ទីដេក ទីអង្គុយ គ្រឿងប្រទីប ។

ពីរបទថា ទស រតនានិ : រតនៈ មាន ១០ យ៉ាង បានដល់កែវ ១០ ប្រការ មានមុក្តា មណី ពិទូរ្យ ជាដើម ។

ពីរបទថា ទស បំសុកូលានិ : សំពត់បង្សុកូល មាន ១០ យ៉ាង មានសេចក្តីថា ឧបសម្បន្នគប្បីធ្វើសេចក្តីខ្វល់ខ្វាយក្នុងចីវរទាំងនេះ គឺ សំពត់ដែលធ្លាក់ក្នុងព្រៃជាទីចោលសាកសព, សំពត់ដែលធ្លាក់ត្រង់ទ្វារផ្សារ, សំពត់ដែលកណ្តុរកកេរ, សំពត់ដែលកណ្តៀរស៊ី, សំពត់ដែលត្រូវភ្លើងឆេះ, សំពត់ដែលគោទំពា, សំពត់ដែលពពែហែកស៊ី, សំពត់គ្របជំបូក, សំពត់ដែលគេចោលក្នុងទីអភិសេក, សំពត់ដែលគេនាំទៅកាន់ព្រៃជាទីចោលសាកសពហើយនាំត្រឡប់មក ។

ក្នុងអដ្ឋកថា កុរុន្ទីពោលថា ចីវរសាធារណៈ ១០ នោះ បានដល់ចីវរ ១០ ប្រភេទ ដោយអំណាចចីវរដែលព្រះធម្មសង្គាហកាចារ្យពោលថា "ពួកឆព្វគ្គិយភិក្ខុ ទ្រទ្រង់ចីវរខៀវសុទ្ធ"[១] ជាដើម ។

តែក្នុងមហាអដ្ឋកថា ពោលថា បានដល់ ចីវរ ១០ ប្រភេទ បន្ថែមសំពត់ងូតទឹក ឬសំពត់ចោមពុង (របស់ភិក្ខុនី) ចូលក្នុងចីវរដែលគួរ ៩ ប្រភេទ ។

១. វិន. មហា. ចីវរក្ខន្ធកៈ. ៨. ៧៥/១៦៩ ។

បុគ្គលមិនគួរសំពះ បានសម្តែងហើយក្នុងសេនាសនក្ខន្ធកៈ ។
អក្កោសវត្ថុ បានសម្តែងហើយក្នុងឱមសវាទសិក្ខាបទ ។
អាការ ១០ បានសម្តែងហើយក្នុងបេសុញ្ញសិក្ខាបទ ។

ពីរបទថា ទស សេនាសនានិ : សេនាសនៈ មាន ១០ យ៉ាង បានដល់ ខ្នើយ ពូក ទ្រនាប់គ្រែ ទ្រនាប់តាំង កម្រាលផែនដី កន្ទេលទន់ (កម្រាលក្រាលលើកម្រាលផែនដី) ប្រមខណ្ឌ (កំណាត់ស្បែក) និសីទនៈ (សំពត់ទ្រាប់អង្គុយ) កម្រាលដែលគេធ្វើដោយស្មៅ កម្រាលដែលគេធ្វើដោយស្លឹកឈើ ។[១]

ប្រើនបទថា ទស វរានិ យាចិំសុ : ជនទាំងឡាយ បានសូមពរទាំង ១០ មានសេចក្តីថា នាងវិសាខាបានសូមពរ ៨ ប្រការ, ព្រះបាទសុទ្ធោទនៈបានទ្រង់សូមពរ ១ ប្រការ, ពេទ្យជីវកបានសូមពរ ១ ប្រការ ។

អានិសង្សនៃយាគូ និងអកប្បិយមំសៈ បានទ្រង់សម្តែងហើយក្នុងភេសជ្ជក្ខន្ធកៈ ។

បទដ៏សេសក្នុងទីទាំងពួងងាយយល់ទាំងអស់ ដូច្នេះឯង ។

ពណ៌នាពួក ១០ ចប់

---

១. វិន. បាចិ. ភូតគាវគ្គ. ៣. ៣៨០/៣៧៧ ។

## ពណ៌នាពួក ១១

[៨៧] វិនិច្ឆ័យក្នុងពួក ១១ គប្បីជ្រាបដូច្នេះ ៖

បទថា ឯកាទស បានដល់ បុគ្គល ១១ ពួក មានបណ្ឌកៈជាដើម ។

ពីរបទថា ឯកាទស បាទុកា : ទ្រនាប់ជើង មាន ១០ យ៉ាង បានដល់ ទ្រនាប់ជើង ១០ យ៉ាង ជាវិការនៃរតនៈ ទ្រនាប់ជើងឈើ ១, ចំណែកទ្រនាប់ជើងធ្វើដោយស្មៅធម្មតា ស្មៅយាប៉ូង និងស្មៅដំណេកទន្សាយជាដើម ចាត់ចូលពួកទ្រនាប់ជើងឈើដូចគ្នា ។

ពីរបទថា ឯកាទស បត្តា : បាត្រ មាន ១១ យ៉ាង បានដល់ បាត្រដែលធ្វើដោយរតនៈ ១០ ប្រភេទរួមទាំងបាត្រដែលធ្វើដោយស្ពាន់ ឬធ្វើដោយឈើ ។

ពីរបទថា ឯកាទស ចីវរានិ : ចីវរ មាន ១១ យ៉ាង បានដល់ ចីវរខៀវសុទ្ធជាដើម ។

ពីរបទថា ឯកាទស យាវតតិយកា : អាបត្តិ ជាយាវតតិយកា មាន ១១ យ៉ាង បានដល់ ឧក្ខិត្តានុវត្តិកា ១ សង្ឃាទិសេសរបស់ភិក្ខុនី៨ អរិដ្ឋសិក្ខាបទ១ ចណ្ឌកាលីសិក្ខាបទ[១] ១ ។

---

១. គឺសោកាវាសសិក្ខាបទក្នុងកុមារិភូតវគ្គ ។

អន្តរាយិកធម៌ទាំងឡាយ ដែលភិក្ខុនីសួចសួរកម្មវាចា គប្បីសួរមានពាក្យថា "នសិ អនិមិត្តា : នាងមិនមែនឥតនិមិត្តទេឬ"[១] ជាដើម ឈ្មោះថា អន្តរាយិកធម៌ ១១ ។

ត្រើនបទថា ឯកាទស ចីវរានិ អធិដ្ឋាតព្វានិ : ចីវរដែលគួរអធិដ្ឋាន មាន ១១ យ៉ាង បានដល់ ត្រៃចីវរសំពត់ងូតទឹកភ្លៀង សំពត់និសីទនៈ សំពត់ក្រាលដេក សំពត់បិទបូស សំពត់ជូតមុខបរិក្ខារចោឡសំពត់ងូតទឹក សំពត់ចោមពុង ។

បទថា ន វិកប្បេតព្វានិ : មិនគួរវិកប្ប មានសេចក្តីថា ចីវរ ១១ ប្រភេទនោះឯង ចាប់ផ្តើមតាំងពីកាលដែលអធិដ្ឋានហើយ មិនគួរវិកប្ប ។

ក្តុំនិងក្រវិល មាន១១ យ៉ាង រួមទាំងដែលត្បាញដោយអំបោះ ។ ទាំងអស់នោះបានសម្តែងហើយក្នុងខុទ្ទកវត្ថុខន្ធកៈ ។

បវារី បានសម្តែងហើយក្នុងបវារីសិក្ខាបទ ។

រម្ងាប់និស្ស័យ ចាកឧបជ្ឈាយ៍ ៥ ចាកអាចារ្យ ៦ រួមជា ១១ យ៉ាងនេះ ។

១. វិន. ចុល្ល. ភិក្ខុនីខន្ធកៈ. ១១. ២៣៧/៣១៣ ។

បុគ្គលមិនគួរសំពះ រួមទាំងបុគ្គលអ្នកអាក្រោតកាយ ទើបជា ១១, បុគ្គលមិនគួរសំពះទាំងអស់នោះ បានសម្តែងហើយក្នុងសេនាសនក្ខន្ធកៈ ។

អតិរេក ១១ គប្បីជ្រាបក្នុងអតិរេក ១៤ ដែលពោលហើយក្នុងកាលមុន តែចាត់ដោយអំណាចពួក ១១ ។

ពីរបទថា ឯកាទស វរានិ : ពួកជនបានសូមពរ ១១ ប្រការ បានដល់ ពរ ១០ ប្រការដែលពោលហើយខាងដើម និងពរដែលព្រះនាងមហាបជាបតីទូលសូម[១] ។

សីមាវិបត្តិ ១១ យ៉ាង ដែលមកក្នុងកម្មវគ្គ ដោយន័យមានពាក្យថា សន្មតសីមាតូចពេកជាដើម ។

ដែលឈ្មោះថា ទោស ១១ ប្រការ របស់បុគ្គលដែលតិះដៀលជេរប្រទេច គប្បីជ្រាបដោយព្រះបាលីថា “ម្នាលភិក្ខុទាំងឡាយ ភិក្ខុ

១. វិន. ចុល្ល. ភិក្ខុនីខន្ធកៈ ១១. ១៨៥/២៧៥ ថា “បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំម្ចាស់សូមអង្វរ សូមព្រះមានព្រះភាគទ្រង់អនុញ្ញាតការថ្វាយបង្គំ ការក្រោកទទួល ការធ្វើអញ្ជលីកម្ម ដល់ពួក ភិក្ខុផង ដល់ពួកភិក្ខុនីផង តាមលំដាប់វស្សាចាស់ខ្ចី” តែទ្រង់មិនអនុញ្ញាត ។

ដែលតិះដៀលព្រះអរិយៈដេរប្រទេចពួកភិក្ខុជាសព្រហ្មចារី, ហើយមិនគប្បីដល់នូវសេចក្តីវិនាសទាំង ១១ យ៉ាងណាមួយទុំះ មិនមែនជាហេតុ មិនមែនជាបច្ច័យឡើយ ។ សេចក្តីវិនាសទាំង ១១ យ៉ាង តើអ្វីខ្លះ ? គឺ (ភិក្ខុនោះ) មិនបាននូវគុណវិសេសដែលខ្លួនមិនទាន់បាន ១ សាបសូន្យចាកគុណវិសេសដែលខ្លួនបានហើយ ១ ព្រះសទ្ធម្មរបស់ភិក្ខុនោះ មិនផូរផង់ ១ មានសេចក្តីមើលងាយក្នុងព្រះសទ្ធម្ម ១ មិនត្រេកអរនឹងប្រព្រឹត្តព្រហ្មចរិយៈ ១ ត្រូវអាបត្តិណាដ៏សៅហ្មង ១ លះបង់សិក្ខាហើយត្រឡប់មក ដើម្បីភេទថោកទាប១ ប៉ះនឹងរោគធ្ងន់ខ្លាំង១ ដល់នូវការឆ្កួត វើវវាយចិត្ត១ ធ្វើកាលកិរិយាទាំងវង្វេង១ លុះបែកធ្លាយរាងកាយស្លាប់ទៅ ទៅកើតក្នុងអបាយ ទុគ្គតិ វិនិបាត នរក១”[១] ។ ក៏ព្រះពុទ្ធវចនៈ ព្រះមានព្រះភាគទ្រង់ប្រាថ្នាថា សទ្ធម្ម ក្នុងបទថា សទ្ធម្មស្ស នេះ ។

បទថា អាសេវិតាយ : ដែលបុគ្គលធ្វើឱ្យថ្មីកហើយ បានដល់សេពមកតាំងពីដំបូង ។

---

១ អង្គ. ឯកា. បឋមនិស្សយវគ្គ. ៥១. ១១៣/២៣៨ ។

បទថា ភាវិតាយ : ចម្រើនហើយ បានដល់ ឱ្យសម្រេច ឬឱ្យចម្រើន ។

បទថា ពហុលីកតាយ : ធ្វើឱ្យគ្រាសគ្រែលហើយ បានដល់ ធ្វើរឿយ ៗ ។

បទថា យានីកតាយ ធ្វើឱ្យដូចជាយានជំនិះហើយ បានដល់ ធ្វើឱ្យដូចយានដែលទឹមទុកល្អហើយ ។

បទថា វត្ថុកតាយ : ធ្វើឱ្យជាទីនៅហើយ បានដល់ ធ្វើឱ្យជាគុណតាំងមាំដោយប្រការដែលទីតាំងមាំ ។

បទថា អនុដ្ឋិតាយ : ឱ្យតាំងនៅញឹកញយហើយ បានដល់ ប្រព្រឹត្តរឿយ ៗ, អធិប្បាយថា អធិដ្ឋានជានិច្ច ។

បទថា បរិចិតាយ : សន្សំទុកមិនបាត់ បានដល់ សន្សំដោយជុំវិញ គឺ សន្សំក្នុងទិសទាំងពួង គឺ សន្សំសព្វទូទៅ, អធិប្បាយថា ឱ្យចម្រើនក្រៃលែង ៗ ។

បទថា សុសមារទ្ធាយ : ប្រារព្ធដោយល្អហើយ បានដល់ ប្រារព្ធល្អព្រម, អធិប្បាយថា បង្អោនចូលទៅកាន់ជាអ្នកជំនាញ ។

ពីរបទថា ន ចាបគំ សុបិនំ : មិនយល់សុបិនអាក្រក់ មានសេចក្ដីថា មិនយល់សប្ដិ ឃើញចំពោះទីអាក្រក់ប៉ុណ្ណោះ, តែរមែងយល់សប្ដិឃើញទីល្អ គឺ ទីជាហេតុនៃសេចក្ដីចម្រើន ។

ពីរបទថា ទេវតា រក្ខន្តិ : ពួកទេវតាតែងរក្សា មានសេចក្ដីថា អារក្ខទេវតាទាំងឡាយ រមែងចាត់តាំងការរក្សាដ៏ប្រពៃតាមធម៌ ។

ច្រើនបទថា តុវដំ ចិត្តំ សមាធិយតិ : ចិត្តបុគ្គលនោះ រមែងចូលកាន់សមាធិដោយរួសរាន់ បានដល់ ចិត្តរមែងតាំងមាំ (ជាសមាធិ) រហ័ស ។

ពីរបទថា ឧត្តរិ អប្បដិវិជ្ឈន្តោ : កាលបើមិនទាន់បានត្រាស់ដឹងនូវគុណធម៌ជាន់ខ្ពស់ទេ មានសេចក្ដីថា កាលមិនធ្វើឱ្យច្បាស់នូវព្រះអរហត្ត ដែលក្រៃលែងជាងមេត្តាឈានឡើងទៅ គង់ជាសេក្ខបុគ្គល ឬបុថុជ្ជនក៏ដោយ កាលធ្វើកាលកិរិយា រមែងជាអ្នកចូលដល់ព្រហ្មលោក ។

ពាក្យដ៏សេសក្នុងទីទាំងពួង ងាយយល់ទាំងអស់ ដូច្នេះឯង ។

ពណ៌នាឯកុត្តរិកៈ មានអធិប្បាយពួក ១១ ជាទីបំផុត ចប់

## ពណ៌នាបុច្ឆាវិសជ្ជនាអំពីឧបោសថកម្មជាដើម

[៩១] វិនិច្ឆ័យក្នុងពាក្យពន្យល់ពាក្យសួរទាំងឡាយ មានពាក្យសួរថា អ្វីជាខាងដើមរបស់ឧបោសថកម្មជាដើម គប្បីជ្រាបដូច្នេះ ៖

ពីរបទថា **សាមគ្គី អាទិ : មានសេចក្តីព្រមព្រៀងជាខាងដើម** មានសេចក្តីថា កាយសាមគ្គីរបស់ភិក្ខុទាំងឡាយអ្នកគិតថា នឹងធ្វើឧបោសថ ហើយជម្រះសីមា នាំឆន្ទៈនិងបារិសុទ្ធិមកប្រជុំគ្នា ជាខាងដើមរបស់ឧបោសថកម្ម ។

ពីរបទថា **កិរិយា មជ្ឈេ : មានការធ្វើជាកណ្តាល** មានសេចក្តីថា កិរិយាដែលធ្វើបុព្វកិច្ចសូធ្យបាដិមោក្ខ ជាកណ្តាលរបស់ឧបោសថកម្ម ។

ពីរបទថា **និដ្ឋានំ បរិយោសានំ : មានការចប់ជាទីបំផុត** មានសេចក្តីថា សេចក្តីចប់បាដិមោក្ខដូច្នេះថា "អស់លោកពល់អង្គ គប្បីព្រមព្រៀងគ្នា គប្បីរីករាយរកគ្នា កុំវិវាទគ្នា គប្បីសិក្សាក្នុងសិក្ខាបទទាំងនោះទៅហោង"[១] ជាទីបំផុត (របស់ឧបោសថកម្ម) ។

ច្រើនបទថា **បវារណាកម្មស្ស សាមគ្គី អាទិ : បវារណាកម្មមានមានសេចក្តីព្រមព្រៀងជាខាងដើម** មានសេចក្តីថា កាយសាមគ្គីរបស់ភិក្ខុទាំងឡាយដែលគិតថា "នឹងធ្វើបវារណា" ហើយជម្រះសីមា

---

១ វិន. បាចិ. ឧទ្ទេសាវសាន. ៤. ៤៩៩/៥០៣ ។

នាំឆន្ទៈ និងបរិវារណាមកប្រជុំគ្នា ជាខាងដើមរបស់បវារណាកម្ម ។

ពីរបទថា **កិរិយា មជ្ឈេ : មានការធ្វើជាកណ្តាល** មានសេចក្តីថា បវារណាញត្តិ និងបវារណាកថា ជាកណ្តាល (របស់បវារណាកម្ម) ។

ពាក្យរបស់ភិក្ខុដែលសង្ឃនវកៈដែលថា "ខ្ញុំឃើញ ខ្ញុំនឹងសម្តែងចេញ" ជាទីបំផុត(របស់បវារណាកម្ម) ។

ភិក្ខុរមែងជាអ្នកគួរដល់កម្ម ដោយវត្ថុណា វត្ថុនោះ ឈ្មោះថា វត្ថុក្នុងកម្មទាំងឡាយ មានតជ្ជនីយកម្មជាដើម ។

បុគ្គលដែលបង្កវត្ថុនោះ ឈ្មោះថា បុគ្គល ។

ពីរបទថា **កម្មវាចា បរិយោសានំ : មានកម្មវាចាជាទីបំផុត** មានសេចក្តីថា ពាក្យចុងបង្អស់នៃកម្មវាចានោះ ៗ យ៉ាងនេះថា "សង្ឃបានធ្វើតជ្ជនីយកម្មដល់ភិក្ខុឈ្មោះនេះហើយ ការធ្វើនូវតជ្ជនីយកម្មនេះ គួរដល់សង្ឃ ព្រោះហេតុនោះ ទើបសង្ឃស្ងៀម, ខ្ញុំសូមចាំទុកនូវដំណើរនេះ ដោយអាការស្ងៀមយ៉ាងនេះ" ជាទីបំផុតរបស់កម្មទាំងឡាយ មានតជ្ជនីយកម្មជាដើម ។

ពាក្យដ៏សេសក្នុងទីទាំងពួង ងាយយល់ទាំងអស់ ដូច្នេះឯង ។

ពណ៌នាបុច្ឆាវិសជ្ជនាអំពីឧបោសថកម្មជាដើម ចប់

# ពណ៌នាបករណៈ អំពីអំណាចប្រយោជន៍

វិនិច្ឆ័យក្នុងអត្ថវសេបករណ៍ គប្បីជ្រាបដូច្នេះ ៖

[៩២] ក្នុងពាក្យថា ឧស អត្ថវសេ : អំណាចប្រយោជន៍ ១០ យ៉ាង ជាដើម ពាក្យដែលគួរពោល បានពោលក្នុងវណ្ណនានៃបឋមបារាជិកហើយ ។

[៩៣] ក្នុងបទទាំងឡាយមានបទថា យំ សង្ឃសុដ្ឋុ តំ សង្ឃជាសុ : អំណាចប្រយោជន៍ណា ដែលជាសេចក្ដីល្អដល់សង្ឃ អំណាចប្រយោជន៍នោះ ឈ្មោះថា សប្បាយដល់សង្ឃ ជាដើម បទដើម ៗ ជាសេចក្ដីរបស់បទក្រោយ ៗ ។

[៩៧] ក៏ដោយការធ្វើឱ្យជាបទតាំងម្ដងមួយបទ គ្រប់ទាំង ១០ បទ ប្រកប ២០ ដង រួម ១០០ បទនេះ ណា ដែលព្រះមានព្រះភាគត្រាស់ក្នុងពាក្យថា "អត្ថ មួយរយ ធម៌មួយរយ"ជាដើម ។ គប្បីជ្រាបអត្ថមួយរយ ដោយអំណាចបទក្រោយ ៗ ក្នុងមួយរយបទនោះ ។ គប្បីជ្រាបធម៌ ១០០ ដោយអំណាចបទដើម ៗ ។

ម្យ៉ាងទៀត សិក្ខាបទដែលព្រះតថាគត ទ្រង់បញ្ញត្តិហើយដល់សាវកទាំងឡាយ ព្រោះអាស្រ័យអំណាចប្រយោជន៍ ១០ យ៉ាង ពួកណា ; អំណាចប្រយោជន៍ ១០ ពួកនោះ ដែលខ្ញុំពណ៌នាហើយ ក្នុងអដ្ឋកថានៃបឋមបារាជិកក្នុងកាលមុន ដោយន័យមានជាដើមយ៉ាងនេះថា បណ្ដាអំណាចប្រយោជន៍ ១០ នោះ ដើម្បីសេចក្ដីល្អដល់សង្ឃ គឺ សេចក្ដីព្រមទទួលពាក្យថា "ល្អហើយ ព្រះអង្គ" ដូចសេចក្ដីព្រមទទួលពាក្យក្នុងការមកថា "ល្អហើយ ទេវៈ" ឈ្មោះថា សង្ឃសុដ្ឋុតា ។

ក៏ភិក្ខុណា ព្រមទទួលពាក្យរបស់ព្រះតថាគត សេចក្ដីព្រមទទួលពាក្យនោះ របស់ភិក្ខុនោះ រមែងមាន ដើម្បីប្រយោជន៍ ដើម្បីសេចក្ដីសុខ អស់កាលយូរ ព្រោះហេតុនោះ ព្រះមានព្រះភាគ កាលនឹងទ្រង់ធ្វើឱ្យច្បាស់នូវសេចក្ដីនេះថា តថាគតនឹងបញ្ញត្តិ ដើម្បីសង្ឃព្រមទទួលពាក្យរបស់តថាគតថា "ល្អហើយ ព្រះអង្គ" នឹងសម្ដែងទោសក្នុងការដែលមិនព្រមទទួល និងអានិសង្សក្នុងការដែលព្រមទទួលមុន ទើបបញ្ញត្តិ និងមិនមែនបញ្ញត្តិសង្កត់សង្កិនដោយបង្ខិតបង្ខំ ដូច្នេះ ទើបត្រាស់ថា ដើម្បីសេចក្ដីល្អដល់សង្ឃ ។ គប្បីជ្រាបអត្ថមួយរយ ព្រោះ

អំណាចប្រយោជន៍ទាំងនោះ មកហើយក្នុងគម្ពីរបរិវារៈនេះ ១០ ជន និងគប្បីជ្រាបធម៌មួយរយ ដោយអំណាចបទដែលបំភ្លឺអត្ថនោះ ៗ

គប្បីជ្រាបនិរុត្តិពីររយទាំងនេះ គឺ ដោយអំណាចនៃនិរុត្តិដែលបំភ្លឺអត្ថនិរុត្តិមួយរយ ដោយអំណាចនៃនិរុត្តិដែលជាតួធម្មតា និរុត្តិមួយរយ ៗ

និងគប្បីជ្រាបញាណបួនរយ គឺ ញាណ ១០០ ក្នុងអត្ថមួយរយ, ញាណ ១០០ ក្នុងធម៌មួយរយ, ញាណ ២០០ ក្នុងនិរុត្តិពីររយ ៗ

ពិតមែន ពាក្យណាដែលព្រះមានព្រះភាគត្រាស់ថា អត្ថ១០០, ធម៌១០០, និរុត្តិ២០០, រួមជាញាណ៤០០ មានក្នុងអំណាចប្រយោជន៍ដែលជាហេតុផ្ដើមធ្វើពាក្យនេះ ទ្រង់អាស្រ័យអត្ថជាដើមនោះ ត្រាស់ហើយ ដូច្នេះឯង ៗ

ពណ៌នាអត្ថវសេនបករណ៍ ចប់

# ពណ៌នាបឋមគាថាសង្គណិកៈ

[៩៩] បាទគាថាថា ឯកំសំ ចីវរំ កត្វា : អ្នកធ្វើចីវរឆៀងស្មាម្ខាង មានសេចក្ដីថា លោកធ្វើចីវរឆៀងស្មាម្ខាង អធិប្បាយថា ដណ្ដប់ឧត្តរាសង្គៈរៀបរយ ។

បាទគាថាថា បគ្គណ្ហិត្វាន អញ្ជលឹ : រួចប្រណម្យអញ្ជលី មានសេចក្ដីថា លើកអញ្ជលីដែលរុងរឿងដោយប្រជុំនៃម្រាមទាំង ១០ ។

បាទគាថាថា អាសីសមានរូបោ វ : ធ្វើហាក់ដូចជាមានបំណង (អ្វីមួយ) សេចក្ដីថា មើលទៅដូចជាមានបំណងចង់ (សួរអ្វី) ។

បាទគាថាថា កិស្ស ត្វំ ឥធមាគតោ : មកក្នុងទីនេះដើម្បីអ្វី មានសេចក្ដីថា លោកប្រាថ្នាប្រយោជន៍អ្វី មកក្នុងទីនេះ ព្រោះហេតុណា ?

អ្នកណាពោលយ៉ាងនេះ ? ព្រះសម្មាសម្ពុទ្ធ ។ ត្រាស់យ៉ាងនោះចំពោះអ្នកណា ? ចំពោះព្រះឧបាលី ។ ព្រះឧបាលីចូលគាល់ព្រះមានព្រះភាគ ទូលសួរគាថានេះថា "សិក្ខាបទទាំងឡាយ ដែលព្រះអង្គបានបញ្ញត្តិទុកក្នុងវិន័យទាំងពីរ តែងមកកាន់ឧទ្ទេសរាល់ថ្ងៃឧបោសថ សិក្ខាបទទាំងនោះ មានប៉ុន្មាន ទ្រង់បញ្ញត្តិក្នុងនគរណាខ្លះ" ដោយប្រការដូច្នេះ ។

លំដាប់នោះ ព្រះមានព្រះភាគ ត្រាស់ពាក្យថា "អ្នកមានប្រាជ្ញា

មោះមុតល្អហើយ” ជាដើម ទ្រង់តបពាក្យសួរនោះរបស់លោក ។ មានន័យដូចគ្នាគ្រប់បញ្ហា ។

ព្រះឧបាលីថេរៈទូលសួរបញ្ហាទាំងពួងនេះ ក្នុងពុទ្ធកាល ដោយប្រការដូច្នេះ ។ ព្រះមានព្រះភាគទ្រង់តបដោយព្រះអង្គឯង ។ ចំណែកក្នុងសង្គីតិកាល ព្រះមហាកស្សបថេរៈសួរ ព្រះឧបាលីថេរៈឆ្លើយ ។

បណ្ដាបទទាំងនោះ បាទគាថាថា ភទ្ទកោ តេ ឧម្មង្គោ : អ្នកមានប្រាជ្ញាមុតល្អហើយ មានសេចក្ដីថា បញ្ហារបស់លោកភ្លឺល្អ ។ ពិតមែន បញ្ហាហៅថា ឧម្មង្គៈ ព្រោះងើបឡើងអំពីងងឹត គឺអវិជ្ជាតាំងនៅ ។

សព្ទថា តគ្ឃ ជានិបាត ប្រើក្នុងអត្ថ គឺហេតុ ។ សេចក្ដីថា លោកសួរយើងព្រោះហេតុណា ព្រោះហេតុនោះ យើងនឹងឆ្លើយដល់លោក ។

ម្យ៉ាងទៀត សព្ទថា តគ្ឃ ជានិបាត ប្រើក្នុងអត្ថ គឺ ព្រមទទួល ។ ពិតមែន ព្រះមានព្រះភាគទ្រង់ទទួលពាក្យ ដោយពាក្យថា “ណ្ហើយចុះ” ។ នេះទើបត្រាស់ថា “តថាគតនឹងប្រាប់” ។

[១០១] ចំពោះសិក្ខាបទ ៣ នេះ គឺ ដុតភ្លើងអាំង ដៃប្រលាក់អាមិស ទឹកលាងបាត្រមានគ្រាប់បាយ ទ្រង់បញ្ញត្តិក្នុងភគ្គជនបទ ។

[១០២] ពីរបទថា យន្តំ អបុច្ឆិម្ហា : ខ្ញុំព្រះអង្គបានសួរហើយនូវប្រស្នាណា មានសេចក្ដីថា ខ្ញុំបានទូលសួរបញ្ហាណាចំពោះព្រះអង្គ ។

បទថា អកិត្តយិ : ព្រះអង្គក៏សម្ដែងហើយ គឺ ព្រះអង្គបាន

ត្រាស់ហើយ ។

បទថា នោ គឺ អម្ហាកំ : ដល់ខ្ញុំព្រះអង្គ ។

ពីរបទថា តន្នំ ព្យាកតំ : ពាក្យណា ដែលខ្ញុំព្រះអង្គបានទូលសួរហើយ ព្រះអង្គក៏បានព្យាករពាក្យនោះ មានសេចក្ដីថា ពាក្យណា ៗ ដែលខ្ញុំបានទូលសួរហើយ ពាក្យនោះ ៗ ដែលព្រះអង្គទ្រង់បានបកស្រាយហើយ ។

បទថា អនញ្ញថា : ដោយមិនមានលើសខ្វះ សេចក្ដីថា ទ្រង់មិនបានដោះស្រាយ គេចកែ ដោយប្រការដទៃ ។

## វិបត្តិ ៤

ឈ្មោះថា សីលវិបត្តិ រមែងមិនមានក្នុងបញ្ហាក្នុងពាក្យថា យេ ទុដ្ឋុល្លា សា សីលវិបត្តិ : អាបត្តិទាំងឡាយណា ជាទុដ្ឋុល្លាបត្តិ អាបត្តិទាំងនោះ ហៅថា សីលវិបត្តិ នេះ សូម្បីដោយពិត ទោះជាយ៉ាងនោះ ពាក្យថា យេ ទុដ្ឋុល្លា សា សីលវិបត្តិ នេះ លោកពោលហើយ ដោយមានបំណងនឹងកែទុដ្ឋុល្លាបត្តិ ។

ពិតមែន ក្នុងវិបត្តិ ៤ ទុដ្ឋុល្លាបត្តិ សង្គ្រោះដោយវិបត្តិ ១ អទុដ្ឋុល្លាបត្តិសង្គ្រោះដោយវិបត្តិ ៣ ។ ព្រោះហេតុនោះ លោកពោលថា

យេ ធុទ្ធល្លា សាសីលវិបត្តិ ហើយទើបពោលថា បារាជិក សង្ឃាទិសេស ហៅថា សីលវិបត្តិ ដើម្បីសម្តែងសីលវិបត្តិនោះឯង ដោយពិស្តារ ។

ឥឡូវនេះ លោកពោលពាក្យថា ថុល្លច្ចយំ ជាដើម ដើម្បីសម្តែងអនុដ្ឋល្លាបត្តិដោយអំណាចវិបត្តិ ៣ ។

ក្នុងពាក្យទាំងនោះ ពាក្យថា យោ ចាយំ អក្កោសតិ ហស្សាធិប្បាយោ : ដូចយ៉ាងភិក្ខុណា មានសេចក្តីប៉ុនប៉ងនឹងសើចលេងហើយជេរ នេះលោក ពោល ដើម្បីចង្អុលវត្ថុនៃទុព្ភាសិត ។

[១០៣] បទថា អញ្ញាចិក្ខន្តិ : តែងពោលបង្អាច់នូវព្រះសម្មាសម្ពុទ្ធ មានសេចក្តីថា កាលពោលថា "ខ្ញុំដឹងច្បាស់នូវធម៌ ដែលព្រះមានព្រះភាគសម្តែងហើយ" យ៉ាងនោះ ឈ្មោះថា ពោលបង្អាច់បង្ខូច ។

[១០៤] ច្រើនបទថា អយំ សា អាជីវវិបត្តិសម្មតា : នេះព្រះសម្មាសម្ពុទ្ធទ្រង់ត្រាស់ថា ជាអាជីវវិបត្តិ មានសេចក្តីថា ឈ្មោះថា អាជីវវិបត្តិ ដែលប្រមូលដោយ ៦ សិក្ខាបទនេះ សន្នតថា វិបត្តិទី ៤ ដូច្នេះឯង ។

ពាក្យសួរថា អធុដ្ឋល្លំ : មិនអាអត្រក់[១] នេះ ជាការឆ្លើយហើយ ដោយពាក្យមានប្រមាណប៉ុណ្ណោះ ។

---

១. (ក្នុង[១០២])

# ប្រមូលសិក្ខាបទ

[១០៥] ឥឡូវនេះ លោកពោលពាក្យថា ឯកាទស ជាដើម ដើម្បីឆ្លើយបញ្ហាដែលថា យេ ច យាវតតិយកា ។ ក៏ព្រោះបញ្ហាដែលថា យេ ច យាវតតិយកា នេះ លោកឆ្លើយហើយ ដោយអំណាចចំនួន យ៉ាងនេះថា យាវតតិយកសិក្ខាបទ ១១, ព្រោះដូច្នោះ ទើបលោកសួរអន្តរាបញ្ហាពួកដទៃ មានពាក្យថា ឆេទនកសិក្ខាបទ មានប៉ុន្មាន ? ជាដើម ដោយអំណាចការបន្តនៃចំនួននុ៎ះឯង ។

[១០៦] លោកពោលថា ឆ ឆេទនកានិ **: សិក្ខាបទដែលមានកិរិយាកាត់ចេញជាវិនយកម្ម** មាន ៦ ជាដើម ក៏ដើម្បីឆ្លើយអន្តរាបញ្ហាទាំងនោះ ។ ក្នុងពាក្យឆ្លើយនោះ ពាក្យថា ភេទនកសិក្ខាបទ ១ ឧទ្ទាលនកសិក្ខាបទ ១ សិក្ខាបទ ១៦ ដែលព្រះមានព្រះភាគទ្រង់បញ្ញត្តិថា ដីងនេះឯង ត្រាស់ខាងក្រោយ ។

បទដ៏សេស បានចែកទុកក្នុងមហាវគ្គអស់ហើយ ។

ក៏ក្នុងពាក្យដែលត្រាស់ខាងក្រោយនោះ ពីរបទថា ឯកំ ភេទនកំ **: សិក្ខាបទដែលមានកិរិយាបំបែកជាវិនយកម្ម** មាន ១ បានដល់ សូចិឃរសិក្ខាបទ ។

ពីរបទថា ឯកតំ ឧទ្ទាលនកំ : សិក្ខាបទដែលមានកិរិយាកកាយចេញជាវិនយកម្ម មាន ១ បានដល់ តួលោនទ្ទមពាប៉ីបសិក្ខាបទ ។

បទថា សោឡស បានដល់ សោទស : ១៦ ។

ពីរបទថា ជានន្តិ បញ្ញត្តា : សិក្ខាបទដែលមានពាក្យថា ដឹង បានដល់ សិក្ខាបទដែលត្រាស់យ៉ាងនេះថា ដឹងហើយ ទ្រង់បញ្ញត្តិហើយ ។

សិក្ខាបទទាំងនោះ គប្បីជ្រាបយ៉ាងនេះ គឺ ៖

ភិក្ខុកាលដឹងហើយ បង្អោននូវលាភរបស់សង្ឃ ដែលគេបង្អោនទៅ (ដើម្បីសង្ឃ) មកដើម្បីខ្លួនវិញ, ដឹងហើយចូលទៅដេកជ្រៀតបៀតនូវភិក្ខុដែលចូលទៅមុន, ដឹងថា ទឹកមានសត្វហើយស្រោចឯងក្តី ប្រើគេឱ្យស្រោចក្តី នូវស្មៅឬដី, ដឹងហើយឆាន់បិណ្ឌបាតដែលភិក្ខុនីបង្គាប់ឱ្យថ្វាយ, ដឹងហើយ រំពៃរកទោស ... និមិត្តតែភិក្ខុឆាន់ហើយ ត្រូវអាបត្តិបាចិត្តិយ, ដឹងហើយបរិភោគទឹកមានសត្វ, ដឹងថាអធិករណៈដែលសង្ឃរម្ងាប់សមគួរតាមធម៌ហើយ, ដឹងហើយ បិទបាំងទុកនូវអាបត្តិអាក្រក់, ដឹងហើយ ឱ្យឧបសម្បទាដល់បុគ្គលដែលមានអាយុមិនទាន់គ្រប់ ២០ ឆ្នាំ, ដឹងហើយ បបួលគ្នាដើរមកឆ្ងាយជាមួយគ្នាមួយអន្លើដោយពួកឈ្មួញជាចោរ, ដឹងហើយ បរិភោគរួមក្តី ... ជាមួយ

នឹងភិក្ខុដែលមានប្រក្រតីពោលយ៉ាងនោះ ជាអ្នកមិនធ្វើតាមធម៌, ដឹងថា សមណុទ្ទេសដែលសង្ឃឲ្យវិនាសយ៉ាងនោះហើយ បញ្ចុះបញ្ចូលក្តី..., ដឹងថា លាភរបស់សង្ឃ គេបង្អោនទៅ (ដើម្បីសង្ឃហើយ) ត្រឡប់បង្អោនមកដើម្បីបុគ្គលវិញ, ភិក្ខុនីដឹងថា ភិក្ខុនីផងគ្នា ត្រូវអាបត្តិបារាជិកហើយ មិនចោទដោយខ្លួនឯង មិនប្រាប់ដល់ពួកគណៈ, ដឹងថា ស្រីជាចោរដែលគេដឹងច្បាស់ថា ត្រូវសម្លាប់ហើយមិនប្រាប់, ដឹងហើយ មិនបានប្រាប់ភិក្ខុដែលមាននៅហើយចូលទៅកាន់អារាម ។

## ចែកសិក្ខាបទ

[១០៧] ឥឡូវនេះ លោកនឹងឆ្លើយបញ្ហាជាដំបូងនេះថា សាធារណំ អសាធារណំ : (សិក្ខាបទ) ដែលជាសាធារណបញ្ញត្តិក្តី ជាអសាធារណបញ្ញត្តិក្តី[១] ទើបពោលពាក្យថា វីសំ ទ្វេ សតានិ : មាន ២២០ ជាដើម ។

[១១០] បណ្តាសិក្ខាបទដែលទូទៅ និងមិនទូទៅទាំងនោះ វិនិច្ឆ័យក្នុងសិក្ខាបទទាំងឡាយ ដែលមិនទូទៅដល់ពួកភិក្ខុនី គប្បីជ្រាបដូច្នេះ ៖

---

១. ក្នុង [១០២] ។

ពីរបទថា ឆ សច្ឆាធិសេសា : សង្ឃាទិសេស ៦ បានដល់ សុក្កវិស្សដ្ឋិសិក្ខាបទ១ កាយសំសគ្គសិក្ខាបទ១ ទុដ្ឋុល្លវាចសិក្ខាបទ១ អត្តកាមបារិចរិយសិក្ខាបទ១ កុដិការសិក្ខាបទ១ វិហារសិក្ខាបទ១ ។

ពីរបទថា ទ្វីហិ[1] អនិយតេហិ អដ្ឋ : អនិយត: ២ ត្រូវជា ៨ សិក្ខាបទ បានដល់ សិក្ខាបទទាំង(៦)នេះ រួមទាំងអនិយត ២ សិក្ខាបទផង ត្រូវជា ៨ ។

ពីរបទថា និស្សគ្គិយា ទ្វាទស : និស្សគ្គិយ ១២ ទៀត បានដល់ សិក្ខាបទ ១២ ទាំងនេះ គឺ ចីវរធោវន:១ ចីវរបដិគ្គហ:១ កោសេយ្យ:១ សុទ្ធកាឡក:១ ទ្វេភាគ:១ ឆព្វស្ស:១ និសីទនសន្ថត ១ លោមសិក្ខាបទ២ បឋមបត្ត:១ វស្សិកសាដិក:១ អារញ្ញក: គឺ សាសង្ក: ១ ។

ពីរបទថា ទ្វេវីសតិ[2] ខុទ្ទកា : ខុទ្ទក ២២ បានដល់ សិក្ខាបទ ២២ ដែលប្រកាសហើយក្នុងបាចិត្តិយកណ្ឌទាំងនេះ គឺ ឱវាទវគ្គទាំងអស់ បរម្បរភោជនសិក្ខាបទ បឋមបវារណាសិក្ខាបទ ទុតិយបវារណាសិក្ខាបទ បណីតភោជនសិក្ខាបទ អចេលកសិក្ខាបទ ឧនវីសតិវស្សសិក្ខាបទ

១. ភូមា. ថៃ. ទ្វេ ។ ២. ថៃ. ទ្វាវីសតិ ។

ទុដ្ឋុល្លសិក្ខាបទ សំវិធានសិក្ខាបទ អន្ទេបុរសិក្ខាបទ វិកាលេគាម ប្បវេសនសិក្ខាបទ និសីទនសិក្ខាបទ វស្សិកសាដិកសិក្ខាបទ ។

[១១១] វិនិច្ឆ័យសូម្បីក្នុងសិក្ខាបទ ដែលមិនទូទៅ ដោយភិក្ខុទាំងឡាយ គប្បីជ្រាបដូច្នេះ ៖

ប្រើនបទថា សចឡម្ហា ធស និស្សរេ : សង្ឃាទិសេស ១០ បានដល់ សិក្ខាបទដែលត្រាស់ទុកក្នុងវិភង្គយ៉ាងនេះថា ១០ សិក្ខាបទ ដែលសង្ឃគប្បីដេញចេញចាកពួក ។ តែ ១០ សិក្ខាបទមកក្នុងមាតិកា យ៉ាងនេះថា សង្ឃាទិសេស ដែលត្រូវបណ្តេញចេញ ។

ពីរបទថា និស្សគ្គិយានិ ទ្វាធស : និស្សគ្គិយ ១២ បានដល់ និស្សគ្គិយដែលទ្រង់ចែកទុកក្នុងភិក្ខុនីវិភង្គប៉ុណ្ណោះ ។

សូម្បីខុទ្ទកសិក្ខាបទ ក៏បានដល់ ខុទ្ទកសិក្ខាបទដែលទ្រង់ចែកក្នុងភិក្ខុនីវិភង្គនោះឯង ។

បាដិទេសនីយៈ ៨ ក៏ដូចគ្នា ។ សិក្ខា ១៣០ របស់ពួកភិក្ខុនី មិនទូទៅដោយភិក្ខុទាំងឡាយយ៉ាងនេះ ។

ក្នុងវគ្គនៃការពន្យល់សិក្ខាបទដែលទូទៅនេះ ពាក្យដ៏សេស ងាយយល់ទាំងអស់ ។

# កងអាបត្តិដែលរម្ងាប់មិនបាន

[១១៤] ឥឡូវនេះ ព្រះឧបាលីថេរៈ កាលនឹងពន្យល់បញ្ហានេះថា ក៏កងអាបត្តិជាដើមដែលលោកចែក រមែងរម្ងាប់ដោយសមថៈពួកណា ? ដូច្នេះ ទើបពោលថា បុគ្គលអ្នកចាលចាញ់ ៨ ពួកទុំះឯង ជាដើម ។

បណ្ដាបទទាំងនោះ លោកសម្ដែងកាលដែលបុគ្គលអ្នកចាញ់ទាំង ៨ នោះជាអ្នកមានភ័យចំពោះមុខ ដោយបទថា **ទុរាសទា : ជាអ្នកមានកិត្តិសព្ទអាក្រក់** នេះ ។

ពិតមែន អ្នកចាញ់ទាំងនោះ ហាក់ដូចជាពស់វែកជាដើម លំបាកនឹងចូលជិតគឺ លំបាកចូលក្បែរ លំបាកនឹងចូលទៅរក ដែលបុគ្គលជាប់ជំពាក់ រមែងប្រព្រឹត្តទៅដើម្បីកាត់ឫសគល់ ។

បទថា **តាលវត្ថុសម្ងូបមា : ឧបមាដូចដើមត្នោតដែលគេគាស់រំលើង** មានសេចក្ដីថា ប្រៀបដូចការដកដើមត្នោតទាំងដើម ធ្វើឱ្យនៅត្រឹមតែជាវត្ថុនៃត្នោត ។ ដើមត្នោតដែលបុគ្គលធ្វើឱ្យនៅត្រឹមតែជាវត្ថុហើយ ជាត្នោតដែលត្រឡប់ដុះដាលប្រក្រតីវិញមិនបាន យ៉ាងណា បុគ្គលដែលចាលចាញ់ទាំង ៨ នោះ រមែងជាអ្នកត្រឡប់មកវិញ ដូចកាលពីដើមទៀតមិនបាន យ៉ាងនោះ ។

ព្រះឧបាលីថេរៈ គ្រាសម្ដែងឧបមា ដែលទូទៅយ៉ាងនេះហើយ នឹងសម្ដែងឧបមាដែលពោលចំពោះម្នាក់ ៗទៀត ទើបពោលថា ប្រៀបដូចស្លឹកឈើលឿងជាដើម ។

បាទគាថាថា អវិរូឡ្ហិ ភវន្តិ តេ : មិនបានលូតលាស់ចម្រើនឡើងទេ មានសេចក្ដីថា ស្លឹកឈើពណ៌លឿងជាដើមទាំងនោះ ជារបស់មានការមិនដុះដាល ដោយភាពជារបស់ខៀវស្រស់ទៀតជាដើម ជាធម្មតាយ៉ាងណា, សូម្បីបុគ្គលដែលចាលចាញ់ទាំងឡាយ ក៏យ៉ាងនោះដែរ រមែងជាអ្នកមិនដុះដាល បានជាបុគ្គលមានសីលតាមប្រក្រតីធម្មតាទៀតទេ ។

ក្នុងពាក្យថា ក៏កងអាបត្តិជាដើម ដែលលោកចែករមែងរម្ងាប់ដោយសមថៈពួកណានេះ ពាក្យយ៉ាងនេះថា កងអាបត្តិជាដើម ដែលលោកចែក គឺ បារាជិកទាំង ៨ នេះមុន រមែងមិនរម្ងាប់ដោយសមថៈពួកណា ៗ ជាការសម្ដែងហើយ ដោយពាក្យមានប្រមាណប៉ុណ្ណេះ ។

# កងអាបត្តិដែលរម្ងាប់បាន

[១១៥] ចំណែកពាក្យថា តេវីសំ សង្ឃាទិសេសា : សង្ឃាទិសេស ២៣ ជាដើម លោកពោលហើយ ដើម្បីសម្ដែងអាបត្តិគ្រឿងបែកជាដើមដែលរម្ងាប់បាន ។

បណ្ដាបទទាំងនោះ ពីរបទថា តីហិ សមថេហិ : ដោយសមថ ៣ យ៉ាង នេះ ជាពាក្យពោលគ្រប់គ្រងសមថៈទាំងអស់ ។

ពិតមែន សង្ឃាទិសេស រមែងរម្ងាប់ដោយសមថៈ ២ ប៉ុណ្ណោះ, មិនរម្ងាប់ដោយតិណវត្ថារកសមថៈទេ, ដ៏សេសរមែងរម្ងាប់ដោយសមថៈទាំង ៣ ។

[១១៦] ពាក្យថា ទ្វេ ឧបោសថា ទ្វេ បវារណា : ឧបោសថមាន ២ យ៉ាង បវារណា មាន ២ យ៉ាង នេះ លោកពោលដោយអំណាចភិក្ខុនិងភិក្ខុនី, ពិតមែន ពាក្យនោះលោកពោលហើយ ដោយអំណាចសម្ដែងត្រឹមតែថា ចំណែកដែលលោកចែកប៉ុណ្ណោះ មិនបានពោលអំពីអំណាចការរម្ងាប់ ដោយសមថៈទាំងឡាយទេ ។

ពិតមែន ចំណែកដែលលោកចែក អធិប្បាយថា ចំណែកដែល

គួរចែកចេញ ៤ សូម្បីទាំងនេះ គឺ ភិក្ខុឧបោសថ ភិក្ខុនីឧបោសថ ភិក្ខុបវារណា ភិក្ខុនីបវារណា ។

ពីរបទថា ចត្តារិ កម្មានិ : សង្ឃកម្ម មាន ៤ យ៉ាង បានដល់ ឧបោសថកម្ម មានជាពួកដោយអធម៌ជាដើម ។

ប្រើនបទថា បញ្ចេវ ឧទ្ទេសា ចត្តារោ ភវន្តិ អនញ្ញថា : ឧទ្ទេសរបស់ភិក្ខុ មាន ៥ ឧទ្ទេសរបស់ភិក្ខុនី មាន ៤ មិនមានក្រៅពីនេះទៀតទេ មានសេចក្តីថា ឧទ្ទេសរបស់ភិក្ខុមាន ៥ របស់ភិក្ខុនីមាន ៤ ដោយប្រការដទៃ មិនមាន ។

[១១៧] គប្បីជ្រាបចំណែកចែកសូម្បីដទៃទៀតទាំងនេះ គឺ កងអាបត្តិមាន ៧ អធិករណ៍មាន ៤, ក៏ចំណែកចែកទាំងនេះ រមែងរម្ងាប់ដោយសមថៈទាំងឡាយ, ព្រោះហេតុនោះ ទើបលោកពោលពាក្យថា សត្តហិ សមថេហិ : ដោយសមថៈ ៧ ជាដើម ។

មួយទៀត អាបត្តិពួកណា អាស្រ័យចំណែកចែក សូម្បីទាំងនេះឯង គឺឧបោសថ ២ បវារណា ២ កម្ម ៤ ឧទ្ទេស ៥ ឧទ្ទេស ៤ មាន, ឧទ្ទេសដោយប្រការដទៃ មិនមាន, កើតឡើងដោយន័យថា

“នស្សន្តុ តេ វិនស្សន្តុ តេ កោ តេហិ អត្ថោ ភិក្ខុទាំងនុ៎ះចូរបាត់បង់ទៅចុះ ភិក្ខុទាំងនុ៎ះចូរវិនាសទៅចុះ ត្រូវការអ្វីដោយភិក្ខុទាំងនោះ”[១] អាបត្តិទាំងនោះ រមែងរម្ងាប់ដោយសមថៈទាំងឡាយ មានប្រការដូចពោលហើយនុ៎ះឯង, ព្រោះហេតុនោះ ចំណែកចែកទាំងនោះ ដែលបណ្ឌិតគប្បីជ្រាបថា លោកពោលហើយ ដើម្បីសម្ដែងសេចក្ដីរម្ងាប់អាបត្តិទាំងឡាយ ដែលមានចំណែកចែកនោះ ជាមូលខ្លះ ។

ពីរបទថា កតិហិ ឯកេន : ឯកិច្ច ដោយសមថៈ ១ មានសេចក្ដីថា កិច្ចាធិករណ៍ រមែងរម្ងាប់ដោយសមថៈតែមួយ ។

១. វិន. មហា. ឧបោសថក្ខន្ធកៈ. ៦. ១៩៥_៨/៤២៤_៤៣៣ ។

# វិគ្រោះបារាជិក

[១១៨] ព្រះឧបាលី គ្រាពន្យល់បញ្ហាទាំងពួងតាមលំដាប់នៃពាក្យសួរយ៉ាងនេះហើយ ឥឡូវនេះ នឹងសម្ដែងត្រឹមតែពាក្យអធិប្បាយ ចំពោះមួយយ៉ាង ៗ នៃកងអាបត្តិ ដែលប្រមូលទុកក្នុងពាក្យថា អាបត្តិក្ខន្ធា ច ភវន្តិ សត្ត ទើបពោលពាក្យថា ឆ្មាភជិកំ ជាដើម ។

បណ្ដាគាថាទាំងនោះ គាថាទី ១ ថា ឆ្មាភជិកំ ជាដើម មានសេចក្ដីដូចតទៅនេះ ៖

បណ្ដាបុគ្គលបារាជិក អាបត្តិបារាជិក និងសិក្ខាបទបារាជិក ឈ្មោះអាបត្តិបារាជិកនេះណា ដែលព្រះមានព្រះភាគត្រាស់ហើយ, បុគ្គលត្រូវអាបត្តិបារាជិកនោះ រមែងជាអ្នកចាញ់ គឺ ដល់សេចក្ដីបរាជ័យ ជាអ្នកឃ្លាត ខុស ធ្លាក់ ដែលសេចក្ដីល្មើសធ្វើឱ្យឆ្ងាយ ចាកសទ្ធម្ម ។ កាលបុគ្គលនោះ មិនត្រូវដេញចេញ (ចាកពួក) ក៏មិនមានសំវាសផ្សេងដោយឧបោសថ និងបវារណាជាដើមទៀត ។ ដោយហេតុនោះ បារាជិកនោះ ទើបព្រះមានព្រះភាគត្រាស់យ៉ាងនោះ គឺ ព្រោះហេតុនោះ អាបត្តិបារាជិកនោះ ទើបព្រះមានព្រះភាគត្រាស់ថា បារាជិក ។

ក៏ក្នុងបទថា ឆ្មាភជិកំ នេះ មានសេចក្ដីសង្ខេបដូច្នេះ ៖

បុគ្គល រមែងជាអ្នកចាញ់ដោយអាបត្តិបារាជិកនោះ ព្រោះហេតុនោះ អាបត្តិបារាជិកនោះ ទើបលោកពោលថា បារាជិក ។

## វិគ្រោះសង្ឃាទិសេស

[១១៩] ពាក្យថា សង្ឃោវ ទេតិ បរិវាសំ : សង្ឃឱ្យបរិវាស ទាញមក ជាដើម លោកពោលហើយ ដើម្បីសម្ដែងតែសេចក្ដីប៉ុណ្ណោះ មិនអើពើព្យញ្ជនៈ សូម្បីក្នុងគាថា ទី ២ ។

ក៏ក្នុងបទថា សង្ឃាទិសេសោ ជាដើមនេះ មានសេចក្ដីដូចតទៅនេះ ៖

ការចេញចាកអាបត្តិនោះណា របស់ភិក្ខុដែលត្រូវអាបត្តិនេះ ហើយប្រាថ្នានឹងចេញ សង្ឃដែលភិក្ខុនោះគប្បីប្រាថ្នា ក្នុងកម្មខាងដើមនៃការចេញចាកអាបត្តិនោះ ដើម្បីប្រយោជន៍ដល់ការឱ្យបរិវាស និងក្នុងកម្មដ៏សេសអំពីកម្មខាងដើម គឺ ក្នុងកណ្ដាលដើម្បីប្រយោជន៍ដល់ការឱ្យមានត្ត ឬដើម្បីប្រយោជន៍ដល់ការឱ្យមានត្ត នឹងមូលាយបដិកស្សនៈ និងក្នុងទីបំផុតដើម្បីប្រយោជន៍ដល់អព្ភាន ។ ក៏ក្នុងកម្មទាំងឡាយមានបរិវាសកម្មជាដើមនេះ កម្មសូម្បីមួយយ៉ាង វៀរសង្ឃចេញ ដែលអ្នកណា ៗ មិនអាចធ្វើបាន ដូច្នេះឯង ។

សង្ឃដែលភិក្ខុគប្បីប្រាថ្នាក្នុងកម្មខាងដើម និងក្នុងកម្មដ៏សេសនៃ

កងអាបត្តិនោះ ហេតុនោះ កងអាបត្តិនោះ ឈ្មោះថា សង្ឃាទិសេស ។

# វិគ្រោះអនិយតៈ

[១២០] សេចក្តីនៃគាថាទី ៣ គប្បីជ្រាបដូច្នេះ ៖

ពីរបទថា អនិយតោ ន និយតោ : ពាក្យថា អនិយត បានសេចក្តីថា មិនទៀង មានសេចក្តីថា ព្រោះមិនមែនទៀង កងអាបត្តិនេះទើបបានឈ្មោះថា អនិយតៈ ។

ពាក្យដែលថា មិនពិតប្រាកដ នេះមានអ្វីជាហេតុ ? ព្រោះសិក្ខាបទនេះ ពិន័យអាបត្តិមិនកំណត់តែមួយផ្នែក, អធិប្បាយថា សិក្ខាបទនេះ ពិន័យអាបត្តិតែមួយផ្នែកមិនបាន ។

សិក្ខាបទនេះ ពិន័យអាបត្តិតែមួយផ្នែក មិនបានយ៉ាងណា ? យ៉ាងនេះ បណ្តាឋានៈ ៣ ឋានៈយ៉ាងណាមួយ ដែលព្រះវិន័យធរគប្បីពិន័យ ។

ពិតមែន លោកពោលទុកក្នុងអនិយតសិក្ខាបទនោះថា ភិក្ខុនោះដែលព្រះវិន័យធរគប្បីពិន័យដោយធម៌ ៣ យ៉ាងណាមួយ ។ ព្រោះហេតុនោះ កងអាបត្តិនោះ ទើបលោកពោលថា អនិយតៈ គឺ ពោលថាមិនមែនទៀង ។

ឧទាហរណ៍ថា បណ្តាឋានៈ ៣, ឋានៈណាមួយ លោកពោលក្នុងកងអាបត្តិនោះ កងអាបត្តិ ឈ្មោះថា អនិយតៈ យ៉ាងណា, បណ្តាឋាន ២, ឋានណាមួយ លោកពោលក្នុងកងអាបត្តិណា កងអាបត្តិសូម្បីនោះក៏ឈ្មោះថា អនិយតៈ ដូចគ្នាដូច្នោះ ។

## វិគ្រោះចុល្លច្ច័យ

[១២១] សេចក្តីនៃគាថាទី ៤ គប្បីជ្រាបដូច្នេះ ៖

បាទគាថាថា អច្ចយោ តេន សមោ នត្ថិ : មិនមែនមានដូចជា ភិក្ខុអ្នកសម្តែងនោះឡើយ មានសេចក្តីថា បណ្តាទោសដែលជាទេសនាគាមិនី ទោសដែលថ្លោស ស្មើដោយថុល្លច្ច័យនោះមិនមាន ដោយហេតុនោះ ការប្រព្រឹត្តិកន្លងនោះ ទើបលោកហៅយ៉ាងនោះ, អធិប្បាយថា ការប្រព្រឹត្តិកន្លងនោះ លោកហៅថា ថុល្លច្ច័យ ព្រោះជាទោសថ្លោស ។

## វិគ្រោះនិស្សគ្គិយ

[១២២] សេចក្តីនៃគាថា ទី ៥ គប្បីជ្រាបដូច្នេះ ៖

ប្រើនបទថា និស្សជ្ជិត្វា យំ ទេសេតិ តេនេតំ : រួចហើយ ទើបសម្តែងអាបត្តិចេញ មានសេចក្តីថា សេចក្តីល្មើសនោះ លោកហៅថា និស្សគ្គិយៈ ព្រោះត្រូវលះបង់ហើយ ទើបសម្តែងអាបត្តិបាន ។

# វិគ្រោះបាចិត្តិយ

[១២៣] សេចក្តីគាថាទី ៦ គប្បីជ្រាបដូច្នេះ ៖

បាទគាថាថា ឫាតេតិ កុសលំ ធម្មំ : សិក្ខាបទណាញ៉ាំង កុសលធម៌ឱ្យធ្លាក់ចុះ មានសេចក្តីថា សេចក្តីល្មើសនោះញ៉ាំងកុសលចិត្ត ពោលគឺ កុសលធម៌របស់បុគ្គលដែលត្រូវអាបត្តិដោយការក្លែង ឱ្យធ្លាក់ទៅ ព្រោះហេតុនោះ ការប្រព្រឹត្តិកន្លងនោះ ឈ្មោះថា ញ៉ាំងចិត្តឱ្យធ្លាក់ទៅ ព្រោះដូច្នោះ ការប្រព្រឹត្តិកន្លងនោះ ឈ្មោះថា បាចិត្តិយៈ ។

ក៏បាចិត្តិយៈណា រមែងញ៉ាំងចិត្តឱ្យធ្លាក់ទៅ, បាចិត្តិយៈនោះ រមែងខុសចំពោះអរិយមគ្គ និង រមែងជាហេតុនៃសេចក្តីវង្វេងភ្លេចភ្លាំងនៃចិត្ត ។ ព្រោះហេតុនោះ ពាក្យថា ខុសចំពោះអរិយមគ្គ និងពាក្យថា ជាហេតុនៃសេចក្តីវង្វេងភ្លេចភ្លាំងនៃចិត្ត លោកពោលហើយ ។

# វិគ្រោះបាដិទេសនីយៈ

[១២៤] ក្នុងបាដិទេសនីយគាថាទាំងឡាយ ពាក្យថា ភិក្ខុមិនមែនជាញាតិ ជាដើម លោកពោលហើយ ដើម្បីសម្តែងការធ្វើភាពជាធម៌ដែលគួរតិះដៀល ដែលព្រះមានព្រះភាគត្រាស់ថា "គារយ្ហំ អាវុសោ ធម្មំ អាបជ្ជឹ : ម្នាលអាវុសោ ខ្ញុំត្រូវអាបត្តិបាដិទេសនីយៈ ដែលព្រះមាន

ព្រះភាគ ទ្រង់តិះដៀលហើយ មិនជាទីសប្បាយ" ។ ក៏អាបត្តិនោះ លោកហៅថា បាដិទេសនីយៈ ព្រោះត្រូវតែសម្ដែងចេញ ។

# វិគ្រោះទុក្កដ

[១២៥] សេចក្ដីនៃទុក្កដ គប្បីជ្រាបដូច្នេះ ៖

ពាក្យថា **អបរទ្ធំ វិរទ្ធញ្ច ខលិតំ :** ទោះខុសក្ដី ឆ្គាំឆ្គងក្ដី ភ្លាំងភ្លាត់ក្ដី នេះទាំងអស់ ជាពាក្យលើកឡើងហៅ ទុក្កដដែលពោលទុកក្នុងពាក្យនេះថា **យញ្ច ទុក្កដំ : អំពើអាក្រក់ណា ។**

ពិតមែន កម្មណា ដែលបុគ្គលធ្វើមិនល្អ ឬធ្វើខុសប្រក្រតី កម្មនោះ ឈ្មោះថា ទុក្កដ ។ ក៏ទុក្កដនោះឯង ឈ្មោះថា ខុស ព្រោះមិនធ្វើតាមការដែលព្រះសាស្ដាត្រាស់, ឈ្មោះថា ទាស់ព្រោះប្រព្រឹត្តទៅទាស់នឹងកុសល ឈ្មោះថា ភ្លាំងភ្លាត់ ព្រោះមិនឈានឡើងកាន់ការបដិបត្តិក្នុងអរិយមគ្គ ។

ចំណែកពាក្យថា **យំ មនុស្សោ ករេ : មនុស្សធ្វើអំពើណាមួយ** នេះ សម្ដែងសេចក្ដីគួរប្រៀបធៀបក្នុងទុក្កដនេះ ។

សេចក្ដីនៃពាក្យនោះថា មនុស្សក្នុងលោកធ្វើបាបណា ក្នុងទីវាល ឬក្នុងទីកំបាំង, បណ្ឌិតទាំងឡាយប្រកាសបាបនោះថា ទុក្កដ យ៉ាងណា, ទុក្កដសូម្បីនេះ ក៏ដូច្នោះឈ្មោះថា បាប ព្រោះជាកម្មលាមក ដែលព្រះពុទ្ធទ្រង់ស្អប់ ព្រោះហេតុនោះ គប្បីជ្រាបថា ទុក្កដ ។

# វិគ្រោះទុព្ភាសិត

[១២៦] សេចក្តីនៃទុព្ភាសិតគាថា គប្បីជ្រាបដូច្នេះ ៖

បាទគាថាថា ទុព្ភាសិតំ ទុរាភដ្ឋំ : បទណាដែលបុគ្គលពោល អាក្រក់ក្តី មានសេចក្តីថា បទណាដែលភិក្ខុពោល គឺ និយាយ ចរចា អាក្រក់ ហេតុនោះ បទនោះ ឈ្មោះថា ដែលភិក្ខុពោលអាក្រក់ ; អធិប្បាយថា បទណាដែលភិក្ខុពោលអាក្រក់ បទនោះ ជាទុព្ភាសិត ។

មានពាក្យដែលនឹងគប្បីពោលឱ្យក្រៃលែងបន្តិច ; សេចក្តីថា ម្យ៉ាងទៀត បទណាសៅហ្មង បទនោះជាបទសៅហ្មង ព្រោះហេតុណា ; ម្យ៉ាងទៀត វិញ្ញូជនទាំងឡាយ រមែងតិះដៀលព្រោះហេតុណា ; អធិប្បាយថា លោកអ្នកដឹងច្បាស់ទាំងឡាយ តិះដៀលបទនោះ ព្រោះហេតុណា ។

បាទគាថាថា តេនេតំ ឥតិ វុច្ចតិ : ព្រោះហេតុដូច្នោះ សិក្ខាបទនោះ តថាគតហៅថា ទុព្ភាសិត មានសេចក្តីថា ព្រោះភាពជាបទសៅហ្មង និងសូម្បីព្រោះសេចក្តីតិះដៀលនៃវិញ្ញូជននោះ បទនោះ លោកតែងពោលយ៉ាងនោះ គឺ បទនោះ លោកពោលថា ទុព្ភាសិតំ ។

# វិគ្រោះសេក្ខិយៈ

[១២៧] សេចក្តីនៃសេក្ខិយគាថា គប្បីជ្រាបដូច្នេះ ៖

ព្រះឧបាលីថេរៈ សម្តែងសេចក្តីដែលព្រះសេក្ខៈមាន ដោយន័យមានពាក្យថា អាទិ ចេតំ ចរណញ្ច : កំពុងប្រព្រឹត្តតាមលំអានមកត្រង់ ជាដើម ព្រោះហេតុនោះ ក្នុងបទថា សេក្ខិយំ នេះ ទើបមានសេចក្តីសង្ខេបដូច្នេះថា នេះជាខគួរសិក្សារបស់ព្រះសេក្ខៈ ។

ពាក្យថា ចាតុម្មហាបារាជិកានិ យំ វុត្តំ : សិក្ខាបទណាដែលតថាគតហៅថា បារាជិក ជាដើមនេះ គប្បីជ្រាបថា លោកពោលដើម្បីសម្តែងសេចក្តី ដែលមិនបានសង្គ្រោះដោយបញ្ញាដែលថា គរុកលហុកញ្ចាបិ ជាដើម តែសង្គ្រោះដោយពាក្យអង្វរនេះថា ហន្ទ វាក្យំ សុណោមតេ (ណ្ហើយចុះ យើងទាំងឡាយនឹងស្តាប់នូវព្រះពុទ្ធដីការបស់ព្រះអង្គ) ។

# ឧបមានៃអាបត្តិ និងអនាបត្តិ

សួរថាក្នុងបទថា ឆន្នមតិវស្សតិ ជាដើម ក៏ន័យនេះឯង ។

បណ្ដាបទទាំងនោះ បទថា ឆន្នមតិវស្សតិ : ភិក្ខុដែលបិទបាំង (មូលាបត្តិ) មានសេចក្ដីថា ផ្ទះដែលមិនបានប្រក់ ដោយស្មៅជាដើម ភ្លៀងរមែងសាចទទឹក ។ តែផ្ទះ ពោលគឺ អាបត្តិនេះ ដែលភិក្ខុបិទទុក ហើយ រមែងទទឹក ។

ពិតមែន ភិក្ខុកាលបិទអាបត្តិដំបូងទុក រមែងត្រូវអាបត្តិដទៃថ្មី ។

ពីរបទថា វិវដំ ណាតិវស្សតិ : ភិក្ខុដែលបើក (ប្រាប់មូលាបត្តិ) មានសេចក្ដីថា ផ្ទះដែលមិនបើក គឺ ប្រក់ល្អហើយ រមែងមិនទទឹកភ្លៀងទេ ។ តែផ្ទះ ពោលគឺ អាបត្តិនេះ ដែលភិក្ខុបើកហើយ រមែងមិនទទឹក ។

ពិតមែន ភិក្ខុកាលបើកបង្ហាញអាបត្តិដំបូង សម្ដែងអាបត្តិ ដែលជាទេសនាគាមិនី ចេញចាកអាបត្តិដែលជាវុដ្ឋានគាមិនី រមែងប្រតិស្ឋានក្នុងចំណែកបរិសុទ្ធិ ។ កាលសង្រួមតទៅ រមែងមិនត្រូវអាបត្តិដទៃ ។

បាទគាថាថា តស្មា ឆន្នំ វិវរេថ : ព្រោះហេតុដូច្នោះ មានសេចក្ដីថា ព្រោះហេតុនោះ កាលសម្ដែងអាបត្តិដែលជាទេសនាគាមិនី និងចេញចាកអាបត្តិដែលជាវុដ្ឋានគាមិនី ឈ្មោះថា បើកអាបត្តិដែលបិទ

ទុក ។

បាទគាថាថា **ឯវន្តំ ឆាតិវស្សតិ : ធ្វើយ៉ាងនេះ ទើបមិនត្រូវអាបត្តិថ្មីទៀត** មានសេចក្តីថា ក៏ផ្ទះ ពោលគឺ អាបត្តិនោះ ដែលភិក្ខុសម្តែងហើយយ៉ាងនោះ រមែងមិនទទឹក ។

បាទគាថាថា **គតិ មិគានំ បវនំ : ព្រៃជាដំណើររបស់ពួកម្រឹគ** មានសេចក្តីថា ព្រៃធំ គឺ ព្រៃដែលក្រាស់ដោយដើមឈើជាដើម ជាគតិ គឺជាទីពឹងរបស់ម្រឹគទាំងឡាយ ដែលម្រឹគកាចមានខ្លាធំជាដើមឱ្យដួលក្នុងទីវាល ។ ម្រឹគទាំងនោះ ដល់ព្រៃនោះហើយ រមែងរីករាយចិត្ត ។ ដោយន័យនេះឯង អាកាសជាមកទៅរបស់ពួកបក្សី, សេចក្តីសាបសូន្យជាគតិរបស់ធម៌ទាំងឡាយ គឺថា សេចក្តីវិនាសជាមករបស់សង្ខតធម៌សព្វទាំងពួង ព្រោះអត្ថថា ត្រូវចូលដល់សេចក្តីវិនាសពិត ។

ពិតមែន សង្ខតធម៌ទាំងនោះ មិនដល់សេចក្តីវិនាស នឹងអាចតាំងនៅ ក៏ទេ ។ ចំណែកនិព្វានតាំងនៅយូរ ជាគតិរបស់ព្រះអរហន្ត អធិប្បាយថា អនុបាទិសេសនិព្វានធាតុ ជាមកទៅតែមួយផ្នែករបស់ព្រះអរហន្តខីណាស្រព ។

បឋមគាថា សង្គណិក វណ្ណនា ចប់

# ពណ៌នាអធិករណភេទ

## សេរីវិសមថៈ ដោយសេរីវិអធិករណ៍

[១២៩] វិនិច្ឆ័យក្នុងអធិករណភេទ គប្បីជ្រាបដូច្នេះ ៖

ព្រះឧបាលីថេរៈ គ្រាពោលសេរីវិអធិករណ៍ថា ការសេរីវេរី ១០ ទាំងនេះហើយបានពោលថា "កាលសេរីវេរីវិវាទាធិករណ៍ រមែងសេរីវេរីសមថៈប៉ុន្មាន ?" ជាដើម ដើម្បីសម្តែងការសេរីវេរីសមថៈ ព្រោះសេរីវេរីអធិករណ៍ទៀត ។

ក្នុងបទទាំងនោះ ប្រើនបទថា វិវាទាធិករណំ ឧក្កោដេន្តោ ទ្វេសមថេ ឧក្កោដេតិ : កាលបើសេរីវេរីវិវាទាធិករណ៍ តែងសេរីវេរីនូវសមថៈ ២ យ៉ាង មានសេចក្តីថា រមែងសេរីវេរី គឺ បដិសេធ ជំទាស់សមថៈ ២ នេះ គឺសម្មុខាវិន័យ ១ យេភុយ្យសិកា ១ ។

ប្រើនបទថា អនុវាទាធិករណំ ឧក្កោដេន្តោ ចត្តារោ : កាលបើសេរីវេរីអនុវិវាទាធិករណ៍ តែងសេរីវេរីនូវសមថៈ ៤ យ៉ាង មានសេចក្តីថា រមែងសេរីវេរីសមថៈ ៤ ទាំងនេះ គឺសម្មុខាវិន័យ សតិវិន័យ អមូឡ្ហវិន័យ តស្សបាបិយសិកា ។

ប្រើនបទថា អាបត្តាធិករណំ ឧក្កោដេន្តោ តយោ : កាលបើសេរីវេរីអាបត្តាធិករណ៍ តែងសេរីវេរីនូវសមថៈ ៣ យ៉ាង បានដល់ រមែង

សើរើសមថៈ ៣ នេះ គឺ សម្មុខាវិន័យ បដិញ្ញាតករណៈ តិណវត្ថារកៈ ។

ប្រែថាបទថា កិច្ចាធិករណំ ឯកេន សមថេន សម្មតិ : កាលបើសើរើកិច្ចាធិករណ៍ តែងសើរើនូវសមថៈ ១ យ៉ាង មានសេចក្ដីថា រមែងសើរើសមថៈ ១ នេះ គឺ សម្មុខាវិន័យ ។

## ការសើរើ ១២

[១៣០] បណ្ដាការសើរើ ១២ ក្នុងវារៈដែលតបពាក្យសួរថា "ការសើរើមានប៉ុន្មាន ?" ជាដើម, ការសើរើ ៣ មុន មានជាដើម គឺ "កម្មដែលសង្ឃមិនទាន់បានធ្វើ រមែងបានក្នុងអនុវាទាធិករណ៍ទី ២ ដោយពិសេស ។

ការសើរើសមថៈ ៣ មានជាដើម គឺ អធិករណ៍ដែលសង្ឃមិនទាន់បានជម្រះ រមែងបានក្នុងវិវាទាធិករណ៍ខាងដើម ។

ការសើរើសមថៈ ៣ មានជាដើម គឺ អធិករណ៍ដែលសង្ឃមិនទាន់បានវិនិច្ឆ័យ រមែងបានក្នុងអាបត្តាធិករណ៍ទី ៣ ។

ការសើរើ ៣ មានជាដើម គឺ អធិករណ៍ដែលសង្ឃមិនទាន់បានរម្ងាប់ រមែងបានក្នុងកិច្ចាធិករណ៍ទី ៤ ។

មួយទៀត ការរើសូម្បីទាំង ១២ រមែងបានក្នុងអធិករណ៍ តែមួយយ៉ាងពិត ។

# ការបានធ្នូវការសើរើ ១០ យ៉ាង

ប្រើនបទថា តត្ថ ជាតកំ អធិការណំ ឧក្កោដេតិ : ភិក្ខុសើរើអធិករណ៍ដែលកើតក្នុងទីនោះ មានសេចក្ដីថា ក្នុងវត្តណាមានអធិករណ៍ ដើម្បីត្រូវការបរិក្ខារ មានបាត្រ និងចីវរជាដើមកើតឡើងដោយន័យមានជាដើមថា បាត្ររបស់ខ្ញុំ ភិក្ខុនេះកាន់យកហើយ, ចីវររបស់ខ្ញុំ ភិក្ខុនេះកាន់យកហើយ, ពួកភិក្ខុម្ចាស់អាវាសប្រជុំគ្នាក្នុងវត្តនោះឯង សម្របសម្រួលពួកភិក្ខុដែលជាសត្រូវដល់ខ្លួនឱ្យយល់ព្រមថា "កុំឡើយ អ្នកមានអាយុ" ហើយឱ្យអធិករណ៍រម្ងាប់ ដោយវិនិច្ឆ័យក្រៅបាលីពិត ៗ ។ នេះឈ្មោះថា អធិករណ៍កើតក្នុងទីនោះ អធិករណ៍នោះរម្ងាប់ហើយ ដោយចំពោះវិនិច្ឆ័យសូម្បីណា វិនិច្ឆ័យសូម្បីនោះ ជាសមថៈមួយពិត ។ សូម្បីភិក្ខុសើរើអធិករណ៍នេះ ក៏ត្រូវអាបត្តិបាចិត្តិយ ។

ពីរបទថា តត្ថ ជាតកំ វូបសន្តំ : ភិក្ខុសើរើអធិករណ៍ដែលកើតក្នុងទីនោះ ហើយរម្ងាប់ទៅវិញ មានសេចក្ដីថា ក៏បើថា អាវាសិកភិក្ខុទាំងឡាយ មិនអាចឱ្យអធិករណ៍នោះរម្ងាប់បានសោត ។ ពេលនោះ ភិក្ខុដទៃជាព្រះថេរៈដែលទ្រទ្រង់វិន័យមក សួរថា "អាវុសោ ហេតុអ្វីបានជាក្នុងវត្តនេះ លះបង់ឧបោសថ ឬបវារណាចេញ ?" និងកាលភិក្ខុទាំងនោះ រៀបរាប់អធិករណ៍នោះ ហើយ ទើបវិនិច្ឆ័យអធិករណ៍នោះ

ដោយសូត្រ ដោយខន្ធកៈ និងបរិវារៈឱ្យរម្ងាប់ចេញ ។ អធិករណ៍នេះឈ្មោះថា កើតក្នុងទីនោះរម្ងាប់ហើយ ។ សូម្បីភិក្ខុសើរើអធិករណ៍នោះ ក៏ត្រូវអាបត្តិបាចិត្តិយដែរ ។

បទថា អន្តរាមគ្គេ : ក្នុងទីពាក់កណ្តាលមក មានសេចក្តីថា បើថា ភិក្ខុដែលជាសត្រូវដល់ខ្លួនទាំងនោះពោលថា "យើងមិនព្រមចុះសម្រុងក្នុងពាក្យកាត់សេចក្តីរបស់ព្រះថេរៈនេះ ព្រះថេរៈនេះ មិនឆ្លាតក្នុងវិន័យ ព្រះថេរៈទាំងឡាយ ដែលទ្រទ្រង់វិន័យនៅក្នុងស្រុកឈ្មោះឯណោះ យើងនឹងទៅកាត់ក្តីនៅឯស្រុកនោះ" ដូច្នេះ កំពុងនាំគ្នាទៅ ក្នុងចន្លោះមកនុ៎ះឯង កំណត់ហេតុបាន ទើបព្រមព្រៀងគ្នាដោយខ្លួនឯង ឬភិក្ខុពួកដទៃញ៉ាំងភិក្ខុទាំងនោះឱ្យព្រមព្រៀងគ្នាបាន សូម្បីអធិករណ៍នេះ ក៏ជាការរម្ងាប់ពិត ។ ភិក្ខុណាសើរើអធិករណ៍ ក្នុងចន្លោះមកដែលរម្ងាប់យ៉ាងនេះ ភិក្ខុនោះ ក៏ត្រូវអាបត្តិបាចិត្តិយដែរ ។

ពីរបទថា អន្តរាមគ្គេ វូបសន្តំ : ដែលស្ងប់រម្ងាប់ហើយក្នុងទីពាក់កណ្តាលមក មានសេចក្តីថា មួយទៀត អធិករណ៍ជាការរម្ងាប់ដោយការយល់ព្រមនុ៎ះឯង ឬដោយការដែលភិក្ខុជាសភាគគ្នាឱ្យព្រមព្រៀងគ្នា ក៏មិនមែនឡើយ ។

ក៏ប៉ុន្តែថា ព្រះវិន័យធរមួយរូបធ្វើដំណើរមក ឃើញហើយ សួរថា "អ្នកមានអាយុពួកលោកនាំគ្នាទៅទីណា ?" កាលភិក្ខុទាំងនោះ ឆ្លើយ

ថា "ទៅស្រុកឈ្មោះឯណោះ" ដោយហេតុឈ្មោះនេះ ទើបពោលថា "កុំឡើយអ្នកមានអាយុ ទៅទីនោះ គ្មានប្រយោជន៍ទេ ?" ហើយញុំាងអធិករណ៍នោះឱ្យរម្ងាប់ដោយធម៌ ដោយវិន័យ ក្នុងទីនោះឯង នេះឈ្មោះថា អធិករណ៍រម្ងាប់ក្នុងចន្លោះមក ។ គង់ជាបាចិត្តិយ សូម្បីដល់ភិក្ខុដែលសើរើអធិករណ៍នោះ ។

ពីរបទថា តត្ថ គតំ : **ដែលដល់ក្នុងទីនោះ** មានសេចក្ដីថា ក៏បើថា ភិក្ខុទាំងនោះ សូម្បីដែលព្រះវិន័យធរពោលថា "កុំឡើយ អ្នកមានអាយុ នឹងមានប្រយោជន៍អ្វីដោយការទៅទីនោះ ?" ឆ្លើយថា "យើងនឹងទៅឱ្យដល់ការកាត់ក្ដីក្នុងទីនោះឯង" មិនអើពើពាក្យរបស់ព្រះវិន័យធរប្រឹងទៅទាល់តែបាន កាលទៅហើយ ប្រាប់សេចក្ដីនោះ ដល់ពួកភិក្ខុដែលជាសភាគគ្នា សភាគភិក្ខុទាំងឡាយ ហាមឃាត់ថា "កុំឡើយ អ្នកមានអាយុ ដែលឈ្មោះថា ការប្រជុំសង្ឃជាការធ្ងន់" ហើយឱ្យនាំគ្នាអង្គុយ វិនិច្ឆ័យឱ្យព្រមព្រៀងគ្នា ក្នុងទីនោះឯង ។ អធិករណ៍សូម្បីនេះ រមែងជាការរម្ងាប់ពិត ។ ភិក្ខុណាសើរើអធិករណ៍ ទៅក្នុងទីនោះ ដែលរម្ងាប់ហើយយ៉ាងនេះ គង់ជាបាចិត្តិយសូម្បីដល់ភិក្ខុនោះ ។

ប្រើនបទថា តត្ថ គតំ វូបសន្តំ : **ដែលដល់ក្នុងទីនោះ ហើយរម្ងាប់** មានសេចក្ដីថា មួយទៀត អធិករណ៍នោះ មិនមែនជាការរម្ងាប់ដោយកិរិយាដែលឱ្យព្រមព្រៀងគ្នារបស់សភាគភិក្ខុទាំងឡាយទេ ។

ក៏ប៉ុន្តែថា ព្រះវិន័យធរទាំងឡាយ ឱ្យរម្ងាប់អធិករណ៍នោះ ដែលឱ្យប្រជុំសង្ឃ ប្រាប់ក្នុងកណ្តាលជំនុំសង្ឃ នេះឈ្មោះថា អធិករណ៍ទៅក្នុងទីនោះរម្ងាប់ហើយ ។ ភិក្ខុដែលសើរើអធិករណ៍នោះ ក៏ត្រូវអាបត្តិបាចិត្តិយដែរ ។

បទថា សង្ឃវិនយំ មានសេចក្តីថា ភិក្ខុសើរើសង្ឃវិន័យដែលសង្ឃឱ្យហើយដល់ព្រះទីណាស្រេច ត្រូវអាបត្តិបាចិត្តិយ ។

ក្នុងអមូឡ្ហវិន័យ ដែលសង្ឃឱ្យហើយដល់ភិក្ខុឆត្តក្តី ក្នុងតស្សបាបិយសិកា ដែលសង្ឃឱ្យហើយដល់ភិក្ខុដែលមានបាបក្រាស់ សូម្បីក្តី មានន័យដូចគ្នា ។

ពីរបទថា តិណវត្ថារកំ ឧក្កោដេតិ : សើរើនូវតិណវត្ថារកៈ មានសេចក្តីថា កាលអធិករណ៍ដែលសង្ឃរម្ងាប់ហើយ ដោយតិណវត្ថារកសមថ: ធម្មតាអាបត្តិ ដែលភិក្ខុចូលទៅរកភិក្ខុមួយរូប អង្គុយប្រហោងផ្គងអញ្ជលីសម្តែងចេញ ឈ្មោះថា សម្តែងចេញ ។

ក៏ភិក្ខុសូម្បីពោលយ៉ាងនេះថា ឈ្មោះថា ការចេញចាកអាបត្តិសូម្បីរបស់ភិក្ខុដែលដេកលក់ នេះណា ការចេញចាកអាបត្តិនោះ មិនពេញចិត្តខ្ញុំ ដូច្នេះ ឈ្មោះថា សើរើតិណវត្ថារកៈ ។ សូម្បីភិក្ខុនោះ ក៏ត្រូវអាបត្តិបាចិត្តិយដែរ ។

# អង្គ ៤ ជាហេតុសើរើអធិករណ៍

ច្រើនបទថា ឆន្ទាគតឹ គច្ឆន្តោ អធិករណំ ឧក្កោដេតិ ទោសាគតឹ ។បេ ។ មោហាគតឹ ។បេ ។ ភយាគតឹ ។បេ ។ គច្ឆន្តោ អធិករណំ ឧក្កោដេតិ : បុគ្គលលុះឆន្ទាគតិ ១ ទើបសើរើនូវអធិករណ៍, លុះទោសគតិ ១ លុះមោហាគតិ ១ លុះភយាគតិ ១ ទើបសើរើនូវអធិករណ៍, មានសេចក្ដីថា ភិក្ខុជាព្រះវិន័យធរ កាលសម្ដែងអធម៌ថា ធម៌ជាដើម សើរើអធិករណ៍ដែលសង្ឃវិនិច្ឆ័យសម្រេចហើយក្នុងកាលមុន ដោយអាការសើរើ ១២ យ៉ាង ណាមួយ ដើម្បីប្រយោជន៍ដល់ជនជាទីស្រឡាញ់ មានឧបជ្ឈាយ៍ជាដើមរបស់ខ្លួន ឈ្មោះថា ដល់ឆន្ទាគតិសើរើអធិករណ៍ ។

ក៏ក្នុងភិក្ខុដែលជាសត្រូវគ្នា ២ រូប ភិក្ខុដែលមានអាឃាត ក្នុងចំណែកមួយ កើតឡើងដោយន័យជាដើមថា គេបានប្រព្រឹត្តធ្វើអំពើមិនជាប្រយោជន៍ដល់យើង កាលសម្ដែងអធម៌ថា ធម៌ជាដើម សើរើអធិករណ៍ដែលសង្ឃវិនិច្ឆ័យសម្រេចហើយ ក្នុងកាលមុន ដោយការសើរើ ១២ យ៉ាង ណាមួយ ដើម្បីលើកសេចក្ដីបរាជ័យឱ្យដល់ភិក្ខុដែលជាសត្រូវនោះ ឈ្មោះថា ដល់ទោសគតិ សើរើអធិករណ៍ ។

ចំណែកភិក្ខុល្ងង់ខ្លៅ កាលសម្តែងអធម៌ថា ធម៌ជាដើម ព្រោះខ្លួនជាមនុស្សល្ងង់ខ្លៅនុ៎ះឯង សើរើអធិករណ៍ ដោយន័យដែលពោលហើយនោះឯង ឈ្មោះថា ដល់មោហាគតិ សើរើអធិករណ៍ ។

ក៏បើថា ក្នុងភិក្ខុ ២ រូប ជាសត្រូវគ្នា មួយរូបជាអ្នកអាស្រ័យកម្មដែលមិនស្មើ អាស្រ័យទិដ្ឋិ និងអាស្រ័យអ្នកមានកម្លាំង ព្រោះជាអ្នកអាស្រ័យកយកម្មជាដើម ដែលមិនស្មើ អាស្រ័យមិច្ឆាទិដ្ឋិ គឺសេចក្តីប្រកាន់ និងអាស្រ័យភិក្ខុដែលមានកេរ្តិ៍ឈ្មោះ បានបក្ខពួកដែលមានកម្លាំង ។ ព្រោះខ្លាចភិក្ខុនោះថា អ្នកនេះនឹងគប្បីធ្វើអន្តរាយដល់ជីវិត ឬអន្តរាយដល់ព្រហ្មចរិយៈ របស់យើង កាលសម្តែងអធម៌ថា ធម៌ជាដើម សើរើអធិករណ៍ ដោយន័យដែលពោលហើយនុ៎ះឯង ឈ្មោះថា ដល់ភយាគតិ សើរើអធិករណ៍ ។

## អ្នកសើរើអធិករណ៍ត្រូវអាបត្តិ

បទថា តទហុបសម្បន្នោ ៖ បុគ្គលទើបតែបានឧបសម្បទាក្នុងថ្ងៃនោះ មានសេចក្តីថា សាមណេរមួយរូបជាអ្នកឆ្លាតជាពហុស្សូត លោកឃើញភិក្ខុទាំងឡាយបរាជ័យក្នុងការកាត់ក្តីហើយ ជាអ្នកសោកសៅ ទើបសួរថា “ហេតុអ្វី ពួកលោកទើបនាំគ្នាសោកសៅ ?” ភិក្ខុទាំងនោះ

ទើបប្រាប់ហេតុនោះ ដល់លោក ។ ទើបលោកពោលនឹងភិក្ខុទាំងនោះយ៉ាងនេះថា "ណ្ហើយចុះ លោកម្ចាស់ លោកចូរឧបសម្បទាឱ្យខ្ញុំ, ខ្ញុំនឹងញ៉ាំងអធិករណ៍នោះឱ្យរម្ងាប់" ។ ភិក្ខុទាំងនោះ ញ៉ាំងលោកឱ្យឧបសម្បទា ។ លោកវាយស្គរឱ្យសង្ឃប្រជុំគ្នាក្នុងថ្ងៃស្អែក ។ លំដាប់នោះ លោកដែលភិក្ខុទាំងឡាយពោលថា "អ្នកណា ឱ្យសង្ឃប្រជុំ ?" ទើបឆ្លើយថា "ខ្ញុំព្រះករុណា" "ឱ្យប្រជុំព្រោះហេតុអ្វី ?" "ពីម្សិលមិញវិនិច្ឆ័យអធិករណ៍មិនល្អ ខ្ញុំនឹងវិនិច្ឆ័យអធិករណ៍នោះក្នុងថ្ងៃនេះ" ។ "ក៏ថ្ងៃម្សិលមិញ លោកទៅទីណា ?", "ខ្ញុំព្រះករុណា នៅជាអនុបសម្បន្នលោកម្ចាស់, តែថ្ងៃនេះខ្ញុំព្រះករុណាជាឧបសម្បន្នហើយ" ។ លោកដែលភិក្ខុទាំងឡាយគប្បីពោលថា "អាវុសោ សិក្ខាបទនេះ ដែលព្រះមានព្រះភាគទ្រង់បញ្ញត្តិហើយដល់ភិក្ខុទាំងឡាយ ប្រហែលដូចលោកថា 'បុគ្គលទើបនឹងបានឧបសម្បទាក្នុងថ្ងៃនោះ សើរើត្រូវឱក្កោដនកបាចិត្តិយ'[១] លោកចូរទៅសម្ដែងអាបត្តិចេញ" ។ សូម្បីក្នុងអាគន្តុកៈក៏ន័យនេះឯង ។

បទថា ការកោ : បុគ្គលជាអ្នកធ្វើ មានសេចក្ដីថា ភិក្ខុទាំងឡាយ អ្នកបរាជ័យនិយាយចំពោះភិក្ខុមួយរូប ទៅកាន់សាលាវិនិច្ឆ័យអធិករណ៍ព្រមទាំងសង្ឃថា "ហេតុអ្វី បានជាពួកលោកកាត់សេចក្ដីនៃ

---

១. វិន. បរិ. អធិករណភេទ. ១៣. ១៣០/១៤៣ ; សមប្បាណវគ្គទី៣ ។

អធិករណ៍យ៉ាងនោះហ្ន៎ លោកម្ចាស់ គួរកាត់សេចក្ដីយ៉ាងនេះ មិនមែនឬ ?” ភិក្ខុនោះពោលថា “ហេតុអ្វី ទើបលោកមិននិយាយយ៉ាងនេះជាមុនហ្ន៎ ?” ដូច្នេះ ឈ្មោះថា សើរើអធិករណ៍នោះ ភិក្ខុណាជាអ្នកធ្វើការសើរើអធិករណ៍យ៉ាងនោះ ជាឧក្កោដនកបាចិត្តិយ សូម្បីដល់ភិក្ខុនោះ ។

បទថា ឆន្ទទាយកោ : បុគ្គលអ្នកឱ្យឆន្ទៈ មានសេចក្ដីថា ភិក្ខុមួយរូប ប្រគល់ឆន្ទៈ ក្នុងការវិនិច្ឆ័យអធិករណ៍ហើយ ឃើញពួកភិក្ខុដែលជាសភាគគ្នាបរាជ័យមកជាអ្នកសោកសៅ ទើបពោលថា “ស្អែកនេះ ខ្ញុំនឹងកាត់ក្ដីនោះ” ឱ្យសង្ឃប្រជុំគ្នាហើយ ដែលភិក្ខុទាំងឡាយពោលថា “ឱ្យប្រជុំសង្ឃ ព្រោះហេតុអ្វី ?” ទើបឆ្លើយថា “កាលម្សិលមិញអធិករណ៍កាត់ក្ដីមិនល្អ ថ្ងៃនេះ ខ្ញុំនឹងកាត់ក្ដីអធិករណ៍នោះឯង” ។ “ក៏កាលម្សិលមិញ លោកចេញទៅណាហ្ន៎ ?” “ខ្ញុំប្រគល់ឆន្ទៈ ហើយអង្គុយ” ។ លោកដែលភិក្ខុទាំងឡាយ គប្បីពោលថា “អាវុសោ សិក្ខាបទនេះ ដែលព្រះមានព្រះភាគទ្រង់បញ្ញត្តិហើយ ដល់ភិក្ខុទាំងឡាយប្រភេទដូចជាលោកអ៊ីចឹងថា “បុគ្គលអ្នកឱ្យឆន្ទៈ សើរើ ត្រូវឧក្កោដនកបាចិត្តិយ”[១]; លោកចូរទៅសម្ដែងអាបត្តិចេញ ។

---

១. វិន. បរិ. អធិករណភេទ. ១៣. ១៣០/១៤៤ ។

# និទានជាដើមនៃអធិករណ៍

[១៣១] វិនិច្ឆ័យក្នុងពាក្យថា វិវាទាធិករណំ កឹនិទានំ : វិវាទាធិករណ៍ មានអ្វីជាគ្រឿងប្រគល់ឱ្យនូវផល ជាដើម គប្បីជ្រាបដូច្នេះ ៖

ឈ្មោះថា មានអ្វីជាគ្រឿងប្រគល់ឱ្យនូវផល ព្រោះអត្ថថា អ្វីជាហេតុផ្តល់នៃអធិករណ៍នោះ ។

ឈ្មោះថា មានអ្វីជាហេតុឱ្យកើត ព្រោះអត្ថថា អ្វីជាហេតុ ជាដែនកើត ព្រមនៃអធិករណ៍នោះ ។

ឈ្មោះថា មានអ្វីជាកំណើត ព្រោះអត្ថថា អ្វីជាកំណើតនៃអធិករណ៍នោះ ។

ឈ្មោះថា មានអ្វីជាដែន ព្រោះអត្ថថា អ្វីជាដែនកើតមុន

ឈ្មោះថា មានអ្វីជាអង្គ ព្រោះអត្ថថា អ្វីជាគ្រឿងប្រជុំ (គ្រឿងផ្សំ)

ឈ្មោះថា មានអ្វីជាសមុដ្ឋាន ព្រោះអត្ថថា អ្វីជាទីកើតនៃអធិករណ៍នោះ ។

បទទាំងនេះទាំងអស់ ជាវេវចនៈរបស់ហេតុនុ៎ះឯង ។

វិនិច្ឆ័យសូម្បីក្នុងពាក្យថា **វិវាទនិទានំ** : មានសេចក្តីទាស់ទែងគ្នាជាគ្រឿងប្រគល់ឱ្យនូវផល ជាដើម គប្បីជ្រាបដូច្នេះ ៖

ឈ្មោះថា មានវិវាទជាគ្រឿងប្រគល់ឱ្យនូវផល (និទាន) ព្រោះអត្ថថា វិវាទ ពោលគឺ រឿងបង្កហេតុឱ្យបែកគ្នា ១៨ ប្រការ ជាហេតុផ្តល់នៃវិវាទាធិករណ៍នោះ ។

ពាក្យថា **វិវាទនិទានំ** នោះ លោកពោលដោយអំណាចវិវាទដែលអាស្រ័យករប្រកែកគ្នាកើតឡើង ។

ឈ្មោះថា មានអនុវាទជានិទាន ព្រោះអត្ថថា ការចោទជាហេតុផ្តល់នៃអនុវាទាធិករណ៍នោះ ។

សូម្បីពាក្យថា **អនុវាទនិទានំ** នេះ លោកពោលដោយអំណាចអនុវាទដែលអាស្រ័យករចោទគ្នាកើតឡើង ។

ឈ្មោះថា មានអាបត្តិជានិទាន ព្រោះអត្ថថា អាបត្តិជាហេតុផ្តល់នៃអាបត្តាធិករណ៍នោះ ។

ពាក្យថា **អាបត្តិនិទានំ** នោះ លោកពោលដោយអំណាចអាបត្តិដែលអាស្រ័យករកើតឡើងយ៉ាងនេះថា ភិក្ខុរមែងត្រូវអាបត្តិ ៤ ដែលមានអាបត្តាធិករណ៍ជាបច្ច័យ ។

ឈ្មោះថា មានកិច្ចជានិទាន ព្រោះអត្ថថា កិច្ច ៤ យ៉ាងជាហេតុប្រគល់ឱ្យនៃកិច្ចាធិករណ៍នោះ, អធិប្បាយថា សង្ឃកម្ម ៤ យ៉ាង ជាហេតុនៃកិច្ចាធិករណ៍នោះ ។

ពាក្យថា **កិច្ចយនិទានំ** នោះ លោកពោលដោយអំណាចកិច្ចទាំងឡាយ ដែលអាស្រ័យករដែលចាំបាច់ត្រូវធ្វើឱ្យកើតឡើង មានសមនុភាសនៈ ៣ ដង ជាដើម ដល់ភិក្ខុនីដែលប្រព្រឹត្តតាមភិក្ខុដែលត្រូវសង្ឃលើកវត្ត ។

នេះជាវាចាប្រកបចំពោះបទតែមួយ ក្នុងចំណែកវិសជ្ជនាអធិករណ៍ទាំង ៤ ។ គ្រប់ ៗ បទគប្បីប្រកបដោយទំនងនេះ ។

ក្នុងវិសជ្ជនាមានពាក្យថា មានហេតុជានិទាន ជាដើមនៃទុតិយបុច្ឆាគប្បីជ្រាបភាវៈនៃនិទានជាដើម ដោយអំណាចនៃកុសលហេតុអកុសលហេតុ និងអព្យាកតហេតុ ៩ ពួក ។

ក្នុងវិសជ្ជនានៃតតិយបុច្ឆា គប្បីជ្រាបថា ផ្សេងគ្នាត្រឹមតែថា ព្យញ្ជនៈ ។ ពិតមែន ហេតុនុ៎ះឯង លោកពោលថា បច្ច័យក្នុងតតិយបុច្ឆានេះ ។

# មូលជាដើមនៃអធិករណ៍

វិនិច្ឆ័យ ក្នុងវារៈដែលតបពាក្យសួរដល់មូល គប្បីជ្រាបដូច្នេះ ៖

[១៣២] ពីរបទថា ទ្វាទស មូលានិ : មានមូល ១២ បានដល់ មូល ១២ ដែលប្រព្រឹត្តទៅខាងក្នុងសន្ធានទាំងនេះ គឺ វិវាទមូល ៦ មានក្រោធ ចងគំនុំ និងសេចក្ដីប្រណាំងប្រជែងជាដើម លោភៈ ទោសៈ និងមោហៈ ៣ អលោភៈ អទោសៈ និងអមោហៈ ៣ ។

ពីរបទថា ចុទ្ទស មូលានិ : មានមូល ១៤ បានដល់ មូល ១២ នោះឯង រួមជាមួយកាយនិងវាចាទើបរួមជា ១៤ ។

ពីរបទថា ឆ មូលានិ : មានមូល ៦ បានដល់ មូល ៦ មានកាយជាដើម ។

វិនិច្ឆ័យក្នុងវារៈ ដែលតបពាក្យសួរដល់សមុដ្ឋាន គប្បីជ្រាបដូច្នេះ ៖

រឿងកកើតសេចក្ដីបែកគ្នា ១៨ ប្រការ ជាសមុដ្ឋាននៃវិវាទាធិករណ៍ ពិតមែន វិវាទាធិករណ៍នោះ រមែងតាំងឡើងក្នុងរឿងកកើតសេចក្ដីបែកគ្នា ១៨ ប្រការទាំងនោះ ឬថា រមែងតាំងឡើង ព្រោះរឿងកកើតសេចក្ដីបែកគ្នាទាំងនោះជាហេតុ, ដោយហេតុនោះ រឿងកកើតសេចក្ដីបែកគ្នាទាំងនោះ លោកទើបពោលថា ជាសមុដ្ឋាននៃវិវាទា

ធិករណ៍នោះ ៗ ក្នុងអធិករណ៍ទាំងពួង ក៏ន័យនេះ ៗ

ក្នុងន័យដែលផ្សេងគ្នាដោយពាក្យថា វិវាទាធិករណ៍ ជាអាបត្តិ ឬ ? ជាដើម ពាក្យថា ដោយអធិករណ៍មួយ គឺ កិច្ចាធិករណ៍នេះ លោកពោលហើយ ដើម្បីសម្តែងបណ្តាអធិករណ៍ទាំងឡាយ ចំពោះអធិករណ៍ដែលជាគ្រឿងរម្ងាប់អាបត្តិទាំងឡាយ ៗ តែកងអាបត្តិទាំងនោះនឹងរម្ងាប់ដោយកិច្ចាធិករណ៍មួយចំណែកប៉ុណ្ណោះ ក៏ទេ ៗ ព្រោះធម្មតាកិច្ចាធិករណ៍ មិនមែនសម្រេចដល់ភិក្ខុដែលសម្តែងក្នុងសំណាក់បុគ្គលទេ ៗ

[១៣៥-៦] ពីរបទថា **ន កតមេន សមថេន : មិនរម្ងាប់ដោយសមថៈណាទេ** មានសេចក្តីថា អាបត្តិដែលមិនមានចំណែកនៅសល់នោះ មិនរម្ងាប់ដូចអាបត្តិដែលមានចំណែកនៅសល់ទេ ៗ ព្រោះថាអាបត្តិដែលជាអនវសេសនោះ ដែលភិក្ខុមិនអាចសម្តែង គឺ មិនអាចតាំងនៅក្នុងចំណែកបរិសុទ្ធិ ចាប់ផ្តើមតាំងពីអនវសេសាបត្តិនោះ ៗ

[១៣៧] ន័យថា **វិវាទាធិករណំ ហោតិ អនុវាទាធិករណំ : វិវាទាធិករណ៍ ទៅជាអនុវាទាធិករណ៍** ជាដើម ងាយយល់ទាំងអស់ហើយ ៗ

[១៤១] ខាងមុខអំពីនោះ លោកពោលបុច្ឆា ៦ គូ មិនវៀរសម្មុខាវិន័យ មានពាក្យថា **យត្ថ សតិវិនយោ : សតិវិន័យ មានក្នុងទីណា** ជាដើម, លោកប្រកាសសេចក្តីហើយ ដោយវិសជ្ជនាបុច្ឆាទាំងនោះឯង ៗ

# សមថៈលាយនិងមិនលាយគ្នា

[១៤៣] វិនិច្ឆ័យក្នុងវារៈ ដែលពន្យល់ពាក្យសួរដល់សមថៈដែលលាយគ្នាជាដើម គប្បីជ្រាបដូចនេះ ៖

បទថា សំសដ្ឋា : លាយប្រឡំគ្នា មានសេចក្តីថា ធម៌ទាំងនេះ គឺ សម្មុខវិន័យក្តី សតិវិន័យក្តី ឈ្មោះថា លាយគ្នា គឺ មិនបែកគ្នា ព្រោះសមថៈទាំង ២ សម្រេចក្នុងខណៈនៃកម្មវាចាឱ្យសតិវិន័យនុ៎ះឯង ។ ក៏ព្រោះសេចក្តីសម្រេចនៃសមថៈទាំង ២ ដូចការជាប់គ្នានៃសន្ទុបចេកក្នុងដើមចេក អ្នកណា ៗ មិនអាចនឹងសម្តែងការបែកសមថៈទាំងនោះចេញពីគ្នាបាន ។ ដូច្នោះ ទើបលោកពោលថា មួយទៀត លោកមិនអាចបែករំលែកធម៌ទាំងនេះ ហើយបញ្ញត្តិឱ្យផ្សេងពីគ្នាបានទេ ។ ក្នុងបទទាំងពួងក៏ន័យនេះ ។

# និទានជាដើមនៃសមថៈ

[១៤៤] វិនិច្ឆ័យក្នុងវារៈដែលពន្យល់ពាក្យសួរថា គឺ និទានោ : មានអ្វីជាគ្រឿងប្រគល់ឱ្យនូវផល គប្បីជ្រាបដូច្នេះ ៖

សម្មុខាវិន័យ ឈ្មោះថា មាននិទានជានិទាន ព្រោះអត្ថថា មាននិទានជាហេតុប្រគល់ឱ្យ ។

ក្នុងនិទានទាំងនោះ គឺ ការចំពោះមុខសង្ឃ ការចំពោះមុខធម៌ ការចំពោះមុខវិន័យ ការចំពោះមុខបុគ្គល ជានិទាននៃសម្មុខាវិន័យ ។ ព្រះខីណាស្រព អ្នកបរិបូណ៌ដោយសតិដែលបានត្រូវចោទ ជានិទាននៃសតិវិន័យ ។

ភិក្ខុឆ្កួត ជានិទាននៃអមូឡ្ហវិន័យ ។

សេចក្តីចំពោះមុខនៃបុគ្គលទាំង ២ គឺ អ្នកសម្តែង និងអ្នកជាទីសម្តែងជានិទាននៃបដិញ្ញាតករណៈ ។

ការដែលសង្ឃមិនអាចនឹងរម្ងាប់អធិករណ៍របស់ភិក្ខុទាំងឡាយដែលទាស់ទែងគ្នា ជានិទាននៃយេភុយ្យសិកា ។

បុគ្គលមានបាបក្រាស់ ជានិទាននៃតស្សបាបិយសិកា ។

អជ្ឈាចារមិនសមគួរដល់សមណៈច្រើន របស់ភិក្ខុទាំងឡាយអ្នកទាស់ទែងគ្នា ជានិទាននៃតិណវត្ថារកៈ ។ វារៈពោលដោយហេតុនិងបច្ច័យ មានន័យដូចពោលហើយនុ៎ះឯង ។

# សមុដ្ឋាននៃសមថៈ

[១៤៥] សេចក្ដីពន្យល់របស់ពាក្យសួរដល់មូល ងាយយល់ទាំងអស់ ។

ក្នុងពាក្យបុច្ឆាអំពីសមុដ្ឋាន ដែលលោកពោលថា សមថៈទាំង ៧ មានសមុដ្ឋាន ៣៦ នោះ តើដូចម្ដេច ? ដូច្នេះ ក៏ពិតមែនហើយ, តែថាបានជាលោកចែកតែសមថៈ ៦ ក្នុងសមថៈមួយ ៗ មានសមុដ្ឋានប្រាំមួយ ៗ ដូច្នេះវិញ ព្រោះសម្មុខាវិន័យមិនមានសមុដ្ឋានទេ ព្រោះមិនមានកម្មសង្គ្រោះ ។

បណ្ដាបទទាំងនោះ ញត្តិគប្បីជ្រាបថា **កម្មកិរិយា** : ការធ្វើញត្តិ ។

ការឈប់ក្នុងវេលាគួរឈប់ ដោយញត្តិនុ៎ះឯង គប្បីជ្រាបថា **ករណ** : ការបញ្ឈប់ញត្តិ ។

ការចូលទៅខ្លួនឯង អធិប្បាយថា ការធ្វើកម្មនោះដោយខ្លួនឯង គប្បីជ្រាបថា **ឧបគមន** : ការចូលទៅធ្វើដោយខ្លួនឯង ។

ការដែលចូលដល់ការអាពធនា អធិប្បាយថា ការអាពធនាអ្នកដទៃ មានសទ្ធិវិហារិកជាដើមថា "លោកចូរធ្វើកម្មនេះ" គប្បីជ្រាបថា **អជ្ឈុបគមន** : ការបង្គាប់ឱ្យគេចូលទៅ ។

កិរិយាដែលយល់ព្រម អធិប្បាយថា បានដល់ ការប្រគល់ឆន្ទៈ

យ៉ាងនេះថា សង្ឃចូរធ្វើកម្មនោះជំនួសខ្ញុំ ហៅថា អធិវាសនា : ការទទួលបន្ទាប់ ។

កិរិយាដែលមិនជំទាស់ថា "កម្មនោះ មិនពេញចិត្តខ្ញុំ, ពួកលោកកុំធ្វើយ៉ាងនោះ" ហៅថា អប្បដិកោសនា : ការមិនហាមឃាត់ ។

គប្បីជ្រាបសមុដ្ឋាន ៣៦ ដោយអំណាចពួកប្រាំមួយ ៦ ពួក ដោយប្រការដូច្នេះ ។

ពាក្យឆ្លើយរបស់ពាក្យសួរដល់អត្ថផ្សេងគ្នា ងាយយល់ទាំងអស់ ។

[១៤៧] វិនិច្ឆ័យក្នុងចម្លើយរបស់ពាក្យសួរដល់អធិករណ៍ គប្បីជ្រាបដូច្នេះ ៖

ត្រើនបទថា អយំ វិវាទោ នោ អធិករណំ : វិវាទនេះ មិនចាត់ជាអធិករណ៍ទេ មានសេចក្តីថា ការប្រកែកគ្នានៃជនទាំងឡាយ មានមាតា និងបុត្រជាដើម ចាត់ជាវិវាទ ព្រោះជាការពោលទាស់គ្នា, តែមិនចាត់ជាអធិករណ៍ ព្រោះមិនមានហេតុដែលត្រូវរម្ងាប់ដោយសមថៈទាំងឡាយ ។ សូម្បីក្នុងអនុវាទជាដើម ក៏ន័យនេះឯង ។

ពាក្យដ៏សេសក្នុងទីទាំងពួង ងាយយល់ទាំងអស់ ដូច្នេះឯង ។

**ពណ៌នាអធិករណភេទ ចប់**

# ពណ៌នាគាថាសង្គណិកៈ ជាតំណមក

[១៥២] វិនិច្ឆ័យក្នុងទុតិយគាថាសង្គណិកៈ គប្បីជ្រាបដូច្នេះ ៖

វាចាដែលសម្តែងការដេញដោលសួរវត្ថុនិងអាបត្តិ ឈ្មោះថា ចោទនា ។

វាចាដែលដាស់តឿនឱ្យនឹកដល់ទោស ឈ្មោះថា សារណា ។

ពីរបទថា សង្ឃោ កិមត្ថាយ : ប្រជុំសង្ឃដើម្បីប្រយោជន៍ មានសេចក្តីថា ប្រជុំសង្ឃដើម្បីប្រយោជន៍អ្វី ?

បាទគាថាថា មតិកម្មំ បន កិស្ស ការណា : ម្យ៉ាងទៀត មតិកម្ម គឺការរៀនមន្ត ដើម្បីហេតុអ្វី មានសេចក្តីថា សេចក្តីយល់ សេចក្តីប្រាថ្នា ត្រាស់ថា មតិកម្ម មតិកម្មនោះ ត្រាស់ទុកព្រោះហេតុនៃអ្វី ?

បាទគាថាថា ចោទនា សារណត្ថាយ : ចោទដើម្បីរំលឹកទោស មានសេចក្តីថា វាចាសម្រាប់ដេញដោលសួរ ដូចពោលហើយ ដើម្បីប្រយោជន៍ដល់ការដាស់តឿន ឱ្យនឹកដល់ទោសដែលបុគ្គលជាប់ចោទនោះ បានធ្វើហើយ ។

បាទគាថាថា និគ្គហត្ថាយ សារណា : ការរំលឹកដើម្បីនឹងសង្កត់សង្កិន (បុគ្គលនោះឱ្យរាងចាល) មានសេចក្តីថា ចំណែកវាចា

សម្រាប់ដាស់តឿនឱ្យនឹកដល់ទោស ដើម្បីប្រយោជន៍ដល់ការគ្របសង្កត់បុគ្គលនោះ ។

បាទគាថាថា សង្ឃោ បរិគ្គហត្ថាយ : ប្រជុំសង្ឃដើម្បីពិនិត្យរកនូវការវិនិច្ឆ័យ មានសេចក្ដីថា សង្ឃដែលប្រជុំគ្នាក្នុងទីនោះ ដើម្បីប្រយោជន៍ក្នុងការជួយគ្នាវិនិច្ឆ័យ, អធិប្បាយថា ដើម្បីប្រយោជន៍នៃការពិចារណាថា ជាធម៌ ឬ មិនជាធម៌ គឺ ដើម្បីប្រយោជន៍ឱ្យបានជ្រាបថាអធិករណ៍នោះ បានវិនិច្ឆ័យត្រឹមត្រូវ ឬមិនត្រឹមត្រូវ ។

បាទគាថាថា មតិកម្មំ បន ធារណត្ថាយ : ឯមតិកម្ម គឺការរៀនមន្តផ្សេង ៗគ្នា (ដើម្បីចូលចិត្តនូវការកាត់សេចក្ដី) មានសេចក្ដីថា ការយល់បំណងប្រាថ្នារបស់ព្រះថេរៈផ្នែកខាងព្រះសូត្រ និងព្រះថេរៈផ្នែកខាងវិន័យទាំងឡាយ ក៏ដើម្បីឱ្យវិនិច្ឆ័យសម្រេចជាផ្នែក ៗ ។

ច្រើនបទថា មា ខោ បដិឃំ : កុំធ្វើសេចក្ដីថ្នាំងថ្នាក់ចិត្ត មានសេចក្ដីថា កុំមានសេចក្ដីក្រោធក្នុងអ្នកជាប់ចោទ ឬអ្នកចោទ ។

ច្រើនបទថា សចេ អនុវិជ្ជកោ តុវំ : បើលោកធ្វើជាវិនយធរ មានសេចក្ដីថា បើថា លោកជាព្រះវិន័យធរអន្ទ្គយវិនិច្ឆ័យអធិករណ៍ដែលចូលទៅកាន់កណ្ដាលជំនុំសង្ឃ ។

បទថា វិគ្គាហិកំ : ដោយរួសរាន់ មានសេចក្ដីថា (លោកកុំ

ពោលពាក្យនាំឱ្យវិវាទ) ដែលប្រព្រឹត្តទៅដោយន័យជាដើមថា "អ្នកមិនមែនចេះដឹងធម៌និងវិន័យនេះទេ"[១] ។

បទថា អនត្ថសញ្ហិតំ : សង្កត់សង្កិនឥតប្រយោជន៍ មានសេចក្ដីថា កុំពោលពាក្យដែលបង្កឱ្យកើតសេចក្ដីសាបសូន្យចេញ គឺ ធ្វើបរិស័ទឱ្យរំជើបរំជួល រាលដាលឡើង ។

វិនិច្ឆ័យក្នុងបទថា សុត្តេ វិនយេ : ក្នុងសូត្រ ក្នុងវិន័យ ជាដើម គប្បីជ្រាបដូច្នេះ ៖

ឧភតោវិភង្គ ឈ្មោះថា សូត្រ, ខន្ធកៈ ឈ្មោះថា វិន័យ, បរិវារៈ ឈ្មោះថា អនុលោម, វិន័យបិដកទាំងអស់ ឈ្មោះថា បញ្ញត្តិ, មហាបទេស ៤ ឈ្មោះថា អនុលោមិកៈ ។

បាទគាថាថា អនុយោគវត្តំ និសាមេថ : ត្រូវលោកពិចារណានូវវត្តដែលគួរប្រព្រឹត្តតាម មានសេចក្ដីថា លោកចូរពិចារណាវត្តក្នុងការសាកសួរ ។

បាទគាថាថា កុសលេន ពុទ្ធិមតា កតំ : ដែលព្រះសម្ពុទ្ធជាអ្នកប្រាជ្ញឥតឆ្មៀវឆ្លាស ទ្រង់ធ្វើ គឺបាននាំមកតម្កល់ទុក មានសេចក្ដីថា ដែលព្រះមានព្រះភាគទ្រង់វាងវៃ ទ្រង់ជាបណ្ឌិត ដល់សេចក្ដីសម្រេចនៃ

---

១ ទីឃ. សីល. ព្រហ្មជាលសូត្រ. ១. ១៦/១៩ ។

ព្រះញាណបារមី ទ្រង់នាំចេញតាំងទុក ។

បទថា សុវុត្តំ : ទ្រង់ពោលទុកមកដោយល្អ មានសេចក្ដីថា ដែលព្រះអង្គទ្រង់តែងតាំងទុកល្អហើយ ។

បទថា សិក្ខាបទានុលោមិកំ : ជាអនុលោមរបស់សិក្ខាបទ មានសេចក្ដីថា សមគួរដល់សិក្ខាបទទាំងឡាយ, សេចក្ដីពន្យល់ចំពោះបទត្រឹមតែប៉ុណ្ណេះ ។

ចំណែកសេចក្ដីពណ៌នាដោយសង្ខេប ព្រមទាំងសេចក្ដីអធិប្បាយក្នុងគាថានេះ ដូច្នេះ ៖

បើថា លោកជាអ្នកពោលអត្តក្ដី កុំពោលប្រញិបប្រញាប់ កុំពោលពាក្យនាំឱ្យវិវាទ មិនប្រកបដោយប្រយោជន៍, ក៏វត្តក្នុងការសាកសួរយ៉ាងណា ដែលព្រះលោកនាថទ្រង់ឆ្លាត មានបញ្ញាទ្រង់ចាត់ទុក តែងតាំងទុកយ៉ាងល្អ ក្នុងសូត្រជាដើមទាំងនោះ អនុលោមដល់សិក្ខាបទទាំងពួង, លោកចូរពិចារណា គឺ ចូរត្រួតមើលអនុយោគវត្តនោះ ។

បាទគាថាថា គតឹ ន ឆាសេន្តោ សម្បរាយិកំ : ហើយនឹងបានញុំាងគតិរបស់ខ្លួន ដែលប្រព្រឹត្តទៅក្នុងលោក មិនឱ្យវិនាសបាន មានសេចក្ដីថា ចូរពិចារណាអនុយោគវត្ត កុំឱ្យវិនាសគតិគឺ សេចក្ដីសម្រេចក្នុងសម្បរាយភពរបស់ខ្លួន, ពិតមែន ភិក្ខុណាមិនពិចារណា

អនុយោគវត្តនោះ សាកសួរ, ភិក្ខុនោះ រមែងឱ្យវិនាសគតិរបស់ខ្លួន ដែលជាសម្បរាយភព, ព្រោះហេតុនោះ ចូរពិចារណាកុំឱ្យខូចគតិនោះបាន ។

ឥឡូវនេះ ព្រះឧបាលីថេរៈពោលពាក្យថា ហិតេសី ជាដើម ដើម្បីសម្ដែងអនុយោគវត្តនោះ ។

បណ្ដាបទទាំងនោះ បទថា ហិតេសី : **លោកកាលស្វែងរកនូវប្រយោជន៍** បានដល់ អ្នកស្វែងគឺ អ្នកស្វែងរកប្រយោជន៍, អធិប្បាយថា ចូរចូលទៅតាំងមេត្រី និងធម៌ជាបុព្វភាគនៃមេត្រីទុក ។

បទថា កាលេ : **តាមកាលដ៏គួរ** បានដល់ ក្នុងកាលដែលចាត់ថា សមគួរ គឺ ក្នុងកាលដែលសង្ឃនិមន្តប៉ុណ្ណោះ, អធិប្បាយថា លោកចូរសាកសួរ ក្នុងកាលសង្ឃប្រគល់ភារៈដល់លោក ។

បាទគាថាថា សហសា វោហារំ មា បធារេសិ : **លោកកុំអាលជឿ សំដី ដោយរហ័សឡើយ** មានសេចក្ដីថា សំនួនដែលពោលដោយប្រញិបប្រញាប់ គឺ ពាក្យដែលពោលដោយប្រញាប់ប្រញាល់ណារបស់អ្នកចោទ និងអ្នកជាប់ចោទទាំងនោះ កុំឃាត់ គឺ កុំកាន់យកសំនួន ( ពាក្យ )នោះ ។

ការបន្តនៃពាក្យឆ្លើយ ហៅថា **អនុសន្ធិ** ក្នុងបាទគាថាថា

បដិញ្ញានុសន្ធិតេន ការយេ : គប្បីវិនិច្ឆ័យតាមដំណាពាក្យដែលប្តេជ្ញានេះ, ព្រោះហេតុនោះ គប្បីពិន័យ តាមពាក្យសារភាព( ប្តេជ្ញា ) និងការបន្តពាក្យកំណត់ អធិប្បាយថា គប្បីកំណត់ការបន្តនៃពាក្យជាចម្លើយហើយទើបពិន័យតាមពាក្យសារភាព ។

ម្យ៉ាងទៀត គប្បីពិន័យតាមពាក្យទទួលសារភាព និងតាមការបន្តនៃពាក្យកំណត់ អធិប្បាយថា គប្បីពិន័យតាមពាក្យទទួលសារភាពរបស់អ្នកជាប់ចោទដែលជាលជ្ជី គប្បីពិន័យតាមការបន្ត សមនៃការប្រព្រឹត្តរបស់អ្នកជាប់ចោទជាអលជ្ជី ។

ព្រោះហេតុនោះ លោកទើបពោលគាថាយ៉ាងនេះថា

បដិញ្ញា លជ្ជីសុ វុត្តា អលជ្ជីសុ ឯតំ ន វិជ្ជតិ
ពហុម្បិ អលជ្ជី ភាសេយ្យ វុត្តានុសន្ធិតេន ការយេ ។

ពាក្យប្តេជ្ញា( ណា ) ដែលវិន័យធរពោលចំពោះពួកបុគ្គលដែលមានសេចក្តីខ្មាស ពាក្យប្តេជ្ញានោះ មិនមានក្នុងពួកបុគ្គលដែលឥតសេចក្តីខ្មាសទេ ( ព្រោះថា ) បុគ្គលដែលឥតសេចក្តីខ្មាស សូម្បីពោលពាក្យច្រើនក្តី ( វិន័យធរ ) គប្បីវិនិច្ឆ័យតាមពាក្យប្តេជ្ញា ដែលជាប់មកជាមួយនឹងវត្តប្រតិបត្តិរបស់បុគ្គលនោះ ។

បណ្ដាបទទាំងនោះ ពីរបទថា វត្តានុសន្ធិតេន ការយេ : (វិន័យធរ) គប្បីវិនិច្ឆ័យតាមពាក្យប្ដេជ្ញា ដែលជាប់មកជាមួយនឹងវត្តប្រតិបត្តិរបស់បុគ្គលនោះ មានសេចក្ដីថា គប្បីពិន័យតាមការបន្តនៃការប្រព្រឹត្ត, អធិប្បាយថា ពាក្យទទួលសារភាពណា នឹងការប្រព្រឹត្តរបស់អលជ្ជីនោះ សមគ្នា, គប្បីពិន័យតាមពាក្យសារភាពនោះ ។

[១៥៣] បទថា សញ្ចិច្ច : មានចិត្តក្លែង បានដល់ ត្រូវទាំងដឹង ។

បទថា បរិគូហតិ : រួបបិទបាំង បានដល់ បិទទុក គឺ មិនសម្ដែងចេញ ។

[១៥៤] បាទគាថាថា សច្ចំ អហម្បិ ជានាមិ : ខ្ញុំដឹងពិត មានសេចក្ដីថា ពាក្យណាដែលព្រះអង្គត្រាស់ហើយ ពាក្យនោះជាពាក្យពិត, សូម្បីខ្ញុំព្រះអង្គក៏ដឹងពាក្យនោះ យ៉ាងនោះដូចគ្នា ។

ពីរបទថា អញ្ញញ្ច តាហំ : សួររកបុគ្គលដទៃទៀតនឹងអ្នក មានសេចក្ដីថា ក៏ឯខ្ញុំព្រះអង្គនឹងទូលសួរព្រះអង្គដល់អលជ្ជីប្រភេទដទៃ ។

[១៥៧] បាទគាថាថា បុព្វាបរំ ន ជានាតិ : បុគ្គលមិនដឹងពាក្យខាងដើម និងពាក្យខាងចុង មានសេចក្ដីថា មិនដឹងពាក្យដែលខ្លួនពោលទុកក្នុងកាលមុន និងខ្លួនពោលខាងក្រោយ ។

បទថា អកោវិទោ : មិនយល់ បានដល់ មិនឆ្លាតក្នុងពាក្យខាងដើមនិងពាក្យខាងចុងនោះ ។

បាទគាថាថា អនុសន្ធិវចនបថំ ន ជានាតិ : មិនដឹងគន្លងពាក្យតគ្នា មានសេចក្តីថា មិនដឹងពាក្យដែលបន្តនៃពាក្យចម្លើយរបស់សាក្សី និងពាក្យដែលបន្តនៃពាក្យកាត់ក្តី ។

[១៥៩] បាទគាថាថា សីលវិបត្តិយា ចោទេតិ : បុគ្គលចោទដោយសីលវិបត្តិក្តី គឺ ចោទដោយអាបត្តិ ២ កង ។

បទថា អាចារទិដ្ឋិយា : ចោទដោយអាចារវិបត្តិក្តី បានដល់ ចោទដោយអាចារវិបត្តិនិងទិដ្ឋិវិបត្តិ ។ កាលទឹងចោទដោយអាចារវិបត្តិ រមែងចោទដោយអាបត្តិ ៥ កង, កាលទឹងចោទដោយទិដ្ឋិវិបត្តិ រមែងចោទដោយមិច្ឆាទិដ្ឋិនិងអន្តគាហិកទិដ្ឋិ ។

បាទគាថាថា អាជីវេនបិ ចោទេតិ : ចោទដោយអាជីវវិបត្តិក្តី មានសេចក្តីថា ចោទដោយសិក្ខាបទ ៦ ដែលបញ្ញត្តិទុក ព្រោះអាជីវៈជាហេតុ ។

បទដ៏សេសដែលក្នុងទីទាំងពួង ងាយយល់ទាំងអស់ ដូច្នេះឯង ។

**ពណ៌នាគាថាសង្គណិកៈ ជាតំណាមក ចប់**

# ពណ្ណនាចោទនាកណ្ឌ

## កិច្ចរបស់ភិក្ខុដែលពោលអត្ថក្តី

[១៦០] ឥឡូវនេះ ព្រះឧបាលីថេរៈផ្តើមពាក្យថា អនុវិជ្ជកេន ចោទកោ បុច្ឆិតព្វោ : វិន័យធរត្រូវសួរភិក្ខុជាអ្នកចោទ ជាដើម ដើម្បីសម្តែងកិច្ចដែលព្រះវិន័យធរគប្បីធ្វើក្នុងពាក្យចោទដែលកើតឡើងហើយយ៉ាងនោះ ។

[១៦១] ក្នុងពាក្យនោះ គាថាថា ទិដ្ឋំ ទិដ្ឋេន : បានឃើញសមតាមហេតុដែលឃើញមែន ជាដើមមានសេចក្តីដូច្នេះ ៖

ភិក្ខុមួយរូប កំពុងចេញឬកំពុងចូលទៅ កាន់ស្ថានទីជាមួយគ្នានឹងមាតុគ្រាមម្នាក់ ដែលអ្នកចោទឃើញហើយ ។ អ្នកចោទនោះ ទើបចោទភិក្ខុនោះដោយអាបត្តិបារាជិក; ចំណែកភិក្ខុអ្នកជាប់ចោទព្រមទទួលការឃើញរបស់អ្នកចោទនោះ តែភិក្ខុអ្នកជាប់ចោទមិនទាន់ដល់បារាជិក ទើបមិនប្តេជ្ញា ព្រោះអាស្រ័យការឃើញនោះ ។ ក្នុងពាក្យរបស់អ្នកចោទ និងអ្នកជាប់ចោទនេះ ការណាដែលអ្នកចោទនោះឃើញហើយ ការនោះសមដោយពាក្យដែលបានឃើញរបស់អ្នកចោទនោះ យ៉ាងនេះថា "អ្នកជាប់ចោទដែលខ្ញុំបានឃើញហើយ" ដោយប្រការដូច្នេះ ។ តែព្រោះហេតុដែលផ្អែកខាងអ្នកជាប់ចោទ មិនព្រមប្តេជ្ញាទោស ដោយអាស្រ័យការ

ឃើញនោះ ទើបឈ្មោះថា អ្នកចោទមានសេចក្តីវង្វៀស មិនបរិសុទ្ធិ អធិប្បាយថា ជាអ្នកវង្វៀសដោយមិនមានមូល ។ សង្ឃគប្បីធ្វើឱបោស ថនឹងបុគ្គលនោះ តាមបដិញ្ញាដែលភិក្ខុនោះ ពោលថា "ខ្ញុំជាអ្នកបរិសុទ្ធិ" ។ ក្នុងពីរគាថាដ៏សេសមានន័យយ៉ាងនេះឯង ។

ពាក្យដ៏សេសក្នុងទីទាំងពួង ងាយយល់ទាំងអស់ ដូច្នេះឯង ។

ពណ៌នាកិច្ចរបស់ភិក្ខុដែលពោលអត្តក្តី ចប់

## ខាងដើមរបស់ចោទនាជាដើម

[១៦៣] វិនិច្ឆ័យក្នុងបុច្ឆាវិសជ្ជនាមានជាដើមថា អ្វីជាខាងដើមរបស់ ចោទនា គប្បីជ្រាបដូច្នេះ ៖

ប្រើនបទថា សច្ចេ ច អកុប្បេ ច ៖ ក្នុងសច្ចវាចា ១ ក្នុងសេចក្តីមិនក្រោធ ១ មានសេចក្តីថា អ្នកជាប់ចោទគប្បីតាំងនៅក្នុងធម៌ ២ ប្រការ គឺ ឆ្លើយតាមពិត ១ មិនខឹងក្រោធចំពោះអ្នកចោទ ១ គឺថា អំពើណាដែលខ្លួនធ្វើ ឬមិនបានធ្វើ អំពើនោះឯង ដែលខ្លួនគប្បីឆ្លើយ (ដូច្នោះ) ។ និងមិនគប្បីឱ្យកើតសេចក្តីល្អក់កករខឹងក្នុងអ្នកចោទ ឬក្នុងភិក្ខុ ដែលពោលអត្តកាត់ក្តី ឬក្នុងសង្ឃ ។

ពីរបទថា ឧត្តិណ្ណានោត្តិណ្ណំ ជានិតព្វំ : ដឹងពាក្យដែលទាក់ទងរកគ្នា និងដឹងពាក្យដែលមិនទាក់ទងរកគ្នា មានសេចក្តីថា សង្ឃគប្បីដឹងពាក្យដែលចូលលក្ខន្តិក:( ស៊ប់ហើយ ) និងមិនចូលលក្ខន្តិក: ។ ក្នុងពាក្យនោះ មានវិធីសម្រាប់ដឹងដូច្នេះ ៖

សង្ឃគប្បីដឹងថា ពាក្យខាងដើមរបស់អ្នកចោទប៉ុណ្ណេះ ពាក្យខាងចុងប៉ុណ្ណេះ ពាក្យខាងដើមរបស់អ្នកជាប់ចោទប៉ុណ្ណេះ ពាក្យខាងចុងប៉ុណ្ណេះ ។

គប្បីកំណត់លក្ខណ: ដែលគួរជឿរបស់អ្នកចោទ គប្បីកំណត់លក្ខណ:ដែលគួរជឿកាន់របស់អ្នកជាប់ចោទ គប្បីកំណត់លក្ខណ: ដែលគួរជឿរបស់ភិក្ខុដែលពោលអត្តក្តី ។ ភិក្ខុអ្នកពោលអត្តក្តី កាលញុំាងការពិចារណា ឱ្យខ្វះខាត សូម្បីមានប្រមាណតិច ដែលសង្ឃគប្បីបង្គាប់ថា អ្នកមានអាយុ លោកចូរពិចារណាឱ្យល្អបង្គាប់ក្តីឱ្យត្រង់ ។ សង្ឃគប្បីបដិបត្តិយ៉ាងនេះ ។

វិនិច្ឆ័យក្នុងពាក្យថា យេន ធម្មេន យេន វិនយេន យេន សត្ថុសាសនេន អធិករណំ វូបសម្មតិ : អធិករណ៍នោះតែងរម្ងាប់បានដោយធម៌ណា ដោយវិន័យណា ដោយពាក្យប្រៀនប្រដៅរបស់ព្រះសាស្តាណា នេះ គប្បីជ្រាបដូច្នេះ ៖

ពាក្យថា ធម៌ បានដល់ រឿងដែលពិត ។

ពាក្យថា វិន័យ បានដល់ កិរិយាដែលអ្នកចោទ និងកិរិយាដែលអ្នកជាប់ចោទឆ្លើយ ។

បទថា សត្ថុសាសនំ បានដល់ ញត្តិសម្បទានិងអនុស្សាវនសម្បទា ។

ពិតមែន អធិករណ៍ រមែងរម្ងាប់ដោយធម៌ ដោយវិន័យ និងដោយសត្ថុសាសនានោះ ព្រោះដូច្នោះ ភិក្ខុអ្នកត្រូតពិនិត្យក្តី គប្បីចោទដោយវត្ថុដែលពិត ហើយឱ្យអ្នកជាប់ចោទរលឹកដល់អាបត្តិ និងញ៉ាំងអធិករណ៍នោះ ឱ្យរម្ងាប់ដោយញត្តិសម្បទា និងអនុស្សាវនសម្បទា ។ ភិក្ខុអ្នកត្រូតពិនិត្យក្តី គប្បីបដិបត្តិយ៉ាងនេះ ។

ពាក្យដ៏សេសក្នុងទីទាំងពួង ងាយយល់ទាំងអស់ ដូច្នេះឯង ។

[១៦៤] សូម្បីបុច្ឆាវិសជ្ជនាមានជាដើមថា ឧបោសថ ដើម្បីប្រយោជន៍អ្វី ? ក៏ងាយយល់ដូចគ្នានោះឯង ។

វិនិច្ឆ័យក្នុងអវសានគាថាទាំងឡាយ គប្បីជ្រាបដូច្នេះ ៖

បាទគាថាថា ថេរេ ច បរិភាសតិ : បុគ្គលណាមើលងាយពួកភិក្ខុជាថេរៈ មានសេចក្តីថា កាលនឹងធ្វើសេចក្តីមើលងាយ រមែងពោលថា ភិក្ខុទាំងនេះមិនដឹងអ្វី ។

បាទគាថាថា **ខតោ ឧបហតិន្ទ្រិយោ** : ជាអ្នកបៀតបៀនខ្លួនឯង ផ្តាច់បង់ឥន្ទ្រិយ មានសេចក្តីថា ឈ្មោះថា ជាអ្នកបៀតបៀនខ្លួនឯង ព្រោះសេចក្តីដែលខ្លួនជាសភាពដែលខ្លួនឯងជីកហើយ ដោយជាអ្នកដល់សេចក្តីលំអៀងដោយឆន្ទាគតិជាដើមនោះ និងដោយការជេរនោះ និងឈ្មោះថា **អ្នកផ្តាច់បង់ឥន្ទ្រិយខ្លួនឯង** ព្រោះឥន្ទ្រិយមានសទ្ធាជាដើម ជាគុណដែលខ្លួនឯងកម្ចាត់ចេញហើយ ។

ពីរបាទគាថាថា **និរយំ គច្ឆតិ ទុម្មេធោ ន ច សិក្ខាយ គារវោ** : ជាអ្នកឥតប្រាជ្ញា មិនមានសេចក្តីគោរពក្នុងសិក្ខា លុះទម្លាយកាយទៅ តែងទៅកាន់នរក មានសេចក្តីថា អ្នកមានខ្លួនដែលគាស់រំលើងហើយ មានឥន្ទ្រិយ ដែលខ្លួនកម្ចាត់ហើយនោះ ឈ្មោះថា អ្នកឥតប្រាជ្ញា ព្រោះមិនមានបញ្ញា និង ឈ្មោះថា មិនមានសេចក្តីគោរពក្នុងការសិក្សា ព្រោះមិនសិក្សាក្នុងសិក្ខា ៣ ព្រោះបែកធ្លាយនៃកាយ រមែងចូលដល់នរក ។

ព្រោះហេតុនោះ ទើបលោកពោលថា មិនគួរអាស្រ័យអាមិស (និងមិនគួរអាស្រ័យបុគ្គល គប្បីវៀរចំណែកទាំង ២ នោះ ចេញ) ធ្វើតាមធម៌ ។

សេចក្តីនៃពាក្យនោះថា មិនគប្បីធ្វើ ព្រោះអាស្រ័យអាមិស ពិត

មែន កាលកាន់យកអាមិសមានចីវរជាដើម ដែលអ្នកចោទ ឬអ្នកជាប់ចោទចំណែកណាមួយឱ្យ ឈ្មោះថា ធ្វើ ព្រោះតែអាស្រ័យអាមិស មិនគប្បីធ្វើយ៉ាងនោះ ។

ត្រើនបទថា ន ច និស្សាយ បុគ្គលំ : កុំអាស្រ័យបុគ្គល មានសេចក្តីថា កាលលំអៀង ព្រោះសេចក្តីស្រឡាញ់ជាដើម ដោយន័យមានជាដើមថា អ្នកនេះ ជាឧបជ្ឈាយ៍របស់យើង ឬថា អ្នកនេះជាអាចារ្យរបស់យើង ឈ្មោះថា ធ្វើព្រោះអាស្រ័យបុគ្គល មិនគប្បីធ្វើយ៉ាងនោះ ។ មកដែលត្រូវ គប្បីវៀរចំណែកទាំង ២ នោះចេញ ធ្វើតាមធម៌ប៉ុណ្ណោះ ។

បាទគាថាថា ឧបកណ្ណកំ ជប្បេតិ : ភិក្ខុខ្សឹបខ្សៀបត្រចៀក មានសេចក្តីថា ខ្សឹបទីជិតត្រចៀកថា លោកចូរនិយាយយ៉ាងនេះ កុំនិយាយយ៉ាងនេះ ។

ពីរបទថា ជិម្ហំ បេក្ខតិ : ស្វែងរកតែទោស មានសេចក្តីថា រមែងគន់រកទោសប៉ុណ្ណោះ ។

បទថា វីតិហរតិ : ធ្វើការវិនិច្ឆ័យឱ្យសាបសូន្យ បានដល់ញ៉ាំងការវិនិច្ឆ័យឱ្យបាត់បង់ ។

ពីរបទថា កុម្មគ្គំ បដិសេវតិ : សេពគប់តែមកដែលខុស

មានសេចក្ដីថា រមែងប្រាប់អាបត្តិ ។

ពីរបទថា អកាលេន ច ចោទេតិ : បុគ្គលអ្នកចោទដោយមិនត្រូវតាមកាល មានសេចក្ដីថា អ្នកដែលព្រះថេរៈមិនបានអារាធនា ចោទក្នុងសម័យមិនមែនឱកាស ។

បាទគាថាថា បុព្វាបរំ ន ជានាតិ : បុគ្គលមិនដឹងពាក្យខាងដើម និងពាក្យខាងចុង មានសេចក្ដីថា មិនដឹងពាក្យដើមផង មិនដឹងពាក្យចុងផង ។

បាទគាថាថា អនុសន្ធិវចនកថំ ន ជានាតិ : បុគ្គលមិនដឹងគន្លងនៃពាក្យតគ្នា មានសេចក្ដីថា មិនដឹងពាក្យសំដី ដោយអំណាចការបន្តសមគ្នានៃពាក្យចម្លើយរបស់សាក្សី និងការបន្តសមគ្នានៃពាក្យវិនិច្ឆ័យ ។

ពាក្យដ៏សេសក្នុងទីទាំងពួង ងាយយល់ទាំងអស់ ដូច្នេះឯង ។

**ចោទនាកណ្ឌកវណ្ណនា ចប់**

បរិវារៈ ចោទនាកណ្ឌ

# ពណ៌នាចូលសង្គ្រាម

[១៦៦] វិនិច្ឆ័យក្នុងចូលសង្គ្រាម គប្បីជ្រាបដូច្នេះ ៖

ប្រជុំសង្ឃ ដើម្បីប្រយោជន៍ដល់ការវិនិច្ឆ័យនូវអធិករណ៍ ហៅថា សង្គ្រាម ក្នុងពាក្យថា ភិក្ខុដែលចូលសង្គ្រាម ។ ពិតមែន ភិក្ខុទាំងឡាយ ដែលជាសត្រូវដល់ខ្លួន និងជាសត្រូវចំពោះព្រះសាសនា រមែងប្រជុំគ្នា សម្តែងសត្ថុសាសនា ក្រៅធម៌ក្រៅវិន័យ ក្នុងទីប្រជុំសង្ឃនោះ ដូចយ៉ាងភិក្ខុវជ្ជីបុត្រអ្នកក្រុងវេសាលីដូច្នោះ ។

ភិក្ខុណា ញុំាំញីលទ្ធិរបស់ភិក្ខុដែលជាសត្រូវទាំងនោះចេញ ចូលក្នុងទីប្រជុំសង្ឃនោះ ដើម្បីប្រយោជន៍ដល់ការសម្តែងវាទៈរបស់ខ្លួន ជាក់អំណាចញុំាំងការវិនិច្ឆ័យឱ្យប្រព្រឹត្តទៅ, អ្នកនោះ ឈ្មោះថា អ្នកចូលសង្គ្រាម ដូចជាព្រះយសត្ថេរដូច្នោះ ។ ភិក្ខុដែលចូលសង្គ្រាមនោះ កាលចូលរកសង្ឃ គប្បីជាអ្នកមានចិត្តកោតក្រែងចូលរកសង្ឃ ។

បទថា **នីចចិត្តេន : គប្បីបន្ទាបបន្ទន់ចិត្ត** បានដល់ អ្នកដកទង់ គឺ មានះចេញ មានចិត្តដែលបានកម្ចាត់មានះចេញហើយ ។

បទថា **រជោហរណសមេន : ស្មើដោយកំណាត់សំពត់សម្រាប់ជូតនូវធូលី** បានដល់ មានចិត្តស្មើដោយសំពត់ជូតជើង, អធិប្បាយថា កាលជើងប្រឡាក់ឬមិនប្រឡាក់ដែលបុគ្គលជូតហើយ សេចក្តីត្រេកអរ

សេចក្តីប្រទូសរ៉ាយ រមែងមិនមានដល់សំពត់ជូតជើង យ៉ាងណា, គប្បីជាអ្នកមានចិត្តមិនត្រេកអរ មិនប្រទូសរ៉ាយក្នុងឥដ្ឋារម្មណ៍ និងអនិដ្ឋារម្មណ៍ យ៉ាងនោះ ។

ពីរបទថា យថាបដិរូបេ អាសនេ : **លើអាសនៈតាមសមគួរ** មានសេចក្តីថា គប្បីដឹងអាសនៈតាមដែលសមគួរអង្គុយ ក្នុងទីដែលត្រូវដល់ខ្លួន មិនត្រឡប់ក្រោយឱ្យភិក្ខុទាំងឡាយដែលជាថេរៈ ។

បទថា អនានាកថិកេន : **មិនពោលពាក្យឥតប្រយោជន៍ផ្សេង ៗ** បានដល់ មិនពោលពាក្យដែលមិនមានប្រយោជន៍នោះ ៗ ដែលមានប្រការផ្សេង ៗ ។

បទថា អតិរច្ឆានកថិកេន : **កុំពោលពាក្យតិរច្ឆានកថា** បានដល់ មិនពោលតិរច្ឆានកថា មានរឿងព្រះរាជាជាដើម ដែលបានឃើញក្តី បានស្តាប់ក្តី បានជ្រាបក្តី ។

ច្រើនបទថា សាមំ វា ធម្មោ ភាសិតព្វោ : **គប្បីសម្តែងធម៌ដោយខ្លួនឯងផង** មានសេចក្តីថា ពាក្យដែលអាស្រ័យរឿង ដែលគួរនិងមិនគួរ ឬដែលអាស្រ័យរូបារូបបរិច្ឆេទ និងលំដាប់នៃសមថៈ លំដាប់នៃវិបស្សនា វត្តក្នុងការឈរ និងអង្គុយជាដើមក្នុងទីប្រជុំសង្ឃ ឈ្មោះថាធម៌ ។ ធម៌បែបនេះ គប្បីពោលខ្លួនឯងក៏បាន អារាធនាភិក្ខុដទៃពោលក៏បាន ។ ភិក្ខុណា អាចពោលពាក្យបែបនោះ ភិក្ខុនោះ ដែលខ្លួនគប្បី

អាភធនាថា អ្នកមានអាយុ បញ្ហាកើតឡើងហើយនៅកណ្ដាលជំនុំសង្ឃ លោកគប្បីពោល ។

ច្រើនបទថា អរិយោ វា តុណ្ហីភាវោ ឆាតិមញ្ញិតព្វោ : កុំមើលងាយព្រះអរិយៈ ដែលមានសភាពជាអ្នកស្ងប់ស្ងៀមផង មានសេចក្ដីថា ព្រះអរិយៈទាំងឡាយកលអន្ទួយស្ងៀម មិនបានអន្ទួយដូចជាពាលបុថុជ្ជនទេ រមែងកាន់យកកម្មដ្ឋានយ៉ាងណាមួយអន្ទួយ, ព្រះអរិយៈដែលមានភាពស្ងៀមជាប្រក្រតី ដោយអំណាចធ្វើកម្មដ្ឋានទុកក្នុងចិត្តយ៉ាងនេះ ឈ្មោះថា មានភាពស្ងៀមជាប្រក្រតី ។ ព្រះអរិយៈនោះ ដែលភិក្ខុចូលសង្គ្រាម មិនគប្បីមើលងាយថា មានប្រយោជន៍អ្វីដោយការព្យាយាមក្នុងកម្មដ្ឋាន, អធិប្បាយថា ខ្លួនគប្បីកាន់យកកម្មដ្ឋានដែលសមគួរដល់ខ្លួនអន្ទួយ ។

ពីរបទថា ន ឧបជ្ឈាយោ បុច្ឆិតព្វោ : មិនត្រូវសួររកឧបជ្ឈាយ៍ មានសេចក្ដីថា មិនគួរសួរថា ឧបជ្ឈាយ៍របស់លោកឈ្មោះអ្វី ? ។ ក្នុងបទទាំងពួងក៏ន័យនេះឯង ។

បទថា ន ជាតិ : មិនរកជាតិ មានសេចក្ដីថា មិនគួរសួរដល់ជាតិយ៉ាងនេះថា លោកជាជាតិក្សត្រិយ៍ឬ ? លោកជាជាតិព្រាហ្មណ៍ឬ ?

បទថា ន អាគមោ : មិនរកអាគម មានសេចក្ដីថា មិនគួរសួរដល់បរិយត្តិដែលរៀន យ៉ាងនេះថា លោកពោលទីឃនិកាយឬ ? លោក

ពោលមជ្ឈិមនិកាយឬ ?

ត្រកូល និងប្រទេស គប្បីជ្រាបដោយអំណាចត្រកូលក្សត្រិយ៍ជាដើម ។

ច្រើនបទថា អត្រស្ស បេមំ វា ទោសោ វា : **សេចក្តីស្រឡាញ់ក្តី សេចក្តីស្អប់ក្តី នឹងមានដល់វិន័យធរនោះ** មានសេចក្តីថា សេចក្តីស្រឡាញ់ ឬសេចក្តីស្អប់ ក្នុងបុគ្គលនោះ គប្បីមានដោយអំណាចនៃហេតុទាំងនោះយ៉ាងណាមួយ ។

ពីរបទថា នោ បរិសកប្បិយេន : **មិនត្រូវបណ្តោតបណ្តោយតាមសេចក្តីគាប់ចិត្តបរិស័ទ** មានសេចក្តីថា មិនគប្បីជាអ្នកឃើញដល់បរិស័ទគឺ បណ្តោយតាមបរិស័ទ; អធិប្បាយថា វត្ថុណាពេញចិត្តបរិស័ទ វត្ថុនោះឯង មិនគប្បីតាំងចិត្ត គឺ ចិត្តប៉ងនឹងពោល ។

ពីរបទថា ន ហត្ថមុទ្ទា ទស្សេតព្វា : **កុំធ្វើវិការផ្សេង ៗដោយដៃ** មានសេចក្តីថា មិនគប្បីធ្វើវិការនៃដៃ ដើម្បីសម្គាល់ដឹងក្នុងន័យដែលគួរពោល និងមិនគួរពោល ។

ពីរបទថា អត្ថំ អនុវិធិយន្តេន : **ត្រូវពិចារណាសេចក្តីសិន** មានសេចក្តីថា គប្បីកំណត់ឱ្យដឹងរហូតអស់កាលវិនិច្ឆ័យប៉ុណ្ណោះ គឺគប្បីអង្គុយពិចារណាដោយល្អិតល្អន់យ៉ាងនេះថា សូត្រនេះអាចបាន

យើងនឹងពោលសូត្រនេះ ក្នុងវិនិច្ឆ័យនេះ ។

ប្រើនបទថា ន ច អាសនា វុដ្ឋាតព្វំ : កុំក្រោកចាកអាសនៈ មានសេចក្ដីថា មិនគប្បីក្រោកចាកទីអង្គុយត្រាច់ទៅក្នុងបរិវេណទីជំនុំ ។ ព្រោះថា កាលព្រះវិន័យធរក្រោក បរិស័ទទាំងពួង រមែងក្រោក ។

បទថា ន វីតិហាតព្វំ : កុំធ្វើការវិនិច្ឆ័យឱ្យសាបសូន្យ មានសេចក្ដីថា មិនគប្បីឱ្យវិនិច្ឆ័យសាបសូន្យ ។

ពីរបទថា ន កុម្មគ្គោ សេវិតព្វោ : កុំសេពគប់មកខុស មានសេចក្ដីថា មិនគប្បីចង្អុលបង្ហាញអាបត្តិ ។

ពីរបទថា អសាហសិកេន ភវិតព្វំ : កុំនិយាយរហ័សរហួន មានសេចក្ដីថា មិនគប្បីជាអ្នកធ្វើដោយប្រញិបប្រញាប់, អធិប្បាយថា មិនគប្បីពោលពាក្យឱ្យខុសភ្លាត់ដោយសេចក្ដីប្រញិបប្រញាប់ ។

បទថា វចនក្ខមេន : ត្រូវចេះអត់ធ្មត់ មានសេចក្ដីថា គប្បីជាអ្នកមានប្រក្រតីអត់ធន់បាននូវពាក្យដែលគ្រោតគ្រាត ។

បទថា ហិតបរិសក្កិនា : ស្វែងរកនូវប្រយោជន៍ មានសេចក្ដីថា គប្បីជាអ្នកស្វែងរកប្រយោជន៍ គឺខ្វល់ខ្វាយដើម្បីប្រយោជន៍ ។ ក្នុងបទទាំង ២ មានអធិប្បាយដូច្នេះថា ករុណាជាចំណែកខាងដើមនៃករុណា ដែលភិក្ខុចូលសង្គ្រាម គប្បីឱ្យចូលទៅតាំងទុក ។

បទថា អនសុរុត្តេន : កុំពោលពាក្យអសុរស បានដល់ មិនគប្បីជាអ្នកពោលពាក្យគ្រោតគ្រាត, អធិប្បាយថា ពាក្យដែលមិនល្អពោលគឺ ពាក្យនាំឱ្យវិវាទ ហៅថា ពាក្យដែលគ្រោតគ្រាត, ពាក្យគ្រោតគ្រាតនោះ ដែលភិក្ខុចូលសង្គ្រាមមិនគួរពោល ។

ពីរបទថា អត្តា បរិគ្គហេតព្វោ : ត្រូវសង្កេតមើលខ្លួន មានសេចក្ដីថា គប្បីត្រួតមើលខ្លួនយ៉ាងនេះថា យើងអាចនឹងវិនិច្ឆ័យ គឺរម្ងាប់អធិករណ៍ឬទេហ្ន៎ ? អធិប្បាយថា គប្បីដឹងប្រមាណខ្លួន ។

ពីរបទថា បរោ បរិគ្គហេតព្វោ : ត្រូវសង្កេតមើលអ្នកដទៃ មានសេចក្ដីថា គប្បីត្រួតមើលអ្នកដទៃយ៉ាងនេះថា បរិស័ទនេះ ជាលជ្ជីឬហ្ន៎ ? ដែលយើងអាចនឹងឱ្យយល់ព្រមឬទេ ?

ពីរបទថា ចោទកោ បរិគ្គហេតព្វោ : ត្រូវសង្កេតមើលអ្នកចោទ មានសេចក្ដីថា គប្បីត្រួតមើលអ្នកចោទយ៉ាងនេះថា អ្នកនេះ ជាអ្នកចោទដោយធម៌ឬទេហ្ន៎ ?

ពីរបទថា ចុទិតកោ បរិគ្គហេតព្វោ : ត្រូវសង្កេតមើលអ្នកជាប់ចោទ មានសេចក្ដីថា គប្បីត្រួតមើលអ្នកជាប់ចោទយ៉ាងនេះថា អ្នកនេះជាអ្នកជាប់ចោទដោយធម៌ឬទេ ?

ពីរបទថា អធម្មចោទកោ បរិគ្គហេតព្វោ : ត្រូវសង្កេតមើលអ្នក

ចោទមិនត្រូវតាមធម៌ មានសេចក្ដីថា គប្បីដឹងប្រមាណអ្នកចោទនោះ ។ សូម្បីក្នុងបទដ៏សេស ក៏ន័យនេះឯង ។

ពីរបទថា វុត្តំ អហាបេន្តេន : កុំបំបាត់ពាក្យដែលនិយាយមកហើយ មានសេចក្ដីថា មិនគប្បីញ៉ាំងពាក្យដែលអ្នកចោទ និងអ្នកជាប់ចោទពោលឱ្យចេញមក ។

ពីរបទថា អវុត្តំ អប្បកាសេន្តេន : កុំប្រកាសផ្សាយពាក្យដែលមិនទាន់បាននិយាយ មានសេចក្ដីថា មិនគប្បីរករកសេចក្ដីដែលមិនបានចូលដល់ចំណុចសំខាន់ ។

ពីរបទថា វេទោ[១] បហាសេតព្វោ : ត្រូវធ្វើអ្នកមានបញ្ញាទន់ឱ្យរីករាយ មានសេចក្ដីថា អ្នកចោទឬអ្នកជាប់ចោទជាអ្នកទន់ខ្សោយ គឺ ជាអ្នកល្ងង់ខ្លៅ គប្បីជួយ គឺ គប្បីជាស់ចិត្តឱ្យអាចហ៊ានថា លោកជាបុត្ររបស់ត្រកូល មិនមែន ឬ ? ហើយចង្អុលបង្ហាញទំនៀមក្នុងការសាកសួរ ហើយចាប់ការសាកសួរដល់អ្នកល្ងង់ខ្លៅនោះ ។

ពីរបទថា ភីរុ អស្សាសេតព្វោ : ត្រូវធ្វើអ្នកដែលភិតភ័យឱ្យស្រួលចិត្ត មានសេចក្ដីថា អ្នកចោទឬអ្នកជាប់ចោទណា កើតសេចក្ដីខ្លាចក្រែងឡើង ព្រោះមិនធ្លាប់ចូលកាន់កណ្ដាលជំនុំសង្ឃ ឬកណ្ដាលគណៈ,

១. ឱ.ម. មន្ទោ ។

ភិក្ខុដូច្នោះ ដែលភិក្ខុពោលអត្តក្តី គប្បីនិយាយលួងលោមថា "លោកកុំខ្លាចឡើយ ចូរដាក់ចិត្តឆ្ពើយចុះ, ពួកយើងនឹងជាអ្នកជិតដិតនឹងលោក" ដូច្នេះ ក៏បាន ហើយចន្លលបង្ហាញទំនៀមក្នុងការសាកសួរ ។

ពីរបទថា ចណ្ឌោ និសេធេតព្វោ : ត្រូវគម្រាមបុគ្គលដែលកាចមានសេចក្តីថា ជាអ្នកប្រទុសរ៉ាយ គប្បីរុករានចេញ គឺ គប្បីបម្រាបចេញ ។

ពីរបទថា អសុចិ វិភាវេតព្វោ : ត្រូវឱ្យបុគ្គលដែលជាអលជ្ជីសម្តែងអាបត្តិចេញ មានសេចក្តីថា ជាអលជ្ជីគប្បីប្រកាសហើយឱ្យសម្តែងអាបត្តិចេញ ។

ពីរបទថា ឧជុ មទ្ទវេន : ត្រូវមានចិត្តត្រង់ មានចិត្តទន់ មានសេចក្តីថា ភិក្ខុណាជាអ្នកត្រង់ មានសីល វៀរចាកសេចក្តីឆ្នាំឆ្គងកោងមកកាយជាដើម, ភិក្ខុនោះ ដែលអ្នកពោលអត្តក្តី គប្បីប្រព្រឹត្តដោយសេចក្តីទន់ភ្លន់ប៉ុណ្ណោះ ។

ក្នុងពាក្យថា ធម្មេសុ ច បុគ្គលេសុ ច : ចំពោះធម៌ផងចំពោះបុគ្គលផង នេះ ភិក្ខុណា ធ្ងន់ក្នុងធម៌ មិនបានធ្ងន់ក្នុងបុគ្គល, ភិក្ខុនេះឯង គប្បីជ្រាបថា អ្នកដាក់ខ្លួនជាកណ្តាល ទាំងក្នុងធម៌ ទាំងក្នុងបុគ្គល ។

# ប្រយោជន៏នៃសូត្រជាដើម

[១៦៧] វិនិច្ឆ័យក្នុងពាក្យថា **សុត្តំ សំសន្ទនត្ថាយ : សុត្តៈ** ដើម្បីនឹងប្រៀបធៀប ជាដើម គប្បីជ្រាបដូច្នេះ ៖

ក៏ប៉ុន្តែថា ភិក្ខុអ្នកត្រួតពិនិត្យក្តី ជាទីស្រឡាញ់ ពេញចិត្តជាទីគោរព និង ជាទីរាប់អានរបស់សព្រហ្មចារីយ៉ាងនេះ គប្បីជ្រាបថា ក្នុងបណ្តាសូត្រជាដើម ដែលអាងសូត្រមក ដើម្បីប្រយោជន៍ដល់ការប្រៀបធៀប គឺ ដើម្បីប្រយោជន៍ដល់ការដេញដោលសួរអាបត្តិ និងអនាបត្តិ ។

ពីរបទថា **ឱបម្មំ និទស្សនត្ថាយ : សេចក្តីឧបមា ដើម្បី**ប្រយោជន៍នឹងពន្យល់សេចក្តីឱ្យជាក់ច្បាស់ មានសេចក្តីថា ការឧបមាដើម្បីប្រយោជន៍ដល់ការចង្អុលបង្ហាញនូវសេចក្តី ។

ពីរបទថា **អត្ថោ វិញ្ញាបនត្ថាយ : អត្ថ ដើម្បីប្រយោជន៍នឹងឱ្យ**ជាក់ច្បាស់ មានសេចក្តីថា អត្ថន័យ ដើម្បីប្រយោជន៍ដល់ការពន្យល់ឱ្យយល់ ។

ពីរបទថា **បដិបុច្ឆា ឋបនត្ថាយ : បដិបុច្ឆា ដើម្បីប្រយោជន៍**នឹងតម្កល់ទុក( នូវបុគ្គល ) មានសេចក្តីថា ការសាកសួរដើម្បីប្រយោជន៍ដល់សេចក្តីរឹងមាំរបស់បុគ្គល ។

ពីរបទថា **ឱកាសកម្មំ ចោទនត្ថាយ : ឱកាសកម្ម ដើម្បី**

ប្រយោជន៍ដល់ការចោទ មានសេចក្តីថា (ការសូមឱកាស) ដើម្បីប្រយោជន៍ដល់ការចោទដោយវត្ថុ ឬដោយអាបត្តិ ។

ពីរបទថា ចោទនា សារណត្ថាយ : ការចោទ ដើម្បីប្រយោជន៍នឹងរំលឹក មានសេចក្តីថា (ការចោទ) ដើម្បីប្រយោជន៍ឱ្យអ្នកជាប់ចោទ រលឹកដល់ទោសតូចធំ ។

ពីរបទថា សារណា សវចនីយត្ថាយ : ការរំលឹក ដើម្បីប្រយោជន៍នឹងធ្វើ(បុគ្គលនោះ)ឱ្យមានមាត់ពាក្យ មានសេចក្តីថា ការដែលឱ្យអ្នកជាប់ចោទ រលឹកដល់ទោសតូចទោសធំ ដើម្បីប្រយោជន៍ជាអ្នកមានពាក្យដែលខ្ទនគប្បីឆ្លើយ ។

ពីរបទថា សវចនីយំ បឡិពោធត្ថាយ : អំពើដែលធ្វើឱ្យមានមាត់ពាក្យ ដើម្បីប្រយោជន៍ដល់ការកន្លល់ មានសេចក្តីថា ជាអ្នកមានពាក្យ ដែលខ្ទនគប្បីឆ្លើយ ដើម្បីប្រយោជន៍ដល់ការឃាត់ទុកយ៉ាងនេះថា "លោកកុំឈានចេញទៅ សូម្បីតែមួយជំហ៊ានចាកអាវាសនេះ" ។

ពីរបទថា បលិពោធោ វិនិច្ឆយត្ថាយ : ការកន្លល់ ដើម្បីប្រយោជន៍នឹងតម្កល់ទុកនូវការវិនិច្ឆ័យ មានសេចក្តីថា (ការឃាត់ទុក) ដើម្បីប្រយោជន៍ដល់ការឱ្យតាំងវិនិច្ឆ័យ ។

ពីរបទថា វិនិច្ឆយោ សន្តីរណត្ថាយ : ការវិនិច្ឆ័យ ដើម្បីប្រយោជន៍ដល់ការពិចារណា មានសេចក្តីថា ការវិនិច្ឆ័យ ដើម្បី

ប្រយោជន៍ដល់ការរិះគិត គឺ ពិចារណាទោស និងមិនមែនទោស ។

ការរិះគិត ដើម្បីប្រយោជន៍ដល់ការស្គាបស្ទង់ឋានៈ និង អឋានៈ គឺ ដើម្បីប្រយោជន៍ឱ្យស្គាល់អាបត្តិ អនាបត្តិ គរុកាបត្តិ លហុកាបត្តិ ។

ពីរបទថា សច្ចេ សម្បរិគ្គហសម្បដិច្ឆនត្ថាយ : ជំនុំសង្ឃ ដើម្បីប្រយោជន៍ទទួលការវិនិច្ឆ័យ មានសេចក្តីថា ដើម្បីប្រយោជន៍ដល់ការទទួលរងវិនិច្ឆ័យ និងដើម្បីប្រយោជន៍ឱ្យបានដឹងថា អធិករណ៍នោះ ដែលអ្នកពោលអត្តក្តី វិនិច្ឆ័យត្រឹមត្រូវ ឬមិនត្រឹមត្រូវ ។

ពីរបទថា បច្ចេកដ្ឋាយិនោ អវិសំវាទកដ្ឋាយិនោ : គួរដល់តំណែងជាធំតាមចំណែក និងគួរដល់តំណែងជាអ្នកពោលពាក្យពិត មានសេចក្តីថា បុគ្គលទាំងនោះ ដែលតាំងនៅក្នុងតំណែងជាធំ ដោយភាពជាឥស្សរិយាធិបតី និងក្នុងឋានៈនៃអ្នកមិនពោលក្លែងឱ្យខុសដែលសង្ឃមិនគប្បីរកកួន ។

## ប្រយោជន៍នៃវិន័យជាដើម

ឥឡូវនេះ ព្រះឧបាលីថេរៈពោលពាក្យថា វិន័យដើម្បីប្រយោជន៍ដល់សំវរៈ ជាដើម ដើម្បីសម្តែងសេចក្តី ដើម្បីបិទឱកាសនៃពាក្យរបស់ជនទាំងឡាយ អ្នកមានបញ្ញាខ្សោយ ដែលនឹងគប្បីពោលយ៉ាងនេះថា ឈ្មោះថា វិន័យ តើមានប្រយោជន៍អ្វី ។

បណ្ដាបទទាំងនោះ ពីរបទថា **វិនយោ សំវរត្ថាយ : វិន័យដើម្បីប្រយោជន៍ដល់សេចក្ដីសង្រួម** មានសេចក្ដីថា វិន័យបញ្ញត្តិ ស្ទើរទាំងអស់ ដើម្បីប្រយោជន៍ដល់សេចក្ដីសង្រួមកាយទ្វារ និងវចីទ្វារ គឺជាឧបនិស្ស័យ អធិប្បាយថា ជាបច្ច័យដល់សីល មានអាជីវបារិសុទ្ធិសីលជាទីបំផុត ។ ក្នុងបទទាំងពួង ក៏ន័យនេះឯង ។

ម្យ៉ាងទៀត ក្នុងធម៌ទាំងឡាយ មានសេចក្ដីមិនក្ដៅក្រហាយចិត្តជាដើមនេះ មានពាក្យអធិប្បាយថា ការមិនមានសេចក្ដីក្ដៅក្រហាយនៃចិត្តដោយអំណាចនៃបុណ្យដែលបានធ្វើទុក និងបាបដែលមិនបានធ្វើទុក ឈ្មោះថា **សេចក្ដីមិនក្ដៅក្រហាយចិត្ត** ។

បីតិទន់ខ្សោយ មិនខ្លាំងក្លា ឈ្មោះថា **បាមោជ្ជៈ** ។

បីតិខ្លាំងក្លា មានកម្លាំង ឈ្មោះថា **បីតិ** ។

ការរម្ងាប់សេចក្ដីខ្វល់ខ្វាយក្នុងកាយនិងចិត្ត ឈ្មោះថា **បស្សទ្ធិ** ។

សុខមកកាយមកចិត្ត ឈ្មោះថា **សុខៈ** ។

ពិតមែន សុខទាំង ២ យ៉ាងនោះ រមែងជាឧបនិស្សយបច្ច័យនៃសមាធិ ។

ចិត្តដែលមានអារម្មណ៍តែមួយ ឈ្មោះថា **សមាធិ** ។

វិបស្សនាយ៉ាងខ្សោយ ឈ្មោះថា **យថាភូតញ្ញាណទស្សនៈ** ។

យថាភូតញ្ញាណទស្សនៈនេះ ជាឈ្មោះរបស់ញាណដែលដឹងសេចក្តីកើតនិងសេចក្តីសាបសូន្យ ។

ពិតមែន សេចក្តីដែលចិត្តមានអារម្មណ៍តែមួយ រមែងជាឧបនិស្សយប្បច្ច័យនៃវិបស្សនាទន់ខ្សោយ ។

វិបស្សនាយ៉ាងខ្លាំងក្លា ដែលចាត់ជាកំពូល ជាហេតុឱ្យដល់ការដេកខ្ពើមចេញ ឈ្មោះថា **និព្វិទា** ។

អរិយមគ្គ ឈ្មោះថា **វិរាគៈ** ។

អរហត្តផល ឈ្មោះថា **វិមុត្តិ** ។

ពិតមែន អរិយមគ្គទាំង ៤ យ៉ាង រមែងជាឧបនិស្សយប្បច្ច័យនៃអរហត្ត ។

បច្ចវេក្ខណញ្ញាណ ឈ្មោះថា វិមុត្តិញ្ញាណទស្សនៈ ។

ពីរបទថា **វិមុត្តិញ្ញាណទស្សនំ អនុបាទាបរិនិព្វានត្ថាយ** : វិមុត្តិញ្ញាណទស្សនៈ ដើម្បីប្រយោជន៍ដល់អនុបាទាបរិនិព្វាន មានសេចក្តីថា វិមុត្តិញ្ញាណទស្សនៈ ដើម្បីប្រយោជន៍ដល់សេចក្តីរលត់អស់មិនមានសេសសល់បច្ច័យ ។ ពិតមែន វិមុត្តិញ្ញាណទស្សនៈនោះ ឈ្មោះថា ជាបច្ច័យដល់សេចក្តីរលត់អស់ មិនមានបច្ច័យ ព្រោះកាលវិមុត្តិញ្ញាណទស្សនៈ ដែលយោគាវចរសម្រេចដោយលំដាប់ហើយ កិលេស និងកង

ទុក្ខ គប្បីរលត់អស់ពិតប្រាកដដូច្នេះឯង ។

ពីរបទថា ឯតទត្ថា កថា : ការពោលនូវព្រះវិន័យ មានអរហត្តផលឬនិព្វាននុ៎ះជាប្រយោជន៍ មានសេចក្ដីថា ធម្មតា វិន័យកថានេះ មានអនុបាទាបរិនិព្វាននោះ ជាប្រយោជន៍ ។ ការប្រឹក្សាវិន័យនុ៎ះឯងឈ្មោះថា មន្តនា : ការប្រឹក្សា ។

បទថា ឧបនិសា : ការពិចារណា មានសេចក្ដីថា សូម្បីភាពជាធម៌ជាបច្ច័យបន្តគ្នាទៅជាដើមថា វិន័យដើម្បីប្រយោជន៍ដល់សំវរៈនេះ ក៏ដើម្បីប្រយោជន៍ដល់អនុបាទាបរិនិព្វាននោះ ។ សេចក្ដីផ្ទៀងសោតៈស្ដាប់ពាក្យដែលជាបច្ច័យបន្តគ្នាទៅនេះ ឈ្មោះថា សេចក្ដីផ្ទៀងសោតៈស្ដាប់ ។ ញាណណា កើតឡើងព្រោះបានស្ដាប់សេចក្ដីនេះ ញាណសូម្បីនោះ ក៏ដើម្បីប្រយោជន៍ដល់អនុបាទាបរិនិព្វាននោះ ។

ប្រើនបទថា យទិទំ អនុបាទា ចិត្តស្ស វិមោក្ខោ : ព្រះអរហត្តផល ឬនិព្វានជាគ្រឿងរួចចាកសេចក្ដីសៅហ្មងនៃចិត្ត ព្រោះមិនមានឧបាទានជាគ្រឿងប្រកាន់ណា មានសេចក្ដីថា សេចក្ដីផុតពិសេសនៃចិត្ត ព្រោះមិនប្រកាន់មាំដោយឧបាទាន ៤ ពោលគឺ អរហត្តផលនេះ, សេចក្ដីផុតពិសេស នៃចិត្តសូម្បីនោះ ក៏ដើម្បីប្រយោជន៍នេះ គឺ ដើម្បីប្រយោជន៍ដល់បរិនិព្វានដែលមិនមានបច្ច័យនុ៎ះឯង ។

# អនុយោគវត្តគាថា

[១៦៨] បណ្ដាអនុយោគវត្តគាថាទាំងឡាយ គាថាដើម មានសេចក្ដីដូចពោលហើយនុ៎ះឯង ។

ក្នុងពាក្យថា វត្ថុំ វិបត្តឹ អាបត្តឹ និទានំ អាការអកោវិទោ បុព្វាបរំ ន ជានាតិ ភិក្ខុណាមិនស្គាល់វត្ថុផង មិនស្គាល់វិបត្តផង មិនស្គាល់អាបត្តិផង មិនស្គាល់និទានផង មិនឈ្លាសក្នុងអាការ គឺហេតុនិងមិនមែនហេតុផង មិនស្គាល់ពាក្យខាងដើម និងពាក្យខាងចុងផង គប្បីធ្វើការភ្ជាប់បទថា វត្ថុំ ជាដើម ដោយបទថា ន ជានាតិ ។ គប្បីធ្វើការភ្ជាប់បទថា អកោវិទោ ដោយបទថា ស វេ តាទិសកោ នេះ ។

ព្រោះហេតុនោះ គប្បីជ្រាបថា វាចាគ្រឿងប្រកបក្នុងពាក្យថា វត្ថុំ ជាដើមនេះ ដូចតទៅនេះ ៖

ភិក្ខុណា មិនស្គាល់វត្ថុនៃវិតិក្កមៈមានបារាជិកជាដើម, មិនដឹងវិបត្តិ ៤ យ៉ាង, មិនដឹងអាបត្តិ ៧ យ៉ាង, មិនដឹងនិទានយ៉ាងនេះថា សិក្ខាបទនេះ ទ្រង់បញ្ញត្តិហើយ ក្នុងនគរឈ្មោះឯណោះ, មិនស្គាល់ខាងដើមនិងខាងចុងថា នេះជាពាក្យមុន នេះជាពាក្យក្រោយ, មិនស្គាល់កម្មដែលធ្វើហើយ ឬមិនទាន់បានធ្វើថា នេះធ្វើហើយ នេះមិនទាន់បានធ្វើ ។

ក្នុងបទថា សមេន ច : ដោយស្មើផង មានពាក្យអធិប្បាយថា

មិនស្គាល់កម្មដែលធ្វើហើយ ឬមិនទាន់បានធ្វើ ដោយសេចក្ដីមិនដឹងជានិច្ចរបស់ភិក្ខុមិនដឹងខាងដើម និងខាងចុងនោះឯង ។ គប្បីជ្រាបការភ្ជាប់នឹងបទថា ន ជានាតិ យ៉ាងនេះមុន ។

ក៏ឯវិនិច្ឆ័យក្នុងពាក្យថា អាការអកោវិទោ : ឈ្លាសក្នុងអាការដែលព្រះមានព្រះភាគត្រាស់ទុកគប្បីជ្រាបដូច្នេះ ៖

បទថា អាការអកោវិទោ បានដល់ អ្នកមិនយល់ហេតុ និងមិនមែនហេតុ ។ ភិក្ខុណា មិនដឹងវត្ថុជាដើម និងមិនយល់អាការ, ភិក្ខុដូច្នោះ ៗ ឯង ព្រះមានព្រះភាគត្រាស់ថា អ្នកមិនគួរជ្រើសរើស ដោយប្រការដូច្នេះ ។

គប្បីធ្វើការភ្ជាប់បទសូម្បីទាំងនេះថា កម្មញ្ច អធិករណញ្ច ដោយបទថា ន ជានាតិ នុ៎ះឯង ។

ក៏ឯវាចាសម្រាប់ប្រកប ក្នុងពាក្យថា កម្មញ្ច ជាដើមនោះដូចតទៅនេះ ៖

ភិក្ខុណា មិនស្គាល់កម្ម និងមិនស្គាល់អធិករណ៍ យ៉ាងនោះឯង, ទាំងមិនយល់សមថៈ ៧ ប្រការផង, មួយទៀត ដែលមានតម្រេកហើយនឹងក្រោធហើយ និងវង្វេងហើយ ព្រោះកិលេសមានរាគៈជាដើម រមែងលំអៀងព្រោះខ្លាចដោយសេចក្ដីខ្លាច រមែងលំអៀងព្រោះខ្លៅ ដោយ

សេចក្ដីល្ងង់, មួយទៀត ព្រោះហេតុដែលខ្លួនជាអ្នកមានតម្រេក និង ព្រោះហេតុដែលខ្លួនជាអ្នកខឹងក្រោធ ទើបលំអៀង ព្រោះសេចក្ដីពេញចិត្ត ព្រោះសេចក្ដីស្អប់ ។

មួយទៀត មិនជាអ្នកឆ្លាតក្នុងបញ្ញត្តិទេ ព្រោះមិនជាអ្នកអាចនឹងញុំាងអ្នកដទៃឱ្យយល់ព្រម ។ មួយទៀត មិនឆ្លាតក្នុងការគួសបញ្ឆាក់ ព្រោះជាអ្នកមិនអាចក្នុងការចង្អុលហេតុ និងមិនមែនហេតុ ។

ឈ្មោះថា អ្នកបានបក្ខពួក ព្រោះបានបរិស័ទជាបក្ខពួកខ្លួន, ឈ្មោះថា អ្នកមិនមានសេចក្ដីខ្មាស ព្រោះជាអ្នកឆ្ងាយចាកហិរិ, ឈ្មោះថា អ្នកមានកម្មខ្មៅ ព្រោះជាអ្នកព្រមព្រៀងដោយកម្មខ្មៅទាំងឡាយ, ឈ្មោះថា អ្នកមិនអើពើ ព្រោះមិនមានសេចក្ដីអើពើក្នុងធម៌ និងសេចក្ដីអើពើក្នុងបុគ្គល ។ ភិក្ខុមានសភាពបែបនោះឯង ព្រះមានព្រះភាគត្រាស់ថា អ្នកមិនគួរជ្រើសរើស ។ គឺ សង្ឃមិនគួរពិចារណា បានដល់ មិនគួរក្រឡេកមើល, អធិប្បាយថា មិនគួរសន្មតតាំងទុកក្នុងតំណែងជាអ្នកធំដោយភាពជាឥស្សរិយាធិបតី ។

យោជនាន័យ សូម្បីនៃគាថាចំណែកស ក៏គប្បីជ្រាបដោយន័យដូចពោលហើយនោះឯង ។

## ចូឡសង្គាមវណ្ណនា ចប់

# ពណ៌នាមហាសង្គ្រាម

វិនិច្ឆ័យក្នុងមហាសង្គ្រាម គប្បីជ្រាបដូច្នេះ ៖

[១៧៦] ប្រើនបទថា វត្ថុតោ វា វត្ថុំ សង្កមតិ : កន្ទួងនូវ **វត្ថុដោយវត្ថុផង** មានសេចក្តីថា អ្នកចោទពោលថា វត្ថុនៃបឋមបារាជិក ដែលខ្ញុំបានឃើញហើយ ឬថា វត្ថុនៃបឋមបារាជិក ដែលខ្ញុំបានស្តាប់ហើយ កាលត្រូវសួរ គឺ ត្រូវបង្ខំថែមទៀត ត្រឡប់ពោលថា វត្ថុនៃបឋមបារាជិក ខ្ញុំមិនបានឃើញ មិនបានឮ វត្ថុនៃទុតិយបារាជិកដែលខ្ញុំបានឃើញហើយ ឬថា វត្ថុនៃទុតិយបារាជិក ដែលខ្ញុំបានឮហើយ ។ គប្បីជ្រាបការប្តូរវត្ថុដ៏សេស ការប្តូរវិបត្តិចាកពីវិបត្តិ និងការប្តូរអាបត្តិចាកអាបត្តិ ដោយន័យនេះឯង ។

ចំណែកភិក្ខុណាពោលថា ខ្ញុំមិនបានឃើញទេ មិនបានឮទេ ដូច្នេះហើយ ខាងក្រោយពោលថា រឿងនោះ សូម្បីខ្ញុំក៏បានឃើញ ឬថា រឿងនោះ សូម្បីខ្ញុំក៏បានឮ ពោលថា ខ្ញុំបានឃើញ ឬថា ខ្ញុំបានឮ ដូច្នេះហើយ ខាងក្រោយត្រឡប់ពោលថា ខ្ញុំមិនបានឃើញទេ មិនបានឮទេ ភិក្ខុនោះ គប្បីជ្រាបថា បដិសេធ ហើយត្រឡប់ប្តេជ្ញា ប្តេជ្ញាហើយ

ត្រឡប់បដិសេធ ។ ភិក្ខុនេះឯង ឈ្មោះថា បង្វែនូវរឿងដទៃដោយរឿងដទៃ ។

[១៧៧] សុក្កវិស្សដ្ឋិសិក្ខាបទ ដោយអំណាចពណ៌, មានពណ៌ខៀវជាដើម និងជាអ្នកមិនមានរោគ លោកពោលថា "វណ្ណា អវណ្ណា : ស្គាល់ទឹកសុក្កមានពណ៌, និងមិនមានពណ៌" ។ សញ្ចរិតសិក្ខាបទ លោកពោលថា "វណ្ណមនុប្បាទនំ : និយាយដឹកនាំបុរសនិងស្ត្រីឱ្យបានគ្នាជាប្ដីប្រពន្ធ" (ញុំាងការសូមឱ្យកើតឡើង) ៣ សិក្ខាបទមានកាយសំសគ្គសិក្ខាបទជាដើម លោកពោលតាមរូបដើមនុ៎ះឯង ។ ៤ សិក្ខាបទនេះ គប្បីជ្រាបថា ជាបុព្វភាគ គឺ បុព្វប្រយោគរបស់មេថុនធម្ម ដោយប្រការដូច្នេះ ។

[១៧៨] អបលោកនកម្ម ៤ នោះ បានដល់ កម្មជាពួកមិនប្រកបដោយធម៌ជាដើម[១] ។ សូម្បីក្នុងកម្មដ៏សេសៗ ក៏ន័យនេះឯង ។

ពួកបួន ៤ ពួក ទើបរួមជា ១៦ ដោយប្រការដូច្នេះ ។

---

១ តាមច្បាប់ក្នុងស្លឹករឹត ជា វគ្គាទីនិ ។

[១៨១] ច្រើនបទថា ពហុជនាហិតាយ បដិបន្នោ ហោតិ : ប្រតិបត្តិដើម្បីមិនជាប្រយោជន៍ដល់ជនច្រើនគ្នា មានសេចក្តីថា ពិតមែន កាលអធិករណ៍ដែលព្រះវិន័យធរ វិនិច្ឆ័យដោយឆន្ទាគតិយ៉ាងនោះ សង្ឃក្នុងវត្តនោះ រមែងបែកគ្នាជា ២ ពួក ។ សូម្បីភិក្ខុនីទាំងឡាយដែលអាស្រ័យឱវាទរស់នៅ ក៏រមែងជា ២ ពួក ។ ពួកឧបាសកក្តី ឧបាសិកាក្តី ក្មេងប្រុសក្តី ក្មេងស្រីក្តី រមែងជា ២ ពួក សូម្បីពួកអារក្ខទេវតារបស់ជនទាំងនោះ ក៏រមែងបែកគ្នាជា ២ ពួកដូចគ្នា ។ តពីនោះ ទេវតាទាំងឡាយ រាប់ភុម្មទេវតាជាដើម ដរាបដល់អកនិដ្ឋព្រហ្ម រមែងចែកជា ២ ពួកដែរ ។

ដោយហេតុនោះ លោកទើបពោលថា ភិក្ខុដែលលុះឆន្ទាគតិជាដើម ដោយវត្ថុទាំងឡាយ ១៨ប្រការ រមែងជាអ្នកបដិបត្តិដើម្បីមិនប្រយោជន៍ដល់ជនជាច្រើន ។ល។ ជាអ្នកបដិបត្តិ ដើម្បីមិនជាប្រយោជន៍ ដើម្បីមិនជាសុខ ដើម្បីទុក្ខ ដល់ជនជាច្រើន ទាំងទេវតានិងមនុស្សទាំងឡាយ ។

[១៨៤] បទថា វិសមនិស្សិតោ : អាស្រ័យនូវកម្មមិនស្មើ

បានដល់ អ្នកអាស្រ័យកយកម្មជាដើម ដែលមិនរៀបរយ ។

បទថា គហននិស្សិតោ : អាស្រ័យនូវព្រៃស្បាត បានដល់ អ្នកអាស្រ័យសេចក្ដីប្រកាន់ ពោលគឺ មិច្ឆាទិដ្ឋិ និងអន្តគាហិកទិដ្ឋិ ។

បទថា ពលវនិស្សិតោ : អាស្រ័យនូវភិក្ខុដែលមានកម្លាំង បានដល់ អ្នកអាស្រ័យភិក្ខុដែលមានឈ្មោះបោះសំឡេងដែលមានកម្លាំង ។

[១៩៥] ពីរបទថា តស្ស អវជានន្តោ : ហើយមើលងាយបុគ្គលនោះ បានដល់ មើលងាយពាក្យរបស់ភិក្ខុនោះ ។ ម្យ៉ាងទៀត បទថា តស្ស នោះ ជាឆដ្ឋីវិភត្តិ ប្រើក្នុងអត្ថនៃទុតិយាវិភត្តិ, អធិប្បាយថា មើលងាយភិក្ខុនោះ ។

[១៩៨] ពីរបទថា យំ អត្ថាយ : ដើម្បីសេចក្ដីណា មានសេចក្ដីថា ដើម្បីប្រយោជន៍ណា ។

ពីរបទថា តំ អត្ថំ : ញុំាងសេចក្ដីនោះ មានសេចក្ដីថា ប្រយោជន៍នោះ ។

ពាក្យដ៏សេសក្នុងទីទាំងពួង ងាយយល់ទាំងអស់ ដូច្នេះឯង ។

**មហាសង្គាមវណ្ណនា ចប់**

# ពណ៌នាកឋិនភេទ

## ធម៌ដែលកើតជាមួយនឹងការក្រាលកឋិន

វិនិច្ឆ័យក្នុងកឋិន គប្បីជ្រាបដូច្នេះ ៖

[២១៣] ពីរបទថា អដ្ឋ មាតិកា : មាតិកា ៨ បានដល់មាតិកា ៨ មានបក្កមនន្តិកា (មានការចៀសទៅជាកំណត់)ជាដើម ដែលត្រាស់ទុកក្នុងកឋិនក្ខន្ធកៈ ។ សូម្បីបលិពោធ និងអានិសង្ស ក៏បានត្រាស់ទុកក្នុងកាលមុនហើយនោះឯង ។

## អនន្តរប្បច្ច័យជាដើម

[២១៤] បទថា បយោគស្ស : នៃបយោគ បានដល់ប្រយោគមានការរកទឹកមកជាដើម ដែលភិក្ខុធ្វើដើម្បីប្រយោជន៍ដល់បុព្វករណៈ ៧ យ៉ាង មានបោកគក់ចីវរជាដើម ។

ព្រើនបទថា គតមេ ធម្មា អនន្តរប្បច្ចយេន បច្ចយោ : ធម៌ប៉ុន្មានយ៉ាង ជាបច្ច័យ(នៃបយោគ) ដោយអនន្តរប្បច្ច័យ មានសេចក្តីថា ធម៌ពួកណាជាធម៌បន្តលំដាប់ ដោយជាប់ដោយប្រយោគដែលមិនទាន់មក រមែងជាបច្ច័យ ។

បទថា សមនន្តរប្បច្ចយេន : ដោយសមនន្តរប្បច្ច័យ មានសេចក្ដីថា ព្រះមានព្រះភាគត្រាស់សួរដល់ធម៌ ដែលបន្ទាប់ជាប់គ្នាជាបច្ច័យ ដោយធម៌ដែលបន្ទាប់ជាប់គ្នាជាបច្ច័យដោយត្រង់នុ៎ះឯង តែធ្វើឱ្យជិតជាង ។

បទថា និស្សយប្បច្ចយេន : ដោយនិស្សយប្បច្ច័យ មានសេចក្ដីថា ធម៌ពួកណា ដូចជាចូលជិតភាពជាធម៌ជាទីអាស្រ័យ គឺ ភាពជាធម៌ជាទីទទួលរងនៃប្រយោគដែលកើតឡើង រមែងជាបច្ច័យ ។

បទថា ឧបនិស្សយប្បច្ចយេន : ដោយឧបនិស្សយប្បច្ច័យ មានសេចក្ដីថា ត្រាស់សួរដល់ធម៌ដែលអាស្រ័យជាបច្ច័យ ដោយធម៌ជាទីអាស្រ័យជាបច្ច័យ ដែលជិតគ្នានុ៎ះឯង តែធ្វើឱ្យជិតជាង ។

ត្រាស់សួរដល់ភាវៈនៃធម៌ដែលកើតមុនជាបច្ច័យ ដោយបទថា បុរេជាតប្បច្ចយេន : ដោយបុរេជាតប្បច្ច័យ នេះ ។

ត្រាស់សួរដល់ភាវៈនៃធម៌ទាំងឡាយ ដែលកើតឡើង មិនមុនមិនក្រោយជាបច្ច័យ ដោយបទថា សហជាតប្បច្ចយេន : ដោយសហជាតប្បច្ច័យ នេះ ។

បទថា បុព្វករណស្ស : នៃបុព្វករណៈ បានដល់ បុព្វករណៈ

មានការបោកគក់ចីវរជាដើមផង ។

បទថា បច្ចុទ្ធរស្ស : នៃបច្ចុទ្ធារ បានដល់ ការដកត្រៃចីវរមានសង្ឃាដិចាស់ជាដើម ។

បទថា អធិដ្ឋានស្ស : នៃអធិដ្ឋាន បានដល់ អធិដ្ឋានចីវរកឋិន ។

បទថា អត្ថារស្ស : នៃការក្រាល បានដល់ ការក្រាលកឋិន ។

ត្រើនបទថា មាតិកានញ្ច បលិពោធានញ្ច : នៃមាតិកាផង នៃបលិពោធផង បានដល់ មាតិកា ៨ និងបលិពោធ ២ ។

បទថា វត្ថុស្ស : នៃវត្ថុ បានដល់ វត្ថុគួរដល់កឋិន មានសង្ឃាដិជាដើម ។

ពាក្យដ៏សេស មានន័យដូចពោលហើយនុ៎ះឯង ។

## បច្ច័យប្រយោគជាដើម

[២១៥] ព្រះមានព្រះភាគ ត្រាស់សួរដល់បុព្វករណៈជាដើម ដែលបានដោយភាពជាបច្ច័យ និងប្រយោគជាដើម ដែលមិនបានដោយភាពជាបច្ច័យ យ៉ាងនោះទាំងអស់ហើយ ឥឡូវនេះ ទីងសម្ដែង

បុព្វករណៈជាដើម ដែលជាបច្ច័យនៃប្រយោគជាដើមនុ៎ះឯង ហើយទើបត្រាស់ពាក្យវិសជ្ជនា ដោយន័យមានពាក្យថា បុព្វករណំ បយោគស្ស អនន្តរបច្ចយេន បច្ចយោ : បុព្វករណៈជាបច្ច័យនៃបយោគ ដោយអនន្តរបច្ច័យ ជាដើម ។

សេចក្តីនៃពាក្យវិសជ្ជនា គប្បីជ្រាបដូច្នេះ ៖

ខ្ញុំនឹងពោលឆ្លើយក្នុងពាក្យដែលព្រះមានព្រះភាគត្រាស់ថា បយោគស្ស កតមេ ធម្មា ជាដើម, បុព្វករណៈជាបច្ច័យ ដោយអនន្តរបច្ច័យនៃប្រយោគ ជាបច្ច័យដោយសមនន្តរបច្ច័យ និស្សយបច្ច័យ និងឧបនិស្សយបច្ច័យនៃប្រយោគ ។

ពិតមែន បុព្វករណៈសូម្បីទាំង ៧ យ៉ាង រមែងជាបច្ច័យ ដោយបច្ច័យ ៤ ទាំងនេះនៃប្រយោគ ព្រោះហេតុដែលប្រយោគនោះ ដែលភិក្ខុរមែងធ្វើដើម្បីប្រយោជន៍ដល់បុព្វករណៈ ដែលខ្លួនគប្បីឱ្យសម្រេចដោយប្រយោគនោះ ។ តែប្រយោគនោះ រមែងមិនបានសូម្បីនូវធម៌មួយ ក្នុងធម៌ទាំងឡាយដែលបានឧទ្ទេសហើយ ក្នុងភាពជាបុរេជាតបច្ច័យប្រយោគនោះ ឈ្មោះថា ជាបុរេជាតបច្ច័យនៃបុព្វករណៈដោយពិត ព្រោះកាលប្រយោគមានបុព្វករណៈ ទើបសម្រេច ។ ដោយហេតុនោះ

ទើបព្រះមានព្រះភាគត្រាស់ថា "ប្រយោគជាបច្ច័យនៃបុព្វករណៈ ដោយជាបុរេជាតប្បច្ច័យ" ។

មួយទៀត ប្រយោគ រមែងបានបច្ឆាជាតប្បច្ច័យ ។ ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា "បុព្វករណៈជាបច្ច័យនៃប្រយោគ ដោយជាបច្ឆាជាតប្បច្ច័យ" ។ ពិតមែន ប្រយោគនោះ ដែលភិក្ខុតែងធ្វើដើម្បីប្រយោជន៍ដល់បុព្វករណៈដែលកើតខាងក្រោយ ។ តែវៀរធម៌ ១៥ ពោលគឺ មាតិកាបលិពោធ និងអានិសង្សចេញហើយ ក្នុងបណ្ដាធម៌មានប្រយោគជាដើម ធម៌ដទៃសូម្បីណាមួយ រមែងមិនបានសហជាតប្បច្ច័យ ។ ព្រោះថា ធម៌ ១៥ នោះប៉ុណ្ណោះ រមែងសម្រេចព្រមគ្នានឹងការក្រាលកឋិន ព្រោះដូច្នោះ ទើបជាសហជាតប្បច្ច័យ អាស្រ័យគ្នានិងគ្នាបាន ។ ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា ធម៌ ១៥ ជាបច្ច័យ ជាសហជាតប្បច្ច័យ ។

វិសជ្ជនាបទទាំងពួង គប្បីជ្រាបដោយឧបាយនេះ ។

បុច្ឆាវិសជ្ជនាមានជាដើមថា បុព្វករណៈ មានអ្វីជានិទាន ងាយយល់ទាំងអស់ ។

# និទាននៃប្រយោគជាដើម

[២២១] វិនិច្ឆ័យក្នុងវិសជ្ជនាពីរបញ្ហាថា ប្រយោគ មានអ្វីជាដើមចម ជាដើម គប្បីជ្រាបដូច្នេះ ៖

ក្នុងពាក្យថា ប្រយោគមានហេតុជាដើមចម មានបច្ច័យជាដើមចម នេះ ចីវរ ៦ ប្រភេទ គប្បីជ្រាបថា ជាហេតុ និងជាបច្ច័យ ។ ពិតមែន ចីវរទាំងនោះឯង ជាហេតុ ចីវរទាំងនោះ ជាបច្ច័យនៃធម៌ទាំងពួង មានបុព្វប្រយោគជាដើម ។ កាលចីវរ ៦ ប្រភេទមិនមាន ប្រយោគក៏មិនមាន បុព្វករណៈជាដើម ក៏មិនមានដែរ ព្រោះហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា "ប្រយោគមានហេតុជាដើមចម" ជាដើម ។

វិនិច្ឆ័យក្នុងសង្គហវារៈ គប្បីជ្រាបដូច្នេះ ៖

[២២២] បទថា វចីភេទេន : បញ្ចេញវាចា បានដល់ បទនូវវាចានេះថា "ខ្ញុំក្រាលកឋិនដោយសង្ឃាដិនេះ, ខ្ញុំក្រាលកឋិនដោយឧត្តរាសង្គៈនេះ, ខ្ញុំក្រាលកឋិនដោយអន្តរវាសកនេះ" ។

វិនិច្ឆ័យក្នុងកតិមូលាទិបុច្ឆាវិសជ្ជនា គប្បីជ្រាបដូច្នេះ ៖

ការដេកនិងការអធិដ្ឋាន ឈ្មោះថា កិរិយានៅកណ្តាល ។

# វិបត្តិនៃកឋិនជាដើម

[២២៧] ពីរបទថា វត្ថុវិបន្នញ្ចេវ ហោតិ : គឺ វត្ថុវិបត្តិ ១ បានដល់ សំពត់មិនគួរ ។ សំពត់ដែលពួកទាយកថ្វាយក្នុងថ្ងៃនេះ សង្ឃឱ្យដល់ភិក្ខុអ្នកក្រាលកឋិនក្នុងថ្ងៃស្អែកនេះ ឈ្មោះថា វិបត្តិដោយកាល ។ សំពត់ដែលកាត់ហើយមិនធ្វើឱ្យសម្រេចក្នុងថ្ងៃនោះឯង ឈ្មោះថា វិបត្តិដោយការធ្វើ ។

[២២៨] វិនិច្ឆ័យក្នុងវិសជ្ជនាពាក្យសួរដែលថា កឋិនំ ជានិតព្វំ : គប្បីស្គាល់កឋិន ជាដើម គប្បីជ្រាបដូច្នេះ ៖

[២២៩] ពីរបទថា តេសញ្ញេវ ធម្មានំ : ការប្រជុំប្រមូលនៃធម៌ទាំងឡាយនោះ មានសេចក្តីថា កាលធម៌ទាំងឡាយ មានរូបធម៌ជាដើម ពួកណាមាន ឈ្មោះកឋិន ទើបមាន, ការផ្សំគឺ ប្រមូលរូបធម៌ជាដើមទាំងនោះ ។ ក៏ពាក្យថា ឆាមំ ឆាមកម្មំ ជាដើម ព្រះមានព្រះភាគទ្រង់សម្តែងថា ពាក្យថា កឋិននេះ ត្រឹមតែ ជានាមក្នុងធម៌ជាច្រើន មិនមែនដោយបរមត្ថធម៌តែមួយទេ ។

ពីរបទថា ចតុវីសតិយា អាការេហិ : ដោយអាការ ១៤ មានសេចក្តីថា (គប្បីជ្រាបវិបត្តិនៃការក្រាលកឋិន) ដោយហេតុដែលពោល

ហើយ ក្នុងកាលមុន (គឺក្នុង[២១០]) មានពាក្យថា គកឋិនំ ន ឧល្លិខិតមត្តេន : សំពត់គ្រាន់តែវាស់ទទឹងបណ្ដោយ ក្រាលមិនឡើងជាកឋិន ជាដើម ។

ពីរបទថា សត្តរសហិ អាការេហិ : ដោយអាការ ១៧ មានសេចក្ដីថា (គប្បីជ្រាបសម្បត្តិនៃការក្រាលកឋិន) ដោយហេតុដែលពោលហើយ ក្នុងកាលមុន មានពាក្យថា "សំពត់ថ្មីក្រាលឡើងជាកឋិន" ជាដើម ។

ពាក្យណា ដែលគប្បីពោលក្នុងនិមិត្តកម្មជាដើម ពាក្យទាំងពួងនោះ បានពោលទុកហើយក្នុងវណ្ណនានៃកឋិនក្ខន្ធកៈ ។

## ការដោះកឋិន

[២៤២] ពីរបទថា ឯកុប្បាទា ឯកនិរោធា : កើតព្រមគ្នារលត់ព្រមគ្នា មានសេចក្ដីថា ការដោះកឋិន សូម្បីកាលកើតឡើង រមែងកើតឡើងជាមួយគ្នា សូម្បីកាលរលត់ រមែងរលត់ជាមួយគ្នា ។

ពីរបទថា ឯកុប្បាទា នានានិរោធា មានសេចក្ដីថា ការដោះកឋិន កាលកើតឡើង រមែងកើតឡើងជាមួយគ្នា, កាលរលត់ រមែងរលត់ក្នុងខណៈផ្សេងគ្នា ។

មានពាក្យអធិប្បាយយ៉ាងណា ? ការដោះសូម្បីទាំងពួង រមែងកើតឡើងព្រមគ្នានឹងការក្រោល, ពិតមែន កាលមានការក្រោល ការដោះរមែងមានជាធម្មតា ។

ក្នុងបណ្ដាការក្រោលកឋិនទាំង ៨ នេះ ពីរខាងដើម កាលនឹងរលត់ រមែងរលត់ គឺ ដល់ការដោះព្រមគ្នានឹងការក្រោល ។ ពិតមែន សេចក្ដីរលត់នៃការក្រោល និងភាពនៃការដោះកឋិនទ្វារ ២ នោះ រមែងមានក្នុងខណៈជាមួយគ្នា ក្រៅពីនេះ រមែងរលត់ក្នុងខណៈផ្សេងគ្នា ។ កាលកឋិនទ្វារបក្កមនន្តិកាជាដើមសូម្បីទាំងនោះ ដល់ហើយនូវភាពជាអាការដោះ ការក្រោលក៏នៅរឹងមាំ ។

ពាក្យដ៏សេសក្នុងបទទាំងពួង ងាយយល់ទាំងអស់ ដូច្នេះឯង ។

**កឋិនភេទវណ្ណនា ចប់**

**បញ្ញត្តិវគ្គវណ្ណនា ចប់**

# ពណ៌នាឧបាលិបញ្ហកៈ

## អង្គ ៥ នៃភិក្ខុដែលកាន់និស្ស័យ

វិនិច្ឆ័យក្នុងឧបាលិបញ្ហា គប្បីជ្រាបដូច្នេះ ៖

[២៤៤] ពាក្យសួរដែលថា កតីហិ នុ ខោ ភន្តេ មានសម្ពន្ធ ដូច្នេះ ៖

បានឮថា ព្រះថេរៈនៅក្នុងទីកំបាំង ទឹកដល់ពួក ៥ ទាំងអស់នេះ ទើបចូលគាល់ព្រះមានព្រះភាគ ដោយគិតថា ឥឡូវនេះ យើងនឹងទូលសួរព្រះមានព្រះភាគ ឱ្យព្រះអង្គដាក់ច្បាប់ ដើម្បីប្រយោជន៍ដល់ភិក្ខុទាំងនេះ មានភិក្ខុដែលកាន់នូវនិស្ស័យជាដើម ហើយទូលសួរបញ្ហា ដោយន័យមានពាក្យថា កតីហិ នុ ខោ ភន្តេ ជាដើម ។

វិនិច្ឆ័យក្នុងពាក្យវិសជ្ជនាបញ្ហាទាំងនោះ គប្បីជ្រាបដូច្នេះ ៖

ពីរបទថា ឧបោសថំ ន ជានាតិ : ភិក្ខុមិនស្គាល់ឧបោសថបានដល់ មិនស្គាល់ឧបោសថ ៩ យ៉ាង ។

ពីរបទថា ឧបោសថកម្មំ ន ជានាតិ : មិនស្គាល់ឧបោសថកម្មបានដល់ មិនស្គាល់ឧបោសថកម្ម ៤ យ៉ាង មានប្រភេទកម្មជាពួកដោយអធម៌ជាដើម ។

ពីរបទថា បាដិមោក្ខំ ន ជានាតិ : មិនចេះបាតិមោក្ខ បាន

ដល់ មិនស្គាល់មាតិកា ២ ។

ពីរបទថា ធាតិមោក្ខុទ្ទេសំ ន ជានាតិ : មិនស្គាល់បាតិមោក្ខុទ្ទេស បានដល់ មិនស្គាល់បាតិមោក្ខុទ្ទេស ៩ យ៉ាង គឺ របស់ភិក្ខុ ៥ យ៉ាង របស់ភិក្ខុនី ៤ យ៉ាង ។

ពីរបទថា បវារណំ ន ជានាតិ : មិនស្គាល់បវារណា បានដល់ មិនស្គាល់បវារណា ៩ យ៉ាង ។

ពីរបទថា បវារណាកម្មំ ន ជានាតិ : មិនស្គាល់បវារណាកម្ម បានដល់ មិនស្គាល់បវារណាកម្ម ៤ យ៉ាង មានប្រភេទកម្មជាពួកដោយអធម៌ជាដើម ។

ពីរបទថា អាបត្តានាបត្តី ន ជានាតិ : មិនស្គាល់អាបត្តិនិងអនាបត្តិ បានដល់ មិនដឹងអាបត្តិនិងអនាបត្តិ ដែលទ្រង់សម្តែងក្នុងសិក្ខាបទនោះ ៗ ។

[២៤៦] ពីរបទថា អាបន្នោ កម្មកតោ : ភិក្ខុត្រូវហើយសង្ឃបានធ្វើកម្មរួចហើយ មានសេចក្តីថា ភិក្ខុត្រូវអាបត្តិហើយ, កម្មរមែងជាកិច្ចដែលសង្ឃធ្វើហើយ ព្រោះការត្រូវនោះជាបច្ច័យ ។

# កម្មរបស់ភិក្ខុមិនគួររម្ងាប់

[២៤៨] ពីរបទថា កម្មំ ន បដិប្បស្សម្ភេតព្វំ : សង្ឃមិនត្រូវរម្ងាប់កម្ម មានសេចក្តីថា កម្មរបស់ភិក្ខុនោះ ដែលសង្ឃមិនគប្បីឱ្យរម្ងាប់ ព្រោះហេតុដែលលោកប្រព្រឹត្ត ដោយបណ្តោយតាមបក្ខពួក, អធិប្បាយថា ដូចបុគ្គលដែលត្រូវចងឆ្នាក់ទុកដោយខ្សែ ដែលខ្លួននឹងគប្បីស្រាយចេញ ដូច្នោះ ។

# អង្គ ៥ របស់ភិក្ខុដែលចូលសង្គ្រាម

[២៤៩] ច្រើនបទថា សចេ ឧបាលិ សង្ឃោ សមគ្គ-ករណីយានិ កម្មានិ ករោតិ : ម្នាលឧបាលិ បើសង្ឃធ្វើកម្មទាំងឡាយ ដែលសង្ឃគប្បីធ្វើដោយសេចក្តីព្រមព្រៀងគ្នា មានសេចក្តីថា បើថា សង្ឃធ្វើកម្មមានឧបោសថជាដើម ដែលភិក្ខុទាំងឡាយអ្នកព្រមព្រៀងគ្នាគប្បីធ្វើ, ដែលឧបត្ថម្ភ (ដល់ការឈ្លោះ) ដែលភិក្ខុណា ៗ មិនគប្បីឱ្យក្នុងកាលកម្មសាមគ្គី មានឧបោសថ និងបវារណាជាដើម ត្រូវវៀរទុក ។ ក៏បើថា សង្ឃឱ្យសម្តែងទោសកន្លងហួសហើយ ធ្វើសង្ឃសាមគ្គីក្តី ធ្វើការរម្ងាប់អធិករណ៍ដោយតិណវត្ថារកវិន័យ ហើយធ្វើ

ឱភាសជនិងបរិវណភក្តិ, កម្មបែបនេះ ចាត់ជាកម្មដែលសង្ឃព្រមព្រៀងគប្បីធ្វើ ។

បទថា តត្រ ចេ : បើ...នោះ មានសេចក្តីថា បើថា ក្នុងកម្មបែបនោះ មិនពេញចិត្តដល់ភិក្ខុសោត, គប្បីធ្វើសេចក្តីឃើញជំទាស់ ក៏បាន យុំគ្រងសេចក្តីព្រមព្រៀងបែបនោះទុក ។ សេចក្តីកាន់ខុសយ៉ាងនោះ មិនគួរកាន់ទុក ។ ក៏ក្នុងកម្មណា ភិក្ខុទាំងឡាយសម្តែងព្រះសាសនាក្រៅធម៌វិន័យ ក្នុងកម្មនោះ មានការឃើញជំទាស់គ្នា យកជាការមិនបាន ព្រោះដូច្នោះ សង្ឃគប្បីហាម ហើយជៀសទៅ ។

## អង្គ ៥ របស់ភិក្ខុដែលពោលមិនជាទីស្រឡាញ់

[២៥០] បទថា ឱស្សិតមន្តី ច : ភិក្ខុនិយាយពាក្យប្រកបដោយលោភៈជាដើម ១ មានសេចក្តីថា អ្នកមានសេចក្តីប្រាថ្នាច្រើនច្រើនតែពោលវាចា ដែលគ្រាស់ដោយលោភៈ ទោសៈ និងមានះ មានវាចាកខ្វក់ មិនសម្តែងប្រយោជន៍ ។

បទថា និស្សិតជប្បី : ជាអ្នកពោលអាងអ្នកដទៃ ១ មានសេចក្តីថា មិនអាចនឹងពោលពាក្យឱ្យសមដល់សេចក្តី មានសេចក្តីដឹងច្រើន តាមធម្មតា របស់ខ្លួន ។ ដោយពិត រមែងអាងអ្នកដទៃ ពោល

យ៉ាងនេះថា "ព្រះរាជា បានត្រាស់នឹងយើងយ៉ាងនេះ, មហាអាមាត្រឯណោះ ពោលយ៉ាងនេះ, អាចារ្យ ឬឧបជ្ឈាយ៍របស់យើងឈ្មោះឯណោះ សម្តែងយ៉ាងនេះ, ព្រះថេរៈអ្នកទ្រទ្រង់ព្រះត្រៃបិដកនិយាយនឹងយើងយ៉ាងនេះ" ។

បទថា ន ច ភាសានុសន្ធិកុសលោ : ជាអ្នកមិនឈ្លាសក្នុងភាសា និង ការវិនិច្ឆ័យ ១ មានសេចក្តីថា ជាអ្នកមិនឆ្លាតក្នុងពាក្យដែលជាដំណារបស់រឿងរ៉ាវ និងក្នុងពាក្យដែលជាដំណារបស់ពាក្យវិនិច្ឆ័យ ។

ពីរបទថា ន យថាធម្មេ យថាវិនយេ : មិនឱ្យសមគួរតាមធម៌ សមគួរតាមវិន័យ មានសេចក្តីថា មិនជាអ្នកចោទជាស់តឿនឱ្យរលឹកដល់អាបត្តិ ដោយវត្ថុដែលពិត ។

ពីរបទថា ឧស្សាទេតា ហោតិ : ជាអ្នកអួតអាងសរសើរលើកបុគ្គលដទៃ មានសេចក្តីថា រមែងលើកអ្នកខ្លះឡើងអាង ដោយន័យជាដើមថា អាចារ្យរបស់ខ្ញុំ ជាអ្នកទ្រទ្រង់ព្រះត្រៃបិដកយ៉ាងច្រើន ជាធម្មកថិកដ៏កំពូល ។

វិនិច្ឆ័យក្នុងទុតិយបទ គប្បីជ្រាបដូច្នេះ ៖

រមែងរុករានមនុស្សខ្លះ ដោយន័យជាដើមថា គេនឹងដឹងអ្វី ។

ពីរបទថា អធម្មំ គណ្ហាតិ : ប្រកាន់យកហេតុដែលមិនមែនជា

និយ្យានិកធម៌ បានដល់ ប្រកាន់ធម៌ដែលជាចំណែកនាំចេញចាកទុក្ខ ។

ពីរបទថា ធម្មំ បដិពាហតិ : ឃាត់ហេតុដែលមិនមែនជានិយ្យានិកធម៌ បានដល់ ជំទាស់ធម៌ដែលជាចំណែកនាំចេញចាកទុក្ខ ។

ច្រើនបទថា សម្ផញ្ចុ ពហុំ ភាសតិ : និយាយពាក្យច្រើនឥតប្រយោជន៍ បានដល់ ពោលពាក្យដែលគ្មានប្រយោជន៍ជាន់ច្រើន ។

ច្រើនបទថា បសយ្ហ បវត្តា ហោតិ : ជាអ្នកនិយាយសង្កត់សង្កិន មានសេចក្ដីថា ជាអ្នកដែលព្រះសង្ឃថេរៈ មិនបានអារាធនាកាលភារៈដែលលោក មិនបានប្រគល់ឱ្យ អាស្រ័យសេចក្ដីប្រកាន់ខ្លួនតែម្យ៉ាង ឱ្យអាចពោលក្នុងកាលមិនមែនឱកាស ។

ពីរបទថា អនោកាសកម្មំ ការាបេត្វា : មិនបានសូមឱកាសជាមុន មានសេចក្ដីថា ជាអ្នកមិនឱ្យភិក្ខុដទៃឱ្យឱកាសជាមុនទេ ក៏ពោល ។

ច្រើនបទថា ន យថាទិដ្ឋិយា ព្យាកតា ហោតិ : មិនព្យាករដោយសមគួរតាមសេចក្ដីយល់របស់ខ្លួន មានសេចក្ដីថា ជាអ្នកមិនព្យាករណ៍អះអាងសេចក្ដីឃើញរបស់ខ្លួន ត្រឡប់ជាអ្នកវៀរសេចក្ដីឃើញ (របស់ខ្លួន)ចេញ មានសេចក្ដីឃើញថា ជាធម៌ជាដើម ក្នុងអធម៌ជាដើម ពោលមិនត្រង់តាមពិត ។

# អង្គរបស់ភិក្ខុដែលមិនគួរនិយាយក្នុងសង្ឃ

[២៥៣] ប្រើនបទថា អាបត្តិយា បយោគំ ន ជានាតិ : មិនស្គាល់ប្រយោគរបស់អាបត្តិ បានដល់ មិនដឹងថា អាបត្តិនេះ ជាកាយប្រយោគ, អាបត្តិនេះជាវចីប្រយោគ ។

ប្រើនបទថា អាបត្តិយា វូបសមំ ន ជានាតិ : មិនស្គាល់ការរម្ងាប់អាបត្តិ បានដល់ មិនដឹងថា អាបត្តិនេះ រម្ងាប់ដោយការសម្តែង, អាបត្តិនេះ រម្ងាប់ដោយការចេញ, អាបត្តិនេះ មិនរម្ងាប់ដោយការសម្តែង មិនរម្ងាប់ដោយការចេញ ។

ប្រើនបទថា ន អាបត្តិយា វិនិច្ឆយកុសលោ ហោតិ : មិនឈ្លាសក្នុងការវិនិច្ឆ័យអាបត្តិ បានដល់ មិនដឹងថា អាបត្តិនេះ មានក្នុងវត្ថុនេះ គឺ មិនអាចដើម្បីលើកអាបត្តិឡើងអះអាងតាមសមគួរដល់ទោស ។

ពីរបទថា អធិករណសមុដ្ឋានំ ន ជានាតិ : មិនស្គាល់សមុដ្ឋាននៃអធិករណ៍ បានដល់ មិនដឹងថា អធិករណ៍នេះ អាស្រ័យភេទករវត្ថុ ១៨ តាំងឡើង, អធិករណ៍នេះ អាស្រ័យវិបត្តិ ៤ តាំងឡើង, អធិករណ៍នេះ អាស្រ័យកងអាបត្តិ ៥ ឬ ៧ តាំងឡើង, អធិករណ៍នេះ អាស្រ័យសង្ឃកិច្ច ៤ យ៉ាងតាំងឡើង ។

ពីរបទថា បយោគំ ន ជានាតិ : មិនស្គាល់ប្រយោគ បាន

ដល់ មិនដឹងថា អធិករណ៍នេះ មានប្រយោគជាខាងដើម ១២, អធិករណ៍នេះ មានប្រយោគជាខាងដើម ១៤, អធិករណ៍នេះ មានប្រយោគជាខាងដើម ៦, អធិករណ៍ នេះ មានប្រយោគជាខាងដើម ១, អធិប្បាយថា ពិតមែន ខាងដើមតាមដែលជារបស់ខ្លួនទុំះឯង នៃអធិករណ៍ទាំងឡាយ ចាត់ជាប្រយោគ, មិនស្គាល់ប្រយោគសូម្បីទាំងពួននោះ ។

ពីរបទថា វូបសមំ ន ជានាតិ **:** មិនស្គាល់ការរម្ងាប់ បានដល់ មិនដឹងថា "អធិករណ៍នេះ រម្ងាប់ដោយសមថ: ២, អធិករណ៍នេះរម្ងាប់ដោយសមថ: ៤, អធិករណ៍នេះ រម្ងាប់ដោយសមថ: ៣, អធិករណ៍នេះ រម្ងាប់ដោយសមថ: ១" ។

ច្រើនបទថា ន អធិករណស្ស វិនិច្ឆយកុសលោ ហោតិ **:** មិនឈ្លាសក្នុងការវិនិច្ឆ័យអធិករណ៍ បានដល់ មិនដឹងដើម្បីវិនិច្ឆ័យអធិករណ៍ឱ្យដល់សេចក្តីរម្ងាប់ ។

ពីរបទថា កម្មំ ន ជានាតិ **:** មិនស្គាល់កម្ម បានដល់ មិនស្គាល់កម្ម ៧ យ៉ាង មានតជ្ជនីយកម្មជាដើម ។

ច្រើនបទថា កម្មស្ស ករណំ ន ជានាតិ **:** មិនស្គាល់ការធ្វើកម្ម បានដល់ មិនដឹងថា កម្មនេះ គួរធ្វើដោយឧបាយនេះ ។

ច្រើនបទថា កម្មស្ស វត្ថុំ ន ជានាតិ : មិនស្គាល់វត្ថុរបស់កម្ម បានដល់ មិនដឹងថា នេះជាវត្ថុនៃតជ្ជនីយកម្ម, នេះជាវត្ថុនៃនិយស្សកម្មជាដើម ។

ច្រើនបទថា កម្មស្ស វត្ថុំ ន ជានាតិ : មិនស្គាល់វត្ថុរបស់កម្ម បានដល់ មិនស្គាល់វត្ថុ ១៨ ប្រការនៃកម្ម ៤ ក្នុងកាលក្រោយក្នុងកម្ម ៧ ប្រភេទ និងវត្ថុ ៤៣ ប្រការនៃឧក្ខេបនីយកម្ម ៣ យ៉ាង ។

ច្រើនបទថា កម្មស្ស វូបសមំ ន ជានាតិ : មិនស្គាល់ការរម្ងាប់របស់កម្ម បានដល់ មិនដឹងថា ភិក្ខុណាប្រព្រឹត្តវត្តហើយសូម កម្មរបស់ភិក្ខុនោះ ដែល

សង្ឃគួររម្ងាប់, ទោសដែលសង្ឃគប្បីឱ្យសម្ដែង ។

ពីរបទថា វត្ថុំ ន ជានាតិ : មិនស្គាល់វត្ថុ បានដល់ មិនស្គាល់វត្ថុនៃកងអាបត្តិ ៧ កង ។

ពីរបទថា និទានំ ន ជានាមិ : មិនស្គាល់និទាន គឺរឿងរ៉ាវដែលទ្រង់បញ្ញត្តសិក្ខាបទ បានដល់ មិនដឹងថា សិក្ខាបទនេះ ព្រះមានព្រះភាគទ្រង់បញ្ញត្តិក្នុងនគរនេះ សិក្ខាបទនេះ ទ្រង់បញ្ញត្តិក្នុងនគរនោះ ។

ពីរបទថា បញ្ញត្តឹ ន ជានាតិ : មិនស្គាល់បញ្ញត្តិ បានដល់ មិនស្គាល់បញ្ញត្តិទាំងបីយ៉ាង ដោយអំណាចបញ្ញត្តិ អនុប្បញ្ញត្តិ

អនុប្បន្នប្បញ្ញត្តិ ។

ពីរបទថា **បទបច្ឆាភដ្ឋំ ន ជានាតិ : មិនស្គាល់សេចក្ដីខាងចុងខាងដើមបទ** បានដល់ មិនស្គាល់បទដែលគួរចាត់ទុកខាងមុខ គឺកាលខ្វនគួរនឹងពោលថា ពុទ្ធោ ភគវា ត្រឡប់ប្រកបឱ្យផ្លាស់មុខ ផ្លាស់ក្រោយចេញ ថា ភគវា ពុទ្ធោ វិញ ។

ប្រើនបទថា **អកុសលោ ច ហោតិ វិនយេ : មិនឈ្លាសក្នុងវិន័យ** បានដល់ ជាអ្នកមិនឆ្លាស ក្នុងបាលី និងអដ្ឋកថានៃព្រះវិន័យ ។

ប្រើនបទថា **ញត្តឹ ន ជានាតិ : មិនស្គាល់ញត្តិ** មានសេចក្ដីថា ក៏ដោយសង្ខេប ញត្តិមាន ២ យ៉ាង គឺ ញត្តិដែលសម្ដែងយ៉ាងនេះថា ឯសា ញត្តិ ១ ញត្តិដែលមិនសម្ដែង ១ ។ ក្នុងញត្តិ ២ យ៉ាងនោះ ញត្តិណា មិនសម្ដែងយ៉ាងនោះ, ញត្តិនោះ ចាត់ជាកម្មញត្តិ ។ ញត្តិណា សម្ដែង, ញត្តិនោះ ចាត់ជាកម្មបាទញត្តិ, មិនស្គាល់ញត្តិនោះដោយប្រការទាំងពួង ។

ប្រើនបទថា **ញត្តិយា ករណំ ន ជានាតិ : មិនស្គាល់ការធ្វើដោយញត្តិ** បានដល់ មិនស្គាល់ការធ្វើកម្មញត្តិ ក្នុងស្ថាន ៩, មិនស្គាល់ការធ្វើកម្មបាទញត្តិ ក្នុងស្ថាន ២ ។

ពីរបទថា ញត្តិយា អនុស្សាវនំ : មិនស្គាល់វិធីសូធ្យដោយញត្តិ បានដល់ មិនដឹងថា ញត្តិនេះ មានអនុស្សាវនា ១ ញត្តិនេះ មានអនុស្សាវនា ៣ ។

ច្រើនបទថា ញត្តិយា សមថំ ន ជានាតិ : មិនស្គាល់សមថៈដោយញត្តិ មានសេចក្តីថា សមថៈ ៤ យ៉ាងនេះណា គឺ សតិវិន័យ អមូឡ្ហវិន័យ តស្សបាបិយសិកា តិណវត្ថារកៈ មិនវៀរចាកញត្តិ, មិនស្គាល់សមថៈនោះថា រម្ងាប់ដោយញត្តិ ។

ច្រើនបទថា ញត្តិយា វូបសមំ ន ជានាតិ : មិនស្គាល់ការរម្ងាប់ញត្តិ មានសេចក្តីថា អធិករណ៍ណារម្ងាប់ដោយញត្តិ សមថៈ ៤ យ៉ាងនេះ មិនស្គាល់សេចក្តីរម្ងាប់នោះនៃអធិករណ៍នោះថា សេចក្តីរម្ងាប់នេះ ធ្វើដោយញត្តិ ។

ពីរបទថា សុត្តំ ន ជានាតិ : មិនចេះសុត្តៈ បានដល់ មិនស្គាល់ឧភតោវិភង្គ ។

ពីរបទថា សុត្តានុលោមំ ន ជានាតិ : មិនចេះសុត្តានុលោម បានដល់ មិនស្គាល់មហាបទេស ៤ ។

ពីរបទថា វិនយំ ន ជានាតិ : មិនចេះវិន័យ បានដល់ មិនស្គាល់ខន្ធកៈ និងបរិវារៈ ។

ពីរបទថា វិនយានុលោមំ ន ជានាតិ : មិនចេះវិនយានុលោម បានដល់ មិនស្គាល់មហាបទេសទាំង ៤ ។

ពីរបទថា ន ច ឋានាឋានកុសលោ : មិនឈ្លាសក្នុងហេតុដែលគួរនិងមិនគួរ១ បានដល់ ជាអ្នកឆ្លាតក្នុងហេតុ និងមិនមែនហេតុ ។

ពីរបទថា ធម្មំ ន ជានាតិ : មិនចេះធម៌ បានដល់ មិនស្គាល់បិដក ២ ដ៏សេសក្រៅអំពីវិន័យបិដក ។

ពីរបទថា ធម្មានុលោមំ ន ជានាតិ : មិនចេះធម្មានុលោម បានដល់ មិនស្គាល់មហាបទេស ៤ ផ្នែកសុត្តន្តៈ ។

ពីរបទថា វិនយំ ន ជានាតិ : មិនចេះវិន័យ បានដល់ មិនស្គាល់ខន្ធកៈ និងបរិវារៈទាំង ៤ ។

ពីរបទថា វិនយានុលោមំ ន ជានាតិ : មិនចេះវិនយានុលោម បានដល់ មិនស្គាល់មហាបទេស ៤ ។

ក៏ឧភតោវិភង្គ ជាការដែលលោកមិនសង្គ្រោះ ក្នុងសេចក្តីថា មិនស្គាល់ វិន័យ ព្រោះហេតុនោះ ពាក្យណាដែលលោកពោលទុកក្នុងកុរុន្ទីថា បទថា វិនយំ បានដល់ មិនស្គាល់វិន័យបិដកទាំងអស់ពាក្យនោះគួរកាន់យក ។

ពីរបទថា ន ច បុព្វាបរកុសលោ ហោតិ ៖ មិនឈ្លាសក្នុងពាក្យខាងដើមនិងពាក្យខាងចុង បានដល់ ជាអ្នកមិនឆ្លាតក្នុងពាក្យដើមនិងពាក្យក្រោយ ។

ពាក្យដ៏សេសក្នុងបទទាំងពួងរាប់ថា ងាយយល់ទាំងអស់ ព្រោះជាពាក្យដែលគួរជ្រាបដោយបដិបក្ខន័យចំពោះពាក្យដែលពោលហើយ និងព្រោះជាពាក្យដែលបានបើកបង្ហាញហើយក្នុងកាលមុន ដូច្នេះឯង ។

ចប់ពណ៌នា នប្បដិប្បស្សម្ភនវគ្គ និងវោហារវគ្គ ។

## ធ្វើសេចក្តីឃើញជំទាស់គ្នា

[២៥៥] វិនិច្ឆ័យក្នុងទិដ្ឋាវិកម្មវគ្គ គប្បីជ្រាបដូច្នេះ ៖

ការធ្វើសេចក្តីឃើញឱ្យច្បាស់ ឈ្មោះថា ការធ្វើសេចក្តីយល់ឃើញឱ្យ ជាក់ច្បាស់ ។

ពាក្យថា ទិដ្ឋាវិកម្ម ៖ ប្រាប់សេចក្តីយល់ឃើញ នេះ ជាឈ្មោះរបស់វិន័យកម្ម ពោលគឺ ការសម្តែងអាបត្តិដែលប្រកាសលទ្ធិ ។

បទថា អនាបត្តិយា ទិដ្ឋឹ អាវិករោតិ ៖ ប្រាប់សេចក្តីយល់ឃើញ ដោយមិនមានអាបត្តិ មានសេចក្តីថា សម្តែងអនាបត្តិពិត ៗ ថាជាអាបត្តិ ។

បទថា អទេសនាគាមិនិយា : មិនមែនជាទេសនាគាមិនី បានដល់ ធ្វើសេចក្ដីឃើញ ទាស់ក្នុងគរុកាបត្តិ អធិប្បាយថា សម្ដែងអាបត្តិសង្ឃាទិសេស និងបារាជិក ។

បទថា ទេសិតាយ : ដែលសម្ដែងហើយ បានដល់ ធ្វើសេចក្ដីយល់ឃើញ សូម្បីក្នុងលហុកាបត្តិដែលសម្ដែងហើយ, អធិប្បាយថា សម្ដែងអាបត្តិដែលសម្ដែងហើយដដែលទៀត ។

ពីរបទថា ចតូហិ បញ្ចហិ ទិដ្ឋី[១] : សេចក្ដីយល់ឃើញជាមួយនឹងភិក្ខុ ៤ រូប ៥ រូប បានដល់ ធ្វើសេចក្ដីយល់ឃើញ ដូចភិក្ខុ ៤-៥ រូប ដែលធ្វើសេចក្ដីយល់ឃើញជាមួយគ្នា, អធិប្បាយថា ៤-៥ រូប សម្ដែងអាបត្តិព្រមគ្នា ។

បទថា មនោមានសេន : ដោយគិតតែក្នុងចិត្ត មានសេចក្ដីថា ធ្វើសេចក្ដីឃើញច្បាស់ដោយនឹកទុកក្នុងចិត្ត ពោលគឺ គិតទុក បានដល់ សម្ដែងអាបត្តិដោយចិត្តប៉ុណ្ណោះ មិនបានបញ្ចេញវាចាទេ ។

បទថា នានាសំវាសកស្ស : មានសំវាសផ្សេងគ្នា មានសេចក្ដីថា ធ្វើសេចក្ដីយល់ឃើញ គឺសម្ដែងអាបត្តិ ក្នុងសំណាក់ភិក្ខុដែលមានសំវាសផ្សេងគ្នាដោយលទ្ធិ ឬភិក្ខុដែលមានសំវាសផ្សេងគ្នាដោយកម្ម ។

---

១. ថៃ : មិនមានពាក្យថា ទិដ្ឋី ។

បទថា នានាសីមាយ : ក្នុងសីមាផ្សេងគ្នា មានសេចក្ដីថា ធ្វើសេចក្ដីយល់ឃើញ ក្នុងសំណាក់ភិក្ខុសូម្បីជាសមានសំវាស តែតាំងនៅក្នុងសីមាផ្សេង ។ ពិតមែន ការដែលភិក្ខុតាំងនៅក្នុងមាឡកសីមា សម្ដែងអាបត្តិដល់ភិក្ខុដែលតាំងនៅក្នុងសីមន្តរិកក្ដី ការដែលភិក្ខុតាំងនៅក្នុងសីមន្តរិកសម្ដែងអាបត្តិដល់ភិក្ខុ សូម្បីឋិតនៅក្នុងអវិប្បវាសសីមាក្ដី មិនគួរ ។

បទថា អបកតត្តស្ស : មិនមែនជាបកតត្ត មានសេចក្ដីថា សម្ដែងក្នុងសំណាក់នៃភិក្ខុដែលសង្ឃលើកវត្ត ឬភិក្ខុដែលត្រូវសង្ឃវៀរឧបោសថ និងបវារណាចេញ ។

## ឱកាសកម្ម

[២៦០] ច្រើនបទថា ឆាលំ ឱកាសកម្មំ កាតុំ : មិនគួរភិក្ខុដទៃបើកឱកាសកម្មឱ្យ មានសេចក្ដីថា មិនគួរដើម្បីធ្វើ, អធិប្បាយថា ដែលភិក្ខុមិនគប្បីធ្វើ ។

ភិក្ខុដែលសង្ឃលើកវត្ត និងភិក្ខុដែលត្រូវសង្ឃវៀរឧបោសថ និងបវារណា ឈ្មោះថា ភិក្ខុមិនមែនជាបកតត្ត សូម្បីក្នុងឱកាសកម្មនេះ ។

បទថា ចាវនាធិប្បាយោ : ដោយប្រាថ្នាដើម្បីឱ្យភិក្ខុដទៃឃ្លាតបានដល់ អ្នកប្រាថ្នានឹងឱ្យឃ្លាតចាកសាសនា ។

## សួរបញ្ហា

[២៦២] ពីរបទថា **មន្ទត្តា មោមូហត្តា :** ដោយសេចក្ដីល្ងង់វង្វេង មានសេចក្ដីថា ព្រោះជាអ្នកល្ងង់ ព្រោះជាអ្នកវង្វេងល្ងង់ ទើបមិនអាចពន្យល់ និងមិនអាចដឹង និងប្រកាសខ្លួនជាអ្នកល្ងង់តែម៉្យាងប៉ុណ្ណោះ ទើបសួរដូចមនុស្សឆ្កួត ។

បទថា **ទាបិច្ចោ :** មានសេចក្ដីប្រាថ្នាលាមក បានដល់ សួរដោយសេចក្ដីប្រាថ្នាលាមកថា "ពួកជននឹងសរសើរយើង ដោយឧបាយយ៉ាងនេះ" ។

បទថា **បរិភវា :** ដោយសេចក្ដីមើលងាយគេ បានដល់ ជាអ្នកប្រាថ្នានឹងលើកសេចក្ដីមើលងាយ ទើបសួរ ។ សូម្បីក្នុងអញ្ញព្យាករណ៍ក៏មានន័យដូចគ្នា ។

ពាក្យដ៏សេសក្នុងបទទាំងពួង ងាយយល់ទាំងអស់ ដូច្នេះឯង ។

ទិដ្ឋាវិកម្មវគ្គវណ្ណនា ចប់

ពាក្យណាដែលនឹងគប្បីពោលក្នុងអត្តាទានវគ្គ និងធុតង្គវគ្គ, ពាក្យទាំងអស់នោះ បានពោលហើយក្នុងកាលមុននុ៎ះឯង ។

# អធិប្បាយមុសាវាទ

[២៧៦] វិនិច្ឆ័យក្នុងមុសាវាទវគ្គ គប្បីជ្រាបដូច្នេះ ៖

មុសាវាទដែលចាត់ជាបារាជិកគាមី ព្រោះអត្ថថា ដល់បារាជិក, អធិប្បាយថា ដល់ភាពជាអាបត្តិបារាជិក ។ សូម្បីក្នុងមុសាវាទក្រៅនេះ ក៏មានន័យដូចគ្នា ។

ក្នុងមុសាវាទ ៥ យ៉ាងនោះ មុសាវាទដែលប្រព្រឹត្តទៅដោយការអួតឧត្តរិមនុស្សធម្មដែលមិនមាន (ក្នុងខ្លួន) ជាបារាជិកគាមី, មុសាវាទដែលប្រព្រឹត្តទៅដើម្បីតាមកម្ចាត់ ដោយបារាជិកមិនមានមូល ជាសង្ឃាទិសេសគាមី, មុសាវាទដែលភិក្ខុពោល (អួតឧត្តរិមនុស្សធម្មដែលមិនមាន) ដោយបរិយាយដល់បុគ្គល ដែលបានយល់សេចក្តីជាដើមថា "ភិក្ខុណា នៅក្នុងវិហាររបស់លោក" ជាថុល្លច្ច័យគាមី, មុសាវាទដែលភិក្ខុពោលដោយបរិយាយដល់បុគ្គលដែលមិនយល់សេចក្តីជាទុក្កដគាមី, មុសាវាទដែលមកថា ភិក្ខុពោលពាក្យកុហកដោយដឹងខ្លួនត្រូវអាបត្តិបាចិត្តិយ; គប្បីជ្រាបថា ជាបាចិត្តិយគាមី ។

# អាការជាហេតុត្រូវអាបត្តិ

[២៧៩] បទថា អទស្សនេន : ដោយអាការមិនឃើញ បានដល់ មិនឃើញព្រះវិន័យធរ ។ ពិតមែន ភិក្ខុកាលកើតសេចក្ដីរង្កៀសក្នុងរបស់ដែលគួរ និងមិនគួរឡើង បានជួបព្រះវិន័យធរហើយ សាកសួរដល់សេចក្ដីដែលជារបស់គួរនិងមិនគួរហើយ ទើបគប្បីលះរបស់ដែលមិនគួរចេញ ធ្វើតែរបស់គួរ តែកាលមិនជួបព្រះវិន័យធរនោះ សូម្បីធ្វើនូវវត្ថុដែលមិនគួរ ដោយសម្គាល់ថា គួរ ក៏រមែងត្រូវអាបត្តិ ។ អាបត្តិដែលគប្បីត្រូវដោយអាការយ៉ាងនេះ ភិក្ខុមិនត្រូវ ព្រោះជួបព្រះវិន័យធរ, ត្រូវព្រោះមិនជួបប៉ុណ្ណោះ ។ ដោយហេតុនោះ ព្រះមានព្រះភាគ ទើបត្រាស់ថា ព្រោះមិនឃើញ ។

បទថា អស្សវនេន : ដោយអាការមិនឮ មានសេចក្ដីថា ដែលភិក្ខុនៅ សូម្បីក្នុងវិហារជាមួយគ្នា ទៅកាន់ទីបម្រើរបស់ព្រះវិន័យធរ មិនសួរដល់វត្ថុដែលគួរ និងមិនគួរ ឬមិនស្ដាប់វត្ថុដែលគួរ និងមិនគួរដែលលោកពោលដល់ភិក្ខុពួកដទៃ រមែងត្រូវអាបត្តិពិត ។ ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា ព្រោះមិនស្ដាប់ ។

បទថា បសុត្តកតា : ដោយដេកលក់ បានដល់ ព្រោះជាអ្នកលង់លក់ ។ ពិតមែន ភិក្ខុរមែងត្រូវអាបត្តិ ព្រោះសិងក្នុងផ្ទះរួមគ្នា

ព្រោះជាអ្នកដេកលក់ក៏បាន ។

មួយទៀត ភិក្ខុកាលត្រូវអាបត្តិ ព្រោះសម្គាល់ថា គួរ ក្នុងរបស់ដែលមិនគួរ ឈ្មោះថា មានសេចក្ដីសម្គាល់នោះ ត្រូវអាបត្តិ ។

ព្រោះភ្លេចសតិ ភិក្ខុរមែងត្រូវអាបត្តិ ដែលត្រូវដោយអំណាចនៃហេតុមានការកន្លងរាត្រី ១ ជាដើម ។

ពាក្យដ៏សេសក្នុងបទទាំងពួង ងាយយល់ទាំងអស់ ដូច្នេះឯង ។

មុសាវាទវគ្គ វណ្ណនា ចប់

## អង្គជាហេតុដាក់ទោស

វិនិច្ឆ័យក្នុងឱវាទវគ្គ គប្បីជ្រាបដូច្នេះ ៖

[២៨៥] បទថា អលាភាយ : មិនឱ្យបានលាភ បានដល់ដើម្បីប្រយោជន៍ដល់ការមិនបានបច្ច័យ ៤, អធិប្បាយថា ភិក្ខុរមែងខ្វល់ខ្វាយ គឺ ព្យាយាម ដោយប្រការដែលភិក្ខុទាំងឡាយមិនបានបច្ច័យ ។

បទថា អត្ថាយ : មិនឱ្យមានប្រយោជន៍ បានដល់ ខ្វល់ខ្វាយប្រាប់ដំណឹងដែលឱ្យទោស បង្កឱ្យកើតសេចក្ដីវិនាស ។

បទថា អនាវាសាយ : មិនឱ្យមានទីលំនៅ បានដល់ ដើម្បីត្រូវ

ការមិនឱ្យនៅ, អធិប្បាយថា ដើម្បីត្រូវការកម្ចាត់ចេញចាកគាមខេត្តជាទីនៅ ។

បទថា សម្បយោជេតិ : ជេរគម្រាម បានដល់ និយាយដឹកនាំដើម្បីប្រយោជន៍ដល់ការសេពអសទ្ធម្ម ។

[២៨៦] ព្រះឧបាលីថេរៈសំដៅយកកម្ម ៧ យ៉ាងណាមួយ ទើបទូលសួរថា "បពិត្រព្រះអង្គដ៏ចម្រើន សង្ឃត្រូវធ្វើកម្មដល់ភិក្ខុនី ដែលប្រកបដោយអង្គប៉ុន្មាន"

[២៨៩] បទថា ន សាកច្ឆាតព្វោ : មិនត្រូវសាកច្ឆា មានសេចក្តីថា មិនគួរពោលរឿងរ៉ាវដែលផ្សេងដោយរឿងគួរមិនគួរកំណត់នាមរូប សមថៈ និងវិបស្សនាជាដើម ។ ក៏ព្រោះហេតុដែលភិក្ខុជាវិញ្ញូណាស្រេពមិនក្លែងពោលឱ្យខុសទេ លោកជាម្ចាស់របស់រឿងរ៉ាវនោះ ភិក្ខុក្រៅពីនោះ មិនបានជាម្ចាស់របស់រឿងទេ ដូច្នោះ ព្រះមានព្រះភាគទើបទ្រង់ហាមក្នុងបញ្ចកៈទី ១ ថា នាសេក្ខេន ហើយត្រាស់ក្នុងបញ្ចកៈទី ២ ថា អសេក្ខេន ជាដើម ។

បទថា ន អត្ថប្បដិសម្ភិទប្បត្តោ : មិនទាន់ដល់អត្ថបដិសម្ភិទា មានសេចក្តីថា ជាអ្នកសម្រេចបដិសម្ភិទា គឺ ជាអ្នកសម្រេចញាណដែលដល់សេចក្តីបែកធ្លាយក្នុងអដ្ឋកថា ក៏ទេ ។

បទថា ន ធម្មប្បដិសម្ភិទប្បត្តោ ៖ មិនទាន់ដល់ធម្មប្បដិសម្ភិទា មានសេចក្តីថា ជាអ្នកសម្រេចញាណដែលបែកធ្លាយ ក្នុងធម៌គឺ បាលី ក៏ទេ ។

បទថា ន និរុត្តិប្បដិសម្ភិទប្បត្តោ ៖ មិនទាន់ដល់និរុត្តិប្បដិសម្ភិទា មានសេចក្តីថា ជាអ្នកសម្រេចញាណដែលបែកធ្លាយក្នុងភាសា គឺវោហារដែលទឹងគប្បីពោល ក៏ទេ ។

បទថា ន បដិភាណបដិសម្ភិទប្បត្តោ ៖ មិនទាន់ដល់បដិភាណប្បដិសម្ភិទា មានសេចក្តីថា មិនបានជាអ្នកសម្រេចសេចក្តីបែកធ្លាយក្នុងញាណទាំងឡាយ មានអត្ថប្បដិសម្ភិទាញាណជាដើម ដែលរាប់ថា បដិភាណ (គឺវាងវៃ) ។

ពីរបទថា យថាវិមុត្តំ ចិត្តំ[១] ន បច្ចវេក្ខតិ ៖ ពិចារណានូវចិត្តដែលរួចហើយចាកកិលេសយ៉ាងណា មានសេចក្តីថា ជាអ្នកមិនបានប្រើសតិគ្រៀងពិចារណា ១៩ ប្រភេទ ពិចារណាចិត្តតាមដែលរួចផុតហើយ ដោយអំណាចផលវិមុត្តិ ៤ យ៉ាង ។

ពាក្យដ៏សេសក្នុងបទទាំងពួង ងាយយល់ទាំងអស់ ដូច្នេះឯង ។

ឱវាទវគ្គវណ្ណនា ចប់

១. ថៃ. មិនមានពាក្យថា ចិត្តំ នេះទេ ។

## អង្គនៃភិក្ខុដែលគួរដល់ឧព្វាហិកា

[២៩១] វិនិច្ឆ័យក្នុងឧព្វាហិកវគ្គ គប្បីជ្រាបដូច្នេះ ៖

បទថា **ន អត្ថកុសលោ : មិនឈ្លាសក្នុងអដ្ឋកថា** បានដល់ ជាអ្នកមិនឆ្លាតក្នុងអដ្ឋកថា គឺជាអ្នកមិនវាងវៃក្នុងការទាញសេចក្តីមកពន្យល់ ។

បទថា **ន ធម្មកុសលោ : មិនឈ្លាសក្នុងបាលី** បានដល់ ជាអ្នកមិនឆ្លាតក្នុងបាលី គឺ ជាអ្នកមិនអាចហ៊ានក្នុងបាលី ព្រោះមិនរៀនតពីអាចារ្យ ។

បទថា **ន និរុត្តិកុសលោ : មិនឈ្លាសក្នុងភាសា** បានដល់ ជាអ្នកមិនឆ្លាតក្នុងការពោលដោយភាសាដទៃ ។

បទថា **ន ព្យញ្ជនកុសលោ : មិនឈ្លាសក្នុងព្យញ្ជនៈ** មានសេចក្តីថា ជាអ្នកមិនឆ្លាតក្នុងការប្រើព្យញ្ជនៈឱ្យមូល ជាប់ដោយសិថិលនិងធនិតជាដើម អធិប្បាយថា ជាអ្នកមិនស្ទាត់ជំនាញក្នុងក្បួនអក្សរ ។

បទថា **ន បុព្វាបរកុសលោ : មិនឈ្លាសក្នុងពាក្យខាងដើមនិងខាងចុង** បានដល់ ជាអ្នកមិនឆ្លាតក្នុងខាងដើម និងខាងចុងនៃអត្ថ ក្នុងខាងដើមនិងខាងចុងនៃធម៌ ក្នុងខាងដើមនិងខាងចុងនៃនិរុត្តិ ក្នុងខាងដើមនិងខាងចុងនៃព្យញ្ជនៈ និងក្នុងពាក្យដើមនិងពាក្យក្រោយ ។

បទទាំងឡាយមានបទថា កោធនោ ជាដើម ព្រះមានព្រះភាគត្រាស់ហើយ ព្រោះមានហេតុដែលភិក្ខុមានសេចក្ដីក្រោធជាដើម គ្របសង្កត់ហើយ រមែងមិនស្គាល់ហេតុ និងមិនមែនហេតុ មិនអាចនឹងកាត់សេចក្ដីបាន ។

ប្រើនបទថា អបសាទេតា ហោតិ នោ សារេតា : ជាអ្នកមិនឱ្យគេរលឹកឃើញ មិនរលឹកស្មារតី មានសេចក្ដីថា ជាអ្នកឱ្យល្ងង់ គឺមិនដាស់តឿនឱ្យកើតសតិឡើង, អធិប្បាយថា មិនបើកបង្ហាញ គឺ បិទបាំងពាក្យរបស់អ្នកចោទ និងអ្នកជាប់ចោទ មិនដាស់តឿនឱ្យរលឹក ។

ពាក្យដ៏សេសក្នុងឧព្វាហិកវគ្គនេះ ងាយយល់ទាំងអស់នោះឯង ។

ឧព្វាហិកវគ្គវណ្ណនា ចប់

## អ្នកមានចិត្តធ្ងន់

វិនិច្ឆ័យក្នុងអធិករណរូបសមវគ្គ គប្បីជ្រាបដូច្នេះ ៖

[២៩៤] ពីរបទថា បុគ្គលគរុ ហោតិ : ជាអ្នកធ្ងន់ក្នុងបុគ្គល មានសេចក្ដីថា ភិក្ខុដែលគិតដល់ហេតុថា អ្នកនេះជាឧបជ្ឈាយ៍របស់យើង, អ្នកនេះជាអាចារ្យរបស់យើង ដូច្នេះជាដើម ប្រាថ្នាសេចក្ដីឈ្នះ

ដល់បុគ្គលនោះ ទើបសម្តែងអធម៌ថា ជាធម៌ ។

ពីរបទថា សង្ឃគរុ ហោតិ : ជាអ្នកធ្ងន់ក្នុងសង្ឃ មានសេចក្តីថា កាលវិនិច្ឆ័យ មិនលះធម៌និងវិន័យចេញ រមែងជាអ្នកឈ្មោះថា ធ្ងន់ក្នុងសង្ឃ ។

កាលកាន់យកបច្ច័យមានចីវរជាដើមវិនិច្ឆ័យ រមែងជាអ្នកឈ្មោះថា ធ្ងន់ក្នុងអាមិស ។

កាលមិនកាន់យកបច្ច័យមានចីវរជាដើមទាំងនោះ វិនិច្ឆ័យតាមធម៌ រមែងជាអ្នកឈ្មោះថា ធ្ងន់ក្នុងព្រះសទ្ធម្ម ។

## សង្ឃភេទ

[២៩៥] ប្រើនបទថា បញ្ចហុបាលិ[១] អាការេហិ : ម្នាលឧបាលិ ដោយអាការ៥ មានសេចក្តីថា សង្ឃរមែងបែកគ្នា ព្រោះហេតុ៥ ។

វិនិច្ឆ័យក្នុងពាក្យថា កម្មេន ឧទ្ទេសេន វោហរន្តោ អនុស្សាវនេន សលាកគ្គាហេន : ដោយកម្ម ដោយឧទ្ទេស ដោយសម្តែងភេទករវត្ថុ ១៨ យ៉ាង ដោយអនុស្សាវនៈ ដោយប្រគល់ស្លាក នេះ គប្បីជ្រាបដូច្នេះ ៖

១. បញ្ចហិ ឧបាលិ ។

បទថា កម្មេន : ដោយកម្ម បានដល់ កម្មយ៉ាងណាមួយ ក្នុងកម្ម ៤ យ៉ាងមានអបលោកនកម្មជាដើម ។

បទថា ឧទ្ទេសេន : ដោយឧទ្ទេស បានដល់ ឧទ្ទេសយ៉ាងណាមួយ ក្នុងបាតិមោក្ខុទ្ទេស ៥ ។

បទថា វោហារន្តោ : ដោយសម្តែង បានដល់ ចន្លុលបង្ហាញ គឺពោល, អធិប្បាយថា សម្តែងរឿងបង្កហេតុឱ្យបែកគ្នា ១៨ យ៉ាង មានសម្តែងអធម៌ថា ធម៌ជាដើម ព្រោះឧប្បត្តិហេតុទាំងនោះ ៗ ។

បទថា អនុស្សាវនេន : ដោយអនុស្សាវនៈ បានដល់ ការថ្លែងវាចាប្រកាសជិតត្រចៀក ដោយន័យជាដើមថា "ពួកលោកដឹងទេថា យើងចេញបួសពីត្រកូលខ្ពស់ និងថា យើងជាពហុស្សូត, គួរដល់ពួកលោកដែរឬ" ដែលញ៉ាំងគំនិតឱ្យកើតឡើងថា "បុគ្គលដូចជាយើងនេះ នឹងគប្បីឱ្យកាន់យកសត្ថុសាសនាក្រៅធម៌ ក្រៅវិន័យអ៊ីចឹងឬ, អវិចីសម្រាប់យើងនឹងត្រជាក់ដូចស្រះឈូកខៀវ មែនឬ ? យើងនឹងមិនខ្លាចអបាយទេឬ ?" ។

បទថា សលាកគ្គាហេន : ដោយប្រគល់ស្លាក បានដល់ ការដែលប្រកាសយ៉ាងនោះ ទប់ចិត្តរបស់ភិក្ខុទាំងនោះ ធ្វើឱ្យជាអ្នកមិនវិលត្រឡប់ជាប្រក្រតីហើយ ឱ្យចាប់ស្លាកថា "ពួកលោកចូរចាប់ស្លាកនេះ" ។

ក៏ក្នុងអាការ ៥ យ៉ាងនេះ កម្មប៉ុណ្ណោះ ឬឧទ្ទេស ជាប្រមាណ ។ ចំណែកការសួធ្យប្រកាសនិងការឱ្យចាប់ស្លាក ជាចំណែកខាងដើម ។ ពិតមែន កាលសួធ្យប្រកាសដោយអំណាចសម្តែងរឿង ១៨ ប្រការ ប្រកាសដើម្បីជាស់ឱ្យកើតសេចក្តីពេញចិត្ត ក្នុងពាក្យប្រកាសនោះ ឱ្យចាប់ស្លាកហើយក្តី សង្ឃក៏មិនជាការដែលលោកបានទម្លាយទេ, តែកាលណាលោកឱ្យភិក្ខុ ៤ រូបឬលើសជាងចាប់ស្លាកយ៉ាងនោះហើយ ធ្វើកម្ម ឬឧទ្ទេសផ្សេកណាមួយ, កាលនោះ លោក ឈ្មោះថាបានទម្លាយសង្ឃហើយពិត ។

ដោយប្រការយ៉ាងនេះ ជាការប្រកាសសេចក្តីដែលខ្ញុំបានពោលទុកក្នុងសង្ឃភេទក្ខន្ធកវណ្ណនា យ៉ាងនេះថា កាលភិក្ខុទាំងឡាយសម្តែងវត្ថុសូម្បីយ៉ាងណាមួយ ក្នុងបណ្តាវត្ថុ ១៨ ហើយ ឱ្យភិក្ខុទាំងឡាយសំគាល់ដឹងដោយហេតុនោះ ៗ ថា លោកទាំងឡាយចូរចាប់ស្លាកនេះ ចូរពេញចិត្តស្លាកនេះ, ដូច្នេះ ឱ្យចាប់ស្លាក ហើយធ្វើសង្ឃកម្មមួយផ្សេកសង្ឃរមែងបែកគ្នា, ចំណែកក្នុងគម្ពីរបរិវារៈព្រះមានព្រះភាគត្រាស់ថា "ម្នាលឧបាលី សង្ឃបែកគ្នាដោយអាការ ៥" ជាដើម, ពាក្យនោះ និងលក្ខណៈនៃសង្ឃភេទនេះ ដែលត្រាស់ក្នុងសង្ឃភេទក្ខន្ធកៈនេះ ដោយន័យសេចក្តី មិនផ្សេងគ្នាទេ, ខ្ញុំនឹងប្រកាសសេចក្តីដែលមិនផ្សេងគ្នានៃពាក្យនោះ ៗ ក្នុងគម្ពីរបរិវារៈនោះឯង ។

# សង្ឃរាជី

[២៩៦] បទថា បញ្ញត្តេ តំ : បញ្ញត្តិអាគន្តុកវត្តនេះ មានសេចក្ដីថា វត្តនោះ តថាគតបញ្ញត្តិហើយ, បញ្ញត្តិទុកក្នុងទីណា ? បញ្ញត្តិទុកក្នុងវត្តខន្ធកៈ ។ ពិតមែន វត្ត ១៤ ពួក ព្រះមានព្រះភាគទ្រង់បញ្ញត្តិហើយ ក្នុងវត្តកខន្ធកៈនោះ ។ ដោយហេតុនោះ ព្រះអង្គទើបត្រាស់ថា "ម្នាលឧបាលី តថាគតបានបញ្ញត្តអាគន្តុកវត្តនេះ ដល់ពួកភិក្ខុជាអាគន្តុកៈ" ជាដើម ។

ច្រើនបទថា ឯវំ ខោ ឧបាលិ សង្ឃរាជិ ហោតិ នោ ចសង្ឃភេទោ : ម្នាលឧបាលិ យ៉ាងនេះហើយហៅថា ការប្រេះឆានៃសង្ឃ តែមិនទាន់ហៅថា បែកធ្លាយនៃសង្ឃទេ មានសេចក្ដីថា ពិតមែន ដោយហេតុត្រឹមប៉ុណ្ណេះ រមែងមានត្រឹមតែការប្រេះឆានៃសង្ឃប៉ុណ្ណោះ, ការបែកនៃសង្ឃមិនទាន់មានទេ ; ក៏ប៉ុន្តែថា ការប្រេះឆានៃសង្ឃនេះ កាលពង្រីកធំឡើងដោយលំដាប់ រមែងប្រព្រឹត្តទៅ ដើម្បីការបែកនៃសង្ឃបាន ។

បទថា យថារត្តំ : តាមលំដាប់រាត្រី សេចក្ដីថា សមគួរដល់បរិមាណនៃរាត្រី គឺ តាមលំដាប់ព្រះថេរៈ ។

ពីរបទថា អាវេណិភាវំ ករិត្វា : ធ្វើសេចក្ដីកំណត់ផ្សេងគ្នា

បានដល់ ធ្វើសេចក្តីកំណត់ទុកមួយផ្នែក ។

ពីរបទថា **កម្មាកម្មានិ ករោន្តិ : ធ្វើកម្មតូចកម្មធំ** មានសេចក្តីថា រមែងធ្វើកម្មទាំងឡាយទាំងតូចទាំងធំ ដរាបដល់ថ្នាក់សង្ឃកម្មដទៃ ៗ ទៀត ។

ពាក្យដ៏សេស ក្នុងអធិករណរូបសមវគ្គសូម្បីនេះ ងាយយល់ទាំងអស់ ។

## ភិក្ខុដែលទម្លាយសង្ឃ

[២៩៨] វិនិច្ឆ័យក្នុងសង្ឃភេទវគ្គទាំង ២ គប្បីជ្រាបដូច្នេះ ៖

ច្រើនបទថា **វិនិធាយ ធិដ្ឋី កម្មេន : បិទបាំងទិដ្ឋិហើយធ្វើកម្មផ្សេងគ្នា** មានសេចក្តីថា ភិក្ខុជាអ្នកមានសេចក្តីឃើញក្នុងអធម៌ជាដើមទាំងនោះ យ៉ាងនេះថា ទាំងនេះ ជាអធម៌ជាដើម អះអាងសេចក្តីឃើញនោះ សម្តែងអធម៌ ជាដើម ទាំងនោះ ដោយអំណាចធម៌ជាដើមហើយធ្វើកម្មផ្សេងគ្នា ។

ភិក្ខុធ្វើកម្មដែលអះអាងសេចក្តីឃើញយ៉ាងណា, ព្រមទាំងកម្មដែលអះអាងសេចក្តីឃើញ ដែលលោកធ្វើហើយយ៉ាងនោះ ៗ រមែងមានអង្គ ៥ ដោយប្រការយ៉ាងនេះ ។

ព្រះបាលីដែលថា ឥមេហិ ខោ ឧបាលិ បញ្ចហង្គេហិ : ម្នាលឧបាលិ ភិក្ខុប្រកបដោយអង្គ ៥ នេះឯង នេះ ជាពាក្យប្រកបសេចក្តីក្នុងបញ្ចកៈ ១ ។ បញ្ចកៈទាំងពួង គប្បីជ្រាបដោយន័យនេះ ។

មួយទៀត អង្គ ៣ មានការប្រកាសជាដើម សូម្បីក្នុងសង្ឃភេទវគ្គនេះ ត្រាស់ហើយដោយអំណាចអង្គជាបុព្វភាគ ដូចគ្នា ។ តែជាអ្នកកែខ្លួនមិនបាន គប្បីជ្រាបដោយអំណាចកម្ម និងឧទ្ទេសនុ៎ះឯង ។

ពាក្យដ៏សេសក្នុងបទទាំងពួង ងាយយល់ទាំងអស់ ។

ពាក្យតិចតួច ដែលមានអត្ថន័យ ដែលខ្ញុំមិនបានពោលហើយក្នុងកាលមុន មិនមានក្នុងសង្ឃភេទវគ្គនេះឡើយ ។

វិនិច្ឆ័យក្នុងអាវាសិកវគ្គ គប្បីជ្រាបដូច្នេះ ៖

[៣០២] ពីរបទថា យថាភតំ និក្ខិត្តោ : ដូចគេនាំយកទៅទម្លាក់ មានសេចក្តីថា (បរិក្ខាររបស់សង្ឃ) ដែលខ្លួននាំមកតាំងទុកយ៉ាងណា ។

[៣០៣] បទថា វិនយព្យាករណា : ការដោះស្រាយវិន័យបានដល់ ពន្យល់បញ្ហាវិន័យ ។

បទថា បរិណាមេតិ : បង្អោន បានដល់ រមែងកំណត់ គឺរមែងសម្តែង រមែងពោល, ពាក្យដ៏សេសក្នុងវគ្គនេះ ងាយយល់ទាំងអស់ឯង ។

# បុគ្គលដែលមិនគួរសំពះ

វិនិច្ឆ័យក្នុងកបិវត្ថុវគ្គ គប្បីជ្រាបដូច្នេះ ៖

[៣០៨] បទថា ឱតមសិកោ បានដល់ អន្ធការគតោ : អ្នកនៅក្នុងទីងងឹត, ពិតមែន កាលភិក្ខុសំពះបុគ្គលដែលនៅក្នុងទីងងឹតនោះ ថ្វាស់ទីងប៉ះខ្ទប់ជើងគ្រែជាដើម ក៏បាន ។

បទថា អសមន្នាហរន្តោ : ភិក្ខុដែលកំពុងខ្វល់ខ្វាយដោយការងារមិនបានធ្វើការអើពើនឹងការសំពះ បានដល់ អ្នកមិនយកចិត្តដាក់ការសំពះ ព្រោះជាអ្នកខ្វល់ខ្វាយក្នុងកិច្ចការ ។

បទថា សុត្តោ : កំពុងដេកលក់ បានដល់ អ្នកឈានចុះកាន់ការលង់លក់ ។

បទថា ឯកាវត្តោ : ភិក្ខុងាកទៅក្នុងទីម្ខាង មានសេចក្ដីថា បុគ្គលដែលងាកមកតែម្ខាង គឺ តាំងនៅក្នុងបក្ខពួកសត្រូវ បានដល់ បុគ្គលមិនត្រូវគ្នា ជាសត្រូវគ្នា បុគ្គលនេះ លោកពោលថា មិនគួរថ្វាយបង្គំ ។ ព្រោះថា បុគ្គលនេះ ដែលភិក្ខុថ្វាយបង្គំហើយ នឹងប្រហារដោយជើងក៏បាន ។

បទថា អញ្ញាវិហិតោ : បញ្ជូនចិត្តទៅកាន់អារម្មណ៍ដទៃ បាន

ដល់ អ្នកកំពុងគិតរឿងដទៃ ។

បទថា ខាទន្តោ : ភិក្ខុកំពុងឆាន់បង្អែម បានដល់ អ្នកកំពុងឆាន់នំ និងរបស់ទំពាជាដើម ។

បុគ្គលដែលកំពុងបន្ទោបង់ឧច្ចារៈ និងបស្សាវៈ ឈ្មោះថា ដែលភិក្ខុមិនគួរថ្វាយបង្គំ ព្រោះជាអ្នកនៅក្នុងឱកាសមិនសមគួរ ។

បទថា ឧក្ខិត្តកោ : ភិក្ខុដែលសង្ឃលើកវត្ត មានសេចក្តីថា ភិក្ខុដែលសង្ឃលើកវត្ត ដោយឧក្ខេបនីយកម្ម សូម្បីទាំង ៣ យ៉ាង មិនគួរថ្វាយបង្គំ ។

តែបុគ្គល ៤ ពួក ដែលសង្ឃដាក់ទោសដោយតជ្ជនីយកម្មជាដើម គួរ ថ្វាយបង្គំ ។ សូម្បីឧបោសថបវារណា រមែងបានជាមួយនឹងបុគ្គលទាំងនោះ ។

ក៏ក្នុងបណ្តាបុគ្គលដែលមិនគួរថ្វាយបង្គំ ដែលពោលហើយតាំងពីដើម ជាអាបត្តិដល់ភិក្ខុដែលថ្វាយបង្គំ នូវបុគ្គលអាក្រោតកាយ និងបុគ្គលដែលសង្ឃលើកវត្តប៉ុណ្ណោះ, ចំណែកការថ្វាយបង្គំបុគ្គលក្រៅអំពីនោះ ដែលលោកហាម ក៏ព្រោះផល គឺ មិនសមគួរ និងព្រោះហេតុដែលពោលហើយក្នុងចន្លោះ ។

តពីនេះទៅ បុគ្គលសូម្បីទាំង ១០ ពួក មានអ្នកឧបសម្បទាខាងក្រោយជាដើមចាត់ជាអ្នកមិនគួរថ្វាយបង្គំ ព្រោះជាវត្ថុនៃអាបត្តិដោយត្រង់ ។ ពិតមែន រមែងជាអាបត្តិដល់ភិក្ខុដែលថ្វាយបង្គំនូវបុគ្គលទាំងនោះ ដោយវិន័យកំណត់តែម្តង ។

ក្នុងបញ្ចកៈ ៥ ទាំងនេះ ជាអនាបត្តិដល់ភិក្ខុដែលថ្វាយបង្គំជន ១៣ ពួក ជាអាបត្តិដល់ភិក្ខុដែលថ្វាយបង្គំជន ១២ ពួក ដោយប្រការដូច្នេះ ។

[៣០៩] ពីរបទថា **អាចរិយោ វន្ទិយោ** : ភិក្ខុជាអាចារ្យ គួរសំពះ មានសេចក្តីថា អាចារ្យទាំង ៥ នេះ គឺ បព្វជ្ជាចារ្យ ឧបសម្បទាចារ្យ និស្សយាចារ្យ ឧទ្ទេសាចារ្យ ឱវាទាចារ្យដែលភិក្ខុគួរថ្វាយបង្គំ ។

ពាក្យដ៏សេសក្នុងបទទាំងពួង ងាយយល់ទាំងអស់ដូច្នេះឯង ។

**ពណ៌នាកថិនក្ខន្ធកវត្ត និង ពណ៌នាខុទ្ធានុលិបញ្ចកៈ ចប់**

# ពណ៌នាសមុដ្ឋាន

[៣១៣] វិនិច្ឆ័យក្នុងពាក្យថា អចិត្តកោ អាបជ្ជតិ : ភិក្ខុមិនមានចិត្តគិតហើយត្រូវ ជាដើម គប្បីជ្រាបដូច្នេះ ៖

ភិក្ខុដែលមិនក្លែង តែត្រូវទោសតាមព្រះបញ្ញត្តិ មានសហសេយ្យជាដើម ឈ្មោះថា អាបត្តិដែលភិក្ខុមិនមានចិត្តគិតហើយត្រូវ, កាលសម្តែងចេញ ឈ្មោះថា មានចិត្តគិតហើយចេញចាកអាបត្តិនោះ ។

ភិក្ខុដែលក្លែងត្រូវទោសយ៉ាងណាមួយ ឈ្មោះថា អាបត្តិដែលភិក្ខុមានចិត្តគិតហើយត្រូវ, កាលចេញដោយតិណវត្ថារកវិន័យ ឈ្មោះថា មិនមានចិត្តគិតហើយចេញចាកអាបត្តិនោះ ។

កាលចេញចាកអាបត្តិ ដែលពោលហើយ ក្នុងកាលមុននុ៎ះឯងដោយតិណវត្ថារកវិន័យ ឈ្មោះថា អាបត្តិដែលភិក្ខុមិនមានចិត្តគិតហើយត្រូវ មិនមានចិត្តគិតហើយចេញចាកអាបត្តិនោះ ។ កាលសម្តែងអាបត្តិក្រៅនេះ ឈ្មោះថា អាបត្តិដែលភិក្ខុមានចិត្ត គិតហើយត្រូវ មានចិត្តគិតហើយចេញចាកអាបត្តិនោះ ។

កាលគិតថា យើងនឹងធ្វើធម្មទាន ធ្វើធម៌ជាដើមដោយបទ ឈ្មោះថា **អាបត្តិដែលភិក្ខុមានកុសលចិត្តហើយត្រូវ** ។

កាលមានចិត្តរីករាយថា "យើងធ្វើតាមពាក្យទូន្មានរបស់ព្រះពុទ្ធ" សម្តែង (អាបត្តិ) ឈ្មោះថា **មានកុសលចិត្តហើយចេញចាកអាបត្តិនោះ** ។

កាលសម្តែង ជាអ្នកដល់សេចក្តីអាក់អន់ចិត្ត ឈ្មោះថា **មានអកុសលចិត្តហើយចេញចាកអាបត្តិនោះ** ។

កាលដេកលក់ចេញដោយតិណវត្ថារកវិន័យ ឈ្មោះថា **មានអព្យាកតចិត្តហើយចេញចាកអាបត្តិនោះ** ។

កាលធ្វើសេចក្តីល្មើស មានការបន្ទាបឱ្យខ្ពាចជាដើម ហើយដល់សេចក្តីសប្បាយចិត្តថា យើងធ្វើតាមពាក្យទូន្មានរបស់ព្រះពុទ្ធ សម្តែងអាបត្តិ ឈ្មោះថា **អាបត្តិដែលភិក្ខុមានអកុសលចិត្តហើយត្រូវ មានកុសលចិត្តហើយចេញចាកអាបត្តិនោះ** ។

ដល់សេចក្តីទោមនស្សនោះឯង សម្តែង ឈ្មោះថា **មានអកុសលចិត្តហើយចេញចាកអាបត្តិនោះ** ។

កាលចេញដោយតិណវត្ថារកវិន័យ តាមន័យដែលពោលហើយនុ៎ះ

៦៨ ឈ្មោះថា **មានអព្យាកតចិត្តហើយចេញចាកអាបត្តិនោះ** ។

កាលត្រូវអាបត្តិព្រោះដេករួមក្នុងផ្ទះ ក្នុងសម័យដែលឈានចុះកាន់ភាពលង់លក់ ឈ្មោះថា **អាបត្តិដែលភិក្ខុមានអព្យាកតចិត្ត ហើយត្រូវ** ។

ចំណែកពាក្យថា **មានចិត្តជាកុសល** ជាដើម គប្បីជ្រាបក្នុងអាបត្តិដែលត្រូវ ព្រោះដេកក្នុងផ្ទះរួមគ្នានេះ តាមន័យដែលពោលនុ៎ះ ៦៨ ។

[៣១៤] ពាក្យថា **បឋមំ បារាជិកំ កតីហិ សមុដ្ឋានេហិ** ជាដើម រាប់ថា ឆាយយល់ទាំងអស់ហើយ ព្រោះមានន័យដូចពោលហើយក្នុងកាលមុន ។

សមុដ្ឋានណា ៗ បានដល់ អាបត្តិណា ៗ, សមុដ្ឋាន និងអាបត្តិនោះ ៗ ទាំងមូលជាការបានពោលរួចហើយ ដោយកំណត់យ៉ាងខ្ពស់ក្នុងពាក្យថា បារាជិក ៤ រមែងកើតដោយសមុដ្ឋាន ៣ ជាដើម ។

## សមុដ្ឋានវណ្ណនា ចប់

# ពណ្ណនាឧត្តិយគាថាសច្ចណិកៈ

[៣២៥] វិនិច្ឆ័យក្នុងវិសជ្ជនាគាថាថា កតិ អាបត្តិយោ[១] កាយិកា : អាបត្តិដែលតាំងឡើងអំពីកាយ មានប៉ុន្មាន ជាដើម គប្បីជ្រាបដូច្នេះ ៖

## អាបត្តិដែលតាំងឡើងអំពីកាយជាដើម

បាទគាថាថា ឆ អាបត្តិយោ កាយិកា : អាបត្តិដែលតាំងឡើងអំពីកាយ មាន ៦ មានសេចក្តីថា អាបត្តិទាំងឡាយ ដែលលោកពោលទុកក្នុងអន្តរបេយ្យាល ដោយន័យមានពាក្យថា ភិក្ខុត្រូវអាបត្តិ ៦ ដោយអាបត្តិសមុដ្ឋានទី ៤ គឺ ភិក្ខុសេពមេថុនធម្មត្រូវអាបត្តិបារាជិកជាដើម ។ ពិតមែន អាបត្តិទាំងនោះត្រាស់ថា ជាប់ដោយកាយ ព្រោះកើតឡើងក្នុងកាយទ្វារ ។

ពីរបទថា ឆ វាចសិកា : អំពីវាចា មាន ៦ មានសេចក្តីថា អាបត្តិទាំងឡាយ ដែលត្រាស់ទុកក្នុងអន្តរបេយ្យាលនោះឯង ដោយន័យមានពាក្យថា ភិក្ខុត្រូវអាបត្តិ ៦ ដោយអាបត្តិសមុដ្ឋានទី ៥ គឺ ភិក្ខុដែលមានសេចក្តីប្រាថ្នាលាមក ដែលសេចក្តីប្រាថ្នាលាមកគ្របសង្កត់

---

១. ថៃ. កតាបត្តិយោ ។

ហើយ ដូច្នេះជាដើម ។

ពីរបទថា ឆាទេន្តស្ស តិស្សោ : អាបត្តិ ៣ មានដល់ឧបសម្បន្នដែលបិទបាំងទោសទុក មានសេចក្តីថា ភិក្ខុនីដែលបិទបាំងទោស ត្រូវអាបត្តិបារាជិក, ភិក្ខុដែលបិទបាំងនូវអាបត្តិសង្ឃាទិសេស ត្រូវអាបត្តិបាចិត្តិយ, បិទបាំងអាបត្តិអាក្រក់របស់ខ្លួន ត្រូវអាបត្តិទុក្កដ ។

ពីរបទថា បញ្ច សំសគ្គបច្ចយា : អាបត្តិ ៥ ដែលត្រូវព្រោះការប៉ះពាល់នូវកាយ មានសេចក្តីថា អាបត្តិ ៥ មានការស្ទាបអង្អែលដោយកាយជាបច្ច័យទាំងនេះ គឺ ការស្ទាបអង្អែលដោយកាយ ជាអាបត្តិបារាជិក ដល់ភិក្ខុនី, ជាអាបត្តិសង្ឃាទិសេស ដល់ភិក្ខុ, ព្រោះកាយនិងវត្ថុជាប់ដោយកាយប៉ះគ្នា ជាអាបត្តិថុល្លច្ច័យ, ព្រោះរបស់ដែលគេវែងទៅនិងរបស់ជាប់ដោយកាយប៉ះគ្នា ជាអាបត្តិទុក្កដ, ព្រោះចាក់ក្រឡេកដោយម្រាមដៃ ជាអាបត្តិបាចិត្តិយ ។

## អាបត្តិដែលត្រូវក្នុងវេលាអរុណរះជាដើម

[៣២៦] ពីរបទថា អរុណុគ្គេ តិស្សោ : អាបត្តិដែលត្រូវក្នុងវេលាអរុណរះឡើង មាន ៣ មានសេចក្តីថា ព្រោះអរុណរះ ភិក្ខុរមែងត្រូវអាបត្តិ ៣ ទាំងនេះ គឺ និស្សគ្គិយបាចិត្តិយ ដោយអំណាចការកន្លង

១ រាត្រី ៦ រាត្រី ៧ ថ្ងៃ ១០ ថ្ងៃ និង ១ ខែ, ភិក្ខុនីនៅប្រាសចាក (ពីសម្មាញ់) រហូតដល់អស់រាត្រី ត្រូវអាបត្តិសង្ឃាទិសេស, ភិក្ខុបិទអាបត្តិទុករហូតដល់អស់យាមទី ១ ក្តី បិទទុករហូតដល់អស់យាមទី ២ ក្តី រហូតដល់អស់យាមទី ៣ ក្តី ក្នុងកាលអរុណរះហើយ លោកឈ្មោះថា បិទអាបត្តិទុក គប្បីឱ្យលោកសម្តែងអាបត្តិទុក្កដ ។

ពីរបទថា ទ្វេ យាវតតិយកា : អាបត្តិដែលត្រូវក្នុងខណៈដែលសង្ឃស្វូធ្យសមនុភាសនកម្មចប់ជាគម្រប់ ៣ ដង មាន ២ មានសេចក្តីថា អាបត្តិឈ្មោះថា យាវតតិយកា[១] មាន ១១ តែបែងចែកជា ២ ដោយអំណាចព្រះបញ្ញត្តិ គឺ យាវតតិយកាបត្តិរបស់ភិក្ខុ យាវតតិយកាបត្តិរបស់ភិក្ខុនី ។

ពីរបទថា ឯកេត្ថ អដ្ឋវត្ថុកា : អាបត្តិដែលត្រូវព្រោះបំពេញវត្ថុឱ្យគ្រប់ទាំង ៨ មានតែ ១ មានសេចក្តីថា អាបត្តិយ៉ាងណាមួយរបស់ភិក្ខុនីទាំងឡាយប៉ុណ្ណោះ ឈ្មោះថា អដ្ឋវត្ថុកា ក្នុងសាសនានេះ ។

ពីរបទថា ឯកេន សព្វសង្គហោ : ក្នុងសាសនានេះ ការសង្គ្រោះទាំងអស់ដោយឧទ្ទេសតែ ១ មានសេចក្តីថា សង្គ្រោះសិក្ខាបទទាំងមូល និងបាដិមោក្ខុទ្ទេសទាំងមូលសង្គ្រោះ ចូលដោយនិទានុទ្ទេសតែមួយនេះថា "លោកអង្គណា មានអាបត្តិ, ត្រូវលោកអង្គនោះប្រាប់"[២] ។

---

១ ក្នុងទំព័រ ៩៧១ ។ ២. វិន. មហា. ឧបោសថក្ខន្ធកៈ. ៦. ១៤៩/៣៤០ ។

# មូលរបស់វិន័យជាដើម

[៣២៧] ច្រើនបទថា វិនយស្ស ទ្វេ មូលានិ : មូលរបស់វិន័យ មានប៉ុន្មាន មានសេចក្តីថា (មូលនៃវិន័យមាន ២គឺ ) កាយ ១ វាចា ១ ។

ច្រើនបទថា គរុកា ទ្វេ វុត្តា : គរុការបត្តិក្នុងវិន័យ មានប៉ុន្មាន មានសេចក្តីថា (អាបត្តិធ្ងន់ លោកពោលទុក២ គឺ ) បារាជិកនិងសង្ឃាទិសេស ។

ពីរបទថា ទ្វេ ទុដ្ឋុល្លច្ឆាទនា : ដែលត្រូវព្រោះបិទបាំងទុដ្ឋុល្លាបត្តិ មាន ២ មានសេចក្តីថា ដែលឈ្មោះថា អាបត្តិព្រោះបិទទោសអាក្រក់ មាន ២ ពួកនេះ គឺ ភិក្ខុនីដែលបិទទោស (គឺ បារាជិករបស់ភិក្ខុនីដទៃ ) ជាអាបត្តិបារាជិក, ភិក្ខុដែលបិទសង្ឃាទិសេស (របស់ភិក្ខុដទៃ ) ជាអាបត្តិបាចិត្តិយ ។

# អាបត្តិដែលត្រូវក្នុងចន្លោះផ្ទះជាដើម

[៣២៨] ពីរបទថា គាមន្តរេ ចតស្សោ : អាបត្តិ ៤ ដែលត្រូវក្នុងចន្លោះផ្ទះ មានសេចក្តីថា អាបត្តិ ៤ យ៉ាង ដោយអំណាចទុក្កដ បាចិត្តិយ ថុល្លច្ច័យ និងសង្ឃាទិសេស ព្រោះចន្លោះស្រុកទាំងនេះគឺ ភិក្ខុ

និងភិក្ខុនីបបួលគ្នា ត្រូវអាបត្តិទុក្កដ ។ ចូលឧបចារៈស្រុកដទៃ ត្រូវអាបត្តិបាចិត្តិយ, ភិក្ខុនី កាលទៅកាន់ចន្លោះស្រុក ក្នុងស្រុកដែលលោមព័ទ្ធ ជំហានដំបូងត្រូវអាបត្តិថុល្លច្ច័យ, ជំហានទី ២ ត្រូវអាបត្តិសង្ឃាទិសេស ។ ជំហានដំបូងត្រូវអាបត្តិថុល្លច្ច័យ, ដែលឈានចូលឧបចារៈនៃស្រុកមិនបានលោមព័ទ្ធ, ជំហានទី២ ត្រូវអាបត្តិសង្ឃាទិសេស ។

ពីរបទថា **ចតស្សោ នទីបារប្បច្ចយា : អាបត្តិ ៤ ដែលត្រូវព្រោះឆ្លងត្រើយស្ទឹងជាបច្ច័យ** មានសេចក្តីថា អាបត្តិ ៤ យ៉ាងទាំងនេះ គឺ ភិក្ខុនិងភិក្ខុនីបបួលគ្នា ត្រូវអាបត្តិទុក្កដ, ឡើងទូក ត្រូវអាបត្តិបាចិត្តិយ, កាលភិក្ខុនី (តែរូបមួយ) ទៅកាន់ត្រើយទន្លេ ក្នុងវេលាឆ្លង ជំហានដំបូងត្រូវអាបត្តិថុល្លច្ច័យ, ជំហានទី២ ត្រូវអាបត្តិសង្ឃាទិសេស ។

ពីរបទថា **ឯកមំសេ ថុល្លច្ចយំ : សាច់មនុស្សតែម្យ៉ាងដែលឆាន់ត្រូវអាបត្តិថុល្លច្ច័យ** មានសេចក្តីថា (ភិក្ខុរមែងត្រូវអាបត្តិថុល្លច្ច័យ) ព្រោះឆាន់សាច់មនុស្ស ។

ពីរបទថា **នវមំសេសុ ទុក្កដំ : សាច់ ៩ ប្រការដែលភិក្ខុឆាន់ត្រូវអាបត្តិទុក្កដ** មានសេចក្តីថា (ភិក្ខុរមែងត្រូវអាបត្តិទុក្កដ) ព្រោះអកប្បិយមំសៈដ៏សេស ។

# អាបត្តិដែលប្រកបដោយវាចាត្រូវតែក្នុងរាត្រីជាដើម

[៣២៩] ប្រើនបទថា ទ្វេ វាចសិកា រត្តឹ : អាបត្តិ ២ ប្រកបដោយវាចាហើយត្រូវតែក្នុងរាត្រី មានសេចក្តីថា ភិក្ខុនីឈរនិយាយក្នុងហត្ថបាសជាមួយនឹងបុរស ក្នុងវេលាងងឹត ៗ យប់ងងឹត មិនមានពន្លឺភ្លើង ត្រូវអាបត្តិបាចិត្តិយ, វៀរហត្ថបាស ឈរនិយាយ ត្រូវអាបត្តិទុក្កដ ។

ប្រើនបទថា ទ្វេ វាចសិកា ទិវា : អាបត្តិ ២ ដែលតាំងឡើងអំពីវាចាហើយត្រូវតែក្នុងវេលាថ្ងៃ មានសេចក្តីថា ភិក្ខុនីឈរនិយាយក្នុងហត្ថបាសជាមួយបុរស ក្នុងឱកាសដែលបិទបាំង ក្នុងពេលថ្ងៃ ត្រូវអាបត្តិបាចិត្តិយ, វៀរហត្ថបាសឈរនិយាយ ត្រូវអាបត្តិទុក្កដ ។

ពីរបទថា ទទមានស្ស តិស្សោ : អាបត្តិ ៣ មានដល់ឧបសម្បន្នដែលឱ្យ មានសេចក្តីថា ត្រូវអាបត្តិ ៣ យ៉ាង ដល់ភិក្ខុដែលឱ្យ យ៉ាងនេះ គឺ មានប្រាថ្នានឹងសម្លាប់ ឱ្យថ្នាំពិសដល់មនុស្ស បើថាគេស្លាប់ដោយថ្នាំពិសនោះ ភិក្ខុត្រូវអាបត្តិបារាជិក, ឱ្យដល់យក្ខ និងប្រេត បើថា យក្ខ និង ប្រេតនោះស្លាប់ ភិក្ខុត្រូវអាបត្តិថុល្លច្ច័យ, ឱ្យដល់សត្វតិរច្ឆាន បើថា វាស្លាប់ ភិក្ខុត្រូវអាបត្តិបាចិត្តិយ, សូម្បីព្រោះឱ្យចីវរដល់ភិក្ខុនីដែលមិនមែនជាញាតិ ក៏ត្រូវអាបត្តិបាចិត្តិយដែរ ។

ពីរបទថា ចត្តារោ ច បដិគ្គហេ : អាបត្តិ ៤ មានដល់ឧបសម្បន្នដែលទទួល មានសេចក្តីថា ត្រូវអាបត្តិសង្ឃាទិសេស ព្រោះចាប់ដៃនិងចាប់ផ្ទួងសក់, ត្រូវអាបត្តិបារាជិក ព្រោះបៀមអង្គជាតិដោយមាត់ ត្រូវនិស្សគ្គិយបាចិត្តិយ ព្រោះទទួលចីវររបស់ភិក្ខុនីមិនមែនជាញាតិ, ត្រូវអាបត្តិថុល្លច្ច័យ ដល់ភិក្ខុនីដែលមានតម្រេក ទទួលរបស់ទំពាររបស់បរិភោគ អំពីដៃបុរសដែលមានតម្រេក, កងអាបត្តិ ៤ រមែងមានព្រោះការទទួល ដោយប្រការយ៉ាងនេះ ។

## អាបត្តិដែលជាទេសនាគាមិនីជាដើម

[៣៣០] ពីរបទថា បញ្ច ទេសនាគាមិនិយោ : អាបត្តិដែលជាទេសនាគាមិនី មាន ៥ បានដល់ លហុកាបត្តិ ៥ កង ។

ពីរបទថា ឆ សប្បដិកម្មា : អាបត្តិដែលជាសប្បដិកម្ម មាន ៦ មានសេចក្តីថា វៀរបារាជិកចេញហើយ អាបត្តិដ៏សេស (មានមកអាចសម្តែងចេញបាន) ។

ពីរបទថា ឯកេត្ថ អប្បដិកម្មា : អាបត្តិ ១ ដែលព្រះពុទ្ធជាអាទិច្ចវង្សទ្រង់ត្រាស់ថា ជាអប្បដិកម្មក្នុងសាសនានេះ មានសេចក្តីថា

( អាបត្តិដែលសម្តែងមិនបានក្នុងសាសនានេះ មានតែម្យ៉ាង គឺ ) អាបត្តិបារាជិក ។

[៣៣១] ច្រើនបទថា វិនយគរុកា ទ្វេ វុត្តា : អាបត្តិ ២ យ៉ាង ដែលព្រះពុទ្ធជាអាទិច្ចវង្សទ្រង់ត្រាស់ថា ជាគរុកាបត្តិក្នុងវិន័យ បានដល់ បារាជិក និងសង្ឃាទិសេស ។

បទថា កាយវាចសិកានិ ច : សិក្ខាបទទាំងអស់សុទ្ធតែតាំងឡើងអំពីកាយនិងវាចា មានសេចក្តីថា សិក្ខាបទទាំងមូលតែម្តង ប្រព្រឹត្តទៅក្នុងមកកាយនិងវាចា ។ សិក្ខាបទណាមួយ ដែលទ្រង់បញ្ញត្តិក្នុងមនោទ្វារ មិនមាន ។

ច្រើនបទថា ឯកោ វិកាលេ ធញ្ញរសោ : រសស្រូវតែមួយ គឺ ថ្នាំឈ្មោះលោណសោចិរកៈដែលគួរឆាន់បានក្នុងវេលាវិកាល បានដល់ ថ្នាំត្រាំដោយអំបិល ។ ពិតមែន រសនៃធញ្ញជាតិប្រភេទមួយនេះឯង គួរក្នុងវិកាល ។

ច្រើនបទថា ឯកា ញត្តិចតុត្ថេន សម្មតិ : ការសន្មតដោយញត្តិចតុត្ថកម្មវាចាមានតែ១ បានដល់ សន្មតភិក្ខុឱ្យទូន្មានភិក្ខុនី ។ ពិតមែន សន្មតដោយញត្តិចតុត្ថកម្ម តែមួយនេះប៉ុណ្ណោះ ដែលព្រះមានព្រះភាគទ្រង់អនុញ្ញាតហើយ ។

# អាបត្តិបារាជិកដែលតាំងឡើងអំពីកាយជាដើម

[៣៣២] ច្រើនបទថា ធារាជិកា កាយិកា ទ្វេ : អាបត្តិបារាជិកដែលតាំងឡើងអំពីកាយ មាន ២ បានដល់ មេថុនធម្មបារាជិករបស់ភិក្ខុ និងកាយសំសគ្គបារាជិករបស់ភិក្ខុនី ។

ពីរបទថា ទ្វេ សំវាសកភូមិយោ : ភូមិនៃសំវាស មាន ២ មានសេចក្តីថា ភិក្ខុធ្វើខ្លួនឱ្យជាសមានសំវាសកៈដោយខ្លួនឯង, ឬសង្ឃព្រមព្រៀងគ្នា ប្រកាសដកភិក្ខុដែលត្រូវសង្ឃលើកវត្តនោះចេញ ។

តែក្នុងកុរុន្ទី ពោលសំវាសកភូមិទុក ២ យ៉ាង ៗ នេះ គឺ ភូមិនៃសមានសំវាសក ១ ភូមិនៃនានាសំវាសក ១ ។

ពីរបទថា ទ្វិន្នញ្ច រត្តិច្ឆេទោ : រាត្រីដាច់ដល់បុគ្គល២ពួក បានដល់ រត្តិច្ឆេទរបស់ភិក្ខុដែលនៅបរិវាស១ របស់ភិក្ខុដែលប្រព្រឹត្តមានត្ត១ ។

ច្រើនបទថា បញ្ញត្តា ទ្វង្គុលា ទុវេ : ទ្រង់បញ្ញត្តិខាតត្រឹមពីរធ្នាប់ មាន ២ សិក្ខាបទ បានដល់ ព្រះបញ្ញត្តិ ពោលអំពីពីរធ្នាប់ ២ យ៉ាង គឺ ព្រះបញ្ញត្តិដែលថា "កាលភិក្ខុនីធ្វើការជម្រះ ដោយទឹក ត្រូវធ្វើការជម្រះបានត្រឹមពីរថ្នាំងម្រាមដៃ ២ ជាកំណត់"[១] ១ ព្រះបញ្ញត្តិដែលថា "ភិក្ខុទុកសក់ ២ ធ្នាប់ ឬ ២ ខែ" នេះ ១ ។

---

១. វិន. ភិក្ខុនី. ៥. ១៦៤/១៦៤ ។

## អាបត្តិដែលធ្វើការវាយតប់ខ្លួនឯងជាដើម

[៣៣៣] ប្រើនបទថា ទ្វេ អត្តានំ វធិត្វាន : ភិក្ខុនីវាយខ្លួនឯង ត្រូវអាបត្តិ ២ មានសេចក្តីថា ភិក្ខុនីធ្វើការវាយតប់ខ្លួនឯង ត្រូវអាបត្តិ ២ យ៉ាង គឺ ធ្វើការវាយតប់ ស្រែកយំ ត្រូវអាបត្តិបាចិត្តិយ, ធ្វើការវាយតប់ មិនស្រែកយំ ត្រូវអាបត្តិទុក្កដ ។

ប្រើនបទថា ទ្វីហិ សង្ឃោ ភិជ្ជតិ : សង្ឃបែកគ្នាដោយអាការ ២ មានសេចក្តីថា (សង្ឃរមែងបែកគ្នាដោយហេតុ ២ ប្រការ គឺ ) ដោយកម្ម ១ ដោយចាប់ស្លាក ១ ។

ពីរបទថា ទ្វេត្ត បឋមាបត្តិកា : អាបត្តិដែលត្រូវជាដំបូង មាន ២ មានសេចក្តីថា ក្នុងវិន័យ សូម្បីទាំងអស់នេះ មានអាបត្តិត្រូវតាំងពីមុនធ្វើ ២ យ៉ាង ជាប់ដោយព្រះបញ្ញត្តិនៃភិក្ខុនិងភិក្ខុនីទាំង ២ ចំណែក ។ តែដោយប្រការក្រៅនេះ បឋមាបត្តិកាបត្តិនោះ រមែងមាន ១៨ គឺ របស់ភិក្ខុ ៩ របស់ភិក្ខុនី ៩ ។

ប្រើនបទថា ញត្តិយា ករណា ទុវេ : ការធ្វើញត្តិ មាន ២ មានសេចក្តីថា ញត្តិកិច្ចមាន ២ គឺ ញត្តិដែលជាកម្ម ១ ញត្តិដែលជាបាទនៃកម្ម ១, ញត្តិកិច្ច រមែងជាកម្មក្នុងស្ថាន ៩, តាំងនៅដោយភាពជាបាទនៃកម្មក្នុងស្ថាន ២ ។

## អាបត្តិក្នុងបាណាតិបាតជាដើម

[៣៣៤] ពីរបទថា **បាណាតិបាតេ តិស្សោ : ក្នុងបាណាតិបាត មានអាបត្តិ ៣** មានសេចក្ដីថា (ព្រោះបាណាតិបាត) រមែងមានអាបត្តិ ៣ ពួកនេះ គឺ ភិក្ខុជីករណ្ដៅទុកមិនចំពោះ (អ្នកណា), បើមនុស្សស្លាប់ ត្រូវអាបត្តិបារាជិក; បើយក្ខ និង ប្រេតស្លាប់ ត្រូវអាបត្តិថុល្លច្ច័យ, បើសត្វតិរច្ឆានស្លាប់ ត្រូវអាបត្តិបាចិត្តិយ ។

ច្រើនបទថា **វាចា បារាជិកា តយោ : អាបត្តិបារាជិកដែលតាំងឡើងអំពីវាចា មាន ៣** មានសេចក្ដីថា (អាបត្តិបារាជិកជាប់ដោយវាចា ៣ គឺ ) បារាជិកក្នុងវិជ្ជប្បដិច្ឆាទិកសិក្ខាបទ ១ ឧក្កិត្តានុវត្តិកា-សិក្ខាបទ ១ អដ្ឋវត្ថុកាសិក្ខាបទ ១ ។

តែក្នុងកុរុន្ទី លោកពោលទុក ៣ យ៉ាងនេះ គឺ បារាជិក ព្រោះអទិន្នាទាន និងសម្លាប់មនុស្ស ដោយបង្គាប់បញ្ជា និងព្រោះអួតឧត្តរិមនុស្សធម្ម ។

ពីរបទថា **ឱភាសនា តយោ : អាបត្តិដែលភិក្ខុនិយាយលួងលោមមាតុគ្រាម ដោយពាក្យអាក្រក់ មាន ៣** បានដល់ សង្ឃាទិសេស ព្រោះនិយាយសរសើរ និងតិះដៀលចំពោះវច្ចមគ្គ ឬបស្សាវមគ្គ, ថុល្លច្ច័យ ព្រោះនិយាយសរសើរ និងតិះដៀលចំពោះអវយវៈ ក្រោម

ជនកាំបិតចុះមក លើជន្លន់ឡើងទៅ វៀរវច្ចមគ្គ ឬបស្សាវមគ្គចេញ, ទុក្កដ ព្រោះនិយាយសរសើរ និងតិះដៀលចំពោះអវយវៈ លើជនកាំបិតឡើងទៅ ក្រោមជន្លន់ចុះមក ។

ពីរបទថា សញ្ចរិត្តេន វា តយោ : អាបត្តិ ៣ ត្រូវព្រោះការដឹកនាំបុរសនិងស្ត្រីឱ្យបានគ្នាជាប្តីប្រពន្ធ មានសេចក្តីថា អាបត្តិ ៣ កងមានព្រោះការនិយាយដឹកនាំជាហេតុ ទាំងនេះ គឺ ភិក្ខុទទួលពាក្យនិយាយដឹកនាំ ត្រឡប់មកប្រាប់ ត្រូវអាបត្តិសង្ឃាទិសេស, ទទួលពាក្យនិយាយដឹកនាំ មិនត្រឡប់មកប្រាប់ ត្រូវអាបត្តិថុល្លច្ច័យ, ទទួលពាក្យមិននិយាយដឹកនាំ មិនត្រឡប់មកប្រាប់ ត្រូវអាបត្តិទុក្កដ ។

## បុគ្គលដែលមិនគួរឱ្យឧបសម្បទាជាដើម

[៣៣៥] ប្រើនបទថា តយោ បុគ្គលា ន ឧបសម្បាទេតព្វា : បុគ្គលដែលមិនត្រូវឱ្យឧបសម្បទា មាន ៣ ពួក មានសេចក្តីថា (បុគ្គលដែលសង្ឃមិនគប្បីឱ្យឧបសម្បទា ៣ ពួកគឺ) បុគ្គលអ្នកមានកាល គឺ អាយុមិនគ្រប់ ១ អ្នកមានអវយវៈខ្វះខាត ១ អ្នកវិបត្តិដោយវត្ថុ ១ ។ ហេតុដែលធ្វើបុគ្គល ៣ ពួកនោះ ឱ្យផ្សេងគ្នា បានពោលហើយ ។

មួយប្រការទៀត ក្នុងបុគ្គល ៣ ពួកនេះ បុគ្គលណា មិនបរិបូណ៌ដោយបាត្រនិងចីវរ និងបុគ្គលណា បរិបូណ៌តែមិនសូម, បុគ្គលទាំងនេះឯង លោកសង្គ្រោះដោយបុគ្គលអ្នកមានអវយវៈខ្វះខាតដោយចំពោះ ។ ចំណែកបុគ្គលអ្នកមានការធ្វើអាក្រក់ថោកទាប មានអ្នកសម្លាប់មាតាជាដើម គប្បីជ្រាបថា សង្គ្រោះដោយបុគ្គលអ្នកវិបត្តិដោយវត្ថុដោយចំពោះ ពោលគឺ បណ្ឌកៈ ឧភតោព្យញ្ជនកៈ និងសត្វតិរច្ឆាន ។ ពិតមែន ន័យនេះ លោកពោលទុកក្នុងកុរុន្ទី ។

ប្រើនបទថា តយោ កម្មានំ[(១)] សង្គហា : ការសង្គ្រោះកម្មមាន ៣ បានដល់ (កម្មសង្គហៈ ៣ យ៉ាង គឺ ) វាចាកំណត់ញត្តិ ពាក្យប្រធានដែលធ្វើការបញ្ឈប់ ពាក្យបញ្ចាក់កម្មដែលស្រេចហើយ ។

ក្នុងកម្មសង្គហៈ ៣ នោះ កម្មទាំងឡាយ ដែលលោកសង្គ្រោះដោយលក្ខណៈទាំង ៣ នេះ គឺ វាចាដែលសូធ្យផ្សេង ដោយពាក្យថា ឧទេយ្យ ករេយ្យ ជាដើម ឈ្មោះថា វាចាកំណត់ញត្តិ ។ ពាក្យសូធ្យប្រកាសផ្សេងដោយពាក្យថា ទេតិ ករោតិ ជាដើម ឈ្មោះថា ពាក្យប្រធានដែលធ្វើការបញ្ឈប់, ពាក្យសូធ្យប្រកាសផ្សេងដោយពាក្យថា ឧិន្នំ កតំ ជាដើម ឈ្មោះថា ពាក្យបញ្ចាក់កម្មដែលស្រេចហើយ ។

---

១. បិដកថា កម្មាន ។

កម្មទាំងឡាយ ដែលលោកសង្គ្រោះដោយលក្ខណៈ ៣ ដទៃទៀត គឺ ដោយវត្ថុ ញត្តិ អនុស្សាវនា ។ ពិតមែន កម្មដែលព្រមដោយវត្ថុ ព្រមដោយញត្តិ និងព្រមដោយអនុស្សាវនា ទើបចាត់ជាកម្មពិត ។ ដោយហេតុនោះ លោកទើបពោលថា កម្មសង្គហៈមាន ៣ ។

ពីរបទថា នាសិតកា តយោ : **បុគ្គលដែលព្រះអង្គទ្រង់ត្រាស់ថា ត្រូវឱ្យវិនាស មាន ៣ ពួក** បានដល់ បុគ្គល ៣ ពួក ដែលសង្ឃឱ្យនាសនៈ( សឹក )ចេញ ដោយអំណាចលិង្គនាសនា សំវាសនាសនា និងទណ្ឌកម្មនាសនា គប្បីជ្រាប ( ដោយបាលី ) យ៉ាងនេះថា "ម្នាលភិក្ខុទាំងឡាយ បើដូច្នោះ អ្នកទាំងឡាយ ចូរឱ្យមេត្តិយាភិក្ខុនីសឹកចេញ,[១] សង្ឃត្រូវឱ្យវិនាសតែភិក្ខុ/សាមណេរដែលប្រទូស្ត,[២] សាមណេរប្រកបដោយអង្គ ១០ គួរឱ្យវិនាស, សង្ឃចូរញ៉ាំងកណ្ឌកសមណុទ្ទេសឱ្យវិនាសចុះ[៣]" ។

ពីរបទថា តិណ្ណន្នំ ឯកវាចិកា : **ជន ៣ ពួក ដែលត្រូវសូធ្យកម្មវាចាតែម្តងបាន** មានសេចក្តីថា អនុស្សាវនាតែមួយគួរដល់ជន ៣ មានឧបជ្ឈាយ៍ជាមួយគ្នា អាចារ្យផ្សេងគ្នា ដោយព្រះបាលីថា

១. វិន. សង្ឃា. ទុដ្ឋទោសសិក្ខាបទ. ២. ២៤៥/២៥៣ ។ ២. វិន. បារា. មេថុនធម្មសិក្ខាបទ. ១. ៤៦/១១១ ។ ៣. វិន. បាចិ. សប្បាណកវគ្គ. ៤. ២៩១/២៩៧ ។

"អនុជានាមិ ភិក្ខវេ ទ្វេ តយោ ឯកានុស្សាវនេ កាតុំ : ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឱ្យភិក្ខុសូធ្យសមនុភាសនាជាមួយគ្នា ចំពោះឧបសម្បទាបេក្ខៈពីរ ឬបីរូបបាន"(១) ។

## អាបត្តិក្នុងអធិដ្ឋានជាដើម

[៣៣៦] ពីរបទថា អធិដ្ឋានេ តិស្សោ : ក្នុងអធិដ្ឋានមានអាបត្តិ ៣ មានសេចក្ដីថា ព្រោះ(អធិដ្ឋាន)មួយបាទ ឬលើសជាង១បាទ ត្រូវអាបត្តិបារាជិក, លើសជាង ១ មាសក តិចជាង ៥ មាសក ត្រូវអាបត្តិថុល្លច្ច័យ, ១ មាសក ឬតិចជាងមួយមាសក ត្រូវអាបត្តិទុក្កដ ។

ពីរបទថា ចតស្សោ មេថុនប្បច្ចយា : អាបត្តិព្រោះមេថុនធម្មជាបច្ច័យ មាន ៤ មានសេចក្ដីថា ភិក្ខុសេពមេថុនក្នុងទ្វារដែលសត្វមិនទាន់ស៊ី ត្រូវអាបត្តិបារាជិក ។ ក្នុងទ្វារដែលសត្វស៊ីហើយដោយច្រើន ត្រូវអាបត្តិថុល្លច្ច័យ, ស៊កអង្គជាតិចូលទៅក្នុងមាត់ដែលហាប្រហ មិនឱ្យប៉ះខួប ត្រូវអាបត្តិទុក្កដ ។ ភិក្ខុនី ត្រូវអាបត្តិបាចិត្តិយ ព្រោះជង្គបត្ថមានសណ្ឋានរលីងដែលធ្វើអំពីអាចម៍ល័ក្ត ។

---

១. វិន. មហា. ឧបោសថក្ខន្ធកៈ. ៦. ១៤០/៣០៥ ។

ពីរបទថា ឆិន្ទន្តស្ស តិស្សោ : អាបត្តិ ៣ មានដល់ភិក្ខុដែលកាត់ មានសេចក្តីថា ត្រូវអាបត្តិបារាជិក ដល់ភិក្ខុដែល (លួច) កាត់ដើមឈើធំ, ត្រូវអាបត្តិបាចិត្តិយ ដល់ភិក្ខុកាត់ភូតគាម, ត្រូវអាបត្តិថុល្លច្ច័យ ដល់ភិក្ខុកាត់អង្គជាតិ ។

ពីរបទថា បញ្ច ឆឌ្ឌិតប្បច្ចយា : អាបត្តិ ៥ ដែលភិក្ខុត្រូវព្រោះចោលជាបច្ច័យ មានសេចក្តីថា ភិក្ខុចោលថ្នាំពិសមិនចំពោះ បើមនុស្សស្លាប់ ព្រោះថ្នាំពិសនោះ ត្រូវអាបត្តិបារាជិក, កាលយក្ខនិងប្រេតស្លាប់ ត្រូវអាបត្តិថុល្លច្ច័យ, កាលសត្វតិរច្ឆានស្លាប់ ត្រូវអាបត្តិបាចិត្តិយ ។ ព្រោះចោល គឺ បញ្ចេញសុក្កៈ ត្រូវអាបត្តិសង្ឃាទិសេស, ព្រោះបន្ទោបង់ឧច្ចារៈនិងបស្សាវៈលើរបស់ខៀវ ត្រូវអាបត្តិទុក្កដក្នុងសេក្ខិយវត្ត, អាបត្តិ ៥ កងនេះ រមែងមាន ព្រោះវត្ថុដែលចោល ជាបច្ច័យ ។

## ពិន័យអាបត្តិត្តួបបញ្ចូលគ្នាជាដើម

[៣៣៧] ច្រើនបទថា បាចិត្តិយេន ទុក្កដា កតា : ក៏មានទុក្កដលាយដោយបាចិត្តិយដែរ មានសេចក្តីថា លោកពិន័យទុក្កដលាយដោយបាចិត្តិយផង ក្នុងសិក្ខាបទទាំង ១០ ក្នុងភិក្ខុនោវាទកវគ្គ ។

ប្រើនបទថា ចតុរេត្ថ នវកា វុត្តា : ក្នុងបឋមសិក្ខាបទនេះ មាននវកៈ ៤ ដែលព្រះអង្គទ្រង់ត្រាស់ទុកមកហើយ មានសេចក្ដីថា ក្នុងសិក្ខាបទទី ១ នុ៎ះឯង លោកពោលពួកប្រាំបួនទុក ៤ ពួក យ៉ាងនេះ គឺ ក្នុងកម្មមិនប្រកបដោយធម៌ ២ ពួក ក្នុងកម្មប្រកបដោយធម៌ ២ ពួក ។

ពីរបទថា ទ្វិន្នំ[១] ចីវរេន ច : អាបត្តិដែលត្រូវព្រោះចីវរមានដល់ភិក្ខុពីរពួក មានសេចក្ដីថា ព្រោះចីវរជាដើមហេតុ រមែងត្រូវអាបត្តិដល់ភិក្ខុដែលឱ្យចីវរដល់ភិក្ខុនី ២ ពួក យ៉ាងនេះ គឺ ត្រូវអាបត្តិបាចិត្តិយដល់ភិក្ខុដែលឱ្យចីវរ ដល់ភិក្ខុនីដែលឧបសម្បទាក្នុងសំណាក់ភិក្ខុទាំងឡាយ, ត្រូវអាបត្តិទុក្កដ ដល់ភិក្ខុដែលឱ្យចីវរដល់ភិក្ខុនី ដែលឧបសម្បទា ក្នុងសំណាក់ភិក្ខុនីទាំងឡាយ ។

បាដិទេសនីយៈ ៨ មកហើយក្នុងបាលីនោះឯង ។

ប្រើនបទថា ភុញ្ជន្តាមកធញ្ញេន បាចិត្តិយេន ទុក្កដា កតា : អាបត្តិទុក្កដលាយដោយបាចិត្តិយ ព្រោះសូមស្រូវស្រស់យកមកឆាន់ក៏មានដែរ មានសេចក្ដីថា លោកពិន័យទុក្កដគួបបញ្ចូលនឹងបាចិត្តិយផងដល់ភិក្ខុនីដែលសូមស្រូវស្រស់ មកកិន បុក ចំអិនឆាន់ ។

១. ថៃ. ទ្វិន្នម្បិ ។

# អាបត្តិក្នុងការដើរជាដើម

[៣៣៩] ពីរបទថា គច្ឆន្តស្ស ចតស្សោ : អាបត្តិ ៤ មានដល់ភិក្ខុដែលដើរ មានសេចក្ដីថា ជាអាបត្តិ ៤ កងនេះដល់អ្នកទៅ គឺត្រូវអាបត្តិទុក្កដ ដល់ភិក្ខុដែលបបួលគ្នា ធ្វើដំណើរជាមួយភិក្ខុនី ឬមាតុគ្រាម, ត្រូវអាបត្តិបាចិត្តិយ កាលឈានចូលឧបចារស្រុក, ភិក្ខុនីណាមួយទៅកាន់ចន្លោះស្រុកតែម្នាក់ឯង កាលភិក្ខុនីនោះ ឈានជំហានដំបូងចូលទៅកាន់ឧបចារស្រុក ត្រូវអាបត្តិថុល្លច្ច័យ ជំហានទី ២ ទៅ ត្រូវអាបត្តិសង្ឃាទិសេស ។

ពីរបទថា ឋិតស្ស វាបិ តត្តកា : អាបត្តិ ៤ មានដល់ភិក្ខុដែលអង្គុយ មានសេចក្ដីថា អាបត្តិ ៤ កងនុ៎ះឯង រមែងមានសួម្បីដល់អ្នកឈរ ។ យ៉ាងណា ? យ៉ាងនេះ គឺ ភិក្ខុនីឈរក្នុងហត្ថបាសរបស់បុរស ដោយអំណាចមិត្តសន្ថវៈ ក្នុងទីងងឹត ឬក្នុងឱកាសកំបាំង ត្រូវអាបត្តិបាចិត្តិយ, ឈរ វៀរហត្ថបាស ត្រូវអាបត្តិទុក្កដ ។ ក្នុងវេលាអរុណរះ ឈរ វៀរហត្ថបាសរបស់ភិក្ខុនីដែលជាសម្លាញ់ ត្រូវអាបត្តិថុល្លច្ច័យ, វៀរហត្ថបាសឈរ ត្រូវអាបត្តិសង្ឃាទិសេស ។

ប្រើនបទថា និសិន្នស្ស ចតស្សោ អាបត្តិយោ និបន្នស្សាបិ-តត្តកា : ឯភិក្ខុដែលដេកក៏មានអាបត្តិប៉ុណ្ណោះដែរ មានសេចក្ដីថា ក៏

សូម្បីបើថា ភិក្ខុនីនោះ អង្គុយក្តី ដេកក្តី រមែងត្រូវអាបត្តិ ៤ កងនោះយ៉ាងនេះឯង ។

## អាបត្តិច្រើនត្រូវក្នុងខណៈជាមួយគ្នា

[៣៤០] ពីរបទថា **បញ្ច បាចិត្តិយានិ : ត្រូវអាបត្តិបាចិត្តិយទាំងអស់ ៥** មានសេចក្តីថា ភេសជ្ជៈ ៥ ដែលភិក្ខុទទួលប្រគេនហើយ មិនលាយគ្នា ដាក់ទុកក្នុងភាជនៈផ្សេងគ្នាក៏ដោយ ក្នុងភាជនៈជាមួយគ្នាក៏ដោយ ។ ព្រោះកន្លង ៧ ថ្ងៃ ភិក្ខុនោះ រមែងត្រូវអាបត្តិបាចិត្តិយទាំង ៥ វត្ថុ ផ្សេងគ្នា ក្នុងខណៈជាមួយគ្នា ។ មិនគប្បីពោលថា ត្រូវអាបត្តិនេះមុន ត្រូវអាបត្តិនេះក្រោយ ។

[៣៤១] ពីរបទថា **នវ បាចិត្តិយានិ : ត្រូវអាបត្តិបាចិត្តិយទាំងអស់ ៩** មានសេចក្តីថា ភិក្ខុណា សូមភោជនប្រណីត ៩ យ៉ាង ពូតបាយមួយពំនូតរួមគ្នានឹងភោជនប្រណីតទាំងនោះឯង ដាក់ទៅក្នុងមាត់ (លេប)ឱ្យកន្លងផុតបំពង់កចូលទៅ, ភិក្ខុនេះ រមែងត្រូវអាបត្តិបាចិត្តិយទាំង ៩ ដោយវត្ថុផ្សេងគ្នា ក្នុងខណៈជាមួយគ្នា ។ មិនគប្បីពោលថា ត្រូវអាបត្តិនេះមុន ត្រូវអាបត្តិនេះក្រោយ ។

# វិធីសម្តែងអាបត្តិ

[៣៨២] ពីរបទថា ឯកវាចាយ ទេសេយ្យ : គួរសម្តែង ដោយវាចាតែ ម្តងបាន មានសេចក្តីថា ភិក្ខុគប្បីសម្តែងដោយវាចាតែ ម្យ៉ាង យ៉ាងនេះថា "លោកដ៏ចម្រើន ខ្ញុំទទួលប្រគេនភេសជ្ជៈ ៥ ឱ្យ កន្លង ៧ ថ្ងៃទៅត្រូវអាបត្តិ ៥ សូមសម្តែងអាបត្តិទាំងនោះ ក្នុងសំណាក់ លោក" អាបត្តិទាំងនោះ ឈ្មោះថា លោកសម្តែងហើយពិត ; មិនមាន កិច្ចដែលនឹងត្រូវធ្វើដោយវាចា ២-៣ ដង ។ សូម្បីក្នុងវិសជ្ជនាទី ២ ក៏ គប្បីពោលថា "លោកដ៏ចម្រើន ខ្ញុំបានសូមភោជនប្រណីត ៩ យ៉ាងឆាន់ ត្រូវអាបត្តិ ៩ សូមសម្តែងអាបត្តិទាំងនោះ ក្នុងសំណាក់លោក" ។

[៣៨៤] ច្រើនបទថា វត្ថុំ កិត្តេត្វា ទេសេយ្យ : គួរប្រាប់វត្ថុ ទើបសម្តែងអាបត្តិបាន មានសេចក្តីថា គប្បីសម្តែងបញ្ចូលវត្ថុ យ៉ាងនេះ ថា "លោកដ៏ចម្រើន ខ្ញុំទទួលប្រគេនភេសជ្ជៈ ៥ ឱ្យកន្លង ៧ ថ្ងៃទៅ, ខ្ញុំសម្តែងអាបត្តិទាំងនោះតាមវត្ថុ ក្នុងសំណាក់លោក" ។ អាបត្តិទាំង ឡាយ ឈ្មោះថា ភិក្ខុនោះ សម្តែងហើយពិត ។ មិនមានកិច្ចដែលនឹង ត្រូវបញ្ជាក់ឈ្មោះអាបត្តិ ។ សូម្បីក្នុងវិសជ្ជនាទី ២ ក៏គប្បីពោលថា "លោកដ៏ចម្រើន ខ្ញុំបានសូមភោជនប្រណីត ៩ យ៉ាង ឆាន់ហើយ, ខ្ញុំ សម្តែងអាបត្តិទាំងនោះតាមវត្ថុ ក្នុងសំណាក់លោក" ។

## ត្រូវអាបត្តិក្នុងខណៈសួរឲ្យសមនុភាសនកម្មជាដើម

[៣៤៦] ពីរបទថា យាវតតិយកេ តិស្សោ : អាបត្តិ ៣ ដែលត្រូវក្នុងខណៈដែលសង្ឃសួរឲ្យសមនុភាសនកម្មជាគម្រប់ ៣ ដង មានសេចក្ដីថា អាបត្តិ ៣ កងក្នុងយាវតតិយកៈទាំងនេះ គឺ ជាអាបត្តិបារាជិកដល់ភិក្ខុនីដែលប្រព្រឹត្តតាមភិក្ខុដែលត្រូវសង្ឃលើកវត្ត, ជាអាបត្តិសង្ឃាទិសេសដល់ភិក្ខុទាំងឡាយ មានភិក្ខុកោកាលិកៈជាដើម ដែលប្រព្រឹត្តតាមភិក្ខុទេវទត្ត ដែលបានទម្លាយសង្ឃ និងជាអាបត្តិបាចិត្តិយដល់នាងចណ្ឌកាឡីភិក្ខុនី ព្រោះមិនលះបង់ទិដ្ឋិដ៏លាមក ។

ពីរបទថា ឆ វោហារបច្ចយា : អាបត្តិ ៦ ដែលត្រូវព្រោះពោលជាបច្ច័យ មានសេចក្ដីថា ភិក្ខុរមែងត្រូវអាបត្តិ ៦ មានវាចាដែលខនប្រកបជាបច្ច័យ ។ យ៉ាងណា ? យ៉ាងនេះ គឺ ភិក្ខុមានសេចក្ដីប្រាថ្នាអាក្រក់ លុះក្នុងអំណាចសេចក្ដីប្រាថ្នា ក៏ពោលអួតនូវឧត្តរិមនុស្សធម្មដែលមិនមាន មិនពិត ព្រោះហេតុអាជីវៈ ព្រោះដំណើរអាជីវៈ ត្រូវអាបត្តិបារាជិក ។ ភិក្ខុនិយាយដឹកនាំបុរសស្ត្រីឱ្យបានគ្នាជាប្ដីប្រពន្ធ ព្រោះហេតុអាជីវៈ ព្រោះដំណើរអាជីវៈ ត្រូវអាបត្តិសង្ឃាទិសេស ។ ភិក្ខុនិយាយ (ប្រាប់គេ)ថា "ភិក្ខុណានៅក្នុងវិហាររបស់អ្នក ភិក្ខុនោះជាព្រះអរហន្ត" ដូច្នេះ ព្រោះហេតុអាជីវៈ ព្រោះដំណើរអាជីវៈ កាលបើអ្នកស្ដាប់ដឹងសេចក្ដីច្បាស់ (ភិក្ខុនោះ) ត្រូវអាបត្តិថុល្លច្ច័យ ។ ភិក្ខុសូម

ភោជនប្រណីត ដើម្បីប្រយោជន៍ដល់ខ្លួនឆាន់ ព្រោះហេតុអាជីវៈ ព្រោះដំណើរអាជីវៈ ត្រូវអាបត្តិបាចិត្តិយ ។ ភិក្ខុនីសូមភោជនប្រណីត ដើម្បីប្រយោជន៍ដល់ខ្លួនឆាន់ ព្រោះហេតុអាជីវៈ ព្រោះដំណើរអាជីវៈ ត្រូវអាបត្តិបាដិទេសនីយៈ ។ ភិក្ខុមិនឈឺ សូមសម្លរក្តី បាយក្តី ដើម្បីប្រយោជន៍ដល់ខ្លួន យកមកឆាន់ ព្រោះហេតុអាជីវៈ ព្រោះដំណើរអាជីវៈ ត្រូវអាបត្តិទុក្កដ ។[១]

ពីរបទថា **ខាទន្តស្ស តិស្សោ : អាបត្តិ ៣ ដែលត្រូវព្រោះទំពាស៊ីជាបច្ច័យ** មានសេចក្តីថា ភិក្ខុត្រូវអាបត្តិថុល្លច្ច័យ ព្រោះសាច់មនុស្ស, ត្រូវអាបត្តិទុក្កដ ព្រោះអកប្បិយមំសៈដ៏សេស, ត្រូវអាបត្តិបាចិត្តិយ ដល់ភិក្ខុនីព្រោះខ្ទឹម ។

ពីរបទថា **បញ្ច ភោជនាបច្ចយា : អាបត្តិ ៥ ដែលត្រូវព្រោះភោជនជាបច្ច័យ** មានសេចក្តីថា ភិក្ខុនីមានតម្រេកទទួលភោជនអំពីដៃនៃបុរសបុគ្គល ដែលមានតម្រេកដែរ ច្របល់ឱ្យលាយគ្នាលេបចូលទៅ, មួយទៀត កាន់យកសាច់មនុស្ស ខ្ទឹម ភោជនប្រណីតដែលខ្លួនសូមដើម្បីប្រយោជន៍ដល់ខ្លួន និង អកប្បិយមំសៈដ៏សេស ច្របល់ឱ្យលាយគ្នាលេបចូលទៅ, រមែងត្រូវអាបត្តិ ៥ មានភោជនជាបច្ច័យ ទាំងនេះ គឺ សង្ឃាទិសេស ថុល្លច្ច័យ បាចិត្តិយ បាដិទេសនីយៈ ទុក្កដ ។

---

១. វិន. បរិ. វីសតិវារៈ. ១២. ៨៧៧/៣៩៩ ។

# ស្ថានៈ ៥ នៃយាវតតិយកាបត្តិជាដើម

[៣៤៧] ពីរបទថា បញ្ច ឋានានិ : នូវស្ថាន ៥ មានសេចក្តីថា យាវតតិយកាបត្តិទាំងពួង រមែងដល់ឋានៈ ៥ យ៉ាងនេះ គឺ សម្រាប់ភិក្ខុនី ប្រព្រឹត្តតាមភិក្ខុដែលសង្ឃលើកវត្ត មិនព្រមលះបង់ ដោយវាចាប្រកាស ៣ ដង ព្រោះញត្តិ ត្រូវអាបត្តិទុក្កដ, ព្រោះកម្មវាចា ២ ត្រូវអាបត្តិថុល្លច្ច័យ, ក្នុងទីបំផុតនៃកម្មវាចា ត្រូវអាបត្តិបារាជិក, (សម្រាប់ភិក្ខុ) ព្រោះព្យាយាមបំបែកសង្ឃជាដើម ត្រូវអាបត្តិសង្ឃាទិសេស និងព្រោះមិនព្រមលះបង់ទិដ្ឋិដ៏លាមក ត្រូវអាបត្តិបាចិត្តិយ ។

ពីរបទថា បញ្ចន្នញ្ច អាបត្តិ : អាបត្តិមានដល់បុគ្គល ៥ ពួក មានសេចក្តីថា ដែលឈ្មោះថា អាបត្តិ រមែងមានដល់សហធម្មិកទាំង ៥ ។ ក្នុងសហធម្មិកទាំង ៥ នោះ ដោយនិប្បរិយាយ អាបត្តិរមែងមានដល់ភិក្ខុនិងភិក្ខុនី ២ ពួកប៉ុណ្ណោះ ។ តែសម្រាប់នាងសិក្ខមានា សាមណេរ និងសាមណេរី អាបត្តិរមែងមានដោយបរិយាយនេះថា ភាពជារបស់មិនគួរ រមែងមិនគួរ ។ សហធម្មិក ៣ នោះ ភិក្ខុមិនគប្បីឱ្យសម្តែងអាបត្តិ, តែគប្បីដាក់ទណ្ឌកម្មដល់ពួកលោក ។

ពីរបទថា បញ្ចន្នំ អធិករណោន ៥ : អធិករណ៍ មានដល់

បុគ្គល ៥ ពួក មានសេចក្ដីថា ក៏ឯអធិករណ៍ រមែងមានដល់សហធម្មិកទាំង ៥ ដូចគ្នា ។ ពិតមែន វិនិច្ឆ័យវោហារ ដើម្បីប្រយោជន៍ដល់បរិក្ខារ មានបាត្រ និងចីវរជាដើម របស់សហធម្មិកទាំង ៥ នុ៎ះឯង ហៅថា អធិករណ៍ ចំណែកវិនិច្ឆ័យវោហារ របស់គ្រហស្ថ រមែងចាត់ជាអដ្ដកម្ម (គឺការពោលក្ដី) ។

[៣៤៨] ច្រើនបទថា បញ្ចន្នំ វិនិច្ឆយោ ហោតិ : ការវិនិច្ឆ័យមានដល់បុគ្គល ៥ ពួក មានសេចក្ដីថា ដែលឈ្មោះថា វិនិច្ឆ័យរបស់សហធម្មិកទាំង ៥ ពួកនុ៎ះឯង ក៏មាន ។

ពីរបទថា បញ្ចន្នំ វូបសមេន ច : ការរម្ងាប់អធិករណ៍មានដល់បុគ្គល ៥ ពួក មានសេចក្ដីថា អធិករណ៍របស់សហធម្មិកទាំង ៥ ពួកនុ៎ះឯង ដែលបានវិនិច្ឆ័យហើយ ឈ្មោះថា ជាការរម្ងាប់ទៅ ។

ពីរបទថា បញ្ចន្នញ្ចេវ អនាបត្តិ : អនាបត្តិមានដល់បុគ្គល ៥ ពួក មានសេចក្ដីថា ដែលឈ្មោះថា អនាបត្តិរមែងមានដល់សហធម្មិកទាំង ៥ ពួកនុ៎ះឯង ។

ច្រើនបទថា តីហិ ឋានេហិ សោភតិ : បុគ្គលរុងរឿងដោយស្ថាន ៣ យ៉ាង មានសេចក្ដីថា ភិក្ខុរមែងល្អដោយហេតុ ៣ មានសង្ឃជាដើម ។ ពិតមែន បុគ្គលអ្នកធ្វើសេចក្ដីល្មើសហើយ សម្ដែងអាបត្តិ

ចេញ ដែលនៅអាចសម្តែង ចេញបាន នៅកណ្តាលជំនុំសង្ឃ ឬនៅកណ្តាលគណៈ ឬក្នុងសំណាក់បុគ្គល រមែងជាអ្នកមានសីលក្តៅនិងអាប់អួ ត្រឡប់តាំងនៅដូចដើម ។ ព្រោះហេតុនោះ ទើបលោកពោលថា បុគ្គលរុងរឿងដោយស្ថាន ៣ យ៉ាង ។

## អាបត្តិមកកាយក្នុងរាត្រីជាដើម

[៣៤៩] ប្រើនបទថា ទ្វេ កាយិកា រត្តឹ : អាបត្តិដែលតាំងឡើងអំពីកាយ ហើយត្រូវតែក្នុងរាត្រី មាន ២ មានសេចក្តីថា ភិក្ខុនីត្រូវអាបត្តិមកកាយទ្វារជាដែនកើត ២ យ៉ាង ក្នុងរាត្រី គឺ កាលសម្រេចការឈរអន្ធយនិង ដេក ក្នុងហត្ថបាសរបស់បុរសក្នុងវេលាងងឹត ៗ យប់ងងឹត ត្រូវអាបត្តិបាចិត្តិយ; កាលសម្រេចការឈរជាដើម លះហត្ថបាស ត្រូវអាបត្តិទុក្កដ ។

ប្រើនបទថា ទ្វេ កាយិកា ទិវា : អាបត្តិដែលតាំងឡើងអំពីកាយ ហើយត្រូវតែក្នុងវេលាថ្ងៃ មាន ២ មានសេចក្តីថា ភិក្ខុនីត្រូវអាបត្តិ ២ កង ក្នុងឱកាសដែលកំបាំង ក្នុងវេលាថ្ងៃ ដោយឧបាយនោះឯង ។

ប្រើនបទថា និជ្ឈន្តស្ស ឯកា អាបត្តិ : អាបត្តិ ១ ដែលត្រូវព្រោះគយគន់ មានសេចក្តីថា អាបត្តិមួយកងនេះ រមែងមានដល់ភិក្ខុដែលសម្លឹងមើល (ដោយព្រះពុទ្ធដីកា)ថា "ម្នាលភិក្ខុទាំងឡាយ តែថាភិក្ខុមិនគួរគ្រេកអរសម្លឹងមើលអង្គជាតមាតុគ្រាមឡើយ ភិក្ខុណាសម្លឹងមើល ភិក្ខុនោះ ត្រូវអាបត្តិទុក្កដ"[១] ។

ពីរបទថា ឯកា បិណ្ឌបាតបច្ចយា : អាបត្តិ ១ ដែលត្រូវព្រោះបិណ្ឌបាតជាបច្ច័យ បានដល់ អាបត្តិទុក្កដ ដែលត្រាស់ក្នុងបាលីនេះថា "ន ច ភិក្ខវេ ភិក្ខាទាយិកាយ មុខំ ឱលោកេតព្វំ : ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយកុំសម្លឹងមើលមុខស្រីដែលប្រគេនចង្ហាន់"[២] ។ ពិតមែន ដោយហោចទៅ សូម្បីសម្លឹងមើលមុខសាមណេរដែលប្រគេនបបរ ឬបាយ ក៏ត្រូវអាបត្តិទុក្កដ ដូចគ្នា ។

តែក្នុងកុរុន្ទីពោលថា ពាក្យថា អាបត្តិតែមួយកង ព្រោះបិណ្ឌបាតជាបច្ច័យ បានដល់ ភិក្ខុឆាន់បិណ្ឌបាត ដែលភិក្ខុនីណែនាំឱ្យថ្វាយ ត្រូវអាបត្តិបាចិត្តិយ ។

---

១. វិន. សង្ឃា. សុក្កវិស្សដ្ឋិសិក្ខាបទ. ២. ៦២/៤៧ ។

២. វិន. ចុល្ល. វត្តក្ខន្ធកៈ. ១១. ៩១/១១៧ ។

# ភិក្ខុដែលសង្ឃលើកវត្តជាដើម

[៣៥០] ពីរបទថា អដ្ឋានិសំសេ សម្បស្សំ : ភិក្ខុឃើញអានិសង្ស ៨ យ៉ាង បានដល់ អានិសង្សដែលត្រាស់ទុកក្នុងកោសម្ពិកក្ខន្ធកៈ ។

ប្រើនបទថា ឧក្ខិត្តកា តយោ វុត្តា : ឧក្ខិត្តកភិក្ខុព្រះមានព្រះភាគទ្រង់ត្រាស់ថា មាន ៣ ពួក បានដល់ (ភិក្ខុដែលសង្ឃលើកវត្ត ៣ ពួក ព្រោះហេតុ ៣ ប្រការ គឺ ) ព្រោះមិនឃើញអាបត្តិ ១ ព្រោះមិនសម្ដែងចេញ ១ ព្រោះមិនព្រមលះបង់ទិដ្ឋិលាមក ១ ។

ពីរបទថា តេចត្តាឡីស សម្មាវត្តនា : ការប្រព្រឹត្តដោយប្រពៃមាន ៤៣ បានដល់ ការប្រព្រឹត្តប្រពៃ ក្នុងវត្តទាំងឡាយ មានប្រមាណប៉ុណ្ណោះ របស់ភិក្ខុដែលត្រូវសង្ឃលើកវត្តទាំងនោះឯង ។

[៣៥១] ពីរបទថា បញ្ចដ្ឋានេ មុសាវាទោ : មុសាវាទដល់ស្ថាន ៥ យ៉ាង មានសេចក្ដីថា មុសាវាទ រមែងដល់ឋានៈ ៥ ពោលគឺ បារាជិក សង្ឃាទិសេស ថុល្លច្ច័យ បាចិត្តិយ និងទុក្កដ ។

ប្រើនបទថា ចុទ្ទស បរមន្តិ វុច្ចតិ : ព្រះមានព្រះភាគទ្រង់

ត្រាស់ថា អាបត្តិដែលមានកំណត់ថ្ងៃ ( នោះ ) មាន ១៤ បានដល់ សិក្ខាបទដែលពោលហើយក្នុងកាលមុន ដោយន័យមាន ១០ ថ្ងៃជាយ៉ាងយូរ ជាដើម ។

ពីរបទថា ទ្វាទស បាដិទេសនីយា : បាដិទេសនីយៈ មាន១២ បានដល់ បាដិទេសនីយៈរបស់ភិក្ខុ៤ បាដិទេសនីយៈរបស់ភិក្ខុនី៨ ។

ពីរបទថា ចតុន្នំ ទេសនាយ ច : បុគ្គល ៤ ពួក ដែលគួរសម្តែងទោស មានសេចក្តីថា ការសម្តែងទោសដែលប្រព្រឹត្តកន្លងរបស់បុគ្គល ៤ ពួក ។ សួរថា ក៏ការសម្តែងទោសដែលប្រព្រឹត្តកន្លង ៤ យ៉ាងនោះ តើអ្វីខ្លះ ? គឺ ឈ្មោះថា ការសម្តែងទោសដែលប្រព្រឹត្តកន្លងរបស់បុគ្គល ៤ ពួកនេះ គឺការសម្តែងទោសដែលប្រព្រឹត្តកន្លងរបស់នាយខ្មាន់ធ្នូ ដែលប្រាថ្នាទៅធ្វើគតព្រះមានព្រះភាគ ដែលភិក្ខុទេវទត្តបញ្ជូនទៅ, ការសម្តែងទោសដែលប្រព្រឹត្តកន្លងនៃឧបដ្ឋាយិការបស់ព្រះអនុរុទ្ធត្ថេរ, ការសម្តែងទោសដែលប្រព្រឹត្តកន្លងរបស់វឌ្ឍលិច្ឆវី, ការសម្តែងទោសដែលប្រព្រឹត្តកន្លងរបស់ភិក្ខុទាំងឡាយ ដែលធ្វើឧក្ខេបនីយកម្មដល់ព្រះវាសភគាមិយត្ថេរ ហើយត្រឡប់មក ។

## មុសាវាទមានអង្គ ៨ ជាដើម

[៣៩២] ពីរបទថា អដ្ឋង្គិកោ មុសាវាទោ : មុសាវាទដែលប្រកបដោយអង្គ ៨ មានសេចក្ដីថា មុសាវាទដែលប្រកបដោយអាការ ៨ យ៉ាង ដែលមានអាការខាងដើមថា "មុសាវាទនៃបុគ្គលនោះ ក្នុងកាលមុនថា អាត្មាអញនឹង ពោលពាក្យកុហក" ដូច្នេះ អាការខាងចុងថា "វិនិធាយ សញ្ញំ : បិទបាំងនូវ សញ្ញា"[១] ចាត់ថា មុសាវាទ ប្រកបដោយអង្គ ៨ ។

សូម្បីអង្គឧបោសថ ៨ ក៏បានពោលហើយ ដោយន័យមានពាក្យថា មិនគប្បីសម្លាប់សត្វជាដើម ។

ពីរបទថា អដ្ឋ ទូតេយ្យង្គានិ : អង្គរបស់ភិក្ខុដែលគួរដល់ទូតកម្ម មាន ៨ បានដល់ (អង្គជួយសង្គ្រោះដល់ភាពជាទូត ៨ ប្រការ) ដែលព្រះមានព្រះភាគត្រាស់ទុកក្នុងសង្ឃភេទក្ខន្ធកៈ ដោយន័យមានពាក្យថា "ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកស្ដាប់បានដោយខ្លួនឯង ១ ញុំាងបុគ្គលដទៃឱ្យស្ដាប់បាន ១"[២] ជាដើម ។

---

១. ខុទ្ទ. មហា. បារាយនវគ្គ. ៦៤. ២៤៩/២៩០ ឃើញអាការនេះជាទី៧, ឯទី៨នោះថា "វិនិធាយ ភាវំ : ព្រោះលាក់ទុកនូវការកើតឡើង" ។ ២. វិន. ចុល្ល. សង្ឃភេទក្ខន្ធកៈ. ១១. ៦២/៧០ ។

តិត្ថិយវត្ត ៨ បានពោលហើយក្នុងមហាខន្ធកៈ ។

[៣៥៣] ពាក្យថា អដ្ឋវាចិកា ឧបសម្បទា : ឧបសម្បទា ប្រកបដោយកម្មវាចា ៨ លោកពោលសំដៅដល់ឧបសម្បទារបស់ភិក្ខុនីទាំងឡាយ ។

ពីរបទថា អដ្ឋន្នំ បច្ចុដ្ឋាតព្វំ : ភិក្ខុនីត្រូវក្រោកទទួលចំពោះភិក្ខុនី ៨ ពួក មានសេចក្តីថា ភិក្ខុនីទាំងឡាយក្រៅនេះ គប្បីក្រោកឡើងឱ្យអាសនៈដល់ភិក្ខុនី ៨ រូប ក្នុងរោងឆាន់ ។

ពីរបទថា ភិក្ខុនោ វាទកោ អដ្ឋហិ : ភិក្ខុប្រកបដោយអង្គ ៨ ទើបគួរប្រដៅភិក្ខុនីបាន មានសេចក្តីថា ភិក្ខុដែលប្រកបដោយអង្គ ៨ ដែលសង្ឃគប្បីសន្មតឱ្យជាអ្នកទូន្មានភិក្ខុនី ។

[៣៥៤] វិនិច្ឆ័យក្នុងគាថាថា ឯកស្ស ឆេជ្ជំ : ឆេជ្ជវត្ថុមានដល់បុគ្គល ១ ពួក គប្បីជ្រាបដូច្នេះ ៖

ក្នុងជន ៩ ភិក្ខុណា ឱ្យចាប់ស្លាកទម្លាយសង្ឃ ការដាច់ រមែងមានដល់ភិក្ខុនោះឯង គឺ រមែងត្រូវអាបត្តិបារាជិក ដូចជាភិក្ខុទេវទត្ត ។ ជាអាបត្តិថុល្លច្ច័យ ដល់បុគ្គល ៤ នាក់ ដែលប្រព្រឹត្តតាមភិក្ខុបំបែកសង្ឃ ដូចភិក្ខុទាំងឡាយ មានព្រះកោកាលិកៈជាដើម ។ មិនមានអាបត្តិដល់បុគ្គល ៤ រូប ដែលជាធម្មវាទី ។ ក៏អាបត្តិនិងអនាបត្តិទាំងនេះ របស់អ្នកទាំងពួង មានវត្ថុជាមួយគ្នា គឺ មានសង្ឃភេទជាវត្ថុប៉ុណ្ណោះ ។

# កម្មជាប់ដោយញត្តិជាដើម

[៣៥៥] វិនិច្ឆ័យក្នុងគាថាថា នវ អាឃាតវត្ថូនិ : អាឃាតវត្ថុ មាន ៩ យ៉ាង គប្បីជ្រាបដូច្នេះ ៖

បទថា នវហិ : ដោយភិក្ខុ ៩ រូប មានសេចក្តីថា សង្ឃរមែងបែកគ្នា ព្រោះភិក្ខុ ៩ រូប ។

ត្រើនបទថា ញត្តិយា ការណា នវ : កិច្ចដែលធ្វើដោយញត្តិ មាន ៩ យ៉ាង មានសេចក្តីថា កម្មដែលសង្ឃគប្បីធ្វើដោយញត្តិ មាន ៩ យ៉ាង ។

ពាក្យដ៏សេស ងាយយល់ទាំងអស់ ។

[៣៥៦] ត្រើនបទថា ទស បុគ្គលា នាភិវាទេតព្វា : បុគ្គល ១០ ពួក ដែលមិនគួរអភិវាទ បានដល់ ជន (ដែលមិនគួរសំពះ) ១០ ពួក ដែលត្រាស់ទុក ក្នុងសេនាសនក្ខន្ធកៈ ។

ពីរបទថា អញ្ជលិសាមិចេន ច : និងបុគ្គលដែលមិនគួរធ្វើអញ្ជលីកម្ម និងសាមីចិកម្ម មានសេចក្តីថា អញ្ជលីកម្មព្រមទាំងសាមីចិកម្ម ដែលភិក្ខុមិនគប្បីធ្វើដល់ជនទាំង ១០ នោះ, អធិប្បាយថា វត្តក្នុងខន្ធកៈ មានសួរដល់ទឹកផឹក និងចាប់យកផ្ចិតស្លឹកត្នោតជាដើម ដែល

ភិក្ខុមិនគប្បីសម្ដែងដល់ជន ១០ ពួកនោះ អញ្ជលីក៏មិនគប្បីផ្គង ។

ពីរបទថា ទសន្នំ ទុក្កដំ : អាបត្តិទុក្កដមានដល់បុគ្គល ១០ ពួក មានសេចក្ដីថា ភិក្ខុដែលធ្វើយ៉ាងនោះ ដល់អ្នកទាំង ១០ នោះឯង ត្រូវអាបត្តិទុក្កដ ។

ពីរបទថា ទស ចីវរធារណា : ការទុកតិរេកចីវរបានត្រឹម ១០ ថ្ងៃ មានសេចក្ដីថា អនុញ្ញាតឱ្យទ្រទ្រង់អតិរេកចីវរទុក ១០ ថ្ងៃ ។

[៣៥៧] ច្រើនបទថា បញ្ចន្នំ វស្សំ វុត្ថានំ ទាតព្វំ ឥធ ចីវរំ : ក្នុងសាសនានេះ បុគ្គលត្រូវឱ្យចីវរដល់បុគ្គល ៥ ពួក ដែលនៅចាំវស្សារួចហើយ បានដល់ គប្បីឱ្យចំពោះមុខសហធម្មិកទាំង ៥ តែម្ដង ។

ពីរបទថា សត្តន្នំ សន្តេ : កាលបើបុគ្គលអ្នកទទួលដ៏សមគួរ បុគ្គលត្រូវឱ្យចីវរដល់បុគ្គល ៧ ពួក មានសេចក្ដីថា កាលមានអ្នកទទួលជំនួសដែលសមគួរគប្បីឱ្យកំបាំងមុខក៏បាន ដល់ជន ៧ ទាំងនេះ គឺ ភិក្ខុដែលជៀសទៅកាន់ទិសផ្សេង ៗ ភិក្ខុឆ្កួត ភិក្ខុដែលមានចិត្តរវើរវាយ ភិក្ខុដែលត្រូវវេទនាគ្របសង្កត់ និងភិក្ខុត្រូវសង្ឃលើកវត្ត ៣ ពួក ។

ពីរបទថា សោឡសន្នំ ន ទាតព្វំ : មិនត្រូវឱ្យចីវរដល់បុគ្គល

១៦ ពួក មានសេចក្តីថា មិនគួរឱ្យដល់ជនដ៏សេស ១៦ ពួកមានបណ្ឌកៈជាដើម ដែលត្រាស់ទុក ក្នុងចីវរក្ខន្ធកៈ ។

[៣៥៨] ត្រើនបទថា កតិសតំ រត្តិសតំ អាបត្តី[១] ជាទយិត្វាន : ភិក្ខុបិទបាំងអាបត្តិអស់មួយរយរាត្រី ត្រូវជាប៉ុន្មានរយអាបត្តិ មានសេចក្តីថា ភិក្ខុបិទអាបត្តិប៉ុន្មានរយ ទុកមួយរយរាត្រី ។

ត្រើនបទថា ទសសតំ រត្តិសតំ អាបត្តី[១] ជាទយិត្វាន : ភិក្ខុបិទបាំងអាបត្តិអស់មួយរយរាត្រី ត្រូវជាមួយពាន់អាបត្តិ មានសេចក្តីថា ភិក្ខុបិទអាបត្តិមួយពាន់ ទុកមួយរយរាត្រី ។

ក៏សេចក្តីសង្ខេបក្នុងពាក្យនេះ ដូចតទៅនេះ ៖

ភិក្ខុណា ត្រូវអាបត្តិសង្ឃាទិសេស មួយថ្ងៃមួយរយ ៗ បិទទុកដប់ថ្ងៃ ៗ គ្រប់ ១០ ដង ។ អាបត្តិមួយពាន់, ឈ្មោះថា ភិក្ខុនោះ បិទទុកមួយរយរាត្រី ។ ភិក្ខុនោះ គប្បីសូមបរិវាសថា អាបត្តិទាំងអស់នោះតែម្តង ខ្ញុំបិទទុក ១០ ថ្ងៃ ហើយជាបារិវាសិកៈ នៅបរិវាស ១០ រាត្រី គប្បីផុតបាន ។

១. ភូមា. អាបត្តិយោ ។

# ទោសរបស់កម្មជាដើម

[៣៥៩] ច្រើនបទថា ទ្វាទស កម្មទោសា វុត្តា : ទ្រង់ត្រាស់ទោសរបស់កម្ម មាន ១២ មានសេចក្តីថា ព្រះមានព្រះភាគត្រាស់ទោសរបស់កម្ម ១២ រាប់កម្មមួយ ៗ ៣ ក្នុងកម្មនីមួយ ៗ យ៉ាងនេះ គឺ អបលោកនកម្ម ជាពួកមិនប្រកបដោយធម៌, ព្រមព្រៀងមិនប្រកបដោយធម៌, ជាពួកប្រកបដោយធម៌; សូម្បីញត្តិកម្ម ញត្តិទុតិយកម្ម ញត្តិចតុត្ថកម្ម ក៏ដូចគ្នា ។

[៣៦០] ពីរបទថា ចតស្សោ កម្មសម្បត្តិយោ : សម្បត្តិរបស់កម្ម មាន ៤ មានសេចក្តីថា កម្មសម្បត្តិដែលត្រាស់ទុក ៤ ប្រការ យ៉ាងនេះ គឺ អបលោកនកម្ម ព្រមព្រៀងប្រកបដោយធម៌ សូម្បីកម្មដ៏សេស ក៏ដូចគ្នា ។

[៣៦១] ពីរបទថា ឆ កម្មានិ : កម្ម មាន ៦ មានសេចក្តីថា កម្ម ៦ យ៉ាង ដែលត្រាស់ទុកយ៉ាងនេះគឺ កម្មមិនប្រកបដោយធម៌ កម្មជាពួក កម្មព្រមព្រៀង កម្មជាពួក ប្រកបដោយធម៌ប្លម កម្មព្រមព្រៀងប្រកបដោយធម៌ប្លម កម្មព្រមព្រៀង ប្រកបដោយធម៌ ។

ច្រើនបទថា ឯកេត្ថ ធម្មិកា កតា : ប្រកបដោយធម៌ មានតែមួយពួក មានសេចក្តីថា ក្នុងកម្ម ៦ យ៉ាងនេះ កម្មព្រមព្រៀង

ប្រកបដោយធម៌តែម្យ៉ាងប៉ុណ្ណោះ ត្រាស់ថា ជាកម្មដែលប្រកបដោយធម៌ ។

សូម្បីក្នុងពាក្យតបក្នុងគាថា ទី ២ កម្មព្រមព្រៀងគ្នាដោយធម៌ទុំះ ៦៨ ក៏ជាកម្មប្រកបដោយធម៌ (ដូចគ្នា) ។

## អាបត្តិរម្ងាប់និងមិនរម្ងាប់

[៣៦៣] ពីរបទថា យំ ទេសិតំ : **បានសម្តែងនូវកងនៃអាបត្តិទាំងឡាយណា** មានសេចក្តីថា កងអាបត្តិពួកណា ដែលព្រះអនន្តជិនទ្រង់សម្តែងហើយត្រាស់ហើយ គឺ ប្រកាសហើយ ។

វិនិច្ឆ័យក្នុងពាក្យថា អនន្តជិនេន ជាដើម គប្បីជ្រាបដូច្នេះ ៖

និព្វាន ហៅថា **អនន្ត:** ព្រោះវៀរចាកភាពជាធម៌មានទីបំផុតជុំវិញ ដែលបណ្ឌិតនឹងកំណត់បាន ។ និព្វាននោះ ដែលព្រះមានព្រះភាគទ្រង់បង្ក្រាបកងកិលេស ឈ្នះហើយ ឈ្នះដាច់ខាតហើយ គឺ សម្រេចហើយ ដល់ព្រមហើយ ប្រៀបដូចរាជសម្បត្តិដែលព្រះរាជាទ្រង់បង្ក្រាបពួកសត្រូវបានហើយ ដូច្នោះ ។ ព្រោះហេតុនោះ ព្រះមានព្រះភាគ បណ្ឌិតទើបតាំងនាមនោះ ព្រះនាមនោះថា **អនន្តជិន:** ប្រែថា ព្រះមានព្រះភាគ

ទ្រង់បាននូវព្រះនិព្វាន ។

ព្រះអនន្តជិនៈនោះឯង ឈ្មោះថា អ្នករឹងមាំ ព្រោះទ្រង់មិនមានវិការ (ប្រែប្រួល) ក្នុងឥដ្ឋារម្មណ៍និងអនិដ្ឋារម្មណ៍ ។ ព្រះអង្គឃើញវិវេក ៥ ពោលគឺ តទង្គវិវេក វិក្ខម្ភនវិវេក សមុច្ឆេទវិវេក បដិបស្សទ្ធិវិវេក និងនិស្សរណវិវេក ព្រោះដូច្នោះ ទើបឈ្មោះថា អ្នកឃើញវិវេក ។ កងអាបត្តិពួកណា ដែលព្រះអនន្តជិនៈ ទ្រង់ជាអ្នករឹងមាំ ទ្រង់ឃើញវិវេកនោះ ទ្រង់សម្តែងហើយ ។

ក្នុងពាក្យថា ឯកេត្ថ សម្មតិ វិនា សមថេហិ : បណ្តាកងនៃអាបត្តិទាំងនុ៎ះ មានតែកងនៃអាបត្តិ ១ គឺបារាជិក ដែលមិនរម្ងាប់ដោយសមថទាំងឡាយទេ នេះ មានបទសម្ព័ន្ធដូច្នេះ ៖

កងអាបត្តិ ៧ ពួកណា ដែលព្រះសាស្តាទ្រង់សម្តែងហើយក្នុងកងអាបត្តិ ៧ នោះ អាបត្តិសូម្បីមួយកង វៀរចាកសមថៈទាំងឡាយចេញហើយ មិនអាចរម្ងាប់បានទេ ។ ដោយពិត ធម៌ទាំងអស់នេះ គឺ សមថៈ ៦ អធិករណ៍ ៤ រមែងរម្ងាប់ គឺ រមែងដល់សេចក្តីប្រកបដោយប្រពៃ ដោយសម្មុខាវិន័យ ។ តែក្នុងធម៌ទាំងនេះ សម្មុខាវិន័យតែម្យ៉ាងនោះឯង វៀរសមថៈទាំងឡាយចេញ រមែងរម្ងាប់ គឺ រមែងដល់ភាពជាសមថៈបាន ។ ពិតមែន ដែលឈ្មោះថា ការវៀរចាកសមថៈដទៃចេញសម្រេចមិនបាននៃសម្មុខាវិន័យនោះ មិនមានទេ ដោយហេតុនោះ លោក

ទើបពោលថា ក្នុងអាបត្តិ ៧ កងនេះ អាបត្តិមួយកងវៀរសមថៈ ចេញក៏រម្ងាប់បាន សេចក្តីនេះ លោកពោលទុកក្នុងអដ្ឋកថាទាំងឡាយដោយអធិប្បាយនេះមុន ៗ តែខ្ញុំកាន់យកសេចក្តីត្រឹមតែបដិសេធនៃនិបាត គឺ វិនា, ពេញចិត្តក្នុងសេចក្តីដែលថា ពាក្យថា ឯកោត្ថ សម្មតិ វិនា សមថេហិ មានសេចក្តីថា ក្នុងអាបត្តិ ៧ កងនោះ កងអាបត្តិបារាជិកតែមួយកង វៀរសមថៈចេញ ក៏រម្ងាប់បានគឺ រមែងរម្ងាប់ដោយសមថៈទាំងឡាយ ក៏ទេ ៗ ពិតមែន សូម្បីព្រះមានព្រះភាគ ក៏បានត្រាស់ពាក្យនេះថា "អាបត្តិណា ជាអនវសេសាបត្តិ (មិនមានចំណែកសេសសល់) អាបត្តិនោះ មិនរម្ងាប់ដោយអធិករណ៍ណាទេ មិនរម្ងាប់ក្នុងទីណាទេ មិនរម្ងាប់ដោយសមថៈណាទេ"[១] ៗ

## បុគ្គលដែលបំបែកសង្ឃទៅកាន់អបាយ

[៣៦៤] បទថា ឆ ឡុនទិយឌ្ឍសតា : បុគ្គល ១៥៤ ពួក មានសេចក្តីថា គប្បីជ្រាបបុគ្គលដែលបំបែកសង្ឃត្រូវទៅកាន់អបាយ ១៥៤ ពួក ដោយអំណាចបុគ្គល ៨ ពួក គុណដោយភេទករវត្ថុ ១៨ យ៉ាង, ដែលព្រះមានព្រះភាគត្រាស់ទុកក្នុងសង្ឃភេទយ៉ាងនេះថា "ម្នាល

១, មាន ១. វិន. បរិ. អធិករណភេទ. ១៣. ១៣៥-៦/១៥២-៤ ៗ

ឧបាលិ ភិក្ខុក្នុងសាសនានេះសម្តែង សភាពមិនមែនធម៌ថាជាធម៌ មានសេចក្តីយល់ឃើញក្នុងអធម៌នោះ ថា មិនមែនជាធម៌មែន មានសេចក្តីយល់ឃើញក្នុងការបំបែក ថាមិនមែនជាធម៌ដែរ១, សេចក្តីយល់ឃើញក្នុងអធម៌នោះ ថាមិនមែនជាធម៌មែន តែមានសេចក្តីយល់ឃើញក្នុងការបំបែកសង្ឃ ថាជាធម៌វិញ១, មានសេចក្តីយល់ឃើញក្នុងអធម៌នោះ ថាមិនមែនជាធម៌មែន តែមានសេចក្តីសង្ស័យក្នុងការបំបែក១, មានសេចក្តីយល់ឃើញក្នុងអធម៌នោះ ថាជាធម៌វិញ តែមានសេចក្តីយល់ឃើញក្នុងការបំបែកថា មិនមែនជាធម៌១, មានសេចក្តីយល់ឃើញក្នុងអធម៌នោះថាជាធម៌វិញ តែមានសេចក្តីសង្ស័យក្នុងការបំបែក១, មានសេចក្តីសង្ស័យក្នុងអធម៌នោះ, មានសេចក្តីយល់ឃើញក្នុងការបំបែកថា មិនមែនជាធម៌១, មានសេចក្តីសង្ស័យក្នុងអធម៌នោះ មានសេចក្តីយល់ឃើញក្នុងការបំបែកថា ជាធម៌ទៅវិញ សេចក្តីសង្ស័យក្នុងអធម៌នោះ និងមានសេចក្តីសង្ស័យក្នុងការបំបែក១ ។[១] នេះ ជាបុគ្គលពួកទី១ ដែលមាន ៨ យ៉ាង ឯបុគ្គលពួកទី២ រហូតដល់ពួកទី១៨ នោះ ក៏មានសេចក្តីប្រហែល ៗ គ្នាដែរ (សេចក្តីពិស្តារមានក្នុងសង្ឃភេទក្ខន្ធកៈ) ។

[៣៦៥] ពីរបទថា អដ្ឋារស ឆាថាយិកា : បុគ្គល ១៨ ពួក

---

១. វិន. ចុល្ល. សង្ឃភេទក្ខន្ធកៈ. ១១. ៧៥/៨៥ ។

ដែលមិនទៅកើតក្នុងអបាយ បានដល់ ជន ១៨ ពួក ដែលព្រះមានព្រះភាគត្រាស់ ក្នុងទីបំផុតនៃសង្ឃភេទក្ខន្ធកៈ រាប់ពួកមួយ ៗយ៉ាងនេះថា "ម្នាលឧបាលិ ភិក្ខុក្នុងសាសនានេះ សម្តែងសភាពមិនមែនធម៌ថា ជាធម៌, មានសេចក្តីយល់ឃើញ ក្នុងធម៌នោះថា ជាធម៌, មានសេចក្តីយល់ឃើញក្នុងការបំបែកថា ជាធម៌, ហើយមិនបិទបាំងទិដ្ឋិ, មិនបិទបាំងសេចក្តីគាប់ចិត្ត មិនបិទបាំងសេចក្តីពេញចិត្ត មិនបិទបាំងសេចក្តីពិតត្រង់ ហើយសូធ្យឱ្យភិក្ខុចាប់ស្លាក ដោយពាក្យថា នេះជាធម៌ នេះជាវិន័យ នេះជាពាក្យប្រៀនប្រដៅរបស់ព្រះសាស្តា លោកទាំងឡាយចូរចាប់ស្លាកនេះចុះ ចូរពេញចិត្តនឹងស្លាកនេះចុះ, ម្នាលឧបាលិ ភិក្ខុបំបែកសង្ឃនេះឯង មិនទៅកើតក្នុងអបាយ មិនទៅកើតក្នុងនរក មិនឋិតនៅអស់ ១ កប្ប គួរដល់កិរិយារក្សាបាន"[១] ។

ពួកប្រាំបី ១៨ ពួក បានពោលរួចហើយ ក្នុងពាក្យវិសជ្ជនាដោយបុគ្គលដែលបំបែកសង្ឃ ១៤៤ ពួក ។

[៣៦៧] វិសជ្ជនាគាថា ទាំងពួង ថា **កតិ កម្មានិ : កម្មមានប៉ុន្មានយ៉ាង** ជាដើម ងាយយល់ទាំងអស់ដូច្នេះឯង ។

អបរទុតិយគាថាសង្គណិកវណ្ណនា ចប់

១. វិន. ចុល្ល. សង្ឃភេទក្ខន្ធកៈ. ១១. ៧៦/៨៨ ។

# ពណ៌នាសេទមោចនគាថា

វិនិច្ឆ័យក្នុងសេទមោចនគាថា គប្បីជ្រាបដូច្នេះ ៖

[៣៧៩] បទថា អសំវាសោ : មិនមានសំវាស មានសេចក្ដីថា អ្នកមិនមានសំវាស ដោយសំវាស មានឧបោសថ និងបវារណាជាដើម ។

ច្រើនបទថា សម្ភោគោ ឯកច្ចោ តហឹ ន លព្ភតិ : សម្ភោគពួកមួយ មិនបានក្នុងបុគ្គលនោះទេ មានសេចក្ដីថា ការបរិភោគរួមជាមួយគ្នាដែលមិនសមគួរ ដែលភិក្ខុនិងភិក្ខុនីទាំងឡាយ រមែងមិនបានក្នុងបុគ្គលនោះ តែបុគ្គលនោះ ដែលភិក្ខុនីជាមាតាបុំណ្ណោះ រមែងបានដើម្បីធ្វើការចិញ្ចឹមថែទាំដោយអាការឱ្យងូតទឹក និងឱ្យបរិភោគជាដើម ។

ពីរបទថា អវិប្បវាសេន អនាបត្តិ : ការនៅរួមមិនត្រូវអាបត្តិ មានសេចក្ដីថា មិនមានអាបត្តិព្រោះដេកក្នុងផ្ទះរួមគ្នា (ដល់ភិក្ខុនី) ។

ច្រើនបទថា បញ្ហា មេសា កុសលេហិ ចិន្តិតា : ប្រស្នានេះពួកលោកអ្នកឈ្លាសវៃ បានគិតមកហើយ មានសេចក្ដីថា បញ្ហានេះដែលអ្នកឆ្លាត គឺ បណ្ឌិតទាំងឡាយ គិតគ្នាហើយ ។

ពាក្យឆ្លើយបញ្ហានោះ គប្បីជ្រាបដោយភិក្ខុនីដែលជាមាតារបស់ទារក ។

ពិតមែន ពាក្យឆ្លើយនោះ ត្រាស់សំដៅដល់បុត្ររបស់ភិក្ខុនីនោះ ។

[៣៨០] គាថាពោលអំពីរបស់មិនគួរចែក ត្រាស់សំដៅដល់គរុភណ្ឌ ។ ក៏សេចក្តីនៃគាថានោះ ខ្ញុំបានពោលរួចហើយ ក្នុងវារៈដែលវិនិច្ឆ័យដោយភ័ណ្ឌ ។

[៣៨១] ច្រើនបទថា ទស បុគ្គលេ ន វទាមិ : យើងមិនបានពោលចំពោះអវន្ទិយបុគ្គលទាំង ១០ ពួកទេ មានសេចក្តីថា ខ្ញុំមិនពោលដល់បុគ្គល ១០ ពួក ដែលពោលហើយក្នុងសេនាសនក្ខន្ធកៈ ។

ច្រើនបទថា ឯកាទស វិវជ្ជិយ : ទាំងអភព្វបុគ្គល ១១ មានសេចក្តីថា មិនបានពោលដល់បុគ្គលគួរវៀរ ១១ ពួក ដែលបានពោលហើយក្នុងមហាខន្ធកៈ ។ បញ្ហានេះត្រាស់សំដៅដល់ភិក្ខុដែលអាក្រាតកាយ ។

[៣៨២] បញ្ហាដែលថា កថំ នុ សិក្ខាយ អសាធារណោ : ភិក្ខុនោះ មិនសាធារណៈដោយសិក្ខា ដូចម្តេច នេះ ត្រាស់សំដៅដល់ភិក្ខុដែលធ្លាប់ជាជាងកោរសក់ ។ ពិតមែន ភិក្ខុដែលធ្លាប់ជាជាងកោរសក់នេះ មិនបានដើម្បីរក្សាកាំបិតកោរទុក ។ តែភិក្ខុពួកដទៃ រមែងរក្សាបាន; ព្រោះហេតុនោះ ភិក្ខុដែលធ្លាប់ជាជាងកោរសក់ ទើបឈ្មោះថា ជា

អ្នកមិនទូទៅចំពោះសិក្ខា ។

[៣៨៣] បញ្ហាដែលថា តំ បុគ្គលំ កតមំ វទន្តិ ពុទ្ធា : ព្រះពុទ្ធទាំងឡាយ ត្រាស់បុគ្គលនោះថា ដូចម្ដេចទៅវិញ នេះ ត្រាស់សំដៅដល់ព្រះពុទ្ធនិមិត្ត ។

[៣៨៤] ពីរបទថា អធោនាភឹ វិវជ្ជិយ : ទាំងអវយវៈតាំងពីផ្ចិតចុះមកក្រោម ក៏លើកលែងដែរ មានសេចក្ដីថា វៀរខាងក្រោមផ្ចិតចេញ ។ បញ្ហានេះ ត្រាស់សំដៅដល់សត្វកពន្ធៈ[១] មិនមានក្បាល មានភ្នែកនិងមាត់នៅត្រង់ទ្រូង ។

[៣៨៥-៦] បញ្ហាទី ១ ដែលថា ភិក្ខុ សញ្ញាចិកាយ កុដឹ : ភិក្ខុធ្វើកុដិដោយការសូមគ្រឿងឧបករណ៍គេមកដោយខ្លួនឯង នេះ ត្រាស់សំដៅដល់កុដិប្រក់ដោយស្មៅ ។ បញ្ហាទី ២ ពោលសំដៅដល់កុដិដែលសម្រេចដោយដីសុទ្ធ ។

[៣៨៧-៨] បញ្ហាទី ១ ដែលថា អាបជ្ជេយ្យ គរុកំ ឆេជ្ជវត្ថុំ

---

១. សត្វកពន្ធៈ ជាសត្វប្រភេទមួយ ដែលចាត់ចូលក្នុងពួកអមនុស្ស លោកថា ជាសត្វនៅគង់កពន្ធធ្មេញមិនចូលបាញ់មិនចេញ ។ ទំនងដូចគ្នានឹងសត្វវេតាល ទេដឹង ពាក្យថា នៅគង់កពន្ធៈ ក៏ចេញមកពីពាក្យនេះ ។

: តែឧបសម្បន្ននោះ ត្រូវគរុការបត្តិ ជាវត្ថុដាច់ចាកភិក្ខុនីភាវៈ នេះ ត្រាស់សំដៅដល់ភិក្ខុនីដែលបិទបាំងទោស ។ បញ្ហាទី ២ ត្រាស់សំដៅដល់អភព្វបុគ្គល មានបណ្ឌកៈជាដើម បើចូលមកបួសហើយ ទោះបីឥតប្រព្រឹត្តអាក្រក់សោះ ក៏ត្រូវតែឱ្យវិនាស គឺ បណ្តេញចេញ ។ ពិតមែន អភព្វបុគ្គលទាំង ១១ ពួកនោះ ត្រូវបារាជិកក្នុងភេទគ្រហស្ថហើយនោះឯង ។

[៣៨៩] បទថា វាចា : កាលទឹងបញ្ចេញវាចា បានដល់ មិនប្រាប់ដោយវាចា ។

ច្រើនបទថា គិរំ នោ ច បរេ ភណេយ្យ : ក៏មិនបានពោលចំពោះអ្នកដទៃឡើយ មានសេចក្តីថា ភិក្ខុមិនត្រូវថ្លែងសូម្បីនូវសំនៀងដេរបុគ្គលពួកដទៃ ដោយបំណងថា ជនទាំងនេះ ទឹងស្តាប់យ៉ាងនេះ, បញ្ហានេះ ត្រាស់សំដៅដល់មុសាវាទនេះថា "ភិក្ខុណា... មិនប្រាប់អាបត្តិដែលមាន ភិក្ខុនោះ ត្រូវសម្បជានមុសាវាទទុក្កដ"[១] ; ពិតមែន ធម្មតាអាបត្តិក្នុងមនោទ្វារ រមែងមិនមានដល់ភិក្ខុនោះ ដែលអន្ទយស្ងៀមដោយបដិញ្ញាមិនប្រកបដោយធម៌ តែព្រោះហេតុដែលមិនប្រាប់អាបត្តិ

១. វិន. មហា. ឧបោសថក្ខន្ធកៈ. ៦. ១៤៩/៣៤០ ។

ដែលគួរប្រាប់អាបត្តិនេះ គប្បីជ្រាបថា កើតពីការមិនធ្វើក្នុងវចីទ្វាររបស់ភិក្ខុនោះ ។

ភិក្ខុនីណាមួយ ទៅកាន់ចន្លោះស្រុកតែម្នាក់ឯង កាលភិក្ខុនីនោះឈាន ១ ជំហានដំបូង ចូលទៅកាន់របងនៃស្រុកដែលមានរបង ត្រូវអាបត្តិថុល្លច្ច័យ ជំហានទី ២ ទៅ ត្រូវអាបត្តិសង្ឃាទិសេស ។

[៣៩០] បញ្ហាដែលថា សង្ឃាទិសេសា ចតុរោ : សង្ឃាទិសេស ៤ សិក្ខាបទ នេះ ត្រាស់សំដៅដល់ ភិក្ខុនីដែលទៅកាន់ត្រើយស្ទឹងខាងនាយតែម្នាក់ឯង ដែលរាប់ជាប់ក្នុងចន្លោះស្រុក ក្នុងវេលាអរុណរះ ។ ពិតមែន ភិក្ខុនីនោះ លួមចេញពីស្រុករបស់ខ្លួន ក្នុងវេលាជិតភ្លឺទៅ កាន់ត្រើយស្ទឹង ដែលមានប្រការដូចពោលហើយ ក្នុងវេលាអរុណរះ រមែងត្រូវអាបត្តិសង្ឃាទិសេស ៤ ដែលកំណត់ដោយការនៅប្រាសចាកគ្នីគ្នារហូតអស់រាត្រី១ ទៅកាន់ចន្លោះស្រុកតែម្នាក់ឯង ១ ទៅកាន់ត្រើយស្ទឹងតែម្នាក់ឯង ១ គេចចេញពីពួកទៅតែម្នាក់ឯង ១ ព្រមគ្នាតែម្តង ។

[៣៩១] បញ្ហាដែលថា សិយា អាបត្តិយោ នានា : ត្រូវអាបត្តិផ្សេង ៗ គ្នា នេះ ត្រាស់សំដៅដល់ភិក្ខុនី ២ រូប ដែលឧបសម្បទា អំពីសង្ឃមួយផ្នែក ។ ពិតមែន ក្នុងភិក្ខុនី ២ រូបនោះ ភិក្ខុទទួលយកចីវរ អំពីដៃនាងភិក្ខុនី ដែលបានឧបសម្បទា អំពីសំណាក់

ភិក្ខុសង្ឃតែម្ខាង ត្រូវអាបត្តិបាចិត្តិយ[១] ។ ភិក្ខុទទួលយកចីវរអំពីដៃភិក្ខុនី ដែលបានឧបសម្បទា អំពីសំណាក់ឯកតោសង្ឃ (គឺខាងភិក្ខុនីសង្ឃតែម្ខាង) ត្រូវអាបត្តិទុក្កដ[២] ។

[៣៩២] ប្រើនបទថា ចតុរោ ជនា សំវិធាយ : ជន គឺភិក្ខុ ៤ រូប បបួលគ្នា មានសេចក្ដីថា អាចារ្យ ១ និងអន្តេវាសិក ៣ លួចភណ្ឌៈ ៦ មាសក ។ គឺ របស់អាចារ្យ លួចដោយដៃរបស់ខ្លួនឯង ៣ មាសក បង្គាប់ឱ្យលួចទៀត ៣ មាសក ព្រោះដូច្នោះ អាចារ្យត្រូវអាបត្តិថុល្លច្ច័យ ។ ចំណែករបស់ពួកអន្តេវាសិក លួចដោយដៃរបស់ខ្លួនឯងមួយរូប ៗ ១ មាសក បង្គាប់ឱ្យលួចមួយរូប ៗ ៥ មាសក ព្រោះហេតុដូច្នោះ អន្តេវាសិកទាំង ៣ នោះ ទើបត្រូវអាបត្តិបារាជិកដោយប្រការយ៉ាងនេះ សេចក្ដីសង្ខេបក្នុងគាថា នេះប៉ុណ្ណេះ ។ ចំណែកសេចក្ដីពិស្ដារបានពោលទុកហើយក្នុងសំវិធាវហារវណ្ណនានៃអទិន្នាទានបារាជិក ។

[៣៩៣] បញ្ហាដែលថា ឆិទ្ទំ តស្មឹ ឃរេ ឧត្ថិ : ក្នុងផ្ទះនោះឥតប្រហោងសោះ នេះ ត្រាស់សំដៅដល់កុដិ ដែលបិទបាំងដោយសំពត់ជាដើម និងវត្ថុដែលកំណត់ជាកម្រាលបាន ។

១. ដូចជាសាកិយានីទាំង ៥០០, ភិក្ខុក្លាយភេទទៅជាភិក្ខុនី ។ ២. វិន. និស្ស. ៣. ៥១/៤៦ ។

[៣៩៤] គាថាថា តេលំ មធុ ផាណិតំ : ប្រេង ទឹកឃ្មុំ ទឹកអំពៅ ត្រាស់សំដៅដល់ការក្លាយភេទ ។

[៣៩៥] គាថាថា និស្សគ្គិយេន : និស្សគ្គិយបាចិត្តិយ ត្រាស់សំដៅដល់ការបង្អោនលាភសង្ឃ ។ ពិតមែន ភិក្ខុណា បង្អោនចីវរ ២ ផ្ទាំង អំពីលាភដែលគេបង្អោនទៅហើយដើម្បីថ្វាយសង្ឃ គឺ ចីវរ ១ ផ្ទាំង ដើម្បីខ្លួន, ១ ផ្ទាំង ដើម្បីភិក្ខុដទៃ ដោយប្រយោគតែមួយថា លោកចូរឱ្យដល់ខ្ញុំ ១ ផ្ទាំង ដល់ភិក្ខុនោះ ១ ផ្ទាំង ។ ភិក្ខុនោះ ត្រូវនិស្សគ្គិយបាចិត្តិយ និងសុទ្ធិកបាចិត្តិយព្រមគ្នា ។

[៣៩៦] បញ្ហាដែលថា កម្មញ្ច តំ កុប្បេយ្យ វគ្គបច្ចយា : សង្ឃកម្មនោះកម្រើក ព្រោះបច្ច័យគឺកម្មនោះជាពួក នេះ ត្រាស់សំដៅដល់គាមសីមា ក្នុងនគរទាំងឡាយ មាននគរពារាណសីជាដើម ដែលមានប្រមាណ ១២ យោជន៍ ។

[៣៩៧] គាថាថា បទវីតិហារមត្តេន : ដោយគ្រាន់តែឈានទៅ ត្រាស់សំដៅយកការនិយាយដឹកនាំ ។ ក៏សេចក្តីនៃគាថានោះ ខ្ញុំបានពោលហើយក្នុងវណ្ណនានៃសញ្ចរិត្តសិក្ខាបទនុ៎ះឯង ។

បញ្ហាដែលថា សព្វានិ តានិ និស្សគ្គិយានិ : តែចីវរទាំងអស់នោះជានិស្សគ្គិយ នេះ ត្រាស់សំដៅដល់ ការប្រើភិក្ខុនី ដែលមិនមែន

ញាតិឱ្យបោកគក់ ។ ពិតមែន សូម្បីបើថា ភិក្ខុនីកាន់យកត្រៃចីវរ ដែលក្អែកជុះអាចម៍ស្រោចលើ ឬប្រលាក់កក់ បោកគក់ដោយទឹក ត្រៃចីវរដែលនៅក្នុងកាយរបស់ភិក្ខុទាំងឯង ជានិស្សគ្គិយ ។

[៣៩៩] ត្រើនបទថា សរណគមនម្បិ ន ច តស្ស អត្ថិ : ម្យ៉ាងទៀត សរណគមរបស់បុគ្គលនោះ ក៏មិនមាន មានសេចក្តីថា សូម្បីការឧបសម្បទាដោយសរណគមន៍ ក៏មិនមាន ។ បញ្ហានេះ ត្រាស់សំដៅដល់ការឧបសម្បទារបស់ព្រះនាងមហាបជាបតី ។

[៤០០] បាទគាថាថា ហនេយ្យ អនរិយំ មន្ទោ : បុគ្គលនោះត្រូវអនន្តរិយកម្ម ព្រោះការសម្លាប់នោះ មានសេចក្តីថា បុគ្គលល្ងង់សម្លាប់បុគ្គលសូម្បីនោះ ជាស្រីក៏ដោយ ជាប្រុសក៏ដោយ ដែលមិនមែនព្រះអរិយបុគ្គល ។ បញ្ហានេះ ត្រាស់សំដៅដល់បិតាដែលក្លាយជាស្រី និងមាតាដែលក្លាយជាប្រុស ព្រោះក្លាយភេទ ។

[៤០១] បញ្ហាដែលថា ន តេនានន្តរំ ផុសេ : ក៏មិនត្រូវអនន្តរិយកម្ម ព្រោះការសម្លាប់នោះ នេះ ត្រាស់សំដៅដល់មាតាបិតាជាសត្វតិរច្ឆាន ដូចមាតារបស់មិគសិង្គតាបស និងបិតារបស់សីហកុមារជាដើម ។

[៤០២] គាថាថា អចោទយិត្វា : ភិក្ខុមិនបានចោទ ត្រាស់

សំដៅដល់ការឧបសម្បទាដោយទូត ។

[៤០៣] គាថាថា **ចោទយិត្វា** : ភិក្ខុបានចោទ ត្រាស់សំដៅដល់ការឧបសម្បទារបស់អភព្វបុគ្គល មានបណ្ឌកៈជាដើម ។

តែពាក្យដែលមកក្នុងកុរុន្ទីថា គាថាទី ១ ត្រាស់សំដៅដល់កម្មមិនចំពោះមុខ ៨ យ៉ាង គាថាទី ២ ត្រាស់សំដៅដល់កម្មរបស់ភិក្ខុដែលមិនមានអាបត្តិ ។

[៤០៤] ពីរបទថា **ឆិន្ទន្តស្ស អាបត្តិ** : ភិក្ខុកាត់ ត្រូវអាបត្តិក៏មាន បានដល់ ភិក្ខុដែលកាត់ដើមឈើធំ ត្រូវអាបត្តិបារាជិក, ភិក្ខុដែលកាត់ស្មៅនិងវល្លិ ត្រូវអាបត្តិបាចិត្តិយ, ភិក្ខុដែលកាត់អង្គជាតិ ត្រូវអាបត្តិថុល្លច្ច័យ ។

ពីរបទថា **ឆិន្ទន្តស្ស អនាបត្តិ** : ភិក្ខុកាត់ មិនត្រូវអាបត្តិក៏មាន គឺ មិនមានអាបត្តិ ដល់ភិក្ខុអ្នកកោរសក់ និងកាត់ក្រចក ។

បទថា **ឆាទេន្តស្ស** : ភិក្ខុបិទបាំង គឺ ជាអាបត្តិ ដល់ភិក្ខុដែលបិទអាបត្តិ ។

បទថា **អនាបត្តិ** : មិនត្រូវអាបត្តិក៏មាន គឺ មិនមានអាបត្តិដល់ភិក្ខុដែលប្រក់ផ្ទះជាដើម ។

[៤០៥] វិនិច្ឆ័យក្នុងគាថាថា **សច្ចំ ភណន្តោ** : ភិក្ខុពោល

**ពាក្យពិត គប្បីជ្រាបដូច្នេះ ៖**

ភិក្ខុនិយាយពាក្យពិត ចំពោះស្ត្រីជាសិខរណី និងខ្ទើយថា "ស្រីមានសិរ ស្រីមានភេទ ២ ដូច្នេះ រមែងត្រូវគរុកាបត្តិ ។ តែជាលហុកាបត្តិ ដល់ភិក្ខុដែលពោលកុហក ព្រោះសម្បជានមុសាវាទ ។ កាលពោលកុហក ព្រោះអួតឧត្តរិមនុស្សធម្មដែលមិនមានពិត ត្រូវគរុកាបត្តិ ។ ជាលហុកាបត្តិ ដល់ភិក្ខុដែលនិយាយពិត ព្រោះអួតឧត្តរិមនុស្សធម្មដែលមានពិត ។

[៤០៦] គាថាថា **អធិដ្ឋិតំ : ចីវរដែលភិក្ខុបានអធិដ្ឋាន** ត្រាស់សំដៅដល់ភិក្ខុដែលមិនលះបង់មុន បរិភោគចីវរដែលជានិស្សគ្គិយ ។

[៤០៧] គាថាថា **អត្ថង្គតេ សុរិយេ : កាលបើព្រះអាទិត្យអស្តង្គតហើយ** ត្រាស់សំដៅដល់ភិក្ខុដែលច្រើនកុត ឬភើអាហារចេញមក ។

[៤០៨] គាថាថា **ន រត្តចិត្តោ : មិនមានតម្រេក** មានសេចក្តីដូចតទៅនេះ ៖

ភិក្ខុមានចិត្តតម្រេក ត្រូវមេថុនធម្មបារាជិក មានថេយ្យចិត្ត ត្រូវអទិន្នាទានបារាជិក ញ៉ាំងអ្នកដទៃឱ្យពេញចិត្តដើម្បីស្លាប់ ត្រូវមនុស្សវិគ្គហបារាជិក ។ តែភិក្ខុដែលទម្លាយសង្ឃ មិនមែនជាអ្នកមានចិត្ត

តម្រេក និងមិនមែនជាអ្នកមានថេយ្យចិត្ត ទាំងជាអ្នកមិនបានបបួលអ្នកដទៃដើម្បីស្លាប់ឡើយ ។ តែការដាច់ គឺ ត្រូវអាបត្តិបារាជិក រមែងមានដល់អ្នកឱ្យស្លាក ។ ជាអាបត្តិថុល្លច្ច័យដល់ភិក្ខុដែលទទួលស្លាក គឺ ប្រព្រឹត្តតាមភិក្ខុបំបែកសង្ឃ ។

[៤០៩] បញ្ហាដែលថា គច្ឆេយ្យ អឌ្ឍយោជនំ : **ហើយទៅកាន់ទីមានប្រមាណកន្លះយោជន៍** នេះ ត្រាស់សំដៅដល់មួយឈើរបស់ត្រកូលមួយ ដូចដើមជ្រៃដែលល្អ ខ្ពស់ត្រឈឹងត្រឈៃ ។ ដើមឈើនោះ មានមែកធំហើយវែង, ប្រវែង ១ យោជន៍ ឬ ២ យោជន៍ ទោះបីភិក្ខុនោះ ទុកដាក់ចីវរក្រោមមួយឈើនោះ ហើយដើរទៅចម្ងាយកន្លះយោជន៍ ហើយអរុណរះឡើង ក៏មិនជាអាបត្តិ ព្រោះមិនទាន់ផុតពីមួយនៅឡើយ[១] ។

[៤១០] គាថាថា កាយិកានិ : **ប្រកបដោយកាយ** ត្រាស់សំដៅដល់ភិក្ខុដែលចាប់សរសៃសក់ ឬម្រាមដៃរបស់ស្រីច្រើននាក់រួមជាមួយគ្នា ក្នុងគ្រាតែមួយ ។

[៤១១] គាថាថា វាចសិកានិ : **ប្រកបដោយវាចា** នេះ ត្រាស់សំដៅដល់ភិក្ខុដែលពោលពាក្យអាក្រក់គ្រោតគ្រាត ដោយន័យជា

១. វិន. បរិ. សេទមោចនគាថា. ១៣. ៤១១ ។

ដើមថា នាងទាំងអស់គ្នា ជាសិខរណី ។

[៤១២] ច្រើនបទថា តិស្សិត្ថិយោ មេថុនំ តំ ន សេវេ : ឧបសម្បន្ន មិនសេពមេថុនធម្មនឹងស្រី ៣ ពួកនោះ មានសេចក្តីថា មិនបានសេពមេថុន សួម្បីក្នុងស្រី ៣ ពួក ដែលត្រាស់ទុក ។

ពីរបទថា តយោ បុរិសេ : នឹងបុរស ៣ ពួកទៀត មានសេចក្តីថា នឹងបានចូលរកប្រុសទាំង ៣ ពួកហើយសេពមេថុន ក៏ទេ ។

ពីរបទថា តយោ ច អនរិយបណ្ឌកេ : នឹងអនរិយជន ៣ ពួក និងបណ្ឌក ៣ ពួក មានសេចក្តីថា នឹងបានចូលរកជន ៦ ពួក សួម្បីទាំងនេះ គឺ អ្នកមិនប្រសើរ ៣ ពួក ពោលគឺ ឧភតោព្យញ្ជនកៈ និងបណ្ឌកៈ ៣ ពួក ហើយ សេពមេថុន ក៏ទេ ។

ពីរបទថា ន ចាចរេ មេថុនំ ព្យញ្ជនស្មឹ : មួយទៀត មិនបានប្រព្រឹត្តមេថុនធម្មក្នុងព្យញ្ជន មានសេចក្តីថា ប្រព្រឹត្តមេថុន សួម្បីដោយអំណាចអនុលោមបារាជិក ក៏ទេ ។

ពាក្យថា ត្រូវឆេជ្ជវត្ថុ (វត្ថុញាំងឱ្យដាច់ភាវៈ) ព្រោះមេថុនធម្មជាបច្ច័យ បានដល់ ត្រូវអាបត្តិបារាជិក ព្រោះមេថុនធម្មជាបច្ច័យ បញ្ហាដូចពោលមកនេះ ត្រាស់សំដៅដល់អដ្ឋវត្ថុកបារាជិក (របស់ភិក្ខុនី) ។ ពិតមែន រមែងដាច់ភាវៈ ព្រោះមេថុនធម្មជាបច្ច័យដល់ភិក្ខុនីនោះ ដែល

ព្យាយាម ដើម្បីស្ទាបអង្អែលដោយកាយដែលជាបុព្វភាគនៃមេថុនធម្ម ។

[៤១៣] គាថាថា **មាតរំ ចីវរំ** : (ភិក្ខុសូម)ចីវរនឹងមាតា នេះ ត្រាស់សំដៅដល់ ការដាស់តឿនឱ្យកើតសតិ ដើម្បីបានសំពត់វស្សិកសាដិក ក្នុងវេលាក្រោយសម័យ ។

ក៏ឯវិនិច្ឆ័យនៃគាថានោះ ខ្ញុំបានពោលហើយ ក្នុងវណ្ណនានៃវស្សិកសាដិកសិក្ខាបទនុ៎ះឯង ។

គាថាថា **កុទ្ធោ អារាធកោ ហោតិ** : **បុគ្គលក្រោធខឹងហើយត្រឡប់ជាត្រេកអរវិញ** ត្រាស់សំដៅដល់វត្តរបស់តិរ្ថិយ ។ សេចក្ដីពិស្ដារនៃពាក្យនោះ ត្រាស់ហើយក្នុងតិត្ថិយវត្តនុ៎ះឯងថា អនុត្ថិយដែលបំពេញវត្ត កាលគុណរបស់ពួកតិរ្ថិយ ដែលជនដទៃសរសើរហើយ ក្រោធហើយ រមែងជាអ្នកញ៉ាំងភិក្ខុទាំងឡាយឱ្យត្រេកអរ ។ កាលគុណនៃព្រះរតនត្រ័យដែលជនដទៃសរសើរហើយ ក្រោធហើយ រមែងជាអ្នកដែលភិក្ខុទាំងឡាយគប្បីតិះដៀល ។

[៤១៥] សូម្បីគាថាទី៣ ក៏ត្រាស់សំដៅដល់តិត្ថិយវត្តនោះឯង ។

[៤១៦] គាថាថា **សង្ឃាទិសេសំ** ជាដើម ត្រាស់សំដៅដល់ភិក្ខុនី ដែលមានតម្រេកទទួលបិណ្ឌបាត អំពីដៃរបស់បុរសដែលមានតម្រេកហើយ លាយបញ្ចូលនឹងសាច់មនុស្ស ខ្ទឹម ភោជនប្រណីត និង

អកប្បិយមំសៈដ៏សេស ហើយបរិភោគ ។

[៤១៧] គាថាថា ឯកោ អនុបសម្បន្នោ ឯកោ ឧបសម្បន្នោ : តែកុលបុត្រមួយរូបជាឧបសម្បន្ន មួយរូបទៀត ជាអនុបសម្បន្ន ជាដើម ត្រាស់សំដៅដល់សាមណេរ ដែលទៅក្នុងអាកាស ។ ក៏បើថាក្នុងសាមណេរ ២ រូប មួយរូបជាអ្នកអង្គុយផុតពីផែនដី សូម្បីតែមួយចុងសរសៃសក់ ដោយឫទ្ធិ ។ សាមណេរនោះ រមែងជាអនុបសម្បន្នពិត ។ សូម្បីសង្ឃអង្គុយក្នុងអាកាស ក៏ មិនគប្បីធ្វើកម្មដល់អនុបសម្បន្ន ដែលនៅលើផែនដី ។ បើធ្វើ កម្មរមែងកម្រើក ។

[៤១៨] គាថាថា អកប្បកតំ : សំពត់ដែលភិក្ខុមិនបានធ្វើពិន្ទុកប្ប ត្រាស់សំដៅដល់ ភិក្ខុដែលមានចីវរត្រូវចោរដណ្តើមយកទៅ ។ សូម្បីវិនិច្ឆ័យនៃគាថានោះ ខ្ញុំបានពោលហើយ ដោយពិស្តារក្នុងសិក្ខាបទនោះឯង ។

[៤១៩] ច្រើនបទថា ន ទេតិ នប្បដិគ្គណ្ហាតិ : ឧបសម្បន្ន ១ មិនបានឱ្យ, ឧបសម្បន្ន ១ មិនបានទទួល មានសេចក្តីថា សូម្បីភិក្ខុនីជាអ្នកប្រើ ក៏មិនបានឱ្យ, ភិក្ខុនីដែលគេប្រើក៏មិនបានទទួលអំពីដៃរបស់ភិក្ខុនីដែលប្រើ ។

ច្រើនបទថា បដិគ្គហោ តេន ន វិជ្ជតិ : ព្រោះហេតុនោះ ការ

ទទួលនោះមិនមានទេ មានសេចក្តីថា ដោយហេតុនោះឯង ភិក្ខុនីដែលប្រើ ក៏មិនមានការទទួលអំពីដៃរបស់ភិក្ខុនីដែលប្រើទេ ។

ពីរបទថា អាបជ្ជតិ គរុកំ : តែឧបសម្បន្ននោះ ត្រូវគរុកាបត្តិ មានសេចក្តីថា សូម្បីកាលជាយ៉ាងនោះ ភិក្ខុនីដែលប្រើ រមែងត្រូវអាបត្តិសង្ឃាទិសេស ព្រោះភិក្ខុនីដែលខ្លួនប្រើទៅបានទទួលបិណ្ឌបាត អំពីដៃបុរសដែលមានតម្រេក ។

ពីរបទថា តញ្ច បរិភោគបច្ចយា : កាលដែលនឹងត្រូវអាបត្តិនោះ ក៏ត្រូវព្រោះការបរិភោគជាបច្ច័យ មានសេចក្តីថា ក៏ភិក្ខុនីដែលប្រើ កាលនឹងត្រូវអាបត្តិនោះ រមែងត្រូវព្រោះការបរិភោគរបស់ភិក្ខុនីដែលទទួលប្រើនោះ ជាបច្ច័យ ។ ពិតមែន រមែងជាអាបត្តិសង្ឃាទិសេសដល់ភិក្ខុនីដែលប្រើ ក្នុងខណៈសម្រេចការឆាន់របស់ភិក្ខុនីដែលទទួលប្រើនោះ ។

[៤២០] គាថាទី ២ លោកពោលសំដៅដល់ការប្រើទៅ ក្នុងការទទួលទឹក និងឈើស្ទន់របស់ភិក្ខុនីដែលប្រើនោះឯង ។ ឯកិច្ចដែលត្រូវនោះ មានវិធីដូចគ្នា នឹងគាថាទី ១ ។

[៤២១] ប្រើនបទថា ន ភិក្ខុនី នោ ច ផុសេយ្យ វជ្ជំ : ឧបសម្បន្នមិនមែនជាភិក្ខុនី តែមិនត្រូវទោស មានសេចក្តីថា ពិតហើយ

ភិក្ខុនីត្រូវអាបត្តិសង្ឃាទិសេសណាមួយ ក្នុង១៧ សិក្ខាបទ សូម្បីបិទទុកដោយមិនអើពើ ក៏មិនត្រូវទោស គឺ មិនត្រូវអាបត្តិថ្មីដទៃ ព្រោះការបិទជាបច្ច័យ ។ លោករមែងបានបក្ខមានត្តប៉ុណ្ណោះ ដើម្បីអាបត្តិដែលបិទទុកក៏ដោយ មិនបិទទុកក៏ដោយ ។ ក៏ឯបុគ្គលនេះ សូម្បីមិនមែនភិក្ខុនី, តែត្រូវគរុកាបត្តិ មានចំណែកនៅសល់ហើយបិទទុក ក៏មិនត្រូវទោស ។

បានឮថា បញ្ហាដែលថា បញ្ហា មេសា កុសលេហិ ចិន្តិតា : ប្រស្នានេះ ពួកលោកអ្នកឈ្លាសវៃ បានគិតមកហើយ នេះ លោកពោលសំដៅដល់ភិក្ខុដែលសង្ឃលើកវត្ត ។ ពិតមែន (សង្ឃ) មិនមានវិនយកម្មជាមួយនឹងភិក្ខុនោះ, ព្រោះហេតុនោះ លោកត្រូវអាបត្តិសង្ឃាទិសេសហើយ សូម្បីបិទទុកក៏មិនត្រូវទោស ដូច្នេះឯង ។

**សេទមោចនគាថាវណ្ណនា ចប់**

# ពណ៌នាបញ្ចវគ្គ

វិនិច្ឆ័យក្នុងកម្មវគ្គ គប្បីជ្រាបដូច្នេះ ៖

[៤២៣] សេចក្តីផ្សេងគ្នានៃកម្ម ៤ យ៉ាង ខ្ញុំបានពោលហើយក្នុងសមថក្ខន្ធកៈនុ៎ះឯង ។ សូម្បីបានពោលហើយក៏ដោយ តែថាកម្មវិនិច្ឆ័យនេះ កាលបានពោលមកតាំងពីដើម រមែងជាវិនិច្ឆ័យដែលច្បាស់លាស់, ព្រោះដូច្នោះ ខ្ញុំនឹងពោលសេចក្តីដែលគួរពោល ក្នុងកម្មវគ្គនេះ ចាប់ផ្តើមតាំងពីដើមតែម្តង ។

ពាក្យថា ចត្តារិ នេះ ជាពាក្យប្រាប់កំណត់ចំនួននៃកម្មទាំងឡាយ ។

ពាក្យថា កម្មានិ ជាពាក្យបង្អុលកម្មដែលកំណត់ទុកហើយ ។

## សេចក្តីផ្សេងនៃកម្ម ៤

កម្មដែលត្រូវញុំាងសង្ឃនៅក្នុងសីមា ឱ្យហត់ចត់ នាំឆន្ទៈរបស់ភិក្ខុដែលគួរដល់ឆន្ទៈមក សូធ្យប្រកាស ៣ ដង ធ្វើតាមអនុមតិរបស់សង្ឃដែលព្រមព្រៀង ឈ្មោះថា អបលោកនកម្ម ។

កម្មដែលត្រូវធ្វើដោយញត្តិតែម្យ៉ាង តាមអនុមតិរបស់សង្ឃដែលព្រមព្រៀងតាមន័យដូចពោលហើយនុ៎ះឯង ឈ្មោះថា ញត្តិកម្ម ។

កម្មដែលត្រូវធ្វើដោយអនុស្សាវនា មានញត្តិជាគម្រប់ ២ យ៉ាងនេះ គឺ ញត្តិ ១ អនុស្សាវនា ១ តាមអនុមតិរបស់សង្ឃដែលព្រមព្រៀង ដោយន័យដូចពោលមកហើយនុ៎ះឯង ឈ្មោះថា ញត្តិទុតិយកម្ម ។

កម្មដែលត្រូវធ្វើដោយអនុស្សាវនា ៣ មានញត្តិជាគម្រប់ ៤ យ៉ាងនេះ គឺ ញត្តិ ១ អនុស្សាវនា ៣ តាមអនុមតិរបស់សង្ឃដែលព្រមព្រៀងគ្នា ដោយន័យដូចពោលហើយនុ៎ះឯង ឈ្មោះថា ញត្តិចតុត្ថកម្ម ។

បណ្តាកម្មទាំងនោះ អបលោកនកម្ម គប្បីធ្វើត្រឹមតែអបលោកនៈ, មិនត្រូវធ្វើដោយអំណាចញត្តិកម្មជាដើម ។ មួយទៀត ញត្តិកម្ម គប្បីធ្វើតាំងញត្តិតែម្យ៉ាង, មិនត្រូវធ្វើដោយអំណាចអបលោកនកម្មជាដើម ។

ចំណែកញត្តិទុតិយកម្ម ដែលត្រូវធ្វើដោយអបលោកនៈក៏មាន មិនត្រូវធ្វើដោយអបលោកនៈក៏មាន បណ្តា ២ យ៉ាងនោះ កម្មធ្ងន់ ៦ យ៉ាងនេះ គឺ សន្មតសីមា ដកសីមា ឱ្យសំពត់កឋិន ដោះកឋិន សម្តែងទីសាងកុដិ សម្តែងទីសាងវិហារ មិនគួរធ្វើអបលោកនៈ; គប្បីធ្វើដោយសូធ្យញត្តិទុតិយកម្មវាចាប៉ុណ្ណោះ ។

កម្មស្រាលទាំងនេះ គឺ សម្មតិ ១៣ ដ៏សេស និង សម្មតិមានការឱ្យកាន់សេនាសនៈ និងឱ្យមត៌កចីវរជាដើម គួរដើម្បីធ្វើទាំង

អបលោកនៈ ។

អាចារ្យពួកខ្លះពោលថា "តែញត្តិទុតិយកម្មនោះ មិនគួរធ្វើដោយអំណាចញត្តិកម្ម និងញត្តិចតុត្ថកម្មពិត ។ កាលធ្វើដោយអំណាចញត្តិចតុត្ថកម្ម រមែងជាកម្មរឹងមាំជាង ; ព្រោះហេតុនោះ គួរធ្វើ" ។ ពាក្យរបស់អាចារ្យទាំងនោះ បានត្រូវជំទាស់ចេញហើយថា "ក៏កាលបើដូច្នោះ កម្មសង្ករៈ (កម្មដែលលាយ ប្រឡប់គ្នា) រមែងមាន ព្រោះហេតុនោះទើបមិនគួរធ្វើ" ។

ក៏បើថា កម្មនោះខូចដោយអក្ខរក្តី ខូចដោយបទក្តី មានបទដែលសូធ្យមិនច្បាស់ក្តី, ការដែលសូធ្យដដែល ៗ ដើម្បីជម្រះកម្មនោះ ក៏គួរ ។ ការសូធ្យដដែល ៗ នេះ ជាទឡ្ហីកម្មរបស់កម្មដែលមិនកម្រើក, ឋិតនៅជាកម្មក្នុងកម្មដែលកម្រើក ។

ញត្តិចតុត្ថកម្ម ត្រូវធ្វើទាំងសូធ្យញត្តិនិងកម្មវាចា ៣ មិនគប្បីធ្វើដោយអំណាចកម្មដទៃ មានអបលោកនកម្មជាដើម ។

ប្រើនបទថា **បញ្ចហាការេហិ វិបជ្ជន្តិ : តែងវិបត្តិព្រោះអាការ ៥** មានសេចក្តីថា កម្ម ៤ នេះ រមែងវិបត្តិដោយហេតុ ៥ ប្រការ ។

# កម្មវិបត្តិដោយវត្ថុ

[៤២៤] ក្នុងពាក្យថា កម្មដែលគួរធ្វើចំពោះមុខ សង្ឃធ្វើមិនចំពោះមុខ កម្មមិនជាធម៌ វិបត្តិដោយវត្ថុនេះ កម្មដែលគួរធ្វើចំពោះមុខក៏មាន កម្មដែលគួរធ្វើមិនចំពោះមុខក៏មាន ។ ក្នុង២ យ៉ាងនោះ ដែលឈ្មោះថា កម្មដែលគួរធ្វើមិនចំពោះមុខមាន ៨ យ៉ាង គឺ ឧបសម្បទាដោយទូត ផ្កាប់បាត្រ ផ្ងារបាត្រ ឧម្មត្តកសម្មតិដែលសង្ឃគប្បីធ្វើដល់ភិក្ខុឆ្កួត សេក្ខសម្មតិដល់ត្រកូលព្រះសេក្ខៈ ព្រហ្មទណ្ឌដល់ព្រះឆន្នភិក្ខុ បកាសនីយកម្មដល់ភិក្ខុទេវទត្ត អវន្ទិយកម្មដែលភិក្ខុនីសង្ឃ គប្បីធ្វើដល់ភិក្ខុដែលសម្តែងអាការមិនគួរជ្រះថ្លា ។ កម្មទាំងពួងនោះ គប្បីជ្រាបតាមន័យដែលខ្ញុំពោលហើយក្នុងទីនោះ ៗ ដូច្នេះឯង ។ កម្មទាំង ៨ យ៉ាងនេះ ដែលសង្ឃធ្វើហើយមិនចំពោះមុខ រមែងជាការធ្វើដោយល្អ មិនកម្រើក ។ កម្មទាំងពួងដ៏សេស គួរធ្វើចំពោះមុខប៉ុណ្ណោះ, គឺ គប្បីធ្វើដោយអាស្រ័យសម្មុខាវិន័យ ៤ យ៉ាងនេះ គឺ ចំពោះមុខសង្ឃ ចំពោះមុខធម៌ ចំពោះមុខវិន័យ ចំពោះមុខបុគ្គល ។

កម្មទាំងពួងដែលធ្វើហើយដោយប្រការយ៉ាងនោះ រមែងជាកម្មធ្វើល្អហើយ ។ តែកម្មទាំងនោះ ដែលមិនធ្វើយ៉ាងនោះ រមែងចាត់ជាកម្មវិបត្តិដោយវត្ថុ ព្រោះធ្វើវៀរវត្ថុ ពោលគឺ សម្មុខាវិន័យ នេះចេញ ។

ព្រោះហេតុនោះ ទើបលោកពោលថា កម្មដែលគួរធ្វើចំពោះមុខ សង្ឃធ្វើមិនចំពោះមុខ កម្មមិនជាធម៌ វិបត្តិដោយវត្ថុ ។

សួរថាក្នុងកម្មទាំងឡាយ មានកម្មដែលគួរធ្វើដោយសាកសួរជាដើម ការធ្វើកិច្ចមានសាកសួរជាដើមនុ៎ះឯង ចាត់ជាវត្ថុ ។ គប្បីជ្រាបកម្មសូម្បីទាំងនោះ វិបត្តិដោយវត្ថុ ព្រោះធ្វើវៀរវត្ថុនោះចេញ ។ តែសេចក្តីនេះ ត្រឹមតែជាសេចក្តីចំពោះពាក្យ ក្នុងពាក្យដែលថា បដិបុច្ឆាករណីយំជាដើមនេះ ។

ត្រើនបទថា បដិបុច្ឆា ករណីយំ[១] អប្បដិបុច្ឆា ករោតិ : កម្មដែលសង្ឃត្រូវធ្វើដោយការសាកសួរ បែរជាធ្វើដោយការមិនសាកសួរវិញ មានសេចក្តីថា កម្មដែលគួរសួរហើយទើបចោទ ហើយឱ្យអ្នកជាប់ចោទរលឹកធ្វើ, សង្ឃធ្វើដោយមិនសាកសួរ មិនចោទ មិនឱ្យអ្នកជាប់ចោទបញ្ចេញចម្លើយឡើយ ។

ត្រើនបទថា បដិញ្ញាយ ករណីយំ អប្បដិញ្ញាយ ករោតិ : កម្មដែលសង្ឃត្រូវធ្វើតាមពាក្យប្តេជ្ញា បែរជាធ្វើតាមពាក្យមិនប្តេជ្ញាវិញ មានសេចក្តីថា កម្មដែលគួរលើកបដិញ្ញាជាគោល ធ្វើតាមបដិញ្ញាដែលអ្នកជាប់ចោទឆ្លើយ យ៉ាងណា, សង្ឃធ្វើដោយកាច់បំបាក់ដល់ភិក្ខុដែល

១. ភូមា. ថៃ. បដិបុច្ឆាករណីយំ ។

ទូញយំត្អូញត្អែ ដោយមិនព្រមប្តេជ្ញា ។

បទថា សតិវិនយារហស្ស : ដល់ភិក្ខុដែលគួរដល់សតិវិន័យ បានដល់ ព្រះខីណាស្រេព ដូចព្រះទព្វមល្លបុត្តត្ថេរ ។

បទថា អមូឡ្ហវិនយារហស្ស : ដល់ភិក្ខុដែលគួរដល់អមូឡ្ហវិន័យ បានដល់ ភិក្ខុឆ្កួត ដូចគគ្គភិក្ខុ ។

បទថា តស្សបាបិយសិកាកម្មារហស្ស : ដល់ភិក្ខុដែលគួរដល់តស្សបាបិយសិកាកម្ម បានដល់ ភិក្ខុដែលមានបាបក្រាស់ស្ទួរដូចឧបវាឡភិក្ខុ ។

ន័យក្នុងបទទាំងពួង ក៏ដូច្នេះឯង ។

ច្រើនបទថា អនុបោសថេ ឧបោសថំ ករោតិ : សង្ឃធ្វើឧបោសថក្នុងថ្ងៃមិនមែនជាថ្ងៃឧបោសថ មានសេចក្តីថា ធ្វើឧបោសថក្នុងថ្ងៃដែលមិនមែនជាថ្ងៃឧបោសថ ។

ថ្ងៃសាមគ្គីរបស់សង្ឃអ្នកបែកគ្នា និងថ្ងៃទី ១៤ និងថ្ងៃទី ១៥ កើត (តាមន័យ)ដែលពោលហើយ ក្នុង១១ ខែដ៏សេស វៀរខែកត្តិកចេញ ឈ្មោះថា ថ្ងៃឧបោសថ ។

កាលធ្វើឧបោសថក្នុងថ្ងៃដទៃ វៀរថ្ងៃឧបោសថទាំង ៣ ប្រការយ៉ាងនោះចេញ ឈ្មោះថា ធ្វើឧបោសថក្នុងថ្ងៃមិនមែនថ្ងៃឧបោសថ ។

ក៏ក្នុងវត្តណា ភិក្ខុទាំងឡាយវិវាទគ្នា ព្រោះហេតុបន្តិចបន្តួច ដើម្បីប្រយោជន៍ដល់បរិក្ខារ មានបាត្រនិងចីវរជាដើម ទើបវៀរឧបោសថឬបវារណាចេញ ។ កាលអធិករណ៍នោះវិនិច្ឆ័យហើយ ភិក្ខុទាំងឡាយក្នុងវត្តនោះ រមែងមិនបានដើម្បីពោលថា ពួកយើងជាអ្នកព្រមព្រៀងគ្នាហើយធ្វើសាមគ្គីឧបោសថក្នុងថ្ងៃដែលជាចន្លោះ ។ កាលធ្វើឧបោសថឈ្មោះថា ជាការធ្វើក្នុងថ្ងៃមិនមែនជាថ្ងៃឧបោសថ ។

ពីរបទថា **អបវារណាយ បវារេតិ** : សង្ឃធ្វើបវារណា ក្នុងថ្ងៃមិនមែនជាថ្ងៃបវារណា មានសេចក្តីថា សង្ឃបវារណាក្នុងថ្ងៃមិនមែនជាថ្ងៃបវារណា ។

ថ្ងៃសាមគ្គីរបស់សង្ឃដែលបែកគ្នា ១ ថ្ងៃដែលសង្ឃបន្ទិតទៅតាំងទុក ១ ក្នុងខែកត្តិកមួយខែ និងថ្ងៃពាក់កណ្តាលខែ ២ ដង ឈ្មោះថា ថ្ងៃបវារណា ។

កាលបវារណាក្នុងថ្ងៃដទៃ វៀរថ្ងៃបវារណាទាំង ៤ ប្រការ យ៉ាងនេះចេញ ឈ្មោះថា បវារណាក្នុងថ្ងៃមិនមែនជាថ្ងៃបវារណា ។ សូម្បីក្នុងការបវារណានេះ ភិក្ខុទាំងឡាយ រមែងមិនបានដើម្បីធ្វើសាមគ្គីបវារណា ព្រោះវិវាទមានប្រមាណបន្តិចបន្តួច ។ កាលធ្វើបវារណា រមែងជាការធ្វើក្នុងថ្ងៃមិនមែនជាថ្ងៃបវារណា ។

ម្យ៉ាងទៀត សូម្បីកាលសង្ឃឱ្យឧបសម្បទា ដល់បុគ្គលដែលមាន

អាយុមិនទាន់គ្រប់ ២០ ឆ្នាំ ឬ បុគ្គលដែលធ្លាប់ត្រូវអន្តិមវត្ថុ ឬអភព្វបុគ្គលណាម្នាក់ ក្នុងអភព្វបុគ្គល ១១ រមែងជាកម្មមិនប្រកបដោយធម៌ វិបត្តិដោយវត្ថុ ។

កម្មទាំងឡាយ រមែងវិបត្តិដោយវត្ថុ ដោយប្រការដូច្នេះ ។

## កម្មវិបត្តិដោយញត្តិ

[៤២៥] មួយទៀត គប្បីជ្រាបវិនិច្ឆ័យក្នុងវិបត្តិដោយញត្តិដូចតទៅនេះ ៖

ពីរបទថា វត្ថុំ ន បរាមសតិ : ភិក្ខុមិនសូត្រចេញឈ្មោះវត្ថុ មានសេចក្ដីថា សង្ឃធ្វើកម្មមានឧបសម្បទាជាដើមដល់បុគ្គលពួកណា មិនចេញឈ្មោះបុគ្គលនោះ (គឺ មិនបញ្ចូលឈ្មោះបុគ្គលនោះ) បានដល់សូធ្យថា "សុណាតុ មេ ភន្តេ សង្ឃោ (...) អាយស្មតោ ពុទ្ធរក្ខិតស្ស ឧបសម្បទាបេក្ខោ : បពិត្រព្រះសង្ឃដ៏ចម្រើន សូមព្រះសង្ឃស្ដាប់ខ្ញុំ ឧបសម្បទាបេក្ខៈរបស់លោកពុទ្ធរក្ខិត" ក្នុងកាលគួរសូធ្យថា "សុណាតុ មេ ភន្តេ សង្ឃោ <u>អយំ ធម្មរក្ខិតោ</u> អាយស្មតោ ពុទ្ធរក្ខិតស្ស ឧបសម្បទាបេក្ខោ : បពិត្រព្រះសង្ឃដ៏ចម្រើន សូមព្រះសង្ឃស្ដាប់ខ្ញុំ <u>ធម្មរក្ខិតនេះ</u> ជាឧបសម្បទាបេក្ខៈរបស់លោកពុទ្ធរក្ខិត" មិនចេញឈ្មោះវត្ថុ (គឺ អយំ ធម្មរក្ខិតោ) យ៉ាងនេះ ។

ពីរបទថា សង្ឃំ ន បរាមសតិ : មិនចេញឈ្មោះសង្ឃ មានសេចក្ដីថា មិនចេញឈ្មោះសង្ឃ គឺសូធ្យថា " សុណាតុ មេ ភន្តេ ( ... ) អយំ ធម្មរក្ខិតោ : បពិត្រលោកដ៏ចម្រើន សូមស្ដាប់ខ្ញុំ ធម្មរក្ខិតនេះ" ដូច្នេះ ក្នុងកាលគួរសូធ្យថា "សុណាតុ មេ ភន្តេ សង្ឃោ អយំ ធម្មរក្ខិតោ : បពិត្រព្រះសង្ឃដ៏ចម្រើន សូមព្រះសង្ឃស្ដាប់ខ្ញុំ ធម្មរក្ខិតនេះ" មិនចេញឈ្មោះសង្ឃ (គឺសង្ឃោ) យ៉ាងនេះ ។

ពីរបទថា បុគ្គលំ ន បរាមសតិ : មិនចេញឈ្មោះបុគ្គល មានសេចក្ដីថា ភិក្ខុណា ជាឧបជ្ឈាយ៍របស់ឧបសម្បទាបេក្ខៈ មិនចេញឈ្មោះភិក្ខុនោះ គឺ មិនចេញឈ្មោះរបស់ភិក្ខុនោះ បានដល់សូធ្យថា "សុណាតុ មេ ភន្តេ សង្ឃោ អយំ ធម្មរក្ខិតោ ( ... ) ឧបសម្បទាបេក្ខោ : បពិត្រព្រះសង្ឃដ៏ចម្រើន សូមព្រះសង្ឃស្ដាប់ខ្ញុំ ធម្មរក្ខិតនេះជាឧបសម្បទាបេក្ខៈ" ដូច្នេះ ក្នុងកាលគួរសូធ្យថា "សុណាតុ មេ ភន្តេ សង្ឃោ អយំ ធម្មរក្ខិតោ អាយស្មតោ ពុទ្ធរក្ខិតស្ស ឧបសម្បទាបេក្ខោ : បពិត្រព្រះសង្ឃដ៏ចម្រើន សូមព្រះសង្ឃស្ដាប់ខ្ញុំ ធម្មរក្ខិតនេះជាឧបសម្បទាបេក្ខៈរបស់លោកពុទ្ធរក្ខិតៈ" មិនចេញឈ្មោះបុគ្គល (គឺ អាយស្មតោ ពុទ្ធរក្ខិតស្ស) យ៉ាងនេះ ។

ពីរបទថា ញត្តឹ ន បរាមសតិ : មិនតាំងញត្តិ មានសេចក្ដីថា

មិនបញ្ចុះញត្តិដោយប្រការទាំងពួង គឺ ក្នុងញត្តិទុតិយកម្ម មិនតាំងញត្តិ ធ្វើអនុស្សាវនាកម្មដោយកម្មវាចាប៉ុណ្ណោះ ។ សូម្បីក្នុងញត្តិចតុត្ថកម្ម ក៏មិនតាំងញត្តិ ធ្វើអនុស្សាវនាកម្ម ដោយកម្មវាចាប៉ុណ្ណោះ ៤ ដង មិនតាំងញត្តិយ៉ាងនេះ ។

ប្រើនបទថា បច្ឆា វា ញត្តឹ ឋបេតិ : ឬតាំងញត្តិខាងក្រោយកម្មវាចា មានសេចក្តីថា ធ្វើអនុស្សាវនាកម្ម ដោយកម្មវាចាមុនហើយទើបពោលថា ឯសា ញត្តិ ហើយពោលថា ខមតិ សង្ឃស្ស តស្មា តុណ្ហី ឯវមេតំ ធារយាមិ ។ តាំងញត្តិខាងក្រោយយ៉ាងនេះ ។ កម្មវិបត្តិដោយញត្តិ ដោយអាការ ៥ ទាំងនេះ ដោយប្រការដូច្នេះ ។

## កម្មវិបត្តិដោយអនុស្សាវនា

[៤២៦] មួយទៀត គប្បីជ្រាបវិនិច្ឆ័យក្នុងវិបត្តិដោយអនុស្សាវនាដូចតទៅនេះ ៖

វត្ថុជាដើម គប្បីជ្រាបតាមន័យមុនដែលពោលហើយនុ៎ះឯង ។ ក៏ការមិនបញ្ជាក់វត្ថុជាដើមទាំងនោះ រមែងមានយ៉ាងនេះ ៖

ក្នុងអនុស្សាវនាទី ១ ថា សុណាតុ មេ ភន្តេ សង្ឃោ ក្តី ក្នុង

អនុស្សាវនាទី ២ ទី ៣ ដែលថា ធុតិយម្បិ ឯតមត្ថំ វទាមិ តតិយម្បិ ឯតមត្ថំ វទាមិ សុណាតុ មេ ភន្តេ សង្ឃោ ក្តី កាលគួរនឹងសួធ្យថា អយំ ធម្មរក្ខិតោ អាយស្មតោ ពុទ្ធរក្ខិតស្ស ឧបសម្បទាបេក្ខោ ភិក្ខុក៏សួធ្យខូចថា សុណាតុ មេ ភន្តេ សង្ឃោ, អាយស្មតោ ពុទ្ធរក្ខិតស្ស ដូច្នេះ ឈ្មោះថា មិនបញ្ចាក់វត្ថុ ។

កាលគួរនឹងសួធ្យថា សុណាតុ មេ ភន្តេ សង្ឃោ, អយំ ធម្មរក្ខិតោ ក៏សួធ្យខូចថា សុណាតុ មេ ភន្តេ អយំ ធម្មរក្ខិតោ ដូច្នេះ ឈ្មោះថា មិនបញ្ចាក់សង្ឃ ។

កាលគួរនឹងសួធ្យថា សុណាតុ មេ ភន្តេ សង្ឃោ, អយំ ធម្មរក្ខិតោ អាយស្មតោ ពុទ្ធរក្ខិតស្ស ក៏សួធ្យខូចថា សុណាតុ មេ ភន្តេ សង្ឃោ, អយំ ធម្មរក្ខិតោ ឧបសម្បទាបេក្ខោ ដូច្នេះ ឈ្មោះថា មិនបញ្ចាក់បុគ្គល ។

ពីរបទថា សាវនំ ហាបេតិ : ធ្វើអនុស្សាវនវិធីឱ្យខូច មានសេចក្តីថា មិនធ្វើការសួធ្យប្រកាសដោយកម្មវាចា ដោយប្រការទាំងពួង ។ គឺ តាំងញត្តិប៉ុណ្ណោះ ២ ដង ក្នុងញត្តិទុតិយកម្ម តាំងញត្តិប៉ុណ្ណោះ ៤ ដង ក្នុងញត្តិចតុត្ថកម្ម ។

ធ្វើនូវអនុស្សាវនា ( វិធី ) យ៉ាងនេះ ។

សូម្បីភិក្ខុណា កាលតាំងញត្តិមួយដងហើយសូធ្យកម្មវាចាមួយ លះអក្ខរ ឬបទចេញ ឬថា ខុសក្នុងញត្តិទុតិយកម្ម សូម្បីភិក្ខុនេះ ឈ្មោះថា លះវាចា ប្រកាសចេញ ដូចគ្នា ។

ចំណែកក្នុងញត្តិចតុត្ថកម្ម កាលតាំងញត្តិមួយដងហើយ សូធ្យប្រកាសដោយកម្មវាចា ត្រឹមតែម្តង ឬ ២ ដងក្តី កាលលះអក្ខរឬបទចេញក្តី កាលពោលខុសក្តី គប្បីជ្រាបថា លះអនុស្សាវនាចេញពិត ។

ក៏វិនិច្ឆ័យក្នុងពាក្យថា ទុរុត្តំ ករោតិ : កាលពោលខុស នេះ គប្បីជ្រាបដូច្នេះ ៖

ដែលភិក្ខុណាពោលអក្ខរដទៃ ក្នុងកាលខនគួរពោលអក្ខរដទៃ ភិក្ខុនេះ ឈ្មោះថា ពោលខុស ។ ព្រោះហេតុនោះ ភិក្ខុដែលនឹងសូធ្យកម្មវាចា គប្បីផ្ចោតចិត្តឱ្យល្អ នូវប្រភេទនៃព្យញ្ជនៈ ដែលលោកពោលទុកថា សេចក្តីបែកធ្លាយដោយបញ្ញាគ្រឿងដឹងព្យញ្ជនៈ ១០ យ៉ាង គឺ សិថិល ធនិត ទីឃៈ រស្សៈ គរុ លហុ និគ្គហិត សម្ព័ន្ធ វវត្ថិតៈ វិមុត្ត ។

ក៏ក្នុងប្រភេទនៃព្យញ្ជនៈ ១០ នេះ ព្យញ្ជនៈទី ១ និងទី ៣ ក្នុងវគ្គទាំង ៥ ឈ្មោះថា សិថិល ( សំឡេងស្រាល ) ។ ព្យញ្ជនៈទី ២

និងទី ៤ ក្នុងវគ្គទាំងនោះឯង ឈ្មោះថា ធនិត ( សំឡេងធ្ងន់ ) ។

ស្រៈដែលនឹងគប្បីពោលដោយរយៈវែង បានដល់ ស្រៈ អា ជាដើម ឈ្មោះថា ទីឃៈ ។

ស្រៈដែលនឹងគប្បីពោលក្នុងរយៈខ្លី គឺ ពាក់កណ្តាលរយៈវែងនោះ បានដល់ ស្រៈ អៈ ជាដើមឈ្មោះថា រស្សៈ ។

ទីឃៈនុ៎ះឯងឈ្មោះថា គរុ ម្យ៉ាងទៀត ស្រៈដែលខ្លីពោលទុកមានព្យញ្ជនៈតម្រួតខាងចុងយ៉ាងនេះថា អាយស្មតោ ពុទ្ធរក្ខិត្តត្ថេរស្ស យស្ស នក្ខមតិ ចាត់ជាគរុ ។ រស្សៈនុ៎ះឯង ឈ្មោះថា លហុ ម្យ៉ាងទៀត ស្រៈដែលពោលមិនឱ្យមានព្យញ្ជនៈតម្រួតខាងក្រោយ យ៉ាងនេះថា អាយស្មតោ ពុទ្ធរក្ខិតជេរស្ស យស្ស ន ខមតិ ក៏ចាត់ជាលហុ ។

អក្ខរដែលពោលបិទមាត់ សង្កត់ករណៈទុកមិនបញ្ចេញ, ធ្វើសំឡេងឱ្យឡើងប្រមុះ ឈ្មោះថា និគ្គហិត ។

បទដែលពោលភ្ជាប់នឹងបទដទៃ ដូច តុណ្ហស្ស ឬថា តុណ្ហិស្ស ឈ្មោះថា សម្ពន្ធ ។

បទពោលញែក, មិនពោលភ្ជាប់នឹងបទដទៃ ដូច តុណ្ហិ អស្ស ឈ្មោះថា វវត្ថិតៈ ។

អក្ខរដែលពោលបើកមាត់ មិនធ្វើសំឡេងឱ្យឡើងតាមប្រមុះ

បញ្ចេញសំឡេង មិនសង្កត់ករណៈទុកឈ្មោះថា វិមុត្ត ។

ក៏ក្នុងប្រភេទព្យញ្ជនៈ មានសិថិលជាដើមនោះ បទដែលទឹងគប្បីថា សុណាតុ មេ ភន្តេ ពោល ត ជា ថ គឺខូចថា សុណាថុ មេ ឈ្មោះថា ធ្វើសិថិលឱ្យជាធនិត និងបទដែលទឹងគប្បីថា បត្តកល្លំ ឯសា ញត្តិ ពោល ត ជា ថ (ត្ត ត្ថ) គឺពោលថា បត្ថកល្លំ ឯសា ញត្ថិ ជាដើម ក៏ដូចគ្នា ។

បទដែលទឹងគប្បីថា ភន្តេ សង្ឃោ ពោល ភ ជា ព, ពោល ឃ ជា គ, គឺពោលថា ពន្តេ សង្គោ ឈ្មោះថា ធ្វើធនិតឱ្យជាសិថិល ។

ចំណែកបទដែលទឹងគប្បីពោលបើកមាត់ថា សុណាតុ មេ ពោលបិទមាត់ឱ្យសំឡេងឡើងប្រមុះថា សុណន្តុ មេ ក្តី បទដែលទឹងត្រូវពោលបើកមាត់ថា ឯសា ញត្តិ ពោលបិទមាត់ ឱ្យសំឡេងឡើងតាមប្រមុះថា ឯសំ ញត្តិ ក្តី ឈ្មោះថា ពោលវិមុត្តឱ្យជានិគ្គហិត ។

ពាក្យដែលទឹងគប្បីបិទមាត់ ឱ្យសំឡេងឡើងតាមប្រមុះថា បត្តកល្លំ ពោលបើកមាត់ មិនធ្វើឱ្យសំឡេងឡើងតាមប្រមុះថា បត្តកល្លា ឈ្មោះថា ពោលនិគ្គហិតឱ្យជាវិមុត្ត ។

ព្យញ្ជនៈទាំង ៤ ពួកនេះ គឺ កាលគួរពោលឱ្យជាសិថិល ពោលជាធនិត, កាលគួរពោលឱ្យជាធនិត ពោលជាសិថិល, កាលគួរពោលឱ្យជាវិមុត្ត ពោលជានិគ្គហិត, កាលគួរពោលឱ្យជានិគ្គហិត ពោលជាវិមុត្ត, រមែងធ្វើកម្មឱ្យខូចខាងក្នុងកម្មវាចា ដោយប្រការ ដូច្នេះ ។ ពិតមែន ភិក្ខុដែលសូធ្យយ៉ាងនោះ ពោលអក្ខរដទៃក្នុងកាលដែលខ្លួនគួរពោលអក្ខរនោះ លោកហៅថា "ពោលខុស" ។

ដែលភិក្ខុជាអ្នកសូធ្យកម្មវាចា គួរពោលអក្ខរនោះ ៗឯង ឱ្យត្រឹមត្រូវតាមឋានយ៉ាងនេះ គឺ ក្នុងព្យញ្ជនៈ ៦ ក្រៅនេះ មានទីឃៈ និងរស្សៈជាដើម ពោលទីឃៈឱ្យតាំងនៅក្នុងទីនៃទីឃៈ ពោលរស្សៈឱ្យតាំងនៅក្នុងទីនៃរស្សៈ កុំឱ្យប្រពៃណីដែលមកហើយដោយលំដាប់សាបសូន្យធ្វើកម្មវាចា ។

តែបើភិក្ខុដែលសូធ្យកម្មវាចាមិនពោលយ៉ាងនោះ កាលគួរនឹងពោលឱ្យជាទីឃៈ ពោលជារស្សៈវិញ ឬកាលគួរនឹងពោលឱ្យជារស្សៈ ពោលជាទីឃៈវិញក្តី កាលគួរនឹងពោលឱ្យជាគរុ ពោលជាលហុវិញ ឬកាលគួរនឹងពោលឱ្យជាលហុ ពោលជាគរុវិញក្តី មួយទៀត កាលគួរនឹងពោលឱ្យភ្ជាប់គ្នា ពោលញែកគ្នាវិញ ឬ កាលគួរនឹងពោលឱ្យញែកគ្នា ពោលភ្ជាប់គ្នាវិញក្តី ។ សូម្បីកាលពោលយ៉ាងនេះ កម្មវាចាក៏មិនខូច ។

ពិតមែន ព្យញ្ជនៈ ៦ នេះ មិនញ៉ាំងកម្មឱ្យខូច ។

ក៏ពាក្យណា ដែលព្រះសុត្តន្តិកត្ថេរទាំងឡាយពោលថា ទ ផ្លាស់ជា ត បាន, ត ផ្លាស់ជា ទ បាន, ច ផ្លាស់ជា ជ បាន, ជ ផ្លាស់ជា ច បាន, យ ផ្លាស់ជា ក បាន, ក ផ្លាស់ជា យ បាន, ព្រោះដូច្នោះ កាលគួរនឹងពោល ទ ជាដើម ពោលជា ត ជាដើមវិញ ក៏មិនខុស ។ ពាក្យនោះដល់កម្មវាចាហើយ រមែងមិនគួរ ។ ព្រោះហេតុនោះ ព្រះវិន័យធរមិនគប្បីពោល ទ ជា ត ។ល ។ មិនគប្បីពោល ក ជា យ គប្បីសូធ្យកម្មវាចា ជម្រះភាសាតាមគួរដល់បាលី វៀរទោសដែលពោលហើយនៃភាសា គឺព្យញ្ជនៈទាំង ១០ យ៉ាងចេញ ។ ពិតមែន កាលពោលដោយប្រការក្រៅនេះហើយ ឈ្មោះថា លះបោលនូវសាវនា ។

ពីរបទថា អកាលេ វា សាវេតិ : សូធ្យក្នុងកាលមិនគួរ ១ មានសេចក្តីថា វៀរញត្តិទុក ធ្វើអនុស្សាវនាកម្មមុន ក្នុងសម័យមិនមែនកាល គឺ មិនមែនឱកាសនៃសាវនាហើយ តាំងញត្តិជាខាងក្រោយ ។

កម្មរមែងវិបត្តិដោយអនុស្សាវនា ដោយអាការ ៥ នេះ ដោយប្រការដូច្នេះ ។

# កម្មវិបត្តិដោយសីមា

[៤២៧] មួយទៀត គប្បីជ្រាបវិនិច្ឆ័យក្នុងវិបត្តិដោយសីមា ដូចតទៅនេះ ៖

សីមាណា មិនល្មមដល់ភិក្ខុ ២១ រូប សីមានោះ ចាត់ថា សីមាតូចពេក ។

តែក្នុងកុរុន្ទីថា ភិក្ខុ ២១ រូប មិនអាចដើម្បីអង្គុយក្នុងសីមាណា សីមានោះចាត់ថា តូចពេក ។ ព្រោះហេតុនោះ សីមាបែបនេះ ដែលសង្ឃសន្មតហើយក៏ដោយ ជាការមិនបានសន្មត រមែងដូចគ្នានឹងគាមខេត្ត ។ កម្មដែលធ្វើក្នុងសីមានោះ រមែងខូច ។ សូម្បីក្នុងសីមាដ៏សេសទាំងឡាយក៏ន័យនេះ ។

ក៏ក្នុងសីមាទាំងនេះ សីមាណា ជាដែនដែលសង្ឃសន្មតលើស ៣ យោជន៍ សូម្បីត្រឹមតែមួយចុងសរសៃសក់ សីមានោះ ចាត់ថា សីមាធំពេក ។

សីមាមាននិមិត្តមិនតជាប់គ្នា ហៅថា សីមាមាននិមិត្តដាច់ ។

ភិក្ខុសួរនិមិត្តក្នុងទិសខាងកើតហើយ សួរក្នុងទិសខាងត្បូង ទិសខាងលិច និងទិសខាងជើង វិលទៅដោយលំដាប់គ្នាហើយ សួរនូវនិមិត្តដែលធ្លាប់សួរហើយក្នុងទិសខាងកើតដដែលទៀតហើយឈប់ ទើបសម

គួរ ។ សីមារមែងជាដែនមាននិមិត្តមិនដាច់យ៉ាងនេះ ។ ក៏បើថា សួរមកតាមលំដាប់ហើយ សួរនិមិត្តក្នុងទិសខាងជើងហើយ ឈប់នៅត្រឹមទិសខាងជើងនោះប៉ុណ្ណោះ, ឈ្មោះថា **សីមាមាននិមិត្តមិនតគ្នា** ។

សីមាណា ដែលសង្ឃសន្មត កំណត់យកដើមឈើមានសំបករឹងក្តី ដង្គត់ឈើក្តី គំនរដីគំនរខ្សាច់យ៉ាងណាមួយក្តី ដែលមិនគួរជានិមិត្តឱ្យជានិមិត្តមួយក្នុងចន្លោះ សីមានោះចាត់ជា**សីមាមាននិមិត្តដាច់** មួយប្រភេទទៀត ។

សីមាណាដែលសង្ឃសន្មតយកនូវស្រមោលយ៉ាងណាមួយ មានស្រមោលភ្នំជាដើមឱ្យជានិមិត្ត សីមានោះ ឈ្មោះថា **សីមាយកស្រមោលជានិមិត្ត** ។

សីមាណា ដែលសង្ឃសន្មត មិនសួរនិមិត្តដោយប្រការទាំងពួង, សីមានោះ ឈ្មោះថា **សីមាមិនមានអ្វីជានិមិត្ត** ។

ភិក្ខុសួរនិមិត្តហើយ ឈរខាងក្រៅនិមិត្ត សន្មតសីមា ឈ្មោះថា **ឈរខាងក្រៅសីមាសន្មតសីមា** ។

ភិក្ខុសន្មតសីមា ក្នុងផ្ទៃទឹកមានទន្លេជាដើមទាំងនេះ ឈ្មោះថា សន្មតសីមាក្នុងទន្លេ ក្នុងសមុទ្រ ក្នុងស្រះកើតឯង ។ សីមានោះ សូម្បីសង្ឃសន្មតហើយយ៉ាងនោះ រមែងមិនជាការសន្មតឡើយ ព្រោះព្រះ

បាលីថា "សព្វា ភិក្ខវេ, នទី អសីមា, សព្វេ សមុទ្ទា អសីមោ, សព្វេ ជាតស្សរោ អសីមោ : ម្នាលភិក្ខុទាំងឡាយ ស្ទឹងទាំងអស់ មិនមែនជាសីមា សមុទ្រទាំងអស់មិនមែនជាសីមា, ជាតស្រះទាំងអស់មិនមែនជាសីមា"[១] ។

ប្រែបទថា សីមាយ សីមំ សម្ភិន្ទតិ : ទម្លាយសីមាដោយសីមា មានសេចក្ដីថា ទម្លាយសីមារបស់អ្នកដទៃដោយសីមារបស់ខ្លួន ។

បទថា អជ្ឈោត្ថរតិ : គ្រប បានដល់ សន្ទូតសង្កត់សីមារបស់អ្នកដទៃ ដោយសីមារបស់ខ្លួន ។

ក្នុងការសន្ទូតសីមានោះ ការទម្លាយគ្នា និងការសង្កត់គ្នា នឹងមានប្រាកដដោយលក្ខណៈយ៉ាងណា, លក្ខណៈទាំងពួងនោះ ខ្ញុំបានពោលស្រួចហើយក្នុងឧបោសថក្ខន្ធកៈ ។

សីមាទាំង ១១ យ៉ាងនេះ មិនចាត់ជាសីមា ប្រាកដដូចតាមខេត្តប៉ុណ្ណោះ ។ កម្មដែលសង្ឃអង្គុយធ្វើក្នុងសីមាទាំងនោះ រមែងខូចដោយប្រការដូច្នេះ ។ ព្រោះហេតុនោះ លោកទើបពោលថា កម្មរមែងវិបត្តិដោយសីមា ដោយអាការទាំង ១១ នេះ ។

---

១. វិន. មហា. ឧបោសថក្ខន្ធកៈ. ៦. ១៦៤/៣៦២ ។

# កម្មវិបត្តិដោយបរិស័ទ

[៤២៩] មួយទៀត គប្បីជ្រាបវិនិច្ឆ័យក្នុងវិបត្តិនៃកម្ម ដោយបរិស័ទ ដូចតទៅនេះ ៖

មិនមានពាក្យតិចតួចដែលចាត់ថា មិនងាយយល់នោះទេ ។

លក្ខណៈរបស់ភិក្ខុដែលចូលកម្ម និងភិក្ខុដែលគួរដល់ឆន្ទៈ ក្នុងកម្មវិបត្តិដោយបរិស័ទនោះ ដែលខ្ញុំគួរពោលក៏មានខ្លះ តែលោកបានពោលទុកខាងមុខហើយនោះឯង ដោយន័យជាដើមថា ចត្តារោ ភិក្ខូ បកតត្តា កម្មប្បត្តា : ភិក្ខុ ៤ រូប ជាបកតត្តដែលគួរដល់កម្ម ដូច្នេះ ។

បណ្តាបទទាំងនោះ ពីរបទថា បកតត្តា កម្មប្បត្តា : ជាបកតត្តដែលគួរដល់កម្ម មានសេចក្តីថា ក្នុងកម្មដែលសង្ឃចតុវគ្គគប្បីធ្វើ ភិក្ខុ ៤ រូបអ្នកមានខ្លួនជាប្រក្រតី គឺ អ្នកដែលសង្ឃមិនបានលើកវត្តដែលសង្ឃមិនបានដាក់ទោស អ្នកមានសីលបរិសុទ្ធិ, ភិក្ខុ ៤ រូប អ្នកចូលកម្ម គឺ អ្នកគួរ អ្នកសមគួរ បានដល់ ជាម្ចាស់របស់កម្ម ។ កម្មនោះ វៀរពួកលោកចេញ រមែងធ្វើមិនបាន ។ ឆន្ទៈក្តី បារិសុទ្ធិក្តី របស់ពួកលោកមិនទាន់មក ។ ចំណែកភិក្ខុដ៏សេស បើសូម្បីមានប្រមាណមួយពាន់រូប ។ បើថា ជាសមានសំវាសកៈ រមែងជាអ្នកគួរដល់ឆន្ទៈ

ទាំងអស់តែម្តង ។ ពួកលោកប្រគល់ឆន្ទៈ និងបារិសុទ្ធិហើយ ទើងមកឬមិនមកក៏ដោយ ។ ចំណែកកម្មគង់តាំងនៅ ។

តែសង្ឃធ្វើកម្មមានបរិវាសជាដើម ដល់ភិក្ខុណា, ភិក្ខុនោះ មិនមែនអ្នកចូលកម្ម ទាំងមិនមែនអ្នកគួរដល់ឆន្ទៈ ។ ម្យ៉ាងទៀត ភិក្ខុនោះដែលលោកហៅថា **កម្មារហបុគ្គល** ក៏ព្រោះហេតុដែលសង្ឃចាត់បុគ្គលនោះឱ្យជាវត្ថុធ្វើកម្ម ។

សូម្បីក្នុងកម្មដ៏សេស ក៏ន័យនេះឯង ។

លោកពោលន័យជាដើមថា **ចត្តារិ កម្មានិ : កម្ម ៤ យ៉ាង** ទុកទៀត ក៏ដើម្បីសម្តែងសេចក្តីដែលអភព្វបុគ្គល មានបណ្ឌកៈជាដើមមិនចាត់ជាវត្ថុ ។

ពាក្យដ៏សេស ក្នុងន័យនេះ ងាយយល់ទាំងអស់ ។

## អបលោកនកម្ម

[៤៣៦] ឥឡូវនេះ ដើម្បីសម្តែងប្រភេទនៃកម្មទាំងនោះ លោកទើបពោលថា អបលោកនកម្មំ កតិ ឋានានិ គច្ឆតិ **: អបលោកកម្មដល់នូវឋានប៉ុន្មាន** ជាដើម ។

បណ្តាបទទាំងនោះ ក្នុងបទដែលថា អបលោកនកម្ម រមែងដល់

ឋានៈ ៥ ពួកណា ? ឋានៈ ៥ ទាំងនេះ គឺ ឱសារណា និស្សារណា ភណ្ឌុកម្ម ព្រហ្មទណ្ឌ ទាំងកម្មលក្ខណៈជាគម្រប់ ៥ នេះ ពាក្យដែលថា ឱសារណា និស្សារណានោះ លោកពោលហើយ ដើម្បីជាបទដែលពីរោះ ។ តែនិស្សារណាមានមុន ឱសារណាមានខាងក្រោយ ។

## និស្សារណា និង ឱសារណា

[៤៣៧] ក្នុង២ យ៉ាងនោះ ទណ្ឌកម្មនាសនាដែលសង្ឃធ្វើដល់កណ្ឌកសាមណេរ គប្បីជ្រាបថា ជានិស្សារណា ។ ព្រោះហេតុនោះ ក្នុងកាលឥឡូវនេះ សូម្បីបើសាមណេរពោលទោសព្រះពុទ្ធ ព្រះធម៌ ឬព្រះសង្ឃ, សម្តែងវត្ថុដែលមិនគួរថា គួរ, ជាអ្នកមានការឃើញខុសប្រកបដោយអន្តគាហិកទិដ្ឋិ; សាមណេរនោះ ដែលភិក្ខុទាំងឡាយ គប្បីហាមប្រាម ឱ្យលះបង់សេចក្តីប្រកាន់នោះចេញ ៣ ដង, បើលោកមិនព្រមលះបង់គប្បីឱ្យប្រជុំសង្ឃ ពោលថា ចូរលះបង់ចេញ, បើលោកមិនព្រមលះបង់ ភិក្ខុដែលឆ្លាតគប្បីធ្វើអបលោកនកម្មដាក់ទោសលោក ។

ក៏ឯកម្មដែលភិក្ខុនោះ គប្បីធ្វើយ៉ាងនេះថា "បពិត្រព្រះសង្ឃដ៏ចម្រើន ខ្ញុំសូមសួរសង្ឃថា សាមណេរឈ្មោះនេះ ៗ មានសេចក្តីឃើញខុស ច្រើនពោលទោសព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ, ពួកសាម

ណេរដទៃ រមែងបានការដេករួមនឹងភិក្ខុទាំងឡាយ ២-៣ យប់ យ៉ាងណា ការដាក់ទោសលោក ដើម្បីមិនបានការដេករួមនោះ គាប់ចិត្តដល់សង្ឃឬ ? បពិត្រព្រះសង្ឃដ៏ចម្រើន ខ្ញុំសូមសួរសង្ឃជាគម្រប់ ២ ដង ។ល ។ បពិត្រព្រះសង្ឃដ៏ចម្រើន ខ្ញុំសូមសួរសង្ឃជាគម្រប់ ៣ ដង ថា សាមណេរ ឈ្មោះនេះ ៗ មានសេចក្តីយល់ខុស ។ល ។ ការដាក់ទោសលោក ដើម្បីមិនបានការដេករួមនោះ គាប់ចិត្តសង្ឃឬ ? ការដាក់ទោសនោះ គាប់ចិត្តដល់សង្ឃហើយ ; នៃមនុស្សក្រៅការ អ្នកចូរចេញទៅចូរវិនាសទៅ” ។

ដោយសម័យដទៃ សាមណេរនោះសូមទោសថា “បពិត្រព្រះសង្ឃដ៏ចម្រើន ខ្ញុំបានធ្វើយ៉ាងនោះ ព្រោះជាអ្នកវង្វេង ព្រោះមិនដឹង ព្រោះជាអ្នកមិនពិចារណា, ខ្ញុំសូមខមាទោសចំពោះសង្ឃ” ដូច្នេះ គប្បីឱ្យលោកសូម ៣ ដង ហើយអត់ទោសដោយអបលោកនកម្មនុ៎ះឯង ។

ក៏ឯសាមណេរនោះ ដែលភិក្ខុទាំងឡាយ គប្បីអត់ទោសយ៉ាងនេះ ៖

ភិក្ខុដែលឆ្លាត គប្បីសូត្រប្រកាស ដោយអនុមតិរបស់សង្ឃនៅកណ្តាលជំនុំសង្ឃថា “បពិត្រព្រះសង្ឃដ៏ចម្រើន ខ្ញុំសួរសង្ឃថា សាមណេរឈ្មោះនេះ ៗ មានសេចក្តីយល់ខុស ច្រើនពោលទោសព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ, ដែលសង្ឃដាក់ទោសហើយ ដើម្បីមិនបានការដេក

រួមនឹងភិក្ខុទាំងឡាយ ២-៣ យប់ ដែលសាមណេរពួកដទៃបាន, ឥឡូវនេះ សាមណេរនេះ ស្ងប់ស្ងៀមហើយ វៀរបានហើយ ប្រព្រឹត្តបន្ទាបខ្លួន វិលចូលរកលជ្ជីធម៌ហើយ តាំងមាំក្នុងហិរិឱត្តប្បៈហើយ សង្ឃបានធ្វើទណ្ឌកម្មហើយ បានមកសារភាពទោស; ការឱ្យសេចក្តីព្រមព្រៀងដោយកាយសម្ភោគ ដូចក្នុងកាលមុន ដល់សាមណេរនេះ គាប់ចិត្តដល់សង្ឃឬ ? គប្បីសូធ្យយ៉ាងនេះ ៣ ដង ។ អបលោកនកម្ម រមែងដល់ឱសារណា និងនិស្សារណា ដោយប្រការដូច្នេះ ។

ភណ្ឌុកម្ម ខ្ញុំបានពោលរួចហើយ ក្នុងមហាខន្ធកវណ្ណនា ។

## ព្រហ្មទណ្ឌ

ព្រហ្មទណ្ឌ ដែលព្រះអានន្ទថេរៈបានពោលទុកហើយ ក្នុងបញ្ចសតិកក្ខន្ធកៈ ។ ក៏ឯព្រហ្មទណ្ឌនោះ ដែលព្រះមានព្រះភាគទ្រង់បញ្ញត្តិចំពោះឆន្នភិក្ខុមួយរូប ក៏ទេ ។ ភិក្ខុសូម្បីដទៃណា ជាអ្នកមានមាត់រឹង សឹកសៀត ជេរ គ្របសង្កត់ភិក្ខុទាំងឡាយ ដោយពាក្យគ្រោតគ្រាត ។ សង្ឃគប្បីដាក់ព្រហ្មទណ្ឌ ដល់ភិក្ខុសូម្បីនោះ ។

ក៏ឯព្រហ្មទណ្ឌនោះ គប្បីដាក់យ៉ាងនេះ ៖

ភិក្ខុដែលឆ្លាត គប្បីសូធ្យប្រកាស ដោយអនុមតិរបស់សង្ឃ នៅ

កណ្ដាលជំនុំសង្ឃថា "បពិត្រព្រះសង្ឃដ៏ចម្រើន ភិក្ខុឈ្មោះនេះ មានមាត់រឹង ជេរ សឹកសៀតភិក្ខុទាំងឡាយ ដោយពាក្យដែលគ្រោតគ្រាត, ភិក្ខុនោះ គប្បីពោលពាក្យដែលខ្លួនប្រាថ្នានឹងពោល, ភិក្ខុឈ្មោះនេះ ដែលភិក្ខុទាំងឡាយមិនគប្បីប្រដៅ មិនគប្បីជាស់តឿន មិនគប្បីទូន្មាន, បពិត្រព្រះសង្ឃដ៏ចម្រើន ខ្ញុំសួរសង្ឃថា ការដាក់ព្រហ្មទណ្ឌដល់ភិក្ខុឈ្មោះនេះ គាប់ចិត្តដល់សង្ឃឬ ? ខ្ញុំសួរជាគម្រប់ ២ ដង ។ល។ ខ្ញុំសួរជាគម្រប់ ៣ ដង ថា ការដាក់ព្រហ្មទណ្ឌដល់ភិក្ខុឈ្មោះនេះ គាប់ចិត្តដល់សង្ឃឬ ?" ។

ព្រហ្មទណ្ឌដែលសង្ឃគប្បីរម្ងាប់ដល់ភិក្ខុនោះ អ្នកប្រព្រឹត្តប្រពៃហើយ សូមខមាទោសហើយ ក្នុងសម័យដទៃ ។ ក៏ឯសង្ឃគប្បីរម្ងាប់យ៉ាងនេះ ៖

ភិក្ខុដែលឆ្លាត គប្បីសូធ្យប្រកាសនៅកណ្ដាលជំនុំសង្ឃថា "បពិត្រព្រះសង្ឃដ៏ចម្រើន ភិក្ខុសង្ឃបានដាក់ព្រហ្មទណ្ឌដល់ភិក្ខុឯណោះ, ភិក្ខុនោះ ស្លូតបូតហើយ ប្រព្រឹត្តឱនលំទោន ចូលមកក្នុងលជ្ជីធម៌ហើយ តាំងមាំក្នុងហិរិឱត្តប្បៈហើយ ពិចារណាហើយ តាំងនៅក្នុងសំវរៈតទៅ, បពិត្រព្រះសង្ឃដ៏ចម្រើន ខ្ញុំសួរសង្ឃថា ការរម្ងាប់ព្រហ្មទណ្ឌដល់ភិក្ខុនោះ គាប់ចិត្តដល់សង្ឃឬ ? ។ គប្បីពោលយ៉ាងនេះ ៣ ដង រម្ងាប់ព្រហ្មទណ្ឌចេញ ដោយអបលោកនកម្មនេះឯង ។

# កម្មលក្ខណៈ

ពីរបទថា កម្មលក្ខណាញ្ញេវ បញ្ចមំ : ជាគម្រប់ ៥ នឹងកម្មលក្ខណៈ មានសេចក្តីថា ក្នុងរឿងទាំងនេះដែលថា "សម័យនោះឯងពួកឆព្វគ្គិយភិក្ខុសាចភក់និងទឹក ទៅលើពួកភិក្ខុនី ដោយគិតថា ធ្វើដូចម្តេចហ្ន៎ នឹងបានពួកភិក្ខុនីត្រេកអរនឹងយើង ។ល ។ បើកកាយបង្ហាញពួកភិក្ខុនី, លាត់ភ្លៅបង្ហាញពួកភិក្ខុនី, បើកអង្គជាតបង្ហាញពួកភិក្ខុនី, ចំអកចំអន់ពួកភិក្ខុនី ( ដោយអសទ្ធម្ម ) ផ្សំផ្គុំ ( ពួកបុរសអ្នកលេង ) ជាមួយនឹងពួកភិក្ខុនី ដោយគិតថា ធ្វើដូចម្តេចហ្ន៎ នឹងបានពួកភិក្ខុនីត្រេកអរនឹងយើង ។ល ។" ដូច្នេះ ព្រះមានព្រះភាគ ទ្រង់បញ្ញត្តិទុក្កដ ដល់ភិក្ខុទាំងនោះ ហើយទ្រង់អនុញ្ញាតអវន្ទិយកម្ម ទុកក្នុងភិក្ខុនីខន្ធកៈ យ៉ាងនេះថា "ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឱ្យ ( ភិក្ខុនីសង្ឃ ) ធ្វើទណ្ឌកម្មដល់ភិក្ខុនោះ ។ លំដាប់នោះ ភិក្ខុទាំងឡាយ មានសេចក្តីត្រិះរិះដូច្នេះថា ភិក្ខុនីសង្ឃត្រូវធ្វើទណ្ឌកម្ម ដូចម្តេចហ្ន៎ ។ ភិក្ខុទាំងនោះ ក្រាបបង្គំទូលសេចក្តីនោះចំពោះព្រះមានព្រះភាគ, ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុនីសង្ឃ គប្បីធ្វើភិក្ខុនោះ ឱ្យជាអវន្ទិយបុគ្គល ( ភិក្ខុដែលភិក្ខុនីមិនគួរសំពះ )"[១] ដូច្នេះ ។ អវន្ទិយកម្មនោះ រមែងជាកម្មលក្ខណៈ

១. វិន. ចុល្ល. ភិក្ខុនីខន្ធកៈ. ១១. ១៩៧_៨/២៨៦_៧ ។

ពិត រមែងជាឋានៈ ដែលគ្រប់ ៥ នៃអបលោកនកម្មនេះ ។

ពិតមែន អវន្ទិយកម្មនោះ ជាកម្មលក្ខណៈ គឺ កម្មនៃអបលោកនកម្មនោះ មិនក្លាយជាយ៉ាងដទៃមានឱសារណាជាដើមទេ ។ ព្រោះដូច្នោះ លោកទើបហៅថា កម្មលក្ខណៈ ។ ការធ្វើអវន្ទិយកម្មនោះ ព្រះមានព្រះភាគបានត្រាស់ទុកក្នុងភិក្ខុនីខន្ធកៈនោះ ហើយ ។

មួយទៀត ដើម្បីសម្តែងអវន្ទិយកម្មនោះ និងទាំងកិរិយាដែលរម្ងាប់ដោយពិស្តារ ខ្ញុំនឹងពោលទុកក្នុងកម្មវគ្គសូម្បីនេះ ៖

ភិក្ខុនីដែលឆ្លាត គប្បីសូធ្យប្រកាសដោយអនុមតិរបស់ភិក្ខុនីសង្ឃដែលប្រជុំគ្នាក្នុងសំណាក់ភិក្ខុនីថា "បពិត្រម៉ែម្ចាស់ ខ្ញុំសួរភិក្ខុនីសង្ឃថា លោកម្ចាស់ឈ្មោះឯណោះ សម្តែងអាការមិនគួរជ្រះថ្លាដល់ភិក្ខុនីទាំងឡាយ, ការធ្វើលោកម្ចាស់នោះ ឱ្យជាអ្នកដែលភិក្ខុនីទាំងឡាយមិនគប្បីថ្វាយបង្គំ គាប់ចិត្តដល់សង្ឃឬ ? ខ្ញុំសួរភិក្ខុនីសង្ឃជាគម្រប់ ២ ដង ។ល ។ ជាគម្រប់ ៣ ដង ថា បពិត្រម៉ែម្ចាស់ លោកម្ចាស់ឈ្មោះឯណោះ សម្តែងអាការមិនគួរជ្រះថ្លាដល់ភិក្ខុនីទាំងឡាយ, ការធ្វើលោកម្ចាស់នោះ ឱ្យជាអ្នកដែលភិក្ខុនីទាំងឡាយ មិនគប្បីថ្វាយបង្គំ គាប់ចិត្តដល់សង្ឃឬ ?" អវន្ទិយកម្មដែលភិក្ខុនីសង្ឃ គប្បីសូធ្យប្រកាស ៣ ដង ធ្វើដោយអបលោកនកម្មយ៉ាងនេះ ។

ចាប់ផ្តើមតាំងពីនោះ ភិក្ខុនោះ ដែលភិក្ខុនីទាំងឡាយមិនគប្បីថ្វាយ

បន្ត ។ បើថា ភិក្ខុនោះ (ដែលភិក្ខុនីទាំងឡាយ មិនថ្វាយបន្តហើយ) ត្រឡប់កើតហិរិនិងឱត្តប្បៈឡើងហើយ ប្រព្រឹត្តត្រឹមត្រូវសោត, គប្បីសូមទោស ភិក្ខុនីទាំងឡាយ ។ កាលនឹងសូមខមាទោស មិនគប្បីទៅកាន់សំណាក់ភិក្ខុនី គប្បីចូលរកសង្ឃ ឬគណៈ ឬភិក្ខុមួយរូបក្នុងវិហារនុ៎ះឯង អង្គុយប្រហោងផ្គងអញ្ជលី សូមខមាទោសថា "បពិត្រលោកដ៏ចម្រើន ខ្ញុំពិចារណាហើយ នឹងតាំងនៅក្នុងសំវរៈតទៅ, នឹងមិនសម្តែងអាការមិនគួរជ្រះថ្លាទៀត, សូមភិក្ខុនីសង្ឃអត់ទោសដល់ខ្ញុំចុះ" ។

សង្ឃឬគណៈនោះ គប្បីបញ្ជូនភិក្ខុមួយរូបទៅ ឬភិក្ខុនោះ គប្បីទៅដោយខ្លួនឯងតែម្តង ហើយពោលនឹងភិក្ខុនីទាំងឡាយថា "ភិក្ខុនេះពិចារណាហើយ តាំងនៅក្នុងសំវរៈតទៅ ភិក្ខុនីសង្ឃដែលភិក្ខុនេះសារភាពទោសហើយ សូមខមាទោសហើយ, សូមភិក្ខុនីសង្ឃ ធ្វើភិក្ខុនេះ ឱ្យជាអ្នកដែលខ្លួនគប្បីថ្វាយបន្តចុះ" ។ ភិក្ខុនីសង្ឃគប្បីធ្វើភិក្ខុនោះឱ្យជាអ្នកដែលខ្លួនគប្បីថ្វាយបន្ត ។

ក៏ឯកាលនឹងធ្វើ គប្បីធ្វើយ៉ាងនេះ ៖

ភិក្ខុនីដែលឆ្លាត គប្បីសូធ្យប្រកាស ដោយអនុមតិរបស់ភិក្ខុនីសង្ឃដែលប្រជុំគ្នាក្នុងសំណាក់ភិក្ខុនីថា "បពិត្រម៉ែម្ចាស់ ខ្ញុំសួរភិក្ខុនីសង្ឃថា លោកម្ចាស់ឈ្មោះឯណោះ សម្តែងអាការមិនគួរជ្រះថ្លា ដល់ភិក្ខុនីទាំងឡាយ; លោកម្ចាស់នោះ ដែលភិក្ខុនីសង្ឃធ្វើឱ្យជាអ្នកដែលខ្លួន

មិនគប្បីថ្វាយបង្គំហើយ បានឈានចុះក្នុងលជ្ជីធម៌ ពិចារណាហើយ តាំងនៅក្នុងសំវរៈតទៅ សារភាពទោសហើយ សូមទោសភិក្ខុនីសង្ឃហើយ, ការធ្វើលោកម្ចាស់នោះ ឱ្យជាអ្នកដែលភិក្ខុនីទាំងឡាយ គប្បីថ្វាយបង្គំ គាប់ចិត្តដល់សង្ឃឬ ?" គប្បីពោល ៣ ដង ។ ភិក្ខុនីសង្ឃគប្បីធ្វើភិក្ខុនោះ ឱ្យជាអ្នកដែលខ្លួនគប្បីថ្វាយបង្គំ ដោយអបលោកនកម្មនុ៎ះឯង យ៉ាងនេះ ។

## កម្មលក្ខណវិនិច្ឆ័យ

ក៏ក្នុងកម្មវគ្គនេះ មានវិនិច្ឆ័យកម្មលក្ខណៈ សូម្បីដែលរួចផុតចាកបាលី គប្បីជ្រាបដូចតទៅនេះ ៖

ពិតមែន ដែលឈ្មោះថា កម្មលក្ខណៈ ទ្រង់បញ្ញត្តិមានភិក្ខុនីសង្ឃជាមូលតែរមែងបានដល់ភិក្ខុសង្ឃដោយពិត ។

ក៏ភិក្ខុសង្ឃធ្វើអបលោកនកម្មណា ក្នុងរោងស្លាក រោងយាគូ រោងភត្ត និងរោងឧបោសថ, អបលោកនកម្មសូម្បីនោះ ជាកម្មលក្ខណៈពិត ។

ការដែលភិក្ខុឆ្លាសប្រតិពល ឱ្យសង្ឃប្រជុំគ្នាហើយ សូធ្យប្រកាស ៣ ដង ធ្វើអបលោកនកម្ម ឱ្យចីវរដល់ភិក្ខុទាំងឡាយ ដែលត្រូវចោរលួចចីវរទៅ ដែលមានចីវរចាស់ និងដែលមានចីវរវិនាស

រមែងគួរ ។ តែរបស់បន្តិចបន្តួចមានម្ជុលជាដើម មានប្រភេទដែលពោលហើយ ក្នុងសេនាសនក្ខន្ធកវណ្ណនា ដែលភិក្ខុអ្នកចែករបស់បន្តិចបន្តួច សូម្បីមិនធ្វើអបលោកន៍ ក៏ឱ្យដល់ភិក្ខុដែលធ្វើចីវរបាន ។ ភិក្ខុដែលចែករបស់បន្តិចបន្តួចនោះប៉ុណ្ណោះ ជាធំក្នុងការឱ្យរបស់បន្តិចបន្តួចទាំងនោះ ។ កាលទឹងឱ្យរបស់ដែលលើសជាងនោះ ត្រូវធ្វើអបលោកន៍ឱ្យ ។ ព្រោះថា សង្ឃជាម្ចាស់របស់ក្នុងការឱ្យរបស់ដែលលើសជាងនោះ ។

សូម្បីគិលានភេសជ្ជៈ ដែលមានសេចក្តីដូចពោលហើយ ក្នុងសេនាសនក្ខន្ធកវណ្ណនានោះ ដែលភិក្ខុអ្នកចែករបស់បន្តិចបន្តួច គប្បីឱ្យខ្លួនឯងក៏បាន ។ គប្បីអបលោកន៍ឱ្យដល់ភិក្ខុដែលត្រូវការច្រើន ។

ក៏ប៉ុន្តែថា ភិក្ខុណា មិនមានកម្លាំងក្តី ជាមនុស្សពិការក្តី ជាច់មកភិក្ខាចារក្តី អាពាធធ្ងន់ក្តី, សម្រាប់ភិក្ខុនោះ កាលទឹងឱ្យអង្ករមួយនាឡិ ឬកន្លះនាឡិរាល់ថ្ងៃ ឬទឹងឱ្យអង្ករ ៥ នាឡិ ឬ១០ នាឡិក្នុងមួយថ្ងៃ អំពីទ្រព្យរបស់សង្ឃដែលកើតក្នុងទីនោះ ក្នុងអាវាសធំទាំងឡាយ ត្រូវឱ្យដោយធ្វើអបលោកនកម្ម ។ ដើម្បីដោះកន្សល់ គឺ បំណុលដល់ភិក្ខុដែលមានសីលជាទីស្រឡាញ់ក្តី ទឹងឱ្យសេនាសនៈ ដែលមិនត្រូវផ្លាស់ប្តូរដល់ភិក្ខុដែលជាពហុស្សូត ជួយភារៈរបស់សង្ឃក្តី ទឹងឱ្យប្រាក់បន្ថែមដល់អារាមិកជន មានកប្បិយការកជាដើម អ្នកធ្វើកិច្ចរបស់សង្ឃក្តី អំពី

ទ្រព្យសង្ឃដែលកើតក្នុងអាវាសនោះ គួរឱ្យដោយអបលោកនកម្ម ប៉ុណ្ណោះ ។

ទឹងឱ្យថែរក្សាអាវាសរបស់សង្ឃ អំពីទ្រព្យរបស់សង្ឃដែលកើតឡើងក្នុងអាវាសនោះ ដែលទាយកថ្វាយ ដោយអំណាចចតុប្បច្ច័យ ក៏គួរ ។ តែដើម្បីកាត់ពាក្យតិះដៀលថា "ភិក្ខុនេះ រមែងចាត់ចែងការដោយកាន់ខ្លួនជាធំ" ទើបគួរសួរសង្ឃដែលមកក្នុងរោងស្លាកជាដើម ឬក្នុងទីប្រជុំដទៃជាមុន ទើបឱ្យថែរក្សា ។

អាវាសដែលភិក្ខុឆ្លាត គប្បីអបលោកន៍ហើយឱ្យថែរក្សា សូម្បីអំពី ទ្រព្យរបស់សង្ឃ ដែលកើតឡើងក្នុងអាវាសនោះ ដែលទាយកថ្វាយចំពោះ ដើម្បីប្រយោជន៍ដល់ចីវរ និងបិណ្ឌបាត ។ សូម្បីទឹងមិនអបលោកន៍ ក៏គួរ ។ តែដើម្បីកាត់ពាក្យតិះដៀលដែលកើតឡើងយ៉ាងនេះថា "ភិក្ខុនេះខ្វាំងក្ខាពិតណាំះ ឱ្យថែរក្សាអាវាសអំពីស្បៀងសង្ឃដែលគេឱ្យ ដើម្បីប្រយោជន៍ដល់ចីវរ និងបិណ្ឌបាត" ទើបគួរធ្វើអបលោកនកម្មមុន ហើយសឹមឱ្យថែរក្សា ។

កាលធ្វើឆត្រឬវេទីលើចេតិយ ឬរោងពោធិ ឬបន្ទប់ឆាន់ដែលមិនទាន់បានធ្វើក្តី ទឹងជួសជុលវត្ថុដែលទ្រុឌទ្រោមក្តី ទឹងធ្វើការបូកប៉ះក្តី បបួលពួកអ្នកស្រុកឱ្យជួយធ្វើ ក៏គួរ ។ បើមិនមានអ្នកធ្វើ, គប្បីឱ្យធ្វើអំពីប្រាក់ចំណូល ដែលផ្ញើទុកដើម្បីចេតិយ ។ សូម្បីកាលប្រាក់ចំណូល

ដែលផ្ទើទុកមិនមាន ក៏គប្បីធ្វើអបលោកន៍ ហើយឱ្យចាត់ចែងធ្វើអំពីទ្រព្យរបស់សង្ឃ ដែលកើតឡើងក្នុងអាវាសនោះ នឹងអបលោកន៍ ហើយធ្វើកិច្ចរបស់ចេតិយ សូម្បីដោយទ្រព្យរបស់សង្ឃក៏គួរ ។ សូម្បីអបលោកន៍ហើយធ្វើកិច្ចរបស់សង្ឃ ដោយទ្រព្យរបស់ចេតិយ មិនគួរទេ ។ តែនឹងកាន់យកជារបស់ខ្ចី ហើយសងវិញ គួរ ។

តែការដែលភិក្ខុទាំងឡាយ អ្នកធ្វើសុធាកម្មជាដើម ត្រង់ចេតិយកាលមិនបានអាហារល្មមញ៉ាំងអត្តភាពឱ្យប្រព្រឹត្តទៅអំពីកិក្ខាចារ ឬអំពីសង្ឃ នឹងកាន់យកអាហារល្មមញ៉ាំងអត្តភាពឱ្យប្រព្រឹត្តទៅ អំពីទ្រព្យរបស់ចេតិយមកឆាន់ ធ្វើវត្ត (ជំនួស) ក៏គួរ ។

នឹងធ្វើសង្ឃភត្តដោយត្រីនិងសាច់ជាដើម ដោយអាងថា "យើងធ្វើវត្ត" មិនគួរទេ ។

ដើមឈើមានផ្លែពួកណា សូម្បីដាំទុកក្នុងវត្ត ជារបស់ដែលសង្ឃហួងហែង រមែងបានការថែរក្សា ។ ភិក្ខុទាំងឡាយ រមែងវាយរគាំងហើយ បែងចែកគ្នាឆាន់នូវផ្លែទាំងឡាយនៃដើមឈើពួកណា, ក្នុងដើមឈើទាំងនោះ មិនគួរធ្វើអបលោកនកម្ម ។

ចំណែកដើមឈើមានផ្លែពួកណា ដែលសង្ឃមិនហួងហែង, ក្នុងដើមឈើទាំងនោះ គួរធ្វើអបលោកនកម្ម ។ ក៏អបលោកនកម្មនោះ គួរធ្វើសូម្បីក្នុងរោងស្លាក រោងយាគូ រោងភត្ត និងទីប្រជុំដទៃ ។ មួយ

ទៀត ក្នុងរោងឧបោសថក៏គួរធ្វើពិត ។ ព្រោះថា ឆន្ទៈនិងបារិសុទ្ធិរបស់ភិក្ខុទាំងឡាយ សូម្បីអ្នកមិនបានមក ក្នុងរោងឧបោសថនោះ ដែលភិក្ខុមួយរូប រមែងនាំមក ។ ព្រោះហេតុនោះ អបលោកនកម្មនោះ រមែងជាកម្មដែលជម្រះឱ្យបរិសុទ្ធិល្អ ។

ក៏ឯកាលនឹងធ្វើ គប្បីធ្វើយ៉ាងនេះ ៖

ភិក្ខុដែលឆ្លាត គប្បីសូធ្យប្រកាសដោយអនុមតិរបស់ភិក្ខុសង្ឃថា "បពិត្រព្រះសង្ឃដ៏ចម្រើន ខ្ញុំសួរសង្ឃថា វត្ថុណាជារបស់សង្ឃ មានឫស សំបក ស្លឹក ពន្លក ផ្កា និងផ្លែ ដែលគួរទំពាឆាន់បានជាដើម មាននៅក្នុងសីមាវត្តនេះ, ការដែលភិក្ខុទាំងឡាយ មកហើយ ៗ បរិភោគវត្ថុទាំងពួងនោះ តាមសប្បាយ គាប់ចិត្តដល់សង្ឃឬ ?" គប្បីសួរ ៣ ដង ។ អបលោកនកម្មនោះ ដែលភិក្ខុ ៤-៥ រូបធ្វើហើយ ក៏សម្រេចជាការបានពិត ។

ភិក្ខុ ២-៣រូបនៅក្នុងវត្តសូម្បីណា, អបលោកនកម្មសូម្បីដែលភិក្ខុទាំងនោះ អង្គុយធ្វើហើយក្នុងវត្តនោះ រមែងដូចគ្នានឹងអបលោកនកម្មដែលសង្ឃធ្វើហើយពិត ។ មួយទៀត ក្នុងវត្តណាមានភិក្ខុតែមួយ, កតិកាវត្តសូម្បីដែលភិក្ខុអង្គុយធ្វើបុព្វករណៈ និងបុព្វកិច្ចហើយក្នុងថ្ងៃឧបោសថនោះ រមែងដូចគ្នានឹងអបលោកនកម្ម ដែលសង្ឃធ្វើហើយនោះដែរ ។

ក៏ឯកតិកាវត្តនោះ ដែលភិក្ខុនឹងធ្វើ សូម្បីធ្វើតាមកាលនៃផ្លែឈើក៏

គួរ ៗ ធ្វើដោយកំណត់យ៉ាងនេះថា ៤ ខែ ៦ ខែ ១ ឆ្នាំ ក៏ដោយ, ធ្វើដោយមិនកំណត់ក៏ដោយ គួរទាំងអស់ ៗ

ក្នុងកាលដែលធ្វើដោយការកំណត់ គប្បីបរិភោគតាមដែលកំណត់ទុក ហើយធ្វើថ្មី ៗ ក្នុងកាលដែលធ្វើដោយមិនកំណត់ គួរត្រឹមកាលដែលដើមឈើទាំងឡាយនៅរស់ ៗ សូម្បីដើមឈើពួកដទៃណា ដែលដុះអំពីពូជទាំងឡាយ នៃដើមឈើទាំងនោះឯង, កតិកានោះ ក៏ប្រើសម្រាប់ដើមឈើទាំងនោះផង ៗ

ក៏បើថា ជាដើមឈើដែលដុះក្នុងវត្តដទៃ, សង្ឃក្នុងវត្តដែលជាអ្នកដាំប៉ុណ្ណោះ ជាម្ចាស់របស់ដើមឈើទាំងនោះ ៗ

សូម្បីពួកដើមឈើណា ដែលអ្នកណា ៗ នាំពូជមកអំពីទីដទៃដាំក្នុងកាលខាងក្រោយក្នុងវត្តពីដើម, សម្រាប់ដើមឈើទាំងនោះ ត្រូវធ្វើកតិកា( ថ្មី )យ៉ាងដទៃ ៗ កាលធ្វើកតិកាហើយ ដើមឈើទាំងនោះ រមែងតាំងនៅក្នុងឋានជារបស់បុគ្គល ៗ គួរបរិភោគផ្លែជាដើម តាមសប្បាយ ៗ

ក៏បើថា ភិក្ខុទាំងឡាយក្នុងវត្តពីដើមនេះ លោមព័ទ្ធឱកាសនោះ ៗ ធ្វើបរិវេណទុកហើយថែរក្សា ៗ ភិក្ខុពួកណា ថែរក្សា, ដើមឈើទាំងនោះ តាំងនៅក្នុងឋានជារបស់ភិក្ខុទាំងនោះ ៗ ភិក្ខុពួកដទៃ រមែងមិនបានដើម្បីបរិភោគ ៗ តែភិក្ខុដែលថែរក្សាទាំងនោះ ត្រូវឱ្យចំណែកទី

១០ ដល់សង្ឃ ហើយទើបបរិភោគ ។

សូម្បីភិក្ខុណា យកមែកឈើលោមព័ទ្ធរក្សាទុកកណ្តាលវត្ត សូម្បីភិក្ខុនោះ ក៏ន័យនេះឯង ។

ដោយការសប្បាយចិត្តថា ព្រះថេរៈមកហើយ សាមណេរទាំងឡាយ ទើបនាំផ្លែឈើតូចធំមកថ្វាយភិក្ខុ ដែលគួរលើកតម្កើងដែលទៅកាន់វត្តចាស់ ៗ ។ បើថា ក្នុងកាលពីដើម ភិក្ខុជាពហុស្សូត ទ្រទ្រង់បរិយត្តិធម៌ទាំងអស់ នៅក្នុងវត្តនោះ ។ ភិក្ខុនោះ គប្បីបរិភោគ ដោយមិនត្រូវមានសេចក្តីរង្កៀសថា ក្នុងវត្តនេះ នឹងមានកតិកាដែលធ្វើទុកយូរយារហើយ ជាពិតប្រាកដ ។ ផ្លែឈើតូចធំក្នុងវត្ត រមែងគួរ សូម្បីដល់ភិក្ខុទាំងឡាយ ដែលជាអ្នកកាន់បិណ្ឌបាតិកធុតង្គ គឺមិនញុំាងធុតង្គឱ្យខូច ។

សាមណេរទាំងឡាយ ថ្វាយផ្លែឈើតូចធំជាច្រើន ដល់អាចារ្យនិងឧបជ្ឈាយ៍របស់ខ្លួន, ភិក្ខុពួកដទៃ កាលមិនបាន រមែងតិះដៀល, ការតិះដៀលនោះ ក៏ត្រឹមតែជាការតិះដៀលប៉ុណ្ណោះ ។

តែបើជាកាលដែលភិក្ខាខ្សត់ខ្សោយ, ជនទាំង ៦០ អាស្រ័យដើមឈើមួយចិញ្ចឹមជីវិត ។ ក្នុងកាលដូច្នោះ ត្រូវបែងចែកគ្នាបរិភោគ ដើម្បីប្រយោជន៍នឹងធ្វើការសង្គ្រោះឱ្យដល់គ្នាទូទៅ ។ ធ្វើដូច្នេះ ជាការប្រពៃ ។

ក៏ឯកតិកាវត្ត មិនទាន់រម្ងាប់ត្រឹមណា, ផ្លែឈើដែលភិក្ខុទាំងនោះ

ឆាន់ហើយ ជាការឆាន់ហើយដោយល្អពិតត្រឹមនោះ ។ ក៏កាលណាហ្ន៎ កតិកាវត្ត ទើបរម្ងាប់ ? ក្នុងកាលណា សង្ឃព្រមព្រៀងប្រជុំគ្នាសូធ្យប្រកាសថា "តាំងពីថ្ងៃនេះទៅ ភិក្ខុទាំងឡាយចូរបែងចែកគ្នាឆាន់" ក្នុងកាលនោះ កតិកាវត្ត រមែងរម្ងាប់ ។ មួយទៀត ក្នុងវត្តដែលមានភិក្ខុមួយរូប កាលពាក្យប្រកាស សូម្បីដែលភិក្ខុមួយរូបប្រកាសហើយ កតិកាដែលប្រកាសពីមុន រមែងរម្ងាប់ដូចគ្នា ។

បើថា កាលកតិការម្ងាប់ហើយ សាមណេរទាំងឡាយមិនបានញុំាងផ្លែឈើទាំងឡាយ ឱ្យជ្រុះចាកដើមទេ មិនបានរើសផ្លែឈើពីផែនដីថ្វាយភិក្ខុទាំងឡាយទេ, ដើរជាន់ផ្លែឈើដែលជ្រុះហើយដោយជើង ។ សង្ឃគប្បីបន្ថែមផ្លែឈើឱ្យដល់សាមណេរពួកនោះ តាំងពីចំណែកទី ១០ ដរាបដល់ពាក់កណ្តាលចំណែកនៃផ្លែឈើ ។ ព្រោះបានបន្ថែមចំណែក ពួកលោកនឹងនាំមកថ្វាយ ពិតប្រាកដ ។

ក្នុងកាលដែលភិក្ខាត្រូវឡប់រកបានងាយ កាលកប្បិយការកទាំងឡាយ មកធ្វើការលោមព័ទ្ធដោយមែកឈើជាដើម រក្សាដើមឈើទុក មិនត្រូវឱ្យចំណែកបន្ថែមដល់ពួកសាមណេរ គប្បីបែងចែកគ្នាបរិភោគ ។

ជនទាំងឡាយ មកពីស្រុកជុំវិញវត្តគិតថា ក្នុងវត្តមានផ្លែឈើតូចធំ ទើបមកសូមដើម្បីប្រយោជន៍ដល់អ្នកជម្ងឺ ឬស្រីមានគភ៌ថា "សូមលោកឱ្យផ្លែដូង ១ ចូរឱ្យផ្លែស្វាយ ១ ចូរឱ្យផ្លែខ្នុរសម្ល ១"; សួរថា

គួរឱ្យឬមិនគួរ ? ឆ្លើយថា គួរឱ្យ ។ ព្រោះថា កាលភិក្ខុទាំងឡាយមិនឱ្យ ពួកគេនឹងខូចចិត្ត ។ តែកាលនឹងឱ្យ ត្រូវប្រជុំសង្ឃសូធ្យប្រកាស ៣ ដង ធ្វើអបលោកនកម្មឱ្យ ឬគប្បីធ្វើកតិកាវត្តតាំងទុក ។

ក៏ឯកតិកវត្តនោះ ដែលសង្ឃគប្បីធ្វើយ៉ាងនេះ ៖

ភិក្ខុដែលឆ្លាត គប្បីសូធ្យប្រកាសដោយអនុមតិរបស់សង្ឃថា "ជនទាំងឡាយ មកពីស្រុកជុំវិញវត្តមកសូមផ្លែឈើតូចធំ ដើម្បីប្រយោជន៍ដល់អ្នកជម្ងឺជាដើម, ការដែលមិនហាមជនទាំងនោះ អ្នកកាន់យកជូន ២ផ្លែ ត្នោត ២ផ្លែ ខ្នុរ ២ផ្លែ ស្វាយ ៥ផ្លែ ចេក ៥ផ្លែ និងការដែលមិនហាមជនទាំងនោះ អ្នកកាន់យកផ្លែឈើអំពីដើមឈើឯណោះ គាប់ចិត្តដល់ភិក្ខុសង្ឃ" ដូច្នេះ គប្បីសូធ្យ៣ដង ។ ចាប់តាំងពីនោះ ជនទាំងនោះកាលសូមដោយប្រាប់ឈ្មោះអ្នកជម្ងឺជាដើម ដែលភិក្ខុទាំងឡាយមិនគប្បីពោលថា ណ្ហើយចុះ ។ តែគប្បីប្រាប់វត្តថា សង្ឃបានតាំងកតិការមិនហាមជនទាំងឡាយ អ្នកកាន់យកផ្លែជូនជាដើម ដោយកំណត់ឈ្មោះនេះ និងអ្នកកាន់យកផ្លែឈើអំពីដើមឈើឯណោះ ។ តែមិនត្រូវដើរតាមប្រាប់ថា "ស្វាយដើមនេះ មានផ្លែឆ្ងាញ់ លោកចូរបេះពីដើមនេះ" ។

មួយទៀត ភិក្ខុដែលសង្ឃសន្មតហើយ គប្បីឱ្យកន្លះចំណែកដល់ជនទាំងនោះ អ្នកមកហើយក្នុងវេលាចែកផ្លែឈើ ។ ភិក្ខុដែលសង្ឃមិនបានសន្មត គប្បីអបលោកន៍ឱ្យ ។ បុគ្គលអ្នកអស់ស្បៀងក្តី ឈ្មួញរទេះ

និងអ្នកធ្វើដំណើរក្តី ឥស្សរជនដទៃក្តី មកសូម គប្បីអបលោកន៍ឱ្យ ។ កាលគេបេះបរិភោគដោយពលក្ការ (កម្លាំង) ក៏មិនគប្បីហាម ។ ព្រោះគេក្រោធហើយ ទឹងគប្បីកាត់ដើមឈើចេញក៏បាន ទឹងគប្បីធ្វើសេចក្តីវិនាសយ៉ាងដទៃក៏បាន ។ កាលគេមកកាន់បរិវេណចំណែកបុគ្គល សូមដោយចេញឈ្មោះអ្នកជម្ងឺ ភិក្ខុដែលជាម្ចាស់របស់ គប្បីប្រាប់ថា ខ្ញុំដាំទុកដើម្បីប្រយោជន៍ដល់មូបជាដើម, បើផ្លែមាន លោកចូរដឹងខ្លួនឯងចុះ ។

ក៏បើថា ដើមឈើទាំងឡាយមានផលច្រើន ។ ភិក្ខុយកបន្លាស្រោសទុក ឆាន់ផ្លែម្តង ៗ ។ ភិក្ខុនោះ កាលមិនប្រាថ្នា (នូវការ) តបស្នងហើយ ក៏គប្បីឱ្យ ។ កាលគេបេះយកដោយពលក្ការក៏មិនគប្បីហាម ។ ហេតុក្នុងការដែលមិនគួរហាមនេះ ខ្ញុំបានពោលទុកហើយក្នុងកាលមុននោះឯង ។

សួនផ្លែឈើរបស់សង្ឃមាន តែមិនបានទទួលការថែរក្សា ។ បើថា ភិក្ខុរបខ្លះថែរក្សាសួននោះ ដោយប្រាថ្នាវត្តជាធំ, សួននោះ តាំងនៅជារបស់សង្ឃ ។ សូម្បីបើថា សង្ឃប្រគល់ឱ្យជាភារៈរបស់ភិក្ខុរបខ្លះថា សប្បុរស លោកចូរជួយថែរក្សាសួន នេះផងចុះ, បើភិក្ខុនោះ ថែរក្សាដោយប្រាថ្នាវត្ត, សូម្បីយ៉ាងនេះ ក៏នៅជារបស់សង្ឃ ។ តែសង្ឃគប្បីឱ្យចំណែកបន្ថែមត្រឹមតែចំណែកទី ៣ ឬពាក់កណ្តាលចំណែក ដល់ភិក្ខុនោះអ្នកប្រាថ្នាចំណែកបន្ថែម ។

ក៏ឯកាលលោកពោលថា ជាកម្មធ្ងន់ ហើយមិនប្រាថ្នា ដោយចំណែកបន្ថែមត្រឹមតែប៉ុណ្ណោះ ភិក្ខុទាំងឡាយគប្បីពោលខ្លះថា "លោកចូរធ្វើផ្លែឈើទាំងអស់ឱ្យជារបស់លោកម្នាក់ ចូរឱ្យត្រឹមតែចំណែកទី ១០ ជាចំណែកមូលតម្លៃ ហើយថែរក្សាចុះ" ។ តែមិនគប្បីឱ្យដោយអំណាចជាច់មូលតម្លៃ ព្រោះសួននោះ ជាគរុភណ្ឌ ។

ភិក្ខុដែលឱ្យចំណែកនៃមូលតម្លៃហើយ ដូច្នោះ ឱ្យសាងសេនាសនៈទីលំនៅដែលមិនទាន់បានសាងខ្លះ ថែរក្សាសេនាសនៈ ដែលគេសាងទុកហើយខ្លះ ហើយប្រគល់សួនដល់ពួកនិស្សិត ។ សូម្បីពួកនិស្សិតនោះ ក៏គប្បីឱ្យចំណែកនៃមូលតម្លៃ ។

ក៏ភិក្ខុទាំងឡាយ អាចនឹងថែរក្សាដោយខ្លួនឯង ក្នុងកាលណា, ក្នុងកាលនោះ សង្ឃមិនគប្បីឱ្យភិក្ខុទាំងនោះថែរក្សា, មិនគប្បីហាម ក្នុងកាលដែលពួកលោកបានថែរក្សាផ្លែឈើហើយ ។ គប្បីហាមក្នុងវេលាដែលផ្ដើមនឹងថែរក្សាប៉ុណ្ណោះ ។ គប្បីពោលថា ពួកលោកបានឆាន់ច្រើនហើយ, ឥឡូវនេះ កុំថែរក្សាឡើយ, ភិក្ខុសង្ឃនឹងថែរក្សាខ្លួនឯង ។

ក៏បើថា អ្នកថែរក្សាដោយប្រាថ្នាវត្តក៏មិនមាន អ្នកថែរក្សាដោយប្រាថ្នាចំណែកបន្ថែមក៏មិនមាន, ទាំងសង្ឃក៏មិនអាចនឹងថែរក្សាបានសោត ; ភិក្ខុ ១ រូប មិនប្រាប់សង្ឃជាមុន ថែរក្សាដោយខ្លួនឯង ធ្វើឱ្យចម្រើនហើយប្រាថ្នាចំណែកបន្ថែម, ចំណែកបន្ថែមដែលសង្ឃគប្បីបន្ថែមឱ្យ

ដោយអបលោកនកម្ម ។

អបលោកនកម្មសូម្បីទាំងពួងនេះ ចាត់ជាកម្មលក្ខណៈពិត ។ អបលោកនកម្ម រមែងដល់ឋានៈ ៥ ទាំងនេះ ដោយប្រការដូច្នេះ ។

# ញត្តិកម្ម

[៤៣៨] មួយទៀត គប្បីជ្រាបវិនិច្ឆ័យ ក្នុងប្រភេទនៃឋាននៃញត្តិកម្ម ដូចតទៅនេះ ៖

វាចាសម្រាប់ហៅឧបសម្បទាបេក្ខៈចូលមក យ៉ាងនេះថា សូមសង្ឃស្តាប់ខ្ញុំ អ្នកមានអាយុ ឈ្មោះនេះ ជាឧបសម្បទាបេក្ខៈ របស់លោកដ៏មានអាយុឈ្មោះនេះ ឧបសម្បទាបេក្ខៈនោះ ខ្ញុំប្រៀនប្រដៅរួចហើយ, បើកម្មមានការគួរដល់សង្ឃហើយ សូមអ្នកមានអាយុឈ្មោះនេះគប្បីមក ព្រោះដូច្នោះ អ្នកមានអាយុឈ្មោះនេះ ដែលខ្ញុំគប្បីហៅថា អ្នកឯងចូរមក ដូច្នេះ ឈ្មោះថា **ឱសារណា** ។

វាចាសម្រាប់បណ្តេញភិក្ខុដែលជាធម្មកថិកចេញ ក្នុងឧព្វាហិកវិនិច្ឆ័យ យ៉ាងនេះថា សូមលោកទាំងឡាយចូរស្តាប់ខ្ញុំ, ភិក្ខុដែលមានឈ្មោះនេះ លោកមិនស្ទាត់សុត្តៈ មិនចាំសុត្តវិភង្គទេ, លោកមិនពិចារណាអត្ថជំទាស់អត្ថដោយស្រមោលនៃព្យញ្ជនៈ, បើកម្មមានការគួរដល់លោក

ទាំងឡាយហើយ បើសង្ឃមានការព្រមព្រៀងគ្នាហើយ, គប្បីបណ្ដេញភិក្ខុឈ្មោះនេះចេញ ពួកយើងដែលនៅសល់គប្បីរម្ងាប់អធិករណ៍នេះ ដូច្នេះ ឈ្មោះថា **និស្សារណា** ។

ញត្តិដែលតាំងដោយអំណាចឧបោសថកម្ម យ៉ាងនេះថា "បពិត្រព្រះសង្ឃដ៏ចម្រើន សូមសង្ឃស្ដាប់ខ្ញុំ ឧបោសថថ្ងៃនេះទី ១៥, បើកម្មមានការគួរដល់សង្ឃហើយ, សង្ឃគប្បីធ្វើឧបោសថ" ដូច្នេះ ឈ្មោះថា **ឧបោសថ** ។

ញត្តិដែលតាំងដោយអំណាចបវារណាកម្ម យ៉ាងនេះថា "បពិត្រព្រះសង្ឃដ៏ចម្រើន សូមសង្ឃស្ដាប់ខ្ញុំ បវារណាថ្ងៃនេះទី ១៥, បើកម្មមានការគួរដល់សង្ឃហើយ, សង្ឃគប្បីបវារណា" ដូច្នេះ ឈ្មោះថា **បវារណា** ។

ញត្តិដែលតាំង ដើម្បីសន្មតិខ្លួនឯង ឬអ្នកដទៃយ៉ាងនេះថា "បពិត្រព្រះសង្ឃដ៏ចម្រើន សូមសង្ឃស្ដាប់ខ្ញុំ អ្នកមានអាយុឈ្មោះនេះជាឧបសម្បទាបេក្ខៈរបស់លោកមានអាយុឈ្មោះនេះ, បើកម្មមានការគួរដល់សង្ឃហើយ, ខ្ញុំគប្បីទូន្មានអ្នកមានអាយុឈ្មោះនេះ" ដូច្នេះក្ដី, ថា "បើកម្មមានការគួរដល់សង្ឃហើយ, អ្នកមានអាយុឈ្មោះនេះ គប្បីប្រៀនប្រដៅអ្នកមានអាយុឈ្មោះនេះ" ដូច្នេះក្ដី, ថា "បើកម្មមានការគួរដល់សង្ឃហើយ, ខ្ញុំគប្បីសួរអន្តរាយិកធម៌ ចំពោះអ្នកមានអាយុឈ្មោះនេះ"

ដូច្នេះក្តី, ថា "បើកម្មមានការគួរដល់សង្ឃហើយ, អ្នកមានអាយុឈ្មោះនេះ គប្បីសួរអន្តរាយិកធម៌ ចំពោះអ្នកមានអាយុឈ្មោះនេះ" ដូច្នេះក្តី, ថា "បើកម្មមានការគួរដល់សង្ឃហើយ, ខ្ញុំគប្បីសួរវិន័យចំពោះអ្នកមានអាយុឈ្មោះនេះ" ដូច្នេះក្តី, ថា "បើកម្មមានការគួរដល់សង្ឃហើយ, អ្នកមានអាយុឈ្មោះនេះ គប្បីសួរវិន័យចំពោះអ្នកមានអាយុឈ្មោះនេះ" ដូច្នេះក្តី, ថា "បើកម្មមានការគួរដល់សង្ឃហើយ, ខ្ញុំដែលអ្នកមានអាយុឈ្មោះនេះ សួរវិន័យហើយ សូមវិសជ្ជនា" ដូច្នេះក្តី, ថា "បើកម្មមានការគួរដល់សង្ឃហើយ, អ្នកមានអាយុឈ្មោះនេះ ដែលអ្នកមានអាយុឈ្មោះនេះ សួរវិន័យហើយ គប្បីវិសជ្ជនា" ដូច្នេះក្តី ឈ្មោះថា **សន្មត ។**

ការឱ្យបរិក្ខារ មានចីវរនិងបាត្រជាដើម ដែលភិក្ខុដទៃលះបង់ យ៉ាងនេះថា "បពិត្រព្រះសង្ឃដ៏ចម្រើន សូមសង្ឃស្តាប់ខ្ញុំ ចីវរនេះរបស់ភិក្ខុដែលមានឈ្មោះនេះ ជានិស្សគ្គិយ ដែលលោកលះបង់ហើយដល់សង្ឃ, បើកម្មមានការគួរដល់សង្ឃហើយ, សង្ឃគប្បីឱ្យចីវរនេះដល់ភិក្ខុមានឈ្មោះនេះ" ថា "បើកម្មមានការគួរដល់លោកទាំងឡាយហើយ, លោកទាំងឡាយ គប្បីឱ្យចីវរនេះ ដល់ភិក្ខុដែលមានឈ្មោះនេះ" ដូច្នេះ ឈ្មោះថា **ការឱ្យ ។**

ការទទួលអាបត្តិយ៉ាងនេះ គឺ ភិក្ខុដែលឆ្លាតវាងវៃគប្បីប្រកាសថា "បពិត្រព្រះសង្ឃដ៏ចម្រើន សូមព្រះសង្ឃស្តាប់ខ្ញុំ ភិក្ខុដែលមានឈ្មោះនេះ

វលើកបានបើកបង្ហាញ ធ្វើឱ្យប្រាកដច្បាស់ គឺសម្តែងអាបត្តិ, បើកម្មមានការគួរដល់សង្ឃហើយ, ខ្ញុំគប្បីទទួលអាបត្តិរបស់ភិក្ខុដែលមានឈ្មោះនេះ" ថា "បើកម្មមានការគួរដល់លោកទាំងឡាយហើយ, ខ្ញុំគប្បីទទួលអាបត្តិរបស់ភិក្ខុឈ្មោះនេះ", លោកដែលភិក្ខុនោះគប្បីពោលថា "លោកឃើញឬ" កាលលោកឆ្លើយថា "ករុណា ខ្ញុំឃើញ" គប្បីពោលថា "លោកគប្បីសង្រួមតទៅ" ដូច្នេះ ឈ្មោះថា **ការទទួល** ។

បវារណាដែលសង្ឃធ្វើយ៉ាងនេះ គឺ អាវាសិកភិក្ខុអ្នកឆ្លាតវាងវៃគប្បីប្រកាសថា "លោកទាំងឡាយជាម្ចាស់អាវាស ចូរស្តាប់ខ្ញុំ, បើកម្មមានការគួរដល់លោកទាំងឡាយហើយ, ឥឡូវនេះ យើងទាំងឡាយគប្បីធ្វើឧបោសថ គប្បីសូធ្យបាដិមោក្ខ គប្បីបវារណាក្នុងកាឡបក្ខដែលនឹងមកខាងមុខ" ។ ភិក្ខុទាំងឡាយ បើភិក្ខុទាំងនោះ ជាអ្នកបង្កសេចក្តីទាស់ទែងគ្នា បង្កសេចក្តីឈ្លោះគ្នា បង្កការវិវាទគ្នា បង្កអធិករណ៍ក្នុងសង្ឃជាប់នៅរហូតដល់អស់កាឡបក្ខនោះសោត ភិក្ខុម្ចាស់អាវាសអ្នកឆ្លាតវាងវៃ គប្បីប្រកាសឱ្យភិក្ខុម្ចាស់អាវាសទាំងឡាយជ្រាបថា "សូមលោកទាំងឡាយជាម្ចាស់អាវាស ចូរស្តាប់ខ្ញុំ, បើកម្មមានការគួរដល់លោកទាំងឡាយហើយ, ឥឡូវនេះ យើងទាំងឡាយគប្បីធ្វើឧបោសថ គប្បីសូធ្យបាដិមោក្ខ, គប្បីបវារណាក្នុងជុណ្ហបក្ខដែលនឹងមកខាងមុខ" ដូច្នេះ ឈ្មោះថា **បន្ថិតបវារណាចេញទៅ** ។

ញត្តិដែលគ្របទូទៅ ដែលជាដើមនៃញត្តិទាំងពួង ដែលធ្វើដោយតិណវត្ថារកសមថៈយ៉ាងនេះ គឺ ភិក្ខុគ្រប់ ៗ រូប គប្បីប្រជុំក្នុងទីជាមួយគ្នា, កាលប្រជុំគ្នាហើយ ភិក្ខុដែលឆ្លាតវាងវៃ គប្បីប្រកាសឱ្យសង្ឃជ្រាបថា "បពិត្រព្រះសង្ឃដ៏ចម្រើន សូមសង្ឃស្តាប់ខ្ញុំ, កាលយើងទាំងឡាយកើតសេចក្តីទាស់ទែងគ្នា ឈ្លោះគ្នា វិវាទគ្នា បានប្រព្រឹត្តអជ្ឈាចារ្យ មិនសមគួរដល់សមណៈជាច្រើន ពោលទាស់ទែងគ្នា, បើយើងទាំងឡាយនឹងគប្បីពិន័យគ្នានិងគ្នា ដោយអាបត្តិទាំងនេះ, ការពិន័យនោះ នឹងគប្បីជាអធិករណ៍ ក៏បាន, បើអធិករណ៍នោះ នឹងគប្បីប្រព្រឹត្តទៅដើម្បីសេចក្តីក្តៀវក្លា ដើម្បីសេចក្តីកាចសាហាវ ដើម្បីសេចក្តីបែកគ្នា, បើកម្មមានការគួរដល់សង្ឃហើយ, សង្ឃគប្បីរម្ងាប់អធិករណ៍នេះ ដោយតិណវត្ថារកសមថៈ វៀរអាបត្តិមានទោសធ្ងន់ វៀរអាបត្តិដែលជាប់ដោយគ្រហស្ថចេញ ដូច្នេះ ឈ្មោះថា កម្មលក្ខណៈ ។

ញត្តិ ២ រាប់មួយចំណែក ៗ ១ ញត្តិ តពីសព្វសង្គាហិកាញត្តិនោះទៅ ក៏ដូចគ្នា ។

ញត្តិកម្ម មានប្រភេទតាមដែលពោលហើយ រមែងដល់ឋានៈ ៩ ទាំងនេះ គឺឱសារណា និស្សារណា ឧបោសថ បវារណា សម្មុតិ ការឱ្យ ការទទួល ការបង្អិតបវារណាចេញទៅ និង កម្មលក្ខណៈជាគម្រប់ ៩ ដោយប្រការដូច្នោះ ។

# ញត្តិទុតិយកម្ម

[៤៣៩] មួយទៀត គប្បីជ្រាបវិនិច្ឆ័យក្នុងប្រភេទនៃឋានៈនៃញត្តិទុតិយកម្ម ដូចតទៅនេះ ៖

គប្បីជ្រាបនិស្សារណា ដែលព្រះមានព្រះភាគត្រាស់ទុកក្នុងខន្ធកៈ ដោយអំណាចផ្កាប់បាត្រដល់វឌ្ឍលិច្ឆវី និងឱសារណា ដែលត្រាស់ដោយអំណាចផ្ងារបាត្រដល់វឌ្ឍលិច្ឆវីនោះឯង ។

គប្បីជ្រាបសម្មតិ ជាប់ដោយសន្មតទាំងនេះ គឺ សន្មតសីមា សន្មតដែនមិននៅប្រាសចាកត្រៃចីវរ សន្មតសន្ថត សន្មតភិក្ខុជាភត្តុទ្ទេសកៈ សន្មតភិក្ខុជាសេនាសនគ្គាហាបកៈ សន្មតភិក្ខុរក្សាឃ្លាំង សន្មតភិក្ខុទទួលចែកចីវរ សន្មតភិក្ខុចែកចីវរ សន្មតភិក្ខុចែកយាគូ សន្មតភិក្ខុចែកផ្លែឈើ សន្មតភិក្ខុចែកបង្អែម សន្មតភិក្ខុចែករបស់បន្តិចបន្តួច សន្មតភិក្ខុទទួលសំពត់ សន្មតភិក្ខុជាបត្តគ្គាហាបកៈ សន្មតភិក្ខុប្រើញោមវត្ត សន្មតភិក្ខុប្រើសាមណេរ ។

ការឱ្យ គប្បីជ្រាបដោយអំណាចការឱ្យចីវរកឋិន និងឱ្យចីវរមតកៈ ។

ការដក គប្បីជ្រាបដោយអំណាចការដោះកឋិន ។

ការសម្តែង គប្បីជ្រាបដោយអំណាចសម្តែងទីសាងកុដិ និងទី

សាឡវិហារ ។

កម្មលក្ខណៈ គប្បីជ្រាបដោយអំណាចញត្តិទុតិយកម្មវាចា ២ ដែលលោកពោលទុកក្នុងតិណវត្ថារកសមថៈ គឺ វៀរញត្តិ ៣ យ៉ាង គឺ សព្វសង្គាហិកាញត្តិ និងញត្តិក្នុងមួយផ្នែកមួយញត្តិ ៗ បានដល់ កម្មវាចាមួយផ្នែកមួយ ៗទៀតចេញ ។

ញត្តិទុតិយកម្ម រមែងដល់ឋានៈ ៧ នេះ ដោយប្រការនេះ ។

## ញត្តិចតុត្ថកម្ម

[៤៤០] មួយទៀត គប្បីជ្រាបវិនិច្ឆ័យក្នុងប្រភេទនៃឋាននៃញត្តិចតុត្ថកម្ម ដូចតទៅនេះ ៖

និស្សារណា គប្បីជ្រាបដោយអំណាចកម្ម ៧ យ៉ាង មានតជ្ជនីយកម្មជាដើម ។ ឱសារណា គប្បីជ្រាបដោយអំណាចការរម្ងាប់កម្មទាំងនោះឯង ។

សម្មុតិ គប្បីជ្រាបដោយអំណាចសន្មតភិក្ខុឱ្យទូន្មានភិក្ខុនី ។

ការឱ្យ គប្បីជ្រាបដោយអំណាចការឱ្យបរិវាស និងឱ្យមានត្ត ។

និគ្គហៈ គប្បីជ្រាបដោយអំណាចមូលាយបដិកស្សនកម្ម ។

សមនុភាសនា គប្បីជ្រាបដោយអំណាចសមនុភាសនា ១១

យ៉ាងទាំងនេះ គឺឧក្កិដ្ឋានុវត្តកសិក្ខាបទ យាវតតិយកសិក្ខាបទ ៨ (របស់ភិក្ខុនី) អរិដ្ឋសិក្ខាបទ និងចណ្ឌកាលីសិក្ខាបទ យាវតតិយកសិក្ខាបទនោះទាំងនេះ ។

ចំណែកកម្មលក្ខណៈ គប្បីជ្រាបដោយអំណាចនៃឧបសម្បទាកម្ម និងអព្ភានកម្ម ។

ញត្តិចតុត្ថកម្ម រមែងដល់ឋានៈ ៧ ទាំងនេះ ដោយប្រការដូច្នេះ ។

ព្រះឧបាលីថេរៈ កាលសម្តែងកម្ម កម្មវិបត្តិ និងការដល់ប្រភេទរបស់ឋានៈនៃកម្មទាំងឡាយ ដែលវៀរចាកវិបត្តិដោយប្រការយ៉ាងនេះហើយ ឥឡូវនេះ នឹងសម្តែងចំនួននៃសង្ឃអ្នកធ្វើកម្មទាំងនោះ ទើបពោលបន្តទៅថា ក្នុងកម្មដែលសង្ឃចតុវគ្គ គប្បីធ្វើជាដើម ។ សេចក្តីនៃពាក្យនោះ បណ្ឌិតគប្បីជ្រាបដោយន័យដែលបានពោលហើយ ក្នុងវណ្ណនានៃកម្មវិបត្តិដោយបរិស័ទនោះឯង ដូច្នេះ ។

ពណ៌នាកម្មវគ្គ ចប់

# ប្រយោជន៏នៃការបញ្ញត្តិសិក្ខាបទ

[៤៤២] ឥឡូវនេះ ព្រះឧបាលីថេរៈ បានផ្តើមពាក្យថា ទ្វេ អត្ថវសេ បដិច្ច : ព្រោះអាស្រ័យប្រយោជន៍ ២ ប្រការ ជាដើម ដើម្បីសម្តែងអានិសង្ស ក្នុងការដែលទ្រង់បញ្ញត្តិសិក្ខាបទទាំងឡាយ ដែលជាទីតាំងនៃកម្មទាំងនោះ ។

បណ្តាបទទាំងនោះ ត្រង់បទថា ទិដ្ឋធម្មិកានំ អាសវានំ សំវរាយ : ដើម្បីរាំងអាសវៈទាំងឡាយក្នុងបច្ចុប្បន្ន មានសេចក្តីថា ដើម្បីប្រយោជន៍ដល់ការប្រុងប្រយ័ត្ន គឺ ដើម្បីប្រយោជន៍ដល់ការបិទនូវពៀរវេរា ដែលប្រព្រឹត្តទៅក្នុងទិដ្ឋធម៌ ៥ មានបាណាតិបាតជាដើម ។

ត្រង់បទថា សម្បរាយិកានំ អាសវានំ បដិឃាតាយ : ដើម្បីឃាត់ហាមអាសវៈទាំងឡាយក្នុងបរលោក មានសេចក្តីថា ដើម្បីប្រយោជន៍ដល់ការកម្ចាត់ គឺ ដើម្បីប្រយោជន៍ដល់ការកាត់ផ្តាច់ បានដល់ដើម្បីប្រយោជន៍ដល់ការមិនកើតឡើងនៃពៀរវេរា ដែលប្រព្រឹត្តទៅក្នុងសម្បរាយភព ពោលគឺ វិបាកទុក្ខ ។

ត្រង់បទថា ទិដ្ឋធម្មិកានំ វេរានំ សំវរាយ : ដើម្បីរាំងពៀរក្នុងបច្ចុប្បន្ន មានសេចក្តីថា ដើម្បីប្រយោជន៍ដល់ការបិទនូវពៀរវេរា ៥ ទាំងនោះឯង ។

ពីរបទថា សម្បរាយិកានំ វេរានំ : ដើម្បីឃាត់ហាមពៀរក្នុងបរលោក មានសេចក្តីថា ដើម្បីប្រយោជន៍ដល់ការកម្ចាត់វិបាកទុក្ខទាំងនោះឯង ។

ច្រើនបទថា ទិដ្ឋធម្មិកានំ វជ្ជានំ សំវរាយ : ដើម្បីរារាំងទោសក្នុងបច្ចុប្បន្ន មានសេចក្តីថា ដើម្បីប្រយោជន៍ដល់ការបិទនូវពៀរវេរា ៥ ទាំងនោះ ។

ពីរបទថា សម្បរាយិកានំ វជ្ជានំ : ដើម្បីឃាត់ហាមទោសក្នុងបរលោក មានសេចក្តីថា ដើម្បីប្រយោជន៍ដល់ការកម្ចាត់វិបាកទុក្ខទាំងនោះឯង ។ ពិតមែន វិបាកទុក្ខនុ៎ះឯង ដែលព្រះមានព្រះភាគត្រាស់ថា ទោស ក្នុងទីនេះ ក៏ព្រោះជាធម៌ដែលបណ្ឌិតគប្បីវៀរ ។

ពីរបទថា ទិដ្ឋធម្មិកានំ ភយានំ : នូវភ័យក្នុងបច្ចុប្បន្ន មានសេចក្តីថា ភ័យទាំងនេះ គឺសេចក្តីតិះដៀល ការចោទ កម្មមានតជ្ជនីយកម្មជាដើម ការវៀរឧបោសថ និងបវារណាកម្មដែលផ្ចាញ់ផ្ចាលសេចក្តីវិនាសបាត់បង់ ឈ្មោះថា ភ័យប្រព្រឹត្តទៅក្នុងទិដ្ឋធម៌, ដើម្បីប្រយោជន៍ដល់ការរារាំងនូវភ័យទាំងនោះ,

ចំណែកភ័យប្រព្រឹត្តទៅក្នុងសម្បរាយភព ក៏គឺ វិបាកទុក្ខនុ៎ះឯង, ដើម្បីប្រយោជន៍ដល់ការរារាំងចំពោះសម្បរាយិកភ័យទាំងនោះ ។

ពីរបទថា ទិដ្ឋធម្មិកានំ អកុសលានំ : នូវភ័យក្នុងបរលោក

មានសេចក្តីថា ដើម្បីប្រយោជន៍ដល់ការរាំងចំពោះអកុសល មានវេរ ៥ និង អកុសលកម្មបថ ១០ ជាប្រភេទ ។

មួយទៀត វិបាកទុក្ខទាំងឡាយ៉ាងឯង លោកពោលថា អកុសលប្រព្រឹត្តទៅក្នុងសម្បរាយភព ព្រោះអត្ថថា មិនរួចផុតភ័យ, ដើម្បីប្រយោជន៍ដល់ការកម្ចាត់អកុសលទាំងនេះ ។

ពីរបទថា **គិហីនំ អនុកម្បាយ : ដើម្បីអនុគ្រោះដល់ពួកគ្រហស្ថ** មានសេចក្តីថា ដើម្បីអនុគ្រោះដល់គ្រហស្ថទាំងឡាយ ដោយអំណាចរក្សាសទ្ធាទុក ។

ពីរបទថា **បាបិច្ឆានំ បក្ខុបច្ឆេទាយ : ដើម្បីផ្តាច់ផ្តិលបក្ខពួករបស់បុគ្គលមានសេចក្តីប្រាថ្នាលាមក** មានសេចក្តីថា គណភោជនសិក្ខាបទ ដែលព្រះមានព្រះភាគទ្រង់បញ្ញត្តិទុក ដើម្បីទម្លាយករឃុំគ្រងគ្នាជាបក្ខពួកនៃបុគ្គលដែលមានសេចក្តីប្រាថ្នាដ៏លាមកទាំងឡាយ ។

ពាក្យដ៏សេសក្នុងទីទាំងពួង ងាយយល់ទាំងអស់ ។

ក៏ក្នុងពាក្យដ៏សេសនេះ គប្បីមានពាក្យណាដែលខ្ញុំគួរពោល, ពាក្យទាំងពួងនោះ ខ្ញុំបានពោលទុកក្នុងវណ្ណនានៃបឋមបារាជិករួចហើយដូច្នេះឯង ។

បរិយាយប្រយោជន៍ក្នុងសិក្ខាបទ ចប់

# ពណ៌នាបញ្ញត្តិវគ្គ

[៤៤៣] បណ្ដាធម៌មានបាដិមោក្ខជាដើម បាតិមោក្ខុទ្ទេសរបស់ភិក្ខុមាន ៥ យ៉ាង, របស់ភិក្ខុនីមាន ៤ យ៉ាង ។

បណ្ដាកម្មមានឱ្យបរិវាសជាដើម ពីរបទថា ឱសារណីយំ បញ្ញត្តំ : បញ្ញត្តឱសារណីយកម្ម មានសេចក្ដីថា ឱសារណីយកម្ម ទ្រង់បញ្ញត្តិសម្រាប់ ភិក្ខុដែលប្រព្រឹត្តក្នុងវត្ត ១៨ឬ ៤៣ អធិប្បាយថា ភិក្ខុដែលសង្ឃ រមែងហៅចូលពួក ដោយកម្មណា កម្មនោះទ្រង់បញ្ញត្តិហើយ ។

ពីរបទថា និស្សារណីយំ បញ្ញត្តំ : បញ្ញត្តនិស្សារណីយកម្ម មានសេចក្ដីថា ភិក្ខុអ្នកបង្ករសេចក្ដីទាស់ទែងជាដើម ដែលសង្ឃ រមែងបណ្ដេញចេញចាកពួកដោយកម្មណា កម្មនោះទ្រង់បញ្ញត្តិហើយ ។

# អានិសង្សនៃបញ្ញត្តិ

[៤៤៤] បណ្ដាបទមានបទថា អប្បញ្ញត្តេ ជាដើម ពីរបទថា អប្បញ្ញត្តេ បញ្ញត្តំ : កាលសិក្ខាបទដែលមិនទាន់បានបញ្ញត្តទុក ព្រះតថាគតទ្រង់បញ្ញត្តសិក្ខាបទឡើង មានសេចក្ដីថា កងអាបត្តិទាំង ៧ ឈ្មោះថា បញ្ញត្តិ ក្នុងសិក្ខាបទដែលអ្នកណា ៗ មិនបានបញ្ញត្តិ ក្នុង

ចន្លោះ ក្រៅពីព្រះកកុសន្ធសម្មាសម្ពុទ្ធ ព្រះកោនាគមនសម្មាសម្ពុទ្ធ និងព្រះកស្សបសម្មាសម្ពុទ្ធ ។

វិនីតកថាមានមក្កដីវត្ថុជាដើម ឈ្មោះថា អនុប្បញ្ញត្តិ ក្នុងសិក្ខាបទដែលទ្រង់បញ្ញត្តិទុកហើយ ។

ពាក្យដ៏សេស ក្នុងបទទាំងពួង ងាយយល់ទាំងអស់ ដូច្នេះឯង ។

ពណ៌នាអានិសង្សវគ្គ ចប់

## សង្គហៈ ការសង្គ្រោះ

[៤៤៥] ឥឡូវនេះ ព្រះឧបាលី ពោលពាក្យថា នវ សង្គហា : សង្គហៈទាំងឡាយ ៩ ជាដើម ដើម្បីសម្តែងសង្គ្រោះសិក្ខាបទទាំងពួងជា ៩ ចំណែក ដោយអាការតែម្យ៉ាង ។

បណ្តាបទទាំងនោះ បទថា វត្ថុសង្គហោ បានដល់ សង្គ្រោះដោយវត្ថុ ។

សេចក្តីចំពោះបទ សូម្បីក្នុងបទដ៏សេស ក៏គប្បីជ្រាបយ៉ាងនេះ ។

ក៏ក្នុងបទថា វត្ថុសង្គហោ ជាដើមនេះ មានអត្ថយោជនាដូចតទៅ

នេះ ៖

សង្គ្រោះដោយវត្ថុ គប្បីជ្រាបមុនយ៉ាងនេះថា ក៏សិក្ខាបទទាំងពួង ឈ្មោះថា ព្រះមានព្រះភាគទ្រង់សង្គ្រោះដោយវត្ថុ ព្រោះហេតុថា មិនមានសូម្បីតែសិក្ខាបទមួយដែលទ្រង់បញ្ញត្តិ ព្រោះហេតុមិនមែនជាវត្ថុ ។

មួយទៀត សង្គ្រោះដោយវិបត្តិ គប្បីជ្រាបយ៉ាងនេះថា ព្រោះហេតុដែលអាបត្តិ ២ កង ទ្រង់សង្គ្រោះដោយសីលវិបត្តិ, អាបត្តិ ៥ កង ទ្រង់សង្គ្រោះដោយអាចារវិបត្តិ, ៦ សិក្ខាបទ ទ្រង់សង្គ្រោះដោយអាជីវវិបត្តិ ដូច្នោះ សិក្ខាបទសូម្បីទាំងពួង ឈ្មោះថា ទ្រង់សង្គ្រោះហើយដោយវិបត្តិ ។

មួយទៀត សង្គ្រោះដោយអាបត្តិ គប្បីជ្រាបយ៉ាងនេះថា ព្រោះហេតុដែលមិនមាន សូម្បីតែសិក្ខាបទមួយ ដែលរួចផុតពីអាបត្តិ ៧ កង ដូច្នោះ សិក្ខាបទទាំងពួង ឈ្មោះថា ទ្រង់សង្គ្រោះហើយដោយអាបត្តិ ។

មួយទៀត សង្គ្រោះដោយនិទាន គប្បីជ្រាបយ៉ាងនេះថា សិក្ខាបទទាំងពួង ទ្រង់បញ្ញត្តិហើយក្នុងនគរ ៧ ព្រោះដូច្នោះ ឈ្មោះថា ទ្រង់សង្គ្រោះហើយដោយនិទាន ។

មួយទៀត សង្គ្រោះដោយបុគ្គល គប្បីជ្រាបយ៉ាងនេះថា ព្រោះហេតុដែលមិនមាន សូម្បីតែសិក្ខាបទមួយ ដែលទ្រង់បញ្ញត្តិក្នុងកាលមិនមានបុគ្គលដែលប្រព្រឹត្តកន្លង ដូច្នោះ សិក្ខាបទទាំងពួង ឈ្មោះថា ទ្រង់

សង្គ្រោះហើយដោយបុគ្គល ។

មួយទៀត សិក្ខាបទទាំងពួង ទ្រង់សង្គ្រោះហើយ ដោយអាបត្តិ ៥ កង និង ៧ កង ។ សិក្ខាបទទាំងអស់នោះ វៀរចាកសមុដ្ឋាន ៦ ចេញ រមែងកើតមិនបាន ព្រោះដូច្នោះ ឈ្មោះថា ទ្រង់សង្គ្រោះហើយ ដោយសមុដ្ឋាន ។

មួយទៀត សិក្ខាបទទាំងពួង ទ្រង់សង្គ្រោះហើយ ដោយអាបត្តាធិករណ៍ក្នុងបណ្តាអធិករណ៍ ៤ ។ សិក្ខាបទទាំងពួង រមែងដល់សេចក្តីរម្ងាប់ដោយសមថៈ ៧ ព្រោះដូច្នោះ ឈ្មោះថា ទ្រង់សង្គ្រោះហើយ ដោយសមថៈ ។

សូម្បីសង្គ្រោះដោយកង អធិករណ៍ សមុដ្ឋាន និងសមថៈ ក្នុងបទថា ខន្ធសង្គហោ ជាដើមនេះ ក៏គប្បីជ្រាបយ៉ាងនេះ ។

ពាក្យដ៏សេស មានន័យដូចពោលហើយក្នុងកាលមុនទាំងឯង ដូច្នេះឯង ។

## ពណ្ណនាបញ្ញត្តិវគ្គ ចប់

# វិនយដ្ឋកថាវសានគាថា

ព្រះលោកនាថទ្រង់ជាអ្នកឈ្នះ កាលទ្រង់ណែនាំបុគ្គលដែលគួរណែនាំ បានត្រាស់វិន័យបិដកណា ដែលសម្ដេចចែកដោយឧភតោវិភង្គខន្ធកៈ និងបរិវារៈ, អដ្ឋកថា ឈ្មោះសមន្តប្បាសាទិកានៃវិន័យបិដកនោះ ចប់បរិបូណ៌ហើយ ដោយគន្ថៈប្រមាណ ២៧,០០០ គត់ ដោយលំដាប់នៃពាក្យត្រឹមតែប៉ុណ្ណោះឯង ។

ក្នុងពាក្យដែលថា "អដ្ឋកថាវិន័យ បណ្ដុះនូវសេចក្ដីជ្រះថ្លាដោយជុំវិញ" នោះ មានពាក្យអធិប្បាយក្នុងសេចក្ដីដែលអដ្ឋកថា ឈ្មោះសមន្តប្បាសាទិកា ជាគម្ពីរបណ្ដុះសេចក្ដីជ្រះថ្លាដោយជុំវិញ ដូច្នេះ ៖

ក្នុងសមន្តប្បាសាទិកានេះ មិនប្រាកដនូវពាក្យបន្តិចបន្តួច ដែលមិនគួរជ្រះថ្លាដល់វិញ្ញូជនទាំងឡាយ អ្នកពិចារណាហើយ ដោយបន្តលំដាប់នៃអាចារ្យ ដោយសម្ដែងប្រភេទនៃនិទាននិងវត្ថុ ដោយវៀរលទ្ធិរបស់ពួកដទៃ ដោយសេចក្ដីហ្មត់ចត់នៃលទ្ធិរបស់ខ្លួន ដោយជម្រះព្យញ្ជនៈឱ្យហ្មត់ចត់ ដោយសេចក្ដីចំពោះបទ ដោយលំដាប់នៃបាលីនិងយោជនា ដោយវិនិច្ឆ័យក្នុងសិក្ខាបទ និងដោយសម្ដែងប្រភេទនៃន័យដ៏សមគួរដល់វិភង្គ ព្រោះដូច្នោះ អដ្ឋកថានៃវិន័យ ដែលព្រះលោកនាថទ្រង់អនុគ្រោះសត្វលោក ទ្រង់ឆ្លាតក្នុងការទូន្មានជនដែលគួរទូន្មាន បាន

ត្រាស់ទុកហើយយ៉ាងនេះ ទើបឱ្យនាមថា "សមន្តបាសាទិកា" ដូច្នេះ ៦៥ ។

ខ្ញុំកាលនៅក្នុងប្រាសាទ ដែលហោមព័ទ្ធដោយកំផែងមាស ដេរដាស់ដោយដើមឈើមានម្លប់ដ៏ត្រជាក់ មានស្រះទឹកដ៏ថ្លា ជាទីរីករាយចិត្ត ដែលឧបាសកម្នាក់ប្រាកដនាមថា មហានិគមសាមី គាត់កើតក្នុងត្រកូលខ្ពស់ ជ្រះថ្លាក្នុងព្រះរតនត្រ័យ ដោយសទ្ធាមិនអាស្រ័វ ទំនុកបម្រុងព្រះសង្ឃគ្រប់កាល បានសាង(ប្រាសាទនោះ) ទុកជិតផ្ទះជាទីបំពេញព្យាយាម (ជាប្រាសាទ)ដ៏ខ្ពស់ត្រដែត ដែលភិក្ខុសង្ឃអ្នកមានចារិតសីលដ៏ស្អាត អាស្រ័យហើយ ដែលឋិតនៅខាងត្បូងនៃមហាវិហារ ដែលប្រដាប់ដោយដើមមហាពោធិព្រឹក្សរបស់ព្រះសាស្តា ដែលប្រតិស្ឋាននៅលើភូមិភាគក្នុងឧទ្យានមាននាមថា មហាមេឃវ័ន (ខ្ញុំ)បានស្តាប់អដ្ឋកថា ដែលព្រះថេរៈក្នុងកោះសីហឡ បានរចនាទុកទាំង ៣ គម្ពីរ ទាំងនេះ គឺ មហាអដ្ឋកថា មហាបច្ចរី និងកុរុន្ទី ក្នុងសំណាក់ព្រះថេរៈអ្នកប្រាកដនូវនាមថា "ពុទ្ធមិត្ត" ជាអ្នកប្រាជ្ញ ដឹងសព្វគ្រប់ក្នុងព្រះវិន័យ មានកេរ្តិ៍ឈ្មោះមកនឹករលឹកដល់ព្រះពុទ្ធសិរិថេរៈ ជាអ្នកមានសីល និងអាចារៈដ៏ល្អស្អាត ទើបបានផ្តើមរចនាអដ្ឋកថាវិន័យយ៉ាងណា ដែលឱ្យសម្រេចប្រយោជន៍អដ្ឋកថាវិន័យនេះ ខ្ញុំបានផ្តើមរចនា ក្នុងឆ្នាំទី ២០ គត់ ដែលជាឆ្នាំដ៏ក្សេម មានជ័យរបស់ព្រះបាទសិរិបាល អ្នកជាទីអាស្រ័យនៅនៃ

សិរី មានព្រះយស ទ្រង់យុំគ្រងលង្កាទ្វីបទាំងអស់ ឱ្យប្រាសចាកចម្រូងចម្រាស់ សម្រេចរៀបរយក្នុងកាលឈានចូលឆ្នាំទី ២១ ។

អដ្ឋកថា វិន័យនេះ ចូលដល់សេចក្ដីសម្រេចបាន ក្នុងលោកដែលចង្អៀតចង្អល់ដោយឧបទ្ទវៈ ដោយអស់រយៈកាលត្រឹមតែមួយឆ្នាំដោយប្រាសចាកឧបទ្ទវៈយ៉ាងណា, សេចក្ដីផ្ដួចផ្ដើមទាំងពួង ដែលអាស្រ័យធម៌ ឆ្ងាយឧបទ្ទវៈរបស់សត្វលោកទាំងមូល ចូរឆាប់រហ័សសម្រេចដូច្នោះចុះ ។

មួយទៀត បុណ្យណា ដែលខ្ញុំមានសេចក្ដីរាប់អានក្នុងព្រះសទ្ធម្មច្រើនរចនាអដ្ឋកថានេះ ដើម្បីឱ្យព្រះធម៌តាំងនៅយូរអង្វែង បានសន្សំហើយ, ដោយអានុភាពនៃបុណ្យទាំងមូលនោះ សូមសត្វទាំងពួងចូរជាអ្នកសោយរសនៃព្រះសទ្ធម្មរបស់ព្រះធម្មរាជាចុះ, សូមព្រះសទ្ធម្មតាំងនៅរហូតអស់កាលយូរអង្វែងចុះ, សូមភ្លៀងចូរធ្លាក់តាមរដូវកាលញុំាងប្រជាជាតិឱ្យរីករាយរហូតអស់កាលយូរចុះ, សូមព្រះរាជា គ្រប់គ្រងផែនដីដោយធម៌ចុះ ដូច្នេះឯង ។

អដ្ឋកថាវិន័យ ឈ្មោះសមន្តប្បាសាទិកា ដែលព្រះថេរៈជាគ្រូទាំងឡាយតាំងនាមថា "ពុទ្ធឃោសៈ" ជាអ្នកប្រដាប់ដោយសទ្ធា បញ្ញា និងសេចក្ដីព្យាយាម ដែលបរិសុទ្ធិក្រៃលែង ជាអ្នករុងរឿងដោយគំនរគុណមានសីលអាចារៈ ការស្មោះត្រង់ និងការទន់ភ្លន់ជាដើម ជាអ្នកអាចឈាន

ចុះកាន់ត្រៃ គឺ លទ្ធិរបស់ខ្លួន និងលទ្ធិដទៃ ជាអ្នកប្រកបដោយបញ្ញាវាងវៃ ជាអ្នកមានអានុភាពនៃញាណមិនទើសទាក់ក្នុងសត្ថុសាសនា និងទាំងអដ្ឋកថា ដែលផ្សេងដោយបរិយត្តិ គឺ ព្រះត្រៃបិដក ជាអ្នកដឹងវេយ្យាករណ៍ច្រើន ជាមហាកវី ជាអ្នកនិយាយប្រសើរ និយាយពាក្យដែលគួរ និយាយក្នុងកាលដែលគួរ ជាអ្នកប្រកបដោយពាក្យដ៏ពីរោះរណ្តំពីរោះយ៉ាងក្រៃលែង ដែលថ្លែងចេញដោយងាយ ដែលឱ្យកើតដល់ករណសម្បត្តិ ដែលជាគ្រឿងប្រដាប់វង្សរបស់ព្រះថេរៈទាំងឡាយ ជាអ្នកនៅក្នុងមហាវិហារ ជាអ្នកញ៉ាំងថេរវង្សឱ្យភ្លឺ មានបញ្ញាមុតមាំល្អក្នុងឧត្តរិមនុស្សធម៌ ដែលប្រដាប់ដោយគុណ មានអភិញ្ញា ៦ និងបដិសម្ភិទាជាដើមជាប្រភេទ មានបដិសម្ភិទាញាណ ដែលបែកធ្លាយជាបរិវារៈ អ្នកមានបញ្ញាបរិបូណ៌ហ្មត់ចត់ល្អ បានរចនាចប់ហើយ ។

សូម្បីព្រះនាមថា "ពុទ្ធោ" របស់ព្រះលោកជេដ្ឋ ទ្រង់មានព្រះទ័យស្អាតស្អំ ស្វែងរកគុណដ៏ធំ នៅប្រព្រឹត្តទៅក្នុងលោកជរាបណា, សូមអដ្ឋកថាព្រះវិន័យនេះ តាំងនៅក្នុងលោក សម្ដែងន័យ ដើម្បីសេចក្ដីបរិសុទ្ធិនៃសីលដល់កុលបុត្រទាំងឡាយដែលស្វែងរកព្រះនិព្វាន ជាទីចេញចាកលោកជរាបនោះហោង ។

# សមន្តបាសាទិកា

## អដ្ឋកថា វិនយបិដក

### បរិវារៈ

## ទុតិយភាគ

## ១៣

## ចប់

# សមន្តបាសាទិកា

## អដ្ឋកថា វិនយបិដក

## បរិវារៈ

## ភាគ ១២_១៣

## ចប់ ដោយបរិបូណ៌



